ក្រុមជំនុំ ទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES



# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤៣ ខែ មករា

ព.ស. ២៥១៤ គ.ស. ១៩៧១

-ភ្នំពេញ-

១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : ឈាង ហ័បអាន

និពន្ធនាយក - អ្នករៀបចំ : លី ធាមតេង

គណៈកម្មការនិពន្ធ :

ព្រះពោធិវង្ស សូរ-ហាយ

លោក ឌឹក-គាម អ្នកស្រី ពេជ-សល់

# បញ្ជីរឿង


| អត្ថបទ | ទំព័រ |
|---|---|
| ១– ពាក្យប្រារព្ធ . . . . . . . . . | ១ |
| ២– កម្មវិធីបុណ្យថ្វាយព្រះភ្លើង ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី ៣១ មករា ១៩៧១ | ៧ |
| ៣ – ក្បួនដង្ហែព្រះបរមសព . . . . . . . . | ១៨ |
| ៤ – សុន្ទរកថា លោករដ្ឋមន្ត្រី ក្រសួងធម្មការ ថ្លែងព្រះរាជជីវប្រវត្តិ និងព្រះកិត្តិគុណ នៃសម្តេចព្រះសង្ឃរាជ . . . . . . | ២៣ |
| ៥– បព្វតោបមកថា : សេចក្តីថ្លែងព្រះកិត្តិគុណ និង ធម្មទេសនា នៃ ព្រះវន័រត ប្រទេសថៃ . . . . . . . | ៣៣ |
| ៦– បរិទេវកថា នៃព្រះតេជព្រះគុណ គឹម-សាង នាយកគណៈពុទ្ធសាសនាថេរវាទ នៅវៀតណាមខាងត្បូង ជាប្រធានគណៈប្រតិភូ នៃព្រះសង្ឃខ្មែរកម្ពុជាក្រោម . . . . . . . . | ៤៦ |
| ៧– ស្នាព្រះហស្ថខ្លះ ៗ ដែលគួរទុកជាដំបូន្មាន និង ជាអនុស្សាវរីយ៍ . . | ៥២ |
| ៨– គុណសោកកថា ( ពាក្យកាព្យរបស់លោក ជា-ប៉ូរ ) . . . | ៩៣ |


## តម្លៃខាង :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ៛

អាណត្តិសូមដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

# កម្មវិធី

## ថ្វាយព្រះភ្លើង សម្តេចព្រះមហាសុមេធាធិបតី

## ព្រះសង្ឃរាជថ្នាក់ទី ១

## ព្រះនាម ជោតញ្ញាណោ ជួន ណាត គណៈមហានិកាយ

---

### - ថ្ងៃទី ១ -

### ថ្ងៃពុធ ១ កើត ខែមាឃ ( ២៣-១-៣១ )

ម៉ោង ១២,០០ – ជួបជុំមន្ត្រីសង្ឃ ឧបាសក ឧបាសិកា សមាជិករដ្ឋាភិបាល សមាជិកសភាទាំងពីរ នាម៉ឺនសព្វមុខមន្ត្រី (ទាហាន-ស៊ីវិល) នៅវត្តឧណ្ណាលោម ។

– រៀបក្បួនដង្ហែព្រះសពតំកល់លើព្រះរាជរថ ។

ម៉ោង ១៣,០០ – លោកប្រមុខរដ្ឋ អញ្ជើញដល់ ។

– ទាហានក្រុមខេមរជាតិទាំង ៣ ក្រុម ក្រុមភ្លេង ក្រុមតន្ត្រីជាតិ ជូនគារវកិច្ចតាមទម្លាប់ ។

– និមន្តព្រះសង្ឃវត្តឧណ្ណាលោម ៨០ អង្គ ថ្វាយសក្ការបូជាករុណាកិច្ច (តាមព្រះជន្មសម្តេច)

– រំកិលព្រះសព ចំពោះមុខបណ្តាពុទ្ធបរិស័ទទាំងអស់ ។

យើងកំពុងតែមានកើតវិការ ដោយសារសង្គ្រាមឈ្លានពាន ចូលរាតត្បាតបង្កើតចលាចល ប៉ុន្តែយើងនៅតែរួបរួមគ្នា រៀបចំពិធីនេះ ជាផ្លូវការបានឧឡារិកអធិកអធមសមរម្យ ក្រោមកិច្ចចាត់ចែងនៃរដ្ឋាភិបាលផ្ទាល់ដោយមានគណៈកម្មាធិការបុណ្យជួយផង ។

កម្មវិធីដែលយើងបានគ្រោងទុកទាំងប៉ុន្មាន យើងធ្វើតាមបានគ្រប់សព្វគ្រប់ឥតខ្ចោះ គ្រាន់តែមានត្រង់ណាដែលវែងពេក ដែលច្រើនហួសពីកាលៈទេសៈនេះធ្វើកើតក៏គ្រាន់តែបំព្រួញខ្លះ ៗ តែប៉ុណ្ណោះ ។ រីឯផ្ទុយវិញនៅក្នុងវាលព្រះមេរុ ដែលយើងបម្រុងរៀបចំធ្វើពិធីតាំងតុ របស់អង្គការពុទ្ធសាសនានិងព្រះសង្ឃមកពីខេត្តនានានោះ យើងនៅតែធ្វើបានពេញលេញដែរ សម្រាប់កំដរបរិយាកាសបុណ្យ កុំឲ្យស្ងប់ស្ងាត់ ដោយសារពេលនេះ ត្រូវមានបំរាមគោចរ មិនឲ្យធ្វើដំណើរក្នុងពេលយប់ ។

ដើម្បីបង្ហាញពិធីបុណ្យនេះនិងដើម្បីទុកជាឯកសារផងនោះ យើងសូមចុះផ្សាយទាំងស្រុងនូវកម្មវិធី និងធ្វើអត្ថាធិប្បាយតាមលំដាប់ថ្ងៃនោះបញ្ជាក់ផង ព្រមទាំងក្បួនដង្ហែព្រះបរមសព ដែលមានគំនូសសំគាល់ត្រង់ណាមានអ្វី ត្រង់ណាធ្វើដូចម្ដេចនោះ ថែមទៀតក្រៅពីនេះ យើងប្រមូលត្រង់អត្ថបទដែលមានតំលៃដទៃ ៗ ទៀត ដែលផុសឡើងក្នុងព្រះរាជពិធី

នេះ ហើយសុទ្ធសឹងជាសេចក្ដីទាក់ទងនឹងព្រះបរមសពផ្ទាល់ផង ដូចជា : សុន្ទរកថាលោករដ្ឋមន្ត្រីក្រសួងធម្មការ, សេចក្ដីប្រកាសព្រះកិត្តិគុណនិងធម្មទេសនានៃសម្ដេចព្រះវន្នរ័ត ប្រទេសថៃឡង់ និង បរិទេវកថានៃព្រះតេជព្រះគុណ ភិម-សាង នាយកគណៈពុទ្ធសាសនាថេរវាទនៅប្រទេសវៀតណាមខាងត្បូង ។

អត្ថបទអស់ទាំងនេះ សុទ្ធសឹងតែមានន័យដោយកម្រណាស់, បានជាយើងពោលថាដោយកម្រ ព្រោះតែហួសពីពេលនេះទៅ ពុំអាចរកបានឡើយ ។ ឯន័យក្នុងនេះសោត ពិតជាផុសផុសចេញមកពីក្រអៅដួងចិត្តនៃអ្នកថ្លែងពិត ។ ដោយសារតែសេចក្ដីស្ដាយស្រណោះ ឬចិត្តវិយោគសោកសៅ ស្ដាយព្រះរូបព្រះកាយនៃសម្ដេចព្រះសង្ឃរាជ ជួន-ណាត (ជោតញ្ញាណោ) មិនចង់ឲ្យព្រះអង្គព្រាត់ចាកទៅឡើយ ទោះបីជាព្រះអង្គមានព្រះជន្មវស្សាហួតដល់ ៨៦ ឆ្នាំហើយក៏ដោយ ។ ស្ដាយណាស់ត្រង់ព្រះទ័យព្រះវាចា ព្រះសកម្មភាព ដែលកំពុងតែមានពលមាំរស់រវើក គ្មានទ្រុឌទ្រោម តាមអំណាចកាលវេលាសន្តតិព្រះអង្គអស់រយៈ ៨៦ វស្សាមកហើយនោះឡើយ ។ មួយទៀត ដោយព្រះអង្គទ្រង់ជ្រាបច្បាស់នូវព្រះអាយុសង្ខារមិនទៀង ហើយនឹងអាចចូលមកយាយីព្រះអង្គក្នុងពេលមិនយូរប៉ុន្មាន ដូចជាព្រះបន្ទូលទ្រង់ត្រាស់ញយ ៗ ជាមួយអ្នក

ដែលចូលទៅគាល់ព្រះអង្គ នោះហើយទើបទ្រង់ឧស្សាហ៍កប់រៀបរឿងរ៉ាវ ប្រាប់គេប្រាប់ឯងឲ្យចេះឲ្យដឹងរឿងចាស់ទាំងនោះផង ដូចជារឿងរ៉ាវទាក់ទងនឹងទំនៀមទម្លាប់ស្រុក, ជំនឿសាសនា, អក្សរសាស្ត្រ, សិល្បៈ ឬ ប្រវត្តិពង្សាវតារ ជាដើម ។

ដូច្នេះ ចំពោះមតិអ្នកសិក្សាខ្លះទៅយល់ថា ការបាត់សម្តេចព្រះសង្ឃរាជព្រះអង្គនេះ ទុកដូចជាបាត់បន្ទូល យ៉ាងមាំមួយដែលជួយគាំទ្រវប្បធម៌ - អរិយធម៌ជាតិ និងបាត់បង់នូវគ្រូធំមួយ ដែលកើតចេញមកពីប្រភពខ្មែរសុទ្ធសាធ ឥតមានការរៀនវិជ្ជាពីបរទេសណាមួយឡើយ បើទោះជាលាយឡំនឹងបាលី - សំស្ក្រឹតខ្លះ ក៏ជាបាលី - សំស្ក្រឹតរបៀបខ្មែរ ដែលធ្លាប់លាយមកក្នុងទំនៀមទម្លាប់ខ្មែររាប់ពាន់ឆ្នាំទៅហើយដែរ ។ ចំពោះមតិពុទ្ធបរិស័ទវិញយល់ថា ការបាត់បង់ព្រះអង្គ ពិតជាបាត់ព្រះមហាថេរមួយព្រះអង្គ ដែលផ្ចិនផ្ចៅពិតប្រាកដក្នុងធម៌វិន័យ ព្រះពុទ្ធឱវាទ ហើយដែលជាព្រះគ្រូមួយព្រះអង្គ ធ្លាប់ប្រទានជំនូនទានគ្មានលស់ថ្លៃណា, ធ្លាប់ផ្សព្វផ្សាយព្រះឱវាទនូវរសជាតិទឹកអម្រឹត ពោលគឺព្រះសទ្ធម្មគ្មានលស់ខាងថ្លៃណា, ធ្លាប់ទេសនា និងទ្រង់និពន្ធបង្រៀន ខ្ចាតទុកជាកេរ្តិ៍, គ្មានលស់ថ្លៃណា, . . . . . បើបាត់ពីព្រះអង្គហើយក្តី ព្រះកេរ្តិ៍និងព្រះនាមពិតជាពុំបាត់ទៅផងទេ ព្រោះបានចារឹកជាប់ក្នុងដួងចិត្តពុទ្ធបរិស័ទខ្មែរ យុវជនខ្មែរ គ្រប់ ១ គ្នាទៅហើយ

សមដូចពុទ្ធភាសិតថា ៖ រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ ពិតប្រាកដមែន ។

មួយចំណែកទៀត បើនិយាយពីព្រះរាជគុណូបការៈ នៃសម្តេចព្រះសង្ឃរាជ ជួន ណាត ( ជោតញ្ញាណោ ) ចំពោះវិជ្ជាឋានពុទ្ធ-សាសនបណ្ឌិត្យយើងវិញ ឃើញថាមានច្រើនឥតឯនឹងថ្លែងថ្លឹងបាន តាំងពីវិជ្ជាឋាននេះកកើតឡើង រហូតដល់ពេលដែលព្រះអង្គផុតព្រះជន្មាយុ ។ ព្រោះនៅមុននេះបន្តិច ក៏ព្រះអង្គនៅតែសព្វព្រះរាជហឫទ័យ ប្រោសប្រទានដំបូន្មានណែនាំ ឲ្យធ្វើយ៉ាងនេះៗដើម្បីសកម្មភាពអង្គការយើងដែរ ។ បើនិយាយតែពីស្នាព្រះហស្តខាងសៀវភៅធម៌និងអក្សរសាស្ត្រវិញ ក៏មានច្រើនឈ្មោះណាស់ ទ្រង់ប្រទានជាកេរ្តិ៍ឲ្យវិជ្ជាឋានពុទ្ធសាស-នបណ្ឌិត្យបោះពុម្ពផ្សាយ ប្រយោជន៍ដល់ការបង្ហាត់បង្រៀនចំពោះអ្នកខ្លះទៅ និងបានកើនថវិកាជាតិដោយសារជាវសៀវភៅទាំងនេះផង ។

ព្រះរាជគុណូបការៈទាំងនេះ យើងខ្ញុំ មិនដឹងជានឹងរកអ្វីតបស្នងសងព្រះគុណបានទេ មានតែកាយ វាចា ចិត្ត ដែលតាំងជាប់ជានិច្ចគោរពតាមព្រះរាជឱវាទដែលព្រះអង្គទ្រង់បានផ្តាំផ្ញើមកហើយនោះ ព្រមទាំងផ្សាយខ្លះព្រះរាជកិត្តិគុណឲ្យយុវជនអនុជនជាតិ យើងបានដឹងពីព្រះមហាករុណាធិគុណដ៏លើសលុបនេះ តអន្តែងរៀងទៅ ។

អាស្រ័យគំនិតនេះហើយ ដែលយើងខ្ញុំតាក់តែងរៀបចំទស្សនា-វដ្តីកម្ពុជសុរិយា ដែលជាទស្សនាវដ្តីកើតឡើងផ្ទាល់អំពីព្រះរាជតម្រិះរបស់ព្រះអង្គតាំងពី គ.ស ១៩២៧ មកនោះ, ធ្វើជាលេខពិសេសមួយសម្រាប់ព្រះរាជពិធីថ្វាយព្រះភ្លើងក្នុងខែ មករា ១៩៧១ នេះ ។

ភ្នំពេញ ថ្ងៃទី ៣១ មករា ១៩៧១

វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

# ពាក្យប្រារព្ធ

## ព្រះរាជពិធីថ្វាយព្រះភ្លើង

## នៃព្រះបរមសពសម្ដេចព្រះសង្ឃរាជ ជួន-ណាត ពីថ្ងៃ ២៧ ដល់ ៣១ មករា ១៩៧១

ចាប់តាំងពីពេលព្រះអង្គចូលព្រះទីវង្គតមក បណ្ដាពុទ្ធបរិស័ទទាំងអស់ តែងតែស្ដាយអាឡោះអាល័យព្រះបរមសពសម្ដេចព្រះសង្ឃរាជ ជ. ណ. (ជោតញ្ញាណោ) ជានិច្ច ៗ នៅរៀងរាល់ថ្ងៃទី ២៥ នៃខែនីមួយ ៗ ពុទ្ធបរិស័ទតែងនាំគ្នា មកជួបជុំកុះករប្រារព្ធពិធីថ្វាយព្រះរាជកុសល រំលឹកដល់ថ្ងៃដែលព្រះអង្គទ្រង់យាងចូលព្រះទីវង្គត ដោយចម្រើនព្រះបរិត្ត ដាក់បាត្រ ឧទ្ទិសកុសលថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធសម្ដេចពុំដែលលស់ខានឡើយ ៗ

រហូតមកដល់ខែមាឃ ចាប់ផ្ដើមពីថ្ងៃ ១ កើតទៅ យើងទាំងអស់គ្នា ក៏បានប្រារព្ធធ្វើពិធីថ្វាយព្រះភ្លើងចំពោះព្រះបរមសពដែលបានតម្កល់ទុកមកអស់រយៈជាងមួយឆ្នាំហើយ ៗ ពិតមែនតែពេលនេះ ស្រុកទេស

— ក្បួនហែចេញពីវត្តឧណ្ណាលោមតាមវិថីស៊ីសុវត្ថិ បត់តាមវិថីសុរាម្រឹត វិថីសុធារស (មាននិស្សិតពុទ្ធិកសាកលវិទ្យាល័យ និងនិស្សិតពុទ្ធិកវិទ្យាល័យ ថ្វាយសត្តប្ប-ករណាភិធម្ម នៅមុខរដ្ឋសភា) បន្តតាមវិថីសុធារសចូលព្រះមេរុ ។

- សម្ដេចព្រះសុធម្មាធិបតី ព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ ជាព្រះអភិធម្ម ។

ម៉ោង ១៥,០០ - ជួបជុំនាម៉ឺនសព្វមុខមន្ត្រី (រាជការ ស៊ីវិល) សមាជិកសមាជិកាសភាទាំងពីរ សមាជិករដ្ឋាភិបាល មករង់ចាំទទួលព្រះសពនៅវេទិកាកិត្តិយស ខាងត្បូងនាទីព្រះមេរុ ។

- លុះក្បួនហែមកដល់ព្រះមេរុហើយ សម្ដេចព្រះសង្ឃ-នាយក ព្រមទាំងមន្ត្រីសង្ឃខាងគណៈមហានិកាយរង់ចាំទទួលសព ។

លើកព្រះកោដ្ឋ ហើយដើរ ហែប្រទក្សិណ ៣ ជុំព្រះមេរុ រួចស្ដេចយាងទៅដាក់លើបញ្ចា ៧ ជាន់ ១

ម៉ោង ១៥,៣០ - លោកប្រមុខរដ្ឋអញ្ជើញដល់ ។

- ទាហានក្រុមខេមរជាតិទាំង ៣ ក្រុម ក្រុមក្មេង ក្រុម តន្ត្រីជាតិ ជូនការវកិច្ចតាមទម្លាប់ ។

- និមន្តមន្ត្រីសង្ឃគណៈធម្មយុត្តិកនិកាយ ៨៦ អង្គ ថ្វាយ សត្តប្បករណាភិធម្ម

## សំលៀកបំពាក់

- សំពត់ស អាវកុតស ស្បែកជើង ស្រោមជើងស ។

ម៉ោង ១៨,០០ - អុជប្រទីបផ្កាលា ទៅទិស ទិន ព្រះមេរុ ជាសក្ការបូជា

ម៉ោង ១៩,០០ - និមន្តព្រះសង្ឃ ៣២ អង្គ ចំរើនព្រះបរិត្ត-សូត្រព្រះធម្ម តាមទិសមសានក្នុងព្រះមេរុ ទាំង ៤ ទិស ក្នុង ១ ទិស ៨ អង្គ ។

ម៉ោង ២០,០០ - និមន្តព្រះធម្មកថិក ១ អង្គ ទេសនា សត្វ ៨ អង្គ ។

# -ថ្ងៃទី ២-

## ថ្ងៃព្រហស្បតិ៍ ២ កើត ខែមាឃ (២៨-១-៧១)

ម៉ោង ១០,០០ - ប្រគេនភត្តាហារព្រះសង្ឃ ៨៥ អង្គ ដោយរាប់បញ្ចូលទាំងព្រះសង្ឃដែលចំរើនព្រះបរិត្តពីល្ងាច និងសូត្រព្រះធម៌ ។

ម៉ោង ១៩,០០ ដល់ម៉ោង ២០,០០ ពិធីដូចថ្ងៃទី ១ ។

ម៉ោង ២៣,០០ – ក្រុមភ្នាក់ងាររៀបចំរំកិលព្រះកោដ្ឋចុះចាកទីបញ្ចា ទៅដំកល់នៅថែវខាងលិច រៀបគ្រឿងជាន់សម្រាប់ថ្វាយព្រះភ្លើងព្រះសព រួចហើយសូមស្តេចយាងតែឡតព្រះកោដ្ឋដំកល់លើគ្រឿងជាន់ក្នុងព្រះមេរុវិញ ។

## -ថ្ងៃទី ៣-

## ថ្ងៃសុក្រ ៣ កើត ខែមាឃ (២៩-១-៧១)

ម៉ោង ១០,០០ — ពិធីដូចថ្ងៃ ២ ។

ម៉ោង១៤,៣០ — ជួបជុំពុទ្ធបរិស័ទ ឧបាសក ឧបាសិកា មន្ត្រីសង្ឃ ទាំងពីរគណៈ ។

ម៉ោង ១៥,០០ — ជួបជុំនាម៉ឺនសព្វមុខមន្ត្រី (ទាហាន-ស៊ីវិល) សមាជិក សមាជិកា សភាទាំងពីរ សមាជិករដ្ឋាភិបាល អង្គទូត នានា (តាមសេចក្តីអញ្ជើញ)

ម៉ោង ១៥,០០ — សម្តេចព្រះសង្ឃនាយកទាំងពីរគណៈនិមន្តដល់ ។

ម៉ោង ១៥,២៥ — លោកប្រមុខរដ្ឋ អញ្ជើញដល់ ។

— ទាហានខេមរជាតិ ទាំង ៣ ក្រុម ក្រុមភ្លេង និង ក្រុមតន្ត្រីជាតិ ធ្វើការគោរពតាមទម្លាប់ ។

— រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សន្តិសុខ និង ធម្មការ ថ្លែងសុន្ទរកថា ។

— និមន្តព្រះសង្ឃទាំងពីរគណៈ ចំនួន ៨៦ អង្គ ថ្វាយសក្ការណភិធម្ម ។

— ថ្វាយផ្កាខ្ញុំបច្ចុន ។

— សម្តេចព្រះសង្ឃនាយកទាំងពីរគណៈថ្វាយព្រះភ្លើង ។

# សំលៀកបំពាក់

សំពត់ស អាវកុតស ស្បែកជើង ស្រោមជើងស ។

ម៉ោង ១៧,០០ — និមន្តសម្ដេចព្រះសុធម្មាធិបតី ព្រះសង្ឃនាយកគណៈ

ធម្មយុត្តិកនិកាយទេសបន្ទូន ។

ម៉ោង ១៩.០០ · និមន្ត ព្រះធម្មកថិក ១ អង្គទេសនាមុខកើន ។

ម៉ោង ២១,០០ ដល់ម៉ោង ២៤,០០ — ពិធីដូចថ្ងៃទី ១ តែគ្មានព្រះសង្ឃសូត្រព្រះ

ធម្មទេ ។

# – ថ្ងៃទី ៤ –

## ថ្ងៃសៅរ៍ ៤ កើត ខែមាឃ ( ៣០-១-៧១ )

ម៉ោង ៧,០០ – ជួបជុំពុទ្ធបរិស័ទ ឧបាសក ឧបាសិកា មន្ត្រីសង្ឃ ។

– និមន្តព្រះសង្ឃ ៤ អង្គធាកៈ ប្រែព្រះរូប និងថ្វាយពិធីព្រាហ្មណ៍ ។

និមន្តព្រះសង្ឃ ៣ អង្គ ទទួលគ្រឿងទេយ្យទាន ៣ អម្រែក ។

ម៉ោង ៧,២០ – ជួបជុំនាម៉ឺនសព្វមុខមន្ត្រី ( ទាហាន ស៊ីវិល ) សមាជិក សមាជិកាសភាទាំងពីរ សមាជិករដ្ឋាភិបាល នៅទីព្រះមេរុ ។

ម៉ោង ៧,៤០ – សម្តេចព្រះសង្ឃនាយកទាំងពីរគណៈនិមន្តដល់ ។

ម៉ោង ៨,០០ – លោកប្រមុខរដ្ឋ អញ្ជើញដល់ ។

– ទាហានក្រុមខេមរជាតិទាំង ៣ ក្រុម ក្រុមភ្លេង ក្រុមតន្ត្រីជាតិ ជូនគារវកិច្ចតាមទម្លាប់ ។

– ហែព្រះអដ្ឋិទៅតម្កល់ក្នុងវេទិកាកិត្តិយសសិន ។

– ឯព្រះអគ្គីដង្ហែទៅបំភ្លើងនៅទីខ្ទបកុម្ភ ។

- ភ្ញាក់ការរៀបចំគ្រឿងបញ្ចាំទៀនវិញ ។

ម៉ោង១០,០០ - រៀបចំវេរភត្តប្រគេនព្រះសង្ឃ ចំនួន ៨៦ អង្គ ។

ម៉ោង១៥,០០ - ជួបជុំពុទ្ធបរិស័ទ ឧបាសក ឧបាសិកា មន្ត្រីសង្ឃ ។

ម៉ោង១៥,១៥ - ជួបជុំទាម៉ុនសព្វមុខមន្ត្រី ( ទាហាន ស៊ីវិល ) សមាជិក សមាជិកាសភាទាំងពីរ សមាជិករដ្ឋាភិបាល នៅ វិព្រះមេរុ ។

ម៉ោង១៥,២៥ - សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ និមន្តមកដល់ ។

ម៉ោង១៥,៣៥ - លោកប្រមុខរដ្ឋ អញ្ជើញមកដល់ ។

- ទាហានក្រុមខេមរជាតិទាំង ៣ក្រុម ក្រុមភ្លេង ក្រុមតន្ត្រីជាតិ ជូនគារវកិច្ចតាមទម្លាប់ ។

- ស្តេចយាងព្រះអដ្ឋិ តង់ក្នុងព្រះកោដ្ឋមាស ហើយដង្ហែទៅដំកល់លើបញ្ចារវិញ ។

- និមន្តព្រះសង្ឃ ១០០ អង្គ ថ្វាយសត្តប្បករណាភិធម្ម ។

ម៉ោង១៨,០០ - និមន្តព្រះសង្ឃ ៣២-អង្គ ចំរើនព្រះបរិត្ត រួចហើយ

និមន្តធម្មកថិក ១ អង្គ  សម្តែងព្រះធម៌ទេសនាបឋម
ក្រាស់ ៗ សត្វី ៨ អង្គ  លុះចប់ព្រះធម៌ទេសនាហើយ
រៀបចំអភិសេកព្រះពុទ្ធរូបមាស  និមន្តព្រះសង្ឃ ៨ អង្គ
សូត្រពុទ្ធាភិសេកដរាបដល់ភ្លឺ ៗ

## សំលៀកបំពាក់

—សំពត់ស អាវកុតស ស្បែកជើង ស្រោមជើងស ៗ

# - ថ្ងៃទី ៥ -

## ថ្ងៃអាទិត្យ ៥ កើត ខែមឃ ( ៣១-១-៧១ )

ម៉ោង ៧,០០ - ជួបជុំពុទ្ធបរិស័ទ ឧបាសក ឧបាសិកា មន្ត្រីសង្ឃនៅ វិព្រះមេរុ ស្តេចយាងព្រះអដ្ឋិដំកល់លើព្រះសាលៀង ហែទៅវត្តឧណ្ណាលោម ។

ម៉ោង ៨,០០ - ជួបជុំនាម៉ឺនសព្វមុខមន្ត្រី ( ទាហាន ស៊ីវិល ) សមាជិក សមាជិកាសភាទាំងពីរ សមាជិក រដ្ឋាភិបាល នៅ វេទិកាមុខព្រះមហាចេតិយវត្តឧណ្ណាលោម ។

ម៉ោង ៨,១៥ - សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ និមន្តដល់ ។

ម៉ោង ៨,៣០ - លោកប្រមុខរដ្ឋ អញ្ជើញដល់ ។

- ទាហានក្រុមខេមរជាតិទាំង ៣ ក្រុម ក្រុមភ្លេង ក្រុមតន្ត្រីជាតិ ជូនគារវកិច្ចតាមទម្លាប់ ។
- និមន្តព្រះសង្ឃ ៥ អង្គឆាក ។
- រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ សន្តិសុខ និង ធម្មការ លើកព្រះអដ្ឋិជូនលោកប្រមុខរដ្ឋ ទទួលយកទៅបញ្ចុះដំកល់ក្នុងមហាចេតិយ ។
- ព្រះសង្ឃសូត្រជយន្តោ ។
- ភ្លេងពិណពាទ្យ ។

- និមន្តព្រះសង្ឃវត្តឧណ្ណាលោម ថ្វាយសក្ការបូជាណា-
កិច្ច ។

## សំលៀកបំពាក់

សំពត់ស អាវកុតស ស្បែកជើង ស្រោមជើងស ។

ម៉ោង ១០,០០ — វេរភត្តប្រគេនព្រះសង្ឃជួចថ្ងៃទី ៤ ។

ម៉ោង ១៥,០០ — និមន្តធម្មកថិក ៣ អង្គ ទេសនាសង្កាយនា និមន្ត
លោកអានត្រ័យ ៨ អង្គ លោកហត្ថបាស ១០០ អង្គ
នៅមហាកុដិវត្តឧណ្ណាលោម ។

ម៉ោង ១៨,០០ — អុជប្រទីបថ្វាលា នៅមហាចេតិយ ។

ភ្នំពេញ នៅថ្ងៃទី ២៥ ខែធ្នូ គ.ស ១៩៧០
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សន្តិសុខ និង ធម្មការ
ហត្ថលេខា : **ឱម គីមអាន**

បានយកសេចក្តីជំរាប សូមអនុញ្ញាត
លោកប្រមុខរដ្ឋ
លោក ឧត្តមសេនីយ៍នាយករដ្ឋមន្ត្រី
ហត្ថលេខា : **លន់ នល់**

លោកប្រមុខរដ្ឋ បានអនុញ្ញាតហើយ
ហត្ថលេខា : **ចេង ហេង**

# ក្បួនដង្ហែព្រះបរមសព

សម្តេចព្រះសង្ឃរាជ ជួន-ណាត [ ជោតញ្ញាណោ ]

ថ្ងៃទី ២៣-១-៧១



ទង់ខ្មែរ ១៤ និងខ្សែពួ ________________ ទង់ធាត ________________

សារវ័តត្រួត ១ នាក់      សារវ័តត្រួត ១ នាក់

សង្ឃការីអម

ពាំងឆ្ងល់

ឧប

| ភ្លេងពិណពាទ្យ ១ វង់ធំ<br>អ្នកវាយស្គរ ៨ នាក់<br>អ្នកសែង ២៤ នាក់ |
|---|

យុវតី ៥០ នាក់ យុវជន ៥០ នាក់
កាន់ផ្កាម្ជុលបន្ទង់ កាន់ផ្កាកញ្ចាំង

| ព្រែតម្កល់ព្រះពុទ្ធរូប<br>និងព្រះត្រៃបិដក |
|---|

សិស្សស្រី ៥០ នាក់    សិស្សប្រុស ៥ នាក់
០ កាន់ទេយ្យទាន    ០ កាន់ទេយ្យទាន

សង្ឃការីអម

សារវ័តត្រួត ១ នាក់      សារវ័តត្រួត ១ នាក់

ទង់ខ្មែរ ១៤ និងខ្សែពួ ________________ ទង់ធាត ១ ________________


ទង់ឥន្ទ្រីយ៍ ១៤
សារវ័ត្រូត ១ នាក់
សង្ឃការីអម
ប៉ាំងកួស់
គ្រូលោក ព្រះអភិធម្ម
សិស្សស្រី ១០០ នាក់ កាន់ទេយ្យទាន
រថយន្តតម្កល់គ្រឿងឥស្សរិយយស
សិស្សប្រុស ១០០ នាក់ កាន់ទេយ្យទាន
ពិណពាទ្យ ១ វង់
រថយន្តតម្កល់ ព្រះឆាយាល័ក្ខ
មន្ត្រីប្រតិភូ ៨០ នាក់
សង្ឃការីអម
សារវ័ត្រូត ១នាក់
ទង់ឥន្ទ្រីយ៍ ១៤


ពាយ័ ៦
បែមន ៦
អគ្និយ៍ ៦
ភូតាន ៦
សារវ័តគ្រូត ១ នាក់
សារវ័តគ្រូត ១ នាក់
ស្រីអម
យ៉ាងកួស់
មន្ត្រីសង្ឃហែអម ៤ អង្គ
ព្រាហ្មណ៍ផ្លុំសង្ខ
យ៉ាងកួស់
យ៉ាងសែង ១
គ្រូអ្នកព្យាយណោត
ភ្លេងខ្លងឆ្នាក់ ១០នាក់
ស្ព្រវផាយោគ
គ្រូគម្ពល់ខ្ទឹមចង់
បរិយត្តបុស្បុក
គម្ពល់ព្រះលព
ឧនាគបុរស
គ្រូផាយោគ
ឧយ៉ាបេសភ្វា
គ្រូស្រីអម
១២នាក់
ស្ព្រវផាយោគ
កួស់សង្វមួយ
ព្រាហ្មណ៍ផ្លុំសង្ខ
មន្ត្រីសង្ឃហែអម ៤ អង្គ
សារវ័តគ្រូត ១ នាក់
សារវ័តគ្រូត នាក់
ពាយ័ ៦
បែមន ៦
អគ្និយ៍ ៦
ភូតាន ៦

សែនក្ងាន់ ៦ ______ ទង់ម្លូរ ១៤ ______ ទង់ឆាគទៀ ១៤ ______ អ្នកកាន់ក្លួយខ្សែពួ

សាវ័កត្រួត ១នាក់ o    សាវ័កត្រួត ១នាក់ o    សាវ័កត្រួត ១នាក់ o

| | | | | |
|---|---|---|---|---|
| | | | 0000000 | 00000000000 |
| 000000000 | 000000000 | 000000000 | 0000000 | 00000000000 |
| 000000000 | 000000000 | 000000000 | 0000000 | 00000000000 |
| 000000000 | 000000000 | 000000000 | | |
| ព្រះសង្ឃទាំងពួងហែតាម | ឧបាសកស្លៀកពាក់ស | ឧបាសិកាស្លៀកពាក់ស | ភ្ញៀវស្ត្រីហែ | ភ្ញៀវបុរសហែតាម |
| ២០០ អង្គ | ១០០ នាក់ | ១០០ នាក់ | | |
| 000000000 | 000000000 | 000000000 | 0000000 | 00000000000 |
| 000000000 | 000000000 | 000000000 | 0000000 | 00000000000 |
| 000000000 | 000000000 | 000000000 | 0000000 | 00000000000 |

o សាវ័កត្រួត ១ នាក់    o សាវ័កត្រួត ១ នាក់    o សាវ័កត្រួត ១ នាក់

សែនក្ងាន់ ៦ ______ ទង់ម្លូរ ១៤ ______ ទង់ឆាគទៀ ១៤ ______ អ្នកកាន់ក្លួយខ្សែពួ

# សុន្ទរកថា លោករដ្ឋមន្ត្រីក្រសួងធម្មការ
# ថ្លែងក្នុងឱកាសពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសព
# សម្តេចព្រះសង្ឃរាជ ជួន ណាត

នៅថ្ងៃទី ២៩-១-៧១

---

សូមក្រាបថ្វាយបង្គំទូលសម្តេចព្រះសង្ឃនាយក ជាអម្ចាស់ទាំងពីរព្រះអង្គ

សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ

សូមគោរព លោកប្រមុខរដ្ឋ

–លោកប្រធានសភាទាំងពីរ

–លោកនាយករដ្ឋមន្ត្រី

–លោកឧបនាយករដ្ឋមន្ត្រី

–លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ

ថ្ងៃនេះជាទិវាដ៏មហាឡារិកមួយ ដែលតស្សូវជនគ្រប់អង្គការ នៃសាធារណរដ្ឋខ្មែរ ព្រមទាំងព្រះសង្ឃ និង ពុទ្ធបរិស័ទទាំងឡាយ ក្រោមអធិបតីភាពនៃលោកប្រមុខរដ្ឋ បានរួបរួមគ្នាប្រារព្ធធ្វើពិធីថ្វាយព្រះភ្លើងចំពោះព្រះបរមសព សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ “**ជួនណាត**” ដែលទ្រង់ជាប្រមុខនៃព្រះសង្ឃគណៈមហានិកាយ និងជាអ្នកប្រាជ្ញមួយព្រះអង្គនៃប្រជាជាតិខ្មែរ និង លើផ្ទៃពិភពអន្តរជាតិ ។

ក្នុងនាមនៃរដ្ឋាភិបាលស្រោចស្រង់ជាតិ និង គណៈកម្មាធិការរៀបចំព្រះរាជពិធីបុណ្យ ខ្ញុំព្រះករុណា-ខ្ញុំ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះសម្តេចជាអម្ចាស់ លោកប្រមុខរដ្ឋ លោកប្រធានសភាទាំងពីរ លោកនាយករដ្ឋមន្ត្រី លោកឧបនាយករដ្ឋមន្ត្រី អគ្គការទូតនានា ព្រមទាំងភ្ញៀវកិត្តិយសគ្រប់ក្រសួង និងពុទ្ធបរិស័ទទាំងឡាយ ដែលបាននិមន្ត អញ្ជើញ មកដើម្បីជាកិត្តិយស និងដើម្បីញុំាងពិធីបុណ្យនេះ ឲ្យបានរុងរឿងអធិកអធមក្រៃលែង ថ្វាយព្រះរាជកុសលចំពោះសម្តេចព្រះសង្ឃរាជ ដែលព្រះអង្គសោយទីវង្គតនៅថ្ងៃទី ២៥ កញ្ញា ១៩៦៩ ក្នុងព្រះជន្ម ៨៦ វស្សា ហើយពុទ្ធបរិស័ទ ប្រជាពលរដ្ឋខ្មែរទាំងមូល មានសេចក្តីទុក្ខក្រៀមក្រំ និងសោកស្តាយជាទីបំផុត ។ ពុទ្ធបរិស័ទ និងរដ្ឋាភិបាលស្រោចស្រង់ជាតិ បានរួបរួមគ្នាធ្វើពិធីបុណ្យរានតាមប្រពៃណី តាំងពីថ្ងៃទី ២៥ កញ្ញា ១៩៦៩ ដើម្បីថ្វាយព្រះរាជកុសលចំពោះវិញ្ញាណក្ខន្ធព្រះបរមសព នៃសម្តេចព្រះសង្ឃរាជ ហើយបានរៀបចំរុងរឿងធ្វើពិធីថ្វាយព្រះភ្លើងកាលពីថ្ងៃទី ១៨ ដល់ថ្ងៃ ២៤ មេសា ១៩៧០ មុននេះ ក៏ប៉ុន្តែអាក់ខានវិញ ដោយសារតែមានពួកទមិឡអឡត្ក័យ យួនវៀតកុង វៀតណាមខាងជើង មកឈ្លានពានទឹកដីបង្កបង្កើតអសន្តិសុខគ្រប់ទិសទីក្នុងប្រទេស ដែលនាំឲ្យខូចខាតអន្តរាយ និងរវល់ការពារជារាល់ថ្ងៃ ។ ទោះបីយ៉ាងនេះក្តី ក៏រដ្ឋាភិបាលស្រោចស្រង់ជាតិ ដែលមានលោកឧត្តមសេនីយ៍នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើ នៃគណៈកម្មាធិការ

រៀបចំពិធីបុណ្យ និង សម្តេចព្រះសង្ឃនាយកគណៈមហានិកាយ ក៏បាន សម្រេចឲ្យរៀបចំធ្វើពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសព នៅថ្ងៃទី ២៧ ដល់ថ្ងៃ ទី ៣១ មករា ១៩៧១ នេះ ដើម្បីឲ្យបានប្រកបតាមប្រពៃណី និង សេចក្តីរុងរឿង ចំពោះបរមសពសម្តេចព្រះសង្ឃរាជ ជាទីគោរព-ស្នេហា គបស្នងព្រះមហាករុណាធិគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះអង្គ ។ ដូច្នេះហើយ ដែលពុទ្ធបរិស័ទគ្រប់ជាន់ថ្នាក់ បានស្មោះស្ម័គ្រចូលមករួបរួមក្នុងពិធីបុណ្យពេលនេះដ៏ឧឡារិក ដើម្បីសម្តែងសេចក្តីគោ-រពកតញ្ញូតាធម៌ ចំពោះព្រះបរមសព និងចំពោះព្រះពុទ្ធសាសនា ដែលជាទីស្រឡាញ់ស្មើជីវិត ។

សម្តេចជាអម្ចាស់ ព្រះតេជគុណ:

លោក-អ្នក ជាទីគោរព

វេលានេះខ្ញុំព្រះករុណា-ខ្ញុំ សូមថ្លែងដោយសង្ខេប នូវជីវប្រវត្តិនៃសម្តេចព្រះសង្ឃរាជដូចតទៅ :

សម្តេចព្រះសង្ឃរាជ "ជួន-ណាត" ទ្រង់ប្រសូត្រនៅថ្ងៃអង្គារ ១១ រោច ខែផល្គុន ឆ្នាំរកធស័ក ព.ស. ២៤២៧ គឺថ្ងៃទី ១១ មីនា ១៨៨៣ នៅភូមិកំរៀង សង្កាត់គោកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ព្រះបិតានាម ជួន ព្រះមាតានាម យក់ ។

ទ្រង់បានរៀនសូត្រពីកុមារ ហើយបានបួសជាសាមណេរ ក្នុងព្រះជន្មាយុ ១៤ ឆ្នាំ បានបំពេញឧបសម្បទាជាភិក្ខុ មានព្រះនាមបញ្ញត្តិថា

«ជាតកាល» ក្នុងព្រះជន្មាយុ ២១ ឆ្នាំ នៅវត្តពោធិ៍ព្រឹក្ស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ហើយព្រះអង្គមកគង់នៅវត្តឧណ្ណាលោម ។ ទ្រង់បានសិក្សាភាសាខ្មែរ ភាសាបាលី និង វិជ្ជាខាងព្រះពុទ្ធសាសនា យ៉ាងជ្រៅជ្រះ ។ កាលឆ្នាំ ១៩១៣ បានប្រឡងជាប់ជា "មហាប្ដូនប្រយោគ" ដែលជាវិញ្ញាសាខ្ពស់បំផុត នៅសម័យនោះ ។

ក្នុងវិស័យពុទ្ធសាសនា ទ្រង់បានផ្សាយភាសាជាតិ នូវសៀវភៅក្បួនខ្នាតនិងធម្មវិន័យជាច្រើនតាំងពីឆ្នាំ ១៩១៧ ដល់ ១៩៦៨ ដើម្បីរៀបចំព្រះសង្ឃគណៈមហានិកាយ ឲ្យមានរបៀបរៀបរយហើយឲ្យប្រតិបត្តិតាមពុទ្ធបញ្ញត្តិ និង ពុទ្ធានុញ្ញាត ព្រមទាំងឲ្យឈោងយកចំណេះខាងភាសាខ្មែរ-បាលី ដែលជាមូលដ្ឋាននៃពុទ្ធសាសនា និង វប្បធម៌ជាតិ ។ កាលឆ្នាំ ១៩១៥ បានប្រឡងជាប់លេខ ២ បានទទួលតែងតាំងជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ បានធ្វើជាបាងក្លាងវង ក្នុងឆ្នាំ ១៩៣៩ និង ជាបាងហ្លាង ក្នុងឆ្នាំ ១៩៤២ ។

កាលឆ្នាំ ១៩១៩ បានធ្វើជាសមាជិកនៃក្រុមជំនុំតែងវចនានុក្រមខ្មែរ ដែលទ្រង់ជាលេខាធិការកាន់កិច្ចការនេះផ្ទាល់ លុះត្រាតែបានចប់វចនានុក្រម ។

ក្នុងវិស័យអក្សរសាស្ត្រខ្មែរនេះ ទ្រង់បានព្យាយាមពេញទំហឹងជាមួយនឹងក្រុមជំនុំវចនានុក្រម រួចទ្រង់បានធ្វើបន្តតែមួយព្រះអង្គឯងរហូតដល់ឆ្នាំ ១៩៣៨ ទើបបានសម្រេចចេញផ្សាយជាលើកទី ១ ហើយទ្រង់

នៅតែបន្តកិច្ចការនេះជាប់រហូតឥតឈប់ឈរ ដើម្បីឲ្យបានកើតវចនានុក្រមខ្មែរ ដែលជាមូលដ្ឋានសម្រាប់ប្រើភាសាជាតិ ។

ទ្រង់បានរៀនភាសាបារាំង-សំស្ក្រឹត ហើយបន្តការសិក្សាភាសាទាំងពីរនេះព្រមទាំងវិជ្ជាអក្សរសិលាចារឹកអស់រយៈកាលពីរឆ្នាំ (១៩២២-២៣) នៅសាលាបារាំងចុងបូព៌ា ជាមួយនឹងសម្តេចសង្ឃនាយក ហួត-តាត ដែលជាកល្យាណមិត្តរួមថ្នាក់ផង ។ ទ្រង់ជាសមាជិកអ្នកឆ្លើយឆ្លងនៃសាលាបារាំងចុងបូព៌ា (១៩៦៣) ហើយជាសមាជិកកិត្តិយស នៃសាលានេះ (១៩៦៨) ។ ក្រៅពីភាសាខ្មែរ-បាលី-សំស្ក្រឹត-បារាំងនេះ ទ្រង់បានចេះសៀម-លាវ យ៉ាងជាក់លាក់ ព្រមទាំងភាសាអង់គ្លេស-វៀតណាមផង ទ្រង់អាចអានសន្ទនា តាមសំនៀងជាតិបរទេសបានឥតមានទើសទាក់ ។

ទ្រង់ជាសមាជិកក្រុមជំនុំខាងបោះពុម្ពផ្សាយសៀវភៅចេញពីសាលាបាលីជាន់ខ្ពស់ (១៩២៥) និងចេញពីក្រសួងសិក្សាធិការ (១៩៣៣) ជាសមាជិកក្រុមជំនុំព្រះត្រៃបិដក (១៩២៩) ជាសមាជិកក្រុមជំនុំវប្បធម៌ (១៩៣៦) ជាអនុប្រធាននៃគណៈកម្មការនេះ (១៩៦៧) ។

ទ្រង់បានចងក្រងសៀវភៅដ៏កម្រ ១ ជាឃ្លាំងវិជ្ជា ដោយទ្រង់បានពុះពារយ៉ាងអង់អាចនូវឧបសគ្គដ៏ធំៗ គ្រប់យ៉ាងក្នុងការផ្សាយគ្រាដំបូង លុះត្រាតែបានសម្រេចដោយជោគជ័យនូវព្រះបំណង ។

ទ្រង់សព្វព្រះទ័យនិពន្ធអត្ថបទអក្សរសាស្ត្រដទៃទៀតជាច្រើន ដូចៈ

ក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ពន្លឺពុទ្ធចក្រ ។ ជាពិសេសទ្រង់ជាអគ្គមគ្គុទេសក៍ ការកាត់ណែនាំក្នុងរឿងបកប្រែពាក្យបរទេសជាភាសាខ្មែរតាំងពីកំណើតខេមរយានកម្មឆ្នាំ ១៩៦៧ ដរាបមក ។ ទ្រង់បានសម្ភាសអក្សរសាស្ត្រតាមវិទ្យុជាតិជារៀងរាល់ថ្ងៃសុក្រ តាំងពីឆ្នាំ ១៩៦១ មក ដើម្បីបំភ្លឺ និងអប់រំអំពីសីលធម៌ ប្រវត្តិសាស្ត្រ និង ពាក្យពេចន៍ ជាអាទិ កំបាំងតាំងឡាយ នេះសឲ្យឃើញនូវសមត្ថភាពនិងបដិភាណរបស់ព្រះអង្គជាជាអ្នកប្រាជ្ញប្រកបដោយព្រះទ័យពុំចេះលាក់លៀម ពុំចេះបញ្ចៀចបញ្ចៀ ពុំចេះសំចៃ ក្នុងការណែនាំឲ្យចេះប្រើពាក្យ ឬ ប្រយោគឲ្យបានត្រឹមត្រូវ ។ ទ្រង់ជាអ្នកប្រាជ្ញធំ ឧស្សាហ៍ធ្វើការណាស់ ហើយជាអ្នកស្នេហាជាតិយ៉ាងមោះមុត ។ ព្រះអង្គជាមេដឹងនាំអប់រំយ៉ាងពូកែហើយមិនចេះនឿយហត់ ។ ព្រះអង្គប្រទានធម្មទេសនាយ៉ាងប៉ិនប្រសប់ និង ពីរោះក្បោះក្បាយដែលនាំឲ្យពុទ្ធបរិស័ទចូលចិត្តគោរពស្ដាប់ ។

ដោយអាស្រ័យថ្វីព្រះហស្ត និង ព្រះសកម្មភាព ក្នុងវិស័យវប្បធម៌ដ៏មានតម្លៃនេះហើយ ទើបប្រទេសជាតិខ្មែរបានអបអរសាទរថ្វាយក្នុងឆ្នាំ ១៩៦៧ ចំពោះព្រះអង្គនូវសញ្ញាបត្រ "បណ្ឌិតអក្សរសាស្ត្រ" ។

ព្រះកិត្តិស័ព្ទរបស់សម្ដេចព្រះសង្ឃរាជបានល្បីសុសសាយរហូតដល់ក្រៅប្រទេស ដែលទ្រង់ត្រូវបានប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាទាំងឡាយចាត់ទុកព្រះអង្គជា ជាមហាអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាមួយអង្គលើផ្ទៃភពអន្តរជាតិ ។ ទ្រង់បានដឹកនាំប្រតិភូសង្ឃទៅប្រទេសលាវ

(១៩៣១ និង ១៩៣៩) ប្រទេសសេរីលង្កា (១៩៥០) ប្រទេសភូមាចំនួនបីលើក (១៩៥៣ ១៩៥៤ និង ១៩៥៥) ដើម្បីចូលរួមក្នុងឆដ្ឋសង្គាយនា

ទ្រង់បានទទួលអំពីរដ្ឋាភិបាល នៃប្រទេសភូមានូវព្រះឋានៈ ជាព្រះអភិធជមហា រដ្ឋគុរុ (១៩៥៧) ដែលជាសមណសក្តិដ៏ខ្ពង់ខ្ពស់បំផុតមានតែមួយគត់ក្នុងសហភាពភូមា ។

ក្រៅពីព្រះសកម្មភាពខាងសាសនា និងវប្បធម៌ទ្រង់បានបំពេញនូវកិច្ចការសាធារណប្រយោជន៍ច្រើន មានកសាងថ្នល់-ស្ពានអគារសិក្សា-គិលានដ្ឋានជាដើម ។

ដោយព្រះមហាឧបការគុណដ៏ធ្ងន់ទាំងនេះ សម្តេចព្រះសង្ឃរាជទ្រង់បានទទួលសមណៈសក្តិជា :

-ព្រះគ្រូសង្ឃសត្ថា នៅឆ្នាំ ១៩១២

-ព្រះសាសនសោភ័ន នៅឆ្នាំ ១៩៣១

-ព្រះពុទ្ធឃោសាចារ្យ នៅឆ្នាំ ១៩៤០

-ព្រះពោធិវង្ស នៅឆ្នាំ ១៩៤៤

-ព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ នៅឆ្នាំ ១៩៤៨

-ជាសម្តេចព្រះសង្ឃនាយក នៅឆ្នាំ ១៩៥០

-សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ គណៈមហានិកាយថ្នាក់ទី ១ នៅឆ្នាំ ១៩៦៣

ហើយទ្រង់បានទទួលគ្រឿងឥស្សរិយយសយ៉ាងប្រសើរថ្លៃថ្លា របស់ប្រទេសខ្មែរ ប្រទេសលាវ ប្រទេសបារាំង ។

ព្រះគុណសម្បទព្រះសកម្មភាពនិងព្រះកិត្តយស យ៉ាងច្រើន និងយ៉ាងប្រសើរទាំងប៉ុន្មាន ក៏គង់មាននៅក្នុងសារគារ និងក្នុងសៀវភៅ ដែលពុទ្ធបរិស័ទអ្នកសប្បុរសបានថែរក្សាទុកចងចាំដរាបពុំមានភ្លេចសោះឡើយ ។

ក្នុងព្រះជន្មាយុ ៨៦ ឆ្នាំក្រោយបំផុតនេះ សម្តេចព្រះសង្ឃរាជថ្វីបើទ្រង់បិតនៅក្នុងព្រះជរាភាពហើយក៏ដោយ ទ្រង់នៅមានស្មារតីនឹងធឹងរឹងរៃ និតខំធ្វើការជារាល់ថ្ងៃ ទ្រង់នៅមានព្រះរាជបន្ទូលយ៉ាងម៉ឺងម៉ាត់ក្រាងក្រអៅដដែល ទាំងព្រះសតិក៏នៅមាំមួនឥតមានភ្លេចភ្លាំងអ្វីទេ ទាំងព្រះឧត្តមគតិក៏នៅជាប់ព្រះទ័យដដែល ។ ទ្រង់មានព្រះបន្ទូលជាចុងក្រោយយ៉ាងច្បាស់ចំពោះសម្តេចព្រះសង្ឃនាយកគណៈមហានិកាយបច្ចុប្បន្នថា ៖ " ខ្ញុំស្គាល់ណាស់ ពេលនេះ ជរាធម៌កាន់តែបៀតបៀនខ្ញុំខ្លាំងឡើង ១, កិច្ចការដែលខ្ញុំត្រូវធ្វើ នៅសល់ច្រើនណាស់ " ។

សម្តេចព្រះសង្ឃរាជ " ជួន ណាត " ជោតញ្ញាណោ ទ្រង់សោយព្រះទិវង្គតយ៉ាងស្រួលស្ងប់ស្ងៀម ក្នុងកណ្តាលព្រះសកម្មភាពរបស់ព្រះអង្គ នៅថ្ងៃទី ២៥ កញ្ញា ១៩៦៩ ក្រោយពីទ្រង់ប្រឈួនតែបីថ្ងៃប៉ុណ្ណោះ ដោយបានបូជាព្រះកាយ និង ព្រះសតិបញ្ញា ដើម្បីព្រះពុទ្ធសាសនា និង

ប្រជាជាតិខ្មែរ ដែលទ្រង់ជាមហាបុរសស្នេហាជាតិមាតុភូមិយ៉ាងមាំ ។ ប្រជាជាតិខ្មែរបានកាន់មរណៈទុក្ខដោយសេចក្តីស្តាយស្រណោះអាឡោះអាល័យយ៉ាងខ្លាំងណាស់ឥតប្រៀបបាន ។ ពុទ្ធបរិស័ទ តាំងព្រះសង្ឃគ្រហស្ថគ្រប់ឋានៈ បានចាត់ចែងពិធីបុណ្យជារៀងមក ដើម្បីឧទ្ទិសថ្វាយព្រះរាជកុសល ចំពោះព្រះវិញ្ញាណក្ខន្ធនៃព្រះអង្គ ហើយនៅពេលនេះបានរួបរួមគ្នាដោយស្មោះស្ម័គ្រ ដើម្បីធ្វើអភិវន្ទនកិច្ចជាចុងក្រោយបំផុតចំពោះព្រះបរមសពជាទីគោរពសម្តេចព្រះសង្ឃរាជជាអម្ចាស់ ។

ព្រះរូបនៃសម្តេចបាត់លត់មែន តែក្នុងដួងចិត្តនៃប្រជារាស្ត្រខ្មែរសំគាល់ថាសម្តេចជាអម្ចាស់ទ្រង់មានព្រះជន្មាយុនៅឡើយ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និង ភាពបរិសុទ្ធ ព្រះរូបសម្តេចបាត់មែនតែព្រះកិត្តិនាមព្រះមាត់ដែលទ្រង់ត្រួសត្រាយទុក ហើយព្រះសកម្មភាពជាប្រយោជន៍ព្រះពុទ្ធសាសនា និង ប្រទេសជាតិ ឋិតនៅជាបរមានជានិរន្តរ៍ ។

ក្នុងនាមនៃសម្តេចព្រះសង្ឃនាយកតាំងពីរគណៈ និងព្រះថេរានុត្ថេរៈ ក្នុងនាមនៃលោកប្រមុខរដ្ឋ សូមមានប្រោសព្រះរាជទានព្រះខន្តីអភ័យទោសចំពោះការគ្គាំគ្គង ដោយប្រការណាមួយ ហើយសូមលើកបញ្ញាកសិដែលកើតឡើងពីការចាត់ចែងពិធីទក្ខិណានុប្បទានទាំងឡាយក្នុងរយៈកាល ១៦ ខែកន្លងមក តាំងពិធីថ្វាយព្រះភ្លើងដ៏មហោឡារិកក្នុងពេលនេះ សូមថ្វាយ

ចំពោះព្រះវិញ្ញាណក្ខន្ធព្រះអង្គ សូមទ្រង់បានឋិតក្នុងសុគតិភព ដ៏រុងរឿងថ្លៃថ្លាតរៀងទៅ ។

សូមព្រះតេជៈបារមីនៃសម្តេចព្រះសង្ឃរាជជាអង្គម្ចាស់ និង អានុភាពនៃរតនៈត្រៃ ព្រមទាំងវត្ថុស័ក្តិសិទ្ធទាំងអស់ក្នុងលោក សូមផ្សព្វផ្សាយសុខចំរើនគ្រប់ប្រការ កើតមានចំពោះសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ លោកប្រមុខរដ្ឋ លោកប្រធានសភាទាំងពីរ លោកនាយករដ្ឋមន្ត្រី លោកឧបនាយករដ្ឋមន្ត្រី ព្រមទាំងអស់លោក-អ្នកគ្រប់ជាន់ថ្នាក់ និងពុទ្ធបរិស័ទទាំងឡាយ ។

សូមសាធារណរដ្ឋខ្មែរ មានជោគជ័យឈ្នះអស់ខ្មាំងសត្រូវ ពួកទមិឡអឡត្តិរ៍យ ដែលឈ្លានពានទឹកដី ។

សូមសាធារណៈរដ្ឋខ្មែរ បានប្រកបសេចក្តីសុខក្សេមក្សាន្ត និង ព្រះពុទ្ធសាសនាចំរើនរុងរឿងអស់កាលជាយូរអង្វែងតទៅ ។

# បព្វតោបមកថា

## របស់ ព្រះធនរ័ត [ បញ្ញាសិរី ] វត្តព្រះជេតពន
## ហៅវត្តពោធិ៍ បាងកក ប្រទេសថៃ

*សម្ដែងក្នុងពិធីបុណ្យថ្វាយព្រះភ្លើង ព្រះសព*

*សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ ប្រទេសកម្ពុជា*

*ក្រុងភ្នំពេញ*

(ថ្ងៃសុក្រ ៣ កើត ខែមាឃ ឆ្នាំចកោស័ក ពុទ្ធសករាជ
២៥១៤ ត្រូវនឹងថ្ងៃ ២៩ មករា គ.ស. ១៩៧១)

យថាបិ សេលា វិបុលា នភំ អាហច្ច បព្វតា
សមន្តា អនុបរិយេយ្យុំ និប្បោថេន្តា ចតុទ្ទិសា
ឯវំ ជរា ច មច្ចុ ច អធិវត្តន្តិ បាណិនោ
ខត្តិយេ ព្រាហ្មណេ វេស្សេ សុទ្ទេ ចណ្ឌាលបុក្កុសេ
ន កិញ្ចិ បរិវជ្ជេតិ សព្វមេវាភិមទ្ទតីតិ ។

*វេលានេះ សូមសម្ដែងព្រះធម៌ទេសនា លម្មសមគួរដល់បុព្វពេត-ពលីទក្ខិណានុប្បទានកិច្ច ដែលរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ មានលោកឧត្តមសេនីយឯក លន់-នល់ ជានាយករដ្ឋមន្ត្រី នៃប្រទេសកម្ពុជា ជាប្រធាន ព្រមទាំងប្រជាជនក្នុងប្រទេសទាំងមូល បានរួមគំនិតគ្នាបំពេញបុណ្យជាសមានឆន្ទៈ ដើម្បីឧទ្ទិសកុសលថ្វាយចំពោះសម្ដេចព្រះមហាសុ-មេធាធិបតី ព្រះសង្ឃរាជនៃប្រទេសកម្ពុជា ជារដ្ឋពិធីដោយកិត្តិយសដ៏ខ្ពង់*

ខ្ពស់បំផុត ហើយជាមហាកុសលដ៏ឧត្ដមតាមប្រពៃណីនិយម ។

មែនពិត សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជនៃប្រទេសកម្ពុជា ដែលលោកអ្នកទាំងឡាយកំពុងធ្វើសេចក្ដីគោរពសក្ការបូជាព្រះសពក្នុងវេលានេះ ទ្រង់ព្រះគុណសម្បត្តិ ដែលជាអស្ចារ្យរបស់ព្រះអង្គដ៏លើសលុបលើសាមញ្ញជនទូទៅ ។

ព្រះអង្គទ្រង់ប្រសូតនៅថ្ងៃទី ១១ មីនា ត្រូវនឹងថ្ងៃ ១១ កើត ខែផល្គុន ឆ្នាំរកា ព.ស. ២៤២៧ នៅភូមិកំរៀង ស្រុកគងពិសី ខេត្រកំពង់ស្ពឺ ទ្រង់បព្វជ្ជាជាសាមណេរតាំងពីព្រះជន្មាយុ ១៤ ឆ្នាំ នៅវត្តពោធិព្រឹក្ស ស្រុកកណ្ដាលស្ទឹង ខេត្រកណ្ដាល ទ្រង់បានសិក្សាភាសាបាលីនៅវត្តឧណ្ណាលោម ចុះពីរព្រះវស្សា ទ្រង់ឆ្លៀវឆ្លាសក្នុងការសិក្សាយ៉ាងក្រៃលែង លុះព្រះជន្មាយុគ្រប់ ២១ វស្សា ទ្រង់ឧបសម្បទាជាភិក្ខុនៅវត្តដើម ។ ព្រះឧបជ្ឈាយ៍ឲ្យនាមបញ្ញត្តិថា " ជោតញ្ញាណោ " ហើយទ្រង់ត្រឡប់មកចាំវស្សានៅវត្តឧណ្ណាលោមវិញ ទ្រង់សិក្សាព្រះធម៌ - វិន័យរៀនកបដកបមក តាល់តែកើតការចេះដឹងដ៏ទូលំទូលាយ ទ្រង់ព្រះប្រាជ្ញាញាណស្ទាត់ជំនាញក្នុងព្រះវិន័យ លើសវិស័យមនុស្សសាមញ្ញធម្មតា ។

ទ្រង់សិក្សាវិជ្ជាក្នុងប្រទេស តាល់តែមិនមានគ្រូអាចារ្យមកបង្ហាត់បង្រៀនព្រះអង្គបានទៀត សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជទ្រង់ពុំត្រឹមតែមានការសិក្សាក្នុងប្រទេសប៉ុណ្ណោះទេ ទ្រង់មានអនាគតំសញាណដ៏វិសេសក្រៃ ទ្រង់ពិចារណាឃើញថា ប្រទេសដែលគេកាន់ព្រះពុទ្ធ

សាសនាក្នុងទ្វីបអាស៊ីនេះមានច្រើនណាស់ គួរតែធ្វើសេចក្ដីស្និទ្ធស្នាល ភក់ទាក់ខ្លះ ក្នុងឋានៈជាមិត្ត នៃប្រទេស ដែលគោរពព្រះពុទ្ធសាសនាដូចគ្នា ដើម្បីប្ដូរសេចក្ដីចេះដឹងដល់គ្នានិងគ្នាឲ្យចម្រើនដល់ប្រទេសជាតិ សេចក្ដីស្និទ្ធស្នាលនឹងកើតមានដល់នានាប្រទេសបាន ត្រូវអាស្រ័យការសិក្សាក្នុងប្រទេសនោះ ៗ ឲ្យចេះដឹងទំនៀមទំលាប់ ត្រូវអាស្រ័យការរាប់អានគ្នា និងត្រូវអាស្រ័យសាមគ្គីធម៌ ជាគោលប្រតិបត្តិ ។

កាលបើបានចូលទៅកាន់ប្រទេសនោះៗ ដើម្បីសិក្សា ហើយសេចក្ដីចម្រើន និងសេចក្ដីជិតជិតស្និទ្ធស្នាល ក៏កើតមានទៀត ។ ហេតុនោះ សម្ដេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជ គ្រាដែលមិនទាន់ទទួលព្រះឋានៈជាសម្ដេចព្រះសង្ឃរាជនៅឡើយ ព្រះអង្គទ្រង់ទៅសិក្សា និងទស្ស-នា នៅប្រទេសផ្សេងៗ ដែលទ្រង់ឃើញថាមានប្រយោជន៍ តាំងពីក្រុងហាណូយជាដើម រហូតដល់ប្រទេសលាវ វៀតណាមខាងត្បូង-ឥណ្ឌូណេស៊ី ប្រទេសភូមា ហើយនិងប្រទេសថៃ ។ សម្ដេចព្រះសង្ឃរាជ ទ្រង់អាចសន្ទនាជា ភាសាយួន ភាសាលាវ ភាសាភូមា ភាសាបារាំង ហើយនិងភាសាថៃ ដោយច្បាស់លាស់ ហើយទ្រង់ដឹងគោលវប្បធម៌របស់ប្រទេសនោះជាក់លាក់ ហេតុនោះហើយបានជាព្រះអង្គយាងទៅប្រទេសណា រមែងបានទទួលការភក់ទាក់ពីប្រទេសនោះ ដ៏លើសលុប ព្រោះព្រះអង្គជាក់ខ្លួនតាមឋានៈនឹងព្រះកិត្តិយស ហើយមានអធ្យាស្រ័យដ៏ទន់ភ្លន់មានមេត្តាដល់សព្វសត្វទៅទាំងអស់ ។

លុះទ្រង់សិក្សា មានសេចក្ដីចេះដឹង សមគួរដល់កម្លាំងបញ្ញាហើយ ទ្រង់ប្រមូលសេចក្ដីចេះដឹង ដែលព្រះអង្គបានសិក្សាបានឃើញនៅក្នុងប្រទេសនោះៗ នាំយកមកកែប្រែ ដើម្បីឲ្យសមល្មមដល់ព្រះធម៌វិន័យនិងភូមិប្រទេសហើយប្រកាសប្រើ ក្នុងការគ្រប់គ្រងគណៈសង្ឃក្នុងប្រទេសកម្ពុជា ។ គណៈសង្ឃក្នុងប្រទេសកម្ពុជាបានចម្រើនល្អគួរណាស់ក្នុងផ្លូវសីលសម្បត្តិ អាចារសម្បត្តិ និងការសិក្សាធ្វើឲ្យឋានៈរបស់គណៈសង្ឃក្នុងប្រទេសកម្ពុជាល្អផើតបាន ស្មើមុខមាត់នឹងពុទ្ធសាសនិកជនទាំងឡាយដែលកាន់កាន់ព្រះពុទ្ធសាសនាឯទៀត ៗ គណៈរដ្ឋាភិបាលរាល់សម័យបានឃើញសេចក្ដីអង់អាចរបស់សម្ដេចព្រះសង្ឃរាជព្រះអង្គនេះ តាំងពីដើមមកទើបបានលើកតំកើងឲ្យមានដំណែងសមណស័ក្តិដោយលំដាប់ រហូតដល់ដំណែងខ្ពស់បំផុត គឺអង្គសម្ដេចព្រះសង្ឃរាជនេះឯង ។

សម្ដេចព្រះសង្ឃរាជកាលបើបានទទួលដំណែង ជាប្រមុខព្រះសង្ឃដូច្នោះហើយ ទ្រង់ប្រើនាទីនោះ ៗ តាមធម៌វិន័យ និងតាមរបៀបកតិកាសង្ឃ ដើម្បីសាមគ្គីជាធំធ្វើឲ្យគណៈសង្ឃនៅរួមគ្នាជាឯកច្ឆន្ទ ស្ថិតនៅក្នុងសន្តិធម៌ពេញទាំងប្រទេស គណៈរដ្ឋាភិបាលក៏បានធូរស្រាលហើយជ្រះថ្លាក្នុងការគ្រប់គ្រងគណៈសង្ឃ ព្រោះគណៈសង្ឃជាកន្លែងកើតនៃសាមគ្គីធម៌ ដឹកនាំទឹកចិត្តរបស់ប្រជាជនឲ្យស្រឡាញ់ជាតិ សាសនា ។ សម្ដេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជ ទ្រង់គ្រប់គ្រងគណៈសង្ឃឲ្យកើតសន្តិធម៌ ទ្រង់ជាអ្នកនាំប្រជាជនឲ្យគោរពស្រឡាញ់ ជាតិ សាសនា មក

ដោយលំដាប់លំដោយ លុះព្រះជន្មាយុច្រើនឡើង ព្រះកម្លាំងកាយ កម្លាំងចិត្តថមថយចុះដែលជាវិស័យរបស់សង្ខារ ។ អាពាធដែលកើតឡើងក្នុងវិស័យជរានេះ គណៈរដ្ឋាភិបាលបានព្យាយាមរក្សាយ៉ាងក្រៃលែង គ្រប់ពេទ្យដែលជំនាញអង់អាច បានព្យាបាល ដើម្បីរក្សាព្រះជន្មាយុព្រះអង្គតាមការចេះដឹងចូលចិត្តយកមកប្រើពាល់តែអស់តម្រិះ ។ ទីបំផុតវិញ្ញាណរបស់សម្ដេចព្រះសង្ឃរាជ ក៏លះបង់រាងកាយ ដែលទុព្វលភាពនោះចេញចាកលោកនេះទៅតាមវិស័យរបស់ហេតុផល ។ ទ្រង់ព្រះប្រឈួនកាលពីថ្ងៃទី ២៣ កញ្ញា ព.ស. ២៥១៣ ហើយព្រះទីវង្គតនៅថ្ងៃទី ២៥ កញ្ញា ឆ្នាំដដែល ។ ទ្រង់ព្រះអាពាធបាន៣ថ្ងៃ ក៏ទ្រង់អស់ព្រះជន្មរលត់ខន្ធទៅ ។ ព្រះទីវង្គតនេះ បានធ្វើឲ្យកើតសេចក្ដីស្លុតចិត្តដល់ប្រជាជនគ្រប់ប្រទេសក្នុងលោក គណៈរដ្ឋាភិបាលបានចាត់ការតម្កល់ព្រះសព តាំងពីដើមរហូតដល់ថ្វាយព្រះភ្លើងព្រះសព ដែលកំណត់នៅថ្ងៃទី ២៩ មករា ព.ស. ២៥១៤ នេះ ។

ក្នុងព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសពសម្ដេចព្រះសង្ឃរាជនៅពេលនេះ គណៈរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ មានលោកឧត្ដមសេនីយ៍ លន់ នល់ ជានាយករដ្ឋមន្ត្រីជាប្រធាន ព្រមទាំងប្រជាជនបានរួបរួមគ្នាជាសមានឆន្ទៈ បំពេញកុសលគួរដល់ព្រះសមណស័ក្តិ និងព្រះកិត្តិយសរបស់ព្រះអង្គយ៉ាងក្រៃលែង ។

ដើម្បីឲ្យព្រះកិត្តិយសរបស់សម្ដេចព្រះសង្ឃរាជ ប្រាកដជាមាន

សេចក្ដីសំខាន់ដល់ប្រទេសកម្ពុជា និងសាកលលោក ត្រឹមណានោះ ក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះសពរបស់ព្រះអង្គនេះ គណៈរដ្ឋាភិបាល នៃសាធារណរដ្ឋកម្ពុជាបានអញ្ជើញទូតានុទូតក្នុងប្រទេសកម្ពុជា ហើយនិងនានាជាតិមករួមថ្វាយព្រះភ្លើងនេះផង ជួយផ្សាយព្រះកិត្តិយសឲ្យប្រាកដដល់សាកលលោកទាំងមូល ។

គណៈសង្ឃនៃប្រទេសថៃ បានជ្រាបច្បាស់នូវគុណសម្បត្តិរបស់សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ យ៉ាងក្រៃលែង កាលបើបានដំណឹងព្រះទីវង្គតរបស់ព្រះអង្គ ក៏នាំឲ្យកើតធម្មសង្វេគ គិតឃើញពល់គ្នាថា ព្រះចេតិយដែលជាបង្គោលជ័យ របស់ប្រទេសកម្ពុជាបានរលំរលាយចុះហើយដោយអាណោចអាធម ។ តែធ្វើយ៉ាងណាបាន ព្រោះសេចក្ដីស្លាប់ជារបស់ប្រចាំលោករមែងកើតឡើងដល់សង្ខារ គឺមានសេចក្ដីកើតឡើងខាងដើម មានការប្រែប្រួលជាកណ្ដាល មានសេចក្ដីស្លាប់ជាទីបំផុត ។ ជីវិតរបស់សត្វគ្រប់រូបត្រូវតែយ៉ាងនេះឯង មិនផុតពីយ៉ាងនេះទៅបានទាំង អតីត បច្ចុប្បន្ន និង អនាគត ដែលនឹងប្រាកដក្នុងកាលខាងមុខ ។

ព្រោះសព្វសត្វទាំងអស់មានគតិធម្មតាប្រចាំជីវិត ដូចជាស្រមោលជាប់តាមខ្លួន អ្នកមានប្រាជ្ញាតិច តែងប្រកាន់ជីវិតរាងកាយរបស់ខ្លួនថាទៀង ហើយខ្វល់ខ្វាយអន្ទះអន្ទែង ដើម្បីជីវិតគង់នៅ ដែលជាហេតុឲ្យកើតសេចក្ដីសោកស្ដាយអាឡោះអាល័យជានិច្ចជាកាល ។ សម្ដេចព្រះបរមសាស្ដា

សម្មាសម្ពុទ្ធជាអម្ចាស់ទ្រង់ឃើញនូវហេតុយ៉ាងនេះហើយ ព្រះអង្គមានព្រះមេត្តាករុណាគិតដល់សព្វសត្វទាំងអស់ ទើបទ្រង់ដាស់តឿនពុទ្ធបរិស័ទមិនឲ្យធ្វេសប្រហែស ក្នុងសភាវធម៌ឲ្យពិចារណាឃើញគតិធម្មតា ដើម្បីរក្សាចិត្តកុំឲ្យក្រវល់ក្រវាយ ក្នុងពេលដែលបានជួបប្រទះសេចក្តីព្រាត់ប្រាសចាករបស់ដែលស្រឡាញ់ពេញចិត្ត ឬក្នុងពេលដែលជួបប្រទះនឹងសភាវៈធម៌នោះក្តាម ក៏មានសតិដឹងទាន់នូវសេចក្តីពិតរបស់ជាតិ គឺ កំណើត ។ មួយទៀត ព្រះអង្គសម្តែងក្នុងបព្វតោបមគាថា ដែលបានផ្តើមមកហើយខាងដើមថា ៖

“យថាបិ សេលា វិបុលា នភំ អាហច្ច បព្វតា ជុច្ចេះ ជាដើម ប្រែសេចក្តីថា : “ភ្នំសុទ្ធតែ ថ្មធំៗ មានកំពស់ទល់នឹងមេឃរមៀលធ្លាក់មកសង្កត់នូវសត្វទាំង ៤ ទិសយ៉ាងណា”

“ឯវំ ជរា ច មច្ចុ ច អធិវត្តន្តិ បាណិនោ” ជរាគឺសេចក្តីចាស់ មរណៈគឺសេចក្តីស្លាប់ រមែងគ្របសង្កត់នូវសត្វទាំងឡាយដូច្នេះដែរ ។ ឈ្មោះថា ជរា មរណៈនេះ មិនរើសមុខអ្នកណាមួយឡើយ ទោះជាក្សត្រក៏ដោយ ព្រាហ្មណ៍ឬក៏អ្នកជំនួញ និងអ្នកទីទាល់ក្រក៏ដោយ រមែងបិតទៅក្នុងអំណាចជរាមរណៈទាំងអស់ ។

ម្យ៉ាងទៀតមនុស្សគ្រប់រូបក៏មិនអាចនឹងឈ្នះជរាមរណៈបាន ដោយចម្បាំងឬដោយកម្លាំងទ្រព្យ ព្រោះហេតុនោះហើយ អ្នកប្រាជ្ញកាលបើឃើញប្រយោជន៍របស់ខ្លួន គួរបណ្តុះសទ្ធា គឺសេចក្តីជឿកម្ម និង ផល

នៃកម្ម ហើយមានសេចក្ដីជ្រះថ្លាក្នុងព្រះរតនត្រ័យ ដើម្បីរកឱកាសបដិ-បត្តិតាមព្រះពុទ្ធោវាទ ។ បុគ្គលណាប្រព្រឹត្តធម៌ដោយកាយ វាចា ចិត្ត បុគ្គលនោះរមែងរីករាយក្នុងលោកនេះ និងលោកខាងមុខ ។

ព្រោះហេតុនោះ បុគ្គលអ្នកប្រាជ្ញ កាលរលឹកនឹកឃើញដល់ពាក្យប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ គួរប្រកបសេចក្ដីជឿ រក្សាសីល និងសេចក្ដីជ្រះថ្លារហូតដល់ការពិចារណាឃើញធម៌រឿយៗ ដូច្នេះឯង ។

សម្ដេចព្រះសង្ឃរាជ ជោតញ្ញាណមហាថេរៈ ទ្រង់មានព្រះកិត្តិយសល្បីល្បាញប្រាកដឡើងបាន ក៏ព្រោះព្រះអង្គគោរពព្រះរតន-ត្រ័យ ដោយការបតិបត្តិតាមព្រះធម៌វិន័យ ដែលជា ស្វាក្ខាតធម៌ ជាធម៌ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងហើយដោយប្រពៃ ទ្រង់មានបដិបទាដ៏ខ្ពង់ខ្ពស់ ទាំងបរិយត្តិធម៌ទាំងបតិបត្តិធម៌ ទើបបានទទួលព្រះសមណស័ក្ដិដ៏ខ្ពស់បំផុតលើគណៈសង្ឃ ។

មែនពិត ព្រះភិក្ខុក្នុងព្រះពុទ្ធសាសនា ដែលបានទទួលការលើកតម្កើងពីសំណាក់ព្រះបរមសាស្ដាថា ជាអ្នកមានគុណធម៌ដ៏មាំទាំមានច្រើនសណ្ឋាន ។ គុណធម៌ទាំង ៥ ប្រការនោះ បើមានក្នុងអ្នកណា អ្នកនោះគួរទទួលការលើកតម្កើងថា ជាព្រះមហាថេរ ខាងចិត្តនឹងធឹង សមតាមបាលីព្រះពុទ្ធភាសិតថា :

យម្ហិ សច្ចញ្ច ធម្មោ ច អហិំសា សញ្ញមោ ទមោ

ស វេ វន្តមលោ ធីរោ ... សោ ថេរោតិ បវុច្ចតិ

បុគ្គលណាប្រកបដោយគុណធម៌ ៥ យ៉ាង គឺ សច្ចៈ ធម្មៈ អហឹសា សញ្ញមៈ ហើយនិង ទមៈ បុគ្គលនោះឈ្មោះថា ជាអ្នកមានបញ្ញា គ្មានមន្ទិល ពុទ្ធាទិបណ្ឌិតទ្រង់សរសើរថា ជាព្រះថេរៈអ្នកមានចិត្តមាំមួន ។

អធិប្បាយថា : សច្ចៈបានដល់សេចក្ដីទៀងត្រង់ និងប្រព្រឹត្តធ្វើអ្វីក៏ត្រូវធ្វើពិតប្រាកដ មិនចាប់នេះចាប់នោះចោល មិនចំពោះត្រង់ណាមួយឲ្យពិតប្រាកដ ស្មូតត្រង់ចំពោះមុខនិងកំបាំងមុខ បុគ្គលដែលមានកិត្តិយសខ្ពស់រមែងមានសច្ចៈជាទីតាំង ព្រោះជាទីទុកចិត្តរបស់បុគ្គលទូទៅគ្រប់រូបៗ បុគ្គលខ្វះសច្ចៈ រមែងមិនជាទីប្រុះប្រា របស់អ្នកណា ៗ ឡើយ សូម្បីតែមាតាបិតារបស់ខ្លួនក៏ដោយ ។ ការដែលមានសច្ចៈដ៏មាំទាំហើយ ជាហេតុឲ្យប្រព្រឹត្តធម៌តទៅ ដូចជាព្រះបរមសាស្ដាទ្រង់បន្លឺព្រះវាចា ប្រកាសសច្ចធម៌កាលគង់ប្រថាប់នៅកន្លែងពោធិបល្ល័ង្កមុននឹងត្រាស់ដឹងថា សូម្បីសាច់ឈាមស្ងួតរីងទៅក៏ដោយ បើមិនបានត្រាស់ដឹងនូវអនុត្តរធម៌ទេ នឹងមិនក្រោកចេញពីពោធិបល្ល័ង្កដោយដាច់ខាត សុខចិត្តបោះបង់ជីវិតនៅត្រង់កន្លែងពោធិបល្ល័ង្កនេះ ព្រោះព្រះអង្គតាំងមាំក្នុងសច្ចវាចា សូម្បីមារមកពិរដបៀតបៀនព្រះអង្គយ៉ាងណា ក៏មិនព្រមធ្លាក់ទៅក្នុងអំណាចរបស់មារនោះឡើយ នេះហើយជាហេតុសំខាន់មួយយ៉ាង ដែលជួយឲ្យព្រះសិទ្ធត្ថ បានត្រាស់ដឹងនូវអនុត្តរធម៌សមតាមបំណងរបស់ព្រះអង្គ ។ បុគ្គលបើមានសច្ចៈជាដើម ហើយរមែងជួយគាំទ្រឲ្យមាំទាំក្នុងការប្រតិបត្តិធម៌តទៅបាន ។

ធម្មៈ ក្នុងនេះ សំដៅយកការិយធម៌ គឺសេចក្ដីព្យាយាម ។ ធម៌នោះ

ជារបស់បរិសុទ្ធស្អាត ៗ របស់បរិសុទ្ធនោះ បើយកទៅប្រើក្នុងផ្លូវខុស ក៏មានទោសដល់អ្នកប្រើ បើយកទៅប្រើក្នុងផ្លូវត្រូវក៏មានគុណ ឧបមាដូចរូបិយប័ណ្ណរបស់រដ្ឋបាល បើយកទៅទិញរកគៀន ក៏មានទោសធ្វើឲ្យក្តៅក្រហាយ បើយកទៅប្រើត្រូវ ដូចជាយកទៅទិញអាហារមកបរិភោគ ក៏មានសេចក្តីសុខកាយសប្បាយយ៉ាងណា សេចក្តីព្យាយាមក៏យ៉ាងនោះដែរ បើព្យាយាមក្នុងផ្លូវត្រូវយើងក៏រួចផុតទោសទុក្ខ ៗ

" វិរិយេន ទុក្ខមច្ចេតិ " បុគ្គលរួចផុតទុក្ខបាន ព្រោះសេចក្តីព្យាយាម បើដូច្នេះ សេចក្តីព្យាយាមរមែងបាននូវសម្បត្តិ វិជ្ជា និងសេចក្តីចំរើនរុងរឿង ៗ

ចំណែកអ្នកដែលមិនមានសេចក្តីព្យាយាម ក៏គឺមនុស្សមិនមានសម្បត្តិ មិនមានការចេះដឹង និងមិនមានកិត្តិយសក្នុងផ្លូវធម្មប្បដិបត្តិ ព្រះអង្គប្រដៅឲ្យមានព្យាយាមធ្វើសេចក្តីល្អ ហើយរក្សាសេចក្តីល្អទុកមិនឲ្យខូចខាតបាត់បង់ទៅ ព្រោះសេចក្តីព្យាយាមជាហេតុនាំឲ្យមាន អហឹសា ៗ

គំនិតបៀតបៀនមនុស្សនិងសត្វឈ្មោះថា ហឹសា ៗ ហឹសានេះកាលបើកើតឡើងហើយ យើងត្រូវកំចាត់បោលចេញពីគំនិតឲ្យអស់ ៗ បើបណ្តោយឲ្យមានហឹសារម្មណ៍ធ្លាក់ចុះក្នុងអំណាចចិត្តហើយ ក៏មានតែការចងពៀរព្យាបាទដល់គ្នានិងគ្នា ៗ បើកំចាត់បោលបានអស់ហើយឈ្មោះថា អហឹសា ៗ បើដូច្នេះបុគ្គលត្រូវព្យាយាម ធ្វើមេត្តាឲ្យជាអារម្មណ៍របស់ចិត្ត គឺត្រូវធ្វើចិត្តឲ្យប្រកបដោយព្រហ្មវិហារធម៌ ៗ មេត្តាចិត្ត

ប្រៀបដូចជាទឹកសម្រាប់លាង រីឯឱសថ ព្យាបាល ឲ្យរស់នៅ ។ មេត្តា នេះ ជាគ្រឿងទ្រទ្រង់លោកឲ្យមានតែសេចក្តីសុខសប្បាយ មិនតែមនុស្សប៉ុណ្ណោះទេ សូម្បីតែសត្វតិរច្ឆានក៏ត្រូវមាន មេត្តា អំពីមនុស្សដែរ ។

មេត្តា ផ្លូវព្រះវិន័យ និងផ្លូវធម៌ មានលក្ខណៈផ្សេងគ្នា មេត្តាផ្លូវវិន័យត្រូវដាក់ទោស មេត្តាផ្លូវធម៌ត្រូវបន្ថយទោស ឬ ឲ្យអភ័យទោស ដូចជាភិក្ខុឆាន់អាហារក្នុងវេលាវិកាល ត្រូវបង្ខំឲ្យចេញពីសមណភេទ មិនព្រមឲ្យនៅជាសមណៈតទៅ ។ ការចេញពីសមណៈភេទនោះ ចាត់ជាមេត្តាផ្លូវព្រះវិន័យ ព្រោះថាបើបណ្តោយឲ្យភិក្ខុល្មើសវិន័យនុកឲ្យទ្រទ្រង់ភេទដូច្នេះតទៅ ក៏មានតែធ្វើបាបកម្មដល់ខ្លួនឯងរាល់ថ្ងៃ បើលាសមណភេទហើយ ទៅបរិភោគល្ងាច ក៏មិនមានបាបកម្មអ្វី មានតែសប្បាយកាយសប្បាយចិត្ត ។ ផែនដីដែលមានប្រយោជន៍ ក៏ត្រូវអាស្រ័យមនុស្សទំរុកកនទីដីនោះ ឲ្យទៅជាស្រែចំការ មនុស្សដែលមានប្រយោជន៍ក៏ព្រោះមនុស្សទំខ្លួនឯងឲ្យមានចំណេះវិជ្ជា បង្ខំខ្លួនឯងឲ្យធ្វើការតាមនាទី ។ រដ្ឋាភិបាលដែលធ្វើការឲ្យជាតិចម្រើនទៅបាន ត្រូវអាស្រ័យច្បាប់បង្ខំខ្លះអាស្រ័យរបៀបបង្ខំខ្លះ ព្រោះហេតុនោះ ការបង្ខំឲ្យធ្វើឬ ជាការគួរសមតាំងផ្លូវលោកផ្លូវធម៌ ។

ចំណែកមេត្តាផ្លូវធម៌នោះ គឺត្រូវអភ័យទោស ឬ បន្ថយទោសជាការឲ្យសេចក្តីសុខដល់មនុស្សដទៃ សត្វដទៃ រហូតដល់មិនគិតរកយាកព្យាបាទចងពៀរវេរដល់គ្នានឹងគ្នា ។

បុគ្គលដែលបំពេញមេត្តាធម៌ ទុកជាមានមេត្តាចំពោះមនុស្សប្រុសស្រី ប្តូទៅដល់សព្វសត្វទាំងអស់ក្នុងលោកក៏ដោយ ត្រូវព្យាយាមសង្រួមចិត្ត ដើម្បីការពារសោមនស្ស ទោមនស្សដែលគ្របសង្កត់ចិត្ត ។ បើសេចក្តីសោមនស្ស ទោមនស្សគ្របសង្កត់ចិត្តបានហើយ អាចបណ្តាលឲ្យធ្វើខុស និយាយខុស គិតខុស គឺការខ្វះមេត្តាចិត្ត ដែលជាគោលធម៌ដ៏ធំរបស់អ្នកធំ ដូច្នេះ សញ្ញមៈ ជាការចាំបាច់ត្រូវធ្វើគ្រប់ប្រការ ។

កាលបើសោមនស្ស ទោមនស្ស កើតឡើងគ្របសង្កត់ចិត្ត ត្រូវប្រើ ទមៈ ទូន្មាន មិនបណ្តោយឲ្យកើតឡើងបាន ។

យេ ចិត្តំ សញ្ញមេស្សន្តិ តេ មោក្ខន្តិ មារពន្ធនា

បុគ្គលណាសង្រួមចិត្តបាន បុគ្គលនោះរមែងផុតពីចំណងនៃមារ គ្រឿងក្រវល់ចិត្ត ។

ចិត្តស្ស ទមថោ សាធុ ការទូន្មានចិត្តបាន ជាការល្អ

ទន្តោ សេដ្ឋោ មនុស្សេសុ បណ្តាជនទាំងឡាយ អ្នកទូន្មានខ្លួនបានឈ្មោះថាជាអ្នកប្រសើរ ។

បុគ្គលប្រកបដោយធម៌ ៤ ប្រការ ដូចអធិប្បាយមកនេះ រមែងបានទទួលគុណសរសើរថាជាអ្នកប្រាជ្ញ មានចិត្តស្អាតផូរផង់ ។ ពុទ្ធាទិបណ្ឌិតសរសើរថា ជាព្រះថេរៈ មានចិត្តខ្ជាប់ខ្ជួន រឹងប៉ឹង ស្មោះត្រង់នឹងធម៌វិន័យ ។

សម្តេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជនៃប្រទេសខ្មែរ ទ្រង់មានព្រះកិត្តិយស ស្អាតបរិសុទ្ធមិនមានមន្ទិល ក៏ព្រះអង្គត្រេកអរ ចំពោះធម៌ ៨ ប្រការនេះ ។ អ្នកទ្រទ្រង់គុណធម៌ដូចនេះ កាលបើជីវិតរស់នៅក៏គួរក្រាបសំពះ កាលបើទទួលមរណភាពទៅហើយ ក៏គួរធ្វើទក្ខិណានុប្បទាន ដូចបានសម្តែងមកហើយ ដោយប្រការដូច្នេះឯង ។

ទីបំផុតនៃព្រះធម្មទេសនានេះ សូមអានិសង្សគុណ វិបុលផល ចូរកើតមានដល់ សម្តេចព្រះសង្ឃរាជ នៃប្រទេសខ្មែរ សមគួរដល់គតិវិស័យក្នុងសម្បរាយិកភពគ្រប់ប្រការ ។

ឃរំ ចប់ដោយប្រការដូច្នេះឯង ។

# បរិទេវកថា

របស់ព្រះតេជព្រះគុណ ធម្មវីរៈយោ គីម-សាង នាយកគណៈ

ពុទ្ធសាសនាថេរវាទ មជ្ឈមណ្ឌល ថ្ងៃធ្វើបុណ្យ នៃមហាពិធីបុណ្យ

ថ្វាយព្រះភ្លើង ព្រះបរមសព សម្ដេចព្រះសង្ឃរាជថ្នាក់ទី ១

ជួន-ណាត ជោតញ្ញាណោ

ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៧១

–សូមថ្វាយបង្គំសម្ដេចសង្ឃនាយកទាំងពីរគណៈ

–សូមថ្វាយបង្គំមន្ត្រីសង្ឃ ព្រះតេជព្រះគុណ ព្រះមហាថេរានុត្ថេរៈ

គ្រប់ព្រះអង្គ

–សូមគោរពបណ្ដាអ្នកដឹកនាំសាសនាជាមិត្តទាំងឡាយ

–សូមចម្រើនពរចំពោះឯកឧត្ដមប្រមុខរដ្ឋ សាធារណរដ្ឋខ្មែរ

–សូមចម្រើនពរចំពោះឯកឧត្ដមប្រធានព្រឹទ្ធសភា

–សូមចម្រើនពរចំពោះឯកឧត្ដមប្រធានរដ្ឋសភា

–សូមចម្រើនពរ ចំពោះឧត្ដមសេនីយ៍ នាយករដ្ឋមន្ត្រី នៃរដ្ឋាភិបាល

សង្គ្រោះជាតិ

–សូមចម្រើនពរចំពោះលោកប្រធានពុទ្ធិកសមាគម មជ្ឈមណ្ឌល

កម្ពុជរដ្ឋ

-សូមបម្រើទានចំពោះឯកឧត្តម- រដ្ឋមន្ត្រី- ភ្នាក់ងាររដ្ឋបាល និង ប្រជាពុទ្ធបរិស័ទទូទៅ

កាលពីវេលាម៉ោង ២០, ២០ នាទី ថ្ងៃព្រហស្បតិ៍ ១៤ កើត ខែភទ្របទ ព.ស. ២៥១៣ ត្រូវនឹងថ្ងៃទី ២៥ កញ្ញា ឆ្នាំ ១៩៦៩ ។ គណៈកម្មាធិការ នីតិប្រតិបត្តិ ពុទ្ធសាសនាថេរវាទ មជ្ឈមណ្ឌល ដែលមានទីស្នាក់ការអចិន្ត្រៃយ៍នៅវត្តចន្ទរង្សីរដ្ឋធានីព្រៃនគរ បានទទួលពត៌មានដ៏ក្រៀមក្រំមួយ ដែលស្ថានីយ៍វិទ្យុប្រទេសកម្ពុជា ផ្សាយក្នុងរលកធាតុអាកាសកម្ពស់ ២១៣ ម៉ែត្រថា: សម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ជួនណាត ជោតញ្ញាណោ បានសោយព្រះទីវង្គត នាមហាកុដិវត្តឧណ្ណាលោម រដ្ឋធានីភ្នំពេញ ។

ដំណឹងដ៏ខ្លោចផ្សានេះ បណ្ដាលឲ្យគណៈកម្មាធិការនីតិប្រតិបត្តិ យើងខ្ញុំចេញសារាចរជាបន្ទាន់ ទៅកាន់វត្តខ្មែរចំនួន ៥០០ វត្តដែលមាននៅគ្រប់ខេត្តទាំង ១៤ ទូទាំងប្រទេសនៅវៀតណាមខាងត្បូង មានព្រះសង្ឃចំនួន២៥.០០០អង្គ និងពុទ្ធសាសនិកខ្មែរជាងពីរលាននាក់ជាអ្នកឧបត្ថម្ភផងនោះ ឲ្យប្រញាប់រៀបចំធ្វើមហាពិធីបង្សុកូល ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធព្រះបរមសព សម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ព្រមទាំងចូលកាន់មរណៈសញ្ញាជាមួយព្រះសង្ឃ និងប្រជាពុទ្ធបរិស័ទនៅប្រទេសខ្មែរក្នុងរយៈវេលាមួយសប្ដាហ៍ជាកំហិត ។

ដំណឹងដ៏ក្រៀមក្រំនេះ បានសាយភាយទូទៅគ្រប់មជ្ឈដ្ឋានប្រជាជនខ្មែរ អ្នកកាន់ព្រះពុទ្ធសាសនានៅវៀតណាមខាងត្បូងទាំងអស់ និងតក់ស្លុតរន្ធត់ចិត្តរៀងៗខ្លួន ពីព្រោះបាត់ខ្លួនព្រះមហាវីរសមណៈមួយព្រះអង្គ ដ៏ឧត្តមបំផុតរបស់ពុទ្ធបរិស័ទទូទៅ ។

លុះដល់វេលាម៉ោង ៦,៣០ នាទី ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៧០ ការិយាល័យគណៈកម្មាធិការនីតិប្រតិបត្តិមជ្ឈមណ្ឌល បានទទួលសារលិខិតមួយច្បាប់ ពីគណៈកម្មាធិការជាតិ និងពុទ្ធសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋតាមរយៈស្ថានឯកអគ្គរដ្ឋទូតសាធារណរដ្ឋខ្មែរ ប្រចាំក្រុងព្រៃនគរ ដើម្បីអារាធនាគណៈប្រតិភូសង្ឃនៅសាធារណរដ្ឋវៀតណាម ឲ្យបានទៅរួមក្នុងមហាពិធីបុណ្យនេះ ។ នេះហើយជាជោគវាសនាដ៏មហាប្រសើររបស់កូនចៅខ្មែរនៅវៀតណាមខាងត្បូង ៖ ទោះបីផ្លូវគមនាគមន៍រវាងប្រទេសទាំងពីរលំបាកយ៉ាងណាក៏ដោយ ក៏គណៈកម្មាធិការនីតិប្រតិបត្តិយើងខ្ញុំ មិនទាន់អស់ពីចិត្តនៅឡើយខំខ្នះខ្នែង រៀបចំលិខិតឆ្លងដែនមួយច្បាប់ទទួលទាប់ ដើម្បីបញ្ជូនគណៈប្រតិភូសង្ឃមួយក្រុម ដែលមានរូបខ្ញុំព្រះករុណាអាត្មាភាពជាអ្នកដឹកនាំ និងឧត្តមគតិផ្ទាល់ ដើម្បីសូមវេលាគន្ធៈមហាគុណដ៏ខ្ពង់ខ្ពស់ និងចូលកាន់មរណៈសញ្ញាជាមួយសម្តេចព្រះតេជព្រះគុណ ព្រះមហាថេរានុត្ថេរៈ និងរដ្ឋាភិបាលស្រោចស្រង់ជាតិ ព្រមទាំងប្រជាពុទ្ធបរិស័ទទូទៅ ។

ហោ ! "មរណាធម្មោម្ហិ មរណំ អនតីតោ"

គ្មានអ្នកណាមួយ អាចគេចឲ្យផុតពីមរណៈបានពិតមែន ថ្ងៃនេះយើង

ត្រូវបាត់ខូវព្រះអគ្គមគ្គុទ្ទេសក៍ ទាំងក្នុងសាសនាមួយព្រះអង្គយ៉ាងពិសិដ្ឋ គ្មានគូប្រដូច របស់ណាយើងមិនចង់ឲ្យបាត់ទៅ ក៏បែរជាបាត់ទៅវិញ ស្ដាយអើយ មហាស្ដាយ ស្ដាយតាំងចរិយា ស្ដាយតាំងធម៌ទេសនា និងពាក្យពេចន៍បាវចនា ដែលព្រះអង្គសម្ដេចធ្លាប់ផ្សាយមកកាន់ប្រជាពុទ្ធបរិស័ទខ្មែរទៅឥតរើសមុខ ជាពិសេសដូចជាការតែងតាំងព្រះមេគណ ព្រះអនុគុណ និងមន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់នៅកូសាំងស៊ីន (វៀតណាមខាងត្បូង) ក្នុងដំណើរស្ដេចនិមន្តមកជាមួយលោកស្រីកាប៉ុឡែសនៅ គ.ស. ១៩២៧ លុះ គ.ស. ១៩៣០ សម្ដេចព្រះអង្គបានស្ដេចចុះទៅរៀបចំធម៌អាចិវិន័យ និងផ្សាយគម្ពីរដីកាខាងផ្នែកសាសនាដល់បណ្ដាព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរនៅកូសាំងស៊ីនម្ដងទៀត ។

ដល់គ.ស ១៩៣៣ ព្រះអង្គសម្ដេចបានស្ដេចនិមន្តចុះរៀបចំឲ្យមានសាខាពុទ្ធសាសនបណ្ឌិត្យនៃប្រចាំដែនកូសាំងស៊ីន (វៀតណាមខាងត្បូង ទៅហូតសព្វថ្ងៃនេះជាដើម ។

ព្រះសកម្មភាពដ៏មហាស្ចារ្យនេះហើយ ដែលនាំឲ្យយើងខ្ញុំជាពុទ្ធបរិស័ទខ្មែរទាំងអស់នៅសាធារណរដ្ឋវៀតណាម ពុំអាចបំភ្លេចបានខូវព្រះសុគុណានិងព្រហ្មវិហារធម៌ ដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គសម្ដេចឡើយ គឺយើងខ្ញុំនៅកត់ត្រាទុកក្នុងបេះដូងតែរៀង ១ ខ្លួន ទោះបីព្រះករជកាយព្រះអង្គ ឃ្លាតបាត់លោកនេះ ទៅកាន់លោកខាងមុខក៏ដោយ ក៏ស្នាព្រះ

ហស្តនិងទេវតារបស់ព្រះអង្គ នៅជិតជាប់តាមយើងខ្ញុំជានិច្ច ។

គណៈកម្មាធិការនីតិប្រតិបត្តិ មជ្ឈមណ្ឌលព្រៃនគរ យើងខ្ញុំសូមសម្តែងសារជាថ្មីម្តងទៀត នូវមហាទុក្ខដ៏ខ្លោចផ្សានិងបរណាសញ្ញាដ៏ក្រៀមក្រំជាមួយសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ មន្ត្រីសង្ឃ ព្រះតេជគុណព្រះមហាថេរានុត្ថេរៈគ្រប់ព្រះអង្គ និងពុទ្ធបរិស័ទទូទាំងប្រទេស ដែលមានឯកឧត្តមប្រមុខរដ្ឋ ឧត្តមសេនីយនាយករដ្ឋមន្ត្រី ជាអគ្គមគ្គុទេសក៍ដ៏ធ្ងើមក្នុងសតវត្សដែលពោរពេញទៅដោយសន្ទុះនៃការវិវឌ្ឍន៍របស់មនុស្សលោកសម័យនេះ ។

ទីបំផុតសូមប្រសិទ្ធិឲ្យបដិសន្ធិវិញ្ញាណក្ខន្ធព្រះបរមសព បានឆាប់ទៅប្រតិស្ឋាន ក្នុងវិមានសុខាល័យ គឺព្រះនិព្វានវិមោក្ខកុំបីខាន ។

សូមឲ្យសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ បានប្រកបទៅដោយជោគជ័យសិរីមង្គល វិបុលសុខមហាប្រសើរ គ្រាន់ជាម្លប់នៃពុទ្ធសាសនិកទូទៅ ។

សូមឲ្យឯកឧត្តមប្រមុខរដ្ឋ ឧត្តមសេនីយនាយករដ្ឋមន្ត្រី អស់លោកនិងប្រជាពុទ្ធបរិស័ទគ្រប់រូប មានប្រសិទ្ធភាពជោគជ័យ ឈ្នះពួកអមិត្តឈ្លានពានទឹកដី និងញ៉ាំងសាធារណរដ្ឋខ្មែរឲ្យឈានឆ្ពោះទៅរកសេចក្តីចំរុងចំរើនរុងរឿងទាន់សម័យលោក ។

សូមឲ្យប្រទេសទាំងពីរ ខ្មែរ-វៀតណាម មានសាមគ្គីភាព ចាប់ដៃគ្នាកំចាត់ខ្មាំងឈ្លានពាន ដើម្បីស្វែងរកសុខសន្តិភាព ជូនប្រជាជនឥណ្ឌូចិន ក៏ដូចជាសាកលលោកកុំបីខាន ។

សូមគោរព

សូមអរព្រះគុណ

សូមអរគុណ

# ស្នាព្រះហស្តខ្លះ ៗ

អត្ថបទ "ស្នាព្រះហស្ត" ទាំងនេះ យើងស្រង់ចេញពីសៀវភៅ "ស្នាព្រះហស្តក្រោយបង្អស់" ប្រមូលក្រងដោយលោក ឌង-លន់ ដែលបានទទួលព្រះរាជបណ្ដាំផ្ទាល់ ហើយលោក អ៊ុំ គីម-ងន អ្នកស្រី ពាន់ ស៊ីប៊ី មានសទ្ធាបោះពុម្ពចែកជាធម្មទាន ក្នុងឱកាសព្រះរាជពិធីថ្វាយព្រះភ្លើង នៃព្រះបរមសពសម្ដេចព្រះសង្ឃរាជ (ជួន ណាត) ដែលទ្រង់ជាអ្នកនិពន្ធអត្ថបទទាំងនេះ ។

## សេវនាសេវនតា

ការគួរសេពគប់ និង មិនគួរសេពគប់

## ព្រះបរមពុទ្ធោវាទ

*អសេវនា ច ពាលានំ កុំសេពគប់ពួកជនពាល, បណ្ឌិតានញ្ច សេវនា គួរសេពគប់ពួកជនបណ្ឌិត ។ ពាក្យថា* ពាល *នេះ មានប្រកតដើមថា* ទ្វិ *"ពីរ" និង* លុ *"កាត់" ផ្លាស់* ទ្វិ *ជា* ពា *ផ្លាស់* លុ *ជា* ល *ផ្សំជា* ពាល *ប្រែថា "អ្នកកាត់ប្រយោជន៍ពីរ" គឺប្រយោជន៍ខ្លួនឯងនិងប្រយោជន៍អ្នកដទៃ ឬប្រយោជន៍បច្ចុប្បន្ន និង ប្រយោជន៍បរលោក ។* ពាល *បើជាគុណបទ ប្រែថា "ក្មេង, ខ្ទន់, ល្ងង់" ។ ពាក្យថា* បណ្ឌិត *មានប្រកតដើមថា* បឌិ *ចេញមកជា* បណ្ឌា *ប្រែថា "ប្រាជ្ញារក្សាខ្លួនឲ្យគេចចៀសរាំងផុតចាកទុច្ចរិត" ផ្សំជាមួយនឹង* ឥក *(បច្ច័យ) សម្រេចរូបជា* បណ្ឌិត *ប្រែថា "អ្នកមានប្រាជ្ញារក្សាខ្លួន ឲ្យគេចចៀសរាំងផុតចាកទុច្ចរិត គឺអ្នកកាន់*

សុចរិតខ្ជាប់ខ្ជួន" ប្រែឲ្យថា "អ្នកប្រាជ្ញ" គឺអ្នកមានគំនិតប្រាជ្ញាយល់ខុសត្រូវ ព្រមទាំងប្រព្រឹត្តកាន់សុចរិតយុត្តិធម៌ខ្ជាប់ខ្ជួនផង " ។ ផ្ទុយគ្នានឹងពាក្យថា ពាល ។ បណ្ដាពាក្យទាំងនេះ ពុទ្ធបរិស័ទពុទ្ធសាសនិកខ្មែរយើងនិយមថាពាក្យ ពាល ថាអ្នកល្ងង់ខ្លៅ ប្រើពាក្យ បណ្ឌិត ជាអ្នកចេះដឹង ដោយហេតុនេះបានជាបព្វជិតពុទ្ធសាសនិក ដែលលាចាកផ្នួសទើបនឹងសឹកថ្មីៗ គេហៅថា បណ្ឌិត ហៅឃ្លាតមកថា អន្ទិត ( ស្រដៀងនឹងសម្ដីប្រាក្រិតនៅប្រទេសឥណ្ឌា ) បានជាគេហៅយ៉ាងនេះព្រោះគេយល់ថា "អ្នកត្រឹមត្រូវ អ្នកចេះដឹង អ្នកហ្មត់ចត់ ត្បិតទើបនឹងលាចេញមកពីវត្តអារាមដែលជាកន្លែងហ្មត់ចត់ ទាំងកំពុងប្រព្រឹត្តសុចរិតខ្ជាប់ខ្ជួនផង,, ( ពិតឬពុំពិតគេហៅនោះ ជានាទីរបស់អ្នកដែលទើបនឹងសឹកនោះឯង គួរណាស់តែប្រព្រឹត្តធម៌កាន់សីលឲ្យបានហ្មត់ចត់ខ្ជាប់ខ្ជួនរៀងទៅ កុំឲ្យអ្នកផងគេរិះគន់និន្ទាខ្លួនបាន កុំឲ្យចុះក្នុងតម្រាថា "អន្ទិតគោលោក ឲ្យស្រីបញ្ឆោត អស់ពោតមួយចម្ការ" ដែលមានរឿងដំណាលថា សឹកមកដាំពោត មានស្រីម្នាក់បញ្ឆោតទិញពោតជឿ តមក ឥតបានសងថ្លៃពោតទាល់តែសោះ, កើតទុក្ខសំកុកសម្កុល ខ្មាសគេសន្ធឹក) ។

## ពាក្យកាព្យឱ្យងាយចាំ

ពាក្យ ៧

គប់ពាលវែងកលទៅរកខុស　　គប់ប្រាជ្ញស្រីប្រុសវែងបានត្រូវ
គប់មិត្តអបលក្ខណ៍វែងអាស្រូវ　　ខុសត្រូវមានព្រោះការសេពគប់ ។

គួរជ្រើសរើសរកជនប្រុសស្រី　　តើមានធម៌អ្វីជាប្រកព
បើឃើញច្បាស់ហើយសឹមសេពគប់　　ឬត្រូវតែឈប់កុំរវល់ ។
បើតាមទំនងព្រះសម្ពុទ្ធ　　វិសុទ្ធទ្រង់ធម៌និម្មល
គួរដឹងថាបើឃើញបុគ្គល　　យល់ខុសពុំគួរសេពគប់ឡើយ ។
សូវនៅម្នាក់ឯងប្រសើរជាង　　ត្រូវតែចៀសវាងជនគោះតើយ
មិនកាន់តាមធម៌ជាគោះត្រើយ　　ព្រងើយដោយយល់ថាខ្លួនត្រូវ ។
មកពីប្រទូស្តគំនិត　　ភ្ជាត់គិតវៃរយល់ព្រៃជាផ្លូវ
យកធម៌សុចរិតជាសត្រូវ　　ក្រឡូវតែម្តងឯទុច្ចរិត ។
ផ្ទុយទេខុសទេគ្រះបោះបង់　　គួរចំផ្ចិតផ្ចង់កាន់សុចរិត
កុំអាងថាស្រេចតែនឹងចិត្ត　　គួរតែអាណិតខ្លួនទើបសម ។
ព្រោះការសេពគប់ខុះសំខាន់　　ប្រយ័ត្នកុំភ័ន្តកុំប្រឡំ
គប់ពាលបានពាលមិនបាច់ទំ　　ដូចគេរាយដំឡៀសខ្ទប់ ។
គប់មិត្តបណ្ឌិតបានបណ្ឌិត　　គំនិតត្រឹមត្រង់អាចបញ្ចប់
ឧបទ្រពចង្រៃឲ្យរម្ងាប់　　សុខស្ងប់អាចមានកើតឯងៗ ។
ព្រះសព្វញ្ញូទ្រង់ត្រាស់ថា　　ជនណាជាមនុស្សពាលជាក់ស្តែង
ស្រាប់តែភ្ញាក់ខ្លួនថាអញឯង　　ជាពាលក្រៃលែងទៅហើយតើ ។
ជននោះបានឈ្មោះថាបណ្ឌិត　　ព្រោះភ្ញាក់គំនិតដោយអើពើ
នឹងអាចញ៉ាំងខ្លួនឲ្យបានរើ　　គំនិតសើរើឲ្យឃ្លាតឆ្ងាយ ។

ឆ្ងុយគ្នាស្រឡះពីជនពាល
ពង្រីកពង្រាលផ្លូវអបាយ
ប្រមុំនៃទុក្ខភយន្តរាយ
កម្ចាយសុខស្ងប់ឲ្យសាបសូន្យ ។
ឥតភ្ញាក់ខ្លួនសោះរើតតែរើត
ឥតគិតអាណិតប្រពន្ធកូន
ទោះបីមិត្តភក្តិនិងបងប្អូន
ខ្លួនខំរំលឹកក៏លែងកើត ។
ជននោះឈ្មោះថាមហាពាល
ពេញស៊ីបជាពាលត្បូងឯកឆើត
គួរសាធុជនកុំឈមមើត
មិនកើតទេគុណក្លាយជាទោស ។
គួរចៀសដូចចៀសផ្លូវតេល
រិចរិលយ៉ាងណាដោយការឆ្គាង
កុំឈ្លោះប្រកាន់ឲ្យរនុស
ក្រែងទោសនឹងមានព្រោះធ្វើគុណ ។

អហំ ដ.ណា ជោតញាណ

មានក្តីគោរពព្រះមានបុណ្យ
ពេលដែលខ្លួនកាន់តែចាស់ស៊ុន
ជីពដូនតម្រប់ប៉ែតសិបប្រាំ ។
ភ្នែកទឹកដល់ពួរករសិត
ចារូបយើងពិតជាមិនទ្រាំ
ដល់រយឆ្នាំទៅរឹងខ្លួចខ្លាំ
ពុំទ្រាំរស់នៅតាមចង់ឡើយ ។
រូបបាក់សូន្យទៅនាមគង់នៅ
ដោយសារចិត្តដៅពុំគោះភ័យ
ប្រឹងកសាងកេរ្តិ៍ពុំព្រងើយ
ខ្លួនបាត់ទៅហើយកេរ្តិ៍គង់នៅ ។
ហេតុនេះអហំខំប្រឹង
ទោះខ្លួនចាស់ម៉ឹងមិនសៅដៅ
ធ្វើនេះរួចធ្វើនោះទៀតទៅ
មិននៅយកស្រួលដោយទម្រន់ ។
មិនព្រមទម្រើសខ្លួនឲ្យភ្លាប់
គាំងចិត្តមាំខ្ជាប់ដោយគិតគណាថ៌
ឃើញថាតរណីយ៍នោះស្រាលពួន
កម្រពេកពន់ក៏ត្រូវប្រឹង ។

មានពាក្យភាសិតតែងប្រាប់ថា រូបតែងជរាមិនរឹងប៉ឹង
ប៉ុន្តែរូបខ្ញុំដេកសម្ងំ រង់ចាំតែពេលអស់ជីវិត ។
កិច្ចការខ្លះធ្វើបានដោយកាយ ខ្លះដោយវាចានិងចិត្តគិត
ទោះខ្លួនចាស់ត្រូវប្រឹងប្រព្រឹត្ត កុំគិតដេកចាំតែពេលស្លាប់ ។
ធ្វើនៅស្ដីទៅគិតឲ្យសព្វ ការអ្វីគួរគាប់ត្រូវកាន់កាប់
ប្រយ័ត្នកុំឲ្យតែខុសច្បាប់ បើច្បាប់បើកផ្លូវត្រូវប្រឹងធ្វើ ។
ប្រយ័ត្នមួយយ៉ាងកុំឲ្យប៉ះ ប្រទះត្រូវចាំលើអំពើ
ជាកម្មអកុសលកុំខ្វល់ធ្វើ ព្រោះកាលបើធ្វើវេងបានទុក្ខ ។
កុំឃើញត្រឹមតែបច្ចុប្បន្ន ប្រយ័ត្នក្រែងក័ន្តទៅខាងមុខ
កុំយល់ថាបេះតែបានសុខ ស្រណុកស្រណានគ្មានទុក្ខឡើយ ។
បានសុខត្រូវនឹកដល់ទុក្ខផង គិតឲ្យហ្មត់ហ្មងកុំគោះគើយ
សុខទុក្ខក្រវែលគ្នាឥតស្បើយ ណ្ហើយត្រឹមប៉ុណ្ណឹងចុះចប់ហោង ។

## ទសពិធរាជធម៌ ១០

ធម៌ ១០ យ៉ាងសម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្ត ព្រមទាំងទ្រង់ណែនាំប្រជាពលរដ្ឋគោរពតាមលំអានព្រះអង្គផង ហៅថា ទសពិធរាជធម៌, គឺ ១- ទាន: ការធ្វើអំណោយ, ២- សីល ការរក្សាសីល ៥ ជានិច្ច ឬរក្សាសីល ១០ (អតិរេកសីល) មួយដងមួយកាល, ៣- បរិច្ចាគ ការ

ចំណាយព្រះរាជទ្រព្យទំនុកបំរុងប្រទេសជាតិ, ៤. អាជ្ជវៈ មានសេចក្ដីត្រង់, មទ្ទវៈ ៥ មានសេចក្ដីទន់ភ្លន់សុភសុភាព, ៦. តបៈ ការកាន់ឧបោសថសីលតាមកំណត់មួងៗ, ៧. អក្កោធនៈ មិនកម្ដៅក្រហាយអ្នកដទៃ, ៨. អវិហឹសា មិនបៀតបៀនអ្នកដទៃ, ៩. ខន្តី មានសេចក្ដីអត់ធន់, ១០. អវិរោធនៈ មិនបំពានលើធម៌ លើច្បាប់ ។

កាលបើកូនកាព្យ មិនបាច់ប្រើយុគលពិន្ទុ (:) នេះ ក៏បាន តាមសម្ផស្សដែលកាព្យត្រូវចាប់ចួនគ្នា ។

## កាព្យពាក្យ ៧

ទសពិធរាជធម៌ដប់ ពីដើមដល់ចប់មានសេចក្ដី
ដូចតទៅនេះជនប្រុសស្រី គប្បីចងចាំគ្រប់ ៗ គ្នា ។
ទីមួយបាលីហៅថាទាន អ្នកមានសទ្ធាគួរជ្រះថ្លា
សង្គ្រោះគ្រោះជនអនាថា ទ័លក្រវេទនាត់តពំនាក់ ។
ទីពីរបាលីហៅថាសីល ត្រូវកាន់កុំខ្ជិលមានប្រុំប្រាក់
គឺសីលទាំងប្រាំដែលមានជាក់ ក្នុងច្បាប់ពុទ្ធចក្រនោះស្រេចស្រាប់ ។
ទីបីបាលីហៅបរិច្ចាគ លំបាកបន្តិចត្រង់លះទ្រព្យ
ចំណាយធ្វើការដែលគួរគាប់ សម្រាប់ប្រទេសជាតិសាសនា ។
ទីបួនបាលីហៅអាជ្ជវៈ ម:ឧរិត្តឃ:ថាចិត្តជា
ទៀងត្រង់ទាំងកាយទាំងវាចា ទាំងចិត្តក៏ត្រូវស្មោះត្រង់ ។

ទីប្រាំបាលីហៅមទ្ទវៈ　　ដែលមានវិគ្គហៈថាទន់ភ្លន់
ត្រែក្តារទន់ភ្លន់សមបំណាក់　　ខែងទាំងសង្ឃទាំងគ្រហស្ថ　ៗ
ប្រាំមួយបាលីហៅតបៈ　　ដែលមានវិគ្គហៈថាដុតដាស់
នឹងកាមារម្មណ៍គ្រប់ទាំងអស់　　កម្តៅចិត្តស្រស់ឲ្យស្ងួតស្ងប់　ៗ
ប្រាំពីរហៅអក្កោធនៈ　　ដែលមានវិគ្គហៈថារម្ងាប់
ក្តីក្រោធប្រទៀតឲ្យបាត់ចប់　　កំហឹងសន្ធប់ស្ងប់ភ្លាម ៗ　ៗ
ប្រាំបីហៅអវិហឹសា　　បិទកាយវាចាដោយចិត្តហាម
មិនឲ្យបៀតបៀនសព្វសត្វតាម　　ទម្លាប់នៃចិត្តឥតមេត្តា　ៗ
ប្រាំបួនមានឈ្មោះថាខន្តី　　ដែលមានសេចក្តីថាចិត្តា
ប៉ុនអត់ប៉ុនធមៈការៈព្រួចម្តា　　ប្រើកាយវាចាចិត្តធន់ទ្រាំ　ៗ
ទីដប់អវិរោធនៈ　　វិគ្គហៈថាៈទោះទោសដោកដាំ
កាន់ធម៌កាន់ច្បាប់ស៊ប់ម៉ែនមាំ　　ប៉ុនទ្រាំពុំហ៊ានរំលោភច្បាប់　ៗ

រាជធម៌ទាំងដប់នេះព្រះពុទ្ធ　　វិសេសវិសុទ្ធទ្រង់ត្រាស់ប្រាប់
ថាមានតាំងពីបុរាណស្រាប់　　ជាច្បាប់ជាប់មានគ្រប់កាលមក　ៗ
ជាធម៌សម្រាប់ព្រះមហាក្សត្រិយ៍　　ព្រះអង្គប្រតិបត្តិមិនឲ្យធ្ពក
ប្រជាពលរដ្ឋក៏ប្រឹងរក　　ក្បួនច្បាប់រៀនយកឲ្យចេះចាំ　ៗ
ដើម្បីប្រព្រឹត្តឲ្យដិតដល់　　ទោះមានកង្វល់ខ្វះក៏ទ្រាំ
ធ្មៀតកាន់ធម៌នេះមិនឲ្យខ្វាំ　　នាំគ្នាប្រតិបត្តិតាមមហាក្សត្រិយ៍　ៗ

ក៏ដូចមិនបាវនៃផ្តល់ផល    ទ្រាំចៀសកន្ទុល់ចៀសវិបត្តិ
គ្រោះកាចរលាយរលប់ខាត    រសាត់ចេញឆ្ងាយទៅឯង ៗ ។
ក្តីសុខចម្រើនកើតកើនឡើង    ប្រទេសថ្កុំថ្កើងឃើញជាក់ស្តែង
ប្រទេសជិតឆ្ងាយកោតស្ញប់ស្ញែង    ថ្លែងការណ៍រាប់រកយកជាមិត្ត ។
មានមិត្តកល្យាណបានក្តីសុខ    ស្រណុកកក់ក្តៅមិនព្រួយចិត្ត
បើឥតមានមិត្តរាប់ផ្តេកផ្តិត    ទោះប្រិតប្រឹងប្រែងក៏ពុំកើត ។
ព្រះពុទ្ធទ្រង់ត្រាស់ពន្យល់ថា    ចង់បានមិត្តភក្តិកល្យាណឆើត
ត្រូវប្រើការឲ្យ ទើបបានកើត    កំណើតនៃមិត្តជិតស្និទ្ធស្នាល ។
មិត្តឲ្យរួយើងត្រូវយើងឲ្យ    ឲ្យមុនឲ្យក្រោយគង់ត្រកាល
ទោះតិចទោះច្រើនតាំងអម្បាល    មានក្តីស្និទ្ធស្នាលជាសឆ្ងាញ់ ។
បុកណាថាទោះផ្ទះចង្អៀត    គង់លៃលកចង្អៀតឲ្យសម្លាញ់
មិត្រភក្តិសំណាក់ឥតគ្នាន់គ្នាញ់    ឈ្នះចាញ់ត្រង់រស់នៃក្តីស្និទ្ធ ។
មួយយ៉ាងថាទោះផ្ទះចង្អៀត    អាចចៀតប៉ះប៉ុនផ្គត់ផ្គង់មិត្រ
បេចិត្តចង្អៀតវិញតាមពិត    អាហារពិសិដ្ឋក៏ឥតឆ្ងាញ់ ។
ព្រះពុទ្ធជាគ្រូទ្រង់ត្រាស់ថា    ឥតរស់ជាតិណាស្មើសម្លាញ់
រាប់រកស្និទ្ធជិតឥតគ្នាន់គ្នាញ់    ឆ្ងាញ់ក្រៃលែងឆ្ងាញ់ក្រប្រៀបបាន ។
ហេតុនោះយើងគួរតែសេពគប់    មិត្រដែលគ្រាន់គ្រប់ចេះរាប់អាន
មាត់ថាដូចម្តេចចិត្តក៏បាន    មិនក្រានយើងបោលមិនថ្កោលទោស ។

មិត្រនេះហៅថាមិត្រកល្យាណ   ចិត្តបានហើយចេះមានសន្ដោស
រាប់រកមិត្រក្ដីឥតទោស   ពុំដែលចាប់ទោសកំហុសឡើយ ។
អហ៊ឺថ្លែងរាប់រៀបប៉ុណ្ណេះ   អ្នកអានល្អមចេះចាំដែរហើយ
បើអានបានយល់កុំតោះតើយ   ចប់ហើយត្រឹមតែប៉ុណ្ណេះហោង ។

វត្តខណ្ឌលោម ក្រុងភ្នំពេញ, ថ្ងៃអាទិត្យទី ១ ព.ស ២៤៩២ / គ.ស ១៩៤៨

# អក្សរខ្មែរ

## កាព្យរំលឹកអំពីអក្សរ

ពាក្យ ៧

អក្សរខ្មែររុងរឿងដោយសារខ្មែរ   ពុំហ៊ានចប់បែរឲ្យភ្លាត់ខុស
ជនខ្មែរគ្រប់គ្នាទាំងស្រីប្រុស   ពុំហ៊ានបន្ថុសឲ្យខូចចង់ ។
ជនខ្មែរស្រុះគ្នាលើកតម្កើង   តម្លើងពាក្យពេចន៍ដោយផ្ចិតផ្ចង់
ខ្មែរជាគ្រហស្ថខ្មែរជាសង្ឃ   ខំប្រឹងតម្រង់អក្សរជាតិ ។
អក្សរវិបត្តិជាតិវិបត្តិ   ខ្ចាយខ្ចាត់កក់កាយក្លាយឃ្លៀងឃ្លាត
ហេតុនេះខ្មែរយើងកុំរាត   ត្រូវរក្សាជាតិឲ្យរឹងប៉ឹង ។
បើដឹងមិនដល់កុំធ្វើចេះ   ចំណេះតិចតួចស្ដួចស្ដើងស្ដឹង
បើចង់ច្បាស់លាស់ត្រូវខំប្រឹង   កុំដេកសម្ងំឲ្យចេះឯង ។

ចំណេះកើតមានព្រោះការរៀន　　កម្ជិលអៀនៈប្រៀនកុំសម្តែង

ធ្វើឲ្យគេស្ញើចគេកោតក្រែង　　ស្លាក់ស្លែងទេកុំរះគន់គេ　ៗ

ត្រូវរិះគន់ខ្លួនឯងជាមុន　　កុំឲ្យស៊ីយស៊ុនខុសទេ

បើធ្ងល់ពុំយល់ត្រូវសួរគេ　　ឥតជាកម្ទេ　ថ្លៃទេតើ　ៗ

ចុកណាជាថោកអីនឹងថៃ　　ថ្លៃអីនឹងមាត់ពោលសើរើ

រៀនទៅសួរទៅទើបគ្រាន់បើ　　គេពិចង់ចេះប្រសើរណាស់　ៗ

ចាស់ជាបើល្ងង់កុំធ្វើចេះ　　បើមានចំណេះឲ្យជាក់ច្បាស់

បើស្ទើងហើយចង់ឲ្យចុះគ្រាស់　　ត្រូវថែមកម្រាស់ផ្សំសាច់គ្នា　ៗ

អចស្ទួចប៉ះប៉ុនយកកម្រាស់　　កុំតាំងកុំប្រាស់ហួសមាត្រា

ប៉ះផ្សំផ្គុំគិតទើបកើតជា　　ពោលឬបន្ទាំម្ទួនជាងមុន　ៗ

បើចេះអក្សរ　និង　ភាសា　　នៃជាតិណា ១ កុំជ្រុលស៊ុន

ចាប់ស័ព្ទប្រែស្រាយក្លាយជាចំកុន　　ស៊ុនគ្រុនប្រែស្រាយឃ្លាតក្តីពិត　ៗ

កាលដែលប្រាព្ធនឹងប្រែស្រាយ　　ត្រូវគិតនាយអាយដោយពិនិត្យ

ឲ្យឃើញសេចក្តីជាខ្មែរពិត　　សឹមប្រែកុំធ្លុតតាមពាក្យគេ　ៗ

ត្រូវប្រែឲ្យមកជាសេចក្តី　　ដែលខ្មែរប្រុសស្រីអាចរិះរេ

ស្តាប់យល់មិនធ្ងល់ទើបហៅប្រែ　　ត្រឹមត្រូវតាមរូបសេចក្តីពិត　ៗ

អ្នករៀនភាសាជនបរទេស　　ខ្វេខ្វួសដោយការឥតបើគិត

កាលខ្លួនកំពុងរៀនប្រឹងប្រឹត　　ប្រែផ្តិតឲ្យចំតាមរូបស័ព្ទ　ៗ

ម្តេចនឹកគិតមកភាសាខ្លួន ឲ្យយល់សំនួនដែលងាយស្តាប់
សម្ទឹងសង្កេតតែរូបស័ព្ទ ក៏ស្រាប់តែប្រែខុសទាំងស្រុង ។
អ្នករៀនសំស្រ្កឹតឬបាលី ប្រែខុសសេចក្តីព្រោះក័ក្តផុង
យល់ខុសទទេជាងដើមចុង ចូលក្នុងរឹងស៊ុងខ្មាសអ្នកផង ។
តិដ្ឋៈបាលីប្រែថាឈរ អ្នករៀនឈ្ងក់វក់ក្តម្ង ៗ
ត្រង់មានសេចក្តីថាស្លូនត្រង់ ប្រែត្រង់ថាឈរហៅឆាប់ស័ព្ទ ។
បាក់ងពាក់គេសួរលោតែត ខ្មែរផ្គតចិត្តជាប់បែរប្រែប្រាប់
អ្នកដែលមិនបេះឲ្យគ្នាស្តាប់ បង្គាប់ថាឲ្យកាន់លើក្បាល ។
មិនប្រាប់ឲ្យគ្នាដឹងថាទូល នេះហៅប្រមូលពុំត្រអាល
ពាក្យខ្មែរថាទូលក៏លើក្បាល ត្រអាលប្រែខុសពីពាក្យខ្លួន ។
តែងកាព្យឲ្យត្រូវតាមសម្ផស្ស តាមកាព្យចាស់ ៗ ដែលមានចួន
កុំបេះតែតែងតាមចិត្តខ្លួន ឲ្យកាព្យមានចួនខុសមាត្រា ។
ពាក្យអឺយនិងអើយ[1]សូរផ្សេងគ្នា ដូចជាប្អូនអើយ[2]ម្តេចឡើយថា
ស្តាប់បងមិនព្យុស្ងួនក្សា ធ្វើជាមិនព្យុព្រោះរឹងខ្លួន ? ។
ព្រះបាទសម្តេចព្រះហរិរក្ស ទ្រង់បានបញ្ជាក់ដោយផ្ទួន ៗ
ក្នុងកាព្យព្រះអង្គដែលមានចួន សំនួនសម្ផស្សកែតមានគ្គង ។

---

១ អានថា អ្ហើយ កុំថាអើយ ឬ អឺយ ឡើយ ។ ២ អានថាប្អូនអ្ហើយ ឬ ប្អូនណើយ កុំថាប្អូនអឺយ ។

កវីគួរតែយកគម្រាប់ គួរកុំប្រញាប់កាត់សេចក្ដី
ស៊ុបបែបនោះមិនគ្រាប់គ្រាន់ ខុសពីបំណងអ្នកប្រាជ្ញចាស់ ។
មានអ្នកតែងកាព្យខ្វះហានថា មេ្ដចមិនកបាឲ្យជាក់ច្បាស់
ប្រើជាកិរិយាស័ព្ទខុសណាស់ គួរផ្លាស់សម្ដីនេះចោលចេញ ។ល។

បទភាកាកតិ

ខ្មែរពីព្រេងនាយ ចង់ឲ្យបានងាយ ប្រើពាក្យរើៗ
គង់ពាក្យដែលត្រូវ ប្រើគ្រឹង ឬស្រឹង្គ អ្នកអានពុំដឹង
ពាក្យទាំងពីរនេះ ។
តែគ្រឹង្គ ឬ ស្រឹង្គ(១) ដោយពុំបានដឹង ព្រោះខ្លួនពុំចេះ
នាំឲ្យប្រែឡំ ផ្សិតឥតចំណេះ សំស្រួតមិនចេះ
ជ្រៅជ្រះមិនយល់ ។
ហេតុនេះបានជា ខ្មែរទាំងអស់គ្នា ក្នុងគ្រាខ្វះខ្វល់
នាំគ្នាលុបចួ ក(២)មិនឲ្យសល់ ថែមទាំងលុបដល់
ឬ(៣)នេះនៅផង ។

១- សំ គ្រឹង្គ > ក្រឹង្គៈ បា សិង្គ "ស្នែង ក្ដុងក្រើ" ។ ២- អ ចំ. សរ (ឲ) ។ ៣- អ.ចំ.
សរ (ឝ) ។

ព្រោះតួចាំងចី អានពុសម្តី ដូចគ្នាតែម្តង
តើទុកធ្វើអ្វី នាំឲ្យតែឆ្គង លុបចោលលែង
កុំឲ្យចង្អៀត ។

ចំណែកខាងលាវ សម័យព្រាវ ៗ ក៏នាំគ្នាទៀត
លុបតួអក្សរ ដប់ពីរបង់សៀត កម្រនឹងទៀត
បង្កើតវិញបាន ។

លាវលុបតួ-ឃ និងតួ ឆ-ឈ វគ្គ-ដ ប៉ុន្មាន
និងតួ-ធ-ភ គ-បពីរប្រាណ ចូករួមទៅបាន
ដប់ពីរអក្សរ ។

សម័យនេះលាវ សរសេរព្រាវ ៗ អស់កាតបវរ
ត្រង់ពាក្យប្រើ-ឃ ប្រើ-គ អក្សរ(១) លាវឃ្លាតអំណរ
រកត្រូវទៅហើយ ។

ហេតុនោះខ្មែរយើង កុំធ្វើទើងមើង យល់ការល្ងើយ ៗ
គិតលុបអក្សរ តួខ្វះចោលឡើយ បើលុបច្នោះហើយ
នៅជាមនុស្សព្រៃ ។

ប្រទេសធំ ៗ គេប្រើនិយម រាល់យប់រាល់ថ្ងៃ
អក្សរភាសា ជាតិគេឲ្យថ្លៃ កុំឲ្យចង្រៃ
រូបកេជាតិបាន ។

---

១- ព្រោះលាវយល់ឃើញថា មានសូរសៀងដូចគ្នា ត្រូវលុបចោលខ្លះទៅ ។

បណ្ឌិត្យសភា គេលើកឲ្យជា បណ្ឌិត្យដ្ឋាន

សម្រាប់ឲ្យជាតិ ឡើងត្រួសត្រើងត្រាន ហើយជាតិគេមាន

ក្តុំក្តើនជានិច្ច ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ ថ្ងៃទី ២២ មករា $\frac{២៥១២}{១៩៦៩}$

សម្តេចព្រះសង្ឃរាជ

ជ.ណ. ជោតញ្ញាណោ

ប.អ.ស. – អ.ម.រ.

## នពសំខ្យា និង បញ្ចសំខ្យា

---

អ អា ឥ ឦ ឧ ឩ ឯ ឱ ញ ន អក្សរ ១០ តួនេះទុកជា

០ ០ ០ ០ ០ ០ ០ ០ ០ ០

ជាសូន្យ (០) ហៅថា សុញ្ញសំខ្យា ឬ សូន្យសំខ្យា ។

ក ខ គ ឃ ង ច ឆ ជ ឈ អក្សរ ៩ តួនេះជាខ្សែសំខ្យា ។

១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩

ដ ឋ ឌ ឍ ណ ត ថ ទ ធ អក្សរ ៩ តួនេះជាខ្សែសំខ្យា ។

១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩

ប ផ ព ភ ម អក្សរ ៥ នេះហៅថា បញ្ចសំខ្យា ។

១ ២ ៣ ៤ ៥

យ រ ល វ ឝ ឞ ស ហ ឡ អក្សរ ៩ នេះជានវសំខ្យា ។

១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩

ត្រូវរាប់ថយក្រោយជាដរាប ដូចជា មាឃវស្សានិ អស់ស្យា

៥ ៤

តាំងឡាយ ៤៥ ពុទ្ធសភេ ខយាមរេ ក្នុងពុទ្ធសករាជ ២៥១២

២ ១ ៥ ២

គ្រិស្តសភេ ឬកិដ្ឋសភេធិតាធយេ ក្នុងគ្រិស្តសករាជ ១៩៦៨ ។

៨ ៦ ៩ ១

ព្រះគន្ថរចនាចារ្យផុះខចង់ប៉ុលទុកជាឧទាហរណ៍ ខាងក្រោមនេះ ឲ្យអ្នកបាលីបាននេះក ៗ គ្នាមកថា ៖

អនញ្ញាកាដ្ឋី ២១.០០០ គឺព្រះវិន័យមាន ២១.០០០ ព្រះធម្មក្ខន្ធ,

០ ០ ០ ២ ១

ន្ធនាឯការី ២១.០០០ គឺព្រះសូត្រមាន ២១.០០០ ព្រះធម្មក្ខន្ធ,

០ ០ ០ ១ ២

ន្ធនាដរវេ ៤២.០០០ គឺព្រះអភិធម្មមាន ៤២.០០០ ព្រះធម្មក្ខន្ធ;

០ ០ ០ ២ ៤

ធ្ធាធក៌យា ៨៤ ០០០ (ទេជាប៉ិដកទាំង ៣ មាន ៨៤.០០០

០ ០ ០ ៤ ៨

ព្រះធម្មក្ខន្ធ គឺ ព្រះធម៌វិន័យមាន ៨៤ ០០០ ព្រះធម្មក្ខន្ធ ) ។

លោកតែងពោលជាបថ្យាវត្តថា

អញ្ញនរីរ ភូមិ ផែនដីមានកម្រាស់ ២៤០.០០០ យោជន៍;

០ ០ ០ ០៤២

អញ្ញាកនិ វុធធិ ទឹកសមុទ្រដែលជ្រៅណាស់ ខាងជម្រៅ ៨៤.០០០ យោជន៍ (វុទធិ កាត់បទសន្ធិជា វ៉ + ឧទធិ "សមុទ្រ", គឺ វ.អាគមដែលចុះថែមមកសម្រួលគាថាជា ជ.គណ:);

អញ្ញាទុតិយោ មេរុ ភ្នំព្រះមេរុ គឺភ្នំព្រះសុមេរុមានកម្ពស់

០ ០ ០ ៨៦ ១

១៦៨.០០០យោជន៍; ធាសវក្កាអៀត តេជសា កំករម៉ែក រំពើក ដោយតេជះនៃព្រះសម្មាសម្ពុទ្ធអង្គនោះ (ក្នុងកាលដែលមាន មហាស្ចារ្យម្គ ។ ។

ពាក្យថាយោជន៍ក្នុងទីនេះ សំដៅយកខ្នាត ៧ ហត្ថដោយគណនា ប្រាស់ពីក្រោមឡើងលើ ឬ ក៏ពីលើចុះក្រោម គឺ ៧ ហត្ថ ហៅថាមួយ យោជន៍ ដូចបាលីដែលធ្លាប់តែមានក្នុងរឿនខ្លះថា យោជនសត្តុទេ-ធោ ឧបោធនិព្រោធរុក្ខា ដើមជ្រៃធំមានកម្ពស់ ៧ យោជន៍ គឺ មានកម្ពស់ ៤៩ ហត្ថ (ហត្ថមធ្យមបុរស គឺហត្ថខ្នាត) ។

មិនពិបាកយល់ប៉ុន្មានទេ, ខ្ញុំអោយត្រឹមតែប៉ុណ្ណោះ អស់លោកអ្នករៀនបាលី ឬ សំស្ក្រឹត ដែលពុំទាន់បានចេះបំខ្យាបែបនេះ គឺល្មមសំគាល់ឲ្យចេះដឹងបានហើយ ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអាទិត្យទី ២១ កក្កដា ២៥១២/១៩៦៨

សម្ដេចព្រះសង្ឃរាជ ជ.ណ. ជោតញ្ញាណោ

ប.អ.ស–អ.ម.វ.

## បុរាណភាសិត

### ត្រុក ៗ អ្នកស្រុកមើលងាយ
### រលាស់គូទខ្វាយ មានឱតមានភ័ក្ត

អត្ថន័យនៃបុរាណភាសិតនេះពោលថា មនុស្សណាមួយ ជាអ្នកមានប្រាជ្ញា យោបល់និងសន្តីថ្វីមាត់ហ្មត់ចត់ ប៉ុន្តែជាមនុស្សចេះអត់ចេះធន់ មានចិត្តធ្ងន់ធ្ងរនឹងធឹង គេពុំសូវបើដឹងថាខ្លួនឬជា ប្រើអាការកិរិយាញើបៗ ត្រុកៗ, ពួកជនអ្នកនៅក្នុងស្រុកភូមិផងរបងជាមួយ និងអ្នកនៅភូមិជិតខាងគ្នា ច្រើនតែមានយោបល់យល់ថា អ្នកនោះឯងជាមនុស្សខ្ទុយមុយ មិនមែនជាអ្នកអង់អាចរលុរលាយខាងសម្ដីសម្ដៅអ្វីទេ គ្រាន់តែជាមនុស្ស

សុភំសុភាពពបចាបប៉ុណ្ណោះ, ស្រាប់តែទៅពេលមួយ អ្នកនោះឯង

បញ្ចេញសម្ដីវោហារ ជាផែកតែក្នុងរឿងអ្វីមួយ ក្នុងវិប្រជុំមហាជន ដែលមានការជជែកវែកញែកដោះស្រាយករណីយៈ មតិដ៏ត្រូវ ឲ្យឃើញជាក់ស្រឡះស្រឡំបាន, ជនខាងឡាយក៏ដូចជាភ័ន្តភាំងស្ងើចសរសើរនៅពេលនោះតែម្ដង, ក៏លែងមើលងាយទៀតមក ៗ ព្រោះហេតុនោះ បានជាមានបុព្វភាសិតថា ត្រុក ៗ អ្នកស្រុកមើលងាយ លាស់គូទខ្លាយ មានទុកមានភ័ន្ត ៗ

មានបុព្វភាសិតមួយយ៉ាងទៀត ប៉ុន្តែមានអត្ថន័យស្រដៀងគ្នានឹងភាសិតខាងលើដែរថា ត្រូវក្រាប់កុកកាសរាប់ កុំក្រាប់កុកកាស មានអត្ថន័យថា កុកសាប់មាឌតូចបន្តិចជាងកុកស, មានខ្នង ស្លឹកស្វាយសម្បុរត្រសក់ស្រគាប, កាលបើវាទំលើទ្រនំ, មើលទៅឃើញច្រឡំនឹងស្លឹកឈើ ស្ទើរតែមើលពុំឃើញច្បាស់ថាជាកុកឡើយ ៗ ឯកុកសនោះ វាទំលើទ្រនំក្ដី វាហើរក្ដី ឃើញតែសម្បុរសដូចគ្នា ព្រោះវាមានតែសម្បុរសមួយយ៉ាង ៗ អត្ថន័យវែងជាងនេះ ស្រដៀងគ្នានឹងបុព្វភាសិតខាងលើថា ត្រុក ៗ អ្នកស្រុកមើលងាយ... នោះដែរ ។ល។

## ពាក្យកាព្យឲ្យងាយចាំ

### បទកាកគតិ

បុកពាត្រុក ៗ ជនទៅក្នុងស្រុក គេច្រើនមើលងាយ
កណ្ដាលជំនុំ ស្រាប់តែកម្សាយ ពុកលឱបាយ
មានទុខមានភ័ក្ដ ៗ

បញ្ចេញសម្ដី    មានភាក្យពិរោះ    កបតាមស្រទន់
មានទុកតញ្ញូខាំង    មួន ៗ មិនមួន    ភក់ហ៊ាក់កក់ខអន់
សុទ្ធតែគ្មានការ    ៗ

ពុំដែលមានឈ្មោះ    ថាខូចអ្នកនោះ    ជាគ្រោះពារ្យ
ឬជាអ្នកបេះ    ចំណេះធម្មិកជ    សោះទេមានការណ៍
កំះចេញប្រាជ្ញប្រែះ    ៗ

ប្រាជ្ញាបង់យល់    សម្ដីទិមល    យោចល់ឈ្លាសឆ្ពុះ
អ្នកស្ដាប់ស្ញប់មែង    ព្រោះឃើញស្ដែងទុះ    ទមាយទម្ពុះ
ការក្រេសម្ងាយ    ៗ

នេះហៅគ្រូក ៗ    ត្រាតែអ្នកស្រុក    ភូមិផងមើលងាយ
ស្រាប់តែមានករណ៍    ដែលត្រូវដោះប្រាយ    លោសកូនខ្វាយ
មានទុគមានភ័ន្ទ    ៗ

ឬដូចកុកសាប់    ស្វាបក្រៅស្រគាប់    ឥតសសាន់រុណ
កាលបើកហើរ    ឃើញស្រដាក់ស្បាន់    ពាស់ថាត្រូវគាន់
គម្រាប់កុកសាប់    ៗ

រីឯកុកស    ទំកំឃើញស    ឥតឃើញស្រគាប់
ហើរកំឃើញស    ជួយពកុកសាប់    ខ្នងស្វាបស្រគាប់
នៅពេលដែលទំ    ៗ

ហេតុនោះបានជា ក្តួកចាស់ព្រឹទ្ធា ចាំឲ្យនិយម
តាមបែបកុកសាប ជាការសមមៀ កុំឲ្យនិយម
តាមកុកសទៀយ ។

បើសាធុជន វិវេគគតណាន៍ យល់ន័យនេះហើយ
ពេញចិត្តប្រព្រឹត្ត ពិនិត្យរឿយ ៗ ប្រើប្ញុកដើយ ៗ
មិនប្រើអន្ទូត ។

កំនៅដោយយ៉ង ក៏ព្រោះខានអាង ថាមិនបាច់អួត
ចាំដល់នៅពេល ប្រណាំងប្រកួត គង់មានគេអួត
គួរខ្មាសខះយើងទេ ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃ ៩ កក្កដា ព.ស. ២៥១២ គ.ស. ១៩៦៨

សម្តេចព្រះសង្ឃរាជ ជ.ណ. ជោតញ្ញាណោ

ប.អ.ស.–អ.ម.រ.

## យសាភិវឌ្ឍកជន

“ជនអ្នកចម្រើនដោយយស”

ឧដ្ឋានវតោ សតីមតោ
សុចិកម្មស្ស និសម្មការិនោ

## សញ្ញតស្ស ច ធម្មជីវិនោ

## អប្បមត្តស្ស យសោភិវឌ្ឍតិ

យសតែងចម្រើនដល់ជន : ១- អ្នកមានព្យាយាមរឹងប៉ឹងមាំ, ២- អ្នកមានស្មារតីខ្ជាប់ខ្ជួនមិនភ្លេចភ្លាំង, ៣- អ្នកមានការងារស្អាតហ្មត់ហ្មង, ៤- អ្នករិះគិតពិចារណាត្រិះត្រៃយល់ការសព្វគ្រប់សិន ហើយទើបធ្វើអ្វីៗ, ៥- អ្នកសង្រួមត្រឿយស្រគត់ស្រគំសមរម្យមិនឆ្គង, ៦- អ្នកបំពេញជីវិតត្រឹមត្រូវតាមគន្លងធម៌ ៧- អ្នកមិនមានប្រមាទ គឺប្រុងប្រយ័ត្នស្មារតីជានិច្ចមិនលុះលង់ក្នុងការធ្វេសប្រហែស (ដោយបរិយាយថា "អ្នកមានសតិ សម្បជញ្ញៈ ជានិច្ច") ។

## អត្ថន័យពាក្យថា យស

១- ឥស្សរិយៈ គឺភាពជាធំឬបុណ្យស័ក្តិ, ២- ភោគទ្រព្យ គឺមានទ្រព្យធនច្រើន, ៣- សម្មានៈ គឺមានអ្នកដៃទាបជាច្រើន, ៤- កិត្តិ មានកេរ្តិ៍ឈ្មោះល្អ គេស្ងើចសរសើរច្រើន, ទាំង ៤ នេះ ហៅថា យស ។ រីឥស្សរិយយស គឺយសនៃអ្នកធំ ឬយសនៃអ្នកមានបុណ្យស័ក្តិ ។ គ្រឿងឥស្សរិយយស គឺវត្ថុរបស់ជាគ្រឿងលើកតម្កើងអ្នកមានឥស្សរិយៈ ។

# ពាក្យកាព្យឲ្យងាយចាំ

ពាក្យ ៩

ផែនណា មានព្យាយាម ដំម៉ឹងម៉ាត់
ប្រុងប្រយ័ត្ន តាំងស្មារតី ខីរក្សា
មានការស្អាត មិនគ្រោតគ្រាត មិនខ្ជីខ្ជា
ពិចារណា ឲ្យឃើញសិន ហើយទើបធ្វើ ៗ
ប្រឹងសង្រួម នូវឥន្ទ្រីយ៍ សមរម្យពិត
មានជីវិត រស់នៅស្រួល ដោយធម៌ស្មោះ
មិនប្រមាទ ឲ្យឃ្លៀងឃ្លាត វែងអែតើ
ជនទោះបើ នៅទីណា តែងមានយស ៗ

## ភាសិតបុរាណថា

ស័ក្តិកុំស្មើយស នាអ្នកខ្ពង់ខ្ពស់
កុំស្មើចិត្តជា

# ពាក្យកាព្យបញ្ញាភាសិតនេះ

បទ កាកគតិ

ភាសិតចាស់ថា ឧះអ្នកណា មានស័ក្តិខ្ពង់ខ្ពស់
មានត្រឹមតែស័ក្តិ ប៉ុន្តែគ្មានយស ច្រើនតែរលស់
គ្មានឈ្មោះនោះឯង ។

បើអ្នកមានជាតិ ត្រកូលអមាត្យ មន្ត្រីជាក់ស្តែង
មានចិត្តអាក្រក់ គេមកស្អប់ស្អែង មានគេខ្លាចក្រែង
ប៉ុន្តែគេស្អប់ ។

ឧះអ្នកណា គ្មានសក្តា ប៉ុន្តែមានទ្រព្យ
មានគេរាប់អាន ជុំញាតិគ្រប់សព្វ ជាប់ទាក់ទាំងជាប់
សង់មូលចូលមក ។

ព្រោះគេមានចិត្ត មេត្តាអាណិត ប្រណីហៅគេ
ស៊ីចុះមិនគិត ដើរទៅហៅមក អ្នកផងចូលជ្រក
ចំពេញយសឡើង ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអាទិត្យទី ២១ កក្កដា ២៥១២/១៩៦៨

សម្តេចព្រះសង្ឃរាជ ជ.ណ. ជោតញ្ញាណោ

ប.អ.ស.—អ.ម.វ.

# បុរាណភាសិត

ប្រើតាមសម័យនិយមព្រះរាជា

## សម្តីជាឯក លេខជាទោ អក្សរជាត្រី

អត្ថន័យថា ពោះនិយាយស្តីមាត់ទទេក្តី ពោះសរសេរសម្តីជាលាយល័ក្ខណ៍អក្សរក្តី សម្តីមានឋានៈជាឯក ទាំងខាងសម្រេចប្រយោជន៍ ទាំងខាងឥតប្រយោជន៍ ។ លេខទុក ក្នុងបុរាណសម័យ មាននាទីត្រឹមតែខាងគណនា បូក-គុណ-ចែក-ដក ប៉ុណ្ណោះ ពោះបើសម័យវិទ្យានិយមសព្វថ្ងៃនេះ ដែលគេលើកលេខជាគណិតវិទ្យាមានឋានៈខ្ពង់ខ្ពស់ក៏ដោយ វិទ្យាលេខក៏នៅតែមានឋានៈជាទោ ដូចក្នុងសម័យបុរាណព្រេងនាយនោះដែរ ។ ឯអក្សរ គិតតែជាប្រភព ឬ ជាមេ ជាគ្រូ នៃវិទ្យាទាំងពួងជាដើមក៏មែន ប៉ុន្តែមានឋានៈត្រឹមតែឲ្យតែវិទ្យាទាំងពួងនិងសម្តីប្រើប្រាស់ប៉ុណ្ណោះ ព្រោះហេតុនោះ អក្សរត្រូវមានឋានៈត្រឹមតែថ្នាក់ត្រី... ។

## ពាក្យកាព្យឲ្យងាយចាំ

### បទកាកគតិ

សម្តីជាឯក ក្នុងការដដែក ថ្លែងការណ៍នានា
លេខអន់សម្តី គប្បីយល់ថា ដដែកគគាំ
ជាដើមតែងភ្លក់ ៗ

ព្រោះមានការយល់ ថែស្ដីមិនផល់ គ្រាន់តែហើបមាត់
ពីរបីប្អូនម៉ាត់ គេស្អាត់សង្កត់ ទៅជាមិនមាត់
ហើយហាមិនរួច ។
សម្ដីស្រួចស្រស់ កិច្ចការទាំងអស់ ឡើងខ្ពស់ត្រដួច
ក្នុងការផដែក រ៉ែកញែកចង្កួច ក្រសោបក្របួច
ឲ្យជាប់គុនបាន ។
ហេតុនោះបានជា ភាសិតថា អ្នកប្រាជ្ញបុរាណ
ហាមចងទុកមក យកតាមលំអាន ប្រាជ្ញមុខថាមាន
សម្ដីជាឯក ។
ឯលេខនព្វន្ត ប្រើការគិតគន់ ចំនួនបែក ៗ
លេខបូកលេខគុណ លេខសងលេខចែក មិនទុកជាឯក
ទុកថាជាគោ ។
ប៉ុន្តែសព្វថ្ងៃ ខ្ពន់ឡើងថ្ងៃ គណិតសេដ្ឋ
សម្រាប់ប្រើប្រាស់ គន់គិតកករក គន់ទិតគាំងត
គណិតគាចប្រាប់ ។
អ្នករៀនវិទ្យា នេះទាំងអស់គ្នា បើមិនប្រញាប់
ខំប្រឹងសិក្សា វិទ្យានេះគាប់ ប្រឡងប្រុងជាប់
ត្រឡប់ជាយែក ។

លុះតែចិត្តចាំ សិក្សាថែមថ្ងៃ ពិនិត្យសង្កេត
ប្រឡងក្រោយទៀត ទើបបានខានវែត ចិត្តខ្វល់ត្រដេត
អក្សរស្ទួនពេកគេហៅ ៗ

អក្សរជាត្រី សរសេរសេចក្តី កើតជាអរោ
ប្រើកុំផែលអស់ ហាក់ស្រស់សន្ធោ ចេញមុខគ្នោ ។
ជាត្រៃវិជ្ជា ៗ

វិជ្ជាបវរ បើគតអក្សរ បានអ្នកកត់ត្រា
ហេតុនេះលោកហៅ ជាជាសាស្ត្រា ចំណេះនានា
អក្សរជាមេ ៗ

បើតាមន័យនេះ ឃើញជាចំណេះ ដែលប្រាជ្ញជ្រះរេ
សរសេរកត់ត្រា ក្រែងមាត់ទទេ យូរទៅធ្វេសធ្វេ
ខំខ្វះក្បួនសូត្របង់ ៗ

គួរលើកអក្សរ ជាគ្រូបវរ នេះឲ្យសមគ្គ
ឲ្យឡើងថ្នាក់ឯក បុះតាទើបត្រង់ ត្រូវតាមចម្រង់
ដែលគួរសង្កេត ៗ

ប៉ុន្តែអ្នកក បានជាចាស់ចា សម្រាប់តែគត់
កុំឲ្យសោយ រលាយបែបបទ ទើបចាស់កំណត
ឲ្យជាត្រីវិញ ៗ

អ្នករៀនវិជ្ជា គួរពិចារណា កុំមានក្តីមេញ
រៀនឯករៀនទោ រៀនត្រីនេះម៉េញ ដល់គួរខ្ញេញ
កាព្យនេះឲ្យចាំ ៗ

គិតយូរៗ ពេក កុំតែសៅដៅ ទើបអាចចំណាំ
បើយល់ន័យហើយ ត្រូវនឹកឲ្យចាំ ចាំស្ទាត់អាចនាំ
ឲ្យលែងខ្វែងខ្វល់ ៗ

វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃព្រហស្បតិ៍ ទី ២៥ កក្កដា ២៥១២/១៩៦៨

សម្តេចព្រះសង្ឃរាជ ជ.ណ. ជោតញ្ញាណោ

ប.អ.ស.-អ.ម.វ.

# អត្តសម្មុដ្ឋាន

ការតាំងខ្លួនដោយខ្លួនឯងឲ្យរួចផុតពីការទ័លក្រ

អប្បកោបិ មេធាវី ឋានេន វិចក្ខណោ
សមុដ្ឋាបេតិ អត្តានំ អណុំ អគ្គឹវ សន្ធមំ

មេធាវី គឺអ្នកប្រាជ្ញខាងការប្រើប្រាជ្ញាខ្មុះខ្មាយ ជាអ្នកចេះពិចារ-ណារិះរៀលលក អាចលើកតម្កើងខ្លួនបាន ដោយទ្រព្យជាដើមតិច

សូម្បីបន្តិចបន្តួចស្តួចស្តើងសោះទេ ដូចគេផ្លុំបង្កាត់រងើកភ្លើងតូចមួយឲ្យ
កាត់នេះសន្ធោសន្ធៅឡើងបាន ដូច្នោះដែរ ។

## ពាក្យកាព្យឲ្យងាយចាំ

### បទកាកគតិ

វរមេធាវី ប្រាជ្ញប្រុះពេញទី ឈ្លាសវៃប្រាកដ
ពេះសានសមៀ ទ្រព្យដោយហ្មត់ចត់ ព្យាយាមទៀងទាត់
គាំងខ្លួនឯងបាន ។
ដើមទុនតិចតួច ពេះពៃលផ្តើមផ្តួច ឲ្យកើតឧបាន
ពីមុនក្រសោះ ផ្ទោះឡើងជាមាន មិនយូរប៉ុន្មាន
បានជាសេដ្ឋី ។
រងើកភ្លើងតូច ដែលរះប្រៀបប្រដូច ទីងក្លែកមាន់ព្រៃ
គេផ្លុំបង្កាត់ ដោយការឃ្មាតខ្មី នេះភ្លើងដូចថ្ងៃ
អាស្រ័យព្យាយាម ។
រកស៊ុតក៏ ។ ដូចកល់ដំណក់ ទឹកត្នោតស្រក់តាម
សកាក់ពាស្រក់ មិនញាប់ក្តាម ។ យូរទៅបានខនម
ថារពេញបំពង់ ។

កុំចង់មានឆាប់ ប្រញាប់ប្រញាប់ ប្រឹងហួសមាឌខ្លួន
ដល់ខ្ចីបុរបគេ ចាយអស់ឥតគន់ ចាល់តែលិចលង់
ដើបក្បាលពុំរួច ។

ដំបូកតូចធំ កើតពីសន្សំ កណ្ដៀរពោធ្លួច
រាស្រះគ្មានទូន ទៀនខ្ពស់ក្រដូច ពុំមែនព្រោះលួច
ទេព្រោះសន្សំ ។

ពុំនោះដូចឃ្មុំ ធ្វើផ្ទុកតូចធំ រាស្រះគ្នាខំ
ហើរត្រឹបកេសរ ផ្កាណាយប្រទ្យំ ប្រមូលមកផ្ញុំ
ធ្វើបានជាផ្ចិត ។

គួរជនចំលង សង្កេតសម្គាល់ យកជាគំនិត
ធ្វើការរកស៊ី ត្រូវខំប្រឹងគិត កុំខ្ចល់គំនិត
យោចល់ទៀយហោង ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ ថ្ងៃសុក្រ ទី ២៦ កក្កដា ព.ស. ២៥១២ គ.ស.១៩៦៨

សម្ដេចព្រះសង្ឃរាជ ជ.ណ. ជោតញ្ញាណោ

ប.អ.ស. អ.ម.រ.

## ពុទ្ធភាសិត និងបុរាណភាសិត

បន្ទាមុតយកបន្ទាដោះ, សេះដាច់ជិះសេះពាយ

ពុទ្ធភាសិតថា: កណ្ដកេន កណ្ដកំ ឧទ្ធរណំ “;ជាបន្ទាដោយ

បន្ទា" បុកណកាសិតថា សេះដាច់ជិះសេះតាម "សេះមួយដាញបណ្តាច់ខ្សែបំណាន់ហោលបាត់ទៅ ត្រូវជិះមួយដៀងតាម ទើបទាន់សេះដែលដាច់នោះ" ។ អ្នកប្រាជ្ញបុកណយកសុភាសិតទាំងពីរមករួមបញ្ចូលគ្នាដូចគតូបទខាងលើ ។ ភាសិតទាំងពីរមានអត្ថន័យផ្ទៀងគ្នាខ្វះបន្តិចបន្តួច ប្រើខាងផ្លូវធម៌ក៏បាន ខាងផ្លូវលោកក៏បាន ។

ខាងផ្លូវធម៌ដូចជា យករូបដោះរូប គឺអារម្មណ៍ឬគំនិតរបស់បុថុជ្ជនដែលយល់ថា រូបប្រុសស្រីស្អាតល្អគួរស្រឡាញ់ ត្រូវប្រើគំនិតផ្ទៀងតាមការណ៍ពិតថា រូបកងសព្វាង្គកាយនៃប្រុសស្រី សុទ្ធតែជាបដិកូលគួរខ្ពើមគួរឆ្អែម ដៀតតាមការណ៍ពិត រូបកាយទាំងស្រុងនៃប្រុសស្រីទាំងខាងក្រៅទាំងខាងក្នុង សុទ្ធតែគគ្រក់ស្មោកគ្រោក នោះញើសក្អែលនិងទឹកមាត់ស្មេស្មកហាកសំបោរ ដែលហៀរហូរចុះចេញតាមរន្ធទ្វារនៃខ្លួនក៏ពុំគាប់ចិត្តលេះបញ្ចៀសឡើយ គឺខ្លួនខ្ពើមឆ្អែមខ្លួនឯង ចាំបាច់បើរូបគេដទៃក្រៅពីខ្លួន តើខ្លួនមិនខ្ពើមឆ្អែមទេឬ ? គំនិតនេះជាបន្ទាដោះបន្ទា គឺ[illegible] គឺ[illegible]

[illegible]នោះ ទើបសុភាសិតនោះថា បន្ទាមុតយកបន្ទាដោះ ។

ខាងផ្លូវលោកដូចជា ការណ៍[illegible] ។ ដែលបង្កើតគ្រោះដល់អ្នក[illegible] [illegible] ដោយមុខការរបស់[illegible]

[illegible]ការណ៍ជួកម្មជាដើម ឲ្យលួតលាស់ចម្រើនមិនរួច គឺផ្ទើរផ្ទាលមិនរួចព្រោះ

អាណានិគមនេះបន្សល់ទុកឲ្យនៅប្រទេសយើងគឺ ការសង្កត់បែបនេះហៅ ថា បញ្ហាមុខ ត្រូវយកបញ្ហាដោះបញ្ហានេះចេញ តើដោះបែបណា ? ត្រូវយកបញ្ហាណាដោះ ? ត្រូវយកការចេះដឹងជាបញ្ហាសម្រាប់ដោះ គឺជនអ្នកប្រទេសនេះ ត្រូវរៀនអក្សរនិងភាសានៃអាណានិគមនោះ ។ ឲ្យបានចេះស្ទាត់ជំនាញ ទាំងត្រូវខំប្រឹងរៀនប្រឹងសង្កេតឲ្យយល់ជាក់នូវមុខការរបរមានពាណិជ្ជកម្មជាដើមនោះផង បើពុំអាចចេះទាំងអស់បណ្ដាញទាំងប្រទេសរបស់ខ្លួន គឺបុរសស្ត្រីយុវជនយុវតីត្រូវខំប្រឹងរៀនរកវិជ្ជាឲ្យបានចេះច្រើននាក់ឡើង ហើយធ្វើការពិសោធន៍ព្រមទាំងជួយយោងគ្នាផងទៀត គឺជួយពន្យល់ណែនាំឲ្យចេះតាមការណ៍ជាប់តិចច្រើនតូចធំ និយមតាមគ្នាឡើង កុំស្តាប់មិត្ត កុំស្អប់សង្គម ប្រុសមាតម ត្រូវយកតម្រាប់រុក្ខជាតិលតាជាតិ ដែលដុះក្នុងព្រៃ វារឡើងយានឈើតូច លតាជាតិលូតវែងតាមដើមឈើ យើងនេះហៅថាយោងគ្នា ។ ការយោងគ្នាបែបនេះពុំមែនត្រឹមតែលូតលាស់ខ្ពស់ស្រងាំប៉ុណ្ណោះឡើយ ថែមទាំងនាំឲ្យត្រង់ផងទៀត ។ កាលណាយើងនេះហៅថាបញ្ហាមុខយកបញ្ហាដោះ គឺយកការរៀនអក្សរ និងភាសាជាតិ អាណានិគមន៍ ដែលសង្កត់នោះជាបញ្ហាដោះ គឺការសង្កត់មុខការរបរមានពាណិជ្ជកម្មជាដើមនោះបាន បើយកវត្ថុមូលត្រូវមែលដោះ ប្រុងកដ៏ជាដោះកុំកើតឡើយ ។ ឯវត្ថុមូលត្រូវមែលនោះ គឺការខម្រេចអំពើនាំគ្នាតូចតិច បិទគិតប្រឹងរៀនអក្សរ និងភាសាជាតិ

អណិកជនដែលប្រើកលល្បិចសង្កត់គំនុំឯង ។ គួរប្រៀបឲ្យជាកញ្ចាស់ថា នេះឯងហើយដែលថាបន្លាមុតយកបន្លាដោះ ។ បើអស់លោកអ្នកនឹងគេគិតពិចារណាឲ្យជិតដល់ក៏គង់នឹងអាចយល់បាន ។

ឯសេះដាច់ជិះសេះតាមនោះ មានអត្ថន័យស្រដៀងគ្នានឹងបន្តិចបន្តួចពីបន្លាមុតយកបន្លាដោះ ដូចជាការចំរើនរៀនចេះទន្ទេញដេញតាមការភ្លេចភ្លាំងម៉ែង ចេះចាំស្ទាត់ជំនាញ ទន្ទេញរំលឹកឡើងចាំរត់មាត់ស្ទាត់ឡើងវិញឬដូចអ្នកធ្លាប់បានសមាធិធម៌ហើយ តែរជាធ្លាក់ចុះសាបសូន្យខានបានទៅវិញ គឺចំរើនយ៉ាងម៉ឺងម៉ាត់ប្រតិបត្តិឲ្យសមាធិធម៌នោះកើតមានឡើងទៀត ដូចពីមុន យ៉ាងនេះហៅថាសេះដាច់ជិះសេះតាម ខាងផ្លូវធម៌ ។ ឯផ្លូវលោកដូចជាយកទ្រព្យជាទុនផ្តល់ចំណេញដេញតាមខាតបង់ ឲ្យមានចំណេញឡើងវិញដូចបុរាណភាសិតមួយយ៉ាងផ្សេងទៀតថា គស់ពៅមិនស្តាយដែក ។ល។ ទាំងផ្លូវធម៌ទាំងផ្លូវលោក បើរកប្រតិបត្តិបែបនេះ ហៅថាសេះដាច់ជិះសេះតាម ។ គួរអស់លោកអ្នកឧបាយកោសលពិចារណាឲ្យបានជិតដល់ហេតុចក់ឲ្យសុភាសិតៈនេះមានអត្ថន័យទូលំទូលាយជាងនេះទៅទៀតផងចុះ ។

## ពាក្យកាព្យឱ្យងាយចាំ

### ពាក្យ ៧

បន្លាមុតត្រូវយកបន្លាដោះ សេះដាច់បោលស្ទុះជិះសេះតាម
ចលក្រត្រូវប្រើក្តីព្យាយាម ដោះភ្នាមទុកស្មើដូចបន្លា ។

បើអាណិកជនណាសង្កត់ ដោយបង្ខំក្លៃកៃបែបណា
ត្រូវរៀនអក្សរនិងភាសា នៃអាណិកជននោះឲ្យចេះ ។
ខាងមុខដំណេញតូចនិងធំ និយមយកការមានចំណេះ
ទុកដូចជាបន្ទាប់ដូចសេះ សម្រាប់ដោះដៃដោយសេរី ។
យកឈើក្រមែលដោះបន្ទា ប្តូរឡើងជិះគោជិះក្របី
ប៉ុលលោកអន្ទ្រាមហុយតែដី ឥតប៉ះជាតាខបុរាណនោះ ។
ត្រូវរៀនបែបបទពាណិជផង កុំរកស៊ីផ្សងព្រេងឥតចេះ
របរធ្វើតែកូនរបេះ អ្នកឥតចំណេះច្រើនលិចលង់ ។
មុខការរបរនេះអ្នកឈ្មួញ ផុតក្តីវិនាសច្រើនមានទ្រព្យ
ពីព្រោះការជួញដូរផ្តក់ផ្តង់ ជិះជាន់អ្នកល្ងង់ឲ្យផងនាប ។
គេក្រោកឈរដើរតបផាប់ ចាប់ផ្តួលសង្កត់ឯងឲ្យក្រាប
ដើបក្បាលមិនរួចក្រោកទ្រុំក្រាប ស៊ីកអាក់អាបម្សៅបភាពខ្ទង់ខ្សោយ ។
ហេតុនេះត្រូវប្រឹងរៀនវិជ្ជា អក្សរភាសាគេកុំខ្វាយ
រៀនពាណិជ្ជកម្មកុំបណ្តោយ ឲ្យអាណិកជនសង្កត់ជាប់ ។
កុំតែប្រព្រឹត្តតាមបែបនេះ ទើបគេមិនជិះជាន់តែងជាប់
អ្នកយ៉ាងកុំការតែទម្លាប់ ជាប់កុខមិនកើតទ្រូវរងាំ ។
ត្រូវរៀនអក្សរនិងភាសា នៃអាណិកជនឲ្យវៃវង់
កុំតែយ៉ាងនេះទើបអ្នកនាង រំលងដោះយកបន្ទាបាន ។

ត្រូវទុកវិទ្យាជាបន្លា ដោះយកបន្លាដែលមុតប្រាក
ឬទុកដូចស្រះមានកែវគាន់ ដ៏បានពន្លឺតាន់ស្រះជាប់ ៗ
ខ្ញុំតែងកាព្យនេះគ្រាន់អ្នកអាន បង់អានកំសាន្តដោយចាំបាច់
គួរអានម្តង ៗ ហើយសម្រេច សម្រួលអត្ថន័យតាមគួរចុះ ៗ

វត្តឧណ្ណាលោម ក្រុងភ្នំពេញ ថ្ងៃសៅរ៍ ទី ២៧ កក្កដា ២៥១២/១៩៦៨

សម្តេចព្រះសង្ឃរាជ ជ.ណ. ជោតញ្ញាណោ

ប.អ.ស-អ.ម.រ.

## កតញ្ញូតា

ភាពនៃអ្នកដឹងគុណ

បទកាកគតិ

កតញ្ញូតា មានន័យប្រាកដ ជនកតញ្ញូ
ត្រូវតែប្រព្រឹត្ត តាមបែបគំរូ ដែលព្រះជាគ្រូ
ប្រាប់ឲ្យគប់គុណ ៗ
មាតាបិតា គ្រូឧបជ្ឈាយ៍ សុទ្ធតែស្រែបុណ្យ
ជនណាក៏ដោយ ដែលគេមានគុណ ក៏ជាស្រែបុណ្យ
ដែលត្រូវសាបព្រោះ ៗ

បណ្តាំពូជពុណ្យ　　កូនស្រីជាគុណ　　កុំឲ្យមានមោះ
បុណ្យខឹងកើតកើន　　ចម្រើនឥតខ្ចោះ　　ត្រូវមានចិត្តស្មោះ
　　កុំលុបគុណពោល ។

កុំគ្រាន់តែថា　　មាតាបិតា　　មានគុណជាគោល
មាតាថាត្រូវតប　　គុណកុំចោល ។　　ធ្វើដៃស្រាល ។
　　សោះតែគេថា ។

ជនអ្នកតបគុណ　　ព្រះពុទ្ធមានបុណ្យ　　ទ្រង់ត្រាស់ទេសនា
សរសើរញឹកញយ　　មានក្នុងសាស្ត្រា　　គម្ពីរដីកា
　　គួរយើងចងចាំ ។

ចេះចាំហើយធ្វើ　　ដោយចិត្តអើពើ　　ឲ្យស៊ប់ឲ្យស៊ាំ
ឲ្យស្គាល់ទឹងគុណ　　គុណតែងតែចាំ　　កុំមែនខ្វេខ្វាំ
　　ព្រោះតបគុណទេ ។

ជនមានចិត្តខ្លាយ　　ច្រើនតែភ្លេសភ្លាយ　　រមិលគុណគេ
កាន់ព្រេងសំណាង　　ពីក្នុងបុព្វ　　ប្រហែសធ្វេសធ្វើ
　　ព្រងើយកន្តើយ ។

អ្នកប្រាជ្ញប្រាប់ថា　　ជនប្រុសស្រីណា　　លុបគុណពោលហើយ
ជនប្រុសស្រីនោះ　　ពុំមានសុខស្បើយ　　យូរប៉ុន្មានឡើយ
　　រែងតែធ្លាក់ខ្លួន ។

កាលដុះខសុះ　ស្រាប់តែមានទុក្ខ　ចេញមុខជួន ៗ
ឲ្យផលកំណាច　ឃោរឃៅតែតស៊ូន　ទោសមកពីខ្លួន
មើលគុណគេ ៗ

ហេតុតែគេចិញ　ព្រោះខ្លួនរំពឹង　អាងបុណ្យបុព្វ
ទោសបច្ចុប្បន្ន　ដុះជាន់ឥតល្ហៃ　ភព្វព្រេងបុព្វ
បើមានគំផ្លាក ៗ

ទោសមើលគុណ　កក់ដ៏មុខបុណ្យ　ព្រេងឲ្យបម្រាក
បង្អង់ឈប់សិន　ផុះបច្ចុរផ្ទាក　ឲ្យផលឥតស្រាក
ព្រោះផ្ទុនទុកាស ៗ

បុណ្យផុះចាស់ចំ　តែងតែវៃព　កុំមេមផ្ដេសផ្ដាស
កាលខានខ្ទាះ　ត្រូវពេលសស្រាស　ហាក់ដូចប្រកាស
ប្រាប់ជាត្រអេញ ៗ

ចេញមុខផ្ដល់ផល　សុខទុក្ខឲ្យដល់　ជនដែលកកាញ
កបងបង្កើត　កំណើតជាអញ　អញជាសម្លាញ់
ត្រូវអញឲ្យផល ៗ

រីបុណ្យឬបាប　ដែលមានសភាព　ជាកម្មតែងផ្ដល់
សុខទុក្ខឲ្យជន　អ្នកធ្វើឲ្យដល់　ខួរក្ដីសល់រៀ
ឬក្ដីសុខសាន្ត ៗ

បុះបកែងកាំង បុណ្យឲ្យនៅគាំង ផ្កាសិនពុំបាន
បញ្ចេញមុខឲ្យផល ជាសុខសម្រាន្ត ស្អកធ្វើតែងបាន
ទទួលរងទុក្ខ ។

បុណ្យក៏កក់កាំង បាចឲ្យនៅគាំង ផ្កាពុំពេញមុខ
ព្រោះមានឱកាស បុណ្យផ្តល់ក្តីសុខ សុខតែមានមុខ
ទំនៃពគ្នា ។

ហេតុនោះគួរផង កុំនៅទម្រន់ កុំគិតខ្ជិល
គួរកសាងបុណ្យ មានគុណមហិមា ទើបបានឈ្មោះថា
អ្នកស្រឡាញ់ខ្លួន ។

# អំពើអាក្រក់ចក់ចិត្តឲ្យងាយធ្វើ

សុករានិ អសាធូនិ អត្តនោ អហិតានិ ច
យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ។

អសាធុកម្ម គឺអំពើរបស់អសប្បុរសទាំងឡាយ ជាអំពើឥតផលប្រយោជន៍ដល់ខ្លួន នេះឯងហើយ ឯអំពើ... កម្មរបស់សប្បុរស ដែលជាអំពើផ្តល់ផលប្រយោជន៍ (ដល់ខ្លួន) អំពើនោះឯង គេពិបាកធ្វើណាស់ គឺមិនងាយនឹងកើតទេ ។

# ពាក្យកាព្យឲ្យងាយចាំ

## ពាក្យ ៩

កម្មអាក្រក់ តែងទាញធ្លាក់ ចិត្តជនផង(១)
ឲ្យគន់ទ្វេ ផុតប្រយោជន៍ របស់ខ្លួន
គេពុំខ្លាច គេអាចហ៊ាន ធ្វើផ្តួន ។
ទោះបីខ្លួន បានវិនាស ក៏ពុំកង ។
រីកម្មណា ជាសាធុ ល្អប្រពៃ
អាចកែប្រែ អាចនាំខ្លួន ឲ្យចៀសវាង
ផុតពាក់ទោស ឥតខុស ក៏អ្នកនាង
ខ្ទះច្រើនយ៉ាង កម្របាន ធ្វើកម្មនោះ ។

## ព្រះបរមពុទ្ធោវាទមួយយ៉ាងថា

សុករំ សាធុនា សាធុ សាធុ បាបេន ទុក្ករំ
បាបំ បាបេន សុករំ អាយរិយេហិ ទុក្ករំ ។

សាធុកម្ម គឺអំពើជាកុសល ជនជាសប្បុរសងាយធ្វើកើត, សាធុ-កម្ម ជនចិត្តបាបពិបាកធ្វើណាស់ គឺមិនងាយនឹងធ្វើកើតះទេ , អំពើបាប ជនចិត្តបាបងាយធ្វើកើត, អំពើបាប អរិយជន គឺជនអ្នកប្រសើរដោយ

១- តាមការ...ណ ពាក្យ ៩ គេសរសេរដាច់ឃ្លា តែនេះ សម្ដេចព្រះវន្ដ... ព្រះហស្ត ឥកឃ្លា ៤ ១ ម៉ាត់ យើងក៏គោរពតាម ទំនងជា...ងាយស្ដាប់ជាឲ្យងាយអាន ។

សីលធម៌ ពិបាកធ្វើណាស់ គឺមិនងាយនឹងហ៊ានប្រថុយធ្វើរឿយ ៗ

## ពាក្យកាព្យឱ្យងាយចាំ

ពាក្យ ៩

សាធុជន ស្រឡាញ់បុណ្យ ងាយធ្វើបុណ្យ
ឯទុជ្ជន ចិត្តរំរន់ ធ្វើពុំកើត
បើបាបវិញ គេងាយធ្វើ ពុំញញើត
អ្នកប្រាជ្ញដើត ធ្វើពុំកើត ព្រោះខ្ពើមបាប ៗ

## ប្រមាទ និង មិនប្រមាទ

អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថាមតា ៗ

សេចក្តីមិនប្រមាទ គឺការមិនធ្វេសស្មារតី ជាផ្លូវនៃអមតនិព្វាន, សេចក្តីប្រមាទ គឺការធ្វេសស្មារតី ជាផ្លូវនៃមច្ចុ គឺការស្លាប់កើត-កើតស្លាប់ ជនទាំងឡាយណាមិនប្រមាទ ជនទាំងនោះមានឈ្មោះថាមិនស្លាប់ ជនទាំងឡាយណាប្រមាទ ជនទាំងនោះឈ្មោះថាដូចជាស្លាប់ស្រេចទៅហើយ ៗ

# ពាក្យកាព្យឱ្យងាយចាំ

## បទកាកគតិ

វិក្តិប្រយ័ត្ន  មិនឲ្យភ្លាំងភ្លាត់  វិបត្តិស្មារតី
ជាផ្លូវអម្រឹត  វិសុទ្ធឥតភ័យ  ឥតទុក្ខសោកអ្វី
កើតមានទៀតឡើយ ។

វិក្តិប្រហែស  ស្មារតីភ្លេចភ្លេស  គំនិតគោះតើយ
ជាផ្លូវមច្ចុ  ស្លាប់កើតឥតស្បើយ  ឥតគោះឥតត្រើយ
វិលកើតវិលស្លាប់ ។

ខ្លួនអ្នកណា  មានចិត្តភ្លៀវភ្លា  ប្រញឹកប្រញាប់
ខំប្រឹងប្រព្រឹត្ត  ពិតតាមធម៌ច្បាប់  អ្នកនោះទោះស្លាប់
ហើយដូចនៅរស់ ។

ខ្លួនអ្នកណា  អាប់ឥតប្រាជ្ញា  ប្រមាទស្រស់ៗ
ភ្លេចភ្លាត់ស្មារតី  កល់ថ្ងៃចាំងអស់  អ្នកនោះនៅរស់
ដោយដកដង្ហើម ។

ព្រះពុទ្ធទ្រង់ប្រាប់  ថាដូចជាស្លាប់  ស្រេចហើយគួរខ្ពើម
ទោះបីនៅរស់  ដោយសារដង្ហើម  អ្នកប្រាជ្ញលោកផ្តើម
ស្មើរក្អួតចង្អោរ ។

ជនផងគួរគិត  គួរផ្ចិតគំនិត  គួរគោតគួរគោរ
គួរគេចចៀសពាន  គួរពន់គួរស្ងោរ  រម្ងាប់ចិត្តចោរ
លួចប្ញុនកុសល ។
យើងជាសាមញ្ញ  នៅមានក្តីត្នាំញ់  ត្នាខឹងរចល់
ក៏ពិតមែនហើយ  ប៉ុន្តែកុំខ្វល់  គួរប្រឹងតម្កល់
ចិត្តកុំប្រមាទ ។
គួរប្រុងប្រយ័ត្ន  ស្មារតីភ្ញាក់  កុំគេចទាក់ទ
អ្នកប្រាជ្ញទាំងឡាយ  មានព្រះជាអាទិ៍  កុំបីឃ្លៀងឃ្លាត
ពាក្យធម៌សុចរិត ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអាទិត្យ ២៣ កក្កដា ២៥១២/១៩៦៨

សម្តេចព្រះសង្ឃរាជ ជ.ណា ជោតញ្ញាណោ

ប.ស.ស—ស.ម.វ.

# គុណរសាភកថា

ដោយ ជា-ប៊ូ

បទកាកគតិ

យើងខ្ញុំបង្គំ ក្រួញក្រាបប្រណម្យ ក្រោមព្រះបាទា
នៃអង្គសម្ដេច ព្រះសង្ឃរាជ អគ្គមេធា
មហាវីរៈ ។
កំពូលអ្នកប្រាជ្ញ ព្រះទ័យអង្គអាច វាងវៃប្រត្យក្ស
តាំងអក្សរសាស្ត្រ តាំងពុទ្ធចក្រ ទ្រង់ជាឯកអគ្គ(១)
អ្នកបដិវត្ត ។
រៀបរៀងធម៌អាថ៌ វិន័យសិក្ខា ដែលមានក្បាំងក្បាត់
ឲ្យបានត្រឹមត្រូវ ត្រង់ដូចបន្ទាត់ ព្រះសង្ឃរល់វត្ត
ប្រតិបត្តិសិក្សា ។
អក្សរសាស្ត្រជាតិ ព្រះអង្គថ្មីឃ្លាត សង្កាត់បេធា
សើរើរៀបរៀង ផ្សៀងផ្ទាត់ភាសា ឲ្យមានលក្ខណា
ថ្លៃថ្លាពិសី ។

---

១- អានថាឯកអាក់ ។

ទោះមានឧបសគ្គ ដើមពោះគ្រោះថ្នាក់ បង្អាក់ម្តងក្តី
ព្រះអង្គឥតកក ពុះពារឃាតក្ខ ប្រយោជន៍ដើម្បី
សិរីខេមក ៗ

ប្រកបព្រះគុណ គុណគាប់មហាជន ជូនឥតឧបមា
តាំងផែនការជាតិ តាំងផ្នែកសាសនា ទ្រង់ព្រះឧស្សាហ៍
ពុំមានរសាយ ៗ

ទោះទ្រង់ជក តែត្រង់ការងារ ពុំមានជិនណាយ
ឥតទ្រង់តម្រិះ ដល់ព្រះអង្គកាយ ព្រះទ័យខ្វល់ខ្វាយ
និងជាតិសាសនា ៗ

កិច្ចការឧត្តម ដែលទ្រង់ខិតខំ ប្រើព្រះប្រាជ្ញា
បំពេញទុកឲ្យ អ្នកក្រោយសិក្សា មានច្រើនប្រការ
ហួសនឹងអធិប្បាយ ៗ

ព្រះទ័យមេត្តា អាសូរករុណា មនុស្សសត្វទាំងឡាយ
ស្មោះស្មើទូទៅ ទោះនៅជិតឆ្ងាយ គ្រប់ក្រុមនិកាយ
ស្រស់ស្រាយកក់តាក់ ៗ

ឥឡូវព្រះអង្គ ប្រសើរសើលទ្រង់ ឯកអង្គអគ្គ:
ទ្រង់ទិវង្គត រលត់ជន្មជាក់ ខានយល់ព្រះភក្ត្រ
ព្រះអង្គទៀតឡើយ ៗ

ពីថ្ងៃនេះទៅ　យើងខ្ញុំរស់នៅ　សោកសៅឥតស្បើយ
អាឡោះអាល័យ　ម្ចាស់ខ្ញុំអើយ(១)　ពីនេះទៅហើយ
　ខានយល់ភក្ត្រា　។
ខានត្រងខានត្រាប់　ខានឮខានស្តាប់　ព្រះពជន្ការ
ឮតែសូរសៀង　ស័ព្ទព្រះវាចា　តាមឃោសនាការ
　ពីអក្សរសាស្ត្រ　។
ដែលទ្រង់បរិយាយ　ពន្យល់ដោះស្រាយ　ដោយក្តីវៃឆ្លាស
រកញែកហេតុផល　ផ្តល់នៃប្រកាស　ដោយព្រះតម្រាស់
　ជាក់ច្បាស់ក្បោះក្បាយ　។
ព្រះកាយបាត់ទៅ　ព្រះកេរ្តិ៍គង់នៅ　ឲ្យយើងតាំងឡាយ
[illegible]ស្ត្រសិក្សា　ក្តីថាពណ្ណរាយ　នឹកឡើងសែនស្តាយ
　ស្តាយឥតឧបមា　។
[illegible]ម្ចាស់ថ្លៃ　យើងខ្ញុំអាល័យ　អាឡោះសោកា
ខ្ទេចក្តុក[illegible]　ស្រយុតចិន្តា　ក្តួលក្តៅខ្លោចផ្សា
　ពុំមានស្រាកស្បើយ　។

---

១- អានថា ខ្ញុំម៉ើយ ។

## ជូនដំណឹង

ដោយកាលទេសៈសព្វថ្ងៃ ការបោះពុម្ពត្រូវលំបាកដោយសារក្រដាសឡើងថ្លៃ ហើយដោយបំណងយើង មិនចង់ឱ្យទស្សនាវដ្ដីនេះឡើងថ្លៃតាមក្រដាសនោះ គណៈកម្មការបោះពុម្ពទស្សនាវដ្ដី ក៏សម្រេច ទុកនៅតម្លៃជាវដែលដូចឆ្នាំមុន គឺ ១ ក្បាល២០ រៀល មួយឆ្នាំ ១២ ក្បាល ២៣០ រៀល ប៉ុន្តែយើងត្រូវបន្ថយទំព័រតិចជាងឆ្នាំមុនបន្តិច ។

ហេតុនេះ សូមលោក-អ្នកអាន មេត្តាអភ័យទោស តាមកាលទេសៈនេះឱ្យទាន ។

ពុទ្ធសាសនបណ្ឌិត្យ

២

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

INSTITUT-BOUDDHIQUE

ឆ្នាំទី ៤៣ ខែ កុម្ភៈ

ព.ស. ២៥១៤ គ.ស. ១៩៧១

-ភ្នំពេញ-




# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : លាង ហាប់អាន

និពន្ធនាយក - អ្នករៀបចំ : លី ធាមតេង

គណៈកម្មការនិពន្ធ :

ព្រះពោធិវង្ស សួរ-ហាយ

លោក ឌិត-តាម អ្នកស្រី ពេជ-សល់

# បញ្ជីរឿង

| អត្ថបទ | ទំព័រ |
|---|---|


## ១– ផ្នែកសាសនា

១– ជីវប្រវត្តិ សម្ដេចព្រះសង្ឃរាជ ជ.ណា. ជោតញ្ញាណោ ទ្រង់រៀបរៀង ៩៧

២– ពាក្យថាធម៌គឺអ្វី ? ព្រះពោធិវង្ស ហួរ-ហាយ រៀបរៀង . . ១០៩

## ២– ផ្នែកអក្សរសាស្ត្រ

៣– វិចារណកថា : លោក ឆេង-ផុន រៀបរៀង . . . . ១១៨

៤– រឿងសាមកុក លោក ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . ១២៦

៥– ល្បងសិក្សាអក្សរសាស្ត្រខ្មែរ លោក លាង ហ័បអាន រៀបរៀង . ១៤៤

៦– រឿងរាជកុល ចម្លងពិនិត្យផ្ទៀងផ្ទាត់ដោយ លោក ឌឹក គាម . . ១៥៥

៧– ក្រមុំព្រហ្មចារី (កំណាព្យ) លោក ផល-ទិត រៀបរៀង . . . ១៧១

## ៣– ផ្នែកកំណត់-ប្រវត្តិការណ៍

៨– សារាចរ ស្ដីពីការកែប្រែធម៌ អាកាសង្ហា . . . . . ១៧៥

៩– សមាជពុទ្ធបរិស័ទនៅសាលចតុមុខ . . . . . . ១៧៧


## តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ។

អាណត្តិសូមដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

## ផ្នែកសាសនា

# ជីវប្បជីវ

## ការឱ្យពរគ្នាទៅវិញទៅមក នៅវេលាដែលជនម្នាក់កណ្ដាស់ឆែតឡើង, ជនឯទៀតឱ្យពរថា "ចូរមានអាយុវែង"

---

មានប្រពៃណីតាំងពីក្នុងបុរាណសម័យព្រេងនាយរៀងមកថា កាលបើជនម្នាក់កណ្ដាស់ឆែតឡើង, ជនអ្នកជិតគ្នានោះ តែងឲ្យពរទៅអ្នកកណ្ដាស់នោះថា "ស្បើយ" ឬថា "មានអាយុវែង" អ្នកដែលកណ្ដាស់ ក៏ត្រូវឲ្យពរតបវិញ ដូចគេឲ្យពរមកខ្លួននោះដែរ នេះជាទម្លាប់របស់ខ្មែរ ។ ឯអ្នកជម្ពូទ្វីប (ឥណ្ឌា) មិនឲ្យពរថា "ស្បើយ" ទេ គេឲ្យពរថា "ចូរមានអាយុវែង" ឬថា "ចូរមានអាយុមួយរយ" ដូចកាលថា "ចូរមានអាយុមួយរយឆ្នាំ" ។

ក្នុងគម្ពីរជាតក ទុកនិបាត ត្រង់គគ្គជាតក មានទំនងថា: ជីវ វស្សសតំ គគ្គាតិ ឥទំ សត្ថា ជេតវន-សមីបេ បសេនទិកោសលរញ្ញោ ការិតេ រាជការាមេ វិហរន្តោ អត្តនោ ខិបិតកំ អារព្ភ កថេសិ ព្រះបរម-សាស្ដាទ្រង់គង់នៅក្នុងរាជការាម ដែលព្រះបាទបសេនទិកោសលទ្រង់មានព្រះរាជសេចក្ដីឲ្យកសាងជិតគ្នានឹងវត្តជេតពន ទ្រង់សម្ដែងនូវគគ្គជាតក

បានបុព្វគាថាថា ជីវ វស្សសតំ គគ្គ នេះជាដើម ប្រារព្ធម្តោះ ការកណ្តាស់ដែតឡើងនៃព្រះអង្គ ។

ឯកស្មឹំ ហិ ទិវសេ ក្នុងសម័យថ្ងៃមួយ ព្រះបរមសាស្តា ទ្រង់គង់សម្តែងធម៌កណ្តាលពុទ្ធបរិស័ទទាំង ៤ គឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា នៈកដ៏ករោម ក្នុងជាព្រះអង្គកណ្តាស់ដែតឡើង ភិក្ខូ ជីវ-តុ ភន្តេ ជីវតុ សុគតោតិ-ឧច្ចាសទ្ទំ មហាសទ្ទំ អកំ-សុ ភិក្ខុទាំងឡាយស្រែកថ្វាយពរព្រះអង្គ ថា "សូមព្រះអង្គមានព្រះជន្ម!, សូមព្រះសុគតមានព្រះជន្ម!" ។ ព្រះភគវតទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ចុះបើគ្រាន់តែកណ្តាស់ ហើយមានអ្នកឲ្យពរបែបនេះ តើអ្នកកណ្តាស់នោះអាចរស់នៅយូរបាន ឬត្រូវគេចមិនផុតពីស្លាប់ដែរ ? ពួកភិក្ខុក្រាបទូល ថា នោ ហេតំ ភន្តេ! សូមទ្រង់ព្រះមេត្តាប្រោស ពុំមែនពិតដូចពរដែលឲ្យនោះទេ! ព្រះសម្ពុទ្ធទ្រង់បញ្ញត្ត ថា ន ភិក្ខវេ ខិបិតេ ជីវាតិ វត្តព្វំ យោ វទេយ្យ អាបត្តិ ទុក្កដស្ស ម្នាលភិក្ខុទាំងឡាយ កាលបើគេកណ្តាស់ ភិក្ខុមិនត្រូវពោលឲ្យពរគេថា "ចូររស់នៅ!" ទេ ភិក្ខុណាពោល ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

សម័យមួយ ក្រោយពីទ្រង់បញ្ញត្តនោះមក ពួកភិក្ខុខ្លះកណ្តាស់ដែតឡើង ពួកគ្រហស្ថគេឲ្យពរថា ជីវថ ភន្តេ! "មានជន្មានយុវែង!

ពានប្រោស" ។ ពួកភិក្ខុទាំងនោះនៅស្ងៀម មិនឲ្យពរគេទៅវិញ ។ គ្រហស្ថទាំងនោះគេនិយាយរិះគន់ថា សព្វថ្ងៃគ្រាន់តែឲ្យពរគេបទៅវិញ ប៉ុណ្ណឹងក៏ពួកភិក្ខុមិនចេះថាដែរ ។ លុះព្រះសព្វញ្ញូបានជ្រាបការណ៍នេះ ទើបព្រះអង្គទ្រង់អនុញ្ញាតដោយអនុលោមតាមប្រពៃណីនិយមថា គិហី ភិក្ខវេ មង្គលិកា, អនុជានាមិ ភិក្ខវេ គិហីនំ ជី-វថ ភន្តេតិ វុច្ចមានេន ចិរំ ជីវាតិ វត្តុំ ម្នាលភិក្ខុទាំងឡាយ ពួកគ្រហស្ថ គេតែងតែត្រូវការដោយមង្គល ម្នាលភិក្ខុទាំងឡាយ អញតថាគតអនុញ្ញាត កាលបើគ្រហស្ថគេឲ្យពរថា "សូមមានអាយុវែង ! ពានប្រោស" ដូចគេឲ្យពរមកខ្លួននោះចុះ ។

លំដាប់នោះ ពួកភិក្ខុក្រាបទូលសួរព្រះអង្គថា ភន្តេ ជីវបដិ-ជីវំ នាម កាលោ ឧប្បន្នោ? សូមទ្រង់ព្រះមេត្តាប្រោស, ចុះការឲ្យពរគេបទៅវិញ ថា "មានអាយុវែង!" នេះ តើកើតមានពីក្នុងកាលណាមក? ព្រះសព្វញ្ញូ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ជីវបដិជីវ ការឲ្យពរតបពរថា "សូមមានអាយុវែង!" នេះ ធ្លាប់មានតាំងពីក្នុងបុរ-ណកាលព្រេងនាយយូរអង្វែងហើយ ជាប់ជាប្រពៃណីរៀងរហូតមកដល់សម័យសព្វថ្ងៃនេះ ។ ពួកភិក្ខុ ក្រាបទូលអារាធនា ។ ព្រះអង្គទ្រង់សម្តែងអតីតនិទានថា :

ក្នុងអតីតកាលព្រេងនាយយូរអង្វែងណាស់ទៅហើយ, ព្រះបាទព្រហ្មទត្តសោយរាជ្យគ្រប់គ្រងក្រុងពារាណសីក្នុងកាសិករដ្ឋ, កាលណោះ

ពោធិសត្វអន្ទោសលោះយកកំណើតកើតក្នុងត្រកូលព្រាហ្មណ៍មួយ ក្នុងកសិការដ្ឋ នោះឯង ។ បិតារបស់ពោធិសត្វនោះជាអ្នកជំនួញ ។ កាលដែលពោធិសត្វជាបុត្រមានអាយុ ១៦ ឆ្នាំ ក្នុងសម័យមួយ, បិតាបាននាំទំនិញទៅលក់តាមនិគមជនបទជាមួយនឹងពោធិសត្វជាបុត្រ, បានទៅដល់ទ្វារក្រុងពារាណសី ក្នុងវេលាថ្ងៃល្ងាចទាប, ឈប់បម្រុងអាហារបរិភោគជិតជុះទ្វារក្រុងនោះ លុះរួចរាល់សព្វគ្រប់ហើយ ក៏សួរឆ្មាំទ្វាររកកន្លែងសម្នាក់ ឆ្មាំទ្វារប្រាប់ថា ឥតមានកន្លែងសម្រាប់ឲ្យអ្នកដំណើរសម្នាក់ទេ គេធ្លាប់តែស្នាក់តាមមានតាមបាន, មានសាលាមួយដែលនៅក្រៅក្រុង ប៉ុន្តែសាលានោះ មានយក្សបិសាចកាចណាស់នៅគ្រប់គ្រងរក្សា ឥតអ្នកណាមួយហ៊ានស្នាក់ក្នុងសាលានោះទេ, បើអ្នកឯងមិនខ្លាចយក្សបិសាចនោះទេ ទៅស្នាក់នៅសាលានោះចុះ ។ ព្រាហ្មណ៍ជាឪពុក ឮឆ្មាំទ្វារនិយាយដូច្នោះ ក៏នឹកខ្លាចខ្មោចបិសាចនោះ ប៉ុន្តែពោធិសត្វជាកូនប្រុសមិនខ្លាចក៏និយាយថា ខ្ញុំមិនខ្លាចទេឪ, ទៅ ! យើងនៅស្នាក់ឯសាលាហ្នឹងចុះ ! ឪកុំខ្លាចយក្សបិសាចកំណាចហ្នឹង! ខ្ញុំខ្នាទក់ ឲ្យវាចូលមកក្រាបជិតបាតជើងឪឲ្យត្រាតែបាន, មកទៅ! ឪកុំខ្លាច, ឥតបើអីទេ! ថាហើយក៏នាំគ្នាទៅ ។ លុះទៅដល់សាលានោះហើយ, ព្រាហ្មណ៍ជាឪពុកដេកលើផែនក្តារសាលា, ពោធិសត្វជាកូនរៀរឃ្លុំយប្រយាចជើងឲ្យឪពុក ។

និយាយពីយក្សបិសាច(១)នោះ ដែលបានទៅបម្រើបម្រាស់ព្រះបាទកុវេរៈ វេស្សវ័ណ អស់រយៈកាល ១២ ឆ្នាំ ក៏បានសាលានោះជាលំនៅ ដោយព្រះបាទវេស្សវ័ណ លោកបាលទេវតាបើកសិទ្ធិឲ្យថា បណ្ដាមនុស្សទាំងឡាយ បើមនុស្សណា ចូលមកស្នាក់ក្នុងសាលានេះ ហើយមនុស្សម្នាក់កណ្ដាស់ផែតឡើង មនុស្សដែលនៅជិតខាងបានពោលឲ្យពរថា "ចូរមានអាយុវែង!" ហើយអ្នកដែលកណ្ដាស់នោះក៏បានពោលឲ្យពរតបមកខ្លួនវិញថា "ចូរមានអាយុវែង!" ដូចគេឲ្យពរខ្លួនដែរ យ៉ាងនេះ, យក្សបិសាចនោះមិនត្រូវហ៊ានស៊ីគេឡើយ បើមនុស្សដែលពុំបានឲ្យពរគ្នាទេ យក្សបិសាចនោះត្រូវមានសិទ្ធិស៊ីគេបាន គឺត្រូវបឺតជញ្ជក់ឈាមមនុស្សទាំងនោះចុះ (ចំពោះតែមនុស្សទាំងឡាយដែលចូលមកក្នុងសាលានោះប៉ុណ្ណោះ ក្រៅពីក្នុងសាលានោះ ស៊ីគេពុំបានឡើយ) ។

យក្សបិសាចនោះ ក៏នៅលើធ្នឹមសាលា ក៏បម្រុងនឹងឲ្យព្រាហ្មណ៍ជាឪពុកពោធិសត្វកណ្ដាស់ ក៏ប្រើអានុភាពពក់ក្លាម ក៏យកម្ទេចល្អិតផង់ចុះមកឲ្យត្រូវចំច្រមុះនៃព្រាហ្មណ៍នោះ គាត់ក៏កណ្ដាស់ផែតឡើង ។ ពោធិសត្វជាកូនអង្គុយស្ងៀម មិនពោលឲ្យពរឪពុកថា "ចូរមានអាយុវែង!" ។ យក្សបិសាចនោះក៏ចុះពីធ្នឹមសាលាមក ដោយក៏សម្ដែងខ្លួនឲ្យពោធិសត្វមើលឃើញ ក៏ទឹងចាប់ស៊ី ។ ពោធិសត្វដឹងទាន់ភ្លាម

---

១ យក្ស ឬ យក្ខ ស្រីថា យក្សិណី ឬ យក្ខិណី "ប្រែថា អទិស្ស មានកាយដែលមនុស្សខ្លាចគេតែងបូជា" ជានាមនៃទេវតា, ភូត, បិសាចទាំងពួង ។ ក្នុងទីនេះ ខ្ញុំហៅថា យក្សបិសាច ឲ្យងាយយល់ ។

ថា យក្សបិសាចនេះវាធ្វើអាពុកអញឲ្យកណ្ដាស់ ព្រោះអញពុំបានឲ្យពរ ថា "ចូរមានអាយុវែង!" ដូច្នេះ ហើយវាទឹងប៉ុនញ៉ះទេដឹង ? ពោធិសត្វគិតឃើញភ្លាម ក៏ឲ្យពរទៅអាពុកភ្លាមថា :

ជីវ វស្សសតំ ភគ្គ អបរាធិ ច វីសតិ
មា មំ បិសាចា ខាទន្តុ ជីវ ត្វំ សរទោសតំ!

ភគ្គ:(១) ចូរមានអាយុមួយរយឆ្នាំ ផ្សំម្ភៃថែមទៀតជា ១២០ ឆ្នាំ! បិសាចចូរកុំស៊ីអញឡើយ! ឪចូររស់នៅជាងមួយឆ្នាំចុះ!

លុះយក្សបិសាចនោះ បានឮសម្ដីពោធិសត្វឲ្យពរអាពុកដូច្នេះហើយ ពុំហ៊ានស៊ីពោធិសត្វ វាគិតថា អញស៊ីវានេះពុំបានទេ អញត្រូវស៊ីអាពុកវាវិញ វាគិតហើយ ក៏ក្រោយផង់ល្អិតចុះមកម្ដងទៀតឲ្យត្រូវចំប្រមុះពោធិសត្វ ៗ ពោធិសត្វ បានឃើញអំពើរបស់វា ក៏ប្រែងខ្លួន រំពេចនោះ ក៏កណ្ដាស់ផ្ទែតឡើង ៗ ព្រាហ្មណ៍ជាអាពុកយល់ច្បាស់ថា បើអញមិនឲ្យពរទេ បិសាចនោះទឹងស៊ីឥឡូវនេះពុំខាន គិតឃើញភ្លាម ក៏ឲ្យពរទៅកូនថា :

ត្វម្បិ វស្សសតំ ជីវ អបរាធិ ច វីសតិ
វិសំ បិសាចា ខាទន្តុ ជីវ ត្វំ សរទោសតំ!

កូនឯងក៏ចូរមានអាយុមួយរយឆ្នាំដែរ ផ្សំម្ភៃថែមទៀតជា ១២០ ឆ្នាំ!

---

១ ពាក្យថា ភគ្គ: នេះជាឈ្មោះនៃបិតា គឺ ពោធិសត្វហៅចេញឈ្មោះបិតារបស់ខ្លួនដូចជាពាក្យថា "ឪ" ដែរ ។

បិសាចចូរស៊ីថ្នាំពិសចុះ! កូនឯងចូររស់នៅជាងមួយរយឆ្នាំចុះ!

យក្ខោ ភិសស្ស វចនំ សុត្វា យក្សបិសាចបានឮសម្ដីពោធិសត្វហើយគិតឃើញថា ឥកោបិ មេ ឆ សត្តា ទានិតុំ អញមិនអាចស៊ីពាំងពីនោះនេះទេ គិតឃើញហើយក៏ឡើងទៅលើធ្នឹមសាលាវិញ ។ អថ នំ ពោធិសត្តោ បុច្ឆិ លំដាប់នោះពោធិសត្វសួរយក្សបិសាចនោះថា កោ យក្ខ តស្មា ត្វំ សាលំ បវិដ្ឋមនុស្សេ ខាទសិ ? នែយក្ស ហេតុអ្វី.ជាអ្នកឯងស៊ីមនុស្សទាំងឡាយដែលចូលមកកាន់សាលានេះ? យក្សបិសាចឆ្លើយថា ទ្វាទសវស្សានិ វេសវណំ ឧបដ្ឋហិត្វា លទ្ធតា ខ្ញុំបានសិទ្ធិនេះ ពីព្រោះខ្ញុំបានគោរពបម្រើម្ចាស់ព្រះបាទវេស្សវណអស់ពេល ១២ ឆ្នាំ គឺព្រះបាទវេស្សវណបានបើកអំណាចឲ្យខ្ញុំ ។ ពោធិ-សត្វសួរថា កឹ បន សព្វេវ ខាទិតុំ លភសិ ? ចុះអ្នកឯងត្រូវបានស៊ីមនុស្សទាំងអស់ តាមតែអ្នកណាក៏ដោយ ឬ? យក្ស-បិសាចឆ្លើយថា ជីវប្បតិជីវកាលកោ ឋបេត្វា អវសេសេ ខាទាមិ លើកលែងតែមនុស្សទាំងឡាយ ដែលមិនចេះពោលពាក្យឲ្យគេត្រូវពរពាមក (នៅពេលដែលគេកណ្តាស់) ថា "ជូនអាយុវែង!"

ឯមនុស្សក្រៅពីនោះ ខ្ញុំត្រូវស៊ី(១) (បឺតជញ្ជក់តែឈាម) ។

ពោធិសត្វបានទូន្មានយក្សបិសាចនោះថា នែយក្ស, កាលពីជាតិមុន អ្នកឯងបានធ្វើអកុសលកម្មដ៏លាមកអាក្រក់ បានជាអ្នកឯងមកចាប់កំណើតជាយក្សបិសាចកាចយោរយៅអាក្រក់ក្រៃយ៉ាងនេះ ឥឡូវនេះ អ្នកឯងខ្វល់ធ្វើកម្មអាក្រក់នោះតទៅទៀត ឥះ មោ ឥមបាយរោ ករិស្ស-សិ អ្នកឯងឈ្មោះថាសត្វដ៏ពិតប្រព្រឹត្តទៅខាងងងឹតសូន្យសុង នែយក្ស ព្រោះហេតុនោះ ចាប់ដើមតាំងពីថ្ងៃនេះតរៀងទៅ អ្នកឯងចូរវៀរចាកអំពើអាក្រក់បាណាតិបាតកម្មជាដើមឲ្យជ្រះស្រឡះចេញ ។ លុះពោធិសត្វទូន្មានយ៉ាងនេះហើយ ក៏គម្រាមយក្សបិសាចឲ្យញើញក័យក្នុងនរកជាក់ស្តែងញ៉ាំងយក្សបិសាចឲ្យទទួលកាន់សីល ៥ ហើយញ៉ាំងយក្សបិសាច

---

១- យក្សបិសាចនោះ នៅទីគោកដែលគេតែហៅថា បិសាចព្រៃឬអារក្ស ឬក៏ខ្មោចព្រៃនោះក្តី ទោះនៅទីទឹកដែលគេហៅថា បិសាចទឹក ឬ អារក្សទឹក ឬក៏ខ្មោចទឹកនោះក្តី សុទ្ធតែនៅក្រោមអំណាចនៃព្រះបាទកុវេរៈ ដែលហៅថាព្រះបាទវេស្សវ័ណ ព្រោះជាម្ចាស់ក្រុងវិស្សាណា ជាលោកបាលមហារាជនៅទិសឧត្តរនៃភ្នំសិនេរុក្នុងមហាឋានកសួត កាលបើយក្ស-បិសាចដែលព្រះបាទវេស្សវ័ណបានបើកសិទ្ធិអំណាចឲ្យត្រង់ទីមានកម្រិតត្រឹមណា អាចបៀតបៀនមនុស្សឬសត្វតិរច្ឆានបានចំពោះតែត្រឹមៈណោះ ហួសពីព្រំដែនៈនោះ សុម្បីតែត្រឹមមួយជំហ៊ានក៏ពុំអាចបៀតបៀនគេបានឡើយ ដោយដាច់ខាត សឹងមានរឿងតំណាលប្រាប់ច្រើនអនេកក្នុងគម្ពីរជាតកផ្សេង ៗ ។ ដោយហេតុនេះឯងបានជាបណ្ឌិតទាំងឡាយ តែងតែរៀសចាកភយន្តរាយមិនឲ្យយក្ស-បិសាចទាំងនោះបៀតបៀនបាន ដូចរឿងនិទានក្នុងភទ្ទជាតកនេះជាដើមស្រាប់ៈ តែជាទេពហេតុស្រាប់ ។ ព្រះសាក្យមុនីបានតែសណ្តារើសយកដោយវិចារណបញ្ញាក៏លុះសម្រេចបុណ្យ ។ បើយល់ថាតិចដូចរឿងទាំងនោះមែន គួរតែប្រយ័ត្នកុំឲ្យតួកយក្សបិសាចវាធ្វើទុក្ខបាន ត្រូវឲ្យដាច់តែកក់កង់យកាផើងកប ។

ឲ្យទូលព្រះបង្គំប្រគល់ខ្លួនធ្វើដូចជាអ្នកបម្រើបម្រាស់ គឺជាអ្នកជួយទំនុកបម្រុងតរៀងទៅ ៗ

បុន ទិវសេ សព្វារត្តា មនុស្សា លុះដល់ស្អែកឡើង មនុស្សទាំងឡាយដែលសញ្ជរទៅមកត្រង់ទីនោះ បានដឹងការណ៍នោះជាក់ប្រាកដ បានដំណឹងតៗគ្នាពីមួយទៅមួយហើយ អ្នកខ្លះក៏ចូលទៅក្រាបទូលព្រះរាជា លុះស្ដេចទ្រង់ជ្រាបរឿងនេះសព្វគ្រប់ហើយ ព្រះអង្គមានព្រះរាជតម្រាស់ឲ្យហៅព្រាហ្មណ៍ឪពុក និងពោធិសត្វ ជាកូនចូលមកគាល់, ទ្រង់បញ្ជាក់បានជ្រាបការណ៍សព្វគ្រប់ហើយ ស្ដេចពេញព្រះរាជហឫទ័យណាស់ ដោយព្រះអង្គជ្រាបមកយូរហើយថា យក្សបិសាចនោះពាំបៀត-បៀនមនុស្សដែលមកស្នាក់ក្នុងសាលានោះ ឲ្យវិនាសអន្តរាយជីវិតច្រើនណាស់ហើយ ព្រះអង្គក៏បានប្រទានឲ្យពោធិសត្វមានយសស័ក្តិជាសេនា-បតី ទ្រង់ប្រោសព្រះរាជទានទ្រព្យសម្បត្តិយសបរិវារ ដល់ព្រាហ្មណ៍ជាបិតានៃពោធិសត្វនោះផង ដោយសារគុណានុភាពនៃពោធិសត្វជាបុត្រដែលបានទូន្មានយក្សបិសាចនោះឲ្យស្លូតតទៅ ៗ

ព្រះរាជា ទ្រង់បានតាំងយក្សបិសាចនោះឲ្យមានឋានៈជាពលិមង្គ-ជិត្តាភោគ គឺ ឲ្យជាអទិស្សមានកាយជាអ្នកទទួលពលិការអំពីមនុស្សទាំងឡាយ ឲ្យជាឲ្យអ្នកជួយទំនុកបម្រុងកសិករដ្ឋ ឲ្យបានសុខសប្បាយតរៀងទៅ ៗ ព្រះមហាក្សត្រិយ៍អង្គនេះ ទ្រង់ឋិតនៅក្នុងរាជ្យតទៅជៀវស្លាប់ ពោធិសត្វជាសេនាបតី ទ្រង់បំពេញការកុសលមានទានជាដើម ដរាប

ដល់ព្រះអង្គបានខ្ទូវសត្តបទ គឺ ផ្លូវនៃបានសួគ៌ក្នុងអវសានកាល នៃព្រះជន្មាយុ ៗ

សត្ថា ឥមំ ធម្មទេសនំ អាហរិត្វា ជីវប្បដិជីវន្នាយ ឥស្មិំ កាលេ ឧប្បន្នត្តិ វត្វា ជាតកំ សមោធានេសិ ព្រះសម្ពុទ្ធជាបរមសាស្តា ទ្រង់សម្តែងព្រះធម៌ទេសនានេះ ហើយ ព្រះអង្គបញ្ជាក់សេចក្តីថា ជីវប្បដិជីវ កើតមានតាំងពីក្នុងកាលណោះមក ហើយព្រះអង្គប្រជុំជាតកថា តទា អានន្ទោ អហោសិ បិតា កស្សបោ, បុត្តោ បន អហមេវ ព្រះពជាក្នុងកាលណោះ ចេរវិលវិញអន្ទោលជាតិមកកើតជា អានន្ទ ព្រាហ្មណ៍ជាបិតា (នៃពោធិសត្វ) អន្ទោលជាតិមកកើតជា មហាកស្សប, ឯបុត្រ (នៃព្រាហ្មណ៍នោះ) គឺអញតថាគតនេះឯង ៗ

ភគ្គជាតកំ និដ្ឋិតំ

ភគ្គជាតកចប់ ។

## បរិយាយ បញ្ជាក់ថែម

រឿងក្នុងសាស្ត្រល្បែង ឬ រឿងប្រលោមលោក ជារឿងប្រឌិតប្រដូច សម្រាប់អានកំសាន្តសប្បាយ ឬ ល្ខោនដែលគេស្នាចមុខហៅថា មុខយក្ស នោះមានសណ្ឋានខុសពីមុខមនុស្សនិងមុខទេពតាឆ្ងាយណាស់ ឯតាម

ការពិតមិនមែនដូច្នោះទេ ពាក្យថា យក្ខ ឬ យក្ស នេះ សំស្ក្រឹតនិងបាលី ប្រាប់ថា មកពីប្រកពដើមថា យជ ប្រែថា "បូជា, កោតខ្លាច, គោរព" សម្រេចរូបថា តាមនាមថា យក្ខ ឬ យក្ស ប្រែថា "អទិស្ស-មានកាយដែលគេកោតខ្លាច គេគោរពបូជា បន់ស្រន់ គេសែនព្រេន" មានអត្ថន័យថា អមនុស្ស ឬ អទិស្សមានកាយ ដែលកើតក្នុងរូបភពមានរូបកាយដែរ ប៉ុន្តែល្អិតណាស់ មនុស្សយើងមើលពុំឃើញ បើគេចង់ឲ្យយើងឃើញមនុស្សយើង ក៏អាចមើលឃើញដែរ ជាពិសេសម្តងៗ ឬក្តុ តែសម្លេងមិនឃើញរូបក៏មានដែរ ។ ភូត បិសាច អសុរកាយ ក្រុមទេវតា រុក្ខទេវតា សមុទ្ទទេវតា ទេវតារក្សាមហាស្វេតច្ឆត្រ . . . ពោះទាំងព្រះឥន្ទ និងទេវតាទាំងអស់ដែលនៅក្នុងឋានសួគ៌ បើហៅដោយរួមថា យក្ខ ឬ យក្ស ដូចគ្នា មិនមែនមានរូបកងដូចយើងធ្លាប់ចំណាំនោះឡើយ ។

ក្នុងគម្ពីរនានាខាងព្រះពុទ្ធសាសនា ពោះព្រះត្រៃបិដកក្តី អដ្ឋកថាក្តី ជាតកជាដើមក្តី មាននិយាយពីយក្សនេះច្រើនអនេកណាស់ ។ ក្នុងមហាបរិនិញ្វានសូត្រ មានតំណាលថា នៅពេលដែលព្រះសក្យ-មុនីសម្មាសម្ពុទ្ធ ទ្រង់ផ្ចង់លើបរិនិព្វានបញ្ចាសនៈ គឺលើគ្រែផ្ចុំបរិនិព្វាន ឧបវាណភិក្ខុ កំពុងបក់គិច ១ ថ្វាយ ព្រះអង្គមានព្រះបញ្ជាឲ្យថយចេញដោយអាការ ហាក់ដូចជាបណ្តេញឲ្យចេញពីទីជិតព្រះអង្គ ព្រះមហាអានន្ទក្រាបបង្គំទូលសួរហេតុនោះ ព្រះអង្គត្រាស់ថា ឧបវាណភិក្ខុ ឥត

មានកំហុសអ្វីក្នុងការបក់នេះទេ ប៉ុន្តែមានពួកទេវតាច្រើនណាស់ណែនណាន់តាន់តាប់ និម្មិតខ្លួនតូចៗ ឈរប្រជ្រៀតគ្នាអើតមើលរូបកាយអញតថាគត ជាបច្ឆិមទស្សនៈ ឃើញចុងក្រោយបំផុត ឧបវាណភិក្ខុ អង្គុយបក់បាំងភ្នែកពួកទេវតា នាំឲ្យទាស់អធ្យាស្រ័យគេ អញតថាគតត្រូវការឲ្យទីជិតនេះស្រឡះស្រឡំ បើកឱកាសឲ្យពួកទេវតាគេឃើញអញតថាគតច្បាស់ចុះ ដ្បិតអំណើះពីថ្ងៃនេះទៅគេលែងបានឃើញអញតថាគតទៀតហើយ ! ។ល។ យើងជាពុទ្ធសាសនិកដែលមានគារវភាពចំពោះព្រះអង្គ កាលបើនឹកឃើញរឿងនេះ កំរែងមានចិត្តអាណោចលន្ទោចដោយនឹកស្តាយអាល័យព្រះអង្គ !

នៅទីបញ្ចប់នេះ សុំបញ្ជាក់ថា អំពីពាក្យថា យក្ខ ឬ យក្ស យក្ខិណី ឬយក្សិណី " យក្សប្រុស យក្សស្រី " នេះ អស់លោកអ្នកអានដែលពុំធ្លាប់គិតឬដែលធ្លាប់គិតដែរ ប៉ុន្តែមានយោបល់ត្រឹមតែយក្សល្ខោននោះ គួរប្រើវិចារណបញ្ញាឲ្យប្រព្រឹត្តទៅតាមន័យដែលបានពោល ហើយអំពីពាក្យថា យក្ខ ជាសាធារណនាមនៃអមនុស្សមានកាយទូទៅនោះចុះ ។

- ចប់ -

វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអាទិត្យទី ២០ តុលា ២៥១២/១៩៦៨

សម្តេចព្រះសង្ឃរាជ ជ·ណ· ជោតញ្ញាណោ

ប.អ.ស.–អ.ម.រ.

# ពាក្យថាធម៌គឺអ្វី?

របស់ព្រះពោធិវង្ស **ស៊ូរ-ហាយ** ចៅអធិការវត្តនិរោធរង្សី

អធិបតីរងក្រុមជំនុំព្រះត្រៃបិដក

នមត្ថុ សុគតស្ស

ជីរន្តិ វេ រាជរថា សុចិត្តា

អថោ សរីរម្បិ ជរំ ឧបេតិ

សតញ្ច ធម្មោ ន ជរំ ឧបេតិ

សន្តោ ហវេ សព្ភិ បវេទយន្តិ

ពុទ្ធភាសិតខាងលើនេះ មានមកក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយ ដែលសម្តែងអំពីធម៌របស់លោកអ្នកសប្បុរស ឬលោកអ្នកស្ងប់រម្ងាប់ មានព្រះសម្ពុទ្ធជាដើម ជាធម៌មិនចេះចាស់ដកដូចរទេះ ឬរាងកាយរបស់មនុស្សសត្វឡើយ ។

ពាក្យថាធម៌ មានស័ព្ទដែលគួរប្រែជាច្រើនយ៉ាងណាស់ ប៉ុន្តែក្នុងទីនេះ ពុំបានរើករញែកចំពោះស័ព្ទថាធម៌នេះទេ សូមចងវិគ្គហៈរបស់ធម៌តែត្រឹម ៤ បែប ដូចតទៅនេះ

១- ចតូសុ អបាយេសុ សំសារេ វា សត្តេ អបតមានេ ធារេតីតិ ធម្មោ សភាពគឺសេចក្តីពិតណា រមែង

ទ្រទ្រង់នូវសត្វទាំងឡាយ មិនឲ្យធ្លាក់ទៅក្នុងអបាយទាំង ៤ ក្នុងសំសារវដ្ត សភាពនោះឈ្មោះថាធម៌ ។

២ – សលក្ខណំ ធារេតីតិ ធម្មោ សភាពណារមែងទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួនគឺកុសលទាំង៤ មានកាមាវចរកុសលជាដើម សភាពនោះឈ្មោះថាធម៌ ។

៣ – ចាបកេ អកុសលេ ធម្មេ ធុនាតីតិ ធម្មោ សភាពណា រមែងកម្ចាត់នូវអកុសលធម៌ដ៏លាមកចេញ (ពាកខ្នួសន្តាន) សភាពនោះឈ្មោះថាធម៌ ។

៤ – សោតាបន្នាទីហិ អរិយេហិ ធារិយតីតិ ធម្មោ សភាពណា ដែលព្រះអរិយៈទាំងឡាយមានព្រះសោតាបន្នបុគ្គលជាដើម តែងទ្រទ្រង់ទុក ( ចាំទុកក្នុងសន្តាន ) សភាពនោះឈ្មោះថាធម៌ ។

៥ – យថានុសិដ្ឋំ បដិបជ្ជមានេ ចតូសុ អបាយេសុ អបតមានេ សត្តេ ធារេតីតិ ធម្មោ សភាពណា ទ្រទ្រង់ធ្វើនូវពួកសត្វដែលប្រតិបត្តិសមគួរ ដល់ពាក្យប្រៀនប្រដៅ មិនឲ្យធ្លាក់ទៅក្នុងអបាយទាំង ៤ សភាពនោះឈ្មោះថាធម៌ ។

ពាក្យថាធម៌ ដូចវិគ្គហៈ ដែលចងក្រងមកនេះមានសេចក្តីជ្រាលជ្រៅដោយពិត ប៉ុន្តែបើតាមវិធីរបស់ព្រះសម្មាសម្ពុទ្ធ បានដល់សេចក្តីពិតដែលតែងរស់នៅប្រចាំលោក ។ ពាក្យថា ធម៌ ឬ ធម្មៈនេះ បានដល់សច្ចធម៌ (សេចក្តីពិត) សុចរិតធម៌ ( ការប្រព្រឹត្តល្អ ) យុត្តិធម៌ (ការ

ប្រព្រឹត្តត្រូវ ) ។ មួយទៀត ការប្រតិបត្តិចំពោះច្បាប់ណាមួយដែលប្រាសចាក អគតិធម៌ ៤ យ៉ាង មានឆន្ទាគតិជាដើម លោកហៅថាធម៌ ។ ពាក្យថា ធម៌នេះ បើទុកជាមិនមានគុណសព្ទថា កុសល ឬ អកុសល នៅជិតខាង ក៏បណ្ឌិតអាចយល់បានតាមដំណើរសេចក្ដី ។

ពាក្យថា ធម៌ ដែលមានមកក្នុងពុទ្ធភាសិតខាងលើនុះ សំដៅយកសន្តិ គឺសេចក្ដីស្ងប់កាយវាចាចិត្ត ចាកកិលេស មានលោភៈជាដើម ដូចសេចក្ដីប្រែនៃភាសិត ព្រមទាំងអធិប្បាយ វែកញែកពង្រីកឲ្យពិស្ដារតទៅនេះ ។

“ រាជរថទាំងឡាយ ដែលនាយជាងរចនាល្អហើយ រមែងចាស់គ្រាំគ្រាទៅពុំខាន ទោះទាំងសរីរៈរាងកាយ ( របស់សត្វទាំងឡាយ ) ក៏ដល់នូវសេចក្ដីចាស់គ្រាំគ្រាដូច្នោះដែរ ទើបឯធម៌របស់លោកអ្នកស្ងប់ មិនដល់នូវសេចក្ដីគ្រាំគ្រាដូច្នោះឡើយ ពួកលោកអ្នកស្ងប់កិលេស រមែងសន្ទនាជាមួយនឹងពួកលោកអ្នកស្ងប់ផងគ្នាបាន ” ។

សុភាសិតដែលអាងមកនេះ ដើម្បីបញ្ជាក់ចំពោះពាក្យថាធម៌ជាសភាវៈឥតរូប ដោយហេតុថាជាច្បាប់សម្រាប់ជឿកាន់ សម្រាប់ប្រព្រឹត្ត ដើម្បីស្ងប់ ឬ លាងជម្រះបោសសម្អាតកិលេសក្នុងខន្ធសន្ដានរបស់សត្វលោកឲ្យជ្រះស្អាត ឲ្យទៅជាមនុស្សវិសុទ្ធស្ងប់ស្ងាប់ ។ មួយទៀត ពាក្យថាធម៌បានដល់សភាវៈឥតរូបបានដែរនាយ ដែល [illegible] ក្នុងលោក សម្រាប់ដឹងបានដោយអាស្រ័យប្រាជ្ញា [illegible]

ច្បាស់ ហើយទ្រង់បានសម្តែងស្រាវជ្រាវប្រកាសចំពោះសត្វលោក ដើម្បីឲ្យសត្វប្រតិបត្តិតាម ។ មួយវិញទៀត ពាក្យថា ធម៌ សំដៅយកទាំងសេចក្តីល្អ ទាំងសេចក្តីអាក្រក់ ទាំងបុណ្យទាំងបាប គុណទោស ទាំងមគ្គផលនិព្វាន ព្រោះសភាវៈទាំងនេះ តែងរស់នៅប្រាកដប្រចាំលោក មិនអាចវិនាសចាកលោក ដោយអន្តរាយណាមួយបានឡើយ សូម្បីលោកធាតុទាំងមូលត្រូវក្ស័យនេះ ក៏មិនអាចសាបសូន្យ ។ ពាក្យដែលគេតែងនិយាយថាព្រះធម៌សាបសូន្យនោះ ដោយហេតុតែមិនមានមនុស្សគោរពសិក្សាប្រតិបត្តិប៉ុណ្ណោះ ។ ពាក្យថា "ធម៌" នេះជាគូនឹងពាក្យថា "វិន័យ" របស់ព្រះសម្ពុទ្ធ រួមពាក្យទាំងពីរម៉ាត់នេះហៅថា ពុទ្ធសាសនា ប្រែថា ប្រៀនប្រដៅអប់រំ ឬជាមេរៀនទន្ទួញរបស់ព្រះសម្មាសម្ពុទ្ធ ដើម្បីបាននូវសន្តិវរបទ គឺផ្លូវសន្តិភាពដ៏ប្រសើរបំផុតរបស់ព្រះពុទ្ធសាសនា ។

ព្រះពុទ្ធសាសនាសម្បូណ៌ដោយទ្រឹស្តី ដោយអត្ថបទ ដោយនិទានដែលប្រកបដោយហេតុផលជាច្រើនណាស់ ជាសាសនាស្រោចស្រង់សត្វលោកឲ្យរួចចាកទុក្ខតាំងអំពីបច្ចុប្បន្ន រហូតដល់អនាគត ទុកជាជាបទសម្រាប់សិក្សាជាន់ខ្ពស់បំផុត ដើម្បីស្វែងរកសន្តិភាពយ៉ាងជាក់ច្បាស់ បើមនុស្សក្នុងលោកគ្រប់ប្រទេសទទួលសិក្សាប្រតិបត្តិតាមដោយហ្មត់ចត់ ។

សេចក្តីក្នុងពុទ្ធកាលិកគាថាខាងលើនុ៎ះ ជាបទសម្រាប់ពិចារណាឲ្យឃើញថា សេចក្តីល្អ, សេចក្តីអាក្រក់, មគ្គផល និព្វាន ជាធម្មជាតនៅថ្មីជានិច្ចគ្រប់កាលទាំងពួង មិនដល់នូវភាពគ្រាំគ្រាបាក់បែកទ្រុឌទ្រោមសាប

សូន្យដូចរូបកាយមនុស្សសត្វ ឬសម្ភារៈណាមួយឡើយ ។ មនុស្សក្នុងសកលលោកគ្រប់ប្រទេស ច្រើនតែមានជំនឿបាក់ផ្ចត់គំនិត ទៅតាមទ្រឹស្ដីសាសនារបស់ខ្លួន ៗ ស្រេចនឹងគ្រូប្រដៅសាសនា ដែលជាអ្នកដឹកនាំមុនដំបូង ។ ក្នុងចំណោមសាសនាដែលនៅគ្រប់ប្រទេស សាសនាខ្លះក៏មានហេតុផលល្អ, សាសនាខ្លះ ក៏ឥតហេតុផលទាល់តែសោះ ប៉ុន្តែដោយអំណាចជំនឿបាក់ផ្ចត់ តាមវង្សត្រកូលជាយូរមកហើយ ជាហេតុនាំឲ្យស្លាប់គំនិត ដែលអាចកែប្រែខ្លួនចេញពីសាសនានោះ ៗ បានដោយក្រណាស់ ។

ព្រះពុទ្ធសាសនាជាសាសនាមានហេតុផល ជាមជ្ឈិមបដិបទាដែលកើតអំពីមហាបុរសមួយរូប គឺព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គមានជាតិជាមនុស្ស ជាព្រះរាជបុត្រព្រះបាទសុទ្ធោទនៈ សោយរាជ្យក្នុងក្រុងកបិលពស្តុរាជធានី សព្វថ្ងៃហៅថាក្រុងកដ្ឋមណ្ឌុ ប្រទេសនេប៉ាល់ តាមប្រវត្តិដោយពិតប្រាកដ ពុំមែនព្រះពុទ្ធដោយមនោគតិរបស់អ្នកនិពន្ធគម្ពីរសាសនានោះឡើយ ។ ឧត្តមគតិរបស់មនុស្ស អ្នកកាន់សាសនាក្នុងលោកផ្សេង ៗ គ្នា ដោយហេតុទ្រឹស្ដីរបស់សាសនានោះ ៗ នាំបំបែរឲ្យទៅជាមនុស្សអ្នកកាន់អ្នកជឿនោះ កាចឃោរឃៅក្នុងការកាប់សម្លាប់ឥតគិតដល់ជីវិតមនុស្សសត្វសោះ រាប់ថាជាសាសនាខុសព្រហ្មវិហារធម៌ មិនគួររាប់ថាសាសនាមានហេតុផលល្អ ប្រព្រឹត្តទៅដើម្បីសន្តិភាពបានឡើយ ។

ឧត្តមគតិរបស់មនុស្សអ្នកកាន់ព្រះពុទ្ធសាសនា សម្បូណ៌ដោយព្រហ្មវិ-

ហារធម៌ចំពោះទាំងមនុស្ស ទាំងតិរច្ឆាន គឺទាំងជីវិត ទ្រព្យសម្បត្តិនិងទីកន្លែងទីកដីរបស់អ្នកដទៃ រាប់ថាជាសាសនា គោរពសិទ្ធិសេរីភាពរបស់មនុស្សសត្វជាសាធារណៈ ឥតរើសពូជពង្សជាតិថ្នាក់វណ្ណៈណាមួយទេ ។ ពុទ្ធសាសនា រាប់ថាជាសាសនាមានហេតុផល សាងសន្តិភាពដើម្បីប្រជា-ពលលោកដោយពិត ជាសាសនាស្លូតសុភាព ចំពោះជីវិត និងទ្រព្យសម្បត្តិនៃគ្នានិងគ្នា សម្រាប់ឧបត្ថម្ភជ្រោមជ្រែងសង្គមមនុស្ស ឲ្យបានសន្តិសុខចម្រើនរុងរឿងតាមឧបនិស្ស័យរបស់មនុស្ស មិនប្រើអំណាចជិះជាន់ឈ្លោះប្រកែក ប្រកាសសង្គ្រាមដល់គ្នានិងគ្នាឡើយ ។

ធម៌ដែលព្រះសម្ពុទ្ធទ្រង់សម្តែងតាំងដើមអំពីបឋមពោធិកាល រហូតដល់បច្ឆិមពោធិកាលនោះមានឈ្មោះថា មានន័យច្រើនយ៉ាងជាអនេក ៗ ធម្មទេសនារបស់ព្រះអង្គ តាមដែលសង្កេតឃើញក្នុងគម្ពីរ ជួនកាលមានសេចក្តីល្អិតញឹកជ្រាលជ្រៅ ជួនកាលរាក់ៗតាមឧបនិស្ស័យវាសនានិងចរិតរបស់បរិស័ទអ្នកស្តាប់ បើព្រះអង្គសម្តែងធម៌ចំពោះគ្រហស្ថសុទ្ធ ដែលមិនលាយដោយពួកបព្វជិតផងទេ ច្រើនតែសម្តែងអំពីអនុបុព្វីកថា ៥ យ៉ាង មានទានកថាជាដើមនិងប្រយោជន៍ ៣ យ៉ាង គឺប្រយោជន៍បច្ចុប្បន្ន ១ បរលោក ១ ព្រះនិព្វាន ១ ។ បើព្រះអង្គសម្តែងចំពោះបព្វជិតច្រើនតែសម្តែងអំពីផ្លូវឈាន សមាបត្តិ និងព្រះនិព្វាន ដើម្បីឲ្យសមតាមកិច្ចរបស់អ្នកបួសក្នុងសាសនា ។ មួយទៀត ធម្មទេសនា ដែលព្រះអង្គសម្តែងចំពោះបុគ្គលនោះៗ ច្រើនតែប្រកាសចង្អុល បង្ហាញធម៌ទាំងពីរ

ចំណែក គឺធម៌ដែលគួរបំពេញឲ្យមានឡើង ហៅថា ភាវនាខន្ធ ១ ធម៌ដែលគួរលះចេញហៅថា បហានក្ខន្ធ ១ ។

កុសលធម៌ទាំងអស់ ដែលគួរបណ្ដុះបង្កើតឲ្យមានឡើង ក្នុងខន្ធសន្ដានហៅថា ភាវនាខន្ធ បានដល់និច្ចសីល ឧបោសថសីល បុញ្ញកិរិយាវត្ថុ ១០ និងសតិប្បដ្ឋាន ៤ ជាដើម ។ អកុសលធម៌ដែលត្រូវលះកាត់កាល់ចោលចេញដូចយ៉ាងកិលេសទាំងឡាយ មានអភិជ្ឈាវិសមលោភៈនិងសំយោជនធម៌ ១០ យ៉ាងជាដើម ហៅថា បហានក្ខន្ធ ។

មនុស្សក្នុងសកលលោក ដែលធ្លាប់មានជំនឿក្នុងសាសនាដោយរៀងខ្លួន គួរពិចារណារឿយ ៗ ឲ្យហ្មត់ចត់ ហើយគួរកែប្រែជំនឿជាថ្មីចំពោះសាសនាដែលមិនមានហេតុមិនមានផល មិនគួរឲ្យគំនិតដេកដួលលង់ទ្រនេសបាត់ធ្លាក់ដូច្នោះឡើយ ។

មួយទៀត ពាក្យថា ធម៌ ដោយសេចក្ដីប្រែដែលមាននៅក្នុងអដ្ឋកថាសង្គីតិសូត្រ បានដល់សត្ថុប្បាវចនៈ ៥ យ៉ាង គឺ:

១–ធម៌ បានដល់ពុទ្ធវចនៈខាងគម្ពីរព្រះសូត្រ

២–អភិធម៌ បានដល់ពុទ្ធវចនៈខាងគម្ពីរព្រះអភិធម្ម

៣–វិន័យ បានដល់សិក្ខាបទក្នុងឧភតោវិភង្គ

៤–អភិវិន័យ បានដល់ពុទ្ធានុញ្ញាត និង ពុទ្ធប្បញ្ញត្តិក្នុងខន្ធកៈនិង បរិវារៈ ។

គោលដៅត្រង់ពាក្យថាធម៌ ដែលព្រះសម្មាសម្ពុទ្ធ សម្ដែងទុកនោះមក ដើម្បីប្រយោជន៍ដ៏ធំបំផុតនោះ ជាពិសេសគឺសម្រាប់ទូន្មានកាយវាចាចិត្តដែលប្រឡាក់ដោយកិលេសមាន លោភៈ ទោសៈ មោហៈ ជាដើមហេតុ សម្រាប់បំផ្លាញជីវិតមនុស្សក្នុងសង្គមឲ្យរងទុក្ខឲ្យព្រាត់ប្រាសវិនាស ។

ព្រោះថា សេចក្ដីទុក្ខភ័យព្រាត់ប្រាសវិនាសទិកសជីវិត មនុស្សសត្វទ្រព្យសម្បត្តិទាំងអស់ ដែលកើតហើយក្ដី ដែលកំពុងកើតឡើងក្នុងបច្ចុប្បន្នក្ដី ដែលនឹងកើតឡើងក្នុងអនាគតក្ដី សុទ្ធតែកើតឡើងអំពីប្រភពនៃកិលេសមានលោភៈជាដើម គឺជាសមុដ្ឋានដើមកំណើតមកពីឫសគល់នៃកិលេស ឬ ថាមានកិលេស ៣ ប្រការ គឺលោភៈ ទោសៈ មោហៈ ជាអកុសលមូល ដែលចាត់ថាជាមូលដ្ឋាននាំបង្កើតទុក្ខភ័យនាំឲ្យហិនហោចទាំងធនធានទាំងជីវិតមនុស្សសត្វ ។ ដែលហៅថាព្រះធម៌នោះសំដៅយកព្រះពុទ្ធសាសនាជាឧបាយក្នុងផ្លូវប្រតិបត្តិ ដើម្បីកាប់ឆ្ការគាស់រំលើងកម្ចាត់ចោលនូវមូលដ្ឋាននៃកិលេស មិនឲ្យលូតលាស់ដុះដាលឡើងតទៅទៀតបាន ដើម្បីសន្តិភាព គឺមគ្គផលនិព្វានជាស្ថាពរ ដោយបានប្រយុទ្ធ យកជ័យជម្នះឈ្នះកិលេសគ្រប់យ៉ាង ទាំងកិលេសគ្រោតគ្រាតនិងកិលេសយ៉ាងល្អិត ។ ព្រោះថា ការឈ្នះរវាងមនុស្ស និងមនុស្សក្ដី រវាងមនុស្សនិងធម្មជាតិក្ដី លោកមិនរាប់ថាជាការឈ្នះពិតឡើយព្រោះនឹងអាច

ត្រឡប់បាញ់វិញក្នុងកាលណាមួយពុំខាន ការឈ្នះទាំងនោះពុំពប់ថាប្រ-
សើរទេ ការឈ្នះកិលេសទើបឈ្មោះថា ជាការប្រសើរបំផុត ជាងជម្នះអ្វី
ទាំងអស់ក្នុងលោកគឺថាជាជម្នះឈ្នះពបលើជាតិ ជរា មរណៈ ដោយពិត ៗ

ពាក្យថាធមិតីអ្វី ? ចប់តែប៉ុណ្ណោះ ។

## វិចារណកថា :

### អំណាច-ប្រាក់-ស្រី

វត្ថុទាំងបីនេះ ជាឧបករណ៍ដ៏ប្រសើរថ្លៃថ្លាណាស់ សម្រាប់មនុស្សលោក ។ អំណាចត្រូវតែមានចំពោះបុគ្គលម្នាក់ ៗ សម្រាប់ញ៉ាំងកិច្ចការអ្វីផងទាំងពួង ឲ្យប្រព្រឹត្តទៅបានស្រួលក្នុងឆាកជីវិតរបស់ខ្លួន ។ ប្រសិនបើគ្មានអំណាចសោះទេ មនុស្សមិនអាចធ្វើអ្វីកើតបានប្រពៃឡើយ ។ អ្នកប្រកបអាជីវកម្មផ្សេង ៗ ត្រូវតែមានអំណាចក្នុងកិច្ចប្រកបមុខរបររបស់ខ្លួន អ្នកធ្វើស្រែចំការត្រូវឲ្យមានអំណាច អ្នកធ្វើពាណិជ្ជកម្មត្រូវឲ្យមានអំណាច ភ្នាក់ងាររដ្ឋការម្នាក់ៗ ត្រូវឲ្យមានអំណាច ចំពោះមុខងាររៀងៗ ខ្លួន ។ល។

ដូច្នេះអំណាចជាឧបករណ៍ចាំបាច់សម្រាប់មនុស្សមួយរូប ៗ ។

ប្រាក់ ក៏ដូច្នោះដែរ គឺជាឧបករណ៍ដ៏សំខាន់នៃមនុស្សក្នុងលោក ។ គេធ្វើការសព្វយ៉ាង ដើម្បីស្វែងរកប្រាក់ ព្រោះប្រាក់ជាទាសៈដ៏ប្រពៃបំផុតរបស់លោកិយ ។ អ្នកស្រែចំការខំធ្វើកសិកម្មដើម្បីឲ្យបានផលិតផល គេយកផលិតផលនេះទៅលក់យកប្រាក់ គេយកប្រាក់នោះទៅរចនាជាអ្វី ៗ តាមសេចក្ដីត្រូវការរបស់ខ្លួនបានទាំងអស់ បើខ្វះប្រាក់ គេរស់បានដោយសេចក្ដីលំបាក ។ ពាណិជ្ជករ ឧស្សាហករ ភ្នាក់ងាររដ្ឋការនានា ។ល។ សុទ្ធតែធ្វើការដើម្បីប្រាក់ ព្រោះប្រាក់នេះមានសារៈសំខាន់ណាស់សម្រាប់ការរស់នៅរបស់មនុស្ស ។

ដូច្នេះប្រាក់ជាឧបករណ៍ចាំបាច់សម្រាប់មនុស្សមួយរូប ៗ ។

ចំណែកស្រី ក៏មិនខុសពីគ្នាប៉ុន្មានដែរ គឺជាឧបករណ៍ដ៏សំខាន់ណាស់ដែរសម្រាប់បុរស ។ វៀរលែងតែអ្នកបួសក្នុងព្រះពុទ្ធសាសនាចេញ បុរសក្រៅពីនេះ ទុកស្រីជាការចាំបាច់ក្នុងដំណើរជីវភាពរបស់ខ្លួនជានិច្ច ។ សូម្បីអ្នកបួសក្នុងពាហិរសាសនាខ្លះ ក៏ស៊ូអត់ទ្រាំដោយខ្វះស្រីពុំបានដែរ ទោះបីវិន័យក្នុងសាសនាហាមឃាត់យ៉ាងណាក៏ដោយ ។ ធម្មជាតិបង្កើតស្រីមកដើម្បីទុកជាគូនឹងបុរស សម្រាប់កាន់ដៃគ្នាទៅអនាគត ។ រឿងស្រីនិងបុរសនេះ គឺជាច្បាប់ធម្មជាតិផ្តាច់ចេញពីគ្នាពុំបាន ។ មានមនុស្សខ្លះ ក្នុងមួយពាន់ បើគ្មានស្រីអាស្រ័យនៃបនិត្យនៅជាមួយទេ មិនអាចធ្វើអ្វីបានទាល់តែសោះ ។

ដូច្នេះ ស្រីជាឧបករណ៍ចាំបាច់សម្រាប់បុរសគ្រប់រូប ។

ព្រះពុទ្ធបរមគ្រូទ្រង់ទេសនាប្រដៅសត្វថា : " ចូរអ្នកពល់គ្នាប្រកាន់យកនូវ មជ្ឈិមាបដិបទា គឺមាគ៌ានេះហើយ ដែលដឹកនាំអ្នកពល់គ្នាឲ្យកាន់កោះត្រើយគឺសុខមង្គល បើអ្នកពល់គ្នាដើរឃ្លាតចាកពីមាគ៌ាដ៏ប្រសើរនេះអ្នក មុខជាជួបប្រទះនូវបរាជ័យ នូវសុខមង្គលដ៏ពិតប្រាកដ ។ យ៉ាងដូចម្តេច មជ្ឈិមាបដិបទា ? គឺកិច្ចប្រព្រឹត្តជាកណ្តាល មិនតិចពេកមិនច្រើនពេក ចុះសេចក្តីថា ធ្វើអ្វីៗ និយមយកភាគមធ្យមជាប្រមាណ ព្រោះអ្វីៗក្នុងលោក សុទ្ធតែមានកម្រិត មានព្រំដែនទាំងអស់ បរិភោគក៏មានកម្រិត ធ្វើការក៏មានកម្រិត សប្បាយក៏មានកម្រិត

កើតទុក្ខក៏ឲ្យមានកម្រិត អំណាចក៏មានកម្រិត ប្រាក់ក៏មានកម្រិត ស្រីក៏មានកម្រិត ៗ ល ៗ អ្វីផងទាំងពួងតែហួសកម្រិតឬហួសព្រំដែន ត្រូវតែផុះ ត្រូវតែបែក ត្រូវតែមិនស្រួល មិនប្រសើរ ត្រូវតែវិនាសហិនហោច ត្រូវតែស្តាយក្រោយ ៗ

ដូច្នេះ ព្រះពុទ្ធទាំងនេះ គាប់ប្រសើរក្រៃលែងសម្រាប់មនុស្សទូទៅ មិនថាជាតិណាឬសាសន៍ណាឡើយ ៗ ព្រះពុទ្ធទ្រង់ត្រាស់បន្ថែមគេទៅទៀតថា៖ សូម្បីអ្នកប្រាជ្ញឲ្យបានដល់នូវអរហត្តមគ្គ អរហត្តផល ជាមហាកុសលជាន់ខ្ពស់បំផុតក្តី ប្រសិនបើមិនប្រតិបត្តិតាមលំនាំមជ្ឈិមាបដិបទានេះទេ ខ្លួនក៏មិនអាចសម្រេចដល់នូវគំនិតប៉ុនប៉ងបានឡើយ ៗ សេចក្តីប្រាជ្ញានោះ ត្រូវតែក្លាយទៅជាអ្វីផ្សេង មានសភាពខុសពីបំណងរបស់ខ្លួន ឬ ដែលនាំឲ្យសាមីជនមានវិប្បដិសារី តែមិនឡើងក៏មាន ៗ

ដូចជាអ្នកត្រូវការទីងអំណាច សេចក្តីរៀបរាប់មកខាងលើ បានបញ្ជាក់ប្រាប់ថា អំណាចជាឧបករណ៍ចាំបាច់របស់មនុស្សក៏ពិតមែន តែបើសាមីជនបង្កើនអំណាចនោះឲ្យមានហួសព្រំដែន ហួសកម្រិត អំណាចនោះត្រូវក្លាយទៅជាទោសចំពោះខ្លួនទៅវិញ ៗ ឧទាហរណ៍មានច្រើនគរគោកស្តីពីរឿងនេះ ៗ ខ្ញុំលើកយកភ្នាក់ងាររដ្ឋការមកពន្យល់ ព្រោះភ្នាក់ងាររដ្ឋការ ចៅសង្កាត់ ចៅហ្វាយស្រុក ប្រមុខខេត្ត ៗលៗ ត្រូវឲ្យមានអំណាចប្រចាំថ្ងៃជានិច្ច បើកាលណាយកអំណាចដែលច្បាប់បានប្រគល់ឲ្យទៅប្រើ ហើយខ្វះក្តីសន្តោស ទៅប្រើអំណាចនោះឲ្យហួសព្រំដែន

ដោយសារតែប្រយោជន៍រួមក្តី ដោយសារតែប្រយោជន៍ផ្ទាល់ខ្លួនក្តីអំណាចដែលខ្លួនមាននោះ នឹងក្លាយទៅជាបិសាចដ៏កាចសាហាវឃោរឃៅ វាយទម្លាក់ខ្លួនឲ្យធ្លាក់ចុះមកពីមុខងារបច្ចុប្បន្នក៏មាន ឲ្យឃាតពីមុខងាររដ្ឋការក៏មាន ឲ្យស្លាប់ខ្លួនក៏មាន ។ អំពីឥស្សរជនជាន់ខ្ពស់បំផុតវិញក៏ដូចគ្នាដែរ គឺថាក្នុងលោកនេះ មិនខ្វះទេប្រមុខរដ្ឋដ៏ច្រើនរូប ដែលត្រូវអំណាចរបស់ខ្លួនវាយបំបាក់ឲ្យធ្លាក់ចុះមកកាន់ទីដ៏ថោកទាបរកកៃមិនទៀងនោះ ។ ប្រមុខរដ្ឋពីអតីតកាលដ៏យូរអង្វែង ដែលត្រូវអំណាចរបស់ខ្លួនរុញច្រានឲ្យធ្លាក់ចុះមកកាន់ទីដ៏ស្មោកគ្រោក ខ្ញុំមិនលើកយកមកពោលក្នុងទីនេះទេ ខ្ញុំសូមលើកយកតែប្រមុខរដ្ឋនាកាលទេសៈបច្ចុប្បន្ន មកជម្រាបជូនដូចតទៅ : ង៉ោ ឌិញយៀម (ប្រទេសយៀកខាងត្បូង) ណាស់គ្រុយម៉ាស់ (ប្រទេសហ្គាណា-ទ្វីបអាហ្វ្រិក) ស៊ីការណូ (ប្រទេសឥណ្ឌូណេស៊ី) ដឺហ្គោល (ប្រទេសបារាំង) សីហនុ (ប្រទេសកម្ពុជា) ។ ប្រមុខរដ្ឋទាំងនេះសុទ្ធតែអំណាចរបស់ខ្លួនរុញច្រានទម្លាក់ពីកៅអីដូចៗគ្នា ព្រោះតែប្រើអំណាចហួសព្រំដែន ។ ត្រង់ចំណុចនេះ មានការណ៍ចម្លែកមួយគួរឲ្យចាប់អារម្មណ៍ គឺថាបណ្តាប្រមុខរដ្ឋទាំងនោះដែលត្រូវធ្លាក់ចេញពីមុខដំណែង ម្នាក់ៗសុទ្ធតែដឹងខ្លួនថា ខ្លួនបានប្រើអំណាចហួសព្រំដែនហើយ ក៏គេនៅស្ងៀមទៅ បណ្តោយទុកឲ្យអ្នកកាន់ការវាងក្រោយរៀបចំស្ថាបនាប្រទេសជាតិ យ៉ាងស្ងៀមស្ងាត់តទៅ ។ ចំណែកប្រមុខរដ្ឋ សីហនុ មិនដូច្នោះ គឺមិនព្រមដឹងខ្លួនខុសទាល់តែសោះ ហើយបែរទៅជា

រំពាវនាវហៅយួនមៀកកុង មៀកមិញ ឲ្យលើកទ័ពមកវាយលុកលុយប្រទេសកម្ពុជា កាប់សម្លាប់ខ្មែរគ្នាឯង ធ្វើឲ្យជនជាតិខ្មែររងទុក្ខវេទនា ប្ដីព្រាត់ប្រពន្ធ ម្ដាយព្រាត់កូន បងព្រាត់ប្អូន ពេញតាំងប្រទេស ។ ប្រមុខរដ្ឋបែបសីហនុនេះ ជាប្រមុខរដ្ឋដ៏ប្លែកគេបំផុតក្នុងសកលលោក រកប្រមុខរដ្ឋណាប្រដូចគ្មាន ។

ព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់សម្ដែងថា: " ជនពាលណាដឹងខ្លួនថាជាពាលពិតនោះ ពាលនោះនឹងក្លាយទៅជាបណ្ឌិតបានខ្លះ ជនពាលណាស្មានខ្លួនឯងថាជាបណ្ឌិត ពាលនោះនឹងនៅជាពាលរហូតតាំងពីចុងជើងរហូតដល់ចុងសក់ មិនអាចកែខ្លួនឲ្យទៅជាបណ្ឌិតបន្តិចបន្តួចបានឡើយ " ។

សូមលោកអ្នកអានទាំងឡាយពិចារណាមើល តើប្រមុខរដ្ឋ សីហនុ ជាជនប្រភេទណា ជាជនគួរសេពគប់កប់អានទៅទៀតឬទេ ? អំពីប្រាក់វិញ ក៏ដូច្នោះដែរ ។ ប្រាក់ពិតជាឧបករណ៍ចាំបាច់សម្រាប់មនុស្សដ៏ប្រាកដមែន តែលុះណាមនុស្សទុកប្រាក់ជាឧបករណ៍ជាទាសៈរបស់ខ្លួនពិត ៗ ។ នៅពេលដែលមនុស្សទុកប្រាក់ជាចៅហ្វាយរបស់ខ្លួន ប្រាក់នឹងក្លាយទៅជាអាសិរពិស ចឹកសម្លាប់ខ្លួនមិនខាន ។ មនុស្សត្រូវការស្វែងរកប្រាក់ដើម្បីទុកជាឧបករណ៍របស់ខ្លួន មនុស្សមិនត្រូវស្វែងរកប្រាក់ឲ្យមានច្រើនហួសសេចក្ដីត្រូវការចាំបាច់នៃខ្លួនឡើយ ។ មនុស្សតែកាលណាបណ្ដោយខ្លួនឲ្យប្រាក់ញាំញីបាន ឲ្យលង់ក្នុងទឹកប្រាក់បាន

ត្រូវតែវិនាសដោយសារប្រាក់នេះដ៏ពិតប្រាកដ ។ ក្សត្រសាមញ្ញក្តី ភ្នាក់ងាររដ្ឋការក្តី ពាណិជ្ជករក្តី អ្នកណា ៗ ក្តី ជាមនុស្សជៀសវាងប្រាក់ពុំរួចឡើយ ។ គេធ្វើអ្វី ៗ ដើម្បីប្រាក់ ព្រោះប្រាក់ជាប្រភពជាមធ្យោបាយដើម្បីញ៉ាំងជីវភាពមនុស្សឲ្យប្រព្រឹត្តទៅបានស្រួល តែត្រូវប្រយ័ត្ន ! ប្រាក់គឺប្រសើរណាស់ ប្រាក់គឺអាក្រក់ណាស់ដែរ គឺថាបើកាលណាមនុស្សពេញចិត្តនឹងប្រាក់ ចូលចិត្តនឹងប្រាក់ ប្រាក់ជ្រុលហួសកម្រិត ជ្រុលហួសព្រំដែន ដែលធម្មជាតិបានកំណត់ទុកឲ្យ មនុស្សត្រូវតែទទួលទុក្ខទោសអំពីប្រាក់ប្រកែកពុំបានឡើយ ។ ប្រាក់នេះវាធ្វើឲ្យមនុស្សឈប់ស្គាល់បងប្អូន ឈប់ស្គាល់ឪពុកម្តាយ និយាយឲ្យខ្លីទៅ គឺឈប់ស្គាល់មនុស្សផងគ្នា ជាទីអវសាន សូម្បីទឹកដីមាតុប្រទេសរបស់ខ្លួន ជាកិត្តិយសធំបណ្តាច់របស់ខ្លួន ក៏មនុស្សលោភប្រាក់ឈប់ត្រូវគិតដល់ ។ អ្នកមានមូនិក ជាប្រពន្ធ សីហនុ ព្រោះតែបណ្តោយខ្លួនឲ្យប្រាក់ញាំញី ឲ្យប្រាក់សង្កត់ជាប់ ឲ្យប្រាក់ធ្វើជាចៅហ្វាយ គិតតែពីដឹកប្រមុះប្តី ឲ្យចុះក្នុងរណ្តៅកក់ជ្រាំ ហើយមិនធ្លាក់តែសីហនុ ខ្លួនឯងក៏ត្រូវទៅជាមួយផងដែរដូចសម្មកម្ពីស ព្រោះតែរឿងប្រាក់នេះ ។ គួរដែរ ឬពុករលួយតែរវាងគ្នាឯងមិនអស់ចិត្តមិនអស់ចង់ ទៅពុករលួយប្រឡាក់ប្រឡូសជាមួយជនបរទេស ដោយបណ្តោយឲ្យយៀកកុង យៀកមិញមកតាំងមូលដ្ឋានទីទ័ពក្នុងទឹកដីជាទីគោរពរបស់ខ្មែរ ដើម្បីធ្វើជាជម្រកអាស្រ័យនៅ ហើយលើកគងទ័ព

ទៅវាយប្រទេសជិតខាងផង វាយខ្មែរផង ព្រោះតែខ្លួនត្រូវការប្រាក់មិនចេះចប់មិនចេះហើយ ការផ្តល់ទឹកដីខ្មែរឲ្យធ្វើជាមូលដ្ឋានទ័ពនេះ មានតម្លៃអនេក គឺស្មើនឹងលក់ប្រទេសជាតិតែម្តង ។ ត្រង់នេះហើយដែលសីហនុត្រូវធ្លាក់ព្រួសពិសរលំធ្លាក់ប្រងាប់ប្រងិលពីកៅអី ដោយទាំងមូនិកជាស្រីកាឡកណ្ណីទៅជាមួយផង ។

ចំពោះមាតុគ្រាមវិញ ក្នុងលោកមានមនុស្សកប់មិនអស់ទេដែលត្រូវវិនាសហិនហោចតែមិនឡើងព្រោះតែស្រីនោះ ។ ខ្ញុំបានពោលរួចហើយថាស្រីជាឧបករណ៍របស់បុរស ក្នុងដំណើរកៀកស្មាគ្នាកសាងជីវិតទៅអនាគត តែបើបុរសល្មោភតណ្ហាល្មោភកាមហួសកម្រិត ស្រីមិនមែនជាឧបករណ៍នៃបុរសទេ គឺឡើងហួស ១ កម្រិតក្លាយទៅជាពស់វែកដីសា ហាវកាចចឹកសម្លាប់បុរសទៅវិញបាន ។ បើបុរសជាមនុស្សសាមញ្ញ គឺត្រូវវិនាសចំពោះតែខ្លួនឯង ឬ គ្រួសារខ្លួនប៉ុណ្ណោះ បើបុរសជាឥស្សរជនកំពូល គឺមិនស្លាប់តែខ្លួនឯងម្នាក់ទេ រមែងដឹកនាំប្រមូលអ្នកដទៃកប់មិនអស់ឲ្យអន្តរាយដោយសារផងដែរពិតប្រាកដ ។ ប្រវត្តិកប់មិនអស់ ទាំងអតីតកាលទាំងបច្ចុប្បន្នកាល ស្តីពីបុរសត្រូវវិនាសខ្លួន អន្តរាយជីវិត ក្រុមគ្រួសារជនរួមឈាមព្រមទាំងផែនដី ដោយសារតែរឿងស្នេហានេះ ។ យើងគ្រប់គ្នាធ្លាប់បានដឹងអស់មកហើយនូវរឿងនេះ ៖ ក្នុងបុរាណកាល ព្រះរាមព្រះល័ក្ស្មណ៍និងក្រុងរាពណ៍ ត្រូវចំណាយពលរេហ៍អស់ប៉ុន្មាន

ដើម្បីច្បាំងដណ្ដើមយកនាងសីតា មានយុទ្ធជនដ៏ច្រើន ក្នុងបច្ចុប្បន្នសម័យត្រូវខាតរៀនសូត្រ ព្រោះបង់វិជ្ជាសម្រាប់គាត្នា និងស្លាប់គាយហោងព្រោះតែរឿងស្រី ៗ ប្រមុខរដ្ឋសីហនុ ត្រូវគេទាញទម្លាក់ពីតំណែង ក៏ព្រោះតែស្រីមូនិក ៗ

រួមសេចក្ដីទៅ វត្ថុទាំងបី គឺ "អំណាច-ប្រាក់-ស្រី" ជាប្រភពនៃសេចក្ដីវិនាសអន្តរាយតែមិនទៀង បើកាលណាហើយយើងមិនមានក្ដីសន្ដោសក្នុងការប្រើវត្ថុទាំងនេះ ៗ អ្វី ៗ តែស្រួលណាស់ ល្អណាស់ ប្រពៃណាស់ សប្បាយណាស់ រីករាយណាស់ តោងតែប្រយ័ត្ន លោតែយើងភ្លេចខ្លួន ស្រាប់តែក្រឡះខ្វាប់ប្រែទៅជាព្រួយណាស់ អាក្រក់ណាស់ លាមកណាស់ ខ្ចួញសោកណាស់ គក់ទ្រូងសុបសៅណាស់ យំលែងបញ្ចេញទឹកភ្នែកតែម្ដង ៗ ដល់ត្រង់នេះគឺចប់ក្បួនស្រេច ៗ

ថ្ងៃទី ៦-៦-៧,

ដេខ-ជ្រីច

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ - កាន

ប្រែ - រៀបរៀង

(ក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសទើបបានអាន
> នឹងចេះឧបាយកលចំណាន ទាំងមានសត្តនេហាជាតិ
>
> យូរ-អ៊ុន

## សាមកុកខ្សែ ៣៦

តាំងពីព្រះចៅស៊ុ គួន បានរាជាភិសេកជាបរមក្សត្រិយ៍ក្នុង ព.ស. ៧៧២ ស្រុកទាំង ២ គឺស្រុកសៃឈួន និង ស្រុកកាំងតាំងបងស្តានមេត្រី, ហោកជៀវឈីស្លាប់, ខុងបេងលើកទ័ពទៅវាយបន្ទាយតាន់ផង បាន, រហូតដល់ស៊ុមាអ៊ីបាញ់កលខុងបេង, ទៀវចៅ ឈីស្លាប់ដោយរបួសធ្លាក់ពីលើសេះ ខុងបេងយំសោកអាល័យតាំងតែពួតធ្លាក់ឈាមទៅជាឈឺជាប់ លើកទ័ពថយទៅស្រុកសៃឈួន ពេទ្យមើលសះជាវិញ ។

---

*ខណៈមានពួកល្បាតសេះ នាំយកពត៌មានទៅក្រាបទូលព្រះចៅស៊ុនគួនថា: ខុងបេងលើកពលទាហានទៅធ្វើការសង្គ្រាម និង ចូជនសម្លាប់ពលទាហានព្រះចៅចូយ៉យស្លាប់វិនាសច្រើនណាស់ ឥឡូវនេះលើកទ័ពត្រឡប់ទៅស្រុកហានតុងហើយ អស់មុខមន្ត្រីទាំងឡាយក៏ថ្វាយបង្គំទូលតបព្រះរាជឱង្ការថា: ឯទាហានក្នុងស្រុកឡុងសៀងនោះ សុទ្ធតែមនុស្សអស់កម្លាំងគ្រាំគ្រាខ្ទួកខ្ទួរណាស់, ព្រោះខុងបេងធ្វើទ័ពបុកម្តេញ*

ខ្ទេចខ្ទីអស់យូរមកហើយ, មួយទៀត ខ្ញុំបានគិតថាស្រុកសៀមនឹងក៏លើកគ្រឡប់មកវិញ ព្រោះធ្វើការនោះមិញបានប្រៀប, សូមព្រះអង្គទ្រង់ធៀបមើលចុះ ស្រុកឡុកអៀងខាងណោះទន់ដៃជាងគេ, គួរយើងនិងរិះរកលើកទ័ពទៅវាយដោយពេលនេះតាហានក៏ពុំបែកខ្ញែកគ្នា, ព្រះចៅស៊ិនគួនក៏ពុំមានថាដូចម្តេច ។

ទៀងជៀវក្រាបទូលថា: វេលានេះស្រុកកាំងតាំងមានហ្វូងហង្សហើរចូលមកយំគ្រប់វេលា ទាំងមករកសម្តែងវិញានុភាពក្នុងផ្ទៃមហាសមុទ្រជាអស្ចារ្យ ហាក់បីដូចទីងប្រាប់ថា ទេសកាលនេះជាសិរីមង្គលដ៏ប្រសើរយ៉ាងឯក, សូមព្រះអង្គទ្រង់ឲ្យរៀបពិធីរាជាភិសេកឲ្យស្រេចការ រួចហើយសឹមលើកពលយោធាទៅវាយយកស្រុកឡុងអៀងចុះ ព្រះចៅស៊ិនគួនក៏យល់ថាត្រូវ ។

លុះដល់រដូវខែផល្គុន (ព.ស. ៨៧៦) ពួកមន្ត្រីនិងរាស្ត្រប្រជាក៏ស្រុះគ្នារៀបការរាជាភិសេកព្រះចៅស៊ិនគួនព្រមស្រេចគ្រប់ប្រការ តាមសណ្តាប់បុរាណាចារ្យពីដើម តាំងព្រះអង្គទ្រង់សោយរាជសម្បត្តិក្នុងចង្វាត់ដែនស្រុកកាំងតាំង ក្នុងថ្ងៃសុភមង្គលឫក្សនោះ ព្រះអង្គទ្រង់ប្រារព្ធចំពោះតាំងស៊ិនគេងជាព្រះរាជទេវសមកុដរាជកុមារ តាំងជូកាត់ចេកប៉ុក្រោជូកាត់កិចជាសេនាបតីស្តាំ តាំងខ្យៀងហ៊ាង បុត្រទៀងជៀវជាសេនាបតីឆ្វេង ឲ្យជួយទំនុកបំរុងតាក់តែងព្រះរាជទេវសតាមប្រពៃណី ។

ឯជូកាត់បេកនោះ ព្រះចៅស៊ិនគួនមានព្រះទ័យប្រោសប្រាណស្រឡាញ់ណាស់ ព្រោះកាលនៅពីតូចអាយុ ៦ ឆ្នាំ ជូកាត់គិននាំចូលទៅស៊ីលៀងក្នុងផ្ទៃព្រះរាជ ព្រះចៅស៊ិនគួនទតឃើញទ្រង់មុខជូកាត់បេកវែងស្រួងដូចមុខជាវទេព្យ ក៏ចាប់យកទេព្យមួយទៀតមកចារឹកអក្សរនៅមុខទេព្យនោះថាជូកាត់បេក ។ អស់នាម៉ឺនព្រះញាក៏នាំគ្នាសើចចំអន់ ជូកាត់បេកក៏គិតខាន់ ក្រោកស្ទុះទៅយកពិធមកសរសេរអក្សរនៅដើមបន្ទាត់ជាអក្សរ ២ តួទៀតថា ទេព្យរបស់ផ្សេងគ្នាថាជាទេព្យរបស់ជូកាត់បេក អស់នាម៉ឺនឃើញដូច្នោះក៏គិតគ្នាថា ជូកាត់បេកជាអ្នករហ័សឆ្លាតក៏នាំគ្នាអួតសរសើរ ព្រះចៅស៊ិនគួនក៏មានព្រះទ័យករុណាស្រឡាញ់ប្រោសប្រាណតាំងពីនោះមក ទើបតាំងឲ្យធ្វើជានាម៉ឺនខាងមុខ ។

លុះព្រះចៅស៊ិនគួនឲ្យរៀបចាត់ការរាជាភិសេក ស្តេចក៏បង្គាប់ឲ្យកេណ្ឌពលទ័ពចូលមកកុំគ្នានឹងលើកទៅវាយយកស្រុកឡុងអៀង, ទៀវជៀវក៏ទូលឃាត់ថា: ព្រះអង្គទើបនឹងទ្រង់បានរាជាភិសេកថ្មី ។ មិនគប្បីលើកកងទ័ពទៅច្បាំងនឹងសត្រូវដូច្នោះទេ, គួរតែគង់ប្រថាប់ឲ្យជាប់នៅក្នុងព្រះរាជវាំងសិន ដើម្បីនឹងហាត់ប្រៀនពួកទាហានឲ្យចេះធ្លុងប៉ិនប្រសប់ហើយតាំងព្រះទ័យ [illegible] តែរាប់អានស្រុកសែ:ឈ្មួនឲ្យជាសម្ពន្ធមិត្រនឹងគ្នា, បើកាលណាបានព្រមព្រៀងតាំងសងទង់ហើយ សឹមលើកទៅប្រមូលបញ្ចូលគ្នាលើកទៅច្បាំងសង្គ្រាម កម្ចាត់សត្រូវវាយយកស្រុក ឡុងអៀង ទើបបានផ្ដាយឆាយ ។

ព្រះចៅស៊ិនគួនក៏យល់ឃើញត្រូវផង, ទើបចាត់ឲ្យបម្រើនាំព្រះរាជសាសន៍ទៅថ្វាយព្រះចៅឡៅសៀនឯស្រុកសៃឈួន នោះព្រះចៅឡៅសៀន ឲ្យប្រជុំអស់មុខមន្ត្រីចូលទៅប្រឹក្សា, អស់នាម៉ឺនក៏ក្រាបទូលថា: ដែលនឹងចងស្ពានមេត្រីនឹងផែនដីស្រុកកាំងតាំង ដើម្បីនឹងជួយច្បាំងកម្ចាត់សត្រូវនោះ. គួរតែពិគ្រោះនឹងខុងបេងជាធំសិន, ព្រះចៅឡៅសៀនក៏យល់ឃើញត្រូវ ទើបត្រាស់ប្រើនាម៉ឺនធំឲ្យនាំព.រ.សារនោះ ទៅប្រឹក្សានិងខុងបេងឯស្រុកហានតុង ។

ខុងបេងដឹងការហើយក៏ឆ្លើយទូលតបថា: ដែលស្រុកសៃឈួននិងស្រុកកាំងតាំង តាំងនៅក្នុងផ្ទៃផែនដីជាមួយគ្នានោះក៏គួរណាស់ តែថាវេលានេះព្រះចៅស៊ុនគួន ទើបនឹងបានរាជាភិសេកថ្មី ។ សូមព្រះអង្គទ្រង់ព្រះរាជមេត្រីឲ្យតែងគ្រឿងបណ្ណាការទៅថ្វាយព្រះចៅស៊ុនគួន ហើយស្ដាប់កិត្តិសព្ទមើលតាមប្រពៃណីផែនដីសិន, បើព្រះចៅស៊ុនគួនប្រាកដជាចងស្ពានមេត្រីនឹងផែនដីយើងពិតហើយ ក៏ត្រូវធ្វើកត្តិកាបដិញ្ញាឲ្យបានពេញជាសក្យានុសក្យទុក តទៅឯមុខក៏ប្រែប្រួលទៅវិញបាន ។

ព្រះចៅឡៅសៀនយល់ឃើញត្រូវ ទើបឲ្យតែងទូតព្រះរាជសាសន៍ជាផ្លូវព្រះរាជមេត្រីទៅវិញទៅមក ហើយធ្វើគ្រឿងរាជបណ្ណាការទូវគ្រឿងយសរបស់ទ្រព្យដ៏មានតម្លៃ ឲ្យគាន់ជិះនាំទៅថ្វាយព្រះចៅស៊ុនគួន ។ ក៏មានព្រះទ័យសោមនស្សឲ្យលោះងព្រះស្លៀកដបម្រើ ដោយគ្រឿង

គោជនាហារតាមបុរាណរាជប្រវេណី រួចតបថ្វាយគ្រឿងបណ្ណាការខ្លះ ព្រះរាជសាស្ន៍ ដែលជាខ្នួសញ្ញាអំពីផែនដីទាំងពីរ ជាមេត្រីនឹងគ្នា, ប្រគល់ឲ្យគាត់ជំនាំសារទៅថ្វាយព្រះចៅឡាវសៀនវិញ ហើយព្រះចៅស៊ិនគួនក៏ប្រឹក្សាខឹងឡុងស៊ិន ១ ក្រាបទូលថា: ដែលព្រះចៅឡាវសៀនមកបានជាត្រឹមតែនឹងផែនដីយើងនេះក៏ព្រោះតែនឹកខុនបេនខ្លាចសុមាំ-អ៊ុំបានជាមកធ្វើមេត្រីនឹងយើង, ការរបស់យើងក៏ត្រូវធ្វើឲ្យបានជាផ្លូវមេត្រីកុំឲ្យបាត់តាមសញ្ញា, ត្រូវតែឲ្យដំណើរតបទៅស្រុកសែលឈូនថា: យើងនឹងលើកទ័ពទៅវាយស្រុកឡុងអៀង ឲ្យខុនបេនលើកទ័ព ១ កងទៅជួយមុខជាសុមាំអ៊ុំនឹងចេញមកតស៊ូខាងខុនបេនជាប្រាកដ ឯខាងយើងនឹងលបលើកចូលទៅវាយយកស្រុកឡុងអៀងតែម្តង គង់បានដោយងាយ, ព្រះចៅស៊ិនគួនក៏យល់ឃើញត្រូវ ទើបចាត់បម្រើឲ្យនាំព្រះរាជសាស្ន៍ទៅថ្វាយព្រះចៅឡាវសៀន ហើយឲ្យកេណ្ឌទ័ពទុកសម្រាប់ព្រមគ្រប់គណាខែត្រ ៗ

ឯព្រះចៅឡាវសៀនបានទទួលព្រះរាជសាស្ន៍ដឹងការហើយ ក៏ត្រាស់ឲ្យទៅប្រាប់ខុនបេន ១ ក៏មានសេចក្តីព្រួយណាស់, គិតថាដំបន់តាខងនោះ, បើនឹងលើកទ័ពទៅក៏ឃើញថាជាទីចង្អៀតណាស់, ទើបចាត់មនុស្សឲ្យទៅស៊ើបល្បាតមើលឲ្យដឹងជាជាយ៉ាងម្តេច, បម្រើល្បាតស៊ើបដឹងការថា: ពៃជៀវឈឺធ្ងន់ ខុនបេនក៏មានព្រួយណាស់, ទើប

ចាត់ឲ្យ ស៊ុយអៀនទិនកៀនស៊ុយ ទាំង ២ នាយឲ្យទាហាន ៥.០០០, បង្គាប់ ដាក់កំហិតឲ្យលើកចូលទៅប្រជិតដល់ទីជើងកំពែងបន្ទាយតាន់ធន, បើឃើញពន្លឺភ្លើងឆេះឡើងកាលណាឲ្យសន្ធុញពលយោធាចូលទៅ, ហើយអ្នកទាំង ២ ត្រូវស្រូតរូតទៅក្នុងវេលា ៣ ថ្ងៃឲ្យបានការ កុំបាច់វិលមកលាយើងឡើយ, ស៊ុយអៀនទិនកៀនស៊ុយឮហើយក៏គំនាប់លាចេញទៅរៀបពលយោធា លើកទៅ, ខុងបេងក៏ប្រុងប្រៀបរៀបកងទ័ពហើយប្រាប់ឲ្យគួនហ៊ិនទិនឡេវប៉ៅចូលមកខ្សឹបប្រាប់ពត៌មាន ឲ្យចេញទៅធ្វើការជាសេចក្តីស្ងាត់ ឲ្យត្រៀមពលណាក់ទុកឲ្យព្រម ។

ឯកោឈុយនិងទៀវខាប់ ដែលចូជិនឲ្យនៅរក្សាគយនៅទីនោះ, លុះដឹងថា : ហោតជៀវឈើធ្ងន់ចុះ ក៏ប្រឹក្សាគ្នាឲ្យទៀវខាប់នាំកងទ័ពចំនួនពល ៣.០០០ លើកទៅនៅក្រោយជុំគ្នាខធន ។

ខណៈនោះ, ខុងបេងកាលដែលប្រើគួនហ៊ុនទិនឡេវប៉ៅលើកទ័ពទៅហើយ, ក៏ប្រមូលរេហ៍ពលលើកស្រូតកាត់ផ្លូវទៅដល់ទ័ពតាន់ធនយ៉ាងប្រញាប់ មុនកងទ័ពស៊ុយអៀនទិនកៀនស៊ុយលើកទៅ, លុះត្រូវពេលកណ្តាលយប់បានចំណាប់កាលណា ក៏ឲ្យទាហានបន្ទុំចូលទៅក្នុងកំពែងបាន, ហើយដុតភ្លើងឆេះឡើង, ខុងបេងក៏ឲ្យទាហានស្នូរស្រែកព្រមគ្នាចូលទៅក្នុងកំពែង, ហើយទន្ទ្រាមដេញកាប់ទ័ពខ្មាំងជាខ្លាំងផ្ទួលប្រចល់ទាហានខ្មាំងក្នុងកំពែងមិនបានដឹងកល ក៏ភ័យរបស់មហិមា នាំគ្នាផ្អើល

ក្បាក់តែប្រពាក់ប្រពូនចេញពីកំពែងបន្ទាយ, ត្រឹមតែបាក់ឆ្ងាយជាន់គ្នាស្លាប់ទីងគណនារាប់ពុំបាន, ឯហេកជៀវក៏មានអាការជម្ងឺកាន់តែធ្ងន់ចុះទឹងក្រោកដោះពុំបានក៏ធ្វើកាលកិរិយាទៅ ។

ឯអ៊ុយអៀនទិងគៀងអ៊ុយ ចំស្រូតលើកទ័ពទៅដល់ដំបន់គាន់ចង, ឃើញស្ងាត់ឈឹងពុំមានទាហានផង់នៅលើសើនបន្ទាយ, ក្រឡេកទៅឃើញពីនាយជាគួអក្សរតារីកស្រុកសែឈួនទៅទង់ជ័យដោតលើកំពែង ក៏ឲ្យពិកាល់ក្នុងចិត្តណាស់, បានព្រួសម្តេងខុងបេងស្រែកចេញមកថា ហេតុដូចម្តេចក៏បានជាអ្នកទាំង ២ នៅយឺតយូរម្ល៉េះ ? អ៊ុយអៀនទិងគៀងអ៊ុយបានព្រួសម្តេងខុងបេងស្រែកដូច្នោះ, ក៏ឲ្យតក់ស្លុតក្នុងវិញ្ញាណ, ញាក់សេះបំពានទៅជិត ហើយក៏នាំលោកចុះលុតជង្គង់គំនាប់, ខុងបេងក៏បង្គាប់ទាហានឲ្យបើកទ្វារទទួលចូលទៅ អ៊ុយអៀន, គៀនអ៊ុយគំនាប់ខុងបេងហើយ ទើបជម្រាបសួរថា ៖ មហាឧបកដធ្វើប្រការម្តេចទើបបានមកដល់ដំបន់គាន់ចងនេះជាមុនអស់យើងខ្ញុំទៅទៀត ។

ខុងបេងតបថា ៖ យើងបានដឹងច្បាស់ថាហេកជៀវឈឺធ្ងន់, បានជាប្រគល់ទាហានឲ្យអ្នកទាំង ២ លើកស្រូតមកប្រញាប់, ប្រាថ្នាទឹងឲ្យព្រួកិត្តិសព្ទទៅដល់ហេកជៀវឲ្យប្រុងការពារកងទ័ពអ្នកឯងខាងណោះ, ឯខ្លួនយើងក៏លើកស្រូតកាត់ទម្លុះផ្លូវតូចមកបង្ខំ, ចូលអុជបន្ទាយឲ្យឆេះឡើង, ហើយចូលចោមរាយបន្ទាយបំបែកបានដោយងាយ, អ៊ុយអៀន,

ទៀនអ៊ុយឮដូច្នោះ ក៏សរសើរថា : មហាឧបភជអាចចេះកលឧបាយ ដូច្នេះ ហាក់ដូចជាទេវតា ។

ខុងបេងថា : ដែលយើងលើកទ័ពមកវាយបានដំបន់តាន់ឆងនេះ ហើយ ក៏គង់នៅគិតធ្វើការតទៅទៀត, បើនឹងបង្អង់ឲ្យយឺតយូរក៏មិនបាន, ព្រោះសត្រូវដឹងខ្លួនប្រាណទីរ៉ប្រុងប្រយ័ត្នការ ពលសេនារបស់យើងក៏ធ្វើបានដោយលំបាកណាស់, ហេតុនេះកុំឲ្យអ្នកទាំង ២ បង្អង់យូរឡើយ គួរហើយនឹងចំស្រូតរូតលើកទៅវាយបន្ទាយសានគួនកុំឲ្យសត្រូវដឹងខ្លួនទាន់ អ៊ុយអៀននិងទៀនអ៊ុយគំនាប់ហើយ ក៏លើកទ័ពចេញទៅ ឯពួកគយសាន់គួនមិនទាន់នឹងត្រៀមទ័ពសោះ លុះឃើញទាហានសត្រូវលើកទៅដល់តក់ស្លុតនឹកភ័យណាស់ នាំគ្នាប្រះរត់ចោលគយទាំងអស់ អ៊ុយអៀន ទៀនអ៊ុយ ក៏លើកទាហានទន្ទ្រានចូលទៅក្នុងទីបន្ទាយគយសាន់គួនបាន ទទួលកងទ័ពឡេវខាប់លើកមកដល់ ដឹងថាគយសាន់គួនខូចបានទៅសត្រូវហើយ ក៏ថយទ័ពលើកត្រឡប់ទៅក្រោយវិញ អ៊ុយអៀន ទៀនអ៊ុយ ឃើញទាហានបានចំណាប់ដូច្នោះមិញ ក៏លើកដេញទ័ពស្កាត់វាយបណ្ដោយទៅ សត្រូវទាំងនោះក៏ស្លាប់វិនាសច្រើនណាស់ ក៏ប្រះរត់បែកខ្ចាត់ខ្ចាយទៅទាំងអស់ ។

អ៊ុយអៀន ទៀនអ៊ុយ ក៏ចាត់បម្រើនាំសំបុត្រមកទៅដល់ខុងបេង ។ ក៏ចូលរៀបលើកទ័ពប្រញាប់ទៅបោះនៅដំបន់ក្នុគីសាន ហើយទើបប្រើក្យា

និងនាយទ័ពនាយកងទាំងពួងថា : តាំងពីយើងលើកមកធ្វើការនៅដំបន់ក្តុំគីសាននេះ, ក៏ជួសការគ្រឡប់លើកទ័ពចេញចូលពីរសាហើយ មិនដែលឆ័យជម្នះសោះ, គ្រានេះយើងធ្វើការសមដូចគំនិតគិតហើយ, មុខជាសុមាអ៊ីសម្គាល់ថា គ្រានេះយើងលើកចូលទៅតាមផ្លូវស្រុកប៉ៃសៀនិងស្រុកយន់ដីរ, មិនលែងនឹងលើកទ័ពមកស្ទាក់ត្រង់ផ្លូវនោះ ចាំរង់ស្ទាក់កម្ចាត់ទ័ពយើងដូចកាលពីគ្រាដំបូង, បើប្រសិនយើងនឹងទៅតាមផ្លូវនោះក៏មិនស្រួល, គួរតែនឹងលើកទៅតាមផ្លូវស្រុកអ៊ឹមបុង ប៉ូតៅ ដើរចៀសប្រថុលចូលទៅវាយយកស្រុកអ៊ឹមបុង ប៉ូតៅ ឲ្យបានជាមុនសិន ប្រសិនបានស្រុកទាំង ២ ដំបន់នេះកាលណា ក៏មុខជានឹងធ្វើការស្រួលរហូតទៅបានដល់ស្រុកឡុកអៀង តើនរណានឹងទទួលភាសាទៅធ្វើការគ្រានេះបាន ។

កៀងអ៊ុយនិងអងបុងក៏ឆ្លើយជម្រាបខុងបេងទទួលខ្ជនថា : យើងខ្ញុំនឹងសុំភាសាទៅឯង ខុងបេងមានអំណរណាស់ ទើបចាត់ពលឲ្យយ៉ាងហើស ក្នុងម្នាក់ពល ១០.០០០ កំណត់ឲ្យកៀងអ៊ុយលើកទៅវាយយកស្រុកប៉ូតៅ ឲ្យអងបុងទៅវាយយកស្រុកអ៊ឹមបេង ទាំង ២ នាយក៏គំនាប់លាលើកទ័ពចេញទៅ ។

ឯខ្សេវខាប់នោះ លុះបានលើកទ័ពទៅដល់ស្រុកឡេងកាន់ បានដឹងដំណឹងច្បាស់ក៏ជម្រាបប្រសាសន៍ កោឈុយថា : គ្រានេះកងទ័ព

ស្រុកសៃឈួនលើកមកយកបន្ទាយគាន់ជងបានហើយ ឯហោកដៀវក៏ទទួលអនិច្ចកម្មទៅទៀត គងវ៉ីកទៀវឈ្មោះហានគួនក៏បានទៅសត្រូវអស់ ឥឡូវនេះខុងបេងលើកទ័ពធំមកតាំងនៅជំបន់កិគីសាន គោឈុយឮដូច្នោះ ក៏ធ្វើសំបុត្រមកក្រាបបង្គំទូលព្រះចៅចូយ៉យ ហើយទើបប្រឹក្សាគ្នាថា : កងទ័ពខុងបេងគ្រានេះ មុខជានឹងលើកមកផ្លូវស្រុកប៉ុសៀ និងស្រុកយង់ជីវជាប្រាកដនឹងទុកចិត្តមិនបាន ទើបតាក់ឡេវខាច់ឲ្យនៅរក្សាស្រុកឡេងគាន់ ឲ្យស៊ុនឡេះទៅរក្សាស្រុកយង់ជីវ ឯខ្លួនគោឈុយឯង ក៏លើកពលទៅការពារស្រុកប៉ុសៀ ។

ខណៈនោះ ព្រះចៅចូយ៉យបានជ្រាបតាមសេចក្ដីសំបុត្រមកហើយ ក៏ទ្រង់ព្រះវិតក្កណាស់ ទទួលធះខនាម៉ឺននាំពតិមានទៅក្រាបទូលថា ៖ ឥឡូវស្រុកកាំងតាំង និង ស្រុកសៃឈួន ជាសម្ពន្ធមិត្រនឹងគ្នាហើយ គិតគ្នានឹងលើកកងទ័ពសន្ធប់គ្នាមកប្រទូសរ៉ាយស្រុកយើង ឯឡុកស៊ុនក៏ត្រៀមពលទាហានជាស្រេច គុំនឹងលើកទ័ពប្រសព្វចូលមកក្នុងរវាង ២ ថ្ងៃ ឬ ៣ ថ្ងៃនេះហើយ ។

ព្រះចៅចូយ៉យទ្រង់ព្រះសណ្ដាប់ក៏ថប់ព្រួយក្នុងព្រះទ័យ ទើបត្រាស់ថា : បើវិតេះគេទាំងពីរស្រុក នឹងលើកទ័ពមកសម្រុកធ្វើទុក្ខយើង ៗ មិនលំបាកណាស់ទៅហើយ ឬ ? សុម៉ាអ៊ីទូល ថា : ព្រះអង្គកុំទ្រង់វិតក្កឡើយ ព្រោះស្រុកកាំងតាំងមិនប្រុងនឹងមកប្រទូសរ៉ាយយើងទេ គេនឹងគេទៅតើ

ជាសត្រូវនឹងគ្នា ខុនបេងគិតតែចង់រកតាំងពីគ្រាដំបូងហៅគេមិនទាន់ លុបគំហឹង ឥឡូវខុនបេងបារម្ភ ខ្លាចក្រែងទ័ពយើងនឹងលើកទៅវាយ ស្រុកសៃឈួន ខ្លាចស៊ិនគួនក្លាយបណ្ដាយពីក្រោយយើង បានជា ក្លែងតាក់តែងមនុស្សឲ្យទៅប្រចុបប្រចែងស្រុកតាំងតាំងជាផ្លូវមេត្រីគ្នា ឯ ស្រុកតាំងតាំងក៏ក្លែងសេចក្ដីធ្វើឲ្យស្ដាប់ចិត្តទេ ។ តែកុំឲ្យខ្លាស ដែល ឡូកស៊ិនបានប្រកាសប្រមូលពលទុកបម្រុងការពារម៉េះ សំណោះនឹងឲ្យ ខុនបេងជឿទុកពោះជាស្មោះត្រង់ប៉ុណ្ណោះ ដែលពិតនោះគឺឡូកស៊ិនក្លែង ទេ បើខុនបេងធ្វើការគេតាំងបក្ខនឹងយើងថ្ងល់ថ្លាយវេលាណា មុខ ជាឡូកស៊ិនឧឹងស្រវាត្រូតខានចុងថៃ សូមព្រះអង្គទ្រង់កុំព្រួយព្រះទ័យ នឹងកងទ័ពស្រុកតាំងតាំងនោះធ្វើអ្វី ។

ព្រះចៅចូយ៉យបណ្ដាយថា អ្នកនិយាយនោះគួរស្ដាប់ណាស់ ឃើញ ថាមានប្រាជ្ញាដែលចេះចៀគផ្ទាស់ដ៏សុខុម គឺជាអ្នកបានចេះដឹងធំហួត ទៅបាន, ខណៈនោះ ព្រះចៅចូយ៉យ ក៏តាំងសុមាត់ឲ្យពេញទ័ជាមេទ័ព ដ៏ចម្បងបំផុត ឲ្យតាំងអាជ្ញាសិទ្ធិគ្រប់ប្រការ សុខាត់ទទួលព្រះរាជទ្រង្គារក្រា តាំងហើយ ក៏ថ្វាយបង្គំលាចេញមករៀបប្រមូលពលយោធានឹងលើក ចេញទៅ, លុះលើកទ័ពទៅដល់ស្រុកឡេងអាន់ ក៏ចាត់ទៀវទាប់និង តៃឡេងឲ្យនាំពល ១០ មុឺនទៅក្ដីសាន ចាំទទួលតហានទ័ពខុនបេង ៗ

កោឈុយ, ស៊ិនទៀ លុះដឹងដំណឹងថា : ស៊ុម៉ាអ៊ុ លើកទ័ពមក បញ្ឈប់នៅគីតិសាន ខ្លួនស៊ុម៉ាអ៊ីនៅស្រុកទៀងអាន ក៏នាំគ្នាស្រែងទាន់ លើកទៅគេស៊ុម៉ាអ៊ុ ។ ក៏សួរថា : ដែលអ្នកទាំង ២ បានទៅឈររក្សា ស្រុកទាំង ២ ដំបន់នោះ បានគេតាំងបញ្ជាំងទីជំរុំរបស់ខ្លួនដែរឬទេ ? កោ-ឈុយនិងស៊ិនទៀឆ្លើយជម្រាបថា ៖ យើងខ្ញុំទាំង ២ បានទៅតាំងទ័ពនៅ ដំបន់នោះ មិនបានប្រទះឃើញទ័ពខុងបេងលើកមកបញ្ជាំងទេ ស៊ុម៉ាអ៊ីសួរថា : បណ្តាអាណាខេត្តទាំងពួងនោះ អ្នកឯងដឹងថា នរណាអាក្រក់ល្អដូច ម្តេចខ្លះ ? ។

កោឈុយ ស៊ិនទៀឆ្លើយថា : អាណាខេត្តធំៗនោះ យើង ខ្ញុំដឹងដំណឹងជាល្អទាំងអស់ តែចំប៉ូគៅនិងអ៊ឹងប៉េងទាំង ២ អន្ទេរនេះ មិន បានឮដំណឹងជាយ៉ាងណា ស៊ុម៉ាអ៊ីថា : បើដូច្នោះ អ្នកឯង ២ នាក់ ចូរនាំពលម្នាក់ ១.០០០ លើកទៅរក្សាស្រុកនោះឲ្យធាប់ចុះ កុំបីឲ្យមាន អន្តរាយ បើអ្នកឯងបានចាត់ការរក្សាទីទាំងឡាយខ្ជាប់ខ្ជួនមាំហើយ ត្រូវជួយគ្នាស្កាត់ខ្ទាត់ទ័ពខុងបេង តាំងពីខាងក្រោយឲ្យរារាំងគេតាំង ដើម្បីយើងនឹងធ្វើចម្បាំងចាប់យកខ្លួនខុងបេងឲ្យបាន ។

កោឈុយ ស៊ិនទៀ ក៏គំនាប់លាស៊ុម៉ាអ៊ីលើកពលចេញទៅ លុះទៅ ដល់កណ្តាលផ្លូវ មានល្បាតសេះមកប្រាប់ថា : ស្រុកប៉ូគៅនិងស្រុកអ៊ឹម-ប៉េង ទ័ពខុងបេងវាយយកបានទៅហើយ ឥឡូវស្រែវលើកពលមកនៅ

ក្រៅស្រុក ចម្ងាយផ្លូវប្រហែល ១៥០ សិន (៦ គម) កោឈុយ ស៊ិនឡេ ឮដូច្នោះក៏ភ័យណាស់ ទើបប្រឹក្សាគ្នាថា ៖ កងទ័ពស្រុកសៀមឈ្នួនលើក មកវាយស្រុកយើងទាំង ២ បានហើយ ហេតុម្តេចក៏ទៅជាលើកពល ចេញមកនៅក្រៅស្រុកវិញដូច្នេះជាការប្លែកណាស់ ប្រហែលវាក្លែងកល ឧបាយបញ្ឆោតយើង ។ ខឹងកន្ទួនចូលទៅម្តេចបាន ទើបនាំគ្នាលើកពល យោធាត្រឡប់មកវិញ ប្រាប់ឱ្យពួសមេ្ងជាវអុចលើកពួលកុំវាំង ២ នាយ កំស្តុករទូកស្ពាកក្រឡេកទៅឃើញខុនបេងកែងខ្លួនស្អកហ្វាក កាន់ផ្តុក ភេមសត្វ ជិះរទេះតូច តួនហ៊ុន ទៀរចៅកាន់ក្របីដើរឆ្វេង·ស្តាំ លើកពលប្រចាំស្ពាក់ពីវផល់ដើងក្នុ កោឈុយ ស៊ិនឡេ ក៏ស្ងាំងកាំង នៅទីនោះ ។

ខុនបេងស្រែកថា : គាថាយទាហាន ២ នាក់កុំតែឲ្យពិបាកឡើយ ត្រូវចូលមកគំនាប់អញតាមសុភាពចុះ ឯកលរបស់ស៊ុមាអ៊ីនោះកន្ទុំអញ មិនបានទេ អញដឹងដល់អស់ហើយ បើឯងមិនចូលមក អញនឹងឲ្យ ទាហានព្រួតចាប់ខ្លួនយកសម្លាប់ឥឡូវនេះ កោឈុយ ស៊ិនឡេក៏ខ្លាច ពន់កម្លាំងញាក់សេះទីងរត់ ទទួលអងបេង កៀនអ៊ុយលើកទាហាន ព័ទ្ធស្ពាក់ពីក្រោយចូលមក កាប់សម្លាប់ទាហានស្លាប់ច្រើនជេរជាស លោកតោលសេះរត់ឡើងទៅលើភ្នំ ទៀរចៅក៏បំបាយសេះដេញប្រូងទីង ចាប់យកខ្លួន ប៉ុន្តែសេះទៅជាយកម្លាំងជាន់លើថ្មរអិលភ្លាត់ធ្លាក់ពីលើ

សេះសន្ទប់ចុះ ទៀតចៅក្រានោះក៏ធ្លាក់ទៅត្រូវមុខលើថ្មបែករបួសជាទម្ងន់ ពួកទាហានក៏ស្ទុះចូលទៅទន្ទ្រានគ្រាហ៍នាំខ្លួនយកមក កោឈុយ ស៊ិន. ទៀតជកខ្លួនធ្លាយរួចពីចំណោមទៅបាន ខុងបេងក៏ឲ្យទាហាននាំខ្លួនទៀតចៅទៅក្យារបួសឯស្រុកសៃឈួន ។

ឯកោឈុយ ស៊ិនទៀ គាត់ទៅជម្រាបស៊ុម៉ាអ៊ីតាមសេចក្តីដែលបានទៅច្បាំងតទីងសត្រូវគ្រប់ប្រការ ស៊ុម៉ាអ៊ីថា ដែលអ្នកតាំង ២ បែកទ័ពមកវេលានេះ យើងក៏មិនប្រកាន់ទោសទេ ព្រោះខុងបេងមានកលឧបាយច្រើនយើងដឹងមិនដល់ ចូរអ្នកឯងនាំគ្នាស្រួតរួតទៅរក្សាស្រុកបៃសៀនិងស្រុកយង់ជីវឲ្យគង់ បើទាហានខុងបេងលើកចូលទៅជន្ទ្រាញជន្ទប្រការម្តេច ក៏កុំឲ្យចេញតស៊ូនឹងគេឡើយ យើងនឹងគិតកលឧបាយមួយយ៉ាងកម្ចាត់ខុងបេងចេញឲ្យបាន កោឈុយ ស៊ិនទៀ គំនាប់ហើយ ក៏លើកពលតម្រង់ទៅស្រុកប៉ៃសៀ ស៊ុម៉ាអ៊ីនិយាយនឹងទៀវខាច់ ខូវតែឡេងថា៖ ឥឡូវខុងបេងវាយបានស្រុកប៉ូគៅ និង ស្រុកយង់ជីវនោះ ឃើញថាពួកវាមិនបាននៅក្នុងបន្ទាយទេ ហេតុនេះ ត្រូវអ្នកឯងទៅគិតបញ្ចុះបញ្ចូលមនុស្សនៅក្នុងស្រុក ដែលនឹងទៅនោះ ត្រូវនាំពល ១០.០០០ លើកប្រួតកាត់ផ្លូវតូចតម្រង់ទៅពីក្រោយ វាយទម្លាយបន្ទាយ ខុងបេង ចូលទៅឲ្យបាន យើងនឹងនាំទាហានលើកព័ទ្ធទៅពីខាងមុខ វាយខ្ទប់ប្រសព្វគ្នាដណ្តើមយកបន្ទាយឲ្យបាន បើបានសមប្រកបហើយ ត្រូវធ្វើការអ្វី

ទីងទៅខាងខុនបេងនោះ ត្រូវតែកម្ចាត់បេញជាក្រោយគង់បានដោយ
ងាយណាស់ ទៀវខាប់ តែខ្សេងកំលើកទាហានប្រួតកាត់តម្រង់ទៅ ។

ឯខុនបេងនោះ ក៏និយាយនឹងនាយទ័ពនាយកងទាំងពួងថា ៖ យើង
មកវាយបានស្រុក ២ ដំបន់នេះ អាចជាមុខជាសុមាអ៊ីសម្គាល់ថា យើង
ចូលទៅនៅក្នុងហើយ បើដូច្នេះពេលយប់នេះមុខជាវាំនឹងពាត់ទាហានប្រួត
កាត់តម្រង់មកលុកបន្ទាយជាប្រាកដ ខុនបេងក៏តាំងពាត់ប្រេះដាក់ឈ្មើខ
ភ្លើងទុកជាច្រើន ហើយបំបែកទាហានឲ្យទៅចាំប៉ីនៅក្នុងព្រៃសងខាងផ្លូវ
ចាំស្ទាក់ទ័ពសុមាអ៊ីដែលលើកមក លុះដល់ពេលយាម ២ ព្រាយ ទៀវ-
ខាប់ តែខ្សេងក៏លើកពលមកដល់ជិតបន្ទាយ ពួកទាហានទាំងឡាយ
បានឮស្នូរសម្លេងមនុស្សនៅលើកំពូលភ្នំក៏សម្រុកស្ទាប់ ឯទៀវខាប់ក៏
ស្រួតចរសេះវិលគេចមកក្រោយ ហើយបង្ខំពលទាំងឡាយដែលនៅ
នៅនោះឲ្យទំស្រួតទៅមុខពាន់គ្នា ស្រាប់តែក្រឡេកឃើញប្រេះខ្សែភ្លើង
ដែលទាហានខុនបេងរុញចូលមកស្ទាក់ពីក្រោយ ក៏តក់ស្លុតរន្ធត់វិញ្ញាណ
ទើបស្រែកហៅទាហានមុខឲ្យថយវិលត្រឡប់ក្រោយ ស្រាប់តែឮស្នូរ
ផាវទឹងឃើញពន្លឺភ្លើងភ្លឺឡើងជុំវិញខ្លួន ឮស្នូរទាហានស្រែករំពងអឺងកង
ពីរចូលមក ខុនបេងនៅលើកំពូលភ្នំ ស្រែកមកថា សុមាអ៊ីសម្គាល់
ថា យើងនៅក្នុងកំពែងស្រុកបានជាលើកសម្រុកចូលមកលុកបន្ទាយយើង
ឥឡូវអ្នកឯងឃើញភ្លើងភ្លឺ អគ្គីទីឯត្រូវដូចគំនិតដែលគិតទុកនោះកំទេ គួរ

ឲ្យនាំគ្នាចូលមកគំនាប់យើងដោយប្រពៃចុះ ខ្ញុំម្នាក់ឯងជាប្រុសជំពោះ ដូចកូនតាហានតូច ១ មិនមាននរណានឹងស្គាល់មុខមាត់ទេ ត្រូវតែគាត់សេចក្តីខ្លាសអៀនទៅចុះកុំកាន់ខ្លួនឡើយ ។

ទៀវនាប់បានឮពាក្យខុនវេងស្រែកមកហើយ ក៏ឲ្យឈឺក្តៅពន់ប្រមាណណាស់ ទើបលើកខ្សែក្រទួយសេះចង្អុលមុខខុនវេងថា: ឯងនេះជាជាតិអ្នកស្រែក្រៅមកអួតតាំងខ្លួនធ្វើធំអង់អាចក្នុងចូលមិនខ្លាច ព្រោះផែនេះជាផែនអញ ។ នឹងព្រួតចាប់យកខ្លួនឯងមកបញ្ជាំឲ្យល្អិតខ្ទេចខ្ទី កុំឲ្យក្អែកលេបស៊ីបាន ជាហើយក៏បរសេះទន្ទ្រានឡើងលើគ្នា ដើម្បីនឹងចាប់ខ្លួនខុនវេង ដោះអស់តាហាន ក៏តាំងតែម្នាក់ជុំថ្មបាញ់នឹងធ្នូសរថ្មចុះមក ទៀវនាប់ឡើងទៅមិនបាន ក៏ញាក់សេះថយថ្ងូរមកវិញ ខុនវេងឲ្យតាហាននោះមិញ ស្ទុះចុះមកដេញកាប់សម្លាប់តាហានទៀវនាប់វិនាសច្រើនណាស់ ខ្លះក៏របួសពិការនឹងគណនាពុំបាន, ទៀវនាប់ខឹងតែឡើងក៏ពារខ្មាយចេញទៅ តាហានខុនវេងសឹងញញើតជុំវិញទៀវនាប់ នឹងក៏ចាប់ខ្លួនទុកពុំបាន ក៏បើកផ្លូវឲ្យចេញទៅ ខណៈកាលទៀវនាប់រកផ្លូវចេញទៅបានក្នុងថ្ងៃនោះ, ខុនវេងសម្លឹងមើលពីលើកំពូលភ្នំ ក៏សរសើរទៀវនាប់ថា: ឈ្មោះនេះឮតែឈ្មោះគេនិយាយមកយូរហើយថាខ្លាំងពូកែ, ទើបតែថ្ងៃនេះបានឃើញច្បាស់នឹងភ្នែកថាខ្លាំងពូកែប្លែកមែន ។ តាហាននេះបើគេទៅមុខគង់តែនឹងធ្វើឲ្យអន្តរាយយើងបានមែន, គួរយើង

នឹងកម្លាត់វាចេញឲ្យដាច់ ទើបខុនបេងលើកពលត្រឡប់ចូលបន្ទាយ ។

ឯសុមាអ៊ុវេលានោះ កំពុងតែចាត់ចែកពលហាន នឹងលើកមក ទទួលឃើញទៀវទាប់,តែឡេង ស្រែកស្ទក់ចូលទៅក៏ភ័យណាស់ ទើបសួរថា: ហេតុម្ដេចបានជាកស្រែកស្ទក់មកដូច្នេះ ទៀវទាប់ក៏ចប់កាយនិយាយប្រាប់សុមាអ៊ុឲ្យស្ដាប់គ្រប់ប្រការ, សុមាអ៊ុឮហើយក៏តូចចិត្តណាស់ និយាយថា: ខុនបេងនេះមានសតិបញ្ញាអង់អាចណាស់ ទើបប្រមូលវិលមកបន្ទាយ, សុមាអ៊ុនិយាយថា: ស្រុកសែឈួននោះផ្លូវនឹងទៅឆ្ងាយណាស់, ហេតុនេះបានជាពលខាំងដែលលើកមកពីនាយចំណាយស្បៀងអាហារដោយស្ដួចស្ដើង ដែលវាមកច្បាំងនឹងយើងប្រាថ្នាឲ្យបានជ័យជម្នះដាច់ ។ បើយើងនឹងចេញតប្រញាប់ ឃើញមិនស្រួលសោះ គួរតែនឹងផ្គាកបន្ទន់ឲ្យយូរ ដើម្បីឲ្យវាដាច់ស្បៀងអាហារ, បើកាលណាស្បៀងវាស្ដើងស្ដួច មុខជាលើកត្រឡប់ទៅឯង, តាំងពីនោះមកសុមាអ៊ុក៏មិនបើកឲ្យទាហានចេញច្បាំងឡើយ ។

ឯខុនបេងដឹងថា: សុមាអ៊ុវាខមិនចេញធ្វើសង្គ្រាមដូច្នោះ ក៏ចេះតែប្រើពលឲ្យទៅស្រែកឡកចំអកឲ្យឈឺចិត្តគ្រប់វេលា, សុមាអ៊ុក៏មិនចេញយុទ្ធនាសោះនៅតែធ្វើកុំដឹងគ្នាប្រមាណជា ១៤ ឬ ១៥ ថ្ងៃ ខណៈនោះប៉ុហ៊ុយជាព្រះរាជបម្រើកាន់ព្រះរាជតម្រាស់ព្រះចៅឡូវសៀន ប្រពានមកដល់ខុនបេងថា: ត្បិតទ្រង់បានជ្រាបដំណឹងថា មហាឧបរាជវាយបាន

អាណាខេត្រ ៤ តំបន់ ទ្រង់មានព្រះរាជហឫទ័យ សោមនស្សណាស់ ពេលដែលមហាឧបរាជលើសខុសពីមុននោះ ទ្រង់ព្រះរាជអនុញ្ញាតលើកឲ្យរួចទោសហើយ ត្រូវមហាឧបរាជនៅឋានាស័ក្តិតាមដើមដូចដែលខុន-បេងបានឃើញសេចក្តីព្រះតម្រាស់ដូច្នោះ ក៏លើកហត្ថាទាំងទ្វីអញ្ជលីប្រណម្យបង្គំគំនាប់ទទួលព្រះតេជៈគុណ ព្រះចៅឡាវសៀនតាមប្រវេណីហើយ ក៏ឲ្យប៉ុហ៊ុយកាន់សំបុត្រមកចូបទៅក្រុងវិញ ។

ខុនបេងគិតឧបាយបញ្ឆោតសុម៉ាអ៊ី ក៏ឲ្យទាហានចេញចាកបន្ទាយថយលឿនលយបណ្តោយទៅតាំងបោះទ័ពនៅក្បែរផ្លូវ ចម្ងាយប្រមាណ ៣០០ ស៊ិន (១២ គ៏) អ្នកល្បាតសេះក៏នាំដំណឹងទៅប្រាប់សុម៉ាអ៊ីថា ខុន-បេងលើកកងទ័ពត្រឡប់ទៅហើយ, សុម៉ាអ៊ីថា : ខុនបេងថយទ័ពទៅវេលានេះ សំណេះទឹងបញ្ឆោតឲ្យយើងដេញតាម, បើយើងតាមគង់ទឹងត្រូវជោយកលគេជាប្រាកដ ទៀវខាប់ទូលថា: ខុនបេងទាល់ប្រកហាកគំនិត ព្រោះតៀតដាច់ស្បៀងអាហារហើយបានជាថយទ័ពទៅ, ហេតុម្តេចប្រសាសន៍គេចជាមិនលើកទ័ពតាមទៅចោមវាយវិញដូច្នេះ ទឹងមកត្រឡប់ថប់ព្រួយខ្លាចកលខុនបេងដូច្នេះ ជាការមិនសមសោះ ។

[នៅមានត]

# ល្បងសិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ

ដោយ **លាង ហាប់អាន**

## កំណត់ការិយាល័យនិពន្ធ

យើងមានសេចក្ដីស្ដាយ ដោយការល្បងសិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ បានអាក់ខានមិនបានផ្សាយ ជូនអ្នកអាន តាំងពីលេខ ២ ឆ្នាំ ១៩៦៩ មកម្ល៉េះ ។ នៅក្នុងលេខ ១ ឆ្នាំ ១៩៦៩ យើងបានចុះផ្សាយជូនដល់ ប្រភេទ *ប្រជុំគតិ និង ព្រេងកថា* គឺផ្នែករឿងដែលមានអ្នកនិពន្ធ ឬកាលបរិច្ឆេទច្បាស់ ។

មុននឹងបន្តការចុះផ្សាយ នូវអត្ថបទតទៅទៀត យើងសូមសង្ខេបគោលនៃការសិក្សាពីត្រឹម "*អ្នកនិពន្ធ និងអត្ថបទខ្លះក្នុងសម័យឧដុង្គ*" ដើម្បីភ្ជាប់ការសិក្សា ចុះផ្សាយរួចមកហើយ និងអត្ថបទចុះផ្សាយថ្មី ។

### ៣- ផ្នែកទី ២– អ្នកនិពន្ធ និងអត្ថបទខ្លះ

ក្នុងសម័យឧដុង្គ (គ.ស. ១៦១៨–១៨៥៩)

### *ទី ១- ស ន្ទ ស្ស ន៍ អ ក្ស រ សិ ល្ប៍*

ព្រះរាជសម្ភារ (កវីរាជក្នុងសតវត្សទី ១៧ គ.ស. ១៦២៩-១៦៣០)

### *ទី ២- ប្រ ភេ ទ អ ក្ស រ សិ ល្ប៍*

*ក- វីរកថា*

*១- ផ្នែករឿង ដែលមានពាយនាម អ្នកនិពន្ធ និងកាលបរិច្ឆេទច្បាស់លាស់*

១ - លោកឧកញ៉ាបក្រី កែវ

- សាស្ត្រា ជាវរឿង (គ.ស. ១៨៣៧)

២- បណ្ឌិត កោ

- សាស្ត្រា ជ័យទត្ត (គ.ស. ១៧៥៤?) ;

៣- បណ្ឌិត ស្អាត ឬ សំអាត

- សាស្ត្រា មុច្ចលិន្ទ ឬ ចន្ទគោរព (គ.ស. ១៨៣៣) :

៤- អរិយគាមុនី ហ៊ីង

- សាស្ត្រា ជិនវង្ស (គ.ស. ១៨៥៦) ;

៥- ចៅពញាភក្តី, ចៅពញាដំឌិតក្សត្រី, ចៅពញាស្រីអញ្ជិត

- សាស្ត្រា ពន្ធយាគ (គ ស. ១៨៥៨);

៦- ភិក្ខុធម្មបញ្ញា ម៉ែន

- សាស្ត្រា វេទ្ធិកា (គ.ស. ១៨៥៩) ;

៧- អ្នកឧកញ៉ា ឧទេន

- សាស្ត្រា មាយមាណព ( ? ) ;

៨- អ្នកឧកញ៉ា ប្រាជ្ញាធិបតី ឬ បញ្ញាធិបតី កែវ

- សាស្ត្រា ព្រះសមុទ្រឃោស; (គ.ស. ១៨១៨) ;

៩- ឧកញ៉ា ព្រះឃ្លាំង ឌង

- សាស្ត្រា បុញ្ញសារសិរសារ (គ.ស. ១៧៩៧) ;

- សាស្ត្រា ព្រះសូម៉ុត្រ ( ? ) ;

- សាស្ត្រា ភោគកុលកុមារ (គ.ស. ១៨០៤);

- សាស្ត្រា លោកនយបករណ៍ (គ.ស. ១៧៩៤) ;

១០- ព្រះបាទសម្តេចព្រះអង្គឌួង

- សាស្ត្រា ល្បើកកាក (គ ស, ១៨១៥) ;

- សាស្ត្រា រឿងចម្ប៉ាថោង ( ? ) ;

១១- ឧកញ៉ា កោសាធិបតី កៅ

- រឿងព្រេងស្មុភមិត្រ (គ ស ១៨៩៩) ;

៤. ផ្នែករឿងដែលមានឈ្មោះអ្នកនិពន្ធ តែគ្មានកាលបរិច្ឆេទ

១- ភិក្ខុបណ្ឌិត ទៀវ

- សាស្ត្រា ចន្ទជីវង្ស

២- កវី ចន្ទ

- សាស្ត្រា ភិនសុវណ្ណ

៣- បណ្ឌិត កោរ

- សាស្ត្រា ព្រះសុភ័ត

៤- កវី យ៉ែម

- សាស្ត្រា វិមានចន្ទ

៥- អ្នកឧកញ៉ា ធម្មាធិបតី ចន្ទ

- សាស្ត្រា សុខមាណព

៦- ចៅពញាភក្តីសង្គ្រាម ពល

- សាស្ត្រា សុភោគ

*៣- ផ្នែករឿងដែលគ្មាននាមអ្នកនិពន្ធ តែមានកាលបរិច្ឆេទ*

- សាស្ត្រា ខ្យងសង្ខ (គ.ស. ១៧២៩);

*៤- ផ្នែករឿងដែលគ្មាននាមអ្នកនិពន្ធ និងគ្មានកាលបរិច្ឆេទ*

- រឿង ព្រះបាទឃសកើ្ត

- សាស្ត្រា ចៅពលឯក

- សាស្ត្រា ទុក្ខមាណព

- ព្រះបាទ ស៊ីសៅរ

- សាស្ត្រា ព្រះមាល័យទេវត្ថេរ (១)

*១- ប្រ ឌិ ត និង ព្រេ ង ក ថា*

*១ រឿងដែលមានអ្នកនិពន្ធ ឬ កាលបរិច្ឆេទច្បាស់*

---

១- អត្ថបទនេះទាំងមូល ពីខាងដើមដល់មកត្រឹមនេះ មាននៅក្នុងទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំទី ៤០ លេខ ១២ ឆ្នាំ១៩៦៨ ពីទំព័រ ១៣២១ ដល់ ១៣៣៦ ។

១- កវី សូរ

- រឿង អាទិលអាវុធ

២- ពៅពញាកដាមាត្យ ទៀង និងព្រះស្រីអញ្ចិតស៊ី

- សាស្ត្រា សុវណ្ណផលា (គ.ស. ១៨០៤) (១)

## ទី ២– រឿងដែលបានអ្នកនិពន្ធ តែគ្មានកាលបរច្ឆេទ

### ១– កវី អេខ លី

បានតែងសាស្ត្រា "ក្អែកដិប" ចោទពីបញ្ហាក្នុងសង្គមគ្រួសារ រហូតដល់សង្គមជាតិ ។ តួឯកសំខាន់ក្នុងរឿង បានរិះរកមធ្យោបាយដោះស្រាយវិបត្តិដែលកើតឡើងចំពោះខ្លួន តាមសន្តិវិធី ហើយថែមទាំងជួយផ្តល់លទ្ធផលល្អចំពោះខ្លួនឯងទៀតផង ។

កវីរូបនេះ មានកំណើតកើតនៅស្រុកព្រែកតាមាក់ បានចេញទៅរកស៊ីនៅឯភូមិតាមឯក ក្នុងខេត្តបាត់ដំបង ហើយលោកក៏ចាប់ផ្តើមតែងរឿងនេះឡើង ។

សាស្ត្រារឿងនេះ តែងជាបទព្រហ្មគីតិ មាន ១ ខ្សែ ។ ពុទ្ធសាសនបណ្ឌិត្យ បានសាស្ត្រានេះមកពីវត្តចុងកោះប្រាក់ ខេត្តកំពង់ចាម ចុះលេខ ៦៦៩(២) ។

---

១- អត្ថបទផ្នែកប្រវត្តិ និងព្រេងកថា ដល់ត្រឹមនេះ មាននៅក្នុងទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំទី ៤១ លេខ ១ ឆ្នាំ ១៩៦៩ ពីទំព័រ ៥៧ ដល់ ៦៤ ។

២- តាមការស្រាវជ្រាវរបស់លោកអ៊ុំ ញ៉ុក ថែម ចុះក្នុងកម្ពុជសុរិយាឆ្នាំទី ៥៧ លេខ ១២ គ.ស. ១៩៦៥ ទំព័រ ១៣១៧ ។

## លក្ខណៈអត្ថបទ

សេចក្ដីផ្ដើម

"សូមថែងថ្លែងដោយបទ    ព្រហ្មគីតគត់ដោយពិរោះ
លើកល្បងប្រាជ្ញា    រឿងខ្មែរជាប់សព្វសេចក្ដី ។
អញខ្ញុំទូនសិរសា    ថ្វាយនមស្ការព្រះជិនស្រី
ព្រះពុទ្ធព្រះធម៌ថ្លៃ    ព្រះសង្ឃសមសីលបរិសុទ្ធ ។
នូវគុណព្រះបិតា    ប្រសើរថ្កើររក្សាបុត្ត
មាតាថ្លៃបរិសុទ្ធ    អ្នកបំបៅអង្គអញខ្ញុំ" ។

សេចក្ដីបញ្ចប់

" កុំផ្ដុកឃ្លាចុងល្បះ    ឲ្យបង្ហៀងប្រះខូចខុសស្ដែង
ចម្លងតាមនេះឯង    កុំទាក់ទែប្រែទៀតណា ។
សេចក្ដីចប់ម៉្លេះហើយ    ព្រះគុណអើយសូមមេត្តា
អញខ្ញុំព្រះករុណា    លើកប្រគេនមកព្រះគុណ ។
សូមតែមគ្គលេខុក    តទៅមុខទុកជាទុន
ជាផ្សារទៅមុខមុន    ទៀងដកចដល់និព្វាន ។
រឿងពាក្យខ្មែរដប់ខែ    ចប់សេចក្ដីពិតពុំមាន
តាមដោយរឿងនិទាន    មានថែងចប់តែម៉្លេះណា(១) " ។

---

១- ទម្រង់សេចក្ដីផ្ដើម និងបញ្ចប់ មានលក្ខណៈតែមួយ ដូចជារឿងប្រលោមកថាក្នុងលំនាំរឿងជាតក បែបពុទ្ធនិយមក្លាយដែរ ។

## ២– កី សុវណ្ណ បញ្ញា

អ្នកនិពន្ធដាក់ថា "សុវណ្ណ បញ្ញា" នេះប្រហែលជាដាក់ "នាមធាយា" ទេ ។

លោកបានតែង "សាស្ត្រា កុមារាណ" កាលពីថ្ងៃព្រហស្បតិ៍ ២ កើត ខែ បុស្ស ឆ្នាំ ថោះសប្តស័ក ព.ស គ្មានបញ្ជាក់ ។

សាស្ត្រាកុមារណនេះ រៀបរៀងជារឿងជាតក ប៉ុន្តែខ្វះសេចក្តីបញ្ចប់ ដោយការសជាតិ ។

អត្ថបទក្នុងផ្នែករឿង គ្មានលក្ខណៈដូចជារឿងជាតកទេ ។ គឺជាលំនាំរឿងនិទានដែលទាក់ទងនឹងទំនៀមទម្លាប់ ពិធីបុណ្យផ្សេង ៗ និងជំនឿរបស់ខ្មែរ កាលពីសម័យព្រេងនាយ ។

តាមអត្ថរូបវិធី សេចក្តីរៀបរាប់របស់គំនេះ មិនសូវរៀបរយទេ ទាំងពាក្យកាព្យសោតទៀត ក៏មិនសូវល្អ មានគក់ច្រើនអន្ទើ ។ របៀបតែងគឺប្រើពាក្យកាព្យ បទ កាកគតិ ពំនោល ព្រហ្មគីត បន្ទោលកាក និងបទឥន្ទ្រជិត ។

ឯកសារជាសាស្ត្រាស្លឹករឹត មាន ១៣ ខ្សែរចប់ (ខ្សែទី១មាន ៣៦ សន្លឹក, ទី ២ មាន ៣៦, ទី ៣ មាន ២៩, ទី ៤ មាន ៣១, ទី ៥ មាន ៣៣, ទី ៦ មាន ៣១, ទី ៧ មាន ៣១, ទី ៨ មាន ៣១, ទី ៩ មាន

៣៩, ទី ១០ មាន ៣៩, ទី ១១ មាន ៣៩, ទី ១២ មាន ២៤, ចំណែក ទី ១៣ មាន ២២ សន្លឹក ) ។

ពិតមែនតែមានច្រើនខ្សែ (ដល់ទៅ១៣) ហើយមិនចប់ទេ ប៉ុន្តែត្រូវគេរៀបញ្ចប់ដោយបទ ។

ពុទ្ធសាសនបណ្ឌិត្យ បានឯកសារដើមមកពីវត្តសិត្បូរ ចុះលេខសាស្ត្រា ១៣៩៣ ។

លក្ខណៈអត្ថបទ :

សេចក្តីផ្តើម :

"នេះគឺបទព្រហ្មគីត ខ្ញុំលើកហត្ថលុតជង្គង់
បង្គំផ្ចិតតម្រង់ ទៅព្រះអង្គត្រាស់វិញ្ញាណ ។
ព្រះស្រីកែវត្រៃត្រ បដកថ្វៃព្រះកម្មដ្ឋាន
ព្រះវិបស្សនាមាន ព្រះអភិធម្មនាំរូបា ។
ព្រះឧត្តរលោកុត្តរ ធម៌បវរប្រាំបួនណា
ព្រះត្រៃលក្ខណញ្ញាណជា នូវព្រះត្រៃសរណគមន៍ ។ ...
អហំនាមនៃ លោកស្រដៃមកនេះជា
នាមសុវណ្ណបញ្ញា ចក្ខុសព្វនឹកសរសេរ ។
នាំផោះសព្ទស័ក នោះទៀតជាក់ខែបុស្ស
ថ្ងៃព្រហស្បតិ៍ឯនេះ ពីកើតខែខេះឯងហោង" ។

សេចក្ដីបញ្ចប់ ៖

" បើលោកណាប្រាជ្ញផង　　មើលហើយហានកុំខ្មា
ជួយតម្រង់ឲ្យជា　　ត្រូវពណ៌នាឡើងបរិយាយ ។
និទាននេះទៀតទេ　　កាព្យបន្ទៃកែអក់ប្រាយ
បរិបូណ៌ចប់បរិយាយ　　អស់សម្រាលណោះហើយនៃ ។
និទានតាមបរិយាយ　　រឿងនិយាយកាយសំដី
សូរេចប៉ុណ្ណោះខ្ញុំ　　អស់មោះនៃបរិបូណ៌ហោង ។ " (១)

## ៣– ភិក្ខុ មុនីភេសរ ឆាមដើម ស្ទ្រូត ៖

កវីៈលោកបានតែង សាស្ត្រា ក្ដាំងជាប់អន្ទាក់ ដែលជាអត្ថបទពាក្យកាព្យ មានរបៀបទកាគតិ បន្ទោលកាក និងភុជង្គលីលា ។ កាល បរិច្ចេទនៃការតែងគ្មានបញ្ជាក់ទេ ។

ចំពោះអក្ខរាវិធី សាស្ត្រានេះមានវិបត្តិច្រើន ទាំងជើងកាព្យ ទាំងឃ្លាល្បះ គឺមានការតក់ច្រើន ។

ពុទ្ធសាសនបណ្ឌិត្យបានឯកសារនេះមកពីវត្តកៀនជ្រៃក្រៅ ក្នុងខេត្តកំពង់ចាម ចុះលេខ ៦៣៣ ។ គឺជាសាស្ត្រាស្លឹករឹត ១ខ្សែចប់ មាន ៥ សន្លឹកកន្ទះ ។

---

១- តាមការស្រាវជ្រាវរបស់លោកអ៊ុំ ញ៉ុក-ថែម ចុះក្នុងកម្ពុជសុរិយាឆ្នាំទី ៣៩ លេខ ៧ គ.ស.១៩៦៧ ទំព័រ ៧៣២ ។

លក្ខណៈអត្ថបទ :

សេចក្ដីផ្ដើម :

" នេះបទកាកគតិ ក្រលីងមាសអើយ ឈប់ស្ទះក្បៀណពី នេះនឹងនិទាន ដំណើរគាព្យា ពីព្រេងនាយហោង ។ អ្នកពិភពមនុ- សេស្សលោក គន់គិតកាព្យផង" ។...

សេចក្ដីបញ្ចប់ :

" រួចហើយគាត់ទៅផ្ទះណា បបួលគ្នាសែងក្ដាន់យកទៅ ។ គាត់ការសាច់ចែកគ្នាទៅ នូវអស់ញាតិនៅ ផ្ទះទៀបជិតខាង ។ និយាយអធិប្បាយអស់យ៉ាង នេះសន្ធេបខាង ចរិយាណិម្មុះហោង(១) " ។

## ៤– អ្នកនិពន្ធ ឧទេន

កវីបានតែង សាស្ត្រា មាយាណាព ដែលប្រហែលជាបកប្រែស្រង់ចេញពីគម្ពីរ ធម្មបទដ្ឋកថាភាគទី ២ ក្នុងរឿងសត្តវគ្គ? បើតាមដំណើររឿងក្នុងជាតកនេះ អត្ថបទរបស់កវីមិនទាន់ចប់ត្រឹមខ្សែ ១ នេះទេ ។

កវីគ្រាន់តែប្រាប់ថា តែងពីថ្ងៃសុក្រ ១៤ កើត ខែពិសាខ ឆ្នាំកេងពោស័ក គ្មានសករាជបញ្ជាក់ទេ ។

ដំណើររឿងជាបែបនិទាន អំពីកំណើតព្រះតន្ត្រ តាមគោលពុទ្ធនិយម ។

១- តាមការស្រាវជ្រាវរបស់លោក អ៊ុំ ញ៉ុក-ថែម ចុះក្នុងកម្ពុជសុរិយាឆ្នាំ ទី ៣៩ លេខ ១១ គ.ស. ១៩៦៧ ទំព័រ ១១៣៦ ។

អត្ថបទនេះជាពាក្យកាព្យ បទកាកគតិ ព្រហ្មគីតិ ភុជង្គលីលា និង ពំនោល ។

ពុទ្ធសាសនបណ្ឌិត្យ បានសាស្ត្រាស្លឹករឹត ១ ខ្សែមាន ២៩ សន្លឹក កន្ទះ មកពីវត្តព្រៃកកុយ ខេត្តកំពង់ចាម ចុះលេខ ៦៥០ ។

## លក្ខណៈអត្ថបទ :

សេចក្តីដើម

« នេះបទកាកគតិ ។ សុក្រវារេ វិសាខមាសេ បុណ្ណមិយា នាគ សំវច្ឆរេ បច្ចុប្បន្នា ឧទេននាមា កាព្យករោ ។

សុកមស្តុ មង្គលាសុ ពហុបេស្តា បច្ចុប្បន្ន ថ្ងៃសុក្រ ខែពិសាខ ពេញបូណ៌មីណា ឆ្នាំរោងទោស័ក» ។ ...

សេចក្តីបញ្ចប់

ឯអស់មាតាឪពុក    នូវអ្នកស្រុកញាតិការ
សន្ធកកត់នាមា    ហៅនាងឧទ្ទកល្យាណ៍ ។
លុះនាងចម្រើនធំ    រូបកងសមលើសលែងស្រី
និត្យនៅនាលោកិយ    កើតកបកាយគ្រប់លក្ខណា ។
ដោយតេជតេជៈស័ល    នាងពុំខ្វល់ខ្លាប់កេរ្យា
សត្វទិនកត្រើណា    ពិព្យាយាមអចិន្ត្រៃយ៍ ។

ផលនោះបានសម្បត្តិ　　　បាបបង់បាត់ចេញឆ្ងាយក្រៃ
ដូចចិត្តខានសព្វថ្ងៃ　　　គិតពុំដាច់ត្រង់សីលា(១) ” ។

---

១- តាមការស្រាវជ្រាវរបស់លោក អុំ ញ៉ុក-ប៉ែម ចុះក្នុងកម្ពុជសុរិយាឆ្នាំ ទី ៣៩ លេខ ១២ ក ស ១៩៦៧ ទំព័រ ១២៦៣ ។

សូមបញ្ជាក់ថា សាស្ត្រានេះ អ្នកតារៈជ័មួង បានបញ្ជាក់កាលបរិច្ឆេទរបស់ខ្លួនថា ចារចប់នៅថ្ងៃ ៥ រោច ខែ កត្តិក ឆ្នាំខាលអដ្ឋស័ក ត្រូវនឹងឆ្នាំ១៩២៧ ។

# រាជគុល

## កំណត់អ្នកផ្សេងពិនិត្យ

សាស្ត្រារាជកុលនេះ មានបាត់ឃ្លាខ្លះ មានលើសឃ្លាខ្លះ ខ្លះមានជើងកាព្យតែ ៤ ខ្លះលើសដល់ទៅ ៨ ។ ត្រង់កន្លែងណាដែលខ្វះជើងកាព្យ ខ្ញុំមានតែងបន្ថែម ។ តែត្រង់ណាខ្ញុំកែបន្ថែមតម្រូវឲ្យត្រូវជើងកាព្យនិងន័យនោះ ខ្ញុំដាក់នៅក្នុងវង់ក្រចក ។ ហើយបើឃ្លាណាដែលបាត់ជើងកាព្យច្រើនពេក ខ្ញុំមិនបន្ថែមទេ ខ្ញុំរក្សាទុកឲ្យនៅច្បាប់ដើម ឯកន្លែងដែលលើសនោះ ខ្ញុំទុកនៅដដែល ។

---

### បទកាកគតិ

១. អហំនាមំ នមោពុទ្ធំ នមស្សិត្វា
នមោសង្ឃំ អតីតកាលេ ។

អញខ្ញុំវន្ទា សម្ដេចកគក់ ដាក់លើសិរ
ក្រុញក្រាបគស់អង្គ ជុំជិតឃាគេ សម្មាពុទ្ធ
ស្ដេចបានត្រាស់ហោង ។

ស្ដេចមានបារមី ត្រាស់ធម៌ប្រាំបី មុខបួនសែនផង
គបទសបារមី សាងតែព្រេងហោង ព្រះអង្គជាច្បង
ត្រៃត្រកតេះនេះណា ។

---

១- លេខដែលខ្ញុំដាក់រៀងនៅមុខកាព្យនេះ ជាលេខទំព័រសាស្ត្រាច្បាប់ដើម ។

ព្រះអង្គសេដ្ឋ ស្តេចជាអគ្គ កំពូលលោកា
នាវានាំសត្វ ច្រើនមហិមា ទៅដល់នគរ
និព្វាននាយហោង ។

បង្គំព្រះធម៌ ជ្រៅជ្រះនូវគាថ ប្រសើរគន្ធ
ជាការគេត្រា នាវាចម្លង សត្វនិករជន
ដាក់ដល់និព្វាន ។

បង្គំព្រះសង្ឃ សីលសុទ្ធលះបង់ សង្ខារហើយបាន
ប្រោសប្រស់សត្វបាន ចម្លងដល់ត្រើយ នគរនិព្វាន
(ជាឋានសុខក្រៃ)(១) ។

សព្វទេពទេវ សោឡសសួគ៌ា នាគយក្ខគ្រុឌនៃ
សូមតេជតេជៈ តបៈជោគជ័យ បម្រើនពរថ្លៃ
ឥឡូវនេះណា ។

លោកគ្រូបង្ការ ខ្ញាប់នេះសោភណា ខ្ញុំពីវគ្គហា
យកមកចម្លង ក្រែងខុសពុំត្រូវ តាមដោយគន្ធ
សេចក្តីនេះហោង ក្បួនដើមគេស្រាប់ (២) ។

---

១- តាមក្បួនសាស្ត្រាបាត់មួយបាទ ខ្ញុំតែងបន្ថែមថា “ ជាឋានសុខក្រៃ ” ឲ្យសមទៅតាមចុងឃ្លា នឹងបាទខាងមុខ “ នាគយក្ខគ្រុឌនៃ ” ។ ២- ឃ្លានេះមានដល់ទៅ ៨ បាទ ខ្ញុំមិនបានលុបៈទុកឲ្យអ្នកអានត្រិះរិះ ។

ខ្ញុំសូមសរសេរ តាមដោយដំណើរ បុព្វហេតុទំនង

ជាតិព្រះអគ្គហោង យោងយកកំណើត ក្នុងសង្សារវដ្ដ

ព្រះអង្គឯងហោង ។

នូវនាងពិម្ពា(១) យើងស្នេះជាតិ ព្រះសាងបារមី

នៅនេះក្សណណា ។

គោះឧឹងទិតាន វៃនមានព្រះមហា ក្សត្រសោយកជា

កោសម័ននគរ ។

ស្ដេចទ្រង់នាមា ព្រះបន្ទូកជា ដោយព្រះនាមករ

ព្រះកជទេពី មហេសីបវរ ទ្រង់ព្រះនាមករ

នាងបន្ទូទេវី ។

២- ស្ដេចមានកជបុ- ត្រីបីប្រាកដ រូបឆោមសោភា

ឥតកជបុត្រា រក្សាវិន័យ ស្នងព្រះបត្រី

នោះគ្មានឡើយហោង ។

រាកជបុត្រី ឈ្មោះទេពក្សត្រី នាងទាចជាច្បង

ប្អូនកណ្ដាល ត្រកាលឥតគួង នាមនាងនោះហោង

ឈ្មោះស្រីក្សត្រា ។

---

១- ពីរវគ្គនេះ ក្នុង ១ វគ្គមានតែ ៤ បាទ ខ្ញុំរុកនៅដដែល ។

នាងពៅបណ្ដាច់ រូបល្អស្រស់ស្រេច ដូចទេពអប្សរ
ដូចកលស្រីសួគ៌ ព្រះវរបិតា កត់ព្រះនាមា
បុត្រនោះសោភ័ណ ។

ឈ្មោះនាងនោះណា ហៅ ពៅកុំផា កផាកវ័ន
គបបញ្ចន្ទ្រីយ លក្ខណាគ្រប់គ្រាន់ (សក្តិសមសោភ័ណ)(១)
ពុំស្មើនាងហោង ។

នាងនាថតាំងបី ឥតព្រះស្វាមី ហើយពៅនៅផង
ព្រះវរបិតា មាតាគ្រប់គ្រង បុត្របីឥតហ្មង
បានទីព្រះទ័យ ។

ហើយមហាក្សត្រា ចិញ្ចឹមរក្សា ពស្ត្រគ្រឿងប្រពៃ
ដោយន័យបន្ទាត់ ក្រមក្រឹត្យក្សត្រថ្លៃ គ្រប់គ្រងផ្ទៃថ្លៃ
ក្រោមក្រមកថា ។

រីក្នុងនគរ ក្សត្រថ្លៃបវរ នោះមានមនុស្ស
ជាអ្នកកម្សត់ ទុគ៌តក្ដីណា ប្រពន្ធនិងស្វា-
មីមិនដែលបាន ។

ទ្រព្យល្អឧត្ដម នោះគ្មានពិតពុំ នឹងសម្រាប់ប្រាណ
ពីក្មេងលុះចាស់ ក្រណាស់ជនឆាន បាបសោកសឹងគ្មាន
ពុំដែលធូរឡើយ ។

---

១- តែងបន្ថែម ។

ឯស្វាមី ឈ្មោះទៅទូរគី ទុគ៌តខ្លះហើយ
តែប្ដីប្រពន្ធ ពុំមានកូនឡើយ ឈ្មោះនាងនោះហើយ
ទុគ៌តកុមារី ៗ

តែងដើរសូមទាន គេឲ្យទើបបាន យកមកហើយស៊ី
ចិញ្ចឹមកាយា ឯងជាប្រក្រតី បានរស់ដរី
និងសូមទានហោង ៗ

កាលណោះបើមាន ជំងឺបៀតបាន ទាំងពីរនាក់ហោង
នឹងដើរសូមទាន ពុំបានជាម្ដង គ្មានអាហារផង
នឹងបរិភោគ ៗ

អាសូរកម្សត់ អាសូរទុគ៌ត ពិបាកលើសលោក
ឯសន្តាន សឹងគ្មានជ័យជោគ សូតឲ្យរស់លោក
៣· អាសូរមហិមា ៗ

បុរសទាំងសង ពិបាកក្ដាត់ហោង ហិនហោចកំព្រា
បានប្រាក់ពីរស្លឹង ពុំដឹងទុកជា សំបៃនៅនា
ផ្ទះនោះសោតហោង ៗ

ពុំបានធ្វើស្រែ ពុំបានដួញប្រៃ តាមចម្ការផង
ពុំដែលលលក់ ទន្ទិញដល់ម្ដង លួចប្លន់សោតផង
ពុំដែលដល់ម្ដង ៗ

ហើយក្នុងចិត្ត ចេះគិតារណា ចិត្តចង់ឲ្យបាន
សម្បត្តិសម្បូណ៌ មិត្តមូលមកប្រាណ នឹងចង់ឲ្យមាន
ដូចអស់លោកជន ។

មានកាលមួយថ្ងៃ បុរសនោះនៃ សំណោះស្នេហ៍ស្ងួន
ទៅនឹងភរិយា អាត្មាឯងហោង នាងអើយចិត្តបង
ថែថប់ប្រែនក្តី ។

ថប់មួយគៀតគ្មាន របស់ធនធាន នឹងគេឡើយនៃ
ធ្វើម្តេចនឹងបាន ឲ្យមានណាថ្ងៃ អស់គេសព្វថ្ងៃ
ប្រក្រតីសព្វកាល ។

រីលោកទាំងឡាយ សន្សំតែកចាយ អស់ទាំងទ្រព្យផង
ឲ្យទៅជាមាន ឲ្យបានផលហោង តាមដោយគន្លង
ច្បាប់ធម៌បុរាណ ។

ហេតុនោះឯងណា រីក្តីប្រាថ្នា លោកជនសឹងបាន
នូវទ្រព្យរបស់ សក្តិយសគ្រប់ប្រាណ ហើយសោកឲ្យមាន
ប្រាថ្នាទៀតទៅ ។

ម្ល៉ោះហើយលោកបាន សម្បត្តិនិព្វាន ប្រសើរនិត្យនៅ
សម្បត្តិទេវតា ក្នុងព្រហ្មទៅ សន្តានសាចំណៅ
នឹងបរិបូណ៌ក្រៃ ។

ឬយើងពីមុន ពុំបានធ្វើបុណ្យ ឲ្យទានទោះនៃ
ទោះឯងទោះអញ កំណាញ់សព្វថ្ងៃ ចិត្តកាចចង្រៃ
ពុំដឹងបាបផង ។

ហេតុបាបនោះឯង កំណើតវង្វេង មកកើតនេះម្ដង
ជាអ្នកទុគ៌ត កម្សត់ទ្រព្យផង គ្មានប្អូនគ្មានបង
កូនចៅផៅពារ ។

ដឹងតែទុគ៌ត ដឹងតែកម្សត់ លំបាកអស្ចារ្យ
៤. តែដើរសុំទាន សព្វហាន់ទូទារ[១] អាក្រក់ទាំងពារ
សម្បុរជ្រីវក្រៃ ។

ទយើងរឹងក្រៃ ចាស[២]បានអង្គរ ស្រូវស្រាប់ប្រពៃ
ធនធានមាសប្រាក់ ឲ្យទានសព្វថ្ងៃ ទាំកែក្បួយ
ជីវិតទៅមោង ។

ប្រាក់យើងពីរស្ទឹង នាងអើយកុំខឹង អញបង់គិតផង
ទិញចបទិញស្រូវ ទឹងធ្វើស្រែលង វក្រង់ទេក្ដាផង
បំពេញឲ្យបាន ។

ស្ទឹងមួយទិញចប ករយាប្រកប ខិងស្មាមប្រាណ
ស្ទឹងមួយទិញស្រូវ យើងទៅរកបាន ជាស្រែឲ្យបាន
សាបស្ទូងតាមផល ។

---

១- ទូទារ ? ២- ចាស និ. ចាស់តែ, ព្រាតែ ។

ប្រសិនមានកំពូ　ស្រូវស្រែផ្លែស្រះប់　យើងអរជាមុន
ហើយសង្ឃឹមបាន　ឲ្យបានជាមុន　ប្រាថ្នាទ្រព្យធន
ដូចអស់លោកផង ។

បុរសពីរនាក់　សឹងព្រះស្រួលស្រាក់　ស្រេចស្រស់ជាមួង
យកប្រាក់ស្លឹងមួយ　ទិញចបហើយយ៉ង(១)　ទិញតាំងស្រូវផង
ស្លឹងមួយទៀតទៅ ។

គិតស្រេចហើយណា　ក្សិណនោះនាំគ្នា　ដើរចេញទៅក្រៅ
ពីស្រុកពីស្រែ　អស់គេធ្វើទៅ　ដើរត្រាច់សំដៅ
រកផលដទៃ ។

ក្សិណនោះយល់ការ　ទំហំប៉ុនថ្នាល　តូបមួយអាស្រ័យ
មានទឹកគង់នៅ　មានស្មៅប្រពៃ　ហៅគ្នាថាវុ
ថ្លុកនេះជាហើយ ។

ចុំវណ្ណកខ្ទប　ស្រេចកាន់ដងចប　ពុំឈរស្ងៀមឡើយ
សន្ទាតកាប់ដី　ដោយពិបាកហើយ　ប្រពន្ធមិញឡើយ
ស្លៀកកំណាត់ផង ។

ដៃប្រចាប់ដី　ជើងជាន់ឈូកឈើ　ឲ្យល្អិតជាម្ដង
ឲ្យល្អប្រពៃ　វិស័យស្រែផង　ដោយចិត្តប៉ុនប៉ង
ខិតធ្វើស្រែជា ។

---

១- ប្រដាប់សម្រាប់រាស ។

ប្តីមិញហត់ណាស់ ជាទីនជូនចាស់ នាងកុំបន្តៃ

មកជួយកាប់ឥញ អញទឹងប្រឹងប្រែង ប្រុងប្រែជួយឯង

ជួយកាប់នាងហោង ។

ជូនចាស់កាន់ចប កាប់ដីមាត់ហប ពេកពន់កន្ទួង

ណោលើកដងចប ស៊ើរជួលខ្លួនផង ចាស់ហើយក៏ដេ

លំបាកខ្លួនក្រៃ ។

តាចាស់សោគណា មើលយល់កិរិយា ញាខ្លួនញោះនៃ

៨. កាសូរប្រពន្ធ ចាប់បបពីដៃ ហេតុចិត្តកាល័យ

កាសូរកិរិយា ។

ចាស់ពីរកាប់ដី គំរប់បីថ្ងៃ បានធំជាខា

ប្រមាណប៉ុនថាល សំណាបធ្វើជា កាតពីរស្មើគ្នា

លើកក្តីប្រពៃ ។

ញែកក្តីកណ្តាល មួយលើកជាថ្នាល សាបស្រូវនោះនៃ

មួយទុកជាស្រែ ទីងស្ទូងវិស័យ ខ្លួនឯងក្រក្រៃ

គិតគួបទៅហោង ។

មើលក្រែងខុសខាត ទឹកហូរតែកប ស្មើគ្នាជាម្តង

សង្រ្គាតខ្វល់ខ្វាយ ទំលាយដីផង ធ្វើពុំឲ្យខ្តង

ឲ្យល្អប្រពៃ ។

លុះធ្វើស្រែស្រេច ស្រូវដែលរំញជាប់ មានតែមួយពៃ
ចែកចេញជាពីរ ភាគមួយសំរែ ភាគមួយនោះនៃ
គ្រាំហើយសាបទៅ ។

លុះសាបស្រូវស្រេច តែងមើលពុំដាច់ ថៃមួយបីដង
ហេតុចិត្តស្រឡាញ់ ស្រូវមិញឥតគ្គង ល្មមដកហើយហោង
ដកហើយស្ទូងទៅ[1] ។

ប្តីស្រីនោះណា ហេតុដូនទិនភា មានចិត្តអាល័យ
តែងដើរទៅមក គយឃ្លាំសព្វថ្ងៃ ស្រូវល្អប្រពៃ
អរឯងមហិមា ។

ហេតុចិត្តព្យាយាម ដូនតាធ្វើតាម ពុំដឹងវៀរវៀច
កម្មកាចឡើយណា ពុំបេះមោសា ភូតភរឡើយហោង[2] ។
ដឹងតែស្ទូតត្រង់ ដឹងតែចិត្តចង់ ឲ្យបានទ្រព្យផង
ឥតលុះភៀតខ្សត់ ទុគិតក្អាក់ហោង គឺមោះប៉ុនប៉ង
ចង់ឲ្យមានក្រៃ ។

ហេតុផលដូនតា ចិត្តចង់ប្រាថ្នា ធ្វើបុណ្យសព្វថ្ងៃ
រំដួលជាលដល់ ក្តៅទទពោកក្រៃ អ្នកយកភ្លើងពាល
នៃក្រោមអាបងា ។

១- បើដាក់ "ហោង" ទើបចាប់ជួនគ្នា ។ ២- ទ៖ ១ ៣៩ ។

កាលនោះព្រះឥ- ន្ទ្រាទ្រើសនរិន្ទ ទ្រង់ព្រះចិន្តា
ដោយព្រះយោបល់ មួយពាន់យោជន៍យល់ ឃើញដូចនិងគា
ប្រសើរឥតគ្គង ។

ព្រះឥន្ទយល់ជាក់ ចន្ទុលថាអ្នក : ទាំងពីរនេះហោង
៦- (មានចិត្តប្រាថ្នា)[១] ចង់បានទ្រព្យផង ហេតុចិត្តប៉ុនប៉ង
ចង់បានទ្រព្យណា ។

នេះហោងគួរអញ ឯងកានបំពេញ ឲ្យដូចប្រាថ្នា
កាសូវដូនចាស់ គាចាស់ចិត្តជា ចង់ដេរអធា-
គតគាប់ប្រពៃ ។

បើចេះគួរអញ អងកានបំពេញ ដូចម្តេចជាក្រោយ
គួរទៅនិមន្ត ពង្សព្រហ្មាថៃ ចាប់ប្រដិសន្ធិ
នុខរជាយា ។

នាងនាថទេវី ជាអគ្គមហេសី ព្រះចន្ទកជា
បើបានកូនប្រុស ស្រេចស្រស់សោភា កូននោះនឹងជា
ពំនាក់ស្ត្រេផង ។

ព្រះរាជបុត្រា នឹងអស់ដូនគា បរិបូណ៌កុង
នឹងឲ្យគាត់បាន របស់ទ្រព្យផង ដូចចិត្តប៉ុនប៉ង
គាត់ប្រង់ប្រាថ្នា ។

១- តែងបន្ថែម ។

កាលនោះព្រះឥ- ន្ទ្រាទ្រើសនរិន្ទ ទ្រង់ព្រះចិន្តា
ដោយព្រះយោបល់ មួយភាន់យោធន៍ប្រា- កដយល់ដូចគា
ប្រសើរឥតគួន ។

ព្រះឥន្ទយល់ជាក់ បន្ទូលថាអ្នក តាំងពីរនេះហោង
មានចិត្តប្រាថ្នា ចង់បានទ្រព្យផង ដោយចិត្តប៉ុនប៉ង
ឲ្យបានទ្រព្យណា ។

ឯអង្គព្រះឥ- ន្ទ្រាទ្រើសនរិន្ទ ទ្រង់ព្រះចិន្តា
ដូច្នោះហើយនៃ ឥន្ទថ្វៃសីលា ហោះតាមវេហាស៍
ទៅដល់កៃលាស ។

នៃទើបព្រះឥន្ទ ស្តេចទ្រង់ព្រះចិ- ន្តាជាសំខុះផ្លាស់
ចង់ឲ្យពោធិ បារមីពោរពាស លើសលោកតាំងផ្តាស
កងកាលនោះហោង ។

ព្រះឥន្ទទតនៅ យល់ព្រះបមពៅ ស្តែងស្តេចជាច្បង
ទិនបានក្រាស់ក្រេប សារពេជញាណហោង ព្រះអង្គកន្ទង
លែងលោកតាំងឡាយ ។

ទើបព្រះឥន្ទ្រា ចុះពាក់សួគ៌ា ត្រៃត្រឹង្សសួគិនាយ
ចុះចូលកៃលាស បពិតភណ្ណាកាយ ស្ថានក្សេមសប្បាយ
ប្រសើរពេកហោង ។

កៃលាសបព្វតា នោះមហាក្សត្រា ឯកអគ្គជាច្បង
សោយរាជសម្បត្តិ ថេរបិតុគ្រប់គ្រង អស់ពលពាលជន
អនេកក្រាស់ក្រៃ ។

៧. ស្តេចទ្រង់នាមករ ព្រះធុរឧទុម្ពរ ប្រសើរថ្លាថ្លៃ
មានអគ្គជាយា ឯការប្រពៃ ព្រះនាមស្រីថ្លៃ
សុវណ្ណមាលា ។

ឬព្រះវៀស្តជ័យ នូវនាងស្រីថ្លៃ មានឯកបុត្រា
-តែមួយព្រះអង្គ ទ្រើសទ្រង់នាមា សន្ទះហៅថា
ពជកុលកុមារ ។

ពជកុលពោធិ ស្តេចមានបារមី តេជៈសម្ភារ
លើសលែងឥន្ទព្រហ្ម គួចជាសដារ ផ្ទាសសព្វប្រការ
ឥតអ្នកស្មើបាន ។

ទើបព្រះឥន្ទ្រា ចូលទៅដល់នា ប្រាសាទវិមាន
គង់ស្រពោធិសត្វ ស្តែងស្តេចបិតបាន រៀបព្រះឥន្ទ្រមាន
បន្ទូលថា ។

គោសាធុមហា បពិត្រកជា បុត្តស្នូចមក្រៃ
អ្នកមានបុណ្យ បារមីក្រាស់ក្រៃ ឥតអ្នកដទៃ
ផ្ទឹមផងកុំបាន ។

ខ្ញុំសូមខំមក ព្រះអគ្គមានបុណ្យ ចរចុះទៅឋាន
ស្រុកកោសម្ពី បុរីកជបាន សាងបារមីមាន
បរិបូណ៌ទៀងហោង ។

ចូរស្តេចបំពេញ តាដូនចាស់មិញ ឲ្យបានទ្រព្យផង
ឲ្យមានរូបល្អ ចាំងពីរឥតគ្គង ខំងជះសោតហោង
យឺនយូរពេកក្រៃ ។

ចូរស្តេចលីលា ចុះទៅឋាននា មនុស្សលោកប្រពៃ
យកប្រដិសន្ធិ ក្នុងឧទរនៃ មល្លិកាស្រីថ្លៃ
កាយិអគ្គជាយា ។

នាងជាទេពី សម្តេចចក្រី ព្រះចន្ទកជា
សោយកផសម្បត្តិ ថេរបិតនៅនា កោសម្ពីនគរ
មនុស្សលោកនាយហោង ។

បើស្តេចស្តែងបាន ទៅកើតនៅឋាន មនុស្សលោកនាយហោង
សាងព្រះបារមី ដោយខំតានជង នៃព្រះពុទ្ធហោង
សម្តែងទេសនា ។

ព្រះពុទ្ធអំពី បុកណមុនី សម្តែងទេសនា
នៅស្ថានមនុស្សលោក ដូចប្តាះឯងណា ទើបត្រាស់បានជា
ព្រះពុទ្ធនោះហោង ។

៨- ភជកុលពោធិ៍ ស្តាប់ព្រះឥន្ទ- មន្តមកឥតឆ្គង
ស្តេចទ្រង់ចិន្តា អរក្រៃកន្លង បន្ទូលទៅផង
សម្តេចឥន្ទ្រា ។

បពិត្រព្រះឥ- ន្ទ្រាទ្រង់សទ្ធិ ឥស្សរទេព
ខ្ញុំទទួលយក និមន្តអ្នកណា ពុំទាន់ប្តេជ្ញា
នឹងអ្នកឡើយហោង ។

បខ្ញុំនឹងមើល ដោយនូវដំណើរ កំណើតមនុស្សផង
គួរបាប់បដិ- សន្ធិជាមួន ដោយនូវគន្លង
បណ្តូលពុទ្ធញាណ ។

សម្តេចឥន្ទ្រា បង្គំក្រាបលា ពោធិ៍ទៅស្ថាន
ត្រៃត្រឹង្សសួគ៌ា ជាតិជាវិមាន ពិភពសួគ៌ឋាន
ពេជ្រយន្តរុងហោង ។

## បទព្រហ្មគីតិ

កាលនោះពោធិសត្វ បុរសរត្នជាច្បះច្បង
ស្តេចចូលទៅប៉ុនប៉ង នឹងក្រាបលាក្សត្រពីរពង្ស ។
ទើបស្តេចឱនព្រះសិរ អញ្ជលីបង្គំត្រង់
ឆ្ពោះក្សត្រទាំងពីរពង្ស ព្រះមាតាបិតាផង ។

ស្តេចពេភមរវេជនទី ទូលព្រះវរបិតាហោង
គ្រឹតស្តេចនៅប៉ុនប៉ង ទីនចុះចាកសួគាល័យ ។
បពិត្រព្រះមាតា ខ្ញុំក្រាបលាអម្ចាស់ថ្លៃ
ខ្ញុំទីនទៅប៉ានឮ មនុស្សលោកនាយនោះឯងហោង ។
បើខ្ញុំទៅបានដល់ ចឹមណ្ឌលមនុស្សលោកផង
ប្តូចិត្តខ្ញុំប៉ុនប៉ង ទីនបំពេញអស់សេចក្តី ។
ទីនបំពេញបានបរិបូណ៌ ខ្ញុំពុំយូរវិលមកវិញ
សូមស្តេចបើកឲ្យផ- ឡូវនេះទីនទៅឆាប់ហោង ។
កាលនោះនាងសុវណ្ណ មាលាគន់គាំងគិតផង
គ្រឹតបុត្របានវៀចវង ពេភមលាលះលាកៈទៅឆ្ងាយ ។
ហេតុគ្រឹតនាងអាល័យ បុត្រមាសថ្លៃវត្ថពខ្ពាយ
ទុកវត្ថុស្ងួវផ្កាយ សព្ទោកពេញជាប់ពៃន ។
នាងនាថស្ងួវសន្ទប់ ញ័រចំប្រថប់ដូចទីនក្បួយ
ជីវិតនាងនាថនៃ គ្រឹតអាល័យបុត្រពុំឆារ ។
ក្បណានោះវរទេវី ថើបសិរសីរភជបុត្រ
ហើយទើបបន្ទូលថា ហៃស្ងួនក្ញាមាសថ្លើមថ្លៃ ។
បាបុត្រម្តាយតែមួយ ជាត្រួយទ្រព្យថ្លើមពុំឆារ
បើបាបាត់ហើយនៃ សម្តាយក្បបេជីវិតហោង ។

# ក្រមុំព្រហ្មចារី

លោក ជិល-ទិត រៀបរៀង

នារីដែលមានវ័យវស្សា
ជួបចូលជន្មាដឹងសេចក្ដី
អាយុគ្រប់ការបុកណស្ដី
ហៅថា យុវតី ស្ត្រីក្រមុំ ៗ

នាមនេះពីរោះខ្ពស់ពន់ពេក
ព្រោះហើយគួរគ្រេកគ្រេងគិតមេ
បុកណបានថែមពាក្យមួយផ្សំ
គឺហៅ “ ក្រមុំព្រហ្មចារី ” ៗ

ស័ព្ទនេះបើប្រែកែក្រោយ
សំដៅយកកាយជាតិស្ត្រី
ដែលនៅក្រមុំសុទ្ធពិសី
ដូចសំពត់ថ្មីគ្មានប្រឡាក់ ៗ

មិនដែលប្រឡែងសម្ដែងតួ
ដើរចូលផ្លូវដួកក្នុងរឿងស្នេហ៍
គឺមិនដែលសោះរឿងរួមរ័ក
នឹងប្រុសលួចលាក់ប្រពៃណី ៗ

ក្រមុំក្រមនេះចាស់ដូនតា
ហៅថា “ ក្រមុំព្រហ្មចារី ”
តម្កើងឋានៈមារយាទស្ត្រី
ខ្ពង់ខ្ពស់ពិសីស្មើលោកសង្ឃ ៗ

ព្រោះគឺព្រះសង្ឃលោកទ្រង់សីល
រៀបរឿងខ្ចូចខិលខាងចកស្បង់
គឺផ្ទុរកាមេស្នេហ៍គិសរង់
បរិសុទ្ធស្អាតអន្តល្អប្រពៃ ៗ

គួរគេបូជាសក្ការៈ
តម្កើងឋានៈខ្ពង់ខ្ពស់ក្រៃ
គួរគេគោរពប្រណម្យដៃ
ធ្វើពានថ្វាយទេយ្យធម៌ផង ៗ

រីឯនារីបុកពិសី
ហៅ “ ព្រហ្មចារី ” ល្អហ្មត់ម៉ង
តែងមានកិត្តិយសល្អកន្ទង
អ្នកផងពេញចិត្តថា “ ប្រពៃ ” ៗ

ប្រុស ៗ គ្រប់ប្រាណតែងប្រាថ្នា ជ្រើសរើសភរិយារួមនិស្ស័យ
ស្ទើរតែគ្រប់រូបតែងរំពៃ ជាដំបូងដៃគឺ " បរិសុទ្ធ " ។
ព្រោះគេយល់ថាយុវតី បង់ព្រហ្មចារីរែងមានពុត
ស្រើបស្រាលអាលកាមគុណផុត រក្សាបរិសុទ្ធខ្លួនពុំបាន ។
ឲ្យប្រុសមួយពីរញាក់ញីលែង សប្បាយជាល្បែងល្បងកម្សាន្ត
រួចហើយវិលរេរះកែប្រាណ លុបដានថាខ្លួនគ្រមុំស្អាត ។
ទើបយកប្ដីក្រោយដោយនូវច្បាប់ ធ្វើបុកចំណាប់មិនខ្មាសញាតិ
ខ្លួនកេរ្តិ៍ពូជដូចអាក្រាត ដូចជាគិតអប្រិយដល់ប្ដីទៀត ។
គេថ្កោលទោសប្ដីថាល្ងើពេក ល្ងង់ដូចជាវែកចំពោលមៀត
ស្ត្រីពេញទេគរបេរបង្អៀត ម្ដេចក៏មកធ្ងៀតយកដែលគេ ។
សម្បត្តិផងស្ត្រីដែលសម្រាំង សម្រិតបិទបាំងរក្សាថែ
ជាកេរ្តិ៍មតិកមកពីម៉ែ គួរថែបរិសុទ្ធទុកឲ្យប្ដី ។
បើប្រុសមួយពីរដឹងសម្ងំស្ស បមរូបស្រូបរស់រួមចិត្តស្ត្រី
រួចកល់ទើបរេកស្វាមី បើប្ដីបានដឹងនឹងយ៉ាងណា ។
ខ្មាសអើយសែនខ្មាសផ្ដាសឲ្យស៊ុន ម្ល៉េះសមប្រុសមុនយល់ភរិយា
ទឹងសើចចំអកប្ដីទាំងថា ភរិយាគាត់ឯងសល់ពីអញ ។
បើមានប្ដីពិតរួចគិតលះ លែងជាប់ស្រឡះអស់ស្រឡាញ់
ជាមេម៉ាយពិតឥតបើកាញ់ នោះគួរស្រឡាញ់រួមស្នេហ៍ស្និទ្ធ ។

គឺប៉ើមេម៉ាយមេម៉ាយចំ　　គឺប៉ើក្រមុំក្រមុំពិត
កុំតែក្រមុំបន្ទំបិទ　　ផ្ចាប់សារស្នេហ៍ស្និទ្ធស្រួចទៅហើយ ។
អាសូរនារីដែលស្មោះត្រង់　　គ្មានចិត្តណាចង់ផ្លាស់ប្តូរឡើយ
តែបានសង្សារណាមួយហើយ　　បងអើយអូនសូមផ្ញើរសនា ។
បំណងប៉ងយកជាគូស្នេហ៍　　ត្រាអស់ជីវិតជាមួយគ្នា
ឯប្រុសចិត្តព្រានគ្មានមេត្តា　　បំពេញតណ្ហាហើយបោះបង់ ។
កាលមកលួងលោមហ៊ានស្បែស្បថ　　គួរជឿប្រាកដជាពិតត្រង់
ដល់ព្រមជូនប្រាណតាមចំណង់　　គេឆ្អែតហើយបង់គេចកែដោះ ។
ខ្លះថាមេបាជាក់កំហិត　　ខ្លះពោលថាចិត្តស្រីមិនស្មោះ
ខ្លះស្តាយភាពខ្លួនទៅកម្ទោះ　　គេមានផ្លូវដោះបោះបង់បាន ។
ខ្លះថាស្រីដែលគេនិយាយ　　ចែចង់បានឆាយខុសលំអាន
យកជាគ្រួសារពិតពុំបាន　　គេយកកម្សាន្តប៉ុណ្ណឹងទេ ។
ឯនារីវិញពេញជាខុស　　ឆាប់ជឿចិត្តប្រុសទ្រុស្តឪម៉ែ
ស៊ូចិត្តគិតថាមិនអីទេ　　លង់ស្នេហ៍គេប្រាប់ ស្តាប់លែងឮ ។
រសជាតិស្នេហាក់សែនឆ្ងាញ់　　ពេលឈ្លក់ស្រឡាញ់ឃើញជាក្អី
ដល់កើតវិបត្តិខ្វាត់ពទ្ធី　　ខ្លះទៅជាឈឺរីងរៃប្រាណ ។
ខ្លះក្តៅហួសពេកថែកញ្ញាបាទ　　ធ្វើអត្តឃាតឃ្លាតចាកឋាន
យំយែកស្រែកថាខ្ញុំខុសប្រាណ　　មិនស្មានថាគេហ៊ានប្រែចិត្ត ។

ខ្លះធ្វើមុខក្រាស់មិនផ្លាស់ខុស
រកប្រុសមួយដែរកែឈឺចិត្ត
បានបាត់បានបង់លង់ចរិត
បង់ក្រឹត្យទៅជាស្រីពេស្យា ។
ខ្លះចេះមារយាទទៀតលាក់ទុក
ជាខ្លួនបរិសុទ្ធអស់ក្រឡា
សុភាពបុរសពេញចិន្តា
បង្ខំមេបាឲ្យចូលស្ដី ។
យកជាប្រពន្ធបង្កើតបុត្រ
ស្មានជាបរិសុទ្ធល្អពិសី
ក្រោយមកដល់ដឹងថាជាស្រី
បង់ព្រហ្មចារីមុនទៅហើយ ។
ខកចិត្តគិតកែប្រែគំនិត
ដកក្តីទុកចិត្តសោះអង្គើយ
ជួនកាលត្រូវលះលែងកន្តើយ
នេះហើយជាទោសព្រោះស្នេហា ។
អាដែងស្នេហ៍តវ៉ាកើតទុក
អាស្រូវឪពុកម្តាយខ្មោចផ្សា
តើគួរបន្ទោសខុសអ្នកណា
បើតាមខ្ញុំថា គឺខ្លួនឯង ។
ភ្លើតភ្លើនល្បូកភ្លើងថាស្រណុក
នុបផ្តុំប្រហុកទុកជាល្បែង
ដល់ក្តៅដល់ស្អុយទើបចម្បែង
ស្រែកយំក្តែង ៗ លែងកែបាន ។

វិធាតា សុរិយា

ផ្នែកកំណត់-ប្រវត្តិការណ៍

ក្រសួងធម្មការ

សាធារណរដ្ឋខ្មែរ

លេខ ១០ ក-ធ

សារាចរ

ប្រញាប់បំផុត

អ្នកឧកញ៉ាពិភក្តិសាសនៈ
រដ្ឋមន្ត្រីក្រសួងធម្មការ

សូមនមស្ការព្រះតេជព្រះគុណ មេគណ អនុគណ គ្រប់ក្រុងខេត្ត អនុខេត្ត ចៅអធិការគ្រប់វត្ត ទាំងពីរគណៈ ក្នុងសាធារណរដ្ឋខ្មែរ

កម្មវត្ថុ: សេចក្តីកែគាថា ១ វគ្គ ក្នុងធម៌ អាការសញ្ញា ។

ដើម្បីឲ្យបានស្រេចតាមការវិវត្តន៍នៃរបបសាធារណរដ្ឋខ្មែរ គណៈកម្មការមួយដែលតែងតាំងឡើង ដោយដីកាចាត់ក្រសួងធម្មការ លេខ ២៣០-ធ ចុះថ្ងៃទី ២៨-១០-៧០ បានធ្វើការប្រជុំមួយ កាលពីថ្ងៃចន្ទទី ២ វិច្ឆិកា ១៩៧០ បានសម្រេចប្តូរពាក្យបាលីក្នុងគាថាមួយ នៃធម៌ អាការសញ្ញា ផ្សាយក្នុងសៀវភៅឈ្មោះ "គហិបដិបត្តិសង្ខេប" របស់វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ត្រង់ទំព័រ ១២៩ ដល់ ១៣០ ដែលថា: "រាជាតោ" នោះថាជា "រដ្ឋតោ" វិញ គឺត្រង់គាថានេះ:

ត្រូវសូត្រថា :

« អាកាសដ្ឋា ច ភុម្មដ្ឋា

ទេវា នាគា មហិទ្ធិកា

បុញ្ញំ នោ អនុមោទន្តុ

ចិរំ រក្ខន្តុ រដ្ឋកេ

ឯសេចក្ដីប្រែជាភាសាខ្មែរ គឺត្រូវប្រែថា :

« ទេវតាទាំងឡាយស្ថិតនៅឯអាកាសក្ដី ស្ថិតនៅលើផែនដីក្ដី នាគទាំងឡាយមានឫទ្ធានុភាពច្រើនក្ដី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវមហាជនក្នុងរដ្ឋទាំងឡាយ ឲ្យបានសុខចម្រើនអស់កាលជាយូរអង្វែងទៅ » ។

ចំពោះសេចក្ដីគាថានេះ សម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ ព្រះអង្គសព្វព្រះហឫទ័យយល់ព្រមហើយ ។

ដូច្នេះសូមព្រះតេជព្រះគុណ មេគណ អនុគណ និង ចៅអធិការគ្រប់វត្តទាំងពីរគណៈ ចាត់ផ្សាយដល់ព្រះសង្ឃ និងពុទ្ធបរិស័ទ ឲ្យអនុវត្តន៍តាមសេចក្ដីគាថានេះតទៅ ។

សារាចរធ្វើនៅក្រសួងធម្មការ ចុះថ្ងៃទី ១ ខែ មីនា ១៩៧១

ជ. រដ្ឋមន្ត្រីក្រសួងធម្មការ

អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ

ទទួលបន្ទុកក្រសួងធម្មការ

ហត្ថលេខា : ឌី - ទូច

# សមាជពុទ្ធបរិស័ទនៅសាលចតុមុខ

## [ ថ្ងៃ ១៧ មេសា ១៩៧១ ]

សេចក្តីរាយការណ៍ របស់លោក លី - ធាមតេង

ដោយសារប្រទេសជាតិយើងកំពុងទទួលរងគ្រោះ ព្រោះសត្រូវចូលឈ្លានពាន រុករានបំផ្លាញដល់ជីវិតអ្នកស្រុក បំផ្លាញវត្តអារាម ជីវិតព្រះសង្ឃ ដែលជាតំណាងពុទ្ធសាសនានោះ; ពុទ្ធបរិស័ទទាំងអស់ក៏កើតការក្តៅក្រហាយពុះពោរឡើង គាំ ប្រយុទ្ធប្រឆាំង នឹងគំនិតអាក្រក់ នៃមិច្ឆអន្យតិរ្ថិយ ពីគ្រប់ទិសទីទាំងអស់ ។

អាស្រ័យហេតុនេះ ពុទ្ធិកសមាគមមជ្ឈមណ្ឌលសាធារណរដ្ឋខ្មែរ រួមជាមួយពុទ្ធិកសមាគមពីរទៀត បានចាត់ចែងធ្វើសមាជពុទ្ធបរិស័ទមួយ នៅសាលសន្និសីទចតុមុខ ដើម្បីប្រមូលយោបល់ និងរកវិធីដោះស្រាយតាមផ្លូវច្បាប់ និងដើម្បីទាញអារម្មណ៍នៃពួក ពុទ្ធសាសនិកសាកល-លោកឲ្យដឹងច្បាស់ថា ព្រះពុទ្ធសាសនាដ៏ជាទីគោរពរបស់យើងនោះ ត្រូវទមិឡឥតសាសនា បៀតបៀនធ្វើទុក្ខបុកម្នេញហើយ ។

វេលាម៉ោង ៩ សមាជិកសមាជទាំងអស់ និមន្ត និងអញ្ជើញមកដល់ៗ ផ្នែកព្រះសង្ឃ មានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាព្រះអធិបតី ឯផ្នែកគ្រហស្ថ មានតំណាងពុទ្ធបរិស័ទគ្រប់ក្រសួងរដ្ឋការ គ្រប់សាលាខេត្រ

និងក្រុង គ្រប់វត្តទាំងអស់ក្នុងរដ្ឋធានីនិងគ្រប់សមាគម សាលាបុណ្យផ្នែកពុទ្ធសាសនា នៅក្រោមអធិបតីភាពនៃប្រធានពុទ្ធិកសមាគមទាំងប ៗ មិនតែប៉ុណ្ណោះ មានអ្នកតំណាងបរិស័ទសាសនាគ្រិស្ត និង សាសនាឥ-ស្លាមនៅប្រទេសខ្មែរ ចូលរួមជាអ្នកសង្កេតការផង ។ ក្រោយដែលជួបជុំហើយ លោក ប៊ុណ្ណា ចន្ទម៉ុល ប្រធានពុទ្ធិកសមាគម បានថ្លែងប្រារព្ធបើកសមាជ និងបញ្ជាក់ពីគោលបំណងរបស់សមាជ ដែលកើតមានឡើងក្នុងពេលនេះ ។

សេចក្តីថ្លែងទាំងស្រុង មានដូចតទៅនេះ :

សូមនមស្ការ ចំពោះសម្តេចព្រះសង្ឃនាយក

ជាអម្ចាស់ ទាំងពីរព្រះអង្គ !

សូមថ្វាយបង្គំ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ !

សូមគោរព លោកស្រី អស់លោក-អ្នក ជាពុទ្ធបរិស័ទ ព្រមទាំងអស់លោកដែលជាតំណាងសាសនាដទៃទៀត ដែលបាននិមន្ត និងអញ្ជើញមករួបរួម ក្នុងការសមាជពុទ្ធបរិស័ទនេះ ។

ក្នុងនាមនៃពុទ្ធបរិស័ទទូទៅ និងពុទ្ធបរិស័ទ ដែលជាតំណាងសមា-គម តំណាងអង្គការ សាលាគណៈ អនុគណៈ ក្រុង ខេត្រ អនុខេត្រក្នុងសាធារណរដ្ឋខ្មែរ វត្តទាំងអស់ក្នុងរដ្ឋធានី ក្នុងនាមនៃពុទ្ធិកសមាគមមជ្ឈមណ្ឌលសាធារណរដ្ឋខ្មែរ និងក្នុងនាមនៃខ្ញុំព្រះករុណា ខ្ញុំបាទផ្ទាល់

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះវត្តមាន របស់សម្តេច ជាអម្ចាស់ ព្រះថេរានុត្ថេរៈ និង មិត្តទាំងអស់ ។

ថ្ងៃនេះ ប្រជាជនពុទ្ធមាមកៈ ក្នុងសាធារណរដ្ឋខ្មែរទាំងមូល ដែលមានយើងទាំងអស់គ្នានេះជាតំណាង បានមូលមកចូលមករួមប្រជុំក្នុងសាលសន្និសីទ ចតុមុខនេះ ដើម្បីធ្វើជាសមាជដ៏មហោឡារិកមួយ ក្នុងគោលបំណងបីយ៉ាង :

គោលបំណងទីមួយ : គឺដើម្បីសម្តែងនូវឆន្ទៈរួម ក្នុងការបញ្ចេញនូវមហាបាតុកម្ម ខាងផ្លូវដ៏ទៀងត្រង់មុតមាំរបស់យើងចំពោះព្រះពុទ្ធសាសនា ដែលជាសាសនារបស់សាធារណរដ្ឋខ្មែរ ។ យើងមានសទ្ធាសិប ដឹកនាំដោយបញ្ញាថា ព្រះពុទ្ធសាសនា ជាសាសនាដែលបានផ្តល់ឲ្យជនជាតិយើង នូវសេចក្តីចម្រើនរុងរឿងនូវសេចក្តីសុខ សន្តិភាពដ៏ត្រជាក់ត្រជុំទាំងផ្លូវកាយទាំងផ្លូវចិត្ត ព្រោះព្រះពុទ្ធសាសនា ជាសាសនា មិនបៀតបៀន ជាសាសនាផ្អែកទៅលើកម្មនិងផល ជាសាសនាផ្អែកលើបញ្ញា លើវិចារណញាណ ។

គោលបំណងទីពីរ : បើព្រះពុទ្ធសាសនា មានសារៈសំខាន់ប្រាកដដូច្នេះ ហើយបើយើងប្រាកដជាស្រឡាញ់ជំពោះមុតចំពោះព្រះពុទ្ធសាសនាយើងហើយ គប្បីយើងរួមគ្នាការពារព្រះពុទ្ធសាសនាដែលមានវត្តអារាម និងព្រះសង្ឃជាទីមិត្តរូប ជាពិសេសក្នុងកាលៈទេសៈ

បច្ចុប្បន្ន ដែលព្រះពុទ្ធសាសនាក្នុងសាធារណរដ្ឋយើងទទួលរងគ្រោះ រងការវិនាសប្រមាថមើលងាយគ្រប់បែបយ៉ាង ពីកងទ័ពឆ្កួល (ទមិឡ) កុម្មុយនិស្ត វៀតកុង - វៀតណាមខាងជើង ។

គោលបំណងទី២: ដោយព្រះពុទ្ធសាសនា ជាសាសនាអាចផ្សាយនូវការសុខស្ងប់ នូវសេចក្ដីសុខសន្តិភាពចំពោះប្រទេសនីមួយៗផង ចំពោះសាកលលោកទាំងមូលផង គប្បីយើងជាពុទ្ធបរិស័ទខំប្រឹងប្រែងរៀបចំយ៉ាងណា ដើម្បីផ្សព្វផ្សាយនូវអនុត្តរធម៌នៃព្រះសម្ពុទ្ធឲ្យបានទូលំទូលាយដោយហ្មត់ចត់ ប្រាកដប្រជាទូទៅគ្រប់សត្វលោក ។ ព្រះធម៌អាចរម្ងាប់នូវ លោភៈ ទោសៈ មោហៈ ដែលជាហេតុដើមនៃការឃោរឃៅ នៃការមិនគោរពសិទ្ធិ-សេរីភាពរបស់អ្នកដទៃ នៃការឈ្លានពាន ការមិនគោរពអធិបតេយ្យ ឯករាជ្យបូរណភាពដែនដី ។ ព្រះពុទ្ធសាសនា អាចផ្សព្វផ្សាយនូវ ព្រហ្មវិហារធម៌ ដែលជាមូលដ្ឋានដ៏ប្រពៃនៃការយោគយល់រវាងមនុស្សនិងមនុស្ស រវាងប្រទេសនិងប្រទេស ។

ក្នុងគោលបំណងបីយ៉ាងដូចបានរៀបរាប់មកនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមទាញអារម្មណ៍ ជាពិសេសរបស់សមាជពុទ្ធបរិស័ទថ្ងៃនេះ ទៅលើគ្រោះថ្នាក់ និងសេចក្ដីវិនាស ដែលពុទ្ធបរិស័ទខ្មែរយើង ដែលវត្តអារាមជាទីគោរពរបស់យើង កំពុងទទួលមកពីការប្រមាថឈ្លានពាន

របស់ខ្មាំងកុម្មុយនិស្តយៀកកុង យួនខាងជើង គឺរយៈពេលមួយឆ្នាំកន្លងមកហើយ និងអនាគត ដែលពុំដឹងជាថ្ងៃណាជាទីបញ្ចប់ ។

ដូចសម្តេចជាអម្ចាស់ ព្រះថេរានុត្ថេរៈ អស់លោកអ្នកជ្រាបខ្លះ ៗ ស្រាប់មកហើយ ពួកកុម្មុយនិស្តវាំងនេះ បានបំផ្លិចបំផ្លាញវត្តអស់ជិត ៣០០ វត្ត បណ្តាលឲ្យព្រះសង្ឃភៀសខ្លួន ពោលគឺសេនាសនៈរបស់ព្រះអង្គ មកស្នាក់នៅក្នុងវត្តជាទីចំនួន ៣៥៩ អង្គ និងភៀសខ្លួនទៅនៅតាមផ្ទះបងប្អូនជាច្រើនពាន់អង្គទៀត ។ ពួកយួនកុម្មុយនិស្តកំណាចនេះ បានធ្វើឃាតកម្មលើព្រះសង្ឃជាច្រើន ៗ មករហូតដល់ថ្ងៃទី ៣០ មីនា ១៩៧១ កន្លងទៅនេះ គឺបានធ្វើឃាតព្រះសង្ឃចំនួន ២៦ អង្គ ។ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមលើកយកឧទាហរណ៍ជាក់ស្តែងមួយមកប្រគេននិងជូនជ្រាប ដើម្បីនឹងបានជ្រាបនូវ គោលដៅពិតប្រាកដរបស់ពួកកុម្មុយនិស្តយៀក-កុង យៀកណាមខាងជើងឈ្លានពានទាំងនេះ ។

នៅថ្ងៃទី ៤ វិច្ឆិកា ១៩៧០ ពួកយួនកុម្មុយនិស្ត បានប្រមូលចៅអធិការវត្តចំនួន ១២០ វត្ត ពីខេត្ត តាកែវ កំពត កំពង់ស្ពឺ កំពង់ឆ្នាំង យកទៅប្រជុំនៅកន្លែងមួយ ក្នុងខាងលិចខេត្តកំពង់ឆ្នាំង ចំនួន ១៥ ថ្ងៃ ។ គេពន្យល់អំពីលទ្ធិកុម្មុយនិស្ត ហើយគេបញ្ជាឲ្យព្រះតេជព្រះគុណ ចៅអធិ-ការវត្តទាំងនោះ ឃោសនា ពន្យល់ប្រជាពលរដ្ឋអំពីលទ្ធិនេះ ។ បន្ទាប់មកព្រះសង្ឃមួយអង្គជាចៅអធិការវត្តបាលិទាស់ សង្កាត់ដំរះពេន

ស្រុកសំរេង ខេត្តតាកែវ ត្រូវគេខ្វេះព្រះនេត្រទាំងគូ ហើយធ្វើគតព្រះអង្គយ៉ាងអាខោចអាធម ព្រោះតែព្រះតេជព្រះគុណអង្គនេះរក្សាសេចក្ដីអង់អាច ការពារលទ្ធិព្រះពុទ្ធសាសនា ហើយមិនព្រមធ្វើតាមបញ្ជារ ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុញ្ញាតពុំរៀបរាប់ ថ្វាយ ប្រគេនជូននូវចំនួនមិនតិចទេ គុកណ្ឌព្រះពុទ្ធរូប វត្តសក្ការៈបូជា គម្ពីរដីកាផ្សេងៗ ដែលបាត់បង់ខូចខាតដោយការបាញ់ ដុតបំផ្លាញ ជាអំពើយង់ឃ្នងពាលសាមាន្យ នៃពួកខ្មែរឡុងប្រែនេះឡើយ ។

តែសូមទាញអារម្មណ៍សម្ដេចជាអម្ចាស់ ព្រះថេរានុត្ថេរៈ ពុទ្ធបរិស័ទព្រមទាំងអស់លោកអ្នកដែលគោរព និងជឿសាសនាដទៃទៀតក៏ដោយឲ្យបានយល់ច្បាស់ថា សង្គ្រាមដែលឆេះរាលដាលមកលើប្រទេសកម្ពុជាយើងនេះ មិនមែនគ្រាន់តែជាសង្គ្រាមដោះស្រាយបញ្ហាដែលមានរវាងយួននិងយួនប៉ុណ្ណោះ ដូចអ្នកផងតែងជឿនោះទេ ។ សង្គ្រាមនេះ ក្រៅអំពីគោលបំណងលើទឹកដី មានគោលដៅមួយធំទៀត គឺពង្រីកលទ្ធិកុម្មុយ-និស្តដោយចម្បាំង បើពោលឲ្យខ្លីទៅ គឺជាសង្គ្រាមសាសនាតែម្ដង ។ កុម្មុយនិស្តនិយម ជាលទ្ធិគ្មានសាសនា មិនជឿ ហើយមិនត្រឹមតែមិនជឿទេ គឺប្រឆាំងជាដាច់ខាត នឹងសាសនា ដែលសទ្ធាតុកក្នុងក្រាំង

ក្បួនរបស់គេថា ជាអាភៀន សម្រាប់សណ្តំសតិអារម្មណ៍របស់ប្រជាពលរដ្ឋ ៗ

អាស្រ័យហេតុដូចបានទូល និងជម្រាបមកនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមសម្តេចជាអម្ចាស់ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ពុទ្ធបរិស័ទគ្រប់រូប កុំព្រងើយកន្តើយនឹងរឿងចម្បាំងបច្ចុប្បន្ននេះ ព្រោះថាល្គឹកណាសាធារណរដ្ឋខ្មែរ នៅមានជោគជ័យ, ព្រះពុទ្ធសាសនាត្រូវតែអាចស្ថិតស្ថេរល្អតកកស់ទៅមុខបាន ៗ តែពេលណាដែលសាធារណរដ្ឋខ្មែរទទួលបកជ័យ ពេលនោះហើយដែលជាពេលបាប់ផុតរលត់នូវពន្លឺព្រះពុទ្ធសាសនា ពេលនោះហើយដែលខ្មែរទូទៅផុតរលត់នូវសិទ្ធិ សេរីភាពរបស់ខ្លួន ស្គាល់តែទុក្ខលំបាកឥតស្រាកស្រាន្ត គ្មានអ្វីជាទីពឹង ព្រោះសូម្បីតែព្រះសង្ឃដែលតែងតែជាម្លប់ ជាពន្លឺតាំងតែពីដូនតា ពប់ម៉ឺនកប់ពាន់ឆ្នាំមកហើយនោះ ក៏នឹងសាបសូន្យដែរ ៗ

យើងចាំជាក់ថា ព្រះពុទ្ធសាសនាយើងប្រកាន់ខ្ជាប់នូវមាគ៌អហឹ-សា ៗ យើងជាពុទ្ធបរិស័ទ ក៏ឥតមានវៀរចាកអហឹសាដែរ ឬថានឹងថាយើងទៅបៀតបៀនដនជាតិណា ប្រទេសណាមួយ ក៏ទេដែរ ៗ តែពោះជាយើងត្រូវតែប្រកាន់ខ្ជាប់នូវអហឹសានេះ ស្របទៅតាមគន្លងនៃព្រះធម៌ដ៏ឧត្តមក៏ដោយ ខ្ញុំព្រះករុណា ខ្ញុំបាទយល់ថា ក្នុងគ្រោះអាសន្ន ដែលមានគ្រោះថ្នាក់ដ៏ធ្ងន់មកគ្របសង្កត់លើយើង ហើយដែលយើងអាច

មើលឃើញអនាគតដ៏ច្បាស់ផងនោះ យើងពុំអាចគោបដៃចាំព្រេងសំណាងបានឡើយ ។ គឺចំណុចនេះហើយ ដែលជាចំណុចធំចំណុចសំខាន់ជាងចំណុចទាំងអស់ ក្នុងបច្ចុប្បន្នកាលនេះ ដែលសមាជពុទ្ធបរិស័ទត្រូវរិះរកមធ្យោបាយដោះស្រាយក្នុងថ្ងៃនេះ ។

ខ្ញុំព្រះករុណា ខ្ញុំបាទ មានសេចក្ដីសង្ឃឹមយ៉ាងមុតមាំថា ដោយព្រះបញ្ញាដ៏វាងវៃនៃសម្ដេចទាំងពីរព្រះអង្គ ដោយការរិះគិតរបស់ព្រះថេរា-នុត្ថេរៈគ្រប់ព្រះអង្គ និងដោយការឈ្លាសវៃនៃអស់លោក-អ្នកទាំងអស់ យើងនឹងរកឃើញជាមួយគ្នា នូវផ្លូវណាមួយដ៏ប្រពៃ ដើម្បីការពារព្រះពុទ្ធសាសនាផង ដើម្បីការពារសាសនាទាំងឡាយដែលផ្ដល់នូវសុខសន្តិភាពចំពោះមនុស្សជាតិ ដូចព្រះពុទ្ធសាសនាផង និងដើម្បីជាប្រយោជន៍ដល់ការយោគយល់រវាងមនុស្សនិងមនុស្ស រវាងជាតិនិងជាតិ រវាងលទ្ធិនិងលទ្ធិ ឲ្យកាន់តែទូលំទូលាយមែនទែនទៅទៀតផង ដើម្បីសន្តិភាពសាកលលោកផង ដើម្បីសុភមង្គលនៃមនុស្សជាតិទាំងមូលផង ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមឆ្លៀតឱកាសនេះ ដើម្បីថ្វាយ ប្រគេន និងជូននូវសព្ទសាធុការពរគ្រប់យ៉ាង ក្នុងពេលចូលឆ្នាំថ្មី ដែលទើបនឹងកន្លងទៅពីម្សិលមិញនេះ ។

សូមអរព្រះគុណ !

សូមអរគុណ !

បន្ទាប់ពីសេចក្តីថ្លែងរបស់លោកប្រធាននេះមក, លោក សុ-ណៃឆាយ អគ្គលេខាធិការនៃពុទ្ធិកសមាគម បានជម្រាបបញ្ជាក់ជូនទីប្រជុំជ្រាបអំពីចំនួនវត្តនិងអគ្គារនានាដែលបានមកចូលរួមក្នុងសមាជនេះ ព្រមទាំងបញ្ជាក់អំពីកម្មវិធីរបស់សមាជផង ។

តមក សមាជិកសមាជ ក៏បានថ្លែងយោបល់រៀង ៗ ខ្លួន ក្នុងទីប្រជុំសមាជ ។ ចាប់ផ្តើមមុនគេ គឺសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ទ្រង់ស្នើយោបល់ព្រះអង្គជូនសមាជ រួចហើយមានសមាជិកច្រើនរូបទៀតក៏បញ្ចេញយោបល់បន្តបន្ទាប់គ្នារហូតដល់ម៉ោង ១៧ ទើបមានការជ្រើសតាំងគណៈកម្មការមួយមានគ្នា ១១ រូប ដើម្បីទទួលភារៈតាក់តែងជាអត្ថបទ "សេចក្តីសម្រេចចិត្ត" របស់សមាជក្នុងបរិស័ទវេលានេះ ។ លោកប្រធានទីប្រជុំ សុំសមាជសម្រាកកន្លះម៉ោង ដើម្បីទុកពេលជូនគណៈកម្មការតាក់តែងតែងសេចក្តី ។ លុះម៉ោង ១៨ លោកប្រធាន និមន្ត-អញ្ជើញសមាជិកសមាជ ចូលកាន់ទីប្រជុំវិញហើយ គណៈកម្មការព្រាងបានជា "សេចក្តីសម្រេចចិត្ត" ក៏យកមកអានជូនសមាជិកអនុម័តដោយលើកដៃជាឯកច្ឆន្ទ ។

សេចក្តីសម្រេចចិត្តនោះមានទាំងស្រុងដូចតទៅ :

# សេចក្តីសម្រេចចិត្តនៃពុទ្ធបរិស័ទខ្មែរ ក្នុងឱកាសសមាជពុទ្ធសាសនិក ដើម្បីការពារព្រះពុទ្ធសាសនា

## នៅថ្ងៃទី ១៧ មេសា ១៩៧១ នៅសាលចតុម្មុខ ក្រុងភ្នំពេញ

---

- ដោយវត្តអារាមជាព្រលឹងខ្មែរ ជាមូលដ្ឋាននៃវប្បធម៌ និង ប្រពៃណីខ្មែរ ជានិមិត្តរូបនៃព្រះពុទ្ធសាសនា ដែលខ្មែរទាំងអស់គ្នាបានគោរពបូជារាប់ពាន់ឆ្នាំមកហើយ

- ដោយបានឃើញថា ចាប់ពីថ្ងៃទី ២៣ មីនា ១៩៧០ រហូតដល់ ១៧ មេសា ១៩៧១ កងទ័ពវៀតកុង-វៀតណាមខាងជើង តែងបានយកវត្តអារាមធ្វើជាមូលដ្ឋានសឹក ហើយបានបំផ្លិចបំផ្លាញវត្តអារាមទាំងនោះអស់ចំនួន ២០៥ វត្តហើយ

- ដោយមានព្រះសង្ឃជាច្រើនអង្គ បានទទួលការុណកម្មយ៉ាងព្រៃផ្សៃ រហូតដល់បាត់បង់ព្រះជន្មាយុ ឬក្លាយទៅជាពិការដេក ៗ

- ដោយបានឃើញព្រះសង្ឃរាប់ពាន់អង្គ បានចាកចោលវត្តអារាម ខានរៀនសូត្រធម៌វិន័យ ខានធ្វើកិច្ចប្រតិបត្តិ តាមគន្លងព្រះពុទ្ធសាសនា ដោយសារតែមានអំពើឈ្លានពានពីពួកទមិឡអន្យតិរ្ថិយ

- ដោយឃើញថា សម្បត្តិវប្បធម៌ ព្រះពុទ្ធរូប គ្រឿងសក្ការបូជា និងប្រាសាទអង្គរដែលជាបេតិកភណ្ឌដ៏ឧត្តុង្គឧត្តមរបស់ជនជាតិខ្មែរ ត្រូវ

ពួកឈ្មានពានទឹកដី បានកំទេច បំផ្លាញឲ្យវិនាស ខាតខាយអស់យ៉ាង ច្រើន

- ដោយឃើញថា ការឈ្លានពានពីទមិឡយៀកកុង យៀក ណាមខាងជើង មកលើព្រះពុទ្ធសាសនាគឺមកលើព្រះសង្ឃ មកលើវត្ត អារាម មកលើសម្បត្តិវប្បធម៌ខ្មែរ ជាអំពើបំផ្លិចបំផ្លាញយ៉ាងសាហាវ យង់ឃ្នងព្រៃផ្សៃ ដែលការផ្ទុនកងលោក គេមិនដែលប្រព្រឹត្តសោះ ឡើយ ។

- ដោយឃើញថា ពុទ្ធសាសនិកខ្មែរជាអ្នកគោរពព្យាក្រឹត កាន់ ធម៌អហឹសាដ៏បរិសុទ្ធ ចង់បានតែសន្តិភាព និង សេចក្តីសុខសាន្តតែ ប៉ុណ្ណោះ ។

- ដោយជឿជាក់ថា ព្រះពុទ្ធសាសនា ជាសាសនាត្រជាក់ ត្រជុំបរមសុខ ។

អាត្មាភាព យើងខ្ញុំទាំងអស់គ្នា ជាពុទ្ធសាសនិក ទាំងសង្ឃ ទាំង គ្រហស្ថ ដែលជាតំណាងគ្រប់វត្ត គ្រប់មជ្ឈដ្ឋាន គ្រប់សមាគម គ្រប់ សង្កាត់ស្រុក ក្រុង ខេត្ត ដែលបានរួមប្រជុំសមាជពុទ្ធបរិស័ទ នាថ្ងៃទី ១៧ មេសា ១៩៧១ នេះ

បានសម្រេចចិត្តជូនទៅ :

១- សុំឲ្យរដ្ឋាភិបាលស្រោចស្រង់ជាតិ ផ្សាយឲ្យបានច្បាស់លាស់

ឲ្យបានពិតប្រាកដ ទៅតាមគន្លងដែលគេចេញជាការប្រតិបត្តិជាក់ស្តែង ពីអ្នកដឹកនាំគ្រប់មជ្ឈដ្ឋាន មានសច្ចធម៌ សុចរិតធម៌ យុត្តិធម៌ សមភាព ជាដើម ។

២- សូមឲ្យរដ្ឋាភិបាលស្រោចស្រង់ជាតិ ចាត់ការគ្រប់មធ្យោ-បាយយ៉ាងម៉ឺងម៉ាត់ ទាំងខាងផ្លូវអប់រំ ទាំងខាងផ្លូវចិត្តសាស្ត្រ ដើម្បីរក្សាពុទ្ធបរិស័ទឲ្យបានមូលចិត្ត មូលគំនិត មូលកម្លាំងជុំវិញរដ្ឋាភិបាល ។

៣- សូមឲ្យពុទ្ធបរិស័ទគ្រប់ប្រភេទ គ្រប់មជ្ឈដ្ឋានរួមកម្លាំងគ្រប់វិស័យ ដើម្បីរក្សាពុទ្ធសាសនាឲ្យបានគង់វង្សតទៅ ។

៤- សូមរដ្ឋាភិបាល ចាត់ការគ្រប់បែបយ៉ាង ដើម្បីដាក់បញ្ចូលវត្ត វត្ថុទាំងឡាយ ដែលនៅក្នុងវត្ត មានព្រះពុទ្ធរូប គ្រឿងសក្ការៈបូជាទាំងឡាយ គម្ពីរដីកានានា ជាសម្បត្តិវប្បធម៌ហើយថែរក្សាការពារ ដូចសម្បត្តិវប្បធម៌ដទៃទៀត តាមបទបញ្ញត្តិនានា ដែលមានចែងក្នុងសន្ធិសញ្ញាក្រុងឡាអេ ឆ្នាំ១៩៥៤ស្តីពីការពារសម្បត្តិវប្បធម៌ ក្នុងពេលសង្គ្រាម ហើយទុកព្រះសង្ឃដែលថែរក្សាវត្តដូចជាអ្នកទទួលភារៈថែរក្សាប្រាសាទបុរាណ ដែលអង្គការអន្តរជាតិ ត្រូវទទួលស្គាល់ ។

៥- ពលរដ្ឋខ្មែរ ពុទ្ធបរិស័ទខ្មែរ មិនត្រៀតត្រែកក្នុងបញ្ហាពលរដ្ឋប្រទេសដទៃឡើយ ។ បញ្ហាយួន ត្រូវទុកឲ្យយួនដោះស្រាយ តាមបទបញ្ញត្តិនៃធម្មនុញ្ញសហប្រជាជាតិ ... បញ្ហាយួនត្រូវស្ថិតនៅតែជា

បញ្ហាយួន មិនត្រូវពាលដាលដល់ប្រទេសខ្មែរឡើយ ។

២- សូមរដ្ឋាភិបាលស្រោចស្រង់ជាតិ អំពាវនាវដល់គ្រប់អង្គការសាសនាក្នុងពិភពលោកឲ្យគេយល់ច្បាស់នូវការពិត អំពីអំពើយង់ឃ្នងអមនុស្សធម៌ដែលយួនកុម្មុយនិស្ត គឺយួនវៀតណាមខាងជើង យួនវៀតកុង បានប្រព្រឹត្តមកលើប្រជាជាតិខ្មែរ និងព្រះពុទ្ធសាសនា ហើយសូមអំពាវនាវដល់អង្គការសាសនាទាំងអស់នោះ ឲ្យរួមសាមគ្គី ក្នុងរណសិរ្សរួមជាតិចម្រុះសាសនាមួយ ដើម្បីទាមទារសិទ្ធិក្នុងជំនឿដែលអង្គការសហប្រជាជាតិ បានដាក់អះអាងក្នុងសេចក្ដីប្រកាសជាសាកលនូវសិទ្ធិនៃមនុស្ស ។

៣- សូមឲ្យរដ្ឋាភិបាលស្រោចស្រង់ជាតិ រៀបឲ្យមានសមាជសាកលលោកផ្នែកសាសនាមួយ ដើម្បីធ្វើឲ្យមានប្រសិទ្ធិភាពដល់សេចក្ដីសម្រេចចិត្ត ក្នុងខ ទី ២ ។ ឯទីកន្លែងប្រជុំសមាជនោះ សូមស្នើឲ្យធ្វើនៅក្រុងភ្នំពេញក្នុងពេលឆាប់ៗ ។

## ជូនដំណឹង

ដោយកាលទេសៈសព្វថ្ងៃ ការបោះពុម្ពត្រូវលំបាកដោយសារក្រដាសឡើងថ្លៃ ហើយដោយបំណងយើង មិនចង់ឱ្យទស្សនាវដ្ដីនេះឡើងថ្លៃតាមក្រដាសនោះ គណៈកម្មការបោះពុម្ពទស្សនាវដ្ដី ក៏សម្រេច ទុកនៅតម្លៃជាវដដែលដូចឆ្នាំមុន គឺ ១ ក្បាល២០ រៀល មួយឆ្នាំ ១២ ក្បាល ២៣០ រៀល ប៉ុន្តែយើងត្រូវបន្ថយទំព័រតិចជាងឆ្នាំមុនបន្តិច ។

ហេតុនេះ សូមលោក-អ្នកអាន មេត្តាអភ័យទោស តាមកាលទេសៈនេះឱ្យទាន ។

ពុទ្ធសាសនបណ្ឌិត្យ

៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤៣ ខែ មីនា

ព.ស. ២៥១៤ គ.ស. ១៩៧១

- ភ្នំពេញ -

៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : លាង ហ័បអាន

និពន្ធនាយក - អ្នករៀបចំ : លី ធាមតេង

គណៈកម្មការនិពន្ធ :

ព្រះពោធិវង្ស សួរ-ហាះយ

លោក ឌឹក-គាម អ្នកស្រី ពេជ-សល់

# បញ្ជីរឿង

| អត្ថបទ | ទំព័រ |
| --- | --- |

## ១– ផ្នែកសាសនា


១– សីលាទិសំសដ្ឋក ស្នាព្រះហស្តបញ្ញាមរាណ: នៃសម្តេចព្រះសង្ឃរាជ ១៩១

២ ព្រះពុទ្ធបដិភាគណាមួយ លោកញ៉ុក-ថែម រៀបរៀង . . . ២០២


## ២– ផ្នែកអក្សរសាស្ត្រ


៣– វិចារណកថា : ធាតុពិតរបស់មនុស្ស លោក ផេង-ជ្រីវ រៀបរៀង ២១០

៤– រឿងសាមកុក លោក ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . ២១៩

៥ រឿងរាជកុល ចម្លងពិនិត្យផ្ទៀងផ្ទាត់ដោយ លោក ឌឹក គាម . . ២៣៧

៦ – ឧបនិស្ស័យ និង ទស្សនវិជ្ជាព្រាហ្មណ៍ ព្រះភិក្ខុ ប៉ាង-ខាត រៀបរៀង . ២៥១

៧– ឯកសារទំនៀមទម្លាប់ ទំនៀមឲ្យឈ្មោះ អ្នកស្រី ពេជ-សល់ រៀបរៀង ២៦៧


## តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០៛០០ ៗ

អាណត្តិសូមផ្ញើជា : លោកនាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

## ផ្នែកសាសនា

### ស្នាព្រះហស្ដបច្ឆាមរណៈ នៃ សម្ដេចព្រះសង្ឃរាជ ជ.ណ.

# សីលានិសំសជាតក

## ជាតកនិយាយពីអានិសង្សសីល

(ព្រមទាំងនិគមគាថា និង កាព្យពាក្យ ៧)

---

បស្ស សទ្ធាយ សីលស្សាតិ ឥទំ សត្ថា ជេត-វនេ វិហរន្តោ ឯកំ សទ្ធំ ឧបាសកំ អារព្ភ កថេសិ ព្រះបរមសាស្ដាទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់សម្ដែងនូវសីលា-និសំសជាតកនេះ មានគាថាបាលីថា បស្ស សទ្ធាយ សីល-ស្ស ជាដើម ប្រារព្ធចំពោះឧបាសកម្នាក់ជាអ្នកមានសទ្ធា ។

មានរឿងថា ឧបាសកនោះ ជាអរិយសាវកអ្នកមានសទ្ធាជ្រះថ្លាណាស់ ថ្ងៃមួយឧបាសកនោះទៅកាន់វត្តជេតពន នៅវេលារសៀលទាប បានដល់ទៅត្រើយម្ខាងនៃទន្លេអចិរវតី មិនឃើញមានទូកនឹងឆ្លងទៅត្រើយនាយសោះ ពីព្រោះអ្នកមានទូកទាំងអស់ ដែលធ្លាប់តែចម្លងមនុស្ស គេឆ្លងទៅចតឯត្រើយខាងនាយ ហើយគេនៅស្ដាប់ព្រះធម្មទេសនាឯវត្តជេតពនអស់ទៅ ។ ឧបាសកនោះនឹករំពឹងព្រះពុទ្ធគុណយកជាអា-រម្មណ៍ដ៏មុតមាំក្នុងចិត្ត កើតមានបីតិដ៏ខ្លាំងក្លា ក៏ដើរលើខ្នងទឹកដូចគេ

ដើរលើផែនដី ដើម្បីឆ្លងទៅឲ្យបានដល់ត្រើយនាយឥតមានផុងជើង ឬ
ទទឹកជើងឡើយ កំពុងដើរលើទឹកដល់ទៅពាក់កណ្តាលទន្លេ បានឃើញ
រលកទឹកឃោលឃ្លោល ។ បីតិដ៏មានកម្លាំងនោះក៏បែរជាទន់ខ្សោយបន្តិច
ទៅវិញ ជើងទាំងពីរកកល់ទឹងផុងទៅក្នុងទឹក គាត់ខំរំពឹងព្រះពុទ្ធគុណ
ឲ្យកើតបីតិខ្លាំងឡើងវិញទៀត គាត់ក៏ដើរលើខ្នងទឹកបានងាយស្រួលដូច
ពីមុន ចេះតែដើរស្រូតរហូតដល់បានឆ្លងផុតទៅដល់ត្រើយម្ខាង ហើយ
ដើរចូលទៅវត្តជេតពនក្រាបថ្វាយបង្គំព្រះបរមសាស្តា ហើយគាត់អង្គុយ
ត្រង់ទីមួយដ៏សមគួរ ។

ព្រះសម្ពុទ្ធបរមសាស្តា ទ្រង់ធ្វើបដិសណ្ឋារៈ តាមការគួរជាមួយនឹង
គាត់ហើយ ព្រះអង្គត្រាស់សួរថា ម្នាលឧបាសក អ្នកឯងមកតាមផ្លូវមិន
សួរមានក្តីលំបាកទេឬ ? គាត់ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស
ខ្ញុំព្រះអង្គញុំាងបីតិមានព្រះពុទ្ធគុណជាអារម្មណ៍ដ៏រឹងប៉ឹង ក៏ដើរលើខ្នងទឹក
មកហាក់ដូចជាគេដើរជាន់លើផ្ទៃដី ឥតបីលំបាកទេរហូតមកដល់ទីនេះ ។
ព្រះបរមសាស្តាទ្រង់តបវិញថា អើឧបាសក ដែលអ្នកឯងនឹកគុណព្រះ
ពុទ្ធ យកពុទ្ធគុណជាអារម្មណ៍ដ៏មាំក្នុងចិត្តយ៉ាងនេះ ពុំមែនមានត្រឹមតែ
អ្នកឯងក្នុងកាលនេះប៉ុណ្ណោះទេ ធ្លាប់មានរឿងតាំងពីក្នុងបុរាណកាលព្រេង
នាយមកហើយដែរ ពីព្រេងនាយ មានឧបាសកទាំងឡាយ បានធ្វើ
ដំណើរតាមសមុទ្រ សំពៅបែកធ្លាយក្នុងកណ្តាលមហាសមុទ្រ គេរំលឹកពុទ្ធ-

គុណទាំងឡាយ ក៏បាននូវទីពំនាក់ដូចអ្នកឯងឥឡូវនេះដែរ ។ ឧបាសកនោះក្រាបទូលអារាធនា, ព្រះអង្គសម្តែងអតីតនិទានថា :

អតីតេ កស្សបសម្មាសម្ពុទ្ធកាលេ សោតាបន្នោ អរិយសាវកោ ឯកេន នហាបិតកុដុម្ពិកេន សទ្ធឹ នាវំ អភិរូហិ ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធកស្សបដែលកន្លងយូរណាស់ទៅហើយ មានឧបាសកសោតាបន្នបុគ្គល ជាអរិយសាវកម្នាក់បានចុះសំពៅជាមួយនឹងកុដុម្ពិកជាជាងកោរកាត់សក់ម្នាក់ ភរិយារបស់ជាងកោរកាត់សក់នោះ បាននិយាយផ្ទុកផ្តាក់ផ្តាំផ្ញើនឹងឧបាសកនោះថា "សុខទុក្ខរបស់ប្តីខ្ញុំ ជាភារៈនៃអ្នកទាំងអស់ ( ខ្ញុំទុកចិត្តលើអ្នក ) " ។ លុះសំពៅចេញទៅបាន ៧ ថ្ងៃ ក៏បែកធ្លាយក្នុងកណ្តាលលំហសមុទ្រ ។ ជនទាំងពីរនាក់បានដេកផ្ងារលើក្តារមួយបន្ទះជាមួយគ្នា បន្ទះក្តារសាត់ទៅដល់កោះតូចមួយ ក៏នាំគ្នាឡើងទៅនៅលើកោះនោះ ។ ជាងកោរកាត់សក់បានសម្លាប់សត្វស្លាបទាំងឡាយយកមកអាំងស៊ី បានបែកឲ្យឧបាសកនោះផង ប៉ុន្តែឧបាសកប្រកែក មិនព្រមទទួលយកមកបរិភោគផងទេ គាត់គិតឃើញថា ក្នុងទីនេះ ក្រៅពីត្រ័យសរណៈឥតមានអ្វីជាទីពឹងពំនាក់របស់យើងឡើយ គិតឃើញយ៉ាងនេះហើយគាត់ក៏ចេះតែរំលឹកគុណទាំងឡាយនៃព្រះរត្នត្រ័យជានិច្ចនិរន្តរ៍ ។ កាលដែលឧបាសកនោះរំលឹកគុណព្រះរត្នត្រ័យជានិច្ចយ៉ាងនេះ តស្មិំ ទីបកេ និព្វត្តោ នាគរាជា អត្តនោ សរីរំ មហានាវំ កត្វា

មាបេសិ នាគរាជដែលកើតនៅក្នុងកោះតូចនោះ ក៏និម្មិតក្លាយខ្លួនធ្វើ ជាសំពៅធំ ។ សមុទ្ទទេវតា និយាមកោ ហាណាវេ អហោសិ សមុទ្ទទេវតាក្លាយខ្លួន ជាមាណពអ្នកកាច់ចង្កូត ។ នាវា សត្តរតនេហិ បូរយិត្ថ សំពៅនោះផ្ទុកពេញដោយរតនៈ ៧ ប្រការ ។ តយោ កូបកា ឥន្ទនីលមណិមយា អហេសុំ ដងក្តោងទាំង ៣ សុទ្ធតែជាកែវឥន្ទនីល សោវណ្ណមយា លង-ការា ស្លាបក្តោងសុទ្ធតែជាមាស រជតមយានិ យោត្តានិ ខ្សែលុកខ្សែលៀវសុទ្ធតែជាប្រាក់ សោវណ្ណមយានិ យដ្ឋិ-យានិ ដងសាវទាំងឡាយសុទ្ធតែជាមាស ។ សមុទ្ទទេវតា នា-វាយ ឋត្វា អត្ថិ ជម្ពុទីបំ គមិកាតិ ឃោសេតិ សមុទ្ទ-ទេវតា បើកសំពៅមកចតក្បែរកោះតូចនោះ ស្រែកខ្លាំង សួរថា “មានអ្នកណាត្រូវការទៅជម្ពូទ្វីបដែរឬទេ(១) ?” ឧបាសកោ មយំ គមិស្សាមាតិ អាហ ឧបាសកនិយាយថា “យើងត្រូវការទៅ” ។ តេនហិ ឯហិ នាវំ អភិរូហាតិ សមុទ្ទទេវតាថា “បើដូច្នោះ មក ចុះសំពៅមក ! ” ។ ឧបាសកនោះចុះសំពៅហើយស្រែកហៅ ជាងកោរកាត់សក់ឱ្យចុះសំពៅជាមួយផង ។ សមុទ្ទទេវតានិយាយថា “ចុះមកបានតែអ្នកឯងប៉ុណ្ណឹង មិនឱ្យអ្នកម្នាក់ទៀតចុះមកជាមួយផងទេ!” ។

១- ជម្ពូទ្វីបនេះ គឺប្រទេសឥណ្ឌាសម័យសព្វថ្ងៃ ។

កឹ ការណាតិ ? ឧបាសកសួរថា "ម៉េចក៏មិនឲ្យគាត់ចុះមកផង ?" សមុទ្ទទេវតាថា ពីព្រោះគាត់ហ្នឹងគ្មានសីលាចារគុណ ព្រោះហេតុនោះ ខ្ញុំបើកសំពៅមកយកតែអ្នកឯងម្នាក់ប៉ុណ្ណឹង មិនបម្រុងនឹងយកអ្នកម្នាក់ហ្នឹងផងទេ ។ ហោតុ អហំ អត្តនោ ទិន្នទានេន រក្ខិត-សីលេន ការិតការណាយ ឯតស្ស បត្តិំ ទម្មិ ឧបាសកនិយាយថា "នុ ! បើដូច្នោះ ខ្ញុំឲ្យចំណែកផលបុណ្យដែលខ្ញុំ បានឲ្យទានបានរក្សាសីល បានចម្រើនភាវនាដល់អ្នកហ្នឹងផង" ។ នហា-បិតោ អនុមោទាមីតិ អាហ ជាងកោរកាត់សក់ថា "ខ្ញុំសូមទទួលអនុមោទនា" គឺគាត់តាំងចិត្តត្រេកអរចំពោះផលបុណ្យដែលឧបា-សកនោះចែកឲ្យគាត់ ។ សមុទ្ទទេវតាក៏យល់ព្រមឲ្យជាងកោរកាត់សក់នោះចុះសំពៅមកផងដែរ ហើយក៏បើកសំពៅត្រាតែចេញផុតពីសមុទ្រចូលតាមដងទន្លេ (គង្គា)[១] បានដល់ទៅក្រុងពារាណសី ហើយប្រើឫទ្ធានុ-ភាពរបស់ខ្លួនជាទេវតា នាំយកទ្រព្យទាំងអស់ទៅដាក់ឯផ្ទះនៃជនទាំងពីរនាក់ ហើយនិយាយរំលឹកថា បណ្ឌិតេហិ សទ្ធឹ សំស-គ្គោ នាម កាតព្វោ សចេ ឥមស្ស នហាបិតស្ស ឥមិនា ឧបាសកេន សទ្ធឹ សំសគ្គោ នាភវិស្ស សមុទ្ទមជ្ឈេយេវ នស្សិស្សតីតិ បណ្ឌិតសំសគ្គស្ស

១- គួរយល់ថា ដោយឫទ្ធានុភាពនៃទេវតា ឥតមានអ្នកណាមើលសំពៅនេះឃើញទេ ។

កុលេណា តជយមានា ទិមា តាថា អវេច “បុគ្គល គួរធ្វើការសេពគប់រាប់រកយកបណ្ឌិតជាមិត្រជាគ្នា ជាងកោរកាត់សក់ បើកុំតែបានសេពគប់រាប់រកយកឧបាសកនេះជាគ្នា កុំអីវិនាសអន្តរាយក្នុងកណ្ដាលមហាសមុទ្រទៅហើយ !” សមុទ្ទទេវតាថ្លែងគុណនៃបណ្ឌិត-សំសគ្គធម៌ គឺធម៌សេពគប់រាប់រកយកបណ្ឌិតសប្បុរសជាមិត្រជាគ្នាតែត្រឹមប៉ុណ្ណោះហើយ ក៏ពោលគាថានេះថា៖

បស្ស សទ្ធាយ សីលស្ស ចាគស្ស ច អយំ[១] ផលំ
នាគោ នាវាយ វណ្ណេន សទ្ធំ វហតិ ឧបាសកំ[២] ។

ចូរមើលចុះ! នេះគឺជាផលានិសង្សនៃសទ្ធា សីល បរិច្ចាគ ទាន ដែលកាឡាខ្លួនជាសំពៅមកនាំឧបាសកអ្នកមានសទ្ធា (ក៏ព្រោះតែសីលាទិគុណនេះឯង) ។

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ ហិ សន្និវាសេន សោត្ថឹ គច្ឆតិ នហាបិតោ ។

បុគ្គលគួរសេពគប់រាប់រកយកសប្បុរសទាំងឡាយជាគ្នា គួរធ្វើនូវមិត្ត-សន្ថវៈ គឺគួររាប់រកយកសប្បុរសជនជាមិត្រ ដូចជាជាងកោរកាត់សក់បាននូវសួស្ដីសិរីសុខចម្រើន ដោយសារការនៅរួបរួមកម្សត់កម្រជាមួយនឹងឧបាសកជាសប្បុរសនេះឯង ។

---

១- ឥទន្តិ ឥមិស្សំ អដ្ឋកថាយំលិខិតំ ។ ២- វហតុបាសកន្តិបិ ។

សមុទ្ទទេវតា ឋិតនៅឯអាកាស សម្ដែងពាក្យខ្លួនយ៉ាងនេះហើយ ក៏នាំនាគរាជទៅកាន់ឋានវិមានរបស់ខ្លួនវិញ ។

ព្រះសក្យមុនីសម្ពុទ្ធជាបរមសាស្ដា ទ្រង់សម្ដែងរឿងជាអតីតនិទាននេះចប់ហើយ ព្រះអង្គប្រកាសនូវអរិយសច្ចធម៌ទាំង ៤ លុះចប់អរិយសច្ចធម៌ហើយ ឧបាសកនោះបានសម្រេចដល់សកទាគាមិផល ។ ព្រះបរមសាស្ដា ទ្រង់ប្រជុំជាតកថា ឧបាសកសោតាបន្នជាអរិយសាវ័កក្នុងកាលនៃព្រះពុទ្ធកស្សបនោះ បានចម្រើននូវអរិយមគ្គ ៗ ទៅទៀតត្រាតែបានសម្រេចអរហត្តផលហើយចូលបរិនិព្វានទៅ ។ នាគរាជក្នុងកាលណោះ អន្ទោលជាតិមកកើតជាសារីបុត្ត ឯសមុទ្ទទេវតាគឺអញតថាគតនេះឯង ។

សីលានិសំសជាតកាទី ១០

ក្នុងអសទិសវគ្គទី ៤ នៃ

ទុកនិបាតវណ្ណនា

-ចប់-

## និគមពាក្យ

និគមវចនេន បនិមា អដ្ឋុរំសនិពទ្ធគាថា

ជ.ណា. ជោតញ្ញាណេន សង្ឃរាជេន រចិតា មយា :

បសន្នេ សាធូ អភិសេវនំ តាកំ

ភោភណាជម្ពុំ សុគតេន ទេសិតំ
សុត្វាបិ សក្កច្ច គារវេន សេវនំ
សីលានិសំសោ បដិទេតិ ត្រៀទិសំ ។
ឃរម្បិ សីលំ អតិតេជវន្តកំ
តស្មា ហិ រក្ខេយ្យ អនូនកំ សទា
សីលញ្ច យោគិស្ស ផលប្បទាយកំ
សីលប្បិយោ ទេវនិកាយរក្ខិតោ ។
កាលេបិ ទុក្ខំ អនុភោតិ យោ នរោ
សោត្វានិសំសំ លភតេវ សោ នរោ
ទេវានុរក្ខញ្ច លភេតិ បណ្ឌិតោ
ភោភណាវត្ថុម្ហិ ឧបាសកោ យថាតិ ។

ចូរសាធុសប្បុរសទាំងឡាយរមិលមើលនូវការសេពគប់ រាប់រកគ្នា ដែលគេបានធ្វើហើយឲ្យជាតម្រាប់ ជាធម៌ដែលគេកាន់រក្សា ក្នុងសម័យបុរាណព្រេងនាយ ដែលព្រះសុគតបរមសាស្ដាទ្រង់សម្ដែងប្រទាននេះចុះ ! បើអស់លោក-អ្នកបានអានបានស្ដាប់ហើយ ចូរធ្វើនូវការសេពគប់ឲ្យស៊ប់ (ចំពោះតែជនជាសប្បុរស កុំសេពគប់ជនជាអសប្បុរសឡើយ) សីលានិសង្សតែងតែផ្ដល់ផលជាសុខចម្រើន ឲ្យដូចរឿងនិទានក្នុងសីលានិសំសជាតកនេះឯង ។ សីលមានតេជះជាក់ស្ដែងក្រៃលែងយ៉ាងនេះ, ហេតុ

នោះ សាធុជនគួររក្សាសីលអស់កាលជានិច្ចកុំឲ្យខ្វះខាត សីលជាគុណជាត ផ្ដល់ផលឲ្យដល់យោគីអ្នកកាន់សីលខ្ជាប់ ជនអ្នកមានសីលជាទីស្រឡាញ់ ពួកទេពតាតែងតែបីបាច់រក្សា ។ ជនអ្នកកាន់សីលណា បើមានទុក្ខព្រួយមួយដងមួយកាល ជនៈនោះតែងតែបាននូវសោត្ថានិសង្ស គឺអានិសង្សជាសុខសួស្ដីសិរីចម្រើន បណ្ឌិត (អ្នកកាន់សីលដ៏ឧត្ដម) តែងតែបាននូវទេវានុរក្ស គឺការបីបាច់រក្សានៃទេពតា ដូចជាឧបាសក (លិចសំពៅ) ក្នុងរឿងនិទានសម័យបុរាណ (ដែលបានពោលរួចហើយ) នោះឯង ។

# កាព្យសម្រាយឱ្យងាយចាំ

## ពាក្យ ៧

កាន់សីលមានសីលជាទីពឹង ពំនឹងថាជាមិត្រមេត្រី
ប្រសើរជាងមិត្រនាលោកីយ៍ សីលចេះតែថ្មីឥតចេះចាស់ ។
កាលពីព្រេងនាយសីលក៏ថ្មី ស្ព្រាវនេះក្ដីនៅជាក់ច្បាស់
ព្រោះសីលបរិសុទ្ធប្រសើរណាស់ ឥតចាស់ទេនៅថ្មីសន្ធាន ។
ព្រះពុទ្ធត្រាស់ថាក្រៅពីសីល មានចាស់រេចរិលព្រោះរូបកាន
តែងតែគ្រាំគ្រាឥតគ្រឿងការ មិនថ្មីសន្ធានដូចសីលឡើយ ។
កុំពោលថាសីលមានថ្មីចាស់ ពោលនោះខុសណាស់ពេកពេកហើយ
បើសីលមានចាស់មែនម្ដេចឡើយ យើងកាន់ក្រោយគេនឹងបានបុណ្យ ។

អ្នកណាគេកាន់ជាប្រក្រតី សីលគេថ្មីៗ តតមានស្អុខ
អ្នកនោះគេមានសីលជាគុណ ផ្ដល់បុណ្យឲ្យគេបានសុខា ។
សីលមានត្រង់ចេតនាវៀរ- បាកចិត្តចង់ពៀរកម្មពុំជា
សីលនៅត្រង់វិរចិត្តា ព្រះពុទ្ធៈហៅថាជាតួសីល(១) ។
ពុំមែនហៅសីលត្រង់មាត់ថា ទោះថាច្រើនចប់ប៉ុន្ដែខិល
មិនកាន់តាមមាត់ថាកាន់សីល សីលរេចសីលវិលព្រោះមិនកាន់ ។
កាន់សីលឧក្រិដ្ឋវែងមានផល ផ្ដល់សុខឲ្យឃើញប្រត្យក្សស្បាន់
ទោះមានគ្រោះកាចមិនភ័យភ័ន្ត មិនស្ទន់មិនស្ទុតឲ្យសៅហ្មង ។
ដូចរឿងនិទានឧបាសក ដែលជាងកាត់សក់គាត់បានផ្គង
យកសាច់អាំងឆ្អិនឲ្យស៊ីផង ខ្ជាបសីលសៅហ្មងមិនព្រមស៊ី ។
ស្រឡាញ់សីលណាស់ជាងជីវិត មិនគិតប៉ុន្មានដល់ជីវី
ខំផ្ចង់កាន់សីលតាមវិធី មុនីបណ្ឌិតពិតទៀងត្រង់ ។
បានជាស្ដេចនាគនិងទេព្ដា រក្សាសមុទ្រថ្លៃងរូបអង្គ
ជានាវាធំបើកតម្រង់ ផ្ចង់មកនាំយកទៅដល់ឋាន ។
អហំ ជ.ណ. ជោតញ្ញាណ បានស្រង់និទានតាមលំអាន
គម្ពីរជាតកពីបុរាណ ដែលព្រះទ្រង់ញាណប្រទានប្រាប់ ។

---

១- ព្រះពុទ្ធត្រាស់ថា ចេតនាហំ ភិក្ខវេ សីលំ វទាមិ “ ម្នាលភិក្ខុទាំងឡាយ អញតថាគតហៅវិរតិចេតនា ថាជាតួសីល ” ។

ប្រសិនបើលោក-អ្នកអាចកាន់ សីលឲ្យជាក់ស្បាន់តាមបណ្ដាប់
នៃព្រាហ្មព្រេងនាយជាគម្រាប់ នឹងបានផលគាប់ប្រសើរហោង ។

វត្តខណ្ឌាលោម ព្រះរាជធានីភ្នំពេញ ថ្ងៃពុធទី ២៥ ធ្នូ ២៥១២/១៩៦៨

## សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ

## ជ·ណ. ជោតញ្ញាណោ

## ប.អ.ស–អ.ម.វ.

# ព្រះពុទ្ធបដិភាណមួយ

## ក្នុងចំណោមព្រះពុទ្ធបដិភាណដ៏ច្រើនអនេក

ស្ដីអំពីការដោះចាប់កំហុសរបស់និគ្រន្ថ ចំពោះការតិះដៀលទេវទត្ត នៃព្រះពុទ្ធជាម្ចាស់។

---

សេចក្ដីដកស្រង់ប្រែសម្រួល អំពី អភយរាជកុមារសូត្រ

គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ផ្នែកសុត្តន្តបិដក ។

ដោយ

លោក ញ៉ុក ថែម

---

គ្រាមួយនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់គង់ប្រថាប់នៅក្នុងវេឡុវ័នវិហារ នាក្រុងរាជគ្រឹះ (ដែនមគធរដ្ឋ) ។ កាលនោះ ព្រះអភយរាជកុមារ បានចូលទៅរកនិគ្រន្ថនាដបុត្រ ជាបព្វជិត (ក្រៅពុទ្ធសាសនា) ដែលមនុស្សទាំងឡាយធ្លាប់រាប់អានថាជាគណាចារ្យ ១ ធំ (ក្នុងសម័យនោះ) ។

លំដាប់នោះ និគ្រន្ថបានពោលថា "នែព្រះរាជកុមារ ចូរទ្រង់ទៅនិយាយចាប់ចិត្ត (ចាប់កំហុស) ព្រះសមណគោតមឲ្យបាន កាលបើទ្រង់អាចធ្វើបាន ទ្រង់នឹងមានកេរ្ដិ៍ឈ្មោះល្បីថា ទ្រង់ឈ្នះព្រះសមណគោតម ដែលល្បីល្បាញថាជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើនជាប្រាកដ" ។

ព្រះអភយរាជកុមារសួរថា " ធ្វើដូចម្ដេចទើបខ្ញុំករុណាអាចនិយាយឲ្យឈ្នះព្រះសមណគោតមបាន?

និគ្រន្ថនាដបុត្រប្រាប់ថា " ចូរទ្រង់ទៅសួរព្រះសមណគោតមថា

តើព្រះគថាគតធ្លាប់មានព្រះតម្រាស់ នូវពាក្យមិនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដទៃខ្លះដែរឬទេ ? បើព្រះសមណៈគោតមឆ្លើយថា " និយាយ " ចូរទ្រង់ទូលថា : បើដូច្នេះមិនប្លែកអ្វីពីមនុស្សបុថុជ្ជនទេ ព្រោះបុថុជ្ជនតែងនិយាយដូច្នេះដែរ ។ បើព្រះសមណគោតមត្រាស់ថា " មិននិយាយ " ចូរទ្រង់ទូលថា : បើដូច្នេះ ចុះហេតុអ្វី ព្រះអង្គត្រាស់ថា ទេវទត្តជាមនុស្សអបាយ មនុស្សនរក ត្រូវធ្លាក់ក្នុងនរកអស់ ១ កល្ប គេមិនអាចជួយកែខៃបានឡើយ ។ ព្រះតម្រាស់នេះ ធ្វើឲ្យទេវទត្តក្រេវក្រោធ តូចចិត្ត (ណាស់) ។ នៃព្រះរាជកុមារ កាលបើព្រះសមណៈគោតម ត្រូវបោទសួរបញ្ហាមានចំណុចពីរ មានជំពាមពីរយ៉ាងនេះ នឹងលេបក៏មិនចូល នឹងខ្ជាក់ចេញក៏មិនរួច ហាក់ដូចបុរសស្ទាក់ក្របាច់ដែកដែលជាប់ក្នុងបំពង់ក ដូច្នោះដែរ " ។

អភយរាជកុមារបានទទួលពាក្យណែនាំរបស់និគ្រន្ថនាដបុត្រៈហើយ ក៏លាត្រឡប់ចូលគាល់ព្រះពុទ្ធជាម្ចាស់ តែយល់ថាពេលនោះជិតព្រលប់ហើយ ចាំព្រឹកឡើងសិនចុះ សឹមអាត្មាអញនិយាយបាច់កំហុសចំពោះសម្តីនៃព្រះសមណគោតមនៅឯផ្ទះអាត្មាអញ គិតដូច្នេះហើយ ទើបក្រាបទូលនិមន្តព្រះអង្គថា " ព្រឹកស្អែកនេះ សូមព្រះដ៏មានព្រះភាគព្រមដោយភិក្ខុ ៣ អង្គ សោយភត្តាហារនៅឯផ្ទះទូលព្រះបង្គំ " ហើយទូលលាត្រឡប់ទៅ ។

ដល់ព្រឹកឡើង ក្រោយព្រះអង្គសោយភត្តាហាររួចស្រេចហើយ

ទើបព្រះអភយរាជកុមារចូលទៅជិតអង្គុយលើអាសនៈខាងផង ហើយក្រាបទូលសួរ តាមពាក្យណែនាំរបស់និគ្រន្ថនាដបុត្រនោះ ៗ លុះអង្គុយស្រួលបួលហើយ ទើបអភយរាជកុមារទូលសួរថា " ព្រះតថាគតធ្លាប់ដែលមានតម្រាស់ នូវពាក្យមិនជាទីស្រឡាញ់ពេញចិត្ត នៃអ្នកដទៃខ្លះដែរឬទេ ?

(ខ្ញុំសុំបើករង់ក្រចកត្រង់ឃ្លានេះបន្តិច សុំអស់លោកអ្នកអានគិតមើល តើព្រះអង្គទ្រង់ឆ្លើយតបនឹងសំណួរនោះដូចម្តេច ? ទ្រង់ឆ្លើយទទួលឬបដិសេធ ? ប្រសិនបើទ្រង់ឆ្លើយទទួល គេក៏ចាប់ខុស ទ្រង់ឆ្លើយបដិសេធ គេក៏ចាប់ខុសដែរ ៗ មុនអស់លោកអានអត្ថបទបន្តទៅទៀត តើអស់លោកគួរឆ្លើយតបនឹងសំណួរបែបនេះដូចម្តេច ?)

ក្នុងអត្ថបទមានសេចក្តីថា ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់តបថា " ម្នាលរាជកុមារ ខនេះតថាគតមិនឆ្លើយតបតែដោយចំណែកមួយទេ គឺសំណួរយ៉ាងនេះ តថាគតត្រូវបំបែកឆ្លើយតាមដំណើរការណ៍ " ៗ

កាលព្រះអង្គទ្រង់ត្រាស់យ៉ាងនេះ ស្រាប់តែអភយរាជកុមារក្រាបទូលវិញភ្លាមថា " ក្នុងរឿងនេះ ពួកនិគ្រន្ថនឹងត្រូវវិនាសហើយ ព្រះអង្គ " ៗ

ទ្រង់ត្រាស់សួរថា " ព្រោះហេតុអ្វី " រាជកុមារពោលយ៉ាងនេះ ?

អភយរាជកុមារក្រាបទូលថា " បពិត្រព្រះដ៏មានព្រះភាគ ទូលបង្គំបានទៅរកនិគ្រន្ថនាដបុត្រ ៗ បានប្រដៅបង្រៀនឲ្យទូលបង្គំមកទូលសួរព្រះអង្គយ៉ាងនេះ ហើយបានក្រាបទូលដំណើររឿងតាំងពីដើមរហូតមក " ៗ

ក្នុងអត្ថបទមានថែងថា ខណៈនោះមានទារកមួយដេកផ្ងារលើភ្លៅរបស់រាជកុមារផង ។

(អស់លោកអ្នកអានគង់សង្ស័យថាចុះហេតុអ្វី អភយរាជកុមារបីទារកដាក់ឲ្យដេកផ្ងារលើភ្លៅរបស់ខ្លួនដូច្នេះ ? អដ្ឋកថាចារ្យ លោកបានពន្យល់ថា ធម្មតាពួកដែលនិយមប្រើកលល្បិច ប្រែងចាប់កំហុសគូសន្ទនារបស់គេ តែងអង្គុយកាន់វត្ថុអ្វីមួយ ( ធ្វើជាលេស ) ដូចជាកាន់ផ្លែឈើ ផ្កាឈើ ស្លឹកឈើជាដើម ។ កាលបើខ្លួនមានជោគជ័យក្នុងការសន្ទនា ក៏គ្របសង្កត់សង្កិនអ្នកដទៃទៅ បើចាញ់វិញ ក៏ធ្វើជាកំពុងស៊ីផ្លែឈើ ហិតក្លិនផ្កា ហែកស្លឹកឈើលេង (បន្ទប់ឬឈប់លែងស្តាប់គូសន្ទនា ) ។ ឯអភយរាជកុមារគិតថា ព្រះពុទ្ធចូលសង្គ្រាមមកច្រើនណាស់ហើយ ធ្លាប់ញាំញីសម្តីគូបរបក្ខមកច្រើនហើយ ។ បើអញឈ្នះ ក៏ប្រសើរណាស់ បើអញចាញ់វិញ អញនឹងក្តិចក្មេងតូចនេះឲ្យស្រែកយំទ្រហឹង (បន្ទប់) ហើយនិយាយប្រាប់គេឯងថា មើលចុះក្មេងនេះយំខ្លាំងណាស់ អស់លោកក្រោកចេញទៅសិនចុះដល់ពេលក្រោយ សឹមជជែកពិភាក្សាគ្នា ។ ហេតុដូច្នេះហើយ ទើបអភយរាជកុមារដាក់ទារកតូចឲ្យដេកផ្ងារលើភ្លៅរបស់ខ្លួន នៅក្នុង ១ ខណៈនោះ ) ។

ភណិតវរតោ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រសើរក្រៃលែងជាងអ្នកពូកែ (អ្នកអភិប្រាយឬអ្នកពិភាក្សាឬអ្នកឆ្លើយឆ្លង) ដទៃ ៗ ទាំងអស់ ទើបទ្រង់ព្រះតម្រិះថា គប្បីគតត្រូវធ្វើទារកតូចនេះជាគ្រឿងឧបមាហើយ ក៏បាក់កាន់ :

របស់គេចេញ ទើបទ្រង់ត្រាស់សួរទៅវិញថា "ម្នាលរាជកុមារ បើកុមារតូចនេះ (រតីសរវៃ) ចាប់កាន់ឈើឬអំបែងក្បឿងហើយដាក់ចូលក្នុងមាត់វា ហើយលេបចូលទៅជាប់ក្នុងបំពង់ក ព្រោះការធ្វេសប្រហែសរបស់ទ្រង់ ឬរបស់ពីលៀង តើទ្រង់ត្រូវធ្វើដូចម្ដេច ?

អភយរាជកុមារក្រាបទូលថា "បើទូលបង្គំមិនអាចយកឈើឬអំបែងក្បឿងចេញមកបានដោយស្រួលទេ ទូលបង្គំត្រូវប្រើដៃឆ្វេងចាប់ទប់ក្បាលវាឲ្យជាប់ ហើយយកម្រាមដៃស្ដាំលូកចាប់ទាញឈើ ឬក្បឿងចេញមកទាំងលោហិត (ក៏ដោយ) ដែលទូលបង្គំធ្វើយ៉ាងនេះ ព្រោះទូលបង្គំមានមេត្តាចំពោះក្មេងនេះឯង ព្រះអង្គ" ។

ព្រះអង្គទ្រង់ត្រាស់ថា "ម្នាលរាជកុមារ រឿងនេះក៏ដូច្នោះដែរ ពោលគឺតថាគតដឹងថាវាចាណា ជាពាក្យមិនពិត មិនមែន មិនមានប្រយោជន៍ មិនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដទៃ ក៏មិនពោលវាចានោះទេ ។ វាចាណា ជាពាក្យពិត ពាក្យមែន តែមិនមានប្រយោជន៍ ទាំងមិនជាទីគាប់ចិត្តរបស់អ្នកដទៃ ក៏មិនពោលវាចានោះដែរ ។ វាចាណាជាពាក្យពិត ពាក្យមែន ទាំងមានប្រយោជន៍ ប៉ុន្តែមិនជាទីគាប់ចិត្តរបស់អ្នកដទៃ តថាគតត្រូវស្គាល់ពេលវេលា តើគួរនិយាយវាចានោះឬមិនគួរនិយាយ បើឃើញថាគួរនិយាយក៏និយាយ ឃើញថាមិនគួរនិយាយក៏មិននិយាយដែរ ។ វាចាណា ជាពាក្យមិនពិតមិនមែន ទាំងមិនមានប្រយោជន៍ ប៉ុន្តែជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដទៃ តថាគតក៏មិនគួរ

និយាយវាចានោះដែរ ។ វាចាណា ជាពាក្យពិត ពាក្យមែន តែគ្មានប្រយោជន៍ ទោះបីវាចានោះជាទីគាប់ចិត្តរបស់អ្នកដទៃក៏ដោយ តថាគតក៏មិនពោលវាចានោះដែរ ។ វាចាណា ជាពាក្យពិត ពាក្យមែន ទាំងមានប្រយោជន៍ផង ទាំងជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដទៃផង តថាគតត្រូវស្គាល់ពេលវេលាដែលគួរពោល នូវវាចានោះដែរ ។ ព្រោះហេតុអ្វី ? - ព្រោះហេតុថា តថាគតតែងមានមេត្តាករុណា ដល់មនុស្សទាំងឡាយ ទាំងពួង ដូច្នេះឯង " ។

(អដ្ឋកថា លោកបានពោលបញ្ជាក់ឧទាហរណ៍ថា ព្រះវាចាដំបូង( ទី ១ ) ដូចគេហៅអ្នកមិនមែនជាចោរ, ថាចោរ មិនមែនទាសាទាសី ថាជាទាសាទាសី អ្នកមិនមែនធ្វើអាក្រក់ ថាធ្វើអាក្រក់ដូច្នេះជាដើម ។ សម្តីដូច្នេះមិនជាទីស្រឡាញ់ពេញចិត្ត របស់អ្នកដទៃផង ទាំងជាសម្តីមិនពិតផង ។

ព្រះវាចាទី ២ ដូចជាហៅអ្នកធ្វើចោរថាជាចោរ នេះជាពាក្យពិតមែន តែមិនជាទីគាប់ចិត្តនៃអ្នកដែលគេហៅទេ ។

ព្រះវាចាទី ៣ ដូចជាពាក្យក្រើនរំលឹកថា អ្នកឯងក្រខ្សត់ក្នុងជាតិនេះ ព្រោះមិនបានធ្វើបុណ្យទានទុកមកអំពីជាតិមុន ឥឡូវ បើអ្នកមិនខំធ្វើបុណ្យទុកក្នុងជាតិនេះទេ ធ្វើម្តេចអ្នកនឹងរួចផុតចាកអបាយភូមិ ក្នុងជាតិខាងមុខទៀត ។ វាចានេះជាសម្តីអាក្រក់ដែរ ទាំងមិនជាទីគាប់ចិត្តនៃអ្នកស្តាប់ទេ ប៉ុន្តែជាពាក្យពិត ពាក្យមែន ទាំងជាពាក្យមាន

ប្រយោជន៍ផង ។ ដូច្នេះ គប្បីយល់ថា ព្រះតថាគត មិនត្រាស់វាចា មិនជាទីគាប់ចិត្តដែលមិនពិត ។ មិនត្រាស់វាចាជាទីគាប់ចិត្ត តែឥត ប្រយោជន៍ ។ ឯព្រះវាចាទី ៣ ព្រះតថាគតត្រាស់សម្តែង មិនឲ្យកន្លង ហួសពេលដែលគួរត្រាស់សម្តែងដែរ គួរជ្រាបថា វាចាដែលប្រៀបនឹង កូនខ្ចីនោះ គឺសំដៅយកវាចាទី ៣ ដែលមិនជាទីគាប់ចិត្តនេះឯង ។ អដ្ឋកថាចារ្យ ។

អត្ថបទបាលី មានពាក្យបន្តទៅទៀតថា កាលអភយរាជកុមារ បានស្តាប់សេចក្តីឆ្លើយតបរបស់ព្រះអង្គដូច្នេះហើយ ក៏ក្រាបទូលសួរដោយ ក្តីជឿនឹងថា បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ មានពួកក្សត្រ ព្រាហ្មណ៍ គហបតី សមណៈ ដែលជាបណ្ឌិតពួកណាមួយ បានចងប្រស្នាចូល មកទូលសួរព្រះតថាគតជាម្ចាស់ ទូលព្រះបង្គំ សូមទូលសួរព្រះអង្គថា តើព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានគិតទុកជាមុន ឬថាពួកណាមួយ មកសួរប្រស្នានឹងតថាគតយ៉ាងនេះ តថាគតនឹងដោះស្រាយយ៉ាងនេះ ឬ ជាសេចក្តីស្រាយនោះ ប្រាកដជាក់ស្តែង ចំពោះព្រះតថាគតជាម្ចាស់ ភ្លាម ៗ ព្រះអង្គ ?

ព្រះអង្គទ្រង់ត្រាស់ថា រាជកុមារ បើដូច្នេះ តថាគតនឹងសុំសួរ ទ្រង់វិញ អំពីរឿងជាងរថនេះដែរ ទ្រង់យល់សមដូចម្តេច សូម ដោះស្រាយដូច្នោះចុះ តើទ្រង់ជាអ្នកឈ្លាសស្ទាត់ជំនាញខាងគ្រឿងរថ មែនឬមិនមែន ?

អភយរាជកុមារទូលថា "ពិតមែនព្រះអង្គ" ។

តថាគតសុំសួរទ្រង់តទៅទៀតថា : "បើមានពួកជនណាមួយមកសួរទ្រង់ថា នេះជាគ្រឿងអ្វីរបស់រថ តើទ្រង់បានដោះស្រាយទុកជាមុន ឬថាកាលបើមានគេមកសួរអញ អញត្រូវដោះស្រាយយ៉ាងនេះ ឬមួយទ្រង់គិតបានភ្លាម ៗ ?

"គិតបានភ្លាម ៗ ព្រះអង្គ" ។

"ម្នាលរាជកុមារ ខនេះក៏ដូច្នោះដែរ សេចក្ដីស្រាយ តែងប្រាកដជាក់ស្ដែងដល់តថាគតភ្លាម ៗ ដែរ ព្រោះហេតុតថាគតបានដឹងច្បាស់ចាក់ធ្លុះកងធម្មធាតុទាំងឡាយហើយ" ។

កាលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្ដែងយ៉ាងនេះហើយ ។ ទើបអភយរាជកុមារក្រាបទូលសរសើរព្រះអង្គថា "ព្រះអង្គទ្រង់ឆ្លើយតបល្អប្រសើរណាស់ នាំឲ្យទូលបង្គំភ្លឺច្បាស់ល្អ ហាក់ដូចគេផ្ងារនូវរបស់ដែលផ្កាប់ ដូចអ្នកបើកគម្របដែលបិទ ដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ដូចគេទ្រោលបំភ្លឺចង្កៀងក្នុងទីងងឹតដូច្នោះ ។ ទូលព្រះបង្គំ សូមគោរពកាប់កានព្រះអង្គ ព្រមទាំងព្រះធម៌ ព្រះសង្ឃ ទុកជាទីពឹងទីរលឹក ចាប់តាំងអំពីថ្ងៃនេះជាដើមទៅ រហូតដល់អស់ជីវិត" ។

ចប់អភយរាជកុមារសូត្រត្រឹមប៉ុណ្ណេះ ។

# ធាតុពិតរបស់មនុស្ស

ប្រសិនបើគេធ្វើកោតវែកញែកមនុស្ស ដើម្បីពិនិត្យរកធាតុពិត គេនឹងប្រទះឃើញយ៉ាងជាក់ច្បាស់នូវធាតុពិតនោះពុំខាន ។ ធាតុពិតរបស់មនុស្សនោះតើដូចម្តេច ហើយមានប៉ុន្មាន ?

តាមច្បាប់ពុទ្ធសាសនា ធាតុរបស់មនុស្សមាន ១១ យ៉ាង ។ តើ ១១ យ៉ាងនោះ គឺអ្វីខ្លះ ? គឺការមិនសម្លាប់សត្វបំបាត់ជីវិតគេ ១ ការមិនលួចទ្រព្យអ្នកដទៃ ១ ការមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ការមិនពោលពាក្យកុហកបោកបញ្ឆោតអ្នកដទៃ ១ ការមិនពោលពាក្យញុះញង់អ្នកដទៃ ធ្វើអ្នកដទៃឲ្យឈ្លោះគ្នា ឲ្យបែកបាក់សាមគ្គីធម៌ ១ ការមិនពោលពាក្យទ្រគោះបោះបោក ពាក្យគគ្រោះគគ្រើយ ជេរប្រទេចផ្ដាសាដែលមិនមែនជាសម្ដីអ្នកមានអារ្យធម៌ មិនមែនជាសម្ដីអ្នកប្រាជ្ញ ១ ការមិនពោលពាក្យឥតប្រយោជន៍ដែលជាហេតុ គ្រាន់តែសម្លាប់ពេលវេលារបស់ខ្លួននិងអ្នកដទៃចោលជាអសារបង់ប៉ុណ្ណោះ ១ ការមិនផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាមូលដ្ឋាននៃសេចក្ដីប្រមាទ ១ ការមិនមានអភិជ្ឈា គឺជាការមិនសំឡឹងរំពៃគយគន់ទ្រព្យអ្នកដទៃ ដើម្បីយកមកជារបស់អម្រស់ខ្លួន ១ ការមិនមានព្យាបាទ គឺមិនចងចិត្តគំនុំគុំគួនចងអា-ឃាតព្យាបាទធ្វើអ្នកដទៃឲ្យដល់នូវទុក្ខទោស ឬរងទុក្ខវេទនា ឬក៏បាត់បង់

ជីវិត ១ ការយល់ឃើញត្រូវតែយល់ថា កម្មតែងឲ្យផល ព្រះពុទ្ធមាន ព្រះធម៌មាន ព្រះសង្ឃមាន មាតាក៏មាន បិតាក៏មាន លោកខាងមុខក៏មាន ។ល។ ទាំង ១១ ប្រការនេះ រួមជាធាតុពិតសម្រាប់ដឹកនាំសត្វលោក ឆ្ពោះទៅកាន់សុគតិឋាន មានឋានមនុស្សនិងឋានទេវតាជាដើមប្រកែកពុំបានឡើយ ។ ទាំង ១១ ប្រការនេះ គណនាដូចបន្ទុកអគ្គិសនីដែលត្រូវតែមាន ២ ជាដាច់ខាត គឺបន្ទុកឈ្មោលនិងបន្ទុកញី ប្រសិនបើខ្វះឬបាត់បន្ទុកណាមួយ ភ្លើងអគ្គិសនីមិនអាចឆេះ ចេញជាពន្លឺ ភ្លឺជះព្រោងព្រាតបានឡើយ ។ រឿងនេះមានឧបមាយ៉ាងណា ធាតុទាំង ១១ ប្រការបើខ្វះធាតុណាមួយ ក៏មិនអាចដឹកនាំសត្វលោកឆ្ពោះទៅកាន់សុគតិឋានបានឡើយ មានឧបមេយ្យដូច្នោះ ។

ឥឡូវ សូមងាកមកដោះស្រាយបញ្ហាមនុស្សម្តង ។ មនុស្សទាំងអស់ក្នុងពិភពលោកដែលមានចំនួនជាច្រើនពាន់លាននាក់ តើសុទ្ធតែត្រូវធាតុពិតទាំង ១១ ប្រការដឹកនាំមកបង្កើតទាំងអស់ពិតអ៊ីចឹងមែន ឬមិនមែនទេ? សូមអ្នកអានទាំងឡាយមេត្តាជ្រាបថាពិតជាអ៊ីចឹងមែនហើយ ។ ព្រោះប្រសិនបើគ្មានធាតុពិតទាំងនេះជាអ្នកដឹកនាំទេ សត្វផ្តេសផ្តាស មិនអាចមានសមត្ថភាពមកចាប់ជាតិជាមនុស្សបានឡើយ ។ រឿងនេះមានឧបមាដូចរដ្ឋការ ត្រូវការប្រឡងជ្រើសរើសយកលេខាធិការការិយាល័យ តែអ្នកដែលមានសមត្ថភាពអាចអនុញ្ញាតឲ្យចូលប្រឡងបាន លុះតែអ្នកនោះមានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ។ ដូច្នេះអ្នកមិនមានសញ្ញាប័ត្រ គឺមិនអាច

ចូលប្រឡងដណ្ដើមយកនាទីជាលេខាធិការបានឡើយ ។ រីឯនាទីជាមនុស្សក៏ដូច្នោះដែរ គឺថាលុះណាតែសត្វណាមានសញ្ញាប័ត្រប្រកបដោយធាតុពិតរបស់មនុស្សទាំង ១១ ប្រការ ទើបអាចមានសមត្ថភាពមកចាប់កំណើតជាមនុស្សបាន ។ បើពោលឲ្យកាន់តែច្បាស់លាស់ជាងនេះទៅទៀត គេអាចសន្និដ្ឋានបានថាការប្រឡងជ្រើសរើសលេខាធិការអាចឲ្យគេបន្លំបានខ្លះដោយប្រើមធ្យោបាយសម្ងាត់ រីឯបេក្ខជនដែលមាននាទីត្រូវទៅយកកំណើតជាមនុស្ស ។ ក្រុមមេប្រយោគគឺកម្ម: ធ្វើការប្រិតប្រៀនមធ្យ័តណាស់ មិនអាចឲ្យបេក្ខជនណាក្លែងបន្លំសូម្បីតែបន្តិចបន្តួចបានឡើយ ។ ឧទាហរណ៍ដូចជាមនុស្សកើតមក ខ្វិន គ ថ្លង់ ខ្វាក់ ឬឆែបមាត់ ។ ល ។ អ្នកទាំងអស់នេះសុទ្ធតែចង់លួចបន្លំ តែត្រូវក្រុមមេប្រយោគដឹង គេក៏ឆូតឈ្មោះចេញភ្លាម គឺថាការខ្វិន គ ថ្លង់ ខ្វាក់ ឆែបមាត់ ។ ល ។ នេះហើយជាការឆូតឈ្មោះចេញពីបញ្ជីមនុស្សធម្មតា ពីភាពមនុស្សត្រឹមត្រូវដូចគេឯង នេះហើយជាទណ្ឌកម្មដែលក្រុមមេប្រយោគគឺកម្ម: បានតម្រូវទៅបេក្ខជនទុច្ចរិត ពោះបីបានកើតមកជាមនុស្សទីងគេក្ដី ក៏ខ្លួនមិនមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីទទួលសេចក្ដីសុខបរិបូណ៌ដូចអ្នកដទៃឡើយ ។

សួរថា : តើមនុស្សរាប់ពាន់លាននាក់ដែលមានសព្វថ្ងៃនៅលើពិភពលោក សុទ្ធជាធាតុពិតទាំង ១១ ដែលនាំមកឲ្យកើតឬ ? បើពិតអ៊ីចឹងមែន

ហេតុអ្វីក៏មានមនុស្សខ្លះ ឬ មនុស្សភាគច្រើន បើតាមការសង្កេត ស្ទើរសឹងជាអ្នកប្រាសចាកធាតុពិតទាំង ១០ ដូច្នេះទៅវិញ ? មើចក៏ធាតុពិតទាំង ១០ មិនធ្វើ ឬ ចេះនាំមនុស្សឲ្យឋិតនៅក្នុងគន្លងធម៌ដើមរបស់ខ្លួនទៅ ? ត្រង់ចំណុចនេះសូមអ្នកអានទាំងឡាយមេត្តាជ្រាបថា ឋានមនុស្សជាឋានកសាង បានសេចក្តីថាជាឋានជាទីប្រជុំចុះនៃអំពើគ្រប់យ៉ាងទាំងកុសល ទាំងអកុសល ។ កឯមនុស្សបុថុជ្ជនមែនតែងាករេទៅរកអំពើទុច្ចរិតដោយភាគច្រើនព្រោះអំពើនេះងាយធ្វើ ងាយប្រព្រឹត្ត ងាយប្រតិបត្តិ ធៀបឧបមាដូចជាត្រីវិស័យដែលមានធាតុសម្រាប់តែងាកចង្អុលទៅទិសឧត្តរ ទោះគេចាប់បង្វិលមកទិសផ្សេងក៏វាមិនព្រមឡើយ វាត្រូវតែងាកចង្អុលទៅទិសឧត្តរជានិច្ច ។ ដូច្នេះទើបព្រះពុទ្ធទ្រង់ប្រដៅថាឲ្យខំប្រព្រឹត្តឬចម្រើនចិត្តទប់ទល់អំពើអកុសលដែលមិនទាន់កើត និងត្រូវព្យាយាមលះបង់អកុសលដែលបានកើតរួចហើយឲ្យជ្រះស្រឡះពីសន្តាន ព្រោះចិត្តបុថុជ្ជនប្រៀបដូចជាត្រីដែលតែងកម្រញាល ឬនេះទៀតទៅរកតែទឹកដែលជាកន្លែងធ្លាប់ត្រាំនៅ ។ សូមអស់លោកចាប់ត្រីបោះទៅលើគោក ដែលមានក្រាលកន្ទេលព្រំគ្រប់ពូកដ៏យ៉ាងស្អាតសាកល្បងមើល ត្រីពិតជាពុំព្រមដេកនៅស្ងៀមលើអាសនៈដ៏ប្រសើរទាំងនោះទេ វាទៀងតែបម្រះខំទៀតទៅរកតែទឹកដ៏ពិតប្រាកដ ។ ចុះកន្លែងណាជាទីត្រាំនៅនៃចិត្តរបស់បុថុជ្ជន ? កន្លែងជាទីត្រាំនៅនៃចិត្តរបស់បុថុជ្ជនគឺ លោភៈ ទោស និង មោហៈ ។

ដូច្នេះធាតុទាំង ១១ ដែលមនុស្សបានធ្លាប់ប្រឹងសន្សំខ្លះៗដោយលំបាកពីជាតិមុនហើយដែលបានដឹកនាំមនុស្សនោះមកតម្កល់ទុកនៅអាសនៈគឺបរគណ្ឌាលនេះ ដើម្បីឲ្យខំប្រឹងសន្សំកសាងតទៅទៀត កុំបុប្ផនដែលក្រាស់ដោយកាម កាលបើបានប្រទះទឹកគឺកិលេស រមែងតែនទៀលទៅរកជាមិនបាន ប្រសិនបើមិនបានទៅសេពគប់នឹងអ្នកប្រាជ្ញជាកល្យាណបុថុជ្ជនទេនោះ ៗ

ចូរយើងគិតស្មានថា មនុស្សទាំងប៉ុន្មានពាន់លាននាក់នៅលើដីមូលនេះគាត់ទុកថាមានចំនួនច្រើនឲ្យសោះ ប៉ុនណាហើយយល់ដូច្នេះ ឈ្មោះថាយល់ដោយភ័ន្តច្រឡំហើយ ៗ ព្រះពុទ្ធទ្រង់ពោលថា : “កិច្ឆោ មនុស្សប្បដិលាភោ ” ការបានកើតមកជាមនុស្សនេះកម្រក្រៃណាស់ គឺថាលុះតែអ្នកនោះឯងប្រកបដោយធាតុពិតទាំង ១១ ដូចពោលខាងលើ ទើបអាចមកកើតជាមនុស្សបាន ៗ ដូច្នេះអ្នកដែលបានកើតមកជាមនុស្សម្នាក់ៗ គាត់ថាជាអ្នកមានភ័ព្វសំណាងដ៏ខ្ពង់ខ្ពស់ណាស់ ៗ មានមួយថ្ងៃព្រះពុទ្ធទ្រង់ស្តេចគោចរជាមួយនឹងភិក្ខុសង្ឃដើរម្រៀន ដើម្បីទៅគាខផខចទមួយ ៗ យាងដល់ពាក់កណ្តាលផ្លូវ ទ្រង់ឈប់សម្រាកក្រោមឈើមួយដើមបរិបូរណ៍ដោយស្លឹកត្រឈើនិងត្រៃឈើ ៗ នាឱកាសនោះព្រះអង្គទ្រង់ឈោងបេះស្លឹកឈើនោះមួយសន្ទឹក មកទុកនៅព្រះហស្តហើយទ្រង់សួរចំពោះភិក្ខុសង្ឃជាចវាំចថា “ម្នាលភិក្ខុទាំងឡាយ ចូរអាវុសោកល់គ្នាថា មើល ចំនួនស្លឹកឈើនៅក្នុងដៃតថាគត និងចំនួនស្លឹកឈើនៅលើដើម

តើខាងណាមានចំនួនច្រើនជាង ” នេះជាចំណោទដ៏ងាយបំផុត អ្នកណាក៏អាចឆ្លើយបានភ្លាម មិនបាច់ចាំពិនិត្យឡើយ ។ ភិក្ខុទាំងនោះក៏ក្រាបបង្គំទូលថា : “ បពិត្រព្រះដ៏មានព្រះភាគ ស្លឹកឈើនៅលើដើម ច្រើនជាងស្លឹកឈើនៅក្នុងព្រះហស្ថរបស់ព្រះអង្គ ។ ព្រះពុទ្ធទ្រង់ត្រាស់ថា : “ភិក្ខុទាំងឡាយគាយត្រូវហើយ គឺស្លឹកឈើនៅក្នុងដៃតថាគតមានចំនួនតិចស្លឹកឈើនៅលើដើមមានចំនួនច្រើន ។ រឿងនេះមានន័យយ៉ាងណា ?

ម្នាលអាវុសោទាំងឡាយ មនុស្សទៅកាន់សុគតិភព ដូចស្លឹកឈើនៅក្នុងដៃតថាគត មនុស្សទៅកាន់ទុគ្គតិភព ដូចស្លឹកឈើនៅលើដើម ” ។ ព្រះពុទ្ធដីកានេះបញ្ជាក់ឲ្យឃើញថាអ្នកដែលបានមកកើតជាមនុស្ស មានចំនួនតិចតួចស្ទួចស្តើងណាស់ ឯអ្នកដែលទៅកាន់អបាយភូមិនោះមានចំនួនយ៉ាងច្រើនមហិមា ។ មិនតែប៉ុណ្ណោះព្រះពុទ្ធទ្រង់ទតយល់គោ ដែលគេបង្ខំឲ្យស៊ីនៅក្បែរនោះដែរ ហើយទ្រង់សួរចំពោះភិក្ខុសង្ឃថា : “ម្នាលអាវុសោទាំងឡាយ ស្នែងគោនិងរោមគោ តើខាងណាមានចំនួនច្រើនជាង ? ភិក្ខុទាំងនោះក្រាបបង្គំទូលថា : “បពិត្រ, ព្រះដ៏មានព្រះភាគដ៏ចម្រើន ស្នែងគោមានចំនួនតិច រោមគោមានចំនួនច្រើន ” ។ ចាប់យកដំណើរនេះជាហេតុព្រះពុទ្ធទ្រង់ត្រាស់ថា : “ ម្នាលអាវុសោទាំងឡាយ ចំនួនស្នែងគោដូចជាសត្វដែលទៅកើតក្នុងសុគតិ ចំនួនរោមគោដូចជាសត្វដែលទៅកាន់ទុគ្គតិ ។ ព្រះពុទ្ធដីកាប៉ុណ្ណោះ បញ្ជាក់បន្ថែមលើពាក្យខាង

លើដែលមានសេចក្តីថា : មនុស្សប៉ុន្មានពាន់លាននាក់នៅលើដីមូលសព្វថ្ងៃ មានចំនួនមិនច្រើនទេ ។ ប្រសិនបើយើងយកចំនួននេះ ទៅប្រៀបធៀបនិងចំនួនសត្វតិរច្ឆានលើដីមូលដែរ ពិតជាឃើញថាចំនួនសត្វតិរច្ឆានច្រើនដ៏លើសលុបក្រៃលែងពិតប្រាកដណាស់ ។ នេះយកតែត្រឹមអបាយ-ភូមិមួយមកពោលផង បើយកអបាយភូមិ ៣ ដទៃគឺ នរក ប្រេត អសុរកាយមកបញ្ចូលថែមទៀត ឃើញថាចំនួនដ៏លើសនោះនឹងទ្វេឡើងដល់អសំខេយ្យមិនខាន ។

សូមអ្នកអានទាំងឡាយលើកយកសត្វត្រីក្នុងទន្លេសាប នៅប្រទេសខ្មែរតែមួយមុខ មកពណ៌នាប្រៀបធៀបក៏ពិតជាឃើញថាចំនួនត្រីនោះរាប់មិនអស់ទៅហើយ ចុះទម្រាំចំនួនត្រីនៅក្នុងទន្លេ ក្នុងបឹងបួដទៃទៀត និងក្នុងសមុទ្រ តើចំនួនដ៏លើស មិនដឹងឡើងដល់កំពស់ណា ឡើងដល់កម្រិតណា ប្រមាណបានឬមិនបាន ? នេះពោលតែអំពីប្រភេទតិរច្ឆានតែមួយមុខ តើអស់លោកអាចរាប់ប្រភេទតិរច្ឆានដទៃទៀតអស់ ឬទេ ? បើតាមយោបល់ខ្ញុំ ថាពិតជាកំណត់ពុំបាន ប្រមាណពុំកើតឡើយ ហើយនេះតែត្រឹមប្រភេទតិរច្ឆានក្នុងប្រទេសខ្មែរដ៏តូចប៉ុណ្ណោះ ចុះទម្រាំប្រភេទតិរច្ឆានលើដីមូលទាំងស្រុង តើរាប់យ៉ាងដូចម្តេចទៅវិញ ? ការយកគ្រឿងអស់នេះមកពិចារណា នាំឲ្យយល់ថាធម៌ដែលព្រះពុទ្ធទ្រង់សម្តែងនោះរឹតតែសម និងត្រូវទ្វេឡើង ជាភិយ្យោភាព ។

រឿងទាំងអស់នេះជាភស្តុតាងថា អ្នកដែលអាចមកចាប់កំណើតជាមនុស្សបានលុះណាតែមានគុណពិតរបស់ខ្លួនទាំង ១០ ជាអ្នកដឹកនាំមក បើពុំដូច្នោះទេ ខ្លួននឹងតែទៅកាន់ទុគ្គតិហើយ កុំសង្ស័យឲ្យសោះ ។

ឥឡូវយើងសូមប្រមើល មើលជនជាតិខ្មែរយើងម្តង ព្រោះជនជាតិខ្មែរចំនួន ៩៩ ភាគរយ តែហានិយាយឡើងកាលណា សុទ្ធតែប្រកាសតាំងខ្លួនជាពុទ្ធសាសនិកទាំងអស់ ។ យើងមានចិត្តត្រេកអរជាអតិបរមា ដោយបានដឹងថាជនជាតិខ្មែរជាអ្នកមានភ័ព្វសំណាងណាស់ ដែលបានចូលបិទទៅក្នុងពុទ្ធសាសនា ជាសាសនាដ៏ឧត្តុង្គឧត្តម រកសាសនាណាមកប្រៀបផ្ទឹមពុំបាន ត្រង់ចំណុចថាពុទ្ធសាសនាតែងតែអំពីភាពពិត ភាពមែន ហើយឲ្យសម្រាប់ប្រតិបត្តិទៀត គឺដើម្បីធ្វើខ្លួនឲ្យទៅជាសត្វដ៏ស្អាតបរិសុទ្ធ ក៏មានយ៉ាងច្រើនអនេក គឺថាមានដល់ទៅ ៨ មុឺន ៤ ពាន់ព្រះធម្មក្ខន្ធ ។ ឬសិនបើជនខ្មែរយើង មានការប្រព្រឹត្ត មានកិរិយាសម្បត្តិសមនឹងស្របទៅតាមការប្រកាសតាំងខ្លួនជាពុទ្ធសាសនិកដូច្នេះមែន ទេពតាក្នុងឋានសួគ៌ មុខជាមានសេចក្តីសង្ស័យមុខជាដោយសេចក្តីភ័យថាឋានរបស់ខ្លួនមិនសូវឲ្យទេ ឋានរបស់ខ្លួនពិតជាមានភាពសប្បាយអ៊ូអរដ៏ពិតប្រាកដ ព្រោះជនជាតិខ្មែរ ទាំងក្រោយមរណកាល នឹងតែទៅកាន់ឋានសួគ៌ពុំខានឡើយ ។ ហើយពួកទេពតាទៀតសោត សុទ្ធសឹងជាសត្វមានចិត្តទូលាយណាស់ មិនមែនមានចិត្តចង្អៀតចង្អល់ដូចជាមនុស្សលោកឡើយ ។

ដូច្នេះ ដើម្បីកុំឲ្យពួកទេវតាអស់នោះខកចិត្ត សូមពុទ្ធសាសនិកខ្មែរទាំងឡាយមេត្តាឧស្សាហ៍ត្រួតពិនិត្យផ្ទៀងផ្ទាត់មើលបន្តិច កុំធ្វេសប្រហែសឲ្យសោះ នូវធាតុពិតរបស់មនុស្សទាំង ១១ ប្រការដូចបានពោលរៀបរាប់ខាងលើកុំបីខាន ព្រោះធាតុពិតទាំង ១១ ប្រការនេះជាខសំខាន់និងចាំបាច់ណាស់ ក្នុងការធ្វើដំណើរទៅកាន់ឋានទេវតា ជាឋានជាទីសុខមនោរម្យលើសឋានមនុស្សនិងគណនាប្រាកដពុំបានឡើយ ។ រីឯធាតុពិតទាំង ១១ ប្រការ ប្រៀបដូចសំបុត្ររថភ្លើង បើឈ្មោះណាប្រាថ្នាទៅបាត់ដំបងតាមអយស្ម័យយាន គេនឹងតែរកទិញសំបុត្រទុកឲ្យហើយៗ ត្រូវរក្សាទុកកុំឲ្យបាត់ទៀតផង ព្រោះនៅពេលចូលទៅឡើងជិះរថភ្លើង សុទ្ធតែមានភ្នាក់ងារប្រចាំការនៅផ្នែករកសំបុត្រនោះត្រង់មាត់ទ្វារចូល បើអ្នកដំណើរណាមួយតែធ្លោយធ្វើឲ្យបាត់សំបុត្រឬថាភ្លេចទិញសំបុត្រ ខ្លួនត្រូវតែខានទៅបាត់ដំបងក្នុងពេលនោះ រួចពុំអាចជជែកតវ៉ាអ្វីបានឡើយ ព្រោះនេះជាបទបញ្ញាជាធរមានរបស់ក្រុមអយស្ម័យយានៗ រីឯអ្នកដែលត្រូវការធ្វើដំណើរទៅសុគតិឋាន ក៏ត្រូវតែឲ្យមានជាប់នឹងខ្លួនជានិច្ចកាល នូវសំបុត្រគឺធាតុពិតទាំង ១១ ប្រការនេះដែរ ។

ថ្ងៃទី ១៦-៤-៧១

ជេង-ជ្រីប

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ - កាន

ប្រែ - រៀបរៀង

## (ក)

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នកភិងវៃឆ្លាសបើបានអាន |
| និងបេះឧបាយកលចំណាន | ទាំងមានសន្តានស្នេហាជាតិ |

យូរ-អ៊ុន

ស៊ុមាអ៊ីថា: ពីឆ្នាំមុននេះ យើងក៏ដឹងថាស្រុកសែឈួនបានស្រូវអង្ករបរិបូណ៌, ពេលនេះក៏ត្រូវលើរដូវស្រូវសាលីទៀតដែរ, ឃើញថាពលរបស់ខុងបេងគង់នៅស៊ីបាន ប្រមាណកន្លះឆ្នាំទៅទៀតមិនអត់ឃ្លានទេ, ដែលគេធ្វើជាថយ វេលានេះចំពោះកលឧបាយហើយ យើងតាមទៅមិនបានទេ ហើយស៊ុមាអ៊ី ក៏ចាត់មនុស្សឲ្យទៅតាមស៊ើបមើល រួចត្រឡប់ទៅប្រាប់ថា បានឃើញកងទ័ពខុងបេងតាំងនៅចម្ងាយពីបន្ទាយចាស់ប្រមាណ ៣០០ សិន (១២ គ៏) ទៀតខាប់ថា: ខុងបេងជាប់ស្បៀងអាហារហើយ បើនឹងលើកបង្ហួសខ្លាចក្រែងយើងដឹង បានជាធ្វើថយជាបន្តិចម្តងៗ ដែលប្រសាសន៍មិនឲ្យលើកតាមទៅនោះ ខ្ញុំបាទមិនយល់ផងសោះ ។

ស៊ុមាអ៊ីឃាត់ហាមថា: ឯខុងបេងនោះឡែបខាយច្រើនណាស់ គិតបញ្ឆោតយើងទេ, បើខំតាមទៅមុខជាថ្ងុះការហើយ លុះព្រឹកឡើង

សុមាអ៊ីឲ្យបម្រើទៅស៊ើបការទៀត បម្រើវិលមកប្រាប់ថា ខុនបេនលើកទ័ពថយពីទីនោះទៅទៀតប្រហែល ៣០០ សិន (១៦ គ) ។

ទៀវខាប់ថា: ខុនបេនលើកទ័ពតែទៅមែនហើយ ប្រសាសន៍មិនឲ្យលើកតាមទៅនោះខុសហើយ បើដូច្នេះ ខ្ញុំនឹងសុំលើកទ័ពទៅវាយបំបែកឲ្យបាន បើទៅខូចការនឹងត្រូវយ៉ាងណា ខ្ញុំបាទនឹងទទួលជូនក្បាលឲ្យប្រសាសន៍ជាប្រាកដ, តែថាសុំឲ្យប្រសាសន៍លោកទៅជាជំនួយជួយផង ។

សុមាអ៊ីឃាត់ហាមទៀវខាប់ជាច្រើនគ្រាក៏មិនស្តាប់ សុមាអ៊ីថា: បើអ្នកឯងចង់ទៅក៏តាមចិត្តចុះ តែកុំគប្បីធ្វើការតាមអំពើចិត្តខ្លួនមិនបានទេ ព្រោះខុនបេនមានប្រាជ្ញាណាស់ ក្រែងមានបង្កប់ទាហានទុកនៅឯណាក៏នឹងខូចការ យើងនឹងលើកជាជំនួយទៅតាមទៀត បើទន់ថយនឹងបានព្រួតគ្នាជួយ បើអ្នកឯងបានតដៃនឹងកងទ័ពខុនបេនគ្រានេះហើយ ចូរកុំឲ្យទន់ដៃនឹងគេ ត្រូវតែបរពលចូលកាប់កិនគ្នាឲ្យពេញកម្លាំងដោយអង់អាច យើងចាំប្រចាំជួនពីក្រោយ ។ សុមាអ៊ីបានចាត់ចែងចែងពលឲ្យទៀវខាប់ តៃឡេង ៣០.០០០ នាក់ ហើយក៏ផ្តាំពាក្យថា ពេលព្រឹកស្អែកនេះ ត្រូវឲ្យអ្នកឯងលើកទៅឲ្យទល់ទ័ពគ្នានឹងខុនបេន តែកុំអាលចូលប្រយុទ្ធគ្នា ត្រូវបង្អង់ទាហានទុកឲ្យក្លាហានសិន ចាំមើលកលការខុនបេននឹងធ្វើម្តេចខ្លះ ។ ទៀវខាប់ តៃឡេង ទទួលបង្គាប់

ហើយ លុះព្រឹកឡើងក៏លើកពលចេញទៅតាំងបន្ទាយតាមស៊ុម៉ាអ៊ីពន្យល់គ្រប់ប្រការ ស៊ុម៉ាអ៊ីក៏លើកតាមជួនទៅ ។

ឯខុងបេងលុះដឹងថា : ស៊ុម៉ាអ៊ីលើកតាមដូច្នោះ លុះដល់ពេលយប់កណ្ដាលអាធ្រាត្រ ក៏ហៅនាយកងនាយទ័ពទាំងពួងមកប្រឹក្សាថា : ទា-ហានស៊ុម៉ាអ៊ីលើកមកគ្រានេះ មុខជាច្បាំងនឹងយើងដោយមាំមួនណាស់ គង់នឹងតាញ់ឈ្នះគ្នាជាប្រាកដ ឯក្នុងកងទ័ពៈយើងក៏មិនឃើញមាននរណា ដែលគ្រាន់បើគួរនឹងឲ្យចេញមុខទៅទទួលអាសាធ្វើការតតាំង នឹងពលខ្មាំង ១០០ ឬ ១០០០ តែម្នាក់ឯងបាន ។ ខុងបេងថាដូច្នោះហើយ ក៏ធ្វើជាសំឡឹងមើលមុខអ៊ុយអៀនៈហើយដាក់មុខជ្រប់ អងបេងឆ្លើយឡើងថា វេលានេះ ខ្ញុំបាទនឹងសុំអាសាមហាឧបកជឲ្យអស់តម្រិះប្រាជ្ញា ខុងបេងថា អ្នកឯងមានចិត្តភក្ដីមេត្រីៈយើង សុំខ្លួនអាសាដូច្នោះ យើងក៏មានសេចក្ដីសោមនស្សណាស់ហើយ តែថាកងទ័ពស៊ុម៉ាអ៊ីវេលានេះ សុទ្ធតែខ្មាំងពូកែណាស់ មិនមែនដូចសព្វគ្រា បើខុសការខាងយើងហើយ ក៏នឹងខូចប្រយោជន៍ច្រើនយ៉ាង ។

អងបេងថា ខ្ញុំបាទសុំអាសាទៅគ្រានេះ មិនមែននឹងអាល័យនៃជីវិតទេសោះ ទោះជាប្រការយ៉ាងណាក៏ស៊ូតែស្លាប់ បើត្រឡប់ធ្វើឲ្យខុសការដោយពលក្ការខាងគេ សុំជូនក្បាលឲ្យលោកកាត់ចោលទៅចុះ ខុងបេងបានឮដូច្នោះក៏បញ្ចោះសរសើរអងបេងថា : យើងយល់ហើយថា

អ្នកឯងជាមនុស្សមានសេចក្តីសត្យពិតត្រង់នឹងយើងពិត ៗ តែយើងឃើញថា ខ្លួនអ្នកឯងតែម្នាក់ពុំនិត្យ ទោះទឹងមានថ្វីដៃពូកែស័ក្តិសិទ្ធិយ៉ាងណា ក៏គង់តចេស្តារិទ្ធិនឹងទាហានសុម៉ាអ៊ុំពុំបាន ចិត្តយើងចង់រកដៃគូដែលក្លា-ហានប្រហែលអ្នកឯងឲ្យទៅកំដរជួយជាពីរផង តែមើលមិនឃើញមានខេ-ណាដូចបំណងប្រាថ្នាឡើយ ។

ទៀវគេកឆ្លើយឡើងថា : មហាឧបរាជកុំជាទុក្ខព្រួយឡើយ ខ្លួនខ្ញុំបាទនេះហើយនឹងសុំអាសាចេញទៅធ្វើការជាមួយនឹងអង់ចេងស៊ូតែស្លាប់ផងគ្នា ឯខុងចេងថា : ទៀវខាប់ទាហានសុម៉ាអ៊ីម្នាក់នោះមិនល្មមទេណា អ្នកឯងមកទទួលអាសាចេញមុខទៅដោយប្រមាណមិនស្គាល់កម្លាំង ក៏គង់នឹងតស៊ូថ្វីដៃទៀវខាប់ពុំបាន ទៀវគេកថា : ខ្លួនខ្ញុំបាទមួយនេះ ប្រ-សាសន៍គួរកប់ថាជាសេនាទាហានមួយដែរ ទោះបីទៀវខាប់ខ្លាំងពូកែយ៉ាងណា ក៏ខ្ញុំបាទស៊ូតែស្លាប់មិនញញើតខ្លាចសោះ ទោះបីភ្លាំងភ្លាត់ផ្គោយថ្វល់ការយ៉ាងណា ខ្ញុំបាទសុំជូនសិរសាឲ្យប្រសាសន៍កាត់បង់ទៅចុះ ។

ខុងចេងឮដូច្នោះក៏គាប់ចិត្តណាស់និយាយថា : បើដូច្នោះចូរអ្នកឯងនាំពលម្នាក់ ១.០០០ លើកទៅពួនបង្កប់នៅក្បែរផ្លូវប្រែកកុំ បើឃើញទាហានកងមុខសុម៉ាអ៊ីលើកមក ចូរបណ្តោយឲ្យគេលើកកងទ័ពចូលឲ្យហួសមកចុះ កុំអាលចេញតទល់ឡើយ បើកាលណាហើយបានឮស្គរនាវដែលទាហានយើងអុចហោកគ្រញៀវឡើង ត្រូវអ្នកឯងវាំងពីរនាក់បរពលចេញ

មកតទល់បិទខ្ទប់ពីក្រោយ វាយប្រសព្វតាមឲ្យហ័សជម្រង់មករកយើងខាងមុខ បើឃើញកងទ័ពសុម៉ាអ៊ីប្រជួនមកជួយ ត្រូវឲ្យទៀវអេកដាក់ត្រឡប់ពលទៅទល់ទប់កងទ័ពសុម៉ាអ៊ីកុំឲ្យពនទីចូលមកជួយគ្នាបាន យើងទឹងគិតមានធ្វើឧបាយមួយជួយអ្នកឯងទៀត អងបេងនិងឡេវអេកទាំង ២ នាយទទួលបង្គាប់ខុងបេងហើយ ក៏លើកទាហានទាំង ២ ម៉ឺនទៅពួនបង្កប់តាមពន្យល់ខុងបេង ។

ខុងបេងបានឲ្យហៅកៀងអ៊ុយនិងលៀវហ៊្វូទៅនិយាយការ ហើយក៏សរសេរអក្ខរជាសេចក្តីស្ងាត់ស៊កក្នុងស្រោមបិទជិត ហើយហុចឲ្យទៅកៀងអ៊ុយ រួចផ្តាំបង្គាប់ថា អ្នកឯងទាំង ២ នាក់ត្រូវតែនាំពល ៣.០០០ ទៅពួនបង្កប់លើកំពូលភ្នំ បើឃើញទ័ពសុម៉ាអ៊ីដោយព័ទ្ធអងបេងនិងឡេវអេកនៅក្នុងចំណោមទីងដោះមិនរួចហើយ ត្រូវហែកស្រោមមើលសំបុត្រនេះ ហើយត្រូវធ្វើតាមបង្គាប់គ្រប់ប្រការឲ្យដូចសំបុត្រនេះចុះ កៀងអ៊ុយនិងលៀវហ៊្វូនទទួលបង្គាប់ ហើយក៏គំនាប់លាលើកពលចេញទៅ ។ ខុងបេងក៏បង្គាប់ង៉ីអ៊ុ និង ង៉ីប៉ាន់, ម៉ាតុង, ទៀវង៉ីថា ពេលព្រឹកស្អែកនេះ បើទ័ពសុម៉ាអ៊ីលើកមកដល់ ចូរអស់អ្នកកុំដណ្តើមយកជ័យជម្នះឡើយ ត្រូវធ្វើជាត្រឡប់មុខវិលមកក្រោយបណ្តោយវិញ ង៉ីអ៊ុ, ង៉ីប៉ាន់, ម៉ាតុង និងទៀវង៉ី ទទួលបង្គាប់ហើយក៏នាំពលទាហានទៅរង់ចាំ ។

ខុងបេង ក៏ចាត់គួនហ៊ុនឲ្យនាំពល ៥.០០០ ទៅពួនបង្កប់នៅក្បែរភ្នំ

ដាក់កំហិតថា : បើឃើញទង់ជ័យក្រហមនៅលើភ្នំបោកពន្យល់កាលណា ឲ្យបរពលចូលបំពារកងទ័ពសុម៉ាអ៊ីទៅចុះ ។

លុះដល់ពេលព្រឹក ទៀវខាប់នាយកងទ័ពសុម៉ាអ៊ី សុម៉ាអ៊ីនិងតៃឡេងក៏លើកព្យុហទ័ពប្រពាក់ប្រពូនចូលមក ប្រទះនឹងកងទ័ពង៉ីអ៊ុ ង៉ីប៉ាន់ម៉ាតុងនិងទៀវង៉ី ទាំងសងខាងក៏តាំងយុទ្ធនាគ្នាជាពន្ទឹកមហិមា កងទ័ពស្រុកសែឈ្នួនច្បាំងរាថយក្រោយ បណ្តោយទៅចម្ងាយផ្លូវប្រមាណ ៤០០ ស៊ិន ( ១៦គី ) ។

គណៈនោះជារដូវគិម្ហន្ត ទាហានសុម៉ាអ៊ីក៏ដេញបំពារមកតាមកម្លាំង បែកញើសជោកអស់ទាំងខ្លួនគ្រប់ៗគ្នា សឹងតែថមថយកម្លាំងចុះ ឯខុងបេងឡើងទៅនៅលើកំពូលភ្នំ ក្រឡេកមើលមកឃើញទាហានសុម៉ាអ៊ីហត់នឿយកម្លាំងទន់ចុះ ឯខ្លួនគួនហ៊ុនដែលបង្កប់ពលខាងណោះ លុះឃើញទង់ក្រវីលើកំពូលភ្នំ ក៏បង្ហំពលចូលប្រកាប់ ឯកងទ័ពង៉ីអ៊ុ ង៉ីប៉ាន់ម៉ាតុងនិងទៀវង៉ីទាំង៤នាយ ក៏ត្រឡប់ផ្កាកមុខមកវាយខ្ទប់ប្រសព្វគ្នានឹងទ័ពគួនហ៊ុន ទៀវខាប់និងតៃឡេងក៏មិនរាថយ រឹតតែដេញទាហានបណ្តោយទៅមុខ លុកប្រកាប់គ្នាជាជ្រួលច្របល់ អងបេងនិងទៀវអេកបានចំណាប់ក៏បរពលចូលតភ្ជាប់ កងទ័ពទៀវខាប់ តៃឡេងក៏ស្លាប់វិនាសដេរដាស របួសពិការឥតគណនារាប់ពុំបាន ។

សុម៉ាអ៊ីឃើញដូច្នោះ ក៏លើកទ័ពជំនួយចូលទៅប្រជួនជួយពីក្រោយ ពោមព័ទ្ធទ័ពអងបេងនឹងទៀវអេកនៅកណ្តាលចំណោម ទៀវអេកគិបំបែក

ទាហានកេមចល់ទ័ពសុមាអ៊ី អេងបេងនិងតួនហ៊ុនក៏បរោលចូលព្រែកប្រយុទ្ធគ្នានឹងទ័ពទៀវខាប់ តែឡេង កងទ័ពទាំងសងខាងក៏ប្រយុទ្ធគ្នាជាដរាលប្របល់ ស្លាប់គរជើងលើគ្នាលើទ័ចប្បាំងនឹងគណនាគ្រាកប់ពុំបានកៀនអ៊ុយនិងលៀវហ្វាទៅលើកំពូលភ្នំ ឃើញសុមាអ៊ីលើកទ័ពៈបាមព័ទ្ធអេងបេងនិងទៀវអេកនៅកណ្តាលចំណោម មើលទៅឃើញទាហានក្រោមកម្លាំងណាស់ ក៏ហែកសំបុត្រខុងបេងដែលនៅនឹងខ្លួននោះមើលឃើញសេចក្តីថាៈ បើកងទ័ពសុមាអ៊ីចោមព័ទ្ធអេងបេងនិងទៀវអេកហើយត្រូវឲ្យស្រួតលើកទ័ពទៅវាយបន្ទាយកសុមាអ៊ីជាប្រញាប់ មុខជាសុមាអ៊ីលើកទ័ពថយទៅវិញ ពោះមិនបានបន្ទាយសុមាអ៊ីណា ក៏គង់បានការប្រសើរតាប់យ៉ាងធំមិនលែង កៀនអ៊ុយនិងលៀវហ្វាក៏លើកទ័ពប្រញាប់ទៅវាយយកបន្ទាយសុមាអ៊ី ។

ខណៈកាលសុមាអ៊ីលើកទ័ពចេញតាកបន្ទាយមក ក៏ឲ្យភ្លុកពិតាល់ចិត្តណាស់ ទើបឲ្យវាយទាហានខុកតាមផ្លូវវៀងមក នោះទាហានដែលនៅតាមផ្លូវឃើញទ័ពកៀនអ៊ុយនិងលៀវហ្វាលើកសំដៅទៅវាយបន្ទាយ ក៏ស្រូតទៅប្រាប់សុមាអ៊ីថាៈ ខុងបេងឲ្យលើកទ័ពទៅវាយយកបន្ទាយយើងហើយ សុមាអ៊ីឮដូច្នោះក៏ភ័យស្លុតស្មារតីឆ្លើយថាៈ យើងដឹងហើយថាខុងបេងឆ្កែកល អស់អ្នកពល់គ្នាមិនស្តាប់ពាក្យយើងសោះ បានជាថូស

ការដូច្នេះ ជាហើយក៏ឲ្យថយទ័ពត្រឡប់ទៅក្រោយនឹងដណ្តើមយកបន្ទាយ ។

ទៀវសេកបានចំណាប់ក៏បង្ខំពលវាយសង្គ្រុញពីក្រោយ ទាហានស៊ុម៉ាអ៊ុក៏បែកព្រាត់ព្រាយខ្ចាត់ខ្ចាយស្លាប់បាត់ជាច្រើនទៀវខាប់និងតៃឡេងឃើញពលទាហានខ្លួនថ្វស់ការដូច្នោះ ក៏បេះបង់ពួកពលទាំងអស់ ចំរត់ដោះទំលាយឲ្យតែរួចខ្លួន កៀនអ៊ុយនិងលៀវហ្វូរឃើញស៊ុម៉ាអ៊ុបែកទ័ពត្រឡប់មកការ ក៏នាំទាហានយោធាចេញពីបន្ទាយស្រួតទៅប្រជុំគ្នានឹងនាយទ័ពនាយកង ហើយត្រឡប់ទៅរកខុងបេង ។

ឯស៊ុម៉ាអ៊ុនោះ លុះទៅដល់បន្ទាយ ឃើញទ័ពខុងបេងលើកវិលត្រឡប់ទៅអស់ ក៏នាំទាហានទាំងនោះចូលបន្ទាយ ហើយនិយាយនឹងនាយទាហាទាំងពួងថា: យើងដឹងច្បាស់ជាឧបាយកលរបស់ខុងបេងយើងក៏បានហាមប្រាមទទឹងទាស់ នោះអ្នកទាំងអស់គ្នាមិនព្រមស្តាប់យើងសោះ បានជាខ្លួនខាតពលរេហ៍ និងគ្រឿងសាស្ត្រាវុធអស់ទាំងម្ល៉េះអំណើះពីនេះទៅមុខ បើនរណាមិនស្តាប់យើង ចចេះចេងការជម្រះប៉ុប៉ានឹងថ្លៃក្លាហាន បើដូចជាគ្រានេះម្តងទៀត យើងនឹងត្រូវកាត់ក្បាលទុកជាបំរាម ។

ខណៈនោះ ទទួលមានមនុស្សកាន់សំបុត្រមកពីសែឈួន ឲ្យ

ដំណឹងមកខុនបេនថា : ដ្បិតទៀវប៉ៅដែលត្រូវបួសធ្លាក់លើសេះនោះ ពេទ្យព្យាបាលក្បាលបួសដែលបែកនឹងថ្មសិលាចំរោងក្បាល គឺបណ្តាលកំរើបខ្លាំងឡើងទទួលអនិច្ចកម្មទៅហើយ ខុនបេនបានដំណឹងដូច្នោះ ក៏ប្រះប្រាណយំសោកាគ្រាំតែក្អួតធ្លាក់ចេញមកសុទ្ធតែឈាម ហើយដួលសន្លប់ទៅ អស់ក្មាក់ងារនាយទាហានក៏ភ័យស្លុតវិញ្ញាណទាំងអស់គ្នា ស្ទុះទៅគ្រាហ៍ឡើង ទើបបានដឹងសេចក្តីតាំងអំពីថ្ងៃនោះទៅ ខុនបេនក៏ទៅជាឈឺជម្ងឺជាប់គ្រោកមិនបាន នាយទ័ពនាយកងនិងទាហានទាំងពួងក៏នាំគ្នាទុកព្រួយសោយដៃមិនចង់ធ្វើការតែរសោះ ។

លុះកន្លងមកពីរថ្ងៃ ខុនបេនក៏ឡើកខ្លួនតាំងឃួតនិងអួនគៀនទាំង ២ នាយចូលមកប្រាប់ថា : វេលានេះយើងក៏មានអាការជម្ងឺឈឺធ្ងន់ ទីងទិយាយបង្គាប់កិច្ចពជការតទៅក៏មិនបាន យើងនឹងលើកទ័ពត្រឡប់ទៅក្រុងសៃឈួនវិញសិន តែថាកុំឲ្យការនេះផ្សាយឮអើកក្រេកឡើយ បើដឹងឮទៅដល់សុម៉ាអ៊ីហើយក៏គង់នឹងលើកទ័ពជាប់តាម សង្គ្រាមយើងក៏នឹងមិនស្រួល ត្រូវអ្នកឯងក្លែងសម្រួល ទាហានទាំងពួងឲ្យប្រុងប្រៀបរៀបត្រៀមខ្លួនឲ្យព្រមចុះ លុះបង្គាប់ហើយ ខុនបេនក៏ឲ្យរៀបខ្លួន ដល់ពេលព្រលប់ក៏លើកទ័ពចេញចាកបន្ទាយ ឡើដើរផ្លូវកាត់ច្រកទូតរះតម្រង់ទៅស្រុកហាន់តុង សុម៉ាអ៊ីដឹងថា ខុនបេនលើកទ័ពទៅអស់រវាង ៥ ថ្ងៃហើយ ក៏អគ្គុយដកដង្ហើមធំថា : ខុនបេននេះមានប្រាជ្ញាដូចទេពតា យើងដឹងមិនដល់កលឧបាយគេទេ ទើបឲ្យពាត់ថែងទាហាននៅរក្សាគយដានតាម

លំអានផ្លូវប្រទល់ដែន កំជាប់កំជាឲ្យត្រួតត្រាគ្រប់ទីដំបន់ហើយ ក៏លើកទ័ពត្រឡប់ចូលទៅក្រុងឡុកអៀង ។

ខុងបេងនោះ លុះលើកទៅដល់ស្រុកហាន់តុងហើយ ក៏ឲ្យនាយទ័ពនាយកងនិងពាហានទាំងអស់ទៅនៅប្រជុំគ្នា ហើយក៏លើកព្យុហយាត្រាទៅគេក្រពេគខ្ទួនឯក្រុងសែឈ្នួន ព្រះចៅឡៅសៀន និងអស់នាម៉ឺនមុខចតុស្តម្ភក្រមការបណ្តាដែលមាននៅក្នុងក្រុងខែត្រក្រៅ ក៏នាំគ្នាទៅសួរអាការជម្ងឺខុងបេងមហាឧបកដដល់ទីគេហដ្ឋានជាអចិន្ត្រៃយ៍ ព្រះចៅឡៅសៀន ទតឃើញខុងបេងឈឺកំពង់រ៉ៃជាទម្ងន់ ក៏ត្រាស់ឲ្យពេទ្យដែលចំណានទៅមើលព្យាបាលជាមាំមួនណាស់ រោគដែលឈឺនោះក៏បានជាសះស្រាល ។

# សាមកុកខ្សែ៣៣

តាំងពីព្រះចៅចូយ៉យបាត់ចូជិនជាមេទ័ពស្តាំ ស៊ុម៉ាអ៊ីជាមេទ័ពឆ្វេង ឡេវហ៊ុនជាទីប្រឹក្សា ឲ្យលើកពលទាហាន ៥០ ម៉ឺនទៅវាយគយតិមកុក រហូតទៅស្រុកហាន់តុង រហូតដល់ទៀវទាប់សេនាឯក ស៊ុម៉ាអ៊ីបាញ់ពលខុងបេងស្លាប់នឹងថ្វីដៃតូចហ៊ុន ក្បៀនអ៊ុយ ស៊ុម៉ាអ៊ី តូចចិត្តលើកទ័ពត្រឡប់ទៅស្រុកឡុកអៀងវិញ ព្រះចៅចូយ៉យជ្រាប ទ្រង់ព្រះកន្សែងអាល័យស្តាយទៀវទាប់ ខុងបេងមានជ័យជម្នះ លើកទ័ពត្រឡប់ទៅស្រុកហាន់តុង ព្រះចៅឡេវសៀនបាត់ឲ្យបីហ៊ុយទៅសួរខុងបេង ៗ ទឹងនឹងលីងៀមបញ្ជោតឲ្យនាំទៅសម្លាប់ គាម៉ឺនសុំទោសរួច ព្រះចៅឡេវសៀនត្រាស់ឲ្យងារលីងៀមចេញពីរាជការ ខុងបេងនឹកអាណិត ក៏តាំងលីហ្វុងជាបុត្រជំនួសបិតា ។

---

*លុះដល់ចូលឆ្នាំថ្មី ចូជិនក៏យកក្រាបទូលព្រះចៅចូយ៉យថា : ដ្បិតកងទ័ពស្រុកសែឈួន លើកមកញាំញីទល់ខបខ័ណ្ឌសីមាជាពជអាណាខែត្រឿយ ៗ ណាស់ កងទ័ពខាងស្រុកយើងក៏បាញ់ប្រៀបគេច្រើនគ្រា ទាហានស្រុកសែឈួនក៏តែតែកំរើបធំក្រៃលែងណាស់ វេលានេះថានឹងស្ងៀមនៅមិនបានទេ ព្រោះយូរទៅមុខជាកងទ័ពស្រុកសែឈួននឹងធ្វើអន្តរាគមស្រុកយើង ឲ្យអាណាប្រជានុរាស្ត្របានសេចក្តីក្តៅក្រហាយឡើងទៀត ក្នុងវេលាកាលនេះក៏គិម្ហន្តរដូវហើយ ទូលព្រះបង្គំជាខ្ញុំនឹងសុំអាសាលើកកងទ័ពទៅជាមួយនឹងស៊ុម៉ាអ៊ី ដើម្បីវាយយកស្រុកសែឈួននឹងស្រុកហាន់តុងឲ្យគ្រាតែបាន កម្ចាត់កជសត្រូវកុំឲ្យបៀតបៀនស្រុកយើងបានទៀត ។*

*ព្រះចៅចូយ៉យយល់ឃើញត្រូវ ទើបតាំងចូជិនជាមេទ័ពខាងស្តាំ*

តាំងសុម៉ាអ៊ីជាមេទ័ពខាងជើង  តាំងឡេវហួនជាទីប្រឹក្សា  ឲ្យកាន់ពលយោធា ១៤ ម៉ឺន  លើកតាមផ្លូវគយកៀមកុក  នឹងទៅវាយស្រុកហាន់ទុង នោះមានល្បាតសេះនាំពត៌មានទៅជម្រាបខុងបេង ។

ខណៈនោះ  ខុងបេងក៏តាំងតែឲ្យហ្វឹកហាត់ពលទាហានឲ្យមានវិជ្ជាគុណអាវុធសស្ត្រា  ដើម្បីនឹងលើកទៅច្បាំងយុទ្ធនា តនឹងកងទ័ពស្រុកឡុកអៀងទៀត  លុះឃើញពួកល្បាតទៅប្រាប់ពត៌មាន  ខុងបេងក៏ឲ្យហៅខ្ញូនទៀវងីនិងអងបេងចូលទៅបង្គាប់ការថា :  ដ្បិតមានកិត្តិសព្ទថា  សុម៉ាអ៊ីនឹងលើកទ័ពមក ៤០ ឬ ៦០ ម៉ឺន  អ្នកឯងត្រូវនាំពលទាហាន ១.០០០ ទៅតាំងទៅដំបន់តាន់ឆងចាំរង់ទ័ពសុម៉ាអ៊ីទុកឲ្យនឹង  រួចសឹមលើកកងទ័ពទៅជួយអងបេងនិងទៀវងីលើកឡើងគំនាប់ខុងបេងហើយជម្រាបថា  ដំណឹងថា  សុម៉ាអ៊ីលើកទ័ពមកច្រើនម្ល៉េះ  មហាឧបរាជមកបើកពលឲ្យយើងខ្ញុំតែត្រឹម ១.០០០ប៉ុណ្ណោះ  កាលណានឹងទៅតស៊ូនឹងសុម៉ាអ៊ីបាន  នឹងមិនខូចទៅទេ ឬ ? ។

ខុងបេងថា :  ហេតុអ្វីអ្នកឯងមកព្រួយការដូច្នេះ  យើងមិនមែនបញ្ជាតឲ្យអ្នកឯងទៅធ្វើការឲ្យសុម៉ាអ៊ីសម្លាប់ទេ  សូម្បីបើអ្នកឯងទៅធ្វើការឲ្យធ្វស់ធ្លោយដោយកលសត្រូវយ៉ាងណា  យើងក៏មិនយកទោសាទេ អងបេងនឹងទៀវងីក៏មិនអាចទទួល  ចេះតែអង្វរករខុងបេងជាច្រើនគ្រា ខុងបេងថា :  អ្នកឯងកុំភ័យព្រួយអ្វីឡើយ  យើងប្រើទៅហើយក្នុងវេលានេះ  ព្រោះយើងគិតពីគ្រោះមើលក្នុងមណ្ឌលអាកាស  យើងផ្កាយបុក្ស

ផតាស្រុកឡុកអៀងមានស្ទឹស្រអាប់ទាបទន់ណាស់ ក្នុងខែៈនេះនឹងមាន ភ្លៀងរំលាជាធំធ្លាក់មកជាយូរថ្ងៃយើងឃើញថាកងទ័ពសុម៉ាអ៊ីនឹងកន្ទងចូល ក្នុងដែនយើងមិនបានទេ ព្រោះមានទឹកជំនន់ធ្លាក់ពីព្រៃលើនឹងហូរមកលិច លង់ កងទ័ពសុម៉ាអ៊ីនឹងត្រឡប់ទៅឯង បានជាយើងឲ្យពលអ្នកឯងតិច ល្មម បើនឹងឲ្យទៅច្រើនក៏នាំឲ្យលំបាកឥតអំពើទេ ខ្លួនយើងនឹងទៅ ប្រមូលពលរេហ៍ឯស្រុកហាន់តុង ទុកឲ្យព្រមព្រៀម បើសុម៉ាអ៊ីថយ ទៅហើយ យើងនឹងលើកទ័ពសន្ទាប់ថែមពីក្រោយទៅ មិនបង្អង់នៅឲ្យ រេហ៍ពលបានសេចក្ដីលំបាក កងទ័ពស្រុកឡុកអៀង គង់ថ្ងស់ការផង យើងអង់បេងនឹងទៀតផង ក៏មានសេចក្ដីសោមនស្សត្រេកអរណាស់ គំនាប់ ហើយក៏លើកពលចេញទៅ ។

ឯខុងបេងនោះលុះបាត់ការហើយ ក៏កេណ្ឌប្រមូលទាហានស្រុកហាន់ តុងឲ្យបម្រុងឲ្យត្រៀមប្រចាំការ ទាំងស្បៀងអាហារបាយទៅតាក ប្រកទៃ ស្លាយគ្រប់ខ្លួន កំណត់បម្រុងឲ្យជួនស៊ីបានជាងមួយខែអស់រដូវភ្លៀង ព្រោះថា មិនឲ្យពលកល់គ្នាព្រួយរវល់ជាំបាយស៊ី នឹងបានធ្វើការជឿនរហ័ស ។

ឯសុម៉ាអ៊ីទិងចូដិន លើកទ[illegible]បានទៅដល់ដំបន់តាន់ធង មិន បានឃើញមនុស្សម្ចាស់ផ្ទះ ១ នៅទទេជាច្រើន ទើបឲ្យកេហៅអ្នកស្រុក មកពិចារណាសួរ អ្នកស្រុកឆ្លើយថា : កា[illegible]ណាកងទ័ពស្រុកសៃឈួន លើកទៅនោះ ឲ្យទាហានដុតផ្ទះអស់ជាច្រើន ចូដិនឮដូច្នោះ ក៏ប្រឹក្សា នឹងសុម៉ាអ៊ីគិតលើកទ័ពស្រួតទៅមុខទៀត ។

សុម៉ាអ៊ីថា : ដែលនឹងលើកកងទ័ពក្នុងចូលទៅទៀតនោះមិនស្រួលទេ ព្រោះវេលាយប់នេះ យើងឃើញផ្កាយក្បាស្រុកមានរស្មីស្រអាប់ណាស់ ក្នុងខែនេះនឹងមានភ្លៀងធំ នឹងលើកទ័ពទៅនោះ មុខជាទាហានបានសេចក្ដីលំបាកខ្លាំងណាស់ សុំឲ្យលោកបង្អង់កងទ័ពទុកនៅទីនេះសិន បើផុតទេសៈកាលៈហើយ សឹមលើកទៅចុះ ចូជិនយល់ឃើញត្រូវផង ក៏បង្អង់កងទ័ពទុក លុះតមកប្រមាណ ១០ ថ្ងៃ ភ្លៀងរំលាធំ ក៏បង្អុរធ្លាក់ចុះមកមិនរាំងរសាះ អស់រវាង ៣០ ថ្ងៃ ទឹកក្នុងទីនោះជ្រៅប្រមាណ ៣ ហត្ថ លិចខ្ទមស្បៀងអាហារ បណ្ដាពួកពលទាហាន ក៏មិនដឹងបើនឹងរកទីសំណាក់អាស្រ័យ អង្គុយដេកឈរក្នុងទីឯណា បានសេចក្ដីលំបាកវេទនា នាំគ្នាទ្រហ៊ូយំព្រងំពេញទាំងព្រៃ កិត្ដិ-ស័ព្ទនោះខ្ទរឮទៅដល់ក្រុងឡុកអៀង នាម៉ឺនទាំងពួង ក៏នាំគ្នាយកសេចក្ដីក្រាបទូល ព្រះចៅចូយ៉ឺយសុំឲ្យហៅកងទ័ពត្រឡប់ចូលមកវិញ ព្រះចៅចូយ៉ឺយក៏យល់ឃើញផង ទើបឲ្យមានព្រះតម្រាស់ចេញទៅហៅកងទ័ពត្រឡប់មកវិញ ។

ខុងបេង ក៏ចាប់យាមមើលដឹងថា: សុម៉ាអ៊ីលើកទ័ពត្រឡប់ទៅវិញហើយ ទើបនិយាយនឹងពួកទាហានទាំងពួងថា: ឥឡូវប្រហែលព្រះចៅចូយ៉ឺយឲ្យមានសំបុត្រមកហៅកងទ័ពត្រឡប់ទៅហើយ និយាយមិនទាន់ផុតពីមាត់ ស្រាប់តែមានបម្រើកាន់សំបុត្រអង់បេង ទៀវង៉ី មកជូន

ខុនឋេង សេចក្ដីថា កំទ័ពសុម៉ាអ៊ីលើកទៅវិញអស់ហើយ ខុនឋេងមាន សេចក្ដីត្រេកអរណាស់ ទើបបង្គាប់អ្នកសំបុត្រឲ្យប្រញាប់វិលត្រឡប់ទៅ ប្រាប់អងឋេង ទៀតថា កុំឲ្យលើកទ័ពតាមទៅឡើយ ។

នាម៉ឺនទាំងពួងនាំគ្នានិយាយថា : សុម៉ាអ៊ីលើកទ័ពត្រឡប់ទៅវិញ បានពេញចំណាប់ខាងយើងហើយ, ហេតុម្ដេចបានជាមហាឧបកដមិនឲ្យ លើកទ័ពទៅតាមវាយពីក្រោយដូច្នោះ ខុនឋេងថា: ឯសុម៉ាអ៊ីនោះជំនាញ ស្ទាត់ក្នុងការសង្គ្រាមណាស់, ទោះបីវាលាថយទ័ពទៅគ្រានេះក៏មិនមែន ទៅទទេ មុខជាមានតែងកលឧបាយឲ្យទាហានពួនបង្កប់ទុកចាំទទួល ទ័ពដែលតាមជាប្រាកដ យើងទឹងតាមទៅក៏មិនលែងត្រូវលើកលឧបាយ របស់សុម៉ាអ៊ីទេត្រូវបណ្ដោយឲ្យវាទៅចុះ ហើយសន្សំយើងលើកទាហាន ទៅចាំនៅទីចាំកុកយកដំបន់គីសានជាមុន កុំឲ្យសុម៉ាអ៊ីដឹងខ្លួនជាមុនទាន់ អស់មន្ត្រីទាំងពួងឆ្លើយថា ដែលមហាឧបកដទៅស្រុកទៀងអាន់នោះ ទៅទឹងផ្លូវដៃទមិនបានឬ ? ឬក៏ចំពោះតែទឹងដើរទៅតាមផ្លូវក្នុងគីសានមួយ យើងខ្ញុំទាំងអស់គ្នាមិនពេញចិត្តសោះ ព្រោះឃើញថាបានដើរទ័ពទៅ តាមផ្លូវនេះ ៣ គ្រាមកហើយមិនបានធ្វើការអ្វីសោះ ។

ខុនឋេងតបថា : ដំបន់ក្នុងគីសាននោះជាមណ្ឌកណ្ដាលនៃទីប្រជុំក្រុង ទៀងអាន់ បើទឹងកេណ្ឌកងពលទាហានឬស្បៀងអាហារផ្សេង ៗ ក៏អា ស្រ័យស្រុកឡុងសេ ។ នោះក៏មករួមតែផ្លូវគីសាន មួយទៀតក៏ជាប្រក

ក្នុងជ្រោះជ្រលងដងស៊ីន   បើនឹងបង្កប់ទាហានក៏បានច្រើនឬ   នឹងធ្វើការសង្គ្រាមក៏បានចំណាប់   ទើបយើងដើរទៅតាមផ្លូវនោះ   ព្រោះឃើញហេតុដូច្នោះអស់នាយទាហានបានឮដូច្នោះ   ក៏លើកដៃឡើងគំនាប់សរសើរខុងបេងថា មានប្រាជ្ញាដូចទេពតា ។

ខណៈនោះ ខុងបេងអាចារ្យក៏ចាត់ប្រើ អ៊ុយអៀន ទៀវង៉ី តៅខេង និង គាន់សេក ឲ្យនាំពលលើកទៅតាមផ្លូវគីកុក ហើយឲ្យ ម៉ាតាយ អងបេង ទៀវអេក និងម៉ាតុង នាំពលទៅតាមផ្លូវដំបន់ចាំកុក កំណត់ឲ្យលើកចេញព្រមគ្នាពីទ័ពគីសាន លុះចាត់ចែងគ្រប់សណ្ឋានរួចហើយ ក៏ឲ្យគួនហ៊ិននិងលៀវហ្វាជាមេកងទ័ពមុខ ខុងបេងក៏លើកលួងចេញទៅ ។

ខណៈកាលស៊ុម៉ាអ៊ី នឹង ប៊ូដិន លើកថយចាកពីដំបន់គាន់ចងនោះ គិតបារម្ភខ្លាចខុងបេងនឹងលើកទ័ពតាម ក៏លើកទ័ពសំរៀមទៅតាមមាត់ជាប្រក្រតី មិនបានស្រួតរូតវៃរហ័ស សេះបម្រើទៅឲ្យដំណឹងដល់ ២ គ្រាថា ៖ មិនបានឃើញកងទ័ពខុងបេងលើកតាមមកទេ ប៊ូដិនក៏និយាយនឹងស៊ុម៉ាអ៊ីថា : យើងដើរកងទ័ពសំរៀមដូច្នេះ អស់ពលរេហ៍សេនាទាហានមានសេចក្ដីលំបាកវេទនាណាស់ វេលានេះឃើញថា ខុងបេងមិនបានលើកទ័ពតាមមកទេ យើងត្រូវតែដើរស្រួតរូតឲ្យលឿនទៅចុះ ។

ស៊ុម៉ាអ៊ីថា : ដែលខុងបេងមិនបានលើកទ័ពតាមយើងដូច្នេះ ព្រោះហេតុថា ខ្លាចក្រែងយើងនឹងបង្កប់ទាហានទុក ទើបបណ្ដាយឲ្យយើងដើរ

មកដោយស្រួល កន្ទ័ពយើងចន្ទាយមកក៏ច្រើនថ្ងៃហើយមុខជាមិនតាមមែន ប្រហែលខុនបេងគាំងទ័ពនៅវិក្កីតសាន ចូជិនថា : ខ្ញុំមិនយល់ឃើញដូច្នោះផង សោះ សុម៉ាអ៊ីថា ៖ លោកមិនជឿខ្ញុំសុំឲ្យញែកកងទ័ពទៅម្នាក់ ១ ផ្លូវចុះ លោកត្រូវទៅនៅក្រោមចាំកុកគយខាងលិច ខ្ញុំនឹងទៅក្រោគីកុកខាងកើត បើកង ១០ ថ្ងៃមិនឃើញខុនបេងលើកទ័ពមកទេ ខ្ញុំនឹងទៅគំនាប់លោកដល់ចន្ទាយ សុំឲ្យលោកយកម្សៅលាបមុខខ្ញុំចុះ ហើយឲ្យលោកយកអាវស្រីបំពាក់ផ្គាល់ខ្ញុំ ឲ្យបានសេចក្តីខ្មាសអស់បណ្តាទាហានទាំងពួង ។

ចូជិនថា : បើខុនបេងលើកទ័ពមកដូចពាក្យលោកថា ខ្ញុំក៏នឹងយកត្រមួននឹងសេះល្អ ដែលព្រះចៅចូយ៉យប្រទានខ្ញុំនោះជូនឲ្យលោក សុម៉ាអ៊ីនឹងចូជិនកាលស្ញែញគាហើយ ទាំងសងខាងក៏លើកបំបែកទ័ពទៅដោយខ្លួន លុះសុម៉ាអ៊ីទៅដល់ជំបន់គីកុកហើយ ក៏ក្លែងខ្លួនបន្ទំជាកូនទាហាន ដើរត្រួតត្រាកងចន្ទាយឃើញទាហានម្នាក់អង្គុយដកដង្ហើមធំជាទុក្ខបន់ស្រន់ថា ភ្លៀងបង្អុរដល់ ៣០ ថ្ងៃហើយបានសេចក្តីលំបាកពេកណាស់ ហើយថែមទាំងលើកមកនៅទីនេះឡើតតែលំបាកវេទនាមួយសាក្រវែងទៅទៀត ដូចមកអង្គុយចាំតែកសេចក្តីទុក្ខដាក់ខ្លួន បើនឹងត្រឡប់ទៅស្រុកឲ្យបានឃើញមុខកាំយាបុត្រនឹងមិនល្អទេ ឬ ? ។

សុមាអ៊ីបានឮដូច្នោះក៏ត្រឡប់ទៅទីសំណាក់វិញ ឲ្យហៅនាយទ័ព នាយកងមកប្រជុំព្រមគ្នា ហើយក៏ឲ្យយកទាហានដែលចរចាមិនត្រូវនោះ មកពិចារណាសួរថា យើងមកធ្វើការទាំងនេះ មិនមែននឹងប្រាថ្នាកេរ្តិ៍ឲ្យបាន សេចក្ដីសុខជាក់ខ្លួនតែម្ដងទេ គឺគិតនឹងឲ្យកើតសេចក្ដីសុខទៅដល់ភរិយា បុត្រអស់អ្នកពល់គ្នាទៅឯនាយ ហេតុម្ដេចក៏ខ្លួនមកនិយាយពាក្យដូច្នេះ គឺខ្លួនឯងនេះគ្មានសេចក្ដីកក្ដីស្នេហានឹងម្ចាស់ផែនដីរបស់ខ្លួន ៗ សុំបៀវត្សរ៍ មករយៈពាន់ថ្ងៃក៏នឹងប្រស័យបានតែមួយថ្ងៃពុំបានសោះ បើដូច្នេះនឹងទុក ខ្លួនឲ្យនៅក្នុងកងទ័ពនេះមិនបានទេ ចំណោះទៅនឹងត្រឡប់ជាសត្រូវខាំង ទើបគាំងបង្គាប់ឲ្យចាប់ខ្លួនទាហាននោះនាំទៅប្រហារជីវិត ពេជ្ឈឃាតក៏ កាត់ក្បាលនាំមកមួយរំពេច ។

ខណៈនោះ អស់បណ្ដាពលទាហានទាំងពួងក៏ភ័យស្ញុតស្ងាំងទាំង អស់គ្នា សុមាអ៊ីថា: អស់អ្នកទាំងឡាយកុំបីភ័យបារម្ភ ត្រូវតែខិតខំ ធ្វើការយកអាសាផែនដីទៅចុះ បើបានឮសូរផាវធំដែលយើងគុជឡើង កណ្ដាលបន្ទាយវេលាណាត្រូវតែស្រូតរូតដោយក្លៀវក្លាចូលតយុទ្ធសង្គ្រាម ឲ្យអស់ថ្វីដៃ កុំគប្បីគិតខ្លាចសេចក្ដីស្លាប់ ទាហានក្នុងកងទ័ពបានឮ ដូច្នោះ ក៏ស្រុះគ្នាជយទៅ ។

(នៅមានត)

# រាជកុល

## (ក)

### បទព្រហ្មគីតិ

ថើមម្តាយដូចគេកាត់ ប្រែមាត់ស្ទើរបែកផង
ទុករក្ខវែងវង ទុក្ខទៀងទល់ទៀបទីក្ស័យ ៗ
មាសអើយម្តាយថប់ថៃ ត្បិតមាសស្នេហ៍ពុំនៅខែ
សមម្តាយក្រក្រាសក្រៃ ក្រោយបាទៅនោះឯណា ៗ
ព្រះបាទឧទុម្ពរ ក្សត្របវរបទូលផង
កូនអើយអាពុកប៉ង បាឯងហើយឲ្យសោយរាជ្យ ៗ
អង្គអញអាពុកបា មានជរាចាស់ឯងអាច
ឲ្យលុះនូវអំណាច ព្រះអម្រឹត្យរហោង ៗ
បើបាបោះបង់ទៅ នេះតឡូវស្ងាត់ជាម្តង
កូនអើយអាពុកវង ទុក្ខទៀងទាល់ក្ស័យជីវ ៗ
កាយោគ យ៉ត ដូចអ្នកតារពុះបេញខ្ចី
ក្តាយផ្ទុះជ្រុះចេញនៃ ទៅទីទៃដូព្ចោះហោង ៗ

ឱរំចិន្ដា ដូចអ្នកការទំលាយផង

ពុះទ្រូងចេញជាម្ដង លូកយកថ្លើមចេញទៅឆ្ងាយ ។

ហេតុត្បិតអញអាល័យ ស្ងួនមាសថ្លៃពុំនៅឡើយ

ទ្រូងទ្រុតពុំល្ហែល្ហើយ ពោរពេញពាសសឹងទុក្ខា ។

ជើងអញដូចគេកាត់ ដាច់ខ្ចាយខ្ចាត់ចេញហើយណា

ពាហុំ ចិន្ដា ដូចគេកាត់ដៃសងខាង ។

សមអញស្ដោះស្ដូះ រត់បម្រះទៅហើយហោង

ត្បិតប្រាសកូនស្ងួនគ្រង ពីឧរាទៅឋានឆ្ងាយ ។

ឥតលុះទីងឃាត់បា បុត្រពំងារឲ្យនៅកាយ

កុំឲ្យស្ងួនពណ្ណពយ នៅឆ្ងាយឡើយណាមាសថ្លៃ ។

កូនអើយកាពុកបា ទ្រូងអួលផ្សាពន់ពេកក្រៃ

ហៀបហាក់ដូចនឹងក្ស័យ ជីវិតនៃឥឡូវណា ។

ឱអញមានពៀរពីរ បាបអំពីមុនមិញហោង

ទើបឥឡូវនេះម្ដង កូនពុំងារប្រាសចេញទៅ ។

សមអញបានបម្រះ ឲ្យព្រាត់ប្រាសកូនសត្គូរ

ទើបគ្រានេះឥឡូវ តាមមកទាន់អញជាម្ដង ។

កូនអើយយើងផ្ដែផ្ដាំ ចូរបាចាំពាក្យពេចន៍ផង

កុំបាភ្លេចឡើយហោង កូនស្ងួនគ្រងកុំភ្លេចឡើយ ។

កូនអើយបើបាបាន
កុំមាសប្រហែសកាយ
កូនអើយអ្នកបំពេញ
រទេះសេះដើរ
បំពេញឲ្យសព្វគ្រប់
កុំឲ្យខ្វះឡើយហោង
បើបាចុះទៅលេង
ហេមពាន្តនោះក្រៃក្រៃ
រីឯសត្វបក្សី
បើវាយល់មនុស្សផង
ព្រះពង្សពោធិសត្វ
ទទួលបណ្តាំផង
ព្រះពោធិសត្វគិត
យោបល់យល់ប្រាសប្រា-
បើអញទៅកើតជា
អម្ចាស់អស់មនុស្សផង
រីព្រះរាជបុត្រី
នាងនោះជាភរិយា

ទៅឯមនុស្សលោកឆាយ
ចូរប្រយ័ត្នឲ្យប្រក្រតី ៗ
ទ្រព្យធនមិញអក្ខោភិនី
ស្រូវអង្ករមាសប្រាក់ផង ៗ
បរិបូណ៌សព្វទ្រព្យជាម្តង
ចូរបាវិលមកឆាប់ក្រៃ ៗ
សត្វដោយស្បែងទៅព្រឹក្សព្រៃ
មានអម្រឹតឲ្យយង់យួង ៗ
ឈ្មោះឥន្ទ្រីយ៍កាចកន្ទង
ហើយវាចាប់បរិភោគា ៗ
បុរសវគ្គនរាបវង
ជាកន្សម្លស់លើសិរសា ៗ
រិះគិតចិត្តពិចារណា
កជនទាគតក្រៃហោង ៗ
បុត្រក្សត្រជាព្រះឡង
គឺព្រះបទុមផាជា ៗ
ពៅពិសីទោះឯណា
អញអំពីបុណ្យណាហោង ៗ

បើឈ្មោះគួរអញទៅ    តាំងនេះគួរជាគន្ធន
ទឹងយកនាងនោះហោង    ជាប្រពន្ធនោះជាក្រៃ ។
រំពឹងស្រេចហើយណា    ទើបព្រះមហាក្សត្រច្បះច្បង
ទៅបានមនុស្សលោកផង    ដោយបំណងក្នុងចិន្តា ។
ព្រះបាទឧទុម្ពរ    ក្សត្របវរបិតាស្ដាប់
ស្ដេចទូលដូច្នោះគាប់    ទើបយកនូវស្រោមសេះថ្វាយ ។
ព្រះពន្សពោធិសត្វ    បង្គំថ្វាត់ក្សត្រពណ្ណកាយ
ទៅទ្រង់គ្រឿងទាំងឡាយ    គឺមកុដអាភមផង ។
ស្ដេចទ្រង់នូវព្រះពស្ត្រ    ល្អស្រេចស្រស់ឥតឯគ្គង
ឈ្មោះកម្ពលរត្នផង    ល្អិតដូចគល់ក្លៀនផ្សែនណា ។
ស្ដេចទ្រង់គ្រឿងប្រដាប់    រូបស្រាប់ស្រេចល្អប្រពៃ
រុងរឿងដូចឥន្ទុថ្ងៃ    ត្រចះចែងថ្ងៃពុំបាន ។
ស្ដែងស្ដេចមានបារមី    បុណ្យឫទ្ធិពន់ប្រមាណ
ឥតអ្នកណាផ្ទឹមបាន    លើសលោកផងទាំងគពក្រៃ ។
ទោះអស់ទាំងទេព្ដា    សោឡស្សសួគ៌នោះនៃ
មកផ្ទឹមនឹងក្សត្រថ្វៃ    ពិតពុំស្មើបានឡើយហោង ។
តិងហោះដោយនភ(១)    អាកាសក្ដីហោះជាមួង
ទឹងដើរលើទឹកផង    សុខសឹងបានឥតសង្ស័យ ។

១— គឺដើរលើអាកាស ។

ហេតុតែបានស្រោមសេះ　　បុទ្ធិគេជះពន់ពេកក្រៃ
ហេតុពន្សព្រុទ្ធាថ្ងៃ　　បានសាងរូបពីមុនមក ។
ស្តេចពាក់ស្រោមអាជនេយ្យ　　ល្អប្រពៃនោះឥតគ្គង
ទក្សិណប័ដុំផង　　នៃប្រាសាទព្រះបិតា ។
ព្រះហស្តថ្វាយបង្គំ　　ក្សត្រឧត្តមពីរអង្គា
បង្គំស្រេចហើយណា　　ឆ្ពោះកាន់ស្រុកកោសម្ពី ។
កាលពោធិសត្វហោះ　　ហើផ្ទេរកផ្ទោះចេញអំពី
ប្រាសាទព្រះបាទបី-　　តាតាមដោយអាកាសហាន ។
រីព្រះវរជិន　　នូវព្រះបិតាមិញមាន
ទុក្ខសោកមកបៀតប្រាណ　　ទប់ពុំបានកាត់អាល័យ ។
រីអស់ស្រីព្រះស្នំ　　ទាំងតូចធំនោះសោកនៃ
នូវបុរោហិតមន្ត្រី　　កស្ត្រផងក្តីសឹងសោកា ។
ប្រាសប្រាណសឹងនទៀល　　ដេកមមៀលអង្គអាត្មា
ហើយកើតជាកោលក-　　ហលមហិមាពេកកន្ទង ។
រីអស់ទាំងទេព្តា　　ឥន្ទព្រហ្មឥសូរផង
សេពសូត្រគាថាហោង　　ឲ្យពរពោធិសត្វថ្ងៃ ។
ព្រះពន្សព្រុទ្ធូល　　ហោះត្រសូលដោយជោគជ័យ
ពាក់ទាំងស្រោមអាជនេយ្យ　　ហោះទ្រៀវទ្រែងឯកអង្គា ។

ស្តេចហោះដោយនភ ដល់សម្ពលីមគគ
ទៅស៊ីស្រូវជូនតា ពាស់នោះអស់ជាមួង ។
ស៊ីស្រេចស្តេចលីលា ចរយាត្រាត្រាច់មួង
ស្តេចផ្ទុំក្នុងព្រៃផង សឹងសក្តិសាធសេះវិស័យ ។
កាលនោះជូនទិនតា ភ្ញាក់និទ្រាពីព្រឹកខៃ
ឡើងជាតាវើយ ៗ ទៅមើលស្រូវយើងពីព្រឹក ។
តាពាស់ធាប់ម្នា មុខគរិយាទៅជាមួង
កម្លាំងជាប្រុសផង (១) មើលទៅស្រូវអស់ហើយ
តាពាស់ទៅដល់ស្រែ មើលចន្ទ្រជាក់ជាមួង
យល់ជានសេះនោះហោង ស៊ីស្រូវអស់ដូច្នោះណា ។
ឯដៃគឹគក់ទ្រូង យល់រល្ហងសោយសោកា
ហេតុសោតស្រូវអាត្មា ស្ទើរសន្ធប់ទៀតទៅក្ស័យ
ប្រាសព្រាណដេកនទៀល ហើយឧរមៀលដោយដីខៃ
ចាំខអញសមក្ស័យ ជីវិតព្វកាលនោះមួង ។
ប្រាក់អញតែពីរស្លឹង ទិញស្រូវនឹងចប់មិញហោង,
ធ្វើឲ្យបានផលផង ខូចអន្តរាយអសារសល់ ។
ខអញ្ចេះម្តេចអ្នកព្វ សូវអញស្លាប់ក្ខូវគាប់ព្រៃ
រស់នៅពុំប្រពៃ តែងរងទុក្ខទោសកយា ។

១- បាត់ ១ ពាក្យ ។

ពីបាកអញពីក្មេង    ពុំដែលទិនហៅបានជា
បានទ្រព្យធនធានណា    ដល់គិតគួរនោះគ្មានឡើយ ។
ជួនបាសតាមក្រោយប្តី    ឮស្វាមីយំពេន
មើលស្រូវមិញបាត់ផង    ហើយក៏តក់ទ្រង់ការគ្នា ។
ដណ្តឹងទៅស្វាមី    ស្រូវយើងចូដូចនោះណា
នុះយើងរឹងរឹង    សមទិនក្សួយដីតែហោង ។
ឯប្តីនុបប្រពន្ធ    កើតទុក្ខធ្ងន់ក្រៃកន្ទង
ផ្តេកផ្តួលខ្លួនជាមួយ    ស្តីទិនក្សួយជនជីវី ។
លុះបានភ្ញាក់ស្មារតី    ទើបស្វាមីប្រាប់ភរិយា
នាងអើយសេះពីណា    មិញមិនដឹងសុំអស់ហោង ។
ជួនបាសទៀងខ្ញុំទៀត    ទ្រង់ចង្អៀតពេកកន្ទង
ថាទុអញនេះម្តង    នេះកើតទុក្ខវេទធ្ងន់ក្រៃ ។
សង្វាតបង់ទ្រព្យ    ពីការគ្នាអញឯងនៃ
ប្រាក់ស្ទូងទុកសំថៃ    ខ្លួនខ្លាចក្រែងបាសមេណោ ។
ម្តេចឡើយមកប្រុសព្រាត់    បង់ខ្វាយខ្វាត់ពីទ្រព្យជា
ស្តាយស្រូវអញមហិមា    សើអញស្លាប់ខ្លួនហើយហោង ។
ប្រុសប្រាណដោយក្តីស្រែ    ខ្ញុំបនៃភ៌ដើមទង
តាំងពីនោះកជាមួយ    ដល់សន្ធប់ទៀបទិនក្សួយ ។

លុះបានភ្ញាក់ស្មារតី ឡើងអំពីសន្ទប់ណា
ពិបាកចិត្តអាល័យ ស្រូវមមៃពុំភ្លេចឡើយ ។
ស្រូវអញល្អប្រពៃ គួរអាល័យពេកម៉្លេះអើយ
ម្តេចព្រាសចេញព្រះនើយ ឲ្យអាសារសូន្យបេះណា ។
ស្មាម៉ីរះកន់ចិត្ត ហើយទើបគិតនឹងករិយា
នាងអើយអញប្រាថ្នា ចង់តាមសេះឲ្យបានយល់ ។
ពោះទៅដល់ស្រុកឆ្ងាយ នោះនៅកាយក្តីសល់ធ្វល់
ប្រសិនបើអញយល់ អម្ចាស់ចាំតាសំណង់ ។
ស្រូវយើងដែលសំពៃ នាងវិលវៃចឹស(១)តាប់ហោង
កាតមួយឲ្យមកបង នឹងកាលទៅតាមសេះនៃ ។
ប្រពន្ធចសស្រូវស្រេច អួយរំពេចប្រកកន់វៃ
សព្វគ្រប់ឲ្យទៅដៃ ប្តីសោតវៃនាប់ម៉ូមា ។
តាតាស់ពេលស្រូវស្រែ មើលចនៃដោយបាតា
សេះជាន់នៅគេទ្ចូ ប្រថពីយល់ជាក់ហើយ ។
តាតាស់ហេតុតោកយ៉ាក ដើរលំបាកពេកគន្ធន
ចរគ្រាប់លេចលេង អស់ព្រៃផង់ឯកអង្គា ។
កាលនោះតាជាប្តី ដើរឃ្លាតខ្ចីដោយវេទនា
កន្លែងព្រៃឯកអង្គា តាមដោយដានសេះនោះហោង ។

១- បុកស្រូវ ។

តាចាស់ដើរទៅដល់ បានយន់យល់សេះនោះហាន

គិតគ្រប់ជប់គន្ធ ជាទុអញអសារសល់ ។

សង្កាតដើរលះបង់ ហោលទាំងប្រពន្ធឥតកូន

ស៊ើអញដើរទៅជួន សេះសខាបទេកូវណា ។

អញគិតស្មានដឹងដល់ បានយន់យល់អម្ចាស់វា

អញនឹងហោរទិស្វា(១) ទះតារយកជាសំណាង ។

អញអកញ្ញាក្រៃ ហៅបង្រ្កៃពេកកន្លង

អកញ្ញម្ដេចច្រើនផង ច្រើនគ្រាផងគ្រាន់មិនថៃល ។

អញប្រាស់តាំងស្រូវស្រែ តាមបន្ទៃមកដល់ជាន

អញគិតជានឹងបាន មិនដឹងផលដូច្នេះឡើយ ។

បើគិតគួរអញបាប សេះនេះខ្លាបៈហើយដឹកទៅ

ឲ្យបានផលលទៅ ស្រុកស្រែអញនោះជាក្រៃ ។

នឹងយកទ្រព្យប្រពៃ ឲ្យជាថ្លៃស្រូវវិញហើយ

ពិតពុំបង្អង់ឡើយ មកសូមលោះពីអញហាន ។

តាចាស់គិតហ្វោះហើយ ពុំលង់ឡើយពោចវល្វ៍ផង

បានបើខ្លាប់ហើយចាប់ចង សេះនោះហាន់ហើយដឹកទៅ ។

---

១- ឃើញហោរ ។

ឯងពង្រោធសត្វ　　តាមដោយកិតឯក្រោយគា
គាត់សោកពុំនាំពារ　　ខឹងចង់ជះឲ្យសប្បាយ ។
គាចាស់ដឹកក្បត្រថ្ងៃ　　ពីក្នុងព្រៃនោះឆ្ងាយ
ពុំផលទឹងលោះលាយ　　សុខសប្បាយពាល់តិចហោង ។
លុះដឹកទៅដល់ផ្ទះ　　ហើយប្រាប់ប្រពន្ធឯងហោង
នាងអើយឯអញបង　　ទៅតាមសេះសោកអញបាន ។
យង់យល់សេះនោះខែ　　នៅក្នុងព្រៃពីក្បសមបាន
ពុំឃើញនៅទីស្ថាន　　ស្រុកទេសគេនោះឡើយហោង ។
អញយល់ជាឥតសាច　　ទើបអញចាប់សេះនេះបង
ខ្លាប់ហើយដឹកមកផង　　ក្រែពេបពះខឹងអម្ចាស់ ។
គាបេនោះគាជាប្តី　　គាត់ស្រដីទឹងជូនចាស់
ប្រាប់ឲ្យដឹងជាក់ច្បាស់　　ដោយដំណើរឥតខ្វះហោង ។

## បទកាកគតិ

គាចាស់នោះណា　　សង្វាតក្បា　　សេះនោះឥតក្តង
បើព្រឹកឡើងហើយ　　ដឹកសេះទៅចង　　ឯក្រោយរបង
នោះឯងសព្វថ្ងៃ ។

កាលនោះអ្នកផង　យល់តាចាស់ចង　សេះសោកល្អក្រៃ
ហើយពិចារណា　ទីនគ្នាថាវើយ　សេះនេះឯងនៃ
ល្អឥតផ្ទឹមបាន　។
រីសេះនេះណា　បើដោយគិតថា　សេះមហាក្សត្រក្សាន្ត
ទើបល្អដល់ម៉្លេះ　រូបសេះនេះមាន　កម្លាំងក្នុងប្រាណ
ឥតអ្នកផ្ទឹមឡើយ　។
ថាហើយអស់គ្នា　ទៅប្រាប់ព្រះញា　ឲ្យជ្រាបជាហើយ
ក្រែងពជអាសា　ក្សត្រាត្រាណត្រើយ　បើលោកយល់ហើយ
យើងបានលាកក្រៃ　។
គិតគ្នាប្នះហើយ　ពុំយូរលង់ឡើយ　ម្នម្នាវ ។
ដើរទៅម្នម្នា　ខ្លះក៏ចាប់ដៃ　ដឹកទៅហើយនៃ
គិតគ្នាទៀតហោង　។
ថាហើយអស់គ្នា　ប្រសិនបើតា　ចាស់កាចកន្ទុង
គាត់យកឯសេះ　លាក់បាត់កន្ទុង　យើងមិញទិនរង
ពោសនោះជូនក្រៃ　។
បើយើងទាំងនេះ　ព្រាយប្រាប់ពីសេះ　ថាឃើញនៅដៃ
តាចាស់នោះណា　រក្សាសព្វថ្ងៃ　មិនដូចពាក្យស្ដី
សមយើងនឹងក្រ　។

ដោយអញគិតថា　គួរតែកែគ្នា　ខ្លះនៅនេះល្អ

ឲ្យមើលចំណាំ　គយឃ្លាំទៅមក　ក្រែងតាហស់យក

សេះលាក់ដោយព្រៃ ៗ

អ្នកខ្លះទៅប្រាប់　លោកឲ្យប្រញាប់　វិលមកវៃ ៗ

កុំផ្សងផ្សូរហើយ　ឲ្យយូរពេកក្រៃ　ម្លោះហើយវៃ ៗ

កុំយូរឡើយណា ៗ

គិតគ្នាព្រមហើយ　កុំផ្សូរផ្សងឡើយ　ដើរទៅម្នា

ខ្លះទៅមើលសេះ　វិលវេះទងគ្នា　បង់មិននាំពារ

ឲ្យតាជំនងផង ៗ

ខ្លះទៅឃ្លាតខ្ចី　រ៉េះរកមន្ត្រី　ជាជំកទ្វង

ឃើញហើយកូលទៅ　សំដៅចុំទបឹង　ប្ដឹងដោយទំនង

ដំណើរនោះណា ៗ

ខ្លះប្ដឹងទៅខ្ចី　ញ៉ីមាត់ស្រដី　ពិបេញភាសា

ក្រឡេកក្រឡៅ　មើលទៅមុខគ្នា　ខ្លះសោកត្រួយថា

អញឲ្យអញហោង ៗ

ម្នាក់សោកប្ដឹងថា　ខ្ញុំបាទអស់គ្នា　ប្ដឹងអ្នកបាទផង

ឲ្យជាជំណឹង　ក្រែងមានគ្គាំគ្គង　បទយើងខ្ញុំផង

យល់សេះល្អក្រៃ ៗ

ឬសេះនោះណា ឃើញនៅដៃគា ចាស់មួយដងៃ
រីឯរូបសេះ នោះល្អប្រពៃ ស៊ើនឹងអាជនេយ្យ
សេះស្លូតបានហោង ។

កាលនោះមន្ត្រី ស្ដាប់ក់ទក់ទី នៃអស់អ្នកផង
សម្ដែងរៀបរាប់ ប្រាយប្រាប់ដើមទង ពីសេះនោះហោង
អវែតឧបមា ។

មន្ត្រីឆ្លើយថា បើបោះបួលគ្នា នាំអញទៅផង
ទៅឲ្យយល់រូប សេះនោះជាម្ដង សម្បុរខ្លួនប្រាណ
នូវគោមធាយា ។

បើសេះនោះល្អ ឃើងនឹងវិរក់ កិច្ចកលមោសា
បំពារបំពោត បញ្ឆោតនៃតា ចាស់នោះកល់គ្នា
ថាសេះអញហោង ។

មន្ត្រីគិតស្រេច ទៅមួយរំពេច បានយល់សេះផង
មើលអស់រូបា អាសាឥតគង់ ល្អគ្រប់គ្រឿងផង
ថ្លៃថ្លឹងពុំបាន ។

មន្ត្រីគិតថា ហើយសេះនេះណា អញយល់ពុំហ៊ាន
យកជាសេះឯង គិតក្រែងខុសប្រាណ អង្គអញនឹងមាន
ទោសធ្ងន់ក្លាត់ហោង ។

បើអញយកទៅ    រក្សាទុកនៅ    ផ្ទះឯងជាមួន
ពុំស្អាតសោះទេ    រីឯអ្នកផង    ទូលប្រាប់ស្ដេចហោង
ពុំលែងឡើយនៃ ។

ស្ដេចជ្រាបសេចក្ដី    អស់អាថ៌អំពី    លំអរអស្សា
ស្ដេចសព្វព្រះទ័យ    លើសក្រៃមហិមា    ហើយស្ដេចនឹងថា
អញជាពោរហោង ។

រីសេះនេះណា    អញនឹងព្រាថា    ពុំបានលើសហោង
បទសេះនេះល្អ    ឥតអ្នកផ្ទឹមបាន    គួរស្ដេចគង់ហោង
សក្ដិសមប្រពៃ ។

មន្ត្រីនោះណា    គិតនឹងអស់គ្នា    ដូច្នោះហើយនៃ
ពុំហ៊ានយកសេះ    នោះមកផងណា    ជាសេះអាគ្នា
ខ្លាចព្រះសម្មា ។

កាលនោះបើយល់    សេះស្លូតមន្ដល    ល្អឥតគណនា
ពុំអាចហ៊ានយក    ជាសេះសត្វា    ពុំហ៊ានពុំពារ
យកមកឡើយហោង ។

ទើបអស់មន្ត្រី    គិតនឹងគ្នាគី    សព្វគ្រប់ជាមួន
ចូលអស់ទាំងគ្នា    មន្ត្រីឡើងផ្គួន    ទូលក្សត្រប្រាសប្បន
ឲ្យជ្រាបទំយា ។

(នៅមានត)

# ឧបនិប័ទ និង ទស្សនវិជ្ជាព្រាហ្មណ៍

(The Upanisad and Brahmanical Philosophy)

សេចក្ដីតទៅនេះ ជាផ្នែកទីបីនៃវេទ ហៅថា ឧបនិស័ទ “ឧប+និ+សទ = អង្គុយជិត,, ។ ឧបនិស័ទនេះ បញ្ឈាក់ពីគោលគំនិតដែលជាអាការៈខាងក្រៅ ។ លទ្ធិដែលស្ដីក្នុងអត្ថបទតទៅនេះសុទ្ធតែជាវិធីហិណ្ឌូទាំងមូល ។ ឧបនិស័ទនេះ មិនត្រឹមតែជាស្រុតិ (Révelation ) ដែលជាវេទផ្នែកមន្ត្រៈនិងព្រាហ្មណៈប៉ុណ្ណឹងទេ ដែលពិតនោះ គឺជាផ្នែកនៃវេទពិតប្រាកដតែម្ដង ជាធម៌ដែលព្រាហ្មណ៍ឬជនហិណ្ឌូគ្រប់រូបត្រូវសិក្សា ហើយអប់រំចិត្តគំនិតខ្លួនតាមធម៌ជានិច្ចនៅនាបច្ចុប្បន្នកាលនេះ។

ដើម្បីសិក្សាឧបនិស័ទឲ្យបានយល់ច្បាស់ ដើមឡើយត្រូវចងចាំទុកនៅក្នុងចិត្តយើងថា អ្នកកាន់ច្បាប់លទ្ធិនេះ បានចែកវេទនេះ ជាពីរផ្នែកគឺ :

ក- ផ្នែកទីមួយហៅថា កម៌–កាណ្ឌ “ផ្នែកការងារ,, ផ្នែកនេះរួមយកទាំងមន្ត្រៈនិងព្រាហ្មណៈមកបញ្ចូលជាមួយផង ។ ផ្នែកនេះហើយជាផ្នែកដែលជនហិណ្ឌូភាគច្រើនមិនអាចយល់ដោយងាយបានទេថា តើកម៌–កាណ្ឌ “ការងារ,, ដែលត្រូវធ្វើដូចម្ដេច ព្រោះជាអាថ៌កំបាំង គេយល់ដោយងាយបានត្រឹមតែការចំណោញអំពើល្អៗ ដោយការសូត្រមន្ត្រៈការបូជាយជ្ញៈរ៏ផ្សេងៗ និងការបំពេញតបធម៌តែប៉ុណ្ណោះ ។ ពិធីងាយទាំងអស់ដែលគេអាចយល់បាននេះ ជនហិណ្ឌូគ្រប់គ្នាអាចធ្វើការ

គោរពបូជាចំពោះអាទិទេព ។ ដែលថែងគាត់ជារូបអ្វីណាមួយក៏បាន តាមពេញចិត្តខ្លួន ព្រោះអាទិទេពមានរូបផ្សេងច្រើនប្រការណាស់ ។

១. ផ្នែកទីពីរហៅថា ជ្ញាន–កាណ្ឌ «ផ្នែកវិជ្ជា» ។ ផ្នែកនេះហើយ ដែលមាននៅក្នុងអត្ថបទឧបនិស័ទ ជាផ្នែកដែលត្រូវស្រាល់ជ្រើសរកតែ អ្នកដែលមានការចេះដឹងច្រើន ហើយមានសមត្ថភាពគ្រប់គ្រាន់ អាចយល់នូវលទ្ធិសាសនានេះបានដោយប្រពៃផង ទើបត្រូវប្រតិបត្តិ ។

យើងបានដឹងថា លទ្ធិសាសនារបស់មនុស្ស ដែលស្ដីថា មានវិជ្ជា ការចេះដឹងពិតប្រាកដ នុះលទ្ធិសាសនាឆាយៗទេ ព្រោះថា គ្រាន់តែគេមានជំនឿ មានអាទិទេព "បរមសត្វៈ" ក្នុងលោកនេះ ហើយ អាទិទេពនេះហើយ ដែលបង្កើតលោកសន្និវាសនេះឡើង តែប៉ុណ្ណោះទុកជាបានការហើយ ។

លទ្ធិដែលជឿថា មានអាទិទេពនេះ កើតមានទូទៅក្នុងពាក្យ ដោយពិត គឺលទ្ធិដែលកើតចេញមកពីគម្ពីរឧបនិស័ទបុរាណនេះឯង ដោយច្រើនពោះជាលទ្ធិនោះៗ លាយឡំដោយលទ្ធិសាសនាអាថ៌កំបាំងឬប្រតិស្ឋឡើងក៏ដោយ ។ គម្ពីរឧបនិស័ទ មានយ៉ាងតិចចំនួន ១៥០ គម្ពីរ តែគម្ពីរដែលសរសេរជាសេចក្ដីពាយបម្រុះដោយគាថាមានច្រើនជាងគេ ស្ដាយណាស់ ព្រោះនៅក្នុងប្រទេសឥណ្ឌា មិនមានឯកសារទុកក្នុងប្រវត្តិសាស្ត្របរិបូណ៌ ល្មមយើងអាចកំណត់កាលបរិច្ឆេទឲ្យបានទៀងទាត់ ដូចកាលបរិច្ឆេទញ ផ្នែកមន្ត្រៈនោះឡើយ ។ ឯរបៀបការសរសេរទៀតសោត មើលទៅឃើញថាមិនមែនជាបែបបុរាណពេកទេ ពោលគឺមិនមានការផ្សេងគ្នា

ណាស់ណាពីបែបសំស្ក្រឹតគន្ធី (Classical samskrit) នោះឡើយ ។ ឧបនិស័ទខ្លះ ដែលមើលទៅឃើញថាចាស់ ក៏ទំនងជាចាស់ត្រឹមត្រូវមុនគ្រិស្តសករាជ ៦ ប៉ុណ្ណោះ ។ អត្ថបទទាំងនេះ រួមចូលនៅក្នុងផ្នែកអារណ្យកទាំងអស់ ឃើញមានក្នុងវគ្គនៃផ្នែកព្រាហ្មណៈខ្លះដែរ តែជាវគ្គមានអាថិគម្ភីរភាពហួសប្រមាណពេក ហើយសម្រាប់ពួកតាបសឬសីសិក្សានៅក្នុងព្រៃស្ងាត់ឆ្ងាយពីស្រុកភូមិ ។ សេចក្ដីពិត ផ្នែកព្រាហ្មណៈមួយៗ មានផ្នែកអារណ្យកៈមួយៗ ប្រកបជាមួយផង ។ ឯឧត្តមគតិខាងទស្សនវិជ្ជាឃើញមានការលាយឡំជាមួយសេចក្ដីឥតប្រយោជន៍ច្រើនណាស់ ជាហេតុនាំឲ្យវគ្គដែលជាឧបនិស័ទនោះ ។ បន្ថែមសេចក្ដីខ្លះសម្រាប់ពិចារណានូវប្រស្នាអាថ៌កំបាំងផ្សេងៗ ដូចជានិយាយដើមកំណើតនៃពិភពលោក ប្រភេទទេវតា ប្រភេទអាត្មននៃមនុស្សលោក ព្រមទាំងការចាក់ចេញទៅវិញទៅមកនៃមនៈ និងរូប ទៀតផង ។

ឯឈ្មោះនៃឧបនិស័ទទាំង ១០ ប្រការដែលសំខាន់ជាងគេនោះ គឺ ឦសាឧបនិស័ទ (ជាប់នៅវគ្គទី ៤០ នៃវាជសនេយីសំហិតា) កេនៈឧបនិស័ទ និង ឆាន្ទោគ្យៈ (នៃសាមវេទ) កឋៈឧបនិស័ទ ប្រស្នៈឧបនិ-ស័ទ មុណ្ឌកៈឧបនិស័ទ មាណ្ឌូក្យឧបនិស័ទ (នៃអថវ៌វេទ) ពហ-ការណ្យកៈឧបនិស័ទ (ផ្ជាប់ជាមួយសតបថព្រាហ្មណៈ) អៃតរេយៈ (ជារបស់ឫគ្វេទ) តៃត្តិរីយៈ(ជារបស់យជុវេទខ្មៅ) ។

ឥឡូវ យើងគួរលើកយកទស្សនវិជ្ជាជំនាន់ដើមដែលនៅត្រើមៗ មក

ពិចារណា ព្រោះស្នាដៃទាំងនេះ ជាស្នាដៃសំញាំវិលវល់ប្រកបដោយឧត្តមគតិលទ្ធិសាសនា ហើយមិនសូវមានប្រយោជន៍ប៉ុន្មាន ទាំងជាហេតុនាំអ្នកសិក្សា មើលទៅហើយ កើតមានការភ័ន្តច្រឡំថែមទៀតផង ។ កាលទស្សនវិជ្ជាជំនាន់ដើមទាំងនេះជាខ្សែជាប់ទាក់ទងនឹងគម្ពីរព្រាហ្មណៈ ព្រមទាំងទស្សនៈផ្សេង ៗ ទៀត យើងមើលឃើញការទាក់ទងទាំងនេះ ដោយក្បួនទីតិការបូជា ដែលមានគាថាលាយឡំច្រើនប្រការជាមួយក្នុងន័យនោះ ប៉ុន្តែទស្សនវិជ្ជាដើមនេះ មានការលូតលាស់ ជាច្រើន ខ្ពស់ជាងព្រាហ្មណៈទៅទៀត មានខ្លះបញ្ចេញគំនិត ជាឧត្តមគតិដើមដ៏សំខាន់ ហើយប្រើពាក្យពេចន៍ខ្ពង់ខ្ពស់ទៀត ហាក់ដូចសម្រាប់គេប្រែលទ្ធិសាសនាដ៏កំបាំងស្តាប់មិនបានទាំងនេះ ឲ្យយល់ងាយ ។

តទៅនេះ ជាសេចក្តីប្រែផ្តិត នៃផ្នែកគម្ពីរ ឦសាឧបនិច័ទ ដែលអ្នកប្រាជ្ញទុកជាគោលដ៏សំខាន់ ជាឧទាហរណ៍ដ៏ប្រពៃសម្រាប់ពន្យល់ឲ្យយល់នូវលទ្ធិអាទិទេពក្នុងគម្ពីរព្រាហ្មណៈដែលមានប្រាកដតាំងពីបូរាណសម័យនៅក្នុងអក្សរសាស្ត្រប្រទេសឥណ្ឌា ដូចតទៅនេះ :

អ្វីដែលកើតមាននៅក្នុងលោកនេះ
ជាធម៌ដែលលោកទុកជាការគ្រប់ដណ្តប់
ដោយមហាភូត ហាក់បីដូចជារុំព័ទ្ធដោយអម្ពរពស្ត្រ ។
មានតែមួយគត់ គឺអាទិទេព ដែលកើតមាន
មិនរំកើបញាប់ញ័រ តែបើស្តេចទៅ ទ្រង់មានសន្ទុះលឿនជាងចិត្ត,

ព្រះអង្គផ្សាយញាណទៅឆ្ងាយ ហើយទេពតាទាំងឡាយ
ក៏ខំរត់ទៅតាមព្រះអង្គឲ្យទាន់; ទុកជាក្នុងពេលសម្រាក
ទ្រង់នៅតែលឿនជាងការហោះដំលឿននៃសត្វដទៃៗទាំងអស់,
ព្រះអង្គ; ប្រៀបបាននឹងអាកាសធាតុ; ទ្រទ្រង់នូវអំពើជាជីវិតទាំង
អស់ ។

ព្រះអង្គស្តេចទៅ ក៏ដូចជាស្តេចមិនទៅ; នៅឆ្ងាយក៏ដូចនៅជិត
ទ្រង់ទតនៅក្នុងពិភពលោកនេះ ។ ទ្រង់ប្រមើលមើល
សព្វសត្វមានជីវិត ហាក់ដូចជានៅក្នុងព្រះអង្គ ហើយព្រះអង្គជា
ដួងពិភពលោក-ប្រថាប់នៅខាងក្នុងទាំងអស់; ហើយតទៅ ទ្រង់ថែ
រក្សាសព្វសត្វ ពុំព្រងើយកន្តើយឡើយ ។

យើងបានឃើញទស្សនវិជ្ជាឧបនិស័ទនេះហើយ យើងគួរសិក្សា ទស្សនវិជ្ជាដទៃៗជាសេចក្តីដោយឡែកផ្សេងពីឧបនិស័ទ គឺមិនមែនជា "ស្រុតិ" (Revelation) របស់អាទិទេពទៀត ។

ទស្សនវិជ្ជាដែលយើងនឹងសិក្សាតទៅ ដូនកាលហៅសាស្ត្រ ៦ ប្រការ ឬ ឧបករណ៍ពន្យល់សច្ចធម៌ ៦ ប្រការ ដែលអ្នកបស្ចិមហៅថា (Six systémes) ។ ទស្សនវិជ្ជាទាំងនេះ មិនកប់បញ្ចូនក្នុងលទ្ធិផ្សេងៗ ដែលមានក្នុងន័យមានធម៌សាស្ត្រ សតវត្សរ៍ទី ១៥ មុនគ្រិស្តសករាជនោះទេ ។ សេចក្តីពិត ទស្សនវិជ្ជានេះ កើតឡើងក្រៅគម្ពីរឧបនិស័ទ តែក្នុងន័យឧបនិស័ទដែរ គឺកើតឡើងក្នុងសម័យដែលគេតែងគម្ពីរមានុវធម៌-សាស្ត្រ (Manu's Las ឬ Loi de Manu) ដូចមានឈ្មោះតទៅនេះគឺ :

១– ន្យាយ: តែងដោយលោកគោតម

២– វៃសេសិក: តែងដោយលោក កណាទ

៣– សាំខ្យ: តែងដោយលោក កបិល

៤– យោគ: តែងដោយលោក បតញ្ជលិ

៥– មីមាំស្សា តែងដោយលោក ជៃមិនិ

៦– វេទាន្ត: តែងដោយលោក ពាទរាយណ:ឬវ្យាស:

ទស្សនវិជ្ជាទាំង ៦ ប្រការខាងលើនេះ តែងថែបជាសូត្រ: (Aphorisme) ទុកជាបាទសម្រាប់ការពិចារណារកសច្ចធម៌ ឬ ជាគោលពិចារណាលទ្ធិសាសនាជំនាន់ក្រោយទាំងអស់ តាមមុខវិជ្ជាមួយៗ ។

កាលបរិច្ឆេទ តែងសូត្រ:(Aphorisme) នេះ មិនមានការកំណត់ត្រឹមត្រូវពិតប្រាកដទេ ថែមទាំងមិនអាចកំណត់បានថា ទស្សនវិជ្ជាផ្សេងៗនេះ គេបានយកមកប្រើជា វិធីសិក្សាតាំងពីកាលណា ឬសូម្បីតែឲ្យបានដឹងថា ទស្សនវិជ្ជាទាំង ៦ ប្រការនេះ វិជ្ជាណាកើតមុនគេក៏កំណត់មិនបាន ។ ខ្លះជាទ្រឹស្តីទ្វៃត: (ទ្វិតភាគ=(Dualisme) ស្តីពីសហាវិជ្ជមាន (Co-Existence) នៃគោលការណ៍ជានិត្យ:២ប្រការ (two eternal principles) ។ ខ្លះទៀតជាទ្រឹស្តីអទ្វៃត: (អទ្វិតភាព=Non-Dualisme) ស្តីពីឯកសច្ច ដោយអាងទៅលើឯកភាពនៃសព្វសត្វ ។ ចំណុចផ្សេងគ្នាច្បាស់លាស់នេះ នឹងមានពន្យល់ទៅខាងមុខ ។ ក្នុងទីនេះ យើងនិយាយចំពោះតែវិជ្ជាដែលជាបរមត្ថ ព្រមទាំងរូបមន្ត្រ: ដែលជាគោលទស្សនវិជ្ជាពិតៗ ប៉ុណ្ណោះ ។

តាមការពិចារណាមើល ឃើញហាក់ដូចជាមានការពិតច្រើនណាស់ថា ប្រមាណជាប្រាំ ឬ ប្រាំមួយបតវត្សរ៍ខាងដើមគ្រិស្តសករាជ មានចលនាមួយធំកើតឡើងខ្លាំងក្លាចំពោះលោក ដែលមានការគិតពិចារណាក្នុងចិត្តទូទៅពេញសកលលោកដែលមានការចម្រើនឡើង ៗ ដោយហេតុនេះ យើងឃើញមានការកើតឡើងនៃអគ្គព្រះសម្ពុទ្ធ នៅក្នុងប្រទេសឥណ្ឌា; ក្រុមលោក Pythagoras នៅប្រទេសក្រិក សាស្ត្រាចារ្យ Zoroaster នៅប្រទេសប៉ារ៉ីស (Perse=Iran) លោកខុងជឺ (eonfucius) នៅប្រទេសចិន ៗ កាលនោះមនុស្សទាំងឡាយចាប់ផ្តើមសួរខ្លួនឯងយ៉ាងមុឹងម៉ាត់ថា :

- ខ្ញុំគឺអ្វី!
- ចុះខ្ញុំមកពីកាលណា ?
- ហើយខ្ញុំកំពុងទៅឯណា?
- តើខ្ញុំអាចពន្យល់ប្រាប់ "ចិត្តខ្ញុំ,, ក្នុងភពមនុស្សនេះបានដូចម្តេច?
- ចុះការទាក់ទងរវាងធម្មជាតិ គឺរូបធម៌និងអរូបធម៌នេះបានដូចម្តេច?
- ក្នុងលោកនេះ តើខ្ញុំមើលឃើញខ្លួនខ្ញុំដូចម្តេច?
- ធ្វើដូចម្តេច ខ្ញុំអាចពន្យល់នូវអាថ៌កំបាំង ដ៏ជ្រាលជ្រៅនៃធម្មជាតិ នូវប្រវត្តិការកើតលោកនេះបាន?
- ចុះអាទិទេពប្រាជ្ញប្រសើរ មានអានុភាពខ្លាំង បានបង្កើតលោកនេះពីអ្វី ដែលទេនៃមែនឬទេ?

– ឬពិភពលោកនេះកើតឡើងព្រម ដោយការប្រសព្វគ្នាឯងៗនៃបរមាណូជានិត្យ: ?

– ឬពុំនោះ បើអាទិទេពមានប្រាជ្ញាមិនមានទីបំផុត ហើយបង្កើតលោកនេះពិតមែន តើខ្ញុំអាចពន្យល់នូវវិសមភាព នៃលក្ខណ: លោកនេះ ដូចម្ដេចបាន -ដូចជាល្អ ឬ អាក្រក់, សុខឬទុក្ខជាដើមនេះ?

– តើអាទិទេពដែលបង្កើតលោកមានរូប ឬ ឥតរូប ?

– តើអាទិទេពមានគុណ ឬ និគុណ?

សេចក្ដីពិត នៅក្នុងប្រទេសឥណ្ឌា ប្រស្នាទាំងនេះ ដោះស្រាយឲ្យពេញចិត្តពុំទាន់បាននៅឡើយទេ ដូចសេចក្ដីដែលយើងបានឃើញនូវក្នុងបទសូត្រ:និងមន្ត្រ:នៃគរីហិណ្យ-អាយនិតិបូរណ កោះយោបីគម្ពីរដូចថា "វេទ ឬ វិជ្ជា" ដែលតែងដោយពួកព្រាហ្មណ៍ក៏ដោយ ក៏មិនបានផ្ដល់ឲ្យនូវការចេះដឹងអ្វីពិតប្រាកដដល់យើង ចំពោះគំណាចសំខាន់ខាងលើនេះដែរ បើបានខ្លះ គ្រាន់តែថ្លែងប្រាប់នូវវិធីស្វែងរកខាងដើមនៅក្នុងចិត្តមនុស្ស ដែលស្វែងរកសច្ច:ធម៌ដោយពន្លឺព្រាលៗនៃបាតុភូតជាធម្មតាប៉ុណ្ណោះ ។

ឯវិធីគេរបស់ព្រាហ្មណ៍ទៀតសោត ក៏មិនបានផ្ដល់អ្វីជាពន្លឺចំពោះចំណុចនេះបន្តិចបន្តួចសោះដែរ គេជាស្ដីពីអ្វីដែលរឹតតែធ្វើឲ្យមានជំនឿផ្ដេសផ្ដាស កាន់តែច្រើនឡើងៗ និងប្រសិទ្ធិភាពនៃយជ្ញពិធី ដែលឥត

ប្រយោជន៍ទៅវិញ ព្រមទាំងបង្កើតឲ្យមានគតិស្សរការពារពង្សមនុស្សទៀត មានវណ្ណៈ ទុកវណ្ណៈស្រមណព្រាហ្មណ៍ថាជាកណ្ដាលហើយនិយាយ ថា មានមាគ៌ាកណ្ដាល ពង្សមនុស្ស និងទេពតាទាំងឡាយ ទៀត ។ ប្រស្នាទាំងនេះ នៅតែត្រូវការដោះស្រាយមិនចេះអស់ ចិត្តគំនិតមនុស្ស នៅតែស្វែងរកមិនឈប់ឈរក្នុងគ្រិត ដែលកើតមានជាប្រពៃណីនេះ ដដែល ហើយមិនមានការពេញចិត្តចំពោះវិធីទិតជាសំបកក្រៅនៅក្នុងចិត្ត សោះ ។ ហេតុនេះទើបអ្នកគិត (Thinkers = Penseurs) ម្នាក់ៗ ខំព្យា-យាមរកតែខ្លួនឯងចំពោះចំណោទធំៗនៃជីវិត ដោយវិចារណញ្ញាណ ខ្លួនឯងឡើង តែការពិតនេះមិនផ្ទុយពីគោលឧបនិស័ទឡើយដូចយើងបាន ឃើញនៅក្នុងឧបនិស័ទនោះស្រាប់ហើយ ។ សេចក្ដីដូចបានពោលមក នេះ យើងគួរកុំភ្លេចថាទស្សនវិជ្ជាទាំងនេះមិនផ្ទុយពីគ្រិតទេ គឺគ្រាន់តែ ថាសេចក្ដីបន្ថែមឲ្យពិស្ដារជួយបំភ្លឺសេចក្ដីប៉ុណ្ណោះ ។ ទស្សនវិជ្ជាទាំង នេះទុកជាភាគនៃវេទរួមជាមួយដែរ ហើយជាវចនៈប្រសើរបំផុត គឺជា កំពូលជាទីប្រជុំចុះនៃគ្រិតដើមទាំងអស់ទៀត ។ ហេតុការណ៍ដែលកើត មានឡើងដូច្នេះ ទំនងជាពួកព្រាហ្មណ៍ កាលបើមិនអាចបដិសេធវណ្ណៈ ក្សត្រនិងវណ្ណៈទាបដទៃទៀតបាន ព្រោះមានការតក៌សមហេតុផលដែរ ហើយដោយពួកខ្លួនឈ្លាសវៃ, ក៏កំរិតវណ្ណៈរបស់ខ្លួនឲ្យខ្ពស់ ទើប លើកតម្កើងទស្សនវិជ្ជាខ្លួន ដែលប្រសើរទុកក្នុងឧបនិស័ទថាមានឋានៈស្មើ នឹងវេទ ។

ដូច្នេះលទ្ធិសាសនាព្រាហ្មណ៍ និងទស្សនវិជ្ជាហេតុផលលូតលាស់ផុះជាលច្ចងគ្នាទៅវិញទៅមក ។ ហើយព្រាហ្មណ៍ណាក៏ដោយអាចទៅជាអ្នកទស្សនវិជ្ជាបាន បើព្រាហ្មណ៍ទាំងនោះសុខចិត្តប្រគល់ទស្សនៈខ្លួនទុកជារបស់តាំងវេទ ។ ប៉ុន្តែបើវណ្ណៈក្សត្រជាអ្នកគិតសេរី (Free-thinker= Penseur libre) ដូចអង្គព្រះសម្ពុទ្ធជាដើមវិញ នោះត្រូវគេបកស្រាយថា អ្នកណាមួយអាចទៅជាសាស្ត្រាចារ្យទស្សនវិជ្ជា ឬ អាចបានទទួលឥស្សរភាពដើម្បីខ្លួន ហើយមិនគោរពចំពោះវេទ ឬចំពោះព្រាហ្មណ៍ទេ អ្នកនោះគេត្រូវចរិហារថាជាអ្នកទ្រុស្តសាសនាមួយរំពេច ។ ទោះម្ដេចម្ដាអ្នកគិតសេរីហើយ មិនជឿតាមដូចសេចក្ដីខាងលើនេះ កើតមានបរិបូណ៌ច្រើននាក់យ៉ាងឆាប់រហ័សនៅក្នុងប្រទេសឥណ្ឌាក្នុងកាលនោះ ។ សេចក្ដីពិត ដំណើរស្របនិងមិនស្របតាមហេតុការណ៍មែននេះ គេបានកត់សម្គាល់ឃើញថា កើតមានរហូតមកនៅក្នុងលទ្ធិហិណ្ឌូ ។ ឯចលនា ចំពោះពុទ្ធសាសនា ផ្នែកខាងអញ្ញទិដ្ឋ (Héritie) មានហេតុការណ៍បែបនេះដែរតែបន្តិចបន្តួចទេ ដែលមានច្រើនចំពោះតែប្រតិកម្មដែលកើតមកពីការសង្កត់សង្កិនពីលទ្ធិសាសនាព្រាហ្មណ៍និងរបៀបវណ្ណៈនោះវិញ ។ ពុទ្ធសាសនាក្នុងសម័យពុទ្ធកាល បើនឹងប្រៀប ប្រៀបដូចជាប៉ាលនាឡិកា ដែលមហាបុរសជាអ្នកត្រាស់ដឹងដូចអង្គព្រះសម្ពុទ្ធទ្រង់បង្វិលធ្វើឡើងក្នុងកាលនោះឯង ។ នេះគឺជាដំណើរនៃការស្ទុះចេញពីអនិស្សរភាពដ៏ឃោរឃៅហួសប្រមាណ ទៅរកទីជម្រកដ៏ត្រជាក់ត្រជុំពោលគឺ

មេត្តាករុណាដ៏ធំទូលាយ ។ នេះគឺជាខាងមភាពការគិតលទ្ធិសាសនាជារបស់ខ្លួន ដែលមិនមានអ្វីមកកាត់បាន ហើយមិនភ័យជាផលវិបាកទៀតផង ។

មួយទៀតលទ្ធិគន្ធបដិបន្ន (Orthodox schools) នៃទស្សនវិជ្ជានេះបានទៅជាដែនកើតនៃទស្សនវិជ្ជាហេតុផល នៃជនដែលធ្លាប់តែធ្វើយជ្ញពិធីហូតចត់នៅបូជនីយដ្ឋានលទ្ធិសាសនាព្រាហ្មណ៍ដោយគោរព ។ លទ្ធិនេះ សុទ្ធតែអនុវត្តទៅតាមគោលគម្ពីរ ដែលជាច្បាប់នៃវេទទាំងអស់ ។ តែទោះម្ដេចម្ដា ក្នុងសម័យនោះ ដោយហេាចណាស់ ក៏គង់មានលទ្ធិពីរលទ្ធិដែរ ក្នុងពួកលទ្ធិទាំង ៦ ដែលបានស្ដីពីកាពផ្ទេផ្ទាត់គ្នាច្បាស់លាស់ ហើយជានិត្យៈនៃចិត្តនិងរូប គឺលទ្ធិវៃសេមិកនិងលទ្ធិសាំខ្យានេះឯងទាំងពីរលទ្ធិនេះដើរបណ្ដោលទៅតាមផ្លូវពុទ្ធសាសនា គឺដើរទៅខាងមិនទទួលស្គាល់ការទិទេពដែលជាអ្នកបង្កើតលោក ។

វិជ្ជាដែលយើងបានសិក្សាមកខាងលើនេះ យើងទុកមួយអន្ទើសិនទុកនិយាយទៅខាងមុខក្នុងនេះក្ដីបន្ទែមរបស់យើង ឥឡូវៈយើងនិយាយចំពោះទស្សនវិជ្ជាដែលកើតឡើងពីឧបនិច័ទសិទ ។ គោលលទ្ធិទៅឃើញមានច្បាស់លាស់ទៅក្នុងគម្ពីរមានវទមិសាស្រ្ដ (Manu's laws) ក្នុងបច្ចុប្បន្នកាលនេះ យើងអាចយល់បានទូវដំទៀពួកអ្នកគិតហិណ្ឌូច្រើននាក់ទោះជានៅក្នុងលទ្ធិណា ឬក្នុងវិធីណាក៏ដោយ ដែលពួកអ្នកគិតហិណ្ឌូទាំងនោះបួលចិត្តកាន់តាម ។

ឯគោលទស្សនវិជ្ជាទាំងអស់នោះដូចតទៅនេះ :

១.អាត្មន៍ ជានិត្យ: (Eternal soul) ទាំងពីរខាង គឺនៅខាងមុខនិងខាងក្រោយ ។ អាត្មន៍នោះ មាន ២ ប្រការគឺ

ក. អាត្មន៍សកលលោកទាំងមូល (Supreme universal soul) ហៅថា បរមាត្មន៍ ព្រហ្មន៍ បុរុស: ។ល។

ខ. អាត្មន៍មួយៗនៃសត្វដែលមានជីវិត (The personal individual soul of living beings) ហៅថា ជីវាត្មន៍ ។

ទោះយោបីអត្តភាព (Entily) ណាមួយជានិត្យ: (Eternal) ក៏ដោយ អាត្មន៍នោះ ។ មិនមានដើមដំបូងទេ ឬ ត្រូវមានទីបំផុត ។ ដូច្នេះ អាត្មន៍នោះទាំងពីរ សកលឬមួយៗ ទោះជាមានរូបផ្សេងគ្នា ឬមានរូបតែមួយ (Identical) ក៏ដោយ ក៏ជាសភាវៈឋិតថេរដកប ហើយតាំងនៅអស់កល្ប ។

២. និត្យភាព (Eternity) នៃរូប (Matter) ឬទ្រព្យ (Substance) នៃពិភពលោកដែលអាស្រ័យហើយលូតលាស់ដុះដាលឡើង ។

សេចក្តីខាងលើនេះ គួរបង់ចាំទុកថា ការវិវត្តន៍ទៅនៃពិភពលោកនេះ តាមសេចក្តីយល់អ្នកសម្ភារនិយម (Matérialiste) ខុះថា កកើតឡើងពីអណូដុំធំ ១ (Gross partichs) នៃរូប ឬបើតាមទស្សនៈគម្ពីរវេទាន្ត:ថា កកើតពីអាត្មន៍ខ្លួនឯង ក្នុងកាលដែលអាត្មន៍ផ្សព្វផ្សាយចេញទៅដោយមាយា (Illusion) ។ នេះជាសេចក្តីពន្យល់ជាទិដ្ឋិជាប់ស្និទ្ធនៃជំនឿរបស់អ្នកទស្សនវិទូហិណ្ឌូដែលថា : នាវស្តុនោ វស្តុសិទ្ធ

(Ex nihilo nihil fit) ប្រែតាមពាក្យថា "ការកើតវត្ថុពីអវត្ថុមិនមានទេ" ប្រែជាសេចក្ដីថា "ទទេ មិនផលិតផលពីទទេឡើយ" ។

៣. អាត្មិ ខ្លួនឯងស្រូបយកគំនិតនិងការចេះដឹងដោយខ្លួនឯង អាច កើតជាគំនិត វិញ្ញាណ វេទនា សញ្ញាបាន ពុំនោះទេ អាចកើត ជាអំពើនិងឆន្ទៈបាន កាលបើប៉ះពាល់ដោយអារម្មណ៍ខាងក្រៅ ហើយ ចូលទៅក្នុងរូបជាផ្នែកនៃកាយ តទៅ ចូលទៅដល់ចិត្ត ឬ មនៈ (Mind ទៀត ។

គួរយល់ចិត្តថា "ចិត្ត ឬ មនៈ" នេះ ជាគន្លងនៃវិញ្ញាណឬជាវិញ្ញា- ណាយតនៈខាងក្នុង គឺជាទ្វារមួយបែបសម្រាប់ឲ្យគំនិតចូលទៅកាន់អាត្មិ ដែលជារបស់កាយ ហើយជាធម្មជាតិមួយផ្សេងពីអាត្មិ ដូចអន្ដរា- យវៈដទៃៗ ដែលនៅក្រៅកាយដែរ ។

៤. ការរួមអាត្មិនិងកាយជាមួយគ្នានេះ ជាហេតុនាំឲ្យកើតជាចំណង និងទុគ្គតភាពចំពោះអាត្មិមនុស្សទូទៅ ។

គួរកត់ចំណាំថា អាត្មិ ដែលរួមជាមួយកាយដូច្នេះហើយ ជា ហេតុនាំឲ្យកើតមានវិញ្ញាណរៀងដែលជារបស់កំណើតបុគ្គលនេះ បុគ្គល ភាពមួយៗ ហើយវិញ្ញាណនោះនេះទទួលអារម្មណ៍ ជាសុខឬជាទុក្ខ (គដ្ឋារម្មណ៍ ឬ អនិដ្ឋារម្មណ៍) ។ តទៅ អាត្មិនេះ ចាប់ផ្ដើមធ្វើអំពើ ហើយអំពើទាំងអស់ល្អឬអាក្រក់ជាហេតុនាំឲ្យកើតជាចំណងចងសត្វព្រោះ ថាអាត្មិនេះនាំមកនូវផលវិបាកដូចសុភាសិតមានដើមថា "អវិស្សមេ

វ ភោត្តព្វំ កតំ កម្មំ សុភាសុភម៌” ប្រែថា “បុគ្គលត្រូវតែបរិភោគនូវផលកម្មល្អឬអាក្រក់ ដែលខ្លួនធ្វើហើយពិតប្រាកដ” ។ ដូច្នេះ បើអំពើជាកុសល ក៏តែងឲ្យផលល្អជាន់ថ្នាក់ បើអំពើជាអកុសល ក៏តែងជាក់ទោសទៅវិញ តាមអំពើនោះៗ ។

៥. ដើម្បីឲ្យរួចផុតស្រឡះពីផលកម្ម ឬ ឲ្យកម្មវិបាកទាំងអស់គ្នាត្រូវឲ្យអាត្មន៍ចេញផុតពីធម៌ដែលជាថ្នាក់ឬជាទោសនេះទៅ ប៉ុន្តែផលជាថ្នាក់ ឬ ការផ្តន្ទាទោសនេះក៏ដោយ មិនមែនជាអវសានជីវិតពេញបរិបូណ៌ពិតទេ ។

នូវយល់ថា ស្ថានសួគ៌ដែលជាវិធីហិណ្ឌូនេះ គ្រាន់តែជាដំណាក់ផ្លូវដើម្បីដើរទៅឲ្យបានដល់សិរហានព្រហ្មតែប៉ុណ្ណោះ ឯទីឋាននរក(១) ក៏ដូចគ្នាដែរ គ្រាន់តែជាន់សោយទុក្ខលំបាកទីលានបាបមួយកាលមួយគ្រាតែប៉ុណ្ណោះទេ ។

តាមទ្រឹស្តីព្រាហ្មណ៍ ដើម្បីឲ្យលុះសិរហាន អាត្មន៍ត្រូវចេញពីកម្មនោះទាំងអស់ វិលវល់ចូលកាន់គតដែលមានរូប អន្ទោលចុះឡើងទៅជាសត្វខ្ពង់ខ្ពស់ ឬ ក្រាលឬទាប តាមអំពើជាបុណ្យជាបាបតទៅ ទើបឡើងទៅខ្ពស់ដល់ថ្នាក់ស្ងបគុណចេញពីគត ក្លាយឈានខ្ពង់ទៅកាន់បានបរមសុខទាំង ៤ ជាន់ទីមួយឈ្មោះ សាលោក្យៈ គឺកើតនៅក្នុងឋានសួគ៌

---

១. នរកព្រាហ្មណ៍ចំនួន ២១ ។ មើលសៀវភៅ Indean wisdom កំណត់លេខ ២, ទំព័រ ៦៧ ។

ជាមួយអាទិទេព" ទីពីរឈ្មោះសាមីប្យៈ "ឋិតនៅជិតអាទិទេព" ទីបី ឈ្មោះសារូប្យៈ "រលាយចូលទៅដូចជាភាពអាទិទេព" ទីបួនរហូតដល់ អវសានជីវិតឈ្មោះសាយុជ្យៈ "គឺការចូលរួមបរិបូណ៌ជាមួយសត្វៈ" ។ នេះទើបដល់ទីបំផុតពិត ។

៦. សង្សារនៃអាត្មន "អាត្មនអន្ទោលទៅមក" ច្រើនជាតិ(១) ណាស់ រាប់មិនអស់ទេ ។ នេះជាសេចក្ដីពន្យល់ច្បាស់លាស់ពីរនៃជីវិតប្រកប ដោយទុក្ខវេទនាក្នុងពិភពលោកនេះ ។

សេចក្ដីនេះ គួរយើងយល់ថា ការទល់ទុក្ខលំបាក រោគាព្យាធិ ទាបខ្ពស់ មានក្រ មានបុណ្យ ឥតបុណ្យ ប្រសើរ មិនប្រសើរ ថោកទាប មិនស្មើនៃទ្រព្យសម្បត្តិ លក្ខណៈចរិតផ្សេងៗគ្នា ឬអាក្រក់ ទាំងអស់នេះ សុទ្ធតែជាផលវិបាកនៃកម្ម ដែលអាត្មនមួយៗបានធ្វើ តាមទំនើងខ្លួនឯងពីអតីតជាតិ ធម៌ទាំងឡាយបញ្ចេញអនុភាពជំរុញខ្លាំងក្លា តាមអាត្មននោះ ។ ដែលហៅថា អទិដ្ឋ "មើលមិនឃើញ" ។ ដូច្នេះ អាត្មនត្រូវទទួលវិបាកនៃកម្មៈរបស់ខ្លួនជាដាច់ខាត ហើយត្រូវអន្ទោល ទៅខាងនេះខាងនោះផង តាមចលនារបស់ខ្លួន មិនមានអ្នកណាទប់ទល់ បានទេ ព្រោះការប្រព្រឹត្តទៅនៃអាត្មន៍នោះអាស្រ័យដោយកម្មៈនៃខ្លួន បានប្រព្រឹត្តនៅក្នុងអតីតជាតិ ជាការផុតពីការត្រួតត្រាទាំងពួង និងការ កំណត់បានទៀតផង ។

១– តាមទ្រឹស្ដីទូទៅថា សត្វទាំងអស់ត្រូវកើតស្លាប់ចំនួន ៨៤ កប្បៈ ។

តាមការពិចារណាចំពោះគោលសារវត្ត នៃទស្សនវិជ្ជាលទ្ធិសាសនាព្រាហ្មណ៍ទាំង ៦ ប្រការខាងលើនេះ យើងឃើញថាមានចំណងសំខាន់មួយនៃលទ្ធិនេះ គឺការអប់រំមនុស្សទាំងឡាយឲ្យវៀរចាកអំពើល្អនិងអាក្រក់គ្រប់យ៉ាងព្រមទាំងការស្រឡាញ់ ការស្អប់ ការពេញចិត្ត ការមិនពេញចិត្ត និងឧបេក្ខាទៀតផង ។ កម្មៈនេះឯងហើយជាចំណងចងអាត្មន៑ដែលជ្រកពួនក្នុងកាយ កាលបើអាត្មនរួចចេញផុតហើយ (វិមុត្តិ) និងប្រាសចាកឥន្ទ្រិយជាគ្រឿងដឹងទាំងអស់ក្នុងអត្តភាពនៃបុគ្គលម្នាក់ៗហើយវិលចូលទៅកាន់អាត្មន៑ជាប្រក្រតីវិញពិត ។ ធម៌នេះកើតជា "ប្រមា ឬជាវិទ្យាពិត =គោលអវសានបំផុត" ដែលភាសាក្រិតថា (Summun bonun) នៃលទ្ធិសាសនាព្រាហ្មណ៍ ។ នេះហើយជាសិរីឋានពិតប្រាកដ គឺជាទីរលត់ហើយប្រាសចាកភពទាំងឡាយៈច្រើនអនេក ដោយការបានចូលរួម(សាយុជ្យ: នៅក្នុងបរមសត្វពិតតែមួយ ព្រោះព្រះអង្គបានរួចចាកគ្រឿងចងគឺកម្មៈ ព្រមទាំងមិនមានគុណគ្រប់ប្រការគឺថា "និគ្គុណហើយដែលហៅថា "សច–ចិទ–អានន្ទ"(១) ព្រោះទីមួយ ព្រះអង្គជាជីវិតបរិសុទ្ធ (មិនមានអ្វីត្រូវរស់ទៀត) ទីពីរ ព្រះអង្គជាគំនិតបរិសុទ្ធ (មិនមានអ្វីត្រូវគិតទៀតទេ) ទីបីព្រះអង្គជាសេចក្តីរីករាយបរិសុទ្ធ (មិនមានអ្វីត្រូវរីករាយតទៅទៀតទេ) ។

១– នេះជា "ត្រៃអង្គ" នៃទស្សនវិជ្ជាលទ្ធិសាសនាព្រាហ្មណ៍ ។

# ទំនៀមឲ្យឈ្មោះ

(តាមឯកសារក្រុមជំនុំទំនៀមទម្លាប់ខ្មែរ)

អ្នកស្រី ពេជ-សល់ រៀបរៀង

---

## សារបានរឿង


១- ទំនៀមឲ្យឈ្មោះចំពោះមនុស្សទូទៅ

២- អំពីនាមត្រកូល

៣- ទំនៀមប្ដូរឈ្មោះ ច្បាប់ព្រះពុទ្ធសាសនាទាក់ទងនឹងឈ្មោះ

៤- ការប្រើឈ្មោះមនុស្ស

ក) ការប្រើឈ្មោះក្នុងសិល្បធម៌

ខ) ការប្រើឈ្មោះក្នុងគ្រួសារ

៥- ក្បួនស្ដីអំពីការប្រើអក្សរឈ្មោះ

ក- ការឲ្យឈ្មោះវត្ថុនិងទីកន្លែងផ្សេងៗ

៦- ការឲ្យឈ្មោះចំពោះរបស់ប្រើប្រាស់

៧- ទំនៀមឲ្យឈ្មោះសត្វ

៨- ឈ្មោះសន្ទត់

៩- ឈ្មោះខ្មោច បិសាច ព្រាយ បងបត អារក្ស អ្នកតា

១០- បញ្ជាមរណនាម

១១- រឿងប្រាជ្ញចំពោះឈ្មោះ

# ទំនៀមឲ្យឈ្មោះ

តាមឯកសាររបស់ក្រុមទំនៀមទម្លាប់ខ្មែរ ដែលបានស្រាវជ្រាវឃើញថា ជនជាតិខ្មែរពីបុរាណកាល មានរបៀបឲ្យឈ្មោះច្រើនបែបច្រើនយ៉ាងណាស់ ដែលផ្អែកទៅលើជំនឿនិងទំនៀមទម្លាប់របស់អ្នកស្រុក ក្នុងភូមិផ្សេងៗក្នុងប្រទេស ហើយទំនៀមឲ្យឈ្មោះនោះទៀត ក៏មិនមែនចេះតែធ្វើដោយស្វាត់ៗទៅទេ គឺគេធ្វើដោយមានពិធីយ៉ាងទៀងទាត់ ហើយហ្មត់ចត់ផង ។ ទំនៀមនៃការឲ្យឈ្មោះនោះ គេធ្វើចំពោះមនុស្សទូទៅតាំងពីនៅក្មេងតូចដូចជាសម័យបច្ចុប្បន្ននេះដែរ ចំពោះសត្វចិញ្ចឹមខ្លះ ដូចជា ឆ្កែ ឆ្មា សេះ ដំរី ។ល។ ចំពោះរបស់ប្រើប្រាស់ ដូចជា ទូកងប្រណាំង កប៉ាល់ ។ល។ ចំពោះទីលំនៅឋាន ដូចជាវត្តអារាម ភូមិស្រុក។ល។ បើត្រឹមតែការឲ្យឈ្មោះនោះ ក៏វាមិនជាការប្លែកអ្វីពីសម័យសព្វថ្ងៃនេះទេ ប៉ុន្តែការដែលចម្លែក គួរឲ្យយើងចង់ដឹងនោះ គឺត្រង់ទំនៀមបុរាណមានក្បួនតម្រាឲ្យឈ្មោះ និងពិធីយ៉ាងប្រិតប្រៀន ល្អិតល្អន់ច្រើនណាស់ មិនមែនចេះតែឲ្យឈ្មោះទៅតាមមនោគតិរៀងខ្លួនងាយៗនោះឡើយ ខ្ញុំនឹងជូនសេចក្តីស្រាវជ្រាវដូចតទៅ :

# ១

## ទំនៀមឲ្យឈ្មោះចំពោះមនុស្សទូទៅ

មនុស្សគ្រប់រូប តែងតែមានឈ្មោះដែលត្រូវបានគេដាក់ឲ្យគាត់ពីតូច ៗ កាលពីជំនាន់ដើម មានទំនៀមនិងក្បួនខ្នាតដាក់ឈ្មោះឲ្យកូនផ្សេងៗគ្នាទៅតាមស្រុកភូមិ ហើយការឲ្យឈ្មោះនេះ គេច្រើនតែធ្វើនៅថ្ងៃបង្កក់ឆ្មបទម្លាក់ជើងក្រាន ៗ ពិធីនេះ តាមគម្ពីរបុរាណគេហៅថា ពិធីនាមមង្គលហាណមង្គល គឺជាពិធីដាក់ឈ្មោះឲ្យកូនតូចដែលទើបនឹងកើត ប៉ុន្តែតាមទម្លាប់ខ្មែរ គេហៅថាពិធីបង្កក់ឆ្មប (១) គឺជាពិធីដើម្បីជោគជ័យសិរីមង្គលដល់កូនតូច និង ជាឱកាសដាក់ឈ្មោះឲ្យកូននោះផង ជូនរង្វាន់ទាន់ទាតបគុណយាយមបផង ។ ពិធីនេះគេត្រូវធ្វើក្នុងពេលណាដែលទារកនោះបានអាយុ ៣ ឬ ៧ ថ្ងៃ (២) ៗ មុននឹងប្រារព្ធធ្វើ ម្ដាយឪពុកដែលបានយករណ្ដាប់មករៀបចំសព្វគ្រប់ហើយ ក៏ប្រមូលញាតិមិត្តឲ្យមកជួបជុំ ហើយយកទារកមកផ្ដេកនៅជិតនោះតាមសមគួរ រួចចាប់ផ្ដើមបើកពិធី ៗ ដំបូងមាតាបិតាចូលទៅចំពោះមុខយាយមបហើយលុតជង្គង់ក្រាបសំពះ សូមខមាទោសនឹងគាត់ គ្រប់ករណីដែលគាត់បានកាន់សាច់ប្រឡាក់ឈាមជួយសង្គ្រោះ ខ្លួនឲ្យផុតអំពីមហាភ័យដ៏ពន្ទឹកនោះ

---

១- ឯកសារទំនៀមទម្លាប់លេខ ៣៥.៤១០ ។ ២- កូនដំបូង គេច្រើនធ្វើនៅថ្ងៃទី ៣ ក្រោយថ្ងៃសម្រាល ។

ដោយហូរហៈសព្វគ្រប់ ព្រមទាំងនាំគ្នាយកប្រេងម្សៅមកលាបបាតដៃ យាយមីបដាបណ្ដើរ ៗ ផង ។ រួចហើយ ក៏លើកស្រូវពាខ្ចុ សំពត់អាវ និងប្រាក់កាសតាមសមគួរ ព្រមទាំងស្លាកពម្លាប បន្ថែម ដែលរៀបចំបម្រុងទុកជាស្រេចហើយនោះ ជូនគាត់ជាកិច្ចតបស្នងសងគុណផង ។ រីឯពួកញាតិមិត្រ ក៏ចាប់ផ្ដើមអុជទៀនធូបហើយសែនព្រេន រួចទើបយាយមីបយកអំបោះចងដៃឲ្យទារក និង មាតា យកកន្ត្រៃច្រឹបសក់ព្រៃកូននោះបីកន្ត្រៃ ដាក់ទៅក្នុងក្អមនោះ ជានិមិត្តរូបនៃការកម្ចាត់ចង្រៃ ហើយក៏រើសឈ្មោះណាមួយដាក់ឲ្យកូនទៅ ។

នៅស្រុកខ្លះគេឲ្យឈ្មោះកូនតាមថ្ងៃដែលវាកើតនោះ តាមលក្ខណៈសរីរៈរាងកាយនិងភេទរបស់វាផង ព្រោះមានក្បួនប្រាប់ថា "បើកូនកើតថ្ងៃចន្ទភេទជាស្រី ត្រូវដាក់ឈ្មោះដូច្នេះ ភេទជាប្រុស ត្រូវដាក់ឈ្មោះដូច្នោះ ។ល។" ក្បួនខ្លះមានពាក្យស្លោកភ្ជាប់ជាមួយផង ហើយអ្នកដែលដាក់ឈ្មោះឲ្យកូនត្រូវតែឲ្យសមតាមន័យនៃស្លោកនោះទៅ ដូចលោកឌួង ឌិច(១) បានដកស្រង់ពាក្យស្លោកពីក្បួនមួយនៅស្រុកលោកថា :

"បើកូនកើតឆ្នាំម្សាញ់ ខែភទ្របទ ថ្ងៃព្រហស្បតិ៍ ត្រូវលើតស់វែកយាយើ មានពាំបកាណតី កេស្ដុំធ្លាយខែក" ។

---

១- សមាជិករបស់ក្រុមខ្ញុំទៀបមួយ អតីតមេឃុំ ឃុំអង្គាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ តាមឯកសារលេខ ១០.០១៣ របស់ក្រុមជំនុំ ។

លោកប៉ាងខាត់ពន្យល់ទៀតថា :

បើកូនកើតត្រូវនឹងថ្ងៃ-ខែ-ឆ្នាំ ដូចពោលលើនេះ ត្រូវឱ្យឈ្មោះ "មាស ឬ "កែវ" តាមពាក្យស្លោកនោះ ។

នៅតំបន់ខ្លះ គេនិយមឱ្យឈ្មោះកូនតាមនាមឪពុកម្ដាយ ឧបមាថា ឪពុកឈ្មោះ ម៉ែន ម្ដាយឈ្មោះ សុខ បើមានកូនប្រុសឱ្យឈ្មោះ មុត មៀច ម៉ៅ ។ល។ បើមានកូនស្រី ឱ្យឈ្មោះ សន សាយ សុន សែម ។ល។ ដោយយកអក្សរដើមនៃនាមម្ដាយដែរ នេះជាការនិយមតាមទម្លាប់របស់គ្រួសារខ្លះទេ ប៉ុន្តែជាទម្លាប់មួយដែលគេនៅនិយមប្រើសព្វថ្ងៃហាក់ខ្ជាប់ខ្ជួននៅឡើយ ។

ចំណែកលោក កែវ-គុល ដែលជាសមាជិកក្រុមជំនុំទំនៀមទម្លាប់ដែរ បានឱ្យការណ៍ថា នៅស្រុកកំពង់ត្រាច (កំពត) អ្នកស្រុកដាក់ឈ្មោះឱ្យកូនចៅ ដោយយកឈ្មោះឆ្នាំដែលវាកើតមកគិត ព្រោះមានក្បួនមួយនិយាយថា :

១- កូនកើតឆ្នាំជូតប្រុស ត្រូវយកឈ្មោះតាមអក្សរ គងពម

- ស្រី -ដ- ឥឯករ

២- កូនកើតឆ្នាំឆ្លូវប្រុស -ដ- ចពលត

- ស្រី -ដ- កឆសឈផ

៣- កូនកើតឆ្នាំខាលប្រុស ត្រូវយកឈ្មោះតាមអក្សរ កគជឃ

\- ស្រី ដ- ដ្ឋសឈឡ

៤- កូនកើតឆ្នាំថោះប្រុស -ដ- កគងខប

\- ស្រី -ដ- សករផ

៥- កូនកើតឆ្នាំរោងប្រុស -ដ- ខពង

\- ស្រី .ដ. ខសធ

៦- កូនកើតឆ្នាំម្សាញ់ប្រុស -ដ- ងគមជ

\- ស្រី -ដ- វសផឡ

៧- កូនកើតឆ្នាំមមីប្រុស -ដ- កងញ

\- ស្រី -ដ- សវធ

៨- កូនកើតឆ្នាំមមែប្រុស .ដ. គងក

\- ស្រី ដ យធរ

៩- កូនកើតឆ្នាំវកប្រុស .ដ. ពរក

\- ស្រី -ដ- សធឈ

១០- កូនកើតឆ្នាំរកាប្រុស .ដ. គកវល

\- ស្រី .ដ. ផករ

១១- កូនកើតឆ្នាំចប្រុស -ដ- ងជរព

\- ស្រី -ដ- ខគសប

១២. កូនកើតឆ្នាំកុរប្រុស ត្រូវយកឈ្មោះតាមអក្សរ កង

– ស្រី .ដ. ផកឡេ

របៀបឲ្យឈ្មោះ តាមទំនៀមស្រុកដែលខ្ញុំពណ៌នាហើយ ខាងលើនេះ គឺមានគ្រួសារខ្លះនៅនិយមប្រើនៅឡើយដែរ ។

ចំណែកលោក សេក សែត នៅឃុំតាំងក្រសាំង ស្រុកសន្ទុក (កំពង់ធំ) ឲ្យការណ៍ថាអ្នកស្រុកនិយមឲ្យឈ្មោះកូនដោយគិតតាមឈ្មោះឆ្នាំដែរ ប៉ុន្តែមានកំណត់តាំងទុកជាដាច់ស្រេចដូច្នេះទៅវិញ ។

១. កូនប្រុសកើតឆ្នាំជូត ត្រូវឲ្យឈ្មោះ ព្រំ ព្រះ សុខ ស្រី

កូនស្រី – .ដ. ទេព ឯម ពុំ

២. កូនប្រុសកើតឆ្នាំឆ្លូវ .ដ. ទេព ទន ចន

កូនស្រី – .ដ. ទៃ អ៊ុន គង់

៣. កូនប្រុសកើតឆ្នាំខាល .ដ សួរ បាន សិទ្ធ ញាន

កូនស្រី – .ដ. ស៊ូរ យស់ ស ទេស

៤. កូនប្រុសកើតឆ្នាំថោះ ដ. គង់ កែស កែវ កាន

កូនស្រី – .ដ. គង់ ទេស ចន្ទ កែវ នន់

៥. កូនប្រុសកើតឆ្នាំរោង ដ. គុន អន អេង

កូនស្រី – .ដ. ម៉ា ពៅ កែស ចន្ទ

៦- កូនប្រុសកើតឆ្នាំម្សាញ់ ត្រូវឲ្យឈ្មោះ សុខ សូរ កែវ ញា

កូនស្រី — .ដ. គង់ រាជ ភន្លួ ដៃ

៧- កូនប្រុសកើតឆ្នាំមមី .ដ. រាជ គុណ ព្រំ

កូនស្រី — .ដ. សួស្តី មន ស្រី

៨- កូនប្រុសកើតឆ្នាំមមែ -ដ- ព្រំ ព្រាជ មាស

កូនស្រី — ដ. ម៉ា ទៃ បុស

៩- កូនប្រុសកើតឆ្នាំវក .ដ. ទេព ទុន ផា ប៊ុន

កូនស្រី — .ដ. ភនួ ទៃ មែ

១០- កូនប្រុសកើតឆ្នាំរកា .ដ. ស្បូរ ប៊ុន ផា ភនួ

កូនស្រី — .ដ. ប៉ុល រស់ យស់ ស៊ុន

១១- កូនប្រុសកើតឆ្នាំច .ដ. វែន តាវ ស្រី ព្រីង

កូនស្រី — .ដ. ឯម កែវ

១២- កូនប្រុសកើតឆ្នាំកុរ .ដ. អាន ភនួ សឹង គង់ រត្ន

កូនស្រី — .ដ. ភនួ អន គង់ ជាន ម៉ា

នៅក្នុងស្រុកជាដែលនេះ លោក ហេក-សែត បានឲ្យការណ៍បន្ថែមទៀតថែលថែរទៅជាតិតាមឈ្មោះថ្ងៃកំណើតទៅវិញគឺ :

បើកូនកើតថ្ងៃអាទិត្យ ឲ្យឈ្មោះ ទិត្យ បើកើតថ្ងៃច័ន្ទឲ្យឈ្មោះ ច័ន្ទ ប៉ុន្តែការឲ្យឈ្មោះកូនតាមឈ្មោះថ្ងៃនេះ តាមការសង្កេតឃើញរបស់ខ្ញុំ

ដូចជាកុំដែលឮមនុស្សណាឈ្មោះ "អង្គារ" ឬ "ព្រហស្បតិ៍" សោះ ឮត្រឹមតែឈ្មោះ ទិត ចន្ទ ពុធ សុក្រ សៅរ៍ ប៉ុណ្ណោះ ។ មិនមែនជាគ្មានកូនដែលកើតនៅថ្ងៃទាំងពីរនោះទេ ប៉ុន្តែដោយពិត គឺឈ្មោះថ្ងៃទាំងពីរនោះ មានស័ព្ទដូចជាប្រសើរហួសពេក បានជាគេមិននិយមយកមកដាក់ឈ្មោះឲ្យមនុស្ស ។ ដូច្នេះហើយទើបគេបង្វែរសេចក្ដីក្នុងក្បួននោះថា ត្រូវដាក់ឈ្មោះកូនយកតាមតួអក្សរនៃឈ្មោះថ្ងៃដែលវាកើតនោះទៅវិញ គឺថា :

| | | | | |
|---|---|---|---|---|
| កូនកើតថ្ងៃ | អាទិត្យ | ទោះស្រីក្ដីប្រុសក្ដី ត្រូវឲ្យឈ្មោះតាមតួអក្សរ | | ទ |
| " | ចន្ទ | " | .ដ. | ច |
| " | អង្គារ | " | .ដ. | អ |
| " | ពុធ | " | .ដ. | ព |
| " | ព្រហស្បតិ៍ | " | .ដ. | ហ |
| " | សុក្រ | " | .ដ. | ស |
| " | សៅរ៍ | " | .ដ. | ស |

គួរសំគាល់ថា ក្បួនទាំងអស់នេះ ជាក្បួនតម្រាផ្អែកទៅតាមហោរាសាស្ត្រ ហើយទោះជាមានគេក្រកុកឲ្យបានគង់វង្សនោះឡើយក្ដី ក៏អ្នកស្រុកឈប់និយមប្រើស្ទើរតែគ្រប់កន្លែងទៅហើយ ។

ដូចកាលម្ដាយឪពុកឲ្យឈ្មោះកូនប្រុសស្រីតាមលក្ខណៈសរីរៈរាងកាយ

របស់វាពីកំណើត ដូចជាកូននោះកើតឡើងខ្មៅជាងគេ ក៏ឲ្យឈ្មោះ "ម៉ៅ" បើកូនសម្បុរសណ្ដែកបាយ ឲ្យឈ្មោះ "សាឯម" ។ បើកូនកើតឡើងតូច ក្រៀចជាងកូនធម្មតា ឲ្យឈ្មោះ ក្ដឹច ក្រៀច ប៊ិច ប៉ុច តូច ជាដើម ។

ខ្មែរបុរាណ ពុំសូវហ៊ានឲ្យឈ្មោះកូនពីរោះ ៗ ដូចសព្វថ្ងៃនេះទេ ព្រោះគេជឿថា ឲ្យឈ្មោះកូនល្អពេក កូននោះទំនង "តាញ់ឈ្មោះ" (១) ដូច្នេះទើបរាស្ត្រខ្មែរបុរាណ ច្រើនមានឈ្មោះតែមួយម៉ាត់ ។ ដូចអធិប្បាយខាងលើស្រាប់ ហើយងាយហៅងាយចាំផង ។ មិនចំពោះតែប្រជារាស្ត្រសាមញ្ញប៉ុណ្ណោះទេ ដែលមានជំនឿយ៉ាងនេះ សូម្បីតែឥស្សរជននិងព្រះរាជវង្សានុវង្ស ក៏ជឿដូច្នេះដែរ យើងនៅចាំបានថា ឧត្តមជនពីសម័យបុរាណច្រើនមាននាមតែមួយម៉ាត់ៗ ដូចជា ឈុន ពេជ្រ ប៉ុន . . . . . . ។ល។ និងព្រះបរមនាមនៃព្រះមហាក្សត្រ ព្រមទាំងព្រះនាមរាជវង្សានុវង្សជាច្រើនទៀត ដូចជាព្រះអង្គឌួង ច័ន្ទ អន អុឹម អេង តន់ គឹម . . , . ។ល។

ហើយគួរចំណាំថា ចំពោះព្រះមហាក្សត្រដែលបានឡើងសោយរាជសម្បត្តិ ទើបមានថ្វាយព្រះនាមថ្មីសម្រាប់រាជ្យ ដូចជាព្រះ អង្គ-ឌួង ជាសម្ដេចព្រះ ហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គតង់ ជាព្រះបរមរាជា ព្រះអង្គអេងជាព្រះឧទ័យ ។ល។

---

១- ធ្វើឲ្យវិនាស ឬអន់ដោយសារឈ្មោះនោះ ។

អ្នកខ្លះយកឈ្មោះសត្វមកដាក់ជាឈ្មោះឲ្យកូនរបស់ខ្លួន(១) ទំនៀមយកឈ្មោះសត្វមកឲ្យឈ្មោះកូននេះ តាមការសង្កេតទៅឃើញថា ឈ្មោះខ្លះឲ្យទៅតាមចំណង់របស់ម្ដាយ ដែលកំពុងមានផ្ទៃពោះ ដូចជាកាលកូននោះនៅក្នុងផ្ទៃ ម្ដាយចង់បរិភោគមាន់ ខ្ចៅ ខ្យង ដល់កូននោះប្រសូតមក គេក៏ឲ្យឈ្មោះវាថា អាមាន់ អាខ្ចៅ អាខ្យងទៅ ៗ ខ្លះគេឲ្យឈ្មោះទៅតាមលក្ខណៈនិងចរិយារបស់វា ដូចជាកើតហើយ គេឃើញវាតូចពេក គេក៏ឲ្យឈ្មោះវាថាអាក្អាត់ឃើញបបូរមាត់វាក្រហមស្អាត គេក៏ឲ្យឈ្មោះវាថាអាសេក ឃើញចរិយាវាបែបធ្មឹងធ្មើយ គេឲ្យឈ្មោះអាគោ ៗលៗ ខ្លះទៀតគេឲ្យឈ្មោះទៅតាមការនឹកឃើញភ្លាម ៗ គ្មានគេទុកអ្វីជាមូលហេតុឲ្យជាក់ទេ ឬទាល់គំនិតនឹករកឈ្មោះអ្វីមិនឃើញក៏ដាក់ឈ្មោះឲ្យជួរ ៗ ទៅ ៗ ប៉ុន្តែការឲ្យឈ្មោះទាំងនេះ ពុំឃើញមានកាន់ត្រណម ឬគោរពអ្វីមួយចំពោះសត្វទាំងនោះទេ ។ ឯឈ្មោះសត្វទៀត គេក៏មិនបេះតែយកគ្រប់សត្វដែរ សត្វដែលធ្លាប់យកមកឲ្យជាឈ្មោះមនុស្សគឺ :

មាន់ ជ្រឹង សេក ក្ងាន ជ្រូក ក្អាត់ ក្រួច ខ្ចៅ ខ្យង ចាប ព្រាប ក្ដាន់ គោ ។ល។

ចំណែកមនុស្សដែលមានឈ្មោះដូចដើមឈើ ដូង ព្រីង ឈូក

---

១. របៀបនេះ នៅមានប្រើសព្វថ្ងៃនៅឡើយ ។

ឡោក ទេព មន្សែត សុភ័ ឯម ក្រវ៉ាន់ រដ្ឋល កុឡាប ប៊ុន ម៉ិះ ។ល។ ក៏មានច្រើន ហើយក៏ពុំឃើញមានកាន់ត្រណមអ្វី ចំពោះដើមឈើដែលជាឈ្មោះខ្លះនោះដែរ ។

ក្នុងចំណោមឈ្មោះ ដែលខ្ញុំបានរាប់ខ្លះ ។ ក្នុងភាពង៏ខាងដើមរួចមក ហើយនោះ ឈ្មោះខ្លះមានសម្លស្រស័ព្ទសមជាឈ្មោះស្ត្រី ឈ្មោះខ្លះទៀត មានសម្លស្រស័ព្ទសមជាឈ្មោះប្រុស ។ នេះចំពោះតែឈ្មោះដែលជាពាក្យខ្មែរសុទ្ធ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏ពុំមានក្បួនកំណត់ជាដាច់ខាតថា ឈ្មោះដូច្នេះត្រូវដាក់ឲ្យបានតែកូនប្រុស ឈ្មោះដូច្នោះត្រូវដាក់ឲ្យបានតែកូនស្រីឡើយ ។ យ៉ាងនេះហើយទើបស្រីក្តី ប្រុសក្តី អាចដាក់ឈ្មោះថា

កង សុន កែម ស៊ិន សុខ សៅរ៍ សាន្ត សន ស៊ុំ វ៉ែន នាង ឡុង រស់ ឡាយ ចន្ទ ផន យ៉ែម យុត ខន ស៊ីប ទួន ។ល។ បានដូចគ្នាទាំងអស់ ។

មានឈ្មោះខ្លះ អ្នកស្រុកមិននិយមដាក់ជាឈ្មោះឲ្យស្រីទេ ដូចជា ជ័យ បុរ មាន សឿង កុយ គ្រៀល គោត សេក គយ ។ល។ គេច្រើនតែយកឈ្មោះផ្កាដាក់ឲ្យស្រី ដូចជាម្លិះ ក្តាំងផា ស្បៃរឿង មារតី ។ល។

ជាតិបរទេសខ្លះ និយមយកឈ្មោះជីតាជីដូនក្នុងគ្រួសារគេ ដែល

មានគុណសម្បត្តិល្អ ឬ មានអាយុវែងមកដាក់ឲ្យកូន ដើម្បីឲ្យកូននោះប្រកបគុណសម្បត្តិល្អដូចអ្នកនោះ ឬ ដើម្បីឲ្យមនុស្សចាស់នោះសប្បាយចិត្ត ដោយឃើញគេហៅឈ្មោះខ្លួនទុក ។ ឯចំណែកជនជាតិខ្មែរពុំមានទម្លាប់ធ្វើដូច្នេះទេ ហើយថែមទាំង បើដូនជាមានគេណាមួយមានឈ្មោះដូចឈ្មោះមនុស្សចាស់ក្នុងគ្រួសារ គេហៅបញ្ចៀស ដើម្បីគោរពដល់ចាស់នោះទៀតផង ព្រោះភាសាខ្មែរ តែកាលណាគេហៅក្មេង ៗ គេប្រើពាក្យថា អា ឬ មេ ដែលជាពាក្យមិនសមរម្យដល់ចាស់ហើយអាចធ្វើឲ្យមនុស្សចាស់អន់ចិត្តផង ។

ចំណែកកូនចៅ៖ គេច្រើនឲ្យឈ្មោះកូនតួអក្សរជាមួយគ្នា ឬ ជាពាក្យសទិសសព្ទ ដូចជា :

សុខ-សែម ឬ សុខ-ជា

ណុប-ណោម សារ៉េ-សារឿន ។ល។

ឥឡូវនេះ ការយល់ថាឈ្មោះល្អនាំឲ្យជាក់ខ្លួននោះ ប្រែជាសាបសូន្យស្ទើរតែអស់ទៅហើយ ។ អ្នកស្រុកខ្លះទៅ ជាពិសេសគឺអ្នកនៅក្រុង ចូលចិត្តឲ្យឈ្មោះកូនជាភាសាបាលី ហើយឲ្យមានន័យល្អតាមគោលបំណងរបស់ខ្លួនផងដូចជា :

ធនី វិចិត្រ កុសល បណ្ណា ។ល។

ការប្រើឈ្មោះជាភាសាបាលីនេះ គេអាចសម្គាល់បានថាឈ្មោះបែបនេះសម្រាប់ប្រុស ឈ្មោះបែបនេះសម្រាប់ស្រី ព្រោះភាសាបាលីចែកពាក្យជាឥត្ថីលិង្គ (ញី) និងជាបុំលិង្គ (ឈ្មោល) តែទោះជាយ៉ាងនេះក៏ដោយ នៅតែមានអ្នកប្រើច្រឡំគ្នា ព្រោះតែការមិនយល់ និងការមិនអើពើរ៉ះគេខុសត្រូវជាច្រើនដែរ ។

ខាងភាសាបាលី ស្រីគេច្រើនយកឈ្មោះណា ដែលមានសំឡេងស្រៈ អា អិ អី នៅចុងសព្ទ ដូចជា :

អមរា ពេហានី កុសិនី

ប្រុសច្រើនប្រើឈ្មោះដែលមាន ស្រៈ អាក់ អុ អូ អោ ដូចជា :

វណ្ណៈ, សុកៈ នេរុ, វិទូ, ខេមរោ ។ល។

ប៉ុន្តែទោះជាគេសម្គាល់បានខ្លះយ៉ាងនេះក្តី គេក៏មិនអាចរៀបចំឈ្មោះឲ្យទៅជាច្បាប់ទៀងទាត់ សម្រាប់ឲ្យដាក់ស្រីឲ្យប្រុសបានឡើយ ។

អំពីនាមត្រកូល :—

ខ្មែរបុរាណមិនប្រើនាមត្រកូល ភ្ជាប់ពីមុខនាមខ្លួនដូចសម័យឥឡូវនេះទេ និងមិនប្រើឈ្មោះសែស្រឡាយដូចជាតិ ចិន យួនផង បើចង់បញ្ជាក់ថាឈ្មោះ សុខ ឬ សៅ ជាអ្នកណា គេច្រើន ប្រើសេចក្តីបន្ថែមថា "ជាកូនឈ្មោះនោះ" សូម្បីតែឈ្មោះដែលប្រាប់ឲ្យដឹងថា ឈ្មោះនេះជាកូន

ទីប៉ុនាន ដូច ចិន យួន គឺមិនមានប្រើដែរ មានតែឈ្មោះ " ពៅ ប៊ុច " ទេ ដែលសម្រាប់ដាក់ឲ្យកូនក្រោយគេបំផុតក្នុងគ្រួសារ ។

ការប្រើនាមត្រកូលភ្ជាប់នឹងនាមខ្លួន ទើបតែនឹងមានប្រើជាផ្លូវការ នៅពេលដែលប្រទេសខ្មែរ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់បារាំងសែស នេះទេ ដោយខ្មែរយកលំនាំច្បាប់សម្រាប់ស្រុកតាមបារាំង ទើបបញ្ញត្តិ ឲ្យកូនអ្នករាជការ និងមនុស្សប្រុសស្រី ដល់អាយុត្រូវបង់ពន្ធខ្លួនជូន រាជការមាននាមត្រកូលនឹងនាមខ្លួន ក្នុងប័ណ្ណសម្គាល់ខ្លួនរៀង ១ ខ្លួន ។

ចំណែកខាងវង្សក្សត្រ ចាប់តាំងពីរជ្ជកាល នៃស្ដេច នរោត្ដម និង ស្ដេច ស៊ីសុវត្ថិ ដែលជាព្រះឱរសនៃព្រះបាទ អង្គ-ឌួង មកព្រះនាមនៃ ក្សត្រទាំងពីរអង្គនេះ នៅជានាមត្រកូលពីរមែកយ៉ាងធំ ក្នុងប្រទេស កម្ពុជា ។ ឯពួកបណ្ដាជន រាស្ត្រសាមញ្ញទូទៅពុំមានប្រើសោះដូចចិន យួនទេ ។

នៅខាងដែនកម្ពុជាក្រោម (កូសាំងស៊ីន) ចាប់តាំងពីអាណាខេត្រ ទាំងនេះ ស្ថិតនៅក្រោមអាណាព្យាបាលយួន យួនបានឲ្យនាមត្រកូល ដល់បណ្ដាជនខ្មែរក្រោមដោយពួកដោយក្រុម ដើម្បីឲ្យងាយសម្គាល់ ហេតុដូច្នេះហើយបានជាពួកខ្មែរក្រោម មាននាមត្រកូលសម្គាល់ស្រុក កំណើតរបស់ខ្លួនជាប់ដល់សព្វថ្ងៃ :

<u>ពួកអ្នកនៅខេត្តចូវដុក</u> : គេឲ្យនាមត្រកូល ចៅ " ឌុ-ចៅ ទូច ,,

ហៅ-យឹម ហៅ-ឯម . . . . . . ។ល។

ពួកអ្នកនៅខាងព្រះត្រពាំង ឃ្លាំង ពោធិ៍សាត់ ព្រែកឫស្សី គេឲ្យនាមត្រកូល ចាប់ សឹង ឡាំ (ឧ-ឡាំ-ឯម ចាប់-ឈួន ចាប់-ចន្ទ សឹង-អ៊ិញ ។ល។)

ពួកអ្នកនៅក្រមួនស និង បារាជ គេឲ្យនាមត្រកូលថា: ទ្រី ង៉ូ ម៉ាយ ដាញ់ លីវ (ឧ-ទ្រី-បាន ង៉ូ-លាន ម៉ាយ-សុវណ្ណ ដាញ់-អ៊ុន, លីវ-ភី) ។

តែសូមកត់សម្គាល់ថា បើនាមត្រកូលទាំងនោះមានពាក្យមួយម៉ាត់ទៀត នៅញែកកណ្ដាលគឺអ្នកនោះ មិនមែនខ្មែរសុទ្ធទេ ច្រើនជាខ្មែរកាត់ចិន ឬ កាត់យួន (ឧ.ទ្រី-ហួរឡាំ, ង៉ូ-តានសី ។

២

ទំនៀមប្ដូរឈ្មោះ :–

ក្រោយអំពីថ្ងៃសម្រាលប៉ុន្មានថ្ងៃនោះ ទារកក៏បានទទួលឈ្មោះអំពីមាតា-បិតា ជួប ឬ គ្រូបាធ្យាយ ដូចបានរៀបរាប់ពីខាងដើមរួចហើយ ប៉ុន្តែលុះយូរៗតទៅមក កូននោះចេះតែឈឺ ឬ ចេះតែស្លូមរើងរៃ នាំឲ្យរវាងដល់គ្រួសារជាញឹកញយពេក តាមទំនៀមខ្មែរបុរាណ គេថាត្រូវផ្លាស់ឈ្មោះឲ្យវា ព្រោះឈ្មោះចាស់មិនប្រកប ។

ការប្តូរឈ្មោះនេះ បើគ្រាន់តែប្រសាត់ៗ ក៏ហាក់ដូចជាមិនសូវសក្តិសិទ្ធិ ។ ដូច្នេះទើបមានពិធីផ្លាស់ឈ្មោះជាការចាំបាច់ ដែលជាប់ជាទំនៀមទម្លាប់មួយ និង ជាជំនឿយ៉ាងមាំរបស់អ្នកស្រុកផង ។ ប៉ុន្តែសព្វថ្ងៃនេះ ដោយជនជាតិខ្មែរភាគច្រើន ផ្តេកជំនឿទៅលើពេទ្យខ្លាំងម៉្លោះហើយ ទំនៀមបុរាណក៏ត្រូវប្រួតកាត់ពោល នៅសល់តែការឧបកិច្ចបន្តិចបន្តួចគ្រាន់តែជាលេបប៉ុណ្ណោះ ។

តាមទំនៀមបុរាណ បើក្មេងណាមួយចេះតែឈឺច្រើនពេក ឪពុកម្តាយ មីង មា តែងរកគ្រូហោរទស្សន៍ទាយមើល តើកូននោះខុសអំពីអ្វី ? បើមើលទៅពុំឃើញមានបុព្វហេតុអ្វីមួយ បណ្តាលឲ្យឈឺពីរ៉ៃនោះទេ គេជឿជាក់ថាត្រូវផ្លាស់ឈ្មោះចាស់ចេញ ព្រោះឈ្មោះនោះមិនប្រកប ។ គេរកគ្រូឲ្យរើសរកថ្ងៃជាមង្គល ដើម្បីធ្វើពិធីផ្លាស់ឈ្មោះឲ្យកូននោះ តាមក្បួនតម្រាហោរាសាស្ត្រ ។

តាមធម្មតា គេច្រើនរកព្រះសង្ឃ ឬ តាព្រឹទ្ធាចារ្យ ឲ្យដាក់ឈ្មោះថ្មីដល់កូននោះ ។ ពុំនោះទេ គេអាចសរសេរឈ្មោះដែលគេស្រឡាញ់មួយជាស្លាក ដាក់ទីងផើងពាន អុជទៀនធូប សម្បូងសម្រូង ហើយឲ្យម្តាយក្មេងនោះចាប់គ្រប់បីដង ។ បើលើកទី ៣ នោះចាប់ចំឈ្មោះអ្វី គេក៏កំណត់ដាក់ឈ្មោះនោះឲ្យកូននោះទៅ នេះជារបៀបទី ១ ។

ទំនៀមម្យ៉ាងទៀត គេរកមនុស្សចាស់ទុំពីរនាក់ប្តីប្រពន្ធ ដែលមិន

ការើសកូន ឲ្យទៅសុំកូននោះនៅត្រង់ផ្លូវបំបែក ។ ទំនៀមនេះគេធ្វើដូច្នេះ គឺកាលបើដល់ថ្ងៃសន្មតនឹងដល់ពេលកំណត់ហើយ ម្ដាយពរកូនដែលចេះ តែពងើប្រើននោះ ទៅចាំនៅផ្លូវត្រឡែងកែង ។ ជនចាស់ពីររូបដែល ពោលមកហើយ ក៏ដើរមកដល់ ហើយធ្វើកិច្ចហៅសុំកូនកូននោះ ។ ម្ដាយក្មេងត្រូវស្រុះចិត្តឲ្យ ប៉ុន្តែមនុស្សចាស់ ។ នោះ ត្រូវពោលបន្ថែមថា ខ្ញុំចាស់ ។ ហើយ រកទឹកដោះនឹងបំបៅកូននាងនេះពុំបានទេ បើដូច្នេះខ្ញុំ ទាំងពីរនាក់ សុំជួលនាងជាម្ដាយពីដើមស្រាប់ ឲ្យថែរក្សាជាមេដោះ ទំរាំ កូននោះលែងបៅ ថាហើយអ្នកសុំក៏ទទួលកូនពរយកទៅផ្ទះខ្លួន ហើយ រៀបបាយ ១ ស្ពក សែនព្រេនបងថៃទទួលកូន ព្រមទាំងឲ្យឈ្មោះជាថ្មី រួច ឲ្យលុយកាក់សំពត់អាវ ជាបំណាច់ទឹកដោះដល់អ្នកស៊ីឈ្នួលរក្សាកូន[1] ។

របៀបម្យ៉ាងទៀត គេនិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត ពីល្ងាច ព្រឹក ឡើងនិមន្តព្រះសង្ឃទទួលភត្ត រួចគេរៀបសំពត់អាវធ្វើងស្លាទិងពានដាក់ ក្រាសកញ្ចក់ប្រេងម្សៅ ហើយធ្វើកិច្ចប្រគេនកូននោះផ្ដាច់ទៅព្រះសង្ឃ[2] ដោយបញ្ជាក់ថា ខ្ញុំចិញ្ចឹមកូននោះមិនប្រកបសោះ ចេះតែឈឺ នាំឲ្យ រវល់រកប្រកបការងារអ្វីមិនបាន ។ ព្រះសង្ឃក៏ធ្វើកិច្ចជាទទួលមែន ។ ហើយដាក់ឈ្មោះថ្មីឲ្យកូននោះថា “ជា” ឬ “សុខ” ទៅវិញ ។ រួចលោកសុំផ្ញើកូននោះនឹងម្ដាយរបៀបដូចខាងលើនោះដែរ ។ បន្ទាប់មក

---

១) សោហ៊ុយដែលចាយក្នុងពិធីទាំងប៉ុន្មានត្រូវម្ដាយរបស់កូននោះចេញទាំងអស់ ។

២) គេច្រើនរកព្រះសង្ឃចាស់ទុំ ដើម្បីបំពេញកិច្ចនោះ ។

ទើបលោកសូត្រធម៌លោសទឹក លើកូននោះ ដើម្បីរំដោះចង្រៃទិនគ្រោះ កាចទាំងឡាយ ។

ដូនកាលក្រោយអំពីការឧបកិច្ចនោះមក ក្មេងនោះក៏បានសេចក្តី សុខដូចបំណងមែន ។

ការធ្វើខាងលើនេះ ប្រហែលគ្នានឹងរបៀបបែងការសេកូនក្មេងដែរ តែរបៀបនេះ ច្រើនធ្វើចំពោះតែអ្នកណាដែលមានកូនពុំគង់ ។

ពិធីបែងការសេនេះ តាមរបៀបស្រុកខ្ញុំ ត្រូវឲ្យមានរៀបចំបង្អែម ចម្អាប ញាំក្ដា ដាក់កន្ទោង តម្កល់លើតែមួយ ដែលមានដោតផ្កាកំទៀន ធូប សម្រាប់បូជាដល់ខ្មោចព្រាយបិសាចផង ។ ជាមួយគ្នានេះ គេរៀប បាយព្រលឹង គឺពូតបាយដាក់ក្នុងកន្ទោងស្លឹកចេកដាក់ក្នុងផ្តិល ហើយយក ក្រមាមួយផ្ទាយជារង្វេលព័ទ្ធជុំវិញកន្ទោងបាយព្រលឹងនោះ ព្រមទាំងមាន ដោតទៀន ១ និងធូប ៣ សរសៃផង ។ វត្ថុនេះជាគ្រឿងឧបរូកិច្ចហៅ ព្រលឹង ។

លុះរៀបចំស្រេចហើយ លោកគ្រូធ្វើពិធីសែនពែបញ្ជូនទៅកាន់ទិស ដែលក្បួនតម្រាកំណត់ឲ្យយកចេញទៅតាមក្បាំងថ្ងៃ ។ គេយកតែទៅដាក់ ត្រង់កន្លែងមួយសមគួរ ប៉ុន្តែគេត្រូវនាំយកបាយព្រលឹងត្រឡប់មកវិញ ។ លុះមកដល់ជើងជណ្តើរ អ្នកកាន់បាយព្រលឹងយកមកវិញនោះ គ្រូស្រែក សួរទៅអ្នកនៅខាងលើផ្ទះថា :

-អ្នកអើយ តើមានអ្នកណាបាត់ព្រលឹងទេ? ត្បិតខ្ញុំរើសបានព្រលឹង ឈ្មោះ “. . . .”

អ្នកនៅលើផ្ទះឆ្លើយជាសុំទិញ តថ្លៃគ្នាតាំងពីថ្លៃមួយចំហៀងនគរធ្លាក់ចុះរហូតមកត្រឹមទឹករលក ១ កែវ (១) ។ នៅពេលនោះ ម្តាយត្រូវលើកកូនបី លោកគ្រូកាន់ម្ជុល ១ សន្ទឹកហុចខាងក្នុយទៅឲ្យម្តាយកាន់ ហើយ លោកឧបកិច្ចសួរ គម្រប់ ៣ ដង ថា ៖

-ដាច់ឬមិនដាច់?

គេត្រូវឆ្លើយថា “ ដាច់ ” គ្រប់ទាំង ៣ ដង ហើយលោកគ្រូក៏ទាញផ្តាច់ស្ទឹកម្ជុលនោះជាពីរទៅ ។ ម្តាយត្រូវប្រគេនកូននោះទៅលោក ហើយលោកសុំផ្ញើនឹងម្តាយវិញដូចរបៀបមុនដែរ ។ ឯគ្រឿងបរិក្ខារឯទៀត មានក្រាស កញ្ចក់ សំពត់ អាវ ជាដើម ម្តាយត្រូវយកប្រាក់ទៅលោះអំពីលោកមកវិញ ។

អ្នកស្រុកខ្លះ ដើម្បីជៀសវាងការរវល់ច្រើន គេគ្រាន់តែរៀបរណ្តាប់សែនបន្តិចបន្តួចដល់អ្នកតាម្ចាស់ស្រុក ដើម្បីធ្វើពិធីប៉ូលប្រណាក រកឈ្មោះថ្មីឲ្យកូន ។ របៀបនេះ គេចងប្រណាកបន្ទាន់នៅចុងខ្សែអំបោះមួយសរសៃ ហើយគេបោះឈ្មោះដែលគេនឹកឃើញ ចង់ដាក់ឲ្យកូននោះ មួយ

---

១) ពាក្យអវក្សថា ប្រហ ។

មង្គល ៗ បើប្រផ្នូលហៅឲ្យសញ្ញាលើឈ្មោះណា គេយកឈ្មោះនោះដាក់ឲ្យកូនទៅ ។

របៀបតាំងឈ្មោះខាងលើនេះ ជារបៀបទាក់ទងដោយត្រង់ទៅលើជំនឿរបស់អ្នកស្រុកដែលគេយល់ថា ឈ្មោះនាំហ្នឹងកប្រកប ដូច្នេះហើយទើបយើងសង្កេតឃើញ ឬចំណាំបានថា ចំពោះអ្នកដែលមានឈ្មោះថា គង់ សុខ ជា នៅ រស់ គប អ្នកនោះពីក្មេង ច្រើនតែឈឺ ឬកើតក្នុងត្រកូលអាសើសកូន ទើបគេឲ្យឈ្មោះដូច្នោះ ដើម្បីឲ្យបានប្រកបតាមឈ្មោះ ។

<u>ច្បាប់ព្រះពុទ្ធសាសនាទាក់ទងនឹងឈ្មោះ</u>

នៅពេលដែលជនណាមួយ បានចូលទៅសុំបួសក្នុងព្រះពុទ្ធសាសនាហើយឧបជ្ឈាយ៍ត្រូវដាក់ឈ្មោះថ្មី ១ ទៀតឲ្យជាភាសាបាលី ដែលជានាមបញ្ញត្តិសម្រាប់កេរបព្វជិត ដើម្បីឲ្យងាយស្រួលក្នុងកិច្ចផ្សេង ៗ របស់សង្ឃ ដូចជាឲ្យឈ្មោះថា : ពុទ្ធថេរ ធម្មថេរ ពុទ្ធបញ្ញោ ។ល។ ប៉ុន្តែនៅពេលហៅគ្នាជាធម្មតា បើលោកអង្គនោះព្រះនាម សុខ ឬ ទិត្យ គេក៏នៅតែហៅថា លោកសុខ លោកទិត្យ ដូចប្រក្រតីដើម មិនចាំបាច់យកនាមបាលីនោះមកប្រើហៅគ្នាទេ ។

ព្រះមហាសុមេធាធិបតី ជួន-ណាត គណៈមហានិកាយ បានរៀបរៀងសៀវភៅមួយ ហៅថា « នាមបញ្ញត្តិ » សម្រាប់បព្វជិតពុទ្ធសាសនិក ៗ ត្រៀតកម្មវាចាក្នុងវេជ្ជកម្មទាំងពួង ក្នុងកិច្ចព្រះពុទ្ធសាសនា

សុទ្ធតែប្រើជាភាសាបាលីទាំងអស់ នឹងយកនាមជាភាសាជាតិដាក់បញ្ចូល ពុំកើត ៗ ការឲ្យនាមបព្វជិតជាភារៈលើឧបជ្ឈាយ៍ ប៉ុន្តែមានឧបជ្ឈាយ៍ខ្លះ ពុំសូវយល់ភាសាបាលី ច្រើនតែឲ្យនាមពុំសូវសម នឹងពុំសូវត្រឹមត្រូវតាមវេយ្យាករណ៍បាលីផង ទើបព្រះមហាសុមេធាធិបតីរៀបចំជាក្បួននេះឡើង ដើម្បីងាយ ក្នុងវិធីឲ្យនាម ៗ

## ៣

ការប្រើឈ្មោះមនុស្ស

តាមប្រពៃណីជាតិខ្មែរ កាលបើនឹងហៅគ្នា គេតែងយកឈ្មោះរៀងខ្លួនជាការសំខាន់ ប៉ុន្តែការហៅឈ្មោះគ្នានេះ មានខ្លះក៏ជាការគួរសម ខ្លះទៀតក៏ជាការខុសឆ្គង ពុំគួរសមទៅវិញ ៗ ចំពោះការហៅចំឈ្មោះគ្នា នៅទីកំបាំងមុខពីម្ចាស់ឈ្មោះនោះ យើងមិនបាច់លើកមកនិយាយទេ ព្រោះតែកាលណានៅឆ្ងាយពីត្រចៀកគេហើយ យើងចង់ហៅចំឈ្មោះគេក្តី មិនចំក្តី ក៏មិនជាការទាស់អ្វីទេ ដោយហេតុថា ពុំគ្មានការគិតក្រែងពីរឿងគួរសម ឬមិនគួរអ្វីទេ ៗ ប៉ុន្តែការហៅគ្នានៅចំពោះមុខម្ចាស់ឈ្មោះវិញ ប្រពៃណីខ្មែរ មានទម្លាប់ដូច្នេះ មនុស្សដែលមានឋានៈប៉ុនគ្នានឹងយើង ចុះមកក្រោម ឬនៅក្រោមជាងយើង យើងអាច

ហៅចំឈ្មោះក្នុងទីចំពោះមុខបានខ្លះ ប្រសិនជាយើងទុកចិត្តមនុស្សនោះ ថាជាមនុស្សស្និទ្ធស្នាលនឹងយើង ប៉ុន្តែបើមនុស្សនោះមិនសូវជាស្និទ្ធស្នាលនឹងយើងទេ ការហៅចំឈ្មោះនៅចំពោះមុខមនុស្សនោះក៏មិនគួរសមដែរ ពីព្រោះក្រែងមនុស្សប្រកាន់ថា យើងចាប់មើលងាយគេ ៗ ចំណែកមនុស្សដែលមានឋានៈខ្ពស់ជាងយើង ឬចាស់ជាងយើង ទំនៀមខ្មែរ ច្រើនមិនឲ្យហៅចំឈ្មោះក្នុងទីចំពោះមុខគេទេ ព្រោះគេសន្មតថា ជាការឆ្គងពេកណាស់ ៗ ដូច្នេះ ដើម្បីនឹងឲ្យមានការសមគួរដែលប្រពៃណីចាត់ថា ជាការត្រឹមត្រូវក្នុងការបម្រើប្រើឈ្មោះហៅគេគ្នាក្នុងទីចំពោះមុខនោះ គេត្រូវយកសព្ទនាមគឺនាមសម្រាប់ប្រើហៅជំនួសឈ្មោះទៀងទាត់មកប្រើ ដូចជា លោក អ្នក នាង ឯង គេប្រស្ដែង ព្រះអង្គ . . . . . ឬពាក្យចង្អុលលំដាប់ថ្នាក់វ័យដូចជា អូន បង ក្មួយ មីង មា យាយតាជាដើម ដែលអាចឲ្យយើងហៅតាម ថ្នាក់វ័យ ថ្នាក់គុណសម្បត្តិនិងកិត្តិយសរបស់គេ ៗ ប៉ុន្តែពាក្យខ្លះដូចជា អា ហង ប្រស្ដែង . . . . . ទាំងនេះ សម័យបច្ចុប្បន្ន គេនាំគ្នាខ្មាប់ឈប់ហៅគ្នាជាធម្មតាច្រើនណាស់ទៅហើយ ទោះជាចំពោះអ្នកអន់ខ្សោយជាងយើងយ៉ាងណាក៏ដោយ ព្រោះគេយល់ថា ពាក្យគ្មានការគួរសមមិនប្រកបដោយសុជីវធម៌ទាល់តែសោះ ។

ការប្រើឈ្មោះអ្នកគ្នានោះ តាមទំនៀមខ្មែរគេកំណត់ដូច្នេះ :

ចំពោះអ្នកមានឋានន្តរសក្តិ ខ្មែរមិននិយមហៅចំឈ្មោះនៅចំពោះមុខសាមីខ្លួនទេ ។ បើចង់និយាយទៅកាន់អ្នកនោះ គេត្រូវហៅតាមឋារសក្តិ ទោះជាអ្នកធំនិយាយទៅកាន់អ្នកតូចក្តី អ្នកតូចនិយាយទៅកាន់អ្នកធំក្តី ដូចយើងធ្លាប់បានឮជារឿយៗ មកហើយ នៅពេលដែលលោកនាយរដ្ឋមន្ត្រីមានប្រសាសន៍ទៅកាន់មន្ត្រីណាមួយ ផ្ទាល់មាត់ដូចជាលោកចៅហ្វាយខេត្ត លោកចៅហ្វាយស្រុក ឬ លោកមេឃុំណាមួយ លោកតែងហៅថា "លោកចៅហ្វាយខេត្ត . . . លោកចៅហ្វាយស្រុក លោកមេឃុំ ។ បើចង់ឲ្យច្បាស់ណាស់ទៅទៀត ទើបលោកចេញឈ្មោះចំថាលោកនេះ លោកនោះ ។ បើជននោះពុំមានឋានៈអ្វីជាសម្គាល់ទេ ក៏ហៅថា លោក ៗ ខេ ៗ ទៅ ។

ចំណែកស្ត្រី បើអ្នកនោះជាភរិយារដ្ឋមន្ត្រី ត្រូវហៅថាលោកជំទាវ ឬលោកស្រី "តាមថ្នាក់" ។ ចំពោះជនសាមញ្ញវិញ បើចាស់ជាង គួរហៅថា "អ្នកបង" ឬ "អ្នក" ទទេក៏បាន បើក្មេងជាង គួរហៅថា "នាង" ឬ "អ្នក" ក៏បាន ។ ប៉ុន្តែពាក្យ "នាង" អាចប្រើបានទូលាយណាស់ ព្រោះក្មេងប្រុសក៏គេហៅថា "នាង" បានដែរ ។ អ្នកខ្លះហៅថែមពាក្យថា "អានាង" ឬ "មេនាង" ដើម្បីប្រាប់ភេទផង ។ ពាក្យថា "នាង" ប្រើហៅ ក្មេងស្រីឬប្រុស តាំងពីក្មេងតូចរហូតដល់វ័យ

ក្រមុំកំឡោះ ប៉ុន្តែប្រើបានចំពោះតែចាស់និយាយទៅកេក្មេង ៗ ពាក្យនេះ និយាយនៅចំពោះមុខមនុស្សក៏ប្រើបាន នៅកំបាំងមុខក៏ប្រើបាន ដូចគេតែងនិយាយថា "នាងគ្រូ" បើនិយាយចំពោះមុខ ឬ និយាយអំពីស្រីម្នាក់ធ្វើគ្រូបង្រៀន ៗ ប៉ុន្តែគេត្រូវ បន្ថែមឈ្មោះថានាងគ្រូ នេះ នាងគ្រូនោះ ទៅតាមឈ្មោះដែលគេនិយាយ ៗ

ចំពោះអ្នកស្និទ្ធស្នាលនឹងគ្នា ហើយអាយុស្របាលគ្នាទៀត ទោះជាស្រីក្តី ប្រុសក្តី គេអាចហៅឈ្មោះគ្នាទៅវិញទៅមកបាន ៗ តែបើឲ្យគួរសមវិញ ស្និទ្ធស្នាលយ៉ាងណាក៏ដោយ គេច្រើននិយមហៅតាមវ័យរបស់មនុស្ស គឺថា បើអ្នកនោះបងក៏ហៅបងទៅ បើប្អូនក៏ហៅប្អូនទៅ ដូចជានិយាយថា បងទៅណា? ប្អូនធ្វើអ្វីហ្នឹង? ។ល។

នៅស្រុកខ្លះ មានស្រុកសណ្តាន់ (កំពង់ធំ) ជាដើម គេនិយមហៅមនុស្សចាស់ ៗ ថា "លោកឪ" "លោកម៉ែ" ។ បើនៅកំបាំងមុខ គេអាចហៅចំឈ្មោះបាន ប៉ុន្តែទោះជាយ៉ាងណា ក៏គេនៅតែគោរពចំពោះវ័យ ឬ ឋានៈមនុស្សដែលគេនិយាយនោះដែរ ៖

ខ.- "តាសែមឈឺខ្លាំងណាស់
មិនសមទៅភ្នំពេញ
អាញឹម ទៅតាមម៉ែវា"

បើចង់និយាយអំពីមនុស្សណាដែលគេមិនស្គាល់ឈ្មោះ ស្គាល់តែ

ស្រុក ឬទីកន្លែងនៅ គេច្រើនប្រើពាក្យថា ពូក កុន ពូកម៉ុ អ្នក . . .

ខ.-ពូកក្រុះបេះ កុនស្កាយខង មុំបឹងកំង ពូកម៉ុទួលទំពូង អ្នកបាត់ដំបង . . . ។ល។

បើអ្នកនោះត្រូវជាសាច់ញាតិក្តី ជាអ្នកដទៃក្តី មានអាយុតិចជាងយើង ហើយតែបានបួសរៀន តាមទំនៀមទម្លាប់ បើអ្នកនោះបានបួសជាភិក្ខុ ដល់សឹកមកកាលបើគេនឹងហៅរកគេប្រើពាក្យថាបណ្ឌិតឬ "អ្នក" ពីមុខឈ្មោះដូចជា "អ្នកផន ឬ បណ្ឌិតផន" ។ បើគ្រាន់តែបានបួសជាសាមណេរទេ គេហៅថា ជី ដូចជា ជីផន ។ ប៉ុន្តែ តាមទម្លាប់ស្រុកខ្លះនៅចំពោះមុខ គេហៅថា "ជីផន" នៅកំបាំងហៅថា "សៀងផន" វិញ ។ ពាក្យថា អ្នក ជី នេះ ពីសម័យបុរាណ គេនិយមហៅណាស់ ថែមទាំងជាប់ជាពាក្យទំនៀមថា បួសមួយហៅជី បួសពីរហៅអ្នក ដល់បួសបីថ្នាក់ហៅអា ។ សព្វថ្ងៃនេះ ប្រើនៅមានហៅតែពាក្យមួយម៉ាត់ទេ ទោះជាបានបួសជាភិក្ខុក្តី ជាសាមណេរក្តី គឺហៅថា បណ្ឌិត ។ ដែលក្លាយជាអន្ទិត ។ ហ្នឹងឯង ។

ក្មេងតូច រហូតដល់វ័យក្រមុំ ឬ កំលោះ តាមធម្មតា គេហៅថាមេ ឬ "អា" ភ្ជាប់ពីមុខឈ្មោះ ដូចជា អាសុខ មេសន អាផន មេសម ឬ ហៅថា ក្សុក ក្សន ក្តន ក្សម ក៏មាន ប៉ុន្តែបើហៅឈ្មោះទាំងនោះថា អាក្សុក មេក្សន អាក្តន មេក្សម .... ដូច្នេះវិញ ពាក្យនេះទៅជា

ពាក្យគ្រោះដែលដូចជា ហៅដោយខឹង ឬ ដោយមើលងាយទៅវិញ ។

អា-មេ-អាដែង-មេដែង :

---

ពាក្យទាំង ៤ ម៉ាត់នេះជាពាក្យគ្រោះ ប៉ុន្តែនៅតំបន់ខ្លះដូចជានៅស្រុកសណ្តាន់ ខេត្តកំពង់ធំ មនុស្សចាស់ទុំ ឬអ្នកមានបណ្តាសក្តិ ប្រើពាក្យខាងលើនេះ ដើម្បីនិយាយទៅកាន់ក្មេងក្រមុំ ឬ កម្លោះណាមួយនោះ បែរទៅជាការសម្តែងសេចក្តីរាប់អានយ៉ាងស្និទ្ធស្នាលទៅវិញ ។

ឯពាក្យថា "នាង" "អ្នក" "លោក" ជាពាក្យគួរសមល្អណាស់ ប៉ុន្តែគេច្រើនប្រើចំពោះតែអ្នកដែលនៅប្រកាន់ឋានៈ ប្រកាន់វ័យ ឬ អ្នកធំ ឬអ្នកដែលទើបនឹងស្គាល់គ្នា មិនទាន់ស្និទ្ធស្នាល ព្រោះពាក្យនេះបង្ហាញនូវភាពមិនស្និទ្ធស្នាល ភាពប្រយោល ភាពនៅគោរពគ្នា នៅក្រែងគ្នា ហើយបើយកពាក្យ "នាង" "អ្នក" "លោកប្រុស" "លោកស្រី" "លោកជំទាវ" ហ្នឹង ទៅប្រើចំពោះមនុស្សធ្លាប់ស្និទ្ធស្នាលខ្លាំង ឬ ចំពោះអ្នកដែលមានឋានៈស្មើនឹងគ្នានោះទេ ពាក្យនោះទៅជាពាក្យចំអកបញ្ឈឺគ្នាជាល្បែង ឬ ដោយខឹងសម្បារទៅវិញ ។

សំនួនពាក្យហៅរកគ្នាដូចខាងលើនេះ តាមការពិត គឺមិនមែនគេនិយមតែនៅខេត្តកំពង់ធំទេ នៅតំបន់ឯទៀតក្នុងរដ្ឋកម្ពុជា ក៏មានប្រើខ្លះទៅដែរ ហើយយល់ន័យដូចគ្នាដែរ ។ ដូចជាមនុស្សម្នាក់ខឹងនឹងបម្រើរបស់ខ្លួន ដែលធ្វើការយឺតដោយខ្ជិល ក៏ស្រែកឲ្យថា :

"មើល ! លោកស្រី សុំអញ្ជើញឲ្យហាស់បន្តិចទៅ" ។

ការប្រើឈ្មោះចំពោះមា ឬ មីងដែលមានវ័យតិចជាងក្មួយ :

នៅស្រុកខ្លះ គេប្រើពាក្យ "តូច" ដាក់នៅមុខឈ្មោះរបស់មីង ឬ មា ដែលមានអាយុតិចជាងខ្លួន ដូចជា "តូចចន្ទ តូចប៊ុន តូចម៉ុត" ជំនួសពាក្យថា មីង ពូ ឬ មា ។ ប៉ុន្តែនៅស្រុកដទៃទៀត ដូចជា ខេត្តបាត់ដំបងជាដើម គេនៅតែហៅថា មីង មា ពូ តាមរបៀបថ្នាក់ទៅ ។

បើមានមនុស្សពីរនាក់ឈ្មោះដូចគ្នា :

នៅខេត្តកំពង់ធំ គេហៅគ្នាទៅវិញទៅមកថា "ម៉ច"(១) ។ បើកាលណាគេឮមនុស្សពីរនាក់ ហៅគ្នាទៅវិញទៅមកថា "ម៉ច" ដូច្នេះគេអាចដឹងបានថា មនុស្សទាំងពីរនាក់នោះមានឈ្មោះដូចគ្នា ។ ប៉ុន្តែការប្រើពាក្យ "ម៉ច" មិនប្រើទូទៅគ្រប់ស្រុកទេ ព្រោះថា នៅស្រុកឯទៀត មនុស្សឈ្មោះដូចគ្នា គេច្រើនហៅឈ្មោះគ្នាទៅវិញទៅមកចំឈ្មោះជាធម្មតា ។

ការប្រើឈ្មោះក្នុងអំពើធ្មប់ :

តាមសេចក្តីអះអាងរបស់គ្រូខ្មែរខ្លះ ដែលបានឲ្យការណ៍មកក្រុមជំនុំទំនៀមទម្លាប់ថា អំពើធ្មប់មានឫទ្ធិ និង ឧបទេសច្រើនយ៉ាង ដើម្បីឲ្យ

១ ឯកសារក្រុមទំនៀមទម្លាប់លេខ ១០.១០៥ ។

មនុស្សឈឺ វេទនាប្ដុ ស្លាប់ ។ មុននឹងធ្វើ គេត្រូវសូត្រមន្តអាគមហៅចំឈ្មោះមនុស្ស ដែលគេចង់ព្យាបាទដើម្បីខាបយកព្រលឹងអ្នកនោះឱ្យមកនៅក្នុងអំណាចគេ ។

របៀបខាប : (១)

តាមរបៀបរបស់គ្រូធ្មប់ម្នាក់បានឱ្យការណ៍មកថា ត្រូវរៀបស្លាធម៌ ១ គូ បាយសីតូច ១ គូ ទឹកអប់ ១ គូ ទៀនធូប កន្ទោងស្លា កន្ទោងបារី ទឹកអប់១ ផ្តិលធំ ទៀនគោលមួយបិទភ្ជាប់នឹងមាត់ផ្តិលនោះ ហើយមានប្រាក់ ១ ស្លឹងបិទជាប់នឹងទៀននោះផង ។

ដល់យប់ស្ងាត់ គ្រូធ្មប់អង្គុយស្មឹងស្មាធិការទាគាថា ត្រសោះអន្ទង ហៅឈ្មោះនោះ ទាល់តែទៀនឆេះដល់ប្រាក់ស្លឹង ។ ធ្លាក់ចុះទៅក្នុងទឹកផ្តិល ទើបគ្រូដាក់កាវនាហើយពិនិត្យមើលប្រាក់ស្លឹង ។ បើប្រាក់ស្លឹងផ្ងារ គេដឹងថាខាបបាន បើផ្កាប់ថាខាបមិនបានទេ ។ បើខាបព្រលឹងមិនបាន ធ្វើឧបទេសអ្វីក៏មិនត្រូវគេដែរ ដូច្នេះគ្រូត្រូវព្យាយាមច្រើនយប់ទៅទៀតឱ្យទាល់តែខាបព្រលឹងគេបាន ទើបអាចធ្វើអំពើត្រូវ ។

ដល់ពេលធ្វើ គ្រូខ្លះយកក្រមួនសូនជារូបមនុស្ស(២) ហើយសរសេរឈ្មោះមនុស្សដែលខ្លួនត្រូវការធ្វើនៅលើរូបនោះ ។ គ្រូខ្លះគ្រាន់តែគូររូប

១- ឯកសាររបស់ក្រុមជំនុំលេខ ១០.០៥៤ ។

២- -ឌិ- ១៥.០០៧ ។

មនុស្សលើក្រដាស ឬលើកំណាត់សំពត់ស ដាក់ឈ្មោះជាមួយផងក៏បាន ។ គេខាបព្រលឹងមកដាក់ក្នុងរូបសូនឬរូបគំនូរនោះ បើជារូបគំនូរ គេមូរឲ្យតូច រួចយកក្រមួនសុទ្ធមកស្រោបពីក្រៅឲ្យជិត យកទៅកប់នៅក្រោមខ្ទមឬនៅមុខខ្ទមអ្នកតា ហើយសន្មតថាថ្ងៃខែឆ្នាំណា ឲ្យមនុស្សនោះឈឺ ឬស្លាប់តាមបំណងរបស់គេ ។

គ្រូមួយទៀត ដែលជាបងប្អូនរបស់ខ្ញុំបាននិយាយប្រាប់ខ្ញុំថា បើចង់ឲ្យមនុស្សណាមួយដែលគេស្អប់ ឈឺវេទនាយូរ គេសូនរូបក្រមួន ហើយដាក់ឈ្មោះដាក់អាយុរបស់មនុស្សនោះ រួចយកកន្លាស់ឬស្បៃស្រួចៗ ឬម្ជុលដោតរូបនោះឲ្យសុសពេញខ្លួន ហើយខ្ចប់កប់ថាឲ្យមនុស្សនោះឈឺចុកសៀតដូចជាគេចាក់ដោតរូបនោះ ។

គ្រូឆ្មបមិនហ៊ានប្រាប់អាថ៌កំបាំងដល់យើងទេឡើយ ព្រោះអំពើអកុសលនេះ រដ្ឋការត្រូវផ្តន្ទាទោស ហើយរបៀបដែលត្រូវធ្វើទៀត ក៏ពិបាកនឹងរៀបកប់ឲ្យបានច្បាស់លាស់ផង ។ ហេតុនេះ ទើបខ្មែរបុរាណចូលចិត្តលាក់ឈ្មោះនិងលក្ខណ៍កំណើតណាស់ ។

ឯរឿងធ្វើស្នេហ៍វិញ ក៏គេប្រើឈ្មោះដូចគ្នា ។ គ្រូដែលនោះបានប្រាប់ខ្ញុំថា គេសូនក្រមួនក៏បាន គូររូបលើក្រដាសក៏បាន រួចគេដាក់ឈ្មោះ ដាក់អាយុរបស់អ្នកដែលគេប៉ុនប៉ងនោះដូចខាងលើដែរ ប៉ុន្តែគេលាបប្រេងម្សៅ ហើយសិកដាក់ក្រោមខ្នើយ រួចសូត្រមន្តគាថា

ខាបហៅព្រលឹងឲ្យតាល់តែអ្នកៈខាះ  យំរក ឬរត់តាមមកនៅជាមួយ ។

រឿងនេះ ខ្មែរខ្លះជឿ ខ្លះមិនជឿទេ ប៉ុន្តែបើយើងបដិសេធថាគ្មាន ឬ មិនមែនសក្តិសិទ្ធិ ប្រហែលជាខុសទេ ។ អំពើធ្មប់ដោយយកឈ្មោះមនុស្សទៅផ្សំនឹងអាគមមានច្រើនយ៉ាង គឺ បើធ្វើដោយសម្អប់ គេធ្វើឲ្យឆ្កួតឲ្យឈឺ ឬ ឲ្យស្លាប់ ឬ គេចង់ចំណែងមិនឲ្យមានគូស្រករ បើធ្វើឲ្យស្រឡាញ់គេហៅថាធ្វើស្នេហ៍ ។ រីឯរបៀបធ្វើអំពើផ្សេង ៗ និងរបៀបដាក់ស្នេហ៍ ខ្ញុំលើកមកនិយាយតែមួយបែបយ៉ាងខ្លី របស់គ្រូម្នាក់គ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះទេ ចំណែកឯរបៀបធ្វើរៀងខាត់វិញមិននិយាយយកជាពិតតែមួយបែបពុំបានឡើយ ពីព្រោះតាមកម្រិតគ្រូនិមួយ ៗ ដែលរៀនពីគ្រូផ្សេង ៗ គ្នា តែងតែមានរបៀបផ្សេងគ្នាតាំងពីរបៀបរៀបកំណាល់គ្រូ មន្តអាគម ពិធីធ្វើ និងគ្រណាមជាដើមឡើងទៅទាំងបំណងទៀត ក៏កំណត់ពុំបាន ដូចជាគ្រូខ្លះនិយាយថា គេធ្វើអំពើដោយបញ្ចូលស្បែកក្របី កាំបិតកោរ កន្ទាស់ឈើទៅក្នុងពោះមនុស្សដែលគេស្អប់ក៏បាន ធ្វើជាស្នេហ៍មុខ ស្នេហ៍ឱ្យរត់តាមក៏បាន ប៉ុន្តែការសំខាន់ ដោយភាគច្រើន គេត្រូវឲ្យស្គាល់ឈ្មោះពិតរបស់មនុស្សដែលគេចង់ធ្វើនោះឲ្យបានជាមុនសិន ទើបគេយកទៅសូត្រ ហៅព្រលឹងបាន ។ ឧទាហរណ៍ : គេចង់ធ្វើស្ត្រីម្នាក់ដែលដែលស្គាល់ជាក់ថាខាងនោះឈ្មោះ “អន” ឲ្យស្រឡាញ់បុរសម្នាក់ទៀត ។ ដំបូង គេត្រូវ

រៀបកំណាល់តាមបែប ហើយអគ្គិយស្មឹងស្មាធិសូត្របរិកម្មហៅព្រលឹងថា “អកាបតិ៍ទើបគ្រូប្រើអញឲ្យខាបព្រលឹងនាង “អន” ឲ្យហងឆាប់ប្រញាប់ស្ដាប់បង្គាប់អញជាគ្រូបាធ្យាយ ឯហ៊ិមម . . . ។” គ្រូខ្លះទៀតបញ្ជាក់ថាសូម្បីស្ដាលតែឈ្មោះប៉ុណ្ណឹង ក៏ពុំទាន់សក្ដិសិទ្ធិដែរ ត្រូវតែអង្កើតស៊ើបសួរឲ្យដឹង ឆ្នាំ ខែ ថ្ងៃ កំណើត របស់អ្នកនោះទៀតផង ទើបបានឆាប់ដូចបំណង ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ យើងអាចរួបរួម ចំពោះតែការប្រើឈ្មោះរបស់គ្រូធ្មប់នេះបានថា ត្រូវតែហៅចំឈ្មោះពិតរបស់អ្នករងគ្រោះ មិនអាចយកឈ្មោះអ៊ីក្រៅ មកប្រើជំនួសបានឡើយ ហើយការហៅឈ្មោះនោះទៀត ត្រូវតែហៅកន្ធ៉ាន:យើងជាអ្នកធំជាងដូចជាសំនួនពាក្យមន្តអាគមដែលបាននិយាយមកពីមុនស្រាប់ ។

ការឲ្យឈ្មោះកូនក្រក– (១) ;

សូមនិយាយអំពីការធ្វើកូនក្រកបន្តិចផងចុះ ដើម្បីឲ្យងាយយល់រឿងកូនក្រកនេះ គឺមានប្រើពិត ពីដំនាន់បុរាណ តែត្រង់បានផលយ៉ាងណាៗខ្លះនោះ ពុំប្រាកដទេ ព្រោះតែងឮចាស់ ៗ តំណាលថា គេអាចធ្វើកូនក្រកបានតែចំពោះកូនប្រពន្ធរបស់ខ្លួនប៉ុណ្ណោះ ។ ដំបូងគេ ត្រូវនិយាយល្បួង

---

១- សេចក្ដីរាយការណ៍របស់លោក ភិន-គូ សង្កាត់អង្គតាសោម ស្រុកត្រាំកក់ (តាកែវ) ។ ស្រង់ចេញអំពីឯកសារទំនៀមទម្លាប់លេខ ៣៣-០៤៨-ចុះថ្ងៃ ២០-៦-៦៣ ស្ដីអំពីរឿងគ្រឿងសស្ត្រាវុធ

សុំកូនដែលនៅក្នុងផ្ទៃម្ដាយ បើប្រពន្ធព្រមទទួលថាឲ្យទើបស្រេចតែការ ដល់នូវជីវិតទាំងម្ដាយទាំងកូននោះ ៈគេមិនត្រូវឲ្យប្រពន្ធដឹងជាមុនទេ ។

តាមសេចក្ដីឲ្យការណ៍របស់លោក ពំណា-គូ ថា ទារកដែលនៅក្នុងផ្ទៃម្ដាយ ដែលអាចយកជាការបាន លុះតែមានកំណត់ពី ៥ ខែទៅ ៧ ខែ ខុសពីរវាងនេះ គេមិនយកទេ ។

ដល់ពេលត្រូវយក គេល្បងនាំប្រពន្ធទៅព្រៃ ដើម្បីធ្វើការនោះឲ្យបានស្ងាត់ តមមិនឲ្យអ្នកណាឃើញទេ ធ្វើការផ្ទាល់តែដៃមួយ ឲ្យសម្រេចសព្វទាំងអស់ ។ អ្នកដែលប្រាថ្នាចង់បានកូនក្រកនោះខ្លាំងជាងគេមានតែចំពោះមនុស្សពីរបីពួកទេ គឺពួកមេចោរ និងមេទ័ពធំ ឯមនុស្សក្រៅពីនោះគ្មានកូនក្រកប្រើការទេ ។

អ្នកដែលមានចិត្តក្លាហាន ហ៊ានធ្វើ ដំបូងត្រូវទៅសិក្សានឹងអ្នកដែលគេចេះដឹង ធ្លាប់មានកូនក្រកប្រើដកបមក ឲ្យគេពន្យល់របៀបធ្វើឲ្យបានចេះស្ទាត់អស់កិច្ចជាមុនសិន តែការនេះជាការក្រ បើគេចេះក៏គេលាក់បំបាំងណាស់ មិនងាយប្រាប់យើងទេ ។ ដំបូងត្រូវល្បងនាំប្រពន្ធទៅរកព្រៃជ្រៅឆ្ងាយ ជាព្រៃមានឧសភាពស្ងប់ស្ងាត់ ហើយលៃយកទាំងស្បៀងអាហារផងសម្រាប់ខ្លួនល្មមគ្រប់គ្រាន់ ។ លុះទៅដល់ទីសមគួរហើយ ក៏នាំប្រពន្ធរកឧសគរទុកនៅកន្លែងនោះ ឲ្យបានចំនួនគ្រប់គ្រាន់នឹងធ្វើការ រួចហើយ ចាប់ប្រពន្ធចងឲ្យដេកផ្ងារសន្ធឹង រួចគេ

ឧបត្ថកៈគាល់សីមាប្រចាំទិសទាំង ៨ នៅជុំវិញកន្លែងដែលធ្វើការនោះ រួចស្រែកមន្តទាញអំពោះព័ទ្ធសីមាទៀត ទើបកាន់កាំបិតចូលទៅវះពោះប្រពន្ធយកកូន បានមកតម្កល់ទុកមួយអន្លើ ក៏តាំងចាប់ផ្តើមធ្វើកនបានស្រេច ដុតបង្កាត់ភ្លើងធ្វើភារកនោះ ដោយដាក់ភ្លើងឲ្យក្តៅបន្តិចម្តង ៗ ឲ្យទាល់តែក្រៀមស្ងួត ទៅតូច ល្មមហើយ គេយកកូនក្រកនោះទៅតម្កល់នៅកន្លែងមួយដ៏សមគួរ រួចគេគូរយន្តពីរផ្ទាំង ជាយន្តកងកន់ពេះ បញ្ចុះមន្តគាថាស្រេច យកទៅដាក់អមរូបកូនក្រកនោះឆ្វេងស្តាំ រួចហើយអុជទៀនធូប បន្ទ្រមការនោះសូត្រមន្តគាថា អន្ទងយឹតខាបជូនវិញ្ញាណបញ្ចូលទៅក្នុងរូបកូនក្រក កាលណាគេដឹងថាចូលហើយ គេដាក់នាមកូនក្រកនោះតាមភេទកូនស្រីប្រុស រួចយកអំពោះមន្តបាលី រុំស្រាក់កូនក្រកឲ្យណែនល្អ ទើបខ្ចក់ម្រ័ក្សណ៍ថែមជាក្រោយកុំឲ្យស្អុយ ។ គេនៅតែក្នុងសីមាព្យាយាមសូត្រហៅឈ្មោះដាទិច្ច ទាល់តែមានឮស្បូរសំឡេងឆ្លើយតបប-ពារគ្នាទៅវិញទៅមកស្តាប់គ្នាបាន ទីងទទួលស្តាប់បង្គាប់រញ្ញា យកការស្ងាត់កំបាំងមកប្រាប់អ្នកជាឪពុកទាំងយប់-ថ្ងៃ មិនឲ្យពួកសត្រូវចូលមកដល់ខ្លួនឡោមព័ទ្ធបាន ឲ្យប្រយ័ត្នគ្រប់ទិសនានាទាំងអស់ បើឪពុកកំពុងដេកលក់ ក៏មកដាស់មកប្រាប់ ឲ្យបានដឹងខ្លួនជាមុនដរាប ។

ឯចំណីអាហារកូនក្រក គេដាក់លាចឲ្យស៊ីរាល់ពេល បុកណាស្តី

ថា ជួនកាលគេចាបបានមកទាំងកូនទាំងម្តាយ មកនៅរួមគ្នាទាំងពីរ ចាំយកការឲ្យគេបានដូចគ្នា ប៊ីដូចប្តីប្រពន្ធរស់នៅរួមគ្នាជាធម្មតា ៗ

គេធ្វើការនេះ ៩ ថ្ងៃទើបស្រេច គេត្រូវកាត់សក់គោលសីមា និងកាត់អំបោះសីមាចោល រួចធ្វើដំណើរចាកទីនោះទៅ ៗ

---

# ៤

## ក្បួនស្តីអំពីការប្រើអក្សរឈ្មោះ

នៅពេលដែលទៅតាំងទីលំនៅក្នុងភូមិណាមួយ សម័យបុរាណ គេមិនចេះតែទៅតាំងនៅតាមចិត្តចង់នោះទេ មុននឹងទៅតាំងនៅជាស្ថាពរ គេតែងពិនិត្យមើលលក្ខណៈជ័យភូមិឲ្យដឹងថា តើភូមិនោះកាលណាបើគេនៅទៅហើយ នឹងបានសេចក្តីសុខសាន្ត ឬ ទុក្ខព្រួយភាព ឬជាយ៉ាងណា ៗ ពីព្រោះគេជឿថា ភូមិស្រុកនិមួយ ៗ មានមនុស្សទៅអាស្រ័យនៅខ្លះក៏បានប្រកប ខ្លះទៀតមិនបានប្រកបទេ ទីងកើតវិនាសអន្តរាយអ៊ីមួយពុំខាន ៗ ប៉ុន្តែការពិនិត្យលក្ខណៈជ័យភូមិនេះ ក្រៅពីសង្កេតមើលលក្ខណៈធម្មជាតិ ដែលអាចផ្តល់ផលប្រយោជន៍សម្រាប់មុខរបររបស់ខ្លួន ហើយ គេនៅមានពិនិត្យទៅតាមក្បួនហោរាសាស្ត្រថែមទៀត បើឃើញថាល្អទើបគេទៅតាំងនៅជាស្ថាពរ ៗ ចំពោះការ

ពិនិត្យធម្មជាតិដែលអាចផ្តល់ប្រយោជន៍ គឺជាការធម្មតាដូចជំនាន់សព្វថ្ងៃនេះដែរ ប៉ុន្តែចំពោះការពិនិត្យរកជ័យភូមិល្អ ឬ អាក្រក់វិញ តម្រាបុរាណស្តីថា ត្រូវយកនាមមនុស្សទៅបូកនឹងនាមភូមិ ។ បើប្រុសឲ្យយកអក្សរដើម បើស្រីឲ្យយកអក្សរចុង ។ នាមភូមិស្រុកក៏ឲ្យយកអក្សរចុងដែរ ។ ឧបមាថា ឈ្មោះ "អ៊ូច" ប្រុសចង់ទៅតាំងទីលំនៅ ១ ភូមិ "បាទយ" ។ គេយកនាមមនុស្សទៅផ្សំនឹងនាមភូមិដូច្នេះ នាមមនុស្ស យកអក្សរ "អ" នាមភូមិយកអក្សរ "យ" ។ អក្សរ "អ" ជានាមគ្រុឌត្រូវលើសេស ១ ។ អក្សរ "យ" ជានាមដំរីត្រូវលើសេស ៨។

យកសេស ១ បូកនឹងសេស ៨ ឃើញ ៩ ។ យក ៩ ទៅគុណនឹង ៣ ឃើញប៉ុន្មាន ឲ្យយកទៅចែកនឹង ៧ ទៀត បើចែកទៅដាច់ គេហៅថាសេសសូន្យ តែបើចែកមិនដាច់ទេ នៅមានសល់ប៉ុន្មាន ឲ្យទាយតាមពាក្យស្លោកសេសដូចខាងក្រោម :

| | |
|---|---|
| សេស ១ | ហៅភូមិមន្ត្រី |
| សេស ២ | — សេដ្ឋី |
| — ៣ | — រាជា |
| — ៤ | — រាស្ត្រប្រជា |

៨

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ


ឆ្នាំទី ៤៣ ខែ មេសា

ព.ស. ២៥១៤ គ.ស. ១៩៧១

- ភ្នំពេញ -

៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : លាង ហ័បអាន

និពន្ធនាយក - អ្នករៀបចំ : លី ធាមតេង

គណៈកម្មការនិពន្ធ :

ព្រះពោធិវង្ស សួរ-ហាយ

លោក ឌឹក-គាម អ្នកស្រី ពេជ-សល់

# បញ្ជីរឿង

អត្ថបទ | ទំព័រ

## ១– ផ្នែកសាសនា


១– អគ្គញ្ញសូត្រ លោក ញ៉ុក-ថែម រៀបរៀង . . . . . ៣០៣

២– រឿងនាងសាមាវតី លោក ប៊ូ-ប៉ូ រៀបរៀង . . . . . ៣១៥


## ២– ផ្នែកអក្សរសាស្ត្រ


៣– វិបារណកថា : លោក លី-ធាមតេង រៀបរៀង . . . ៣៣៤

៤– រឿងសាមកុក ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . ៣៧៨

៥- ល្បើកដុច លោក លីធាម-តេង ស្រាវជ្រាវ . . . . ៣៥៤

៦– រឿងរាជកុល ច់ម្លងពិនិត្យផ្ទៀងផ្ទាត់ដោយ លោក ឌឹក គាម . . ៣៧០


## ៣– ផ្នែកកំណត់-ប្រវត្តិការណ៍


៧– ពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ . . . . . . ៣៩២

៨– ក្រឹត្យតែងតាំងមន្ត្រីសង្ឃ . . . . . . . . . ៤០០


---

## តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ។

អាណត្តិសូមដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

BIBLIOTHEQUE
NATIONALE
DU CAMBODGE
P.K_1
1971_4

ផ្នែកសាសនា

# អគ្គញ្ញសូត្រ

អត្ថបទស្ដីអំពី

## ទស្សននិយមផ្ទុយគ្នារវាងព្រាហ្មណនិយម និង ពុទ្ធនិយម

១- ពួកព្រាហ្មណ៍យល់និងប្រកាន់ថា មានតែពួកព្រាហ្មណ៍ទេ ដែលជាពួកប្រសើរខ្ពង់ខ្ពស់ជាងពួកវណ្ណៈដទៃទៀតទាំងអស់ ព្រោះពួកព្រាហ្មណ៍ជាបុត្ររបស់ព្រហ្ម ។

២- ពុទ្ធនិយមបានប្រឆាំងជំទាស់នឹងទស្សនៈនេះ ដោយបញ្ជាក់ថា តម្លៃរបស់មនុស្សដែលខ្ពង់ខ្ពស់ ឬ ថោកទាប មិនមែនពឹងនៅលើពូជពង្សវង្សត្រកូល ឬវណ្ណៈអ្វីទេ គឺពឹងនៅលើសកម្មភាពល្អ-អាក្រក់របស់មនុស្សទេតើ !

៣- នយលក្ខណៈ ជាសេចក្ដីពន្យល់បំភ្លឺបន្ថែមរបស់អ្នកប្រែ-រៀបរៀងអត្ថបទ ។

សេចក្ដីដកស្រង់ប្រែសម្រួលអំពី អគ្គញ្ញសូត្រ នៃ ពាដិកវគ្គ ទីឃនិកាយ សុត្តន្តបិដក ។

ដោយ

លោក ញ៉ុក-ថែម

គ្រាមួយនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់គង់ប្រថាប់ឯកុដិ ដែលនាងវិសាខាសាងថ្វាយ ក្នុងវត្តបុព្វារាម នាក្រុងសាវត្ថី ។ គ្រានោះ វាសេដ្ឋមាណពនិងភារទ្វាជមាណព មានបំណងចង់ចូលបួសជាភិក្ខុ ក្នុងធម្មវិន័យនេះ ទើបនាំគ្នាទៅទទួលការអប់រំ ក្នុងសំណាក់នៃភិក្ខុទាំងឡាយ ។

ពេលរសៀលថ្ងៃមួយ វាសេដ្ឋមាណពនិងភារទ្វាជមាណពចូលទៅគាល់ព្រះបរមគ្រូ ដែលព្រះអង្គកំពុងចង្ក្រម ។ ព្រះអង្គត្រាស់សួរថា " ចុះពួកព្រាហ្មណ៍បានជេរស្តីអ្នកទាំងពីរដូចម្តេចខ្លះ ឬទេ ? "

– " ពួកព្រាហ្មណ៍បានជេរស្តីទូលព្រះបង្គំទាំងពីរនាក់យ៉ាងសម្បើមព្រះអង្គ " ។

– " ពួកព្រាហ្មណ៍ជេរស្តីអ្នកទាំងពីរយ៉ាងដូចម្តេចខ្លះ ? "

– " ពួកព្រាហ្មណ៍បានពោលថា ពួកព្រាហ្មណ៍ប៉ុណ្ណោះ ជាពួកប្រសើរ ពួកដទៃទៀតជាពួកថោកទាបទេ ពួកព្រាហ្មណ៍ប៉ុណ្ណោះ ជាពួកស ពួកដទៃទៀត ជាពួកខ្មៅទេ ពួកព្រាហ្មណ៍ជាពួកបរិសុទ្ធ ពួកដទៃទៀតមិនបរិសុទ្ធទេ ព្រោះពួកព្រាហ្មណ៍ជាបុត្ររបស់ព្រហ្ម ជាឱរសរបស់ព្រហ្ម ពួកអ្នកឯងបានលះបង់ពួកប្រសើរ ទៅចូលនឹងពួកថោកទាប គឺពួកក្បាលត្រងោល ពួកសមណៈ ពួកពល ពួកខ្មៅ ពួកកើតអំពីជើងព្រហ្ម ។ ពួកអ្នកឯង ដែលបានលះបង់ពួកប្រសើរ ទៅចូលក្នុងពួកថោកទាបដូច្នេះ មិនគួរសមសោះឡើយ ។ ពួកព្រាហ្មណ៍បានជេរ

ស្តី ខ្ញុំព្រះអង្គទាំងពីរនាក់ ដូចបានក្រាបទូលមកនេះព្រះអង្គ(១) ។

លុះវាសេដ្ឋភារទ្វាជ និងភារទ្វាជមាណពក្រាបបង្គំទូលឲ្យព្រះអង្គទ្រង់បានជ្រាបដូច្នោះហើយ ទើបទ្រង់ត្រាស់បញ្ជាក់ថា ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ពួកព្រាហ្មណ៍ទាំងនោះ នឹករលឹកមិនឃើញឡើយ នូវដើមកំណើតរបស់ពួកខ្លួន អំពីបុរាណកំណើតដ៏វែងឆ្ងាយ បានជាហ៊ានពោលថា មានតែពួកព្រាហ្មណ៍ប៉ុណ្ណោះប្រសើរ ពួកដទៃទៀត សុទ្ធតែជាកទាប, ពួកព្រាហ្មណ៍ប៉ុណ្ណោះជាពួកស ពួកដទៃទៀត សុទ្ធតែជាពួកខ្មៅ, ជាពួកមិនបរិសុទ្ធ, មានតែពួកព្រាហ្មណ៍ទេជាបុត្ររបស់ព្រហ្ម, ជាឱរសរបស់ព្រហ្ម, កើតអំពីព្រះឱស្ឋព្រហ្ម កើតអំពីព្រហ្ម ព្រហ្មនិរមិតឡើង ជាទាយាទរបស់ព្រហ្មដូច្នេះ " ។

ម្នាលវាសេដ្ឋៈ ភារទ្វាជៈ ឯសេចក្តីពិតមិនមែនដូច្នោះទេ គឺនាងព្រាហ្មណីរបស់ព្រាហ្មណ៍ រមែងមានរដូវមានផ្ទៃពោះ ប្រសូតបុត្របំបៅបុត្របាន (ដូចជាពួកស្ត្រីក្នុងវណ្ណៈផ្សេងៗ) ដែរ ។ ពួកព្រាហ្មណ៍ទាំងនោះ បាប់កំណើតឡើង ក្នុងផ្ទៃនៃពួកនាងព្រាហ្មណីយ៉ាងជាក់ស្តែង

១- ការណ៍ដែលពួកព្រាហ្មណ៍ជេរស្តីបន្ទោសពួកព្រាហ្មណ៍ខ្លះ ដែលជ្រះថ្លានឹងពុទ្ធសាសនា ដោយសំដីប្រមាថមើលងាយចំពោះពួកពុទ្ធបរិស័ទយ៉ាងនេះ តើអ្នកអានអត្ថបទនេះយល់ដូចម្តេច មុនលោកអ្នកនឹងអានបន្តទៅមុខទៀត ។

តាមទស្សនពុទ្ធនិយម តែងនិយមយកសន្តិវិធីជាមធ្យោបាយដោះស្រាយវិបត្តិ ។ តើអស់លោកពុទ្ធិកជន ប្រើមធ្យោបាយដោះស្រាយយ៉ាងណា ដើម្បីឲ្យគូប្រឆាំងធំទាស់សុខចិត្តយល់ស្របតាមសេចក្តីពន្យល់របស់យើង និងដើម្បីចៀសវាងការឈ្លោះប្រកែកគ្នាដោយសំដីមិនសមរម្យផ្សេងៗ ។

ប៉ុន្តែពួកព្រាហ្មណ៍ពោល (អាងហេតុផ្សេងពីការពិត) ដូច្នេះ ឈ្មោះថាពោលបង្កាច់ព្រហ្ម ពោលមុសាចំពោះព្រហ្ម យ៉ាងនេះ ទំនងត្រូវទទួលបាបដ៏ច្រើនពុំខាន(១) ។

ព្រះពុទ្ធជាម្ចាស់ទ្រង់បានត្រាស់សម្តែងបន្តទៅទៀតថា : ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ក្រុមជន ៤ ពួក គឺក្សត្រព្រាហ្មណ៍ វៃស្យៈ សូទ្រៈ ទាំងនោះ ល្អក៏មាន អាក្រក់ក៏មាន សក៏មានខ្មៅក៏មាន បរិសុទ្ធក៏មាន មិនបរិសុទ្ធក៏មាន គឺអ្នកខ្លះពួកខ្លះ ប្រព្រឹត្តអំពើបាណាតិបាត អទិន្នា-ទាន កាមេសុមិច្ឆាចារ ពោលមុសាវាទ ពោលពាក្យញុះញង់ ពោលពាក្យហោកទាបគ្រោតគ្រាត និយាយផ្តេសផ្តាស សំឡឹងចង់បានតែរបស់ទ្រព្យអ្នកដទៃ ចងចិត្តព្យាបាទអ្នកដទៃ មានទស្សនៈ យល់ខុស ។ អំពើណាមួយ ជាអកុសល អ្នកចេះដឹងក៏យល់ថាជាអកុសល ជាអំពើមានទោស ជាអំពើមិនគួរធ្វើ អ្នកចេះដឹងក៏យល់ថាមិនគួរធ្វើ មិនមែនជារបស់អរិយៈ ជាអំពើខ្មៅ មានផលខ្មៅ ជាអំពើដែលអ្នកចេះដឹងតិះ-ដៀល ។ អំពើទាំងនោះ តែងមានពិតប្រាកដ ក្នុងក្រុមក្សត្រខ្លះ ក្រុម

១- ពួកព្រាហ្មណ៍ដែលលើកតម្កើងតែពួកខ្លួន ហើយបន្តុះបង្អាប់ពួកវណ្ណៈដទៃ ដោយមិនសមហេតុសមផលយ៉ាងនេះជាអយុត្តិធម៌ពេកណាស់ ក្នុងសង្គមមនុស្ស ។ រឿងនេះ ទស្សនៈពុទ្ធនិយមបានបដិសេធចោលទាំងស្រុង ដូចព្រះតម្រាស់ត្រាស់ទូន្មានមាណពពីរនាក់ដែលជ្រះថ្លាចំពោះព្រះអង្គថា ពួកព្រាហ្មណ៍មិនមែនកើតចេញអំពីព្រហ្ម ដូចគេជឿប្រកាន់មកនោះទេ គឺពួកព្រាហ្មណ៍ទាំងអស់ កើតមកពីម្តាយគេ ជានាងព្រាហ្មណី និងឪពុកគេជាព្រាហ្មណ៍ ដូចជាពួកជនក្នុងវណ្ណៈដទៃទៀត ដែលបានចាប់កំណើតមកអំពីមាតាបិតារបស់គេរៀងៗខ្លួនដូច្នោះដែរ ។

ព្រាហ្មណ៍ខ្លះ ក្រុមវៃស្យៈខ្លះ ក្រុមសូទ្រៈខ្លះ គឺក្សត្រខ្លះ ព្រាហ្មណ៍ខ្លះ វៃស្យៈខ្លះ សូទ្រៈខ្លះ បានប្រព្រឹត្តអំពើអាក្រក់ទាំងនោះដែរ ។ អ្នកដែលបានប្រព្រឹត្តអំពើអាក្រក់ទាំងនោះ យ៉ាងណាទីមួយក៏ដោយ ក៏គួរចាត់ទុកជាមនុស្សអាក្រក់ មនុស្សខ្មៅ ជាមនុស្សមិនបរិសុទ្ធដែរ ។

មានក្សត្រខ្លះ ព្រាហ្មណ៍ខ្លះ វៃស្យៈខ្លះ សូទ្រៈខ្លះបុត្តកខ្លះ ដែលបានវៀរចាកអំពើអកុសលទាំងឡាយ មានបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទជាដើម ។ អំពើណាជាកុសល អ្នកចេះដឹងក៏យល់ថាជាកុសល ជាអំពើឥតទោស អ្នកចេះដឹងក៏យល់ថាឥតទោសដែរ ជាអំពើគួរធ្វើ ក៏ចេះដឹងក៏យល់ថាគួរធ្វើដែរ ជារបស់អរិយៈ អ្នកចេះដឹងក៏យល់ថាជារបស់អរិយៈដែរ ជាអំពើស មានផលក៏សដែរ ជាអំពើដែលអ្នកចេះដឹងតែងសរសើរ ។ អំពើទាំងនោះ រមែងមានពិតប្រាកដ ក្នុងក្រុមក្សត្រខ្លះ ។ ព្រាហ្មណ៍ខ្លះ វៃស្យៈខ្លះ និងសូទ្រៈខ្លះ ។ អ្នកណាមួយដែលបានវៀរចាកអំពើអកុសលធ្វើតែអំពើល្អទាំងនោះ ទោះបីជាជនក្រុមណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សល្អ ចាត់ទុកជាពួកស ជា

ពួកមនុស្សបរិសុទ្ធដូចគ្នាទាំងអស់ (១) ។

គទៅនេះ ជាសេចក្តីសង្ខេប ស្តីអំពីប្រវត្តិនៃមនុស្សលោក មាន សេចក្តីតំណាលថា ព្រះពុទ្ធជាម្ចាស់ ទ្រង់លើកយកហេតុដែលព្រះបាទ បសេនទិកោសល ព្រះអធិរាជ ទ្រង់ធ្វើសក្ការៈគោរពកោបអាទរបូជាព្រះ អង្គ រួចទ្រង់បានសរុបរួមសេចក្តីថា មនុស្សមានជាតិកំណើតផ្សេង ៗ គ្នា មានពូជពង្សវង្សត្រកូលផ្សេង ៗ គ្នា ដែលបានចូលមកបួសក្នុង សាសនារបស់ព្រះអង្គហើយ គួរហៅថាជាបុត្ររបស់ព្រះពុទ្ធ ជាទាយាទ របស់ព្រះពុទ្ធកើតអំពីព្រះឧរស្ថព្រះពុទ្ធ ជាអ្នកកើតដោយធម៌ ជាអ្នកដែល ធម៌និម្មិតឡើង ជាទាយាទនៃធម៌ដូចគ្នាទាំងអស់ ព្រោះពាក្យថា ធម្ម- កាយក្តី ព្រហ្មកាយក្តី ធម្មភូតក្តី ព្រហ្មភូតក្តី សុទ្ធតែសំដៅដល់ តថាគតដែរ ។

លុះទ្រង់សម្តែងយ៉ាងនេះហើយ ទើបទ្រង់សម្តែងការវិវត្តន៍ ការ ប្រែប្រួលផ្លាស់ប្តូរនៃពិភពលោក គឺលោកវិនាស លោកចម្រើន ហើយ

---

១– ព្រះពុទ្ធតម្រាស់នេះ មានន័យប្រកបដោយឧត្តមគតិ មានលក្ខណៈជាមនុស្សលោក និយមទូទៅ ។ ទ្រង់បានបដិសេធបោលនូវលទ្ធិប្រកាន់ពូជសាសន៍ វណ្ណៈខ្ពស់-ទាប ឋានៈ ធំ-តូច ឬពណ៌សម្បុរទាំងអស់ ។

លទ្ធិនិយមបានឲ្យតម្លៃដល់មនុស្សជាតិទូទៅស្មើៗគ្នាទាំងអស់ ។ ប៉ុន្តែដោយផ្លូវតាមការ ប្រព្រឹត្តនិងគុណសម្បត្តិ មនុស្សអាចមានតម្លៃខុសប្លែកគ្នាខ្លះៗដែរ ។ ដូចមនុស្សប្រព្រឹត្តតែ អំពើល្អ ចៀសវាងការប្រព្រឹត្តអាក្រក់ថោកទាបផ្សេងៗ គេត្រូវចាត់ទុកមនុស្សនោះ ជាមនុស្ស ល្អត្រឹមត្រូវដូចគ្នាទាំងអស់ ។ ឯអ្នកប្រព្រឹត្ត ក្រក់ត្រូវចាត់ទុកជាមនុស្សអាក្រក់ដូចគ្នាដែរ ។ ដូច្នេះបញ្ហាជាមូលដ្ឋានត្រូវបិតនៅលើអំពើរបស់មនុស្សដូចគ្នាទាំងអស់ ។

មានព្រហ្មចុះមកបរិភោគខ្ទជាសេនៃផែនដី រួចប្រែក្លាយមកជាមនុស្ស ។ អំណើះកាលតមក មនុស្សទាំងនេះបែងចែកជាពួកជាក្រុម គឺពួកក្សត្រ ពួកព្រាហ្មណ៍ ពួកវៃស្យៈ ពួកសូទ្រៈ រួមសេចក្ដីថា ដើមកំណើតនៃមនុស្សទួទៅ ក្នុងកល្បនិមួយ ៗ ប្រែក្លាយមកអំពីព្រហ្មដូចគ្នាទាំងអស់ ហើយព្រហ្មនោះក៏ប្រែក្លាយមកអំពីសត្វផ្សេង ៗ ដែរ ។

ក្នុងអគ្គញ្ញសូត្រ មានសេចក្ដីបន្ទះទៅទៀតថា មុនកើតមានក្សត្រឡើងនោះ ក្នុងសង្គមមនុស្សសម័យនោះ មានវិបត្តិកើតឡើងដោយមានមនុស្សខ្លះលោកដណ្ដើមស្រូវសាលីរបស់អ្នកដទៃ មានការវាយដំគ្នា មានរឿងបៀតបៀនគ្នាកើតឡើង ទើបមនុស្សទាំងឡាយជំនុំគ្នាជ្រើសរើសមនុស្សម្នាក់មានរូបល្អ រាងកាយមាំមួន មានអំណាចច្រើនជាងគេ ឲ្យធ្វើជានាយក (អ្នកដឹកនាំ) ហៅថា "មហាជនសម្មតិ" បានសេចក្ដីថា អ្នកដែលមហាជនសន្មតតែងតាំងបង្កើតឡើង ។

តមក មហាជនសម្មតិ មាននាមថ្មីមួយទៀត ថា "ក្សត្រិយ" ប្រែថា អ្នកជាធំក្នុងស្រែចម្ការស្រែ សម្រាប់បែងចែកផលិតផលស្រូវ ។

តមកទៀត មនុស្សទាំងឡាយមានសេចក្ដីពេញចិត្ត សប្បាយរីករាយនឹងអំពើប្រកបដោយធម៌របស់ក្សត្រនោះ ទើបជំនុំតាំងនាមថ្មី ១ ទៀត ជាគម្រប់ទី ៣ ហៅថា "រាជា" ប្រែថា អ្នកញុំាងប្រជាជនឲ្យត្រេកអររីករាយដោយធម៌ ។ ដូច្នេះ ឃើញថា ធម៌ជាសភាវៈប្រសើរបំផុត ក្នុងសង្គមមនុស្សលោក ។

អំណើះកាលត ៗ មកទៀត មានមនុស្សពួកខ្លះ គិតឃើញថា អំពើអាក្រក់ផ្សេង ៗ មានកើតឡើង ដូចជាការលួចប្លន់ ការត្មះតិះដៀលគ្នា ការកុហកគ្នា ចាប់ផ្ដើមពីយកស្ត្រីគ្នា ជាដើម ។ ជនចំពួកនេះ យល់ឃើញថា គួរតែយើងរាល់គ្នាលះបង់អំពើបាបអកុសលទាំងនោះ ចោលចេញ ។ ពួកនេះហើយដែលមានឈ្មោះថាព្រាហ្មណ៍ (គឺថា អ្នករៀរចាកបាបអកុសល) ។ ពួកព្រាហ្មណ៍ទាំងនោះ នាំគ្នាធ្វើខ្ទមប្រក់ស្លឹកឈើនៅក្នុងព្រៃដោយស្ងប់ស្ងៀម ពេលព្រឹកប្លាច គេនាំគ្នាទៅសុំអាហារ តាមភូមិ ស្រុក និគម និង ជានី យកទៅបរិភោគ ហើយគេរិះគិតតែខាងធូរធម៌ សំឡឹងធម៌ (ពិចារណាធម៌) នៅក្នុងខ្ទមរៀង ៗ ខ្លួន ។ មនុស្សទាំងឡាយនាំគ្នាហៅពួកនោះថា "ពួកឈាយិកា" (ប្រែថាពួកសំឡឹងធម៌ ពិនិត្យធម៌) ។

ចំណែកឯពួកមិនសំឡឹងធម៌រស់នៅជិតភូមិស្រុក ជាពួកគិតតាក់តែងគម្ពីរទាំងឡាយ ។ មនុស្សទាំងឡាយនាំគ្នាហៅពួកនោះថា "អជ្ឈាយិកា" (ប្រែថា ពួកមិនសំឡឹងធម៌) ។ គេចាត់ទុកជាពួកថោកថយក្នុងសម័យនោះ ប៉ុន្តែពួកគេទុកដាក់ពួកគេថាជាពួកថ្លៃថ្នូរ ក្នុងកាលឥឡូវនេះ ។ ពួកនេះហើយ ដែលប្រកាន់ខ្លួនថាជាព្រាហ្មណ៍ គេបានទុកដាក់វណ្ណៈព្រាហ្មណ៍ ថាជាវណ្ណៈប្រសើរខ្ពង់ខ្ពស់ជាងពួកវណ្ណៈដទៃទៀតរហូតត ៗ ដក ។

តាមការពិត ពួកក្រោយនេះ ជាពួកអន់ថយកាលពីដំបូង មិន

មែនជាពួកថៃថ្ប កាលពីមុនមកនោះទេ ។ ឯពួកមានគុណសម្បត្តិប្រសើរ កាលអំពីមុននោះ គឺពួកសំឡឹងធម៌ ដែលរស់នៅតែក្នុងព្រៃ មិនមែនជាពួកតាក់តែងគម្ពីរព្រាហ្មណ៍រស់នៅជិតភូមិស្រុក ដែលជាដើមកំណើតនៃពួកព្រាហ្មណ៍ក្នុងបច្ចុប្បន្នកាលនេះទេ(១) ។

ក្នុងសង្គមមនុស្សសម័យនោះ ដែលមានគ្រួសារបានប្រកបការងារផ្សេង ៗ (ក្នុងអត្ថបទបាលីថា វិសុំ វិសុំកាម្មន្តេ បយោជេន្តិ ពួកជនប្រកបការងារផ្សេង ៗ គ្នា ដូចពាក្យឈ្មួញ អ្នកស្រែចំការ និងអ្នកធ្វើការងារផ្សេងទៀតដោយសេរី មិនមែនជាអ្នកស៊ីឈ្នួលទេ ) ហៅថា ពួកវៃស្សៈ ឬ វេស្ស ។

ឯមនុស្ស ១ ពួកទៀត ជាអ្នកធ្វើការស៊ីឈ្នួលអ្នកដទៃ ឬ ធ្វើជាកូនឈ្នួលគេហៅថា សូទ្រៈ ( យើងធ្លាប់ហៅថា គូលី ឬ កម្មករ ) ។

លុះអំណើះកាលត ៗ មកទៀត មានក្សត្រខ្លះ ព្រាហ្មណ៍ខ្លះ វៃស្សៈខ្លះ សូទ្រៈខ្លះ មានចិត្តធុញទ្រាន់នឿយណាយ នឹងជីវភាពរបស់ខ្លួន

១- តាមអត្ថបទខាងលើនេះ បញ្ជាក់ឲ្យយើងបានដឹងនូវដើមកំណើតនៃពួកព្រាហ្មណ៍ ថា សង្គមមនុស្សជាន់ដើមនោះ ក្រោយមានវិបត្តិកើតឡើង មានមនុស្សពួកខ្លះ បានលះបង់គ្រួសារទៅរស់នៅក្នុងព្រៃ ត្រិះរិះពិចារណាធម៌ ដែលហៅថា ឈាយិកា ៗ នេះហើយដែលជាប្រភពនៃតាបសឬឥសី ដូចមានចេញឈ្មោះក្នុងអក្សរសាស្ត្រឬអក្សរសិល្ប៍ទាំងឡាយពីព្រេងនាយ ។

មានមនុស្សបុរាណ ១ ពួកទៀតចូលចិត្តរស់នៅជិតភូមិស្រុក គិតតាក់តែងគម្ពីរព្រាហ្មណ៍ឡើង ហៅថា ពួកអជ្ឈាយិកា ៗ នេះមានគ្រួសារ បន្តកូន-ចៅដូចមនុស្សធម្មតាដែរ ។ តាមអត្ថបទជាមនុស្សចំពួកនេះហើយ ដែលជាដើមកំណើតនៃពួកព្រាហ្មណ៍ ដែលបានបន្តពូជពង្សព្រាហ្មណ៍រហូតមកដល់បច្ចុប្បន្នកាលនេះ ។

ក៏បានលះបង់គ្រួសារបុត្រភរិយាទ្រព្យសម្បត្តិ មិនធ្វើការងារដូចអ្នកស្រុកទេ ពួកនេះហៅថា "សមណៈ" ប្រែថាពួកស្ងប់រំងាប់(១) ។

កាលព្រះអង្គទ្រង់ត្រាស់សម្ដែង អំពីកំណើតនៃពួកក្សត្រ ព្រាហ្មណ៍ វៃស្យៈ សូទ្រៈ និងសមណៈ ដូចបានពោលមកនេះហើយ ទើបទ្រង់ត្រាស់បញ្ជាក់ថា ក្សត្រក្ដី ព្រាហ្មណ៍ក្ដី វៃស្យៈក្ដី សូទ្រៈក្ដី សមណៈក្ដី ណាមួយតែប្រព្រឹត្តអំពើទុច្ចរិត ដោយកាយវាចាចិត្ត ដល់វេលាស្លាប់ទៅ ក្សត្រ ព្រាហ្មណ៍ វៃស្យៈ សូទ្រៈ និងសមណៈនោះ ៗ ក៏នឹងទៅកើតក្នុងអបាយទុគ្គតិវិនិបាតនរក ដូចគ្នាទាំងអស់ ។

ចំណែកឯអ្នកប្រព្រឹត្តល្អ ( សុចរិត ) ដោយកាយវាចាចិត្តវិញ ដល់វេលាស្លាប់ទៅ នឹងទៅកើតក្នុងគតិលោក ដែលមានអារម្មណ៍ល្អជាទីរីករាយ ( ដែលយើងហៅថា ឋានសួគ៌ ) បានដូចគ្នាដែរ ។

ឯអ្នកដែលធ្វើល្អខ្លះ អាក្រក់ខ្លះ លាយឡំគ្នា ទោះជាក្សត្រក្ដី ព្រាហ្មណ៍ក្ដី វៃស្យៈក្ដី សូទ្រៈក្ដី សមណៈក្ដី ដល់វេលាស្លាប់ទៅ ជួនបានទៅកើតជាមនុស្សក៏មានខ្លះ ទៅកើតជាសត្វតិរច្ឆានក៏មានខ្លះ ។ ឯអ្នកដែលធ្វើ ឯអ្នកដែលធ្វើអកុសលច្រើន កុសលតិច បើកុសល

---

១- តាមសេចក្ដីតំណាលនេះ ពួកសមណៈនោះកើតក្រោយពួកឈាយិកៈនិងអជ្ឈាយិកា ដែលជាដើមកំណើតនៃពួកព្រាហ្មណ៍ ។ ការធ្វើខ្លួនជាសមណៈគ្មានកំណត់វណ្ណៈអ្វីទេ គឺវណ្ណៈទាំង ៤ អាចចេញទៅបួសរស់នៅក្នុងព្រៃបំពេញកិច្ចការរបស់សមណៈ គឺចម្រើនសមណៈធម៌ មេត្តាភាវនា ជាដើម ។ ដូច្នោះហើយ បើគេឃើញច្រើនប្រទះអត្ថបទបាលីក្នុងគម្ពីរទាំងឡាយថា "សមណព្រាហ្មណា" ប្រែថា សមណៈនិងព្រាហ្មណ៍ទាំងឡាយ ។

ផ្តល់លទ្ធផលមុន កុសលក៏នាំទៅកើតក្នុងត្រកូលក្សត្រខ្លះ ព្រាហ្មណ៍ខ្លះ ៗ ទោះបីបានកើតក្នុងត្រកូលក្សត្រ ឬ ព្រាហ្មណ៍ បើអកុសលកម្មតាមផ្តល់លទ្ធផលផង ទឹងធ្វើឲ្យទៅជាខ្វាក់ក្អកក៏មាន ពិកពិការជើងដៃក៏មាន ជាគជាថ្លង់ក៏មាន ៗ ដល់វេលាស្លាប់ អកុសលមានកម្លាំងខ្លាំងក្លា ក៏នាំទៅកើតជាសត្វតិរច្ឆាន បើមានកុសលកម្មតាមជួយឧបត្ថម្ភគាំទ្រខ្លះ ក៏គ្រាន់តែឲ្យបានទៅជាដំរីមង្គលខ្លះ សេះមង្គលខ្លះ ឬ ជាគោមង្គលខ្លះ របស់ក្សត្រ ឬ របស់ព្រាហ្មណ៍ខ្លះប៉ុណ្ណោះ ៗ ដូច្នេះអ្នកដែលបានប្រព្រឹត្តទាំងកុសល ទាំងអកុសល ទោះបីបានទៅកើតជាមនុស្សក្តី ជាសត្វតិរច្ឆានក្តី តែងតែបានសេចក្តីសុខខ្លះ សេចក្តីទុក្ខលំបាកខ្លះជាធម្មតា ៗ

ឯអ្នកដែលធ្វើកុសលកម្មគឺអំពើល្អតែមួយយ៉ាង ដល់ស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ ៗ ឯអ្នកដែលធ្វើអកុសលកម្ម គឺអំពើអាក្រក់តែមួយយ៉ាង ដល់ស្លាប់ទៅ តែងទៅកើតក្នុងនរក(១) ៗ

---

១-លទ្ធិព្រាហ្មណនិយម ដែលធ្លាប់តែជឿប្រកាន់ត ។ គ្នាមកថា មានតែពូជពង្សព្រាហ្មណ៍ទេដែលខ្ពង់ខ្ពស់ប្រសើរជាង ពូជពង្សសាសន៍ជាតិដទៃទៀតទាំងអស់ ។

ឯពុទ្ធនិយមវិញ មានទស្សនៈផ្ទុយគ្នាស្រឡះ គឺព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ជាក់ទស្សនៈរបស់ព្រះអង្គយ៉ាងច្បាស់លាស់ថា តម្លៃរបស់មនុស្សគ្រប់សាសន៍ជាតិ គ្រប់ពណ៌សម្បុរ គ្រប់វណ្ណៈ មិនមែនឋិតនៅលើពូជសាសន៍ជាតិ ឬវណ្ណៈអ្វីឡើយ ។ សកម្មភាពល្អ-អាក្រក់ គុណសម្បត្តិ-គុណវិបត្តិ មានសមត្ថភាព ឬ គ្មានសមត្ថភាពដែលធ្វើឲ្យមនុស្សមានតម្លៃខុសប្លែកគ្នាខ្លះ ៗ ។

(លេខយោងតទៅទំព័រទី ៣១៤)

ផល់ចប់ព្រះពុទ្ធតម្រាស់ ដែលព្រះអង្គទ្រង់បានត្រាស់សម្តែងដល់ខ្ញុំនហើយ ទើបរាសេដ្ឋមាណពនិងការទ្វាជមាណព ក្រាបបង្គំទូលសរសើរ ព្រះពុទ្ធបដិភាណរបស់ព្រះអង្គ ដោយចិត្តសោមនស្សត្រេកអរយ៉ាងក្រៃលែង ។

# សន្នគចប់ អគ្គញ្ញាសូត្រត្រឹមប៉ុណ្ណោះ

ទស្សនៈពុទ្ធនិយមនេះ សូម្បីបានចាប់កំណើតឡើង កាលពីជាង ២៥ សតវត្សមកហើយក៏ដោយ ក៏នៅតែមានតម្លៃ សមហេតុសមផលជរាបមកដល់សព្វថ្ងៃនេះ ។ ហើយជាពិសេស ក្នុងពេលថ្មី ៗ នេះ លោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ទើបនឹងប្រកាសផ្សាយជាសាកលមិនឲ្យប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ដែលជាឧត្តមគតិស្របគ្នាទាំងស្រុងនឹងទស្សនៈពុទ្ធនិយមនេះ

# រឿងព្រះនាងសាមាវតី

លោក ញ៊ូ-ញ៊ូ រៀបរៀង

កាលព្រះសាស្តា ស្តេចអាស្រ័យនគរកោសម្ពី គង់នៅក្នុងឃោសិតារាម ទ្រង់ព្រះប្រារព្ធសេចក្តីស្លាប់និងសេចក្តីវិនាសនៃស្រីប្រាំរយនាក់ មានព្រះនាងសាមាវតីជាប្រធាន ព្រមទាំងញាតិរបស់ព្រះនាងមាគន្ទិយា ព្រះនាងមាគន្ទិយាជាប្រធាន ត្រាស់ព្រះធម្មទេសនានេះដែលមានពាក្យផ្តើមថា "សេចក្តីមិនប្រមាទជាផ្លូវមិនស្លាប់" ដូច្នេះជាដើម ។

និងពណ៌នាសេចក្តីក្នុងរឿងនោះតាមលំដាប់ដូចតទៅនេះ :

ក្នុងអតីតកាល មានព្រះរាជាពីរព្រះអង្គ គឺព្រះបាទអល្លកប្បៈ សោយរាជ្យក្នុងអល្លកប្បរដ្ឋមួយព្រះអង្គ ព្រះបាទវេដ្ឋទីបកៈ សោយរាជ្យក្នុងវេដ្ឋទីបករដ្ឋមួយព្រះអង្គ ទាំងពីរព្រះអង្គនេះជាសម្លាញ់និងគ្នាតាំងពីកុមារមក ទ្រង់សិក្សាសិល្បៈក្នុងត្រកូលអាចារ្យជាមួយគ្នា ដោយការកន្លងទៅនៃព្រះជនករបស់ព្រះអង្គ ៗ បានជាព្រះរាជាគ្រប់គ្រងស្វេតច្ឆត្រក្នុងដែនប្រមាណដប់យោជន៍ៗ ។ ស្តេចទាំងពីរព្រះអង្គនោះតែងស្តេចទៅមកជួបគ្នាជារឿយ ៗ ស្តេចឈរគង់ផ្ទុំជាមួយគ្នា ឃើញមហាជនកើតនិងស្លាប់ ហើយប្រឹក្សាគ្នាថា ឈ្មោះថារបស់ដែលជាប់តាមអ្នកទៅកាន់បរលោកមិនមានទេ ដោយហោចទៅសូម្បីតែរាងកាយរបស់ខ្លួនក៏ត្រូវលះបង់ចោលទាំងអស់ ប្រយោជន៍អ្វីដោយឃរាវាសរបស់ពួកយើងៗនឹងបួស ហើយទ្រង់ប្រគល់រជ្ជសម្បត្តិដល់ព្រះឱរសនិងព្រះជាយា ទ្រង់ព្រះផ្នួសជាឫសីនៅក្នុង

ប្រទេសព្រហ្មពាន្តប្រឹក្សាគ្នាទៀតថា យើងទាំងពីរនាក់លះបង់ចោលរាជសម្បត្តិចេញមកបួស មិនមែនមិនអាចនឹងចិញ្ចឹមជីវិត បានហើយទើបចេញមកបួសទេ កាលបើយើងនៅក្នុងទីកន្លែងជាមួយគ្នា ក៏មិនប្លែកអ្វីអំពីគ្រហស្ថដែរ ព្រោះដូច្នោះយើងនឹងនៅមួយចំណែកម្នាក់ លោកនៅលើភ្នំនោះ ខ្ញុំនឹងនៅលើភ្នំនេះ ប៉ុន្តែដល់កន្ទះខែក្នុងថ្ងៃឧបោសថនឹងនៅរួមគ្នា ។ ខាងក្រោយមក លោកទាំងពីររូបនឹករិតក្កថា សូម្បីយ៉ាងនេះ សេចក្តីប្រឡូកប្រឡំ ដោយពួករបស់យើង ក៏គង់តែនៅមានជាប្រាកដ ទើបមូលចិត្តគ្នាជាថ្មីថា លោកគប្បីអុជភ្លើងទុកលើភ្នំរបស់លោក ខ្ញុំនឹងអុជភ្លើងទុកលើភ្នំរបស់ខ្ញុំ ទីងដឹងអាការដែលនៅមានជីវិតដោយគ្រឿងសម្គាល់នោះ ។ លោកធ្វើគ្រប់គ្នាតាមកតិកានោះហើយ ។

ចំណេរមកខាងក្រោយ វេដ្ឋទីបកតាបសធ្វើកាលៈហើយទៅកើតជាទេវតាជាព្រះរាជមានសក្តិធំ ។ លំដាប់នោះ លុះដល់កន្ទះខែ អល្លកប្បតាបសមិនឃើញ (ពន្លឺ) ភ្លើង ក៏បានដឹងច្បាប់ថា សម្លាញ់របស់អញធ្វើកាលៈទៅហើយ ។ សូម្បីទេវតាជាព្រះរាជាសំឡឹងមើលសិរីភាពជាទេវតារបស់ខ្លួនហើយ ទើបពិចារណាមើលកម្ម (របស់ដែលធ្វើទុក) ឃើញកិរិយាដែលខ្លួនធ្វើចាប់ដើមអំពីចេញបួសហើយគិតថា អញនឹងទៅសួរសម្លាញ់របស់អញឥឡូវនេះ ហើយលះបង់អត្តភាពនោះចេញ (ធ្វើ) ជាមនុស្សធ្វើដំណើរផ្លូវទៅកាន់សំណាក់ព្រះអល្លកប្បតាបសនោះ សំពះហើយឈរនៅចំណែកម្ខាង ។

លំដាប់នោះ ព្រះអល្លកប្បតាបសសួរថា អ្នកមកអំពីណា ?

ទេវពជ- ខ្ញុំជាមនុស្សវេទ្ធនិងខ្ញុំមកអំពីឆ្ងាយណាស់លោកម្ចាស់ ចុះលោកតែម្នាក់ឯងទេឬដែលនៅក្នុងទីនេះ ឬ មានមនុស្សឯទៀតខ្លះដែរលោកម្ចាស់ ?

ព្រះតាបស- មានសម្លាញ់របស់អាត្មាម្នាក់ (ផង) ។

ទេវពជ- ចុះគេនៅទីណា ?

ព្រះតាបស- នៅលើភ្នំនោះ ប៉ុន្តែ កាលថ្ងៃឧបោសថមិនបានអុជភ្លើង ប្រហែលជាស្លាប់ហើយមើលទៅ ។

ទេវពជ- យ៉ាងនោះឬ លោកម្ចាស់ ?

ព្រះតាបស- យ៉ាងនោះហើយ អ្នកមានអាយុ ។

ទេវពជ- ខ្ញុំគឺគេនោះឯងហើយ លោកម្ចាស់ ។

ព្រះតាបស- អ្នកទៅកើតទីណា ?

ទេវពជ- ខ្ញុំទៅកើតជាទេវពជមានសក្តិធំក្នុងទេវលោក ខ្ញុំមកដោយតាំងចិត្តថា នឹងសួរ (យើញ) លោកម្ចាស់ កាលលោកម្ចាស់នៅក្នុងទីនេះ មានអន្តរាយអ្វីៗខ្លះដែរឬទេ ?

ព្រះតាបស- តើអ្នកមានអាយុ អាត្មាត្រូវលំបាកព្រោះអាស្រ័យដំរីៗ

ទេវពជ- ចុះដំរីវាធ្វើអ្វីដល់លោកម្ចាស់ ?

ព្រះតាបស- វាជុះអាចម៍ក្នុងឋានជាទីបោស យកជើងឈូសហើយកាយអាចម៍ដីឡើង កាលអាត្មាជញ្ជូនអាចម៍ទៅចោល គៀរដីឲ្យស្មើក៏លំបាក ។

ទេវកដ- ចុះលោកប្រាថ្នាមិនឲ្យពួកវាមកឬទេ ?

ព្រះតាបស- អើ ! អាវុសោ ។

ទេវកដ- បើដូច្នោះ ខ្ញុំនឹងធ្វើមិនឲ្យពួកវាមក ទេវកដពោលដូច្នេះហើយ បានឲ្យពិណនិងមន្តដែលដំរីចូលចិត្តដល់ព្រះតាបស កាលឲ្យបានបង្ហាញខ្សែពិណបីខ្សែឲ្យព្រះតាបសរៀនមន្តបីបទហើយពន្យល់វិធីថា កាលលោកដេញខ្សែនេះវាយ (អាន) មន្តបទនេះ ហ្វូងដំរីមិនអាចដើម្បីនឹងត្រឡប់ងាកមើល បោលទៅ កាលលោកដេញខ្សែនេះ វាយមន្តបទនេះ ហ្វូងដំរីនឹងត្រឡប់ងាកមើលខាងក្រោយ បោលទៅ កាលលោកដេញខ្សែនេះ វាយមន្តបទនេះ ដំរីជាមេខ្វាងនឹងបង្អោនខ្លួនចូលមករកដូច្នេះហើយ ពោលថា លោកពេញចិត្តបែបណា គប្បីធ្វើបែបនោះចុះ សំពះលាព្រះតាបសហើយចៀសចេញទៅហើយ ។

ព្រះតាបសវាយមន្តបទសម្រាប់បណ្ដេញ ដេញខ្សែពិណសម្រាប់បណ្ដេញឲ្យរត់ទៅ ញ៉ាំងហ្វូងដំរីឲ្យរត់ចេញទៅហើយ ។

សម័យនោះ ព្រះម្ចាស់ផែនដីមួយអង្គព្រះនាមថា បរន្តបៈ គ្រប់គ្រងនគរកោសម្ពី ។ ថ្ងៃមួយ ព្រះអង្គព្រមដោយព្រះទេវីមានព្រះគភ៌គង់នៅលើផ្ទៃកណ្ដាលវាល ទ្រង់អាំងកំដៅថ្ងៃ ។ ព្រះទេវីទ្រង់ដណ្ដប់ព្រះកូសាកម្ពលពណ៌ក្រហមដ៏មានតម្លៃមួយសែន ដែលនៅកូសាសម្រាប់ទ្រង់របស់ព្រះម្ចាស់ផែនដីហើយគង់ស្រាស់សន្ទនានឹងព្រះរាជា ហូតព្រះ

ទំរង់មានតម្លៃមួយសែនចេញពីព្រះអង្គុលីព្រះរាជា ហើយទ្រង់ពាក់ក្នុងអង្គុលីរបស់ខ្លួន ។

សម័យនោះ សត្វហត្ថលិង្គហើរមកតាមអាកាសឃើញព្រះទេវីដោយសេចក្ដីស្មានសម្គាល់ថាដុំសាច់ ទើបសំឡេចស្លាបចាំងពីលើចោះពួយចុះមក (ឆាប) ។ ព្រះរាជាទ្រង់ស្គុត (ព្រះហឫទ័យ) ព្រោះសូរចោះពួយរបស់វា ទ្រង់ក្រោកចូលក្នុងព្រះរាជនិវេសន៍ (ទីកំបាំង) ។ ព្រះទេវីមិនអាចនឹងស្ដេចទៅដោយរហ័សបានព្រោះគភ៌ចាស់ខែនឹងទ្រង់ខ្លាចខ្លាំង ។ លុះសត្វនោះឆាបបានព្រះនាងក្ដាប់ទានទុកក្នុងរង្វង់ក្រចក ហើយហើរទៅកាន់អាកាស ។ ន័យថា សត្វពួកនោះទ្រទ្រង់ (ស្មើ) កម្លាំងដំរីប្រាំក្បាល ហេតុនោះ វានាំសត្វអ្វី ៗ ទៅតាមអាកាសហើយ (ច្រើនតែ) ទំក្នុងទីដែលចូលចិត្តចឹកសាច់ស៊ី ។ ឯព្រះទេវីនោះ ត្រូវវានាំទៅ ខ្លាចអំពីមរណភ័យទ្រង់ព្រះចិន្ដាថា បើអញស្រែកឡើង ធម្មតាសម្លេងមនុស្សរមែងជាទីតាំងនៃសេចក្ដីញាប់ញ័ររបស់សត្វតិរច្ឆាន វាបានឮសម្លេង(អញ) ហើយនឹងទម្លាក់អញចោល កាលបើដូច្នោះ អញក៏នឹងដល់នូវជីវិតក្ស័យព្រមទាំងបុត្រក្នុងគភ៌ ប៉ុន្តែវា (បន្ទាបចុះ) ទំក្នុងទីណា រៀបនឹងចឹកអញស៊ី អញនឹងបន្លឺសម្លេងដេញវាឲ្យរត់ទៅក្នុងទីនោះ ព្រះនាងទ្រង់អត់សង្កត់ព្រះហឫទ័យទុកបាន ព្រោះព្រះនាងមានបញ្ញាឈ្លាសវៃ ។ ក្នុងគ្រានោះ ក្នុងប្រទេសព្រៃហិមពាន្ត មានជ្រៃធំមួយដើមដុះឡើងបន្តិចហើយប្រតិស្ឋានទៅដោយអាការនៃមណ្ឌប ។ សត្វនោះវានាំម្រឹគជាដើមទៅស៊ី

គ្រន់ដើមជ្រៃនោះ ជានិច្ច ដូច្នោះវាទើបនាំព្រះទេវីនោះទៅទីនោះទៀត ដាក់ទុកក្នុងចន្លោះប្រគាបហើយ ងាកមើលផ្លូវដែលហើរមក ៗ ន័យថា ជាធម្មតារបស់ពួកវា ខណៈនោះ ព្រះទេវីទ្រង់ព្រះចិន្តាថា គួរដេញអាសត្វនេះឲ្យវារត់ឥឡូវនេះ ហើយទ្រង់លើកព្រះហស្តទាំងពីរឡើង ធ្វើសម្លេងបាតព្រះហស្តនិងសម្លេងតាមព្រះឱស្ឋ (ទះព្រះហស្តផង ស្រែកកំទរផង) ឲ្យវារត់ទៅហើយ លុះវេលាព្រះអាទិត្យអស្តង្គត ខ្យល់កម្មជវាត (ខ្យល់កើតអំពីកម្ម) ក្នុងព្រះគភ៌របស់ព្រះនាងក៏រើកហើយ មហាមេឃតាំងឡើង សម្លេងផ្គរលាន់គ្រប់ទិស ៗ ពពួកមហេសក្ខតាំងនៅក្នុងសេចក្តីសុខ (ដល់គ្រា) មិនបានត្រឹមតែពាក្យល្អលោមថា កុំខ្លាចឡើយព្រះម្ចាស់ មានទុក្ខខាងមុខ មិនបានទ្រង់ផ្ទំលក់សោះឡើយ រហូតដល់ព្រឹកឡើង កាលរាត្រីភ្លឺ ពលាហកកាំងទៅព្រមទាំងអរុណរះឡើង ព្រះឱរសក្នុងព្រះគភ៌របស់ព្រះនាងប្រសូតិ បានមានក្នុងខណៈតែមួយជាមួយគ្នា ៗ ព្រះនាងទើបទ្រង់ឲ្យព្រះនាមព្រះឱរសថា ឧទេន ព្រោះប្រសូត្រជាប់ទាក់ទងនឹងរដូវមេឃនិងវេលាអរុណរះឡើង ៗ

ទីលំនៅរបស់ព្រះអល្លកប្បតាបសមិនឆ្ងាយអំពីទីនោះទេ ៗ តាមប្រក្រតីក្នុងថ្ងៃភ្លៀងធ្លាក់ លោកមិនបានចូលទៅកាន់ព្រៃ ដើម្បីត្រូវការផលផលាផលទេ ព្រោះខ្លាចត្រជាក់ ទៅកាន់គល់ឈើនោះ រើសឆ្អឹងសត្វដែលសត្វស៊ីសាច់ហើយ យកមកដាំស្ងោរហុតរសដូច្នោះ សូម្បីថ្ងៃនោះលោកក៏បានទៅក្នុងទីនោះ ដោយប្រាថ្នានឹងរើសឆ្អឹងយកមក កំពុងតែរក

ផ្អឹងនៅគល់ឈើ បានឮសំឡេងទាក (ស្រែក) ខាងលើ ទើបងើយឡើង មើលឃើញព្រះទេវីហើយសួរថា អ្នកជាអ្វី កាលព្រះទេវីត្រាស់តបថា ខ្ញុំជាមនុស្សទើបសួរតទៅទៀតថា មកយ៉ាងណាបាន កាលព្រះទេវីទ្រង់បន្ទូលហេតុថា សត្វហត្ថលិង្គនាំខ្ញុំមក ទើបពោលដឹកនាំថាអញ្ជើញចុះមក ។

ព្រះទេវី– លោកម្ចាស់ ខ្ញុំខ្លាចអំពីជាតិប្រឡូកប្រឡំគ្នា ។

ព្រះតាបស– ជាជាតិអ្វី ?

ព្រះទេវី– ខ្ញុំជាក្សត្រ ។

ព្រះតាបស- សូម្បីអាត្មាក៏ជាក្សត្រដូចគ្នា ។

ព្រះទេវី– បើដូច្នោះ សូមអញ្ជើញពោលមាយានៃក្សត្រ ។

លោកបានពោលហើយ ។ ព្រះទេវីទើបត្រាស់ថា បើដូច្នោះ សូមលោកឡើងមកទទួលទារកតូចរបស់ខ្ញុំចុះទៅផង ។ លោកធ្វើផ្លូវសម្រាប់ឡើងទៅដោយខាងម្ខាង ទទួលព្រះរាជទារក កាលព្រះទេវីត្រាស់ថា កុំយកដៃពាល់ត្រូវខ្ញុំ មិនពាល់ត្រូវព្រះនាងឡើយ នាំព្រះរាជទារកចុះមកហើយ សូម្បីព្រះទេវីក៏ស្ដេចចុះមកហើយដែរ ។ ទើបព្រះអល្លកប្បតាបសនាំព្រះនាងទៅកាន់អាស្រមបទហើយ មិនធ្វើសីលភេទ (ទំលាយសីល) ចិញ្ចឹមដោយសេចក្ដីអនុគ្រោះ រកទឹកឃ្មុំដែលប្រាសចាកកូនឃ្មុំមក បេះស្រូវសាលីដែលកើតឯងយកមកដាំបបរឲ្យ ។ កាលលោកចិញ្ចឹមដោយអាការយ៉ាងនេះ ខាងក្រោយព្រះនាងទ្រង់ព្រះចិន្តាថា : ផ្លូវដែលមកនឹងផ្លូវ

ទៅអញមិនដឹងសោះឡើយ តាំងអញមិនមានសូម្បីតែសេចក្តីស្និទ្ធស្នាល នឹងព្រះតាបសនេះផង កំណាកនេះនឹងបោះបង់ចោលអញទៅទីណាបាត់ហើយ អញនឹងត្រូវតែស្លាប់ក្នុងទីនេះទាំងពីរនាក់ គួរតែអញនឹងធ្វើកិរិយាយ៉ាងណាមួយហើយទំលាយសីលលោកនេះចេញ ធ្វើឲ្យបោះបង់ចោលអញមិនរួច ។ តមកបានទ្រង់ប្រលោមលួងលោមលោកដោយសម្តែងព្រះកូសាស្មៀកដណ្តប់ផុតៗ របូត ៗ ញ៉ាំងព្រះតាបសឲ្យដល់សីលវិនាសហើយ ។ តាំងអំពីនោះមក ទាំងពីរនាក់បានទៅសមគ្គសង្វាសនឹងគ្នាហើយ ។

ខាងក្រោយថ្ងៃមួយ ព្រះតាបសពិចារណាមើលផ្លូវចរផ្កាយនក្សត្រ ឃើញដួងផ្កាយនក្សត្ររបស់ព្រះបាទបរន្តបៈសៅហ្មងហើយពោលថា នាងចម្រើន ព្រះបាទបរន្តបៈក្នុងនគរកោសម្ពីទីវង្គតហើយ ។

ព្រះទេវី– ព្រោះហេតុអ្វីបានជាលោកម្ចាស់និយាយយ៉ាងនេះ លោកមានសេចក្តីគំនុំនឹងព្រះអង្គ ឬ ?

ព្រះតាបស– មិនមានទេនាង យើងឃើញផ្កាយនក្សត្ររបស់ព្រះអង្គសៅហ្មងបានជាយើងនិយាយយ៉ាងនេះ ។

ព្រះនាងទ្រង់ព្រះកន្សែងហើយ ។ ទីនោះ ព្រះតាបសសួរថា ម៉េចក៏យំ កាលព្រះនាងប្រាប់អាការដែលព្រះពជានោះជាព្រះស្វាមីរបស់ខ្លួនហើយលួងលោមថា កុំយំថ្វីឡើយនាង ធម្មតាអ្នកដែលកើតមកហើយមានសេចក្តីស្លាប់ទៀងទាត់ណាស់ ។

ព្រះទេវី- ដឹងហើយ លោកម្ចាស់ ។

ព្រះតាបស- បើដឹងហើយ ហេតុអ្វីក៏យំ ?

ព្រះទេវី- ធរាសរបស់ខ្ញុំសមគួរដល់រាជសម្បត្តិរបស់ត្រកូល បើកូនទៅក្នុងនគរនោះ នឹងបានតម្រង់សេតច្ឆត្រ (ស្នងព្រះបិតា) ឥឡូវនេះមានសេចក្ដីវិនាសធំហើយហ្ន៎ ខ្ញុំយំព្រោះសេចក្ដីសោកដូច្នេះទេតើលោកម្ចាស់ ។

ព្រះតាបស- ឈប់ចុះប្អូនកុំគិតឡើយ បើប្រាថ្នារាជសម្បត្តិដល់កូនហើយ យើងនឹងធ្វើអាការដែលបានដល់កូន ។

ព្រះទេវី- បើយ៉ាងហ្នឹង ប្រពៃហើយ លោកម្ចាស់ ។

ព្រះតាបស- តើយ៉ាងហ្នឹងហើយនាង ។ លំដាប់នោះ ព្រះតាបសបានឲ្យពិណនិងមន្ត ដែលដំរីចូលចិត្ត ដល់ព្រះរាជកុមារហើយ ។ គ្រានោះ ដំរីជាច្រើនសែនមកប្រជុំគ្នាត្រង់គល់ជ្រៃមួយ ។ ទើបព្រះតាបសប្រាប់ព្រះរាជកុមារថា កាលបើដំរីរាំមិនទាន់មក ទៅចូរឡើងដើមជ្រៃ កាលបើហ្វូងរាំមកហើយ ចូរកាយមន្តបទនេះ ដេញខ្សែពិណនេះ ហ្វូងរាំទាំងអស់មិនអាច សូម្បីនឹងបែរងាកមើល នឹងបោលរត់ទៅ កាលបើដូច្នោះ ទៅគប្បីចុះមក ។ ព្រះរាជកុមារនោះទ្រង់ធ្វើតាមយ៉ាងនោះហើយ ស្ដេចត្រឡប់មកប្រាប់ប្រព្រឹត្តិហេតុនោះ ។ លុះដល់ថ្ងៃទីពីរ ព្រះតាបសប្រាប់ព្រះរាជកុមារថា ថ្ងៃនេះ ទៅចូរកាយមន្តបទនេះ ដេញខ្សែពិណនេះ ដំរីទាំងឡាយនឹងបែរងាកមើលខាងក្រោយបោលរត់ទៅ ។

កំគ្រានោះ ព្រះរាជកុមារបានទ្រង់ធ្វើតាមបង្គាប់ ហើយស្ដេចត្រឡប់មក ប្រាប់ប្រព្រឹត្តិហេតុនោះ ៗ លំដាប់នោះ ព្រះតាបស បានហៅព្រះមាតារបស់ព្រះរាជកុមារមកហើយប្រាប់ថា នាងចូរឲ្យបណ្ដាំដល់ព្រះឱរសរបស់នាង ព្រះឱរសទៅអំពីនេះហើយ នឹងបានជាព្រះរាជា ៗ ព្រះនាងត្រាស់ហៅព្រះឱរស (មក) ហើយត្រាស់ប្រាប់ថា នែកូន ឯងជាព្រះឱរសព្រះបាទបរន្តបៈក្នុងនគរកោសម្ពី សត្វហត្ថលិង្គនាំមាតាមកព្រមទាំងឯងទៅក្នុងគតិ ហើយត្រាស់ប្រាប់នាមសេនាបតីជាដើម ត្រាស់ផ្ដាំតទៅទៀតថា កាលបើគេមិនជឿ ឯងគួរបង្ហាញសំពត់កម្ពលសម្រាប់ទ្រង់នឹងព្រះទម្រង់គ្រឿងពាក់របស់ព្រះបិតានេះ ហើយទ្រង់បញ្ជូនទៅ ៗ ព្រះរាជកុមារទ្រង់ត្រាស់នឹងព្រះតាបសថា ឥឡូវនេះ ខ្ញុំនឹងត្រូវធ្វើយ៉ាងណា ៗ

ព្រះតាបស— អ្នកចូរអង្គុយលើមែកឈើទាប ៗ ហើយពាយមន្តបទនេះ ដេញខ្សែពិណានេះ ដំរីមេខ្លាំងនឹងបង្អោនខ្នងចូលមករកអ្នកអង្គុយលើខ្នងវា នៅយករាជ្យសម្បត្តិ ៗ

គ្រានោះព្រះរាជកុមារនោះ ថ្វាយបង្គំព្រះមាតានិងព្រះបិតាហើយទ្រង់ធ្វើយ៉ាងនោះ កាលដំរីមកហើយ គង់លើខ្នងត្រាស់ប្រាប់ត្រចៀកថា យើងជាឱរសព្រះបាទបរន្តបៈក្នុងនគរកោសម្ពី ឯងជួយចាត់ការ យករាជ្យសម្បត្តិរបស់ព្រះបិតាឲ្យដល់យើងផង ៗ វាបានឮរឿងនោះហើយ ពេទ៍ជាសម្មេង ដំរីថា ដំរីច្រើនពាន់ប្រជុំគ្នាចុះ ៗ

ដំរីទាំងឡាយបានប្រជុំគ្នាជាច្រើនពាន់ ៗ ក៏ស្រែកពេទ៍ប្រាប់ម្តងទៀតថា បណ្តាដំរីចាស់ ៗ ត្រឡប់ទៅវិញបាន ៗ ដំរីចាស់ទាំងឡាយត្រឡប់ទៅហើយ ៗ ដំរីមេខ្មៅនិងស្រែកពេទ៍ប្រាប់ម្តងទៀតថា បណ្តាដំរីនៅក្មេងពេកត្រឡប់វិញបាន ៗ ដំរីទាំងនោះនាំគ្នាត្រឡប់ហើយ ៗ ព្រះរាជកុ-មារដែលមានដំរីជាច្រើនពាន់ហោមរោមជាយោធា ស្តេចដល់ស្រុកក៏តាំងនៅជាយខែត្រដែន (ព្រះនគរ) ហើយ ទ្រង់ប្រកាសបបួលថា យើងជាឱរសព្រះរាជា អ្នកប្រាថ្នាសម្បត្តិចូរមកជាមួយនឹងយើងចុះ ទ្រង់ធ្វើសេចក្តីកៀរគរមនុស្សតាំងអំពីស្រុកនោះមក ស្តេចដល់ហើយទើបឡោមព័ទ្ធនគរហើយ ទ្រង់បញ្ជូនសាសន៍ទៅ សេចក្តីជាខជាប់ខាតថា ត្រូវឲ្យការច្បាំង ឬ រជ្ជសម្បត្តិដល់ខ្ញុំ (យ៉ាងណាមួយ) ៗ អ្នកនគរទាំងឡាយឆ្លើយថា ពួកយើងខ្ញុំនៅមិនទាន់ឲ្យបានទាំងពីរប្រការ ព្រោះព្រះទេវីទ្រង់ព្រះគភ៌ចាស់ខែរបស់យើងខ្ញុំទាំងឡាយ ត្រូវសត្វហត្ថលិង្គឧាបឆក់យកទៅអង្គព្រះនាងនៅមានព្រះជន្មជីព ឬ អស់ព្រះជន្ម ក៏មិនទាន់បានដឹង ពួកយើងខ្ញុំនឹងឲ្យការច្បាំង ឬ រជ្ជសម្បត្តិមិនទាន់បានទេ រហូតវេលាដែលមិនទាន់បានដឹងប្រព្រឹត្តិហេតុរបស់ព្រះនាង ៗ ន័យថា ការជាព្រះរាជាតាមខែ្សព្រះវង្សបានមានឡើងក្នុងគ្រានោះ ៗ លំដាប់នោះ ព្រះរាជកុមារទើបទ្រង់កាយកប់ប្រាប់ថា ខ្ញុំឯងជាឱរសរបស់ព្រះនាង ហើយទ្រង់ហៅនាមនៃសេនាបតីជាដើម កាលបើគេមិនជឿដោយវិធីយ៉ាងនោះ ទ្រង់បង្ហាញសម្ពត់ត្រកម្ពលនិងព្រះធម្រង់ ៗ អ្នកនគរទាំងឡាយចាំសម្ពត់

រត្តកម្ពលនិងព្រះទម្រង់បាន អស់សេចក្តីសង្ស័យ ហើយបើកទ្វាររាំង អភិ-សេកព្រះរាជកុមារក្នុងភាពជាព្រះរាជាហើយ ។

នេះសេចក្តីកើតឡើងនៃព្រះបាទឧទេនមុន ។

ក៏កាលទុព្ភិក្ខភ័យកើតៈឡើងក្នុងអល្លកប្បរដ្ឋ មនុស្សប្រុសម្នាក់ឈ្មោះកោតុហលិក: មិនអាចដើម្បីនឹងចិញ្ចឹមជីវិត ទើបនាំភរិយាឈ្មោះកាលីមានកូមខ្ចី តាំងចិត្តថានឹងទៅរកស៊ីចិញ្ចឹមជីវិតក្នុងនគរកោសម្ពីដាក់ស្បៀងចេញដំណើរទៅ ។ លោកខ្លះពោលថា កាលមហាជនកំពុងតែស្លាប់ព្រោះអហិវាតករោគ គេទើបនាំគ្នាចេញរត់ទៅក៏មាន ។ គេនាំគ្នាដើរទៅ លុះអស់ស្បៀងហើយ គឺសេចក្តីស្រេកឃ្លានបៀតបៀនហើយ មិនអាចនឹងនាំទារកទៅបាន ។

លំដាប់នោះ ស្វាមីនិយាយនឹងភរិយាថា ប្អូនស្រីចំរើន កាលយើងនៅមានជីវិត គង់តែនឹងបានបុត្រទៀត យើងចោលវាទៅចុះ ។

ធម្មតាហឫទ័យរបស់មាតាទន់ ព្រោះដូច្នោះ នាងទើបឆ្លើយតបថាខ្ញុំមិនអាចនឹងចោលបុត្រដែលនៅទាំងរស់បានទេ ។

ស្វាមី– បើដូច្នោះ នឹងធ្វើយ៉ាងណា ?

ភរិយា – យើងផ្លាស់ប្តូរគ្នានាំវាទៅ ។

មាតា ដល់វារៈរបស់ខ្លួន លើកបុត្រនោះឡើងហាក់ដូចជាកួងផ្កាចំឡែក (ឧបទុម) គ្រង់ទ្រូងហើយនាំទៅ ដោយបង្កើះឲ្យដល់បិតា ។ សូម្បីព្រោះសេចក្តីឃ្លានក្នុងទីដែលគេទទួលបុត្រដាក់ទុកហើយ ៗ វេទនា

កើតឡើងដល់គេជាខ្លាំង គេទើបនិយាយនឹងភរិយានោះហើយ ៗ ញយៗ ថា នាងចំរើន កាលបើយើងនៅមានជីវិត គង់តែនឹងបានបុត្រទៀត ៗ យើងបោលវាទៅចុះ ៗ ឯភរិយានោះក៏បានហាមឃាត់ជាច្រើនដងច្រើនគ្រា (តមក) នាងទើបនៅស្ងៀម ៗ ទារកត្រូវគេផ្លាស់ប្តូរគ្នាទៅមកអស់កម្លាំងហើយដេកលក់នៅដៃបិតា ៗ គេដឹងអាការដែលទារកនោះដេកលក់ហើយ ឲ្យមាតាដើរទៅខាងមុខ ដាក់បុត្រនោះឲ្យដេកលើកម្រាលស្លឹកឈើ ខាងក្រោមគល់ឈើមួយគុម្ព ដើរតទៅហើយ ៗ មាតាងាកមកមើលមិនឃើញបុត្រហើយ សួរថា អ្នកប្តីបុត្រខ្ញុំទៅណា ?

បិតា– អញដាក់ឲ្យដេកក្រោមគុម្ពឈើមួយគុម្ព ៗ

ភរិយា– អ្នកប្តីកុំញ៉ាំងខ្ញុំឲ្យវិនាសឡើយ បើខ្ញុំវៀរ(ប្រាសពី) បុត្រហើយ មិនអាចនឹងរស់នៅបានទេ ចូរទៅនាំបុត្រមកឲ្យខ្ញុំ នាងពោលដូច្នេះហើយគក់ទ្រូងទួញយំ ៗ

លំដាប់នោះ ស្វាមីត្រឡប់ទៅនាំយកបុត្តនោះមក ៗ ឯបុត្រក៏បានស្លាប់បាត់បង់ក្នុងចន្លោះផ្លូវហើយ ៗ នាយកោតុហលិកបិតាបោលបុត្រក្នុងទីមានប្រមាណប៉ុណ្ណោះឯង ក្នុងកពជាលំដាប់ត្រូវគេបោលដល់ ៧ ដងព្រោះផលនៃកម្មនោះ ៗ ឈ្មោះថាកម្មដ៏លាមកនេះ មិនគួរមើលងាយថាមានប្រមាណតិចទេ ៗ គេទាំងពីរនាក់នោះ ធ្វើដំណើរទៅដល់ត្រកូលនាយគោបាល (អ្នករក្សាគោ) មួយកន្លែង ៗ

ក្នុងថ្ងៃនោះ នាយគោបាលមានបុណ្យធេនុមង្គល ( ការមង្គល

ដែលគេធ្វើព្រោះមេគោគ្រមុំជាហេតុ) ។ ព្រះបច្ចេកពុទ្ធមួយអង្គចាត់ក្នុងផ្ទះនាយគោបាលជានិច្ច (សម្គាល់សេចក្ដីថា បដិគាហកគ្រប់គ្រគ្រូលទទួលអាហារបិណ្ឌបាត្រទីនោះរាល់ថ្ងៃទៅ) ។ គេនិមន្តលោកឲ្យឆាន់ហើយ បានធ្វើការមង្គល ។ គេគាត់តែងបាយបាយាសទុកជាច្រើន ។ នាយគោបាលឃើញអ្នកទាំងពីរដើរមក ទើបសួរថា មកអំពីណា ដឹងសេចក្ដីប្រព្រឹត្តទៅទាំងពួងហើយ ជាមនុស្សមានចិត្តអាណិតអាសូរ ធ្វើសេចក្ដីអនុគ្រោះក្នុងគេហើយ ប្រើបម្រើឲ្យ ។ បាយបាយាសព្រមដោយសប្បិល្មមគ្រាន់ ។ ភរិយាទើបនិយាយនឹងស្វាមីថា អ្នកថ្លៃ កាលបើអ្នកនៅរស់ ខ្ញុំក៏បានឈ្មោះថានៅរស់ដែរ អ្នកមានចំពោះជាច់ខាត (ចាកអាហារ) មកយូរ អញ្ជើញពិសាតាមត្រូវការចុះ ហើយចាប់យកបាយបាយាស ព្រមដោយសប្បិដាក់ទុកចំពោះមុខគេ ខ្លួនឯងបរិភោគសប្បិសាបៗ តែបន្តិចបន្តួចប៉ុណ្ណោះ ។ ស្វាមីបរិភោគច្រើនហើយ នៅតែមិនអាចកាត់ចំណង់ក្នុងអាហារបាន ព្រោះសេចក្ដីខ្វាចមកអស់ ៧,៨ ថ្ងៃ ។ នាយគោបាលប្រើបម្រើឲ្យយកបាយបាយាសឲ្យគេពីរនាក់ហើយ ចាប់ផ្ដើមបរិភោគខ្លួនឯង ។ នាយគោតុហលិកអង្គុយមើលគេ ឃើញនាយគោបាលពូតដុំបាយបាយាសឲ្យមេសុនខ ដែលដេកនៅក្រោមជើងតាំង នឹកក្នុងចិត្តថាសុនខនេះមានបុណ្យបានភោជនបែបនេះជានិច្ច ។ ក្នុងចំណែករាត្រី គេមិនអាចញ៉ាំងបាយបាយាសនោះឲ្យរលួយទៅបានធ្វើកាលៈហើយ កើតក្នុងផ្ទៃមេសុនខនោះ ។ លុះភរិយាគេធ្វើការបញ្ចុះសពរួចហើយ ធ្វើ

ការឈ្នួលនៅក្នុងផ្ទះនោះឯង បានអង្ករមួយនាឡិដាំបាយហើយ ដាក់ក្នុងបាត្រព្រះបច្ចេកពុទ្ធពោលឧទ្ទិសថា លោកម្ចាស់ សូមផលបុណ្យចំណែកនេះ នឹងដល់ទៅតាសៈរបស់លោកម្ចាស់ ហើយនឹកថា អញគួរតែនៅក្នុងផ្ទះនេះឯង លោកម្ចាស់ លោកមកទីនេះជាប់ជានិច្ច ទេយ្យធម្មតែមានឬមិនមានក៏ដោយ កាលអញថ្វាយបង្គំធ្វើវេយ្យាវច្ចករ ញ៉ាំងចិត្តឲ្យជ្រះថ្លារាល់ថ្ងៃ គង់តែនឹងបានទទួលបុណ្យច្រើនដូច្នេះ ហើយនាងនៅធ្វើការឈ្នួលក្នុងផ្ទះជាប្រាកដ ។

មេសុនខនោះឯងសម្រាលកូនសុនខឈ្មោលតែមួយគត់ ក្នុងថ្ងៃខែទី ៦ ឬ ទី ៧ ។ នាយគោបាលឲ្យបម្រើឲ្យទឹកដោះស្រស់មេគោក្រមុំមួយដល់វា ។ វាចម្រើនធំហើយអស់កាលមិនយូរពេក ។ ខាងក្រោយ ព្រះបច្ចេកពុទ្ធឆាន់ឲ្យដុំកត្តដល់វាមួយដុំជានិច្ច ។ វាអាស្រ័យដុំកត្តបានសេចក្តីស្នេហាក្នុងព្រះបច្ចេកពុទ្ធហើយ ។ នាយគោបាលទៅកាន់ទីបម្រើព្រះបច្ចេកពុទ្ធ (មួយថ្ងៃពីរដងជាដរាប) ។ សូម្បីកាលគេដើរទៅ បានយកដំបងវាយគ្រង់គុម្ពឈើនឹងផែនដីក្នុងស្ថានដែលមានម្រឹគសាហាវ (សត្វសាហាវដូចខ្លា) ក្នុងចន្លោះផ្លូវ បញ្ចេញសំឡេងដេញថា សុសុ ដូច្នេះបីដង ឲ្យពាលម្រឹគទាំងឡាយគេចចេញទៅហើយ ។ សូម្បីសុនខ ក៏បានទៅជាមួយគេផងដែរ ។ ថ្ងៃមួយ គេផ្តាំព្រះបច្ចេកពុទ្ធថា លោកម្ចាស់ គ្រាណាខ្ញុំរកឱកាស (ទៅ) មិនបាន គ្រានោះនឹងបញ្ជូនសុនខនេះទៅ លោកគប្បីមកតាមគ្រឿងសម្គាល់ដែលបញ្ជូនវានេះ

ទៅ ៗ ចាប់ដើមអំពីនោះមក ក្នុងថ្ងៃរកឱកាសមិនបាន បានបញ្ជូនសុនខ ទៅ ប្រាប់ថាកូនទៅនាំព្រះបច្ចេកពុទ្ធមកចុះ ៗ ដោយពាក្យតែពាក្យមួយម៉ាត់ប៉ុណ្ណោះ វាស្ទុះបោលទៅ (មិនឈប់ចាំស្ដាប់ទៀតទេ) លុះដល់ទីដែលម្ចាស់ (ធ្លាប់) វាយគុម្ពឈើនិងផែនដីព្រះបីដង ដឹងអាការដែលខ្លួនដេញពាលម្រឹគឲ្យចៀសចេញទៅ ដោយសំឡេងនោះហើយ ដើរ(ដើរតទៅ) ដល់លំនៅព្រះបច្ចេកពុទ្ធ អ្នកដែលធ្វើការប្រតិបត្តិ ជម្រះកាយអំពីព្រឹកហើយ ចូលទៅកាន់បណ្ណសាលាអង្គុយហើយ ព្រះបីដងទៀតត្រង់ទ្វារបណ្ណសាលា ឲ្យលោកដឹងថាខ្លួនមកហើយ ដេកចាំចំណែកម្ខាង ៗ កាលព្រះបច្ចេកពុទ្ធកំណត់វេលាដ៏គួរហើយ ដើរចេញក្រៅបណ្ណសាលា វាព្រុះដើរ នាំទៅខាងមុខ ៗ ៗ ព្រះបច្ចេកពុទ្ធកាលល្បងមើលវាក្នុងបន្ទោះ ១ បានដើរបែកទៅផ្លូវដទៃ ( ដែលមិនមែនផ្លូវទៅផ្ទះនាយគោ-បាល) ៗ ទីនោះវាទើបឈរទទឹងកំងខាងមុខលោក ព្រះ ជាទីប្រាប់ថាមិនមែនផ្លូវនោះទេ ហើយនាំលោកត្រឡប់កាន់ផ្លូវដែលត្រង់ទៅ ផ្ទះម្ចាស់ខ្លួន ៗ ខាងក្រោយ ថ្ងៃមួយលោក ល្បងមើលវាទៀត ធ្វើជាដើរទៅកាន់ផ្លូវដទៃ ដល់វាទឹងឈរទទឹងមុខហាមឃាត់ ក៏មិនត្រឡប់ យកជើងទាត់វា ឲ្យចៀសចេញ ហើយដើរតទៅ ៗ សុនខដឹងអាការដែលលោកមិនត្រឡប់ហើយ ស្ទុះទៅខាំជាយសំពត់អន្តរវាសក: (ស្បង់) ទាញទុក ទាញលោកទៅកាន់ផ្លូវដែលត្រូវទាល់តែបាន ៗ វាញុំាងសេចក្ដីស្នេហាមានកម្លាំងឲ្យកើតឡើងក្នុងព្រះបច្ចេកពុទ្ធនោះដោយប្រការ

ដូច្នោះ ។ អំពីនោះមក កាលដទៃទៀត សម័យព្រះបច្ចេកពុទ្ធមាន ចីវរចាស់ដាច់ដាចហើយ ទើបនាយគោបាលថ្វាយសំពត់ ដើម្បីធ្វើចីវរ ដល់លោក ។

ព្រះបច្ចេកពុទ្ធពន្យល់គេថា អាវុសោ ធម្មតាចីវរធ្វើមនុស្សតែម្នាក់ឯង ធ្វើបានដោយលំបាក អាត្មានឹងទៅកាន់សប្បាយហើយ ពឹងកម្លាំងអ្នកដទៃជួយធ្វើ ។

នាយគោបាល– និមន្តលោកម្ចាស់ធ្វើក្នុងទីនេះចុះ ។

ព្រះបច្ចេកពុទ្ធ– មិនអាច នឹងធ្វើបានទេ អាវុសោ ។

នាយគោបាល– បើដូច្នោះ សូមលោកម្ចាស់កុំនៅខាងក្រៅយូរពេកព្រះករុណា ។

សុនខបានឈរស្ដាប់ចរចាគ្នានិងគ្នា ។

ព្រះបច្ចេកពុទ្ធពោលថា នៅចុះ ឧបាសក នាយគោបាលត្រឡប់ហើយ អណ្ដែតឡើងកាន់វេហាស៍ អាកាសជាទីកកាយនៃសត្វស្វាប បែរមុខចំពោះទៅកក្នុងគន្ធមាទន៍ទៅហើយ ។ សុនខឃើញលោកទៅតាមអាកាសឈរព្រុះ ទាល់តែលោកកំបាំងវង្វេងចក្ខុខ្លួន ហទ័យបែកហើយ។

ធម្មតាសត្វតិរច្ឆាននេះ មានអធ្យាស្រ័យត្រង់ឥតវៀចវេរទេ ចំណែកមនុស្សទាំងឡាយ ចិត្តគិតទៅយ៉ាងដទៃ មាត់និយាយទៅយ៉ាងដទៃ (មិនត្រង់គ្នាសោះ) ។

ហេតុនោះឯង នាយនេស្យហត្ថាគេហបុត្រ (បុត្រនាយជាង. . .) ទើបទូលសម្តេចព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន រាងគឺមនុស្សនេះសាំញាំ បពិត្រព្រះអង្គដ៏ចម្រើន រាងគឺបណ្តាសត្វចិញ្ចឹមងាយ ។

ព្រោះទិដ្ឋិទៀងត្រង់មិនវៀចវេរនោះឯង រ៉ា(សុនខ)ធ្វើកាលៈហើយកើតក្នុងកពតាវត្តិង្ស មាននាងអប្សរមួយពាន់ចោមរោម សោយមហាសម្បត្តិហើយ ។ ទេវបុត្រ (កំណើតសុនខ) នោះ កាលបើខ្សឹបដិតគុម្ពត្របៀកអ្នកណា ១៦ សម្លេងឮខ្ទរទៅដល់ដប់ពីរយោជន៍ ឯសម្លេងនិយាយជាធម្មតាដូចជាគ្របទេពនគរមានប្រមាណមួយម៉ឺនយោជន៍ទាំងអស់ ហេតុនោះឯង លោកទើបមាននាមថា ឃោសកទេវបុត្រ ។

សួរថា ចុះនោះជាផលរបស់អ្វី ?

ឆ្លើយថា ផលរបស់ការព្រុះព្រោះសេចក្តីស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ ។

លោកឋិតនៅក្នុងតាវត្តិង្សពិភពនោះមិនបានយូរប៉ុន្មានក៏ច្យុត ។

រីទេវបុត្រទាំងឡាយរមែងច្យុតចាកទេវលោកដោយហេតុបួនប្រការ គឺ ១ អស់អាយុ ២ អស់បុណ្យ ៣ អស់អាហារ ៤ ក្រោធខឹងដូច្នេះ ។ ក្នុងបួនយ៉ាងនោះ អ្នកធ្វើបុញ្ញកម្មទុកច្រើន កើតក្នុងទេវលោកហើយឋិតនៅរហូតដល់អស់អាយុ (លុះច្យុតហើយ) កើតក្នុងជាន់លើ ៗ ឡើងទៅយ៉ាងនេះ ឈ្មោះថាច្យុតដោយអស់អាយុ ។ អ្នកធ្វើបុណ្យទុកបន្តិចបន្តួច មានបុណ្យសូន្យអស់ក្នុងចន្លោះ ដូចដាក់ស្រូវត្រឹមបួនប្រាំតៅទុក

ក្នុងកោដ្ឋាគារ (ជង្រុកល្មួង) ធ្វើកាលៈក្នុងចន្លោះ (ស្លាប់ក្នុងអាយុនៅមិនគួរស្លាប់) យ៉ាងនេះ ឈ្មោះថាច្យុតដោយអស់បុណ្យ ។ មួយពួកទៀត បរិភោគកាមគុណ (ជ្រុលពេកទៅ) មិនបានបរិភោគអាហារដោយភ្លេចស្មារតីទឹក (អស់កម្លាំង) លំបាកកាយហើយធ្វើកាលៈ យ៉ាងនេះ ឈ្មោះថាច្យុតដោយអស់អាហារ ។ មួយពួកទៀត ចង់បាន សម្បត្តិរបស់អ្នកដទៃ កាលបើមិនអាចនឹងបានយកជាកម្មសិទ្ធិរបស់ខ្លួន ក៏ក្រោធខឹង ហើយធ្វើកាលៈ យ៉ាងនេះ ឈ្មោះថាច្យុតដោយក្រោធខឹង ។

ឯឃោសកទេវបុត្រនេះ បរិភោគកាមគុណជ្រុលពេកទៅភ្លេចស្មារតីទឹក ច្យុតដោយអស់អាហារ ។ ក៏លុះច្យុតហើយចាប់បដិសន្ធិក្នុងផ្ទៃនាងនគរសោភិនី (ស្រីពេស្យា) ក្នុងនគរកោសម្ពី ។ ក្នុងថ្ងៃសម្រាលនាងនគរសោភិនីនោះ សួរស្រីបម្រើថា វាប្រុសឬស្រី កាលស្រីបម្រើប្រាប់ថា ប្រុសអ្នកម្ចាស់ បង្គាប់ឲ្យបោះបោលថា យកចុះមេឯង ចូរលើកក្មេងនេះដាក់ប្រែងបោះបោលត្រង់គំនរសម្រាម ។ មែនពិត នាងនគរសោភិនីទាំងឡាយចិញ្ចឹមតែកូនស្រី កូនប្រុសមិនចិញ្ចឹមទេ ព្រោះប្រពៃណីរបស់ពួកវា កូនស្រីទើបបន្តទៅបាន ។ ក្អែកខ្លះ សុនខខ្លះ ឈរចោមរោមទារក ព្រោះផលនៃការព្រះ មានសេចក្តីស្នេហាក្នុងព្រះបច្ចេកពុទ្ធជាហេតុ សូម្បីក្អែក ឬខ្លែងតែមួយ ក៏មិនអាចចូលជិតបាន ។

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

## ពិចារណាកថា :

# វត្តអារាមជាឃ្លាំងវប្បធម៌ជាតិ

ដោយ លី-ធាមតេង

បើគេពុំបានសម្លឹងមើល ហើយរិះគិតឲ្យឆ្ងាយទៅដល់អតីតកាលទេ គេពុំបានទទួលយកពាក្យដែលដាក់ជាចំណងជើងអត្ថបទនេះ ថាជាពាក្យត្រូវឡើយ ព្រោះសព្វថ្ងៃ គេឃើញវប្បធម៌កលដាលសាយភាយទៅតាមសាលាតូច-ធំ និងតាមសៀវភៅក្បួនខ្នាតផ្សេង ៗ បោះពុម្ពព្រាតព្រោងទៅហើយ ៗ ការយល់ឲ្យបានវែងឆ្ងាយនោះ ជាឧបករណ៍សំខាន់ណាស់ក្នុងវិស័យកសាងជាតិ យើងតោងតែ ពិចារណាឲ្យល្អិតល្អន់សិនមុននឹងសន្មតថា វប្បធម៌យើងដូច្នេះឬដូច្នោះ ៗ

ហេតុអ្វីក៏យើងពោលថា វត្តអារាមជាឃ្លាំងវប្បធម៌ ?

លោកអ្នកអនេកទាំងឡាយ ដែលមានវ័យច្រើនចូលសិប់ទៅក្នុងបច្ឆិមវ័យ ឬ អ្នកនៅក្នុងមជ្ឈិមវ័យខ្លះ ក៏នៅចាំទាំងអស់គ្នាថា : ពីដើមរៀងមក កុលបុត្រខ្មែរយើងគ្រប់ស្រុកភូមិ សុទ្ធតែទៅក្រេបជញ្ជក់ចំណេះវិជ្ជាពីវត្តអារាម អ្វី ៗ ឲ្យតែជាផ្នែកការចេះដឹងទាំងប៉ុន្មាន តែងផ្សាយចេញមកពីវត្តអារាម ។

ព្រោះយើងយល់មកហើយថា ដែលហៅថា "វប្បធម៌" គឺជាគ្រឿងមតិក ខាងចំណេះប្រាជ្ញាស្មារតី ដែលបុព្វបុរសបានបង្កើតឡើងទុកជាគ្រឿងឲ្យយើងតកូនតចៅជាច្រើនសតវត្ស ៗ សព្វថ្ងៃនេះ ការសាងជាតិ សាងប្រទេស ក៏គោងតែយកវប្បធម៌ជាផ្នែកធំមួយក្នុងផែនការកសាងនេះដែរ គឺខាងនយោបាយ សម្រាប់រកកិត្តិនាមជូនជាតិឲ្យទៅជាស្រុកខ្លាំងពូកែល្បីល្បាញ មានសេរីភាព មានឯករាជ្យខាងសេដ្ឋកិច្ច សម្រាប់គាក់តែងគោតទ្រព្យរបស់ជាតិ, ខាងសង្គមកិច្ច សម្រាប់រៀបរយរបបរស់នៅឲ្យស្រួលបួលក្នុងស្រុកភូមិ ឯខាងវប្បធម៌ គឺធ្វើឲ្យបណ្តាជនមានចំណេះប្រាជ្ញា ស្មារតីមុតមាំ ពោលគឺការអប់រំគ្រប់វិស័យ មានវិស័យសិក្សាសិល្ប: សាសនា អក្សរសាស្ត្រ ទំនៀមទម្លាប់ជាដើម ៗ គ្រាន់តែយើងរាប់ប៉ុណ្ណោះ ក៏ឃើញថា ទំហំវប្បធម៌នេះធំទូលាយ ហើយគ្របដណ្តប់ផ្ទាល់ទៅលើជីវភាពប្រចាំថ្ងៃរបស់អ្នកស្រុកជានិច្ចផង ៗ

បើយើងឃើញវប្បធម៌ជាអ្វីរួចហើយ ទើបយើងយល់ថា តើរបស់អស់ទាំងនេះ ពីមុនមកមាននៅឯណា ? តែងផ្សាយចេញពីទីណា ? នោះយើងឆ្លើយយ៉ាងខ្លីថា បើវប្បធម៌នោះ ជាវប្បធម៌ខ្មែរពិត ។ តែងតែមានហើយផ្សាយចេញមកពីវត្តអារាមទាំងអស់ ៗ

ពីដើមមក កូនខ្មែរតែងដឹងក្តីពិតប្រាកដហើយ គេនាំយកទៅនៅវត្តផ្ញើនឹងព្រះសង្ឃ លោកបង្ហាត់បង្រៀនតាំងពីអក្សរ លេខនព្វន្ត ធម៌វិន័យរហូតដល់ការងារសម្រាប់ធ្វើជាមុខរបរផ្សេង ៗ ទៀត ដូចជាជាងឆ្លាក់

ជានស្លាប់ ជានសំណាន់ ។ល។ បានន័យថា ឲ្យតែបួសរៀនរួចចេញពីវត្តមកវិញ គេមានការចេះដឹងល្មមប្រកបរបររកស៊ីបាន ហើយចាប់សាងគ្រួសារប្រចាំជីវិតទៅ ។ ក្នុងដំណើរជីវិតរាល់ថ្ងៃនោះទៀតសោត បើមានជួបឧបសគ្គ កើតទុក្ខកង្វល់អ្វីមួយ ក៏គេយកវត្តជួយដោះស្រាយដែរ ដូចជាទៅសួរយោបល់ព្រះសង្ឃសុំឲ្យលោកជួយគិត ផ្សងគម្ពីរ ផ្សងគម្រា ឬ និមន្តលោកសូត្រយាងព្រះគ្រោះរំដោះឧត្បាទចង្រៃ ចម្រើនបរិត្តលើកកាសី ។ល។ ឬមួយបើគេអផ្សុកគ្មានទស្សនីយភាពសិល្បៈឯណាកំសាន្តទេ មានតែអានសាស្ត្រារឿង ស្តាប់ព្រះធម៌ ស្តាប់ទេសនាជាតកផ្សេង ៗ ជាកិច្ចលំហែអារម្មណ៍ ។ បើគេបានប្រកបភោគផលសមបំណងវិញ ក៏នាំគ្នាធ្វើបុណ្យទាន កសាងសេនាសនៈក្នុងវត្តអារាម ដើម្បីបង្កើនចិត្តសទ្ធា និង បង្កើនសាមគ្គីជួបជុំមូលផ្តុំគ្នា ។ ជូនកាលការប្រជុំនេះ បានទៅជាមធ្យោបាយប្តូរយោបល់កសាងសេចក្តីចម្រើនស្រុកភូមិថែមទៀតផង ។ មិនតែប៉ុណ្ណោះក្បួនខ្នាតរបស់ខ្មែរគ្រប់បែបតែងតែត្រូវព្រះសង្ឃលោកប្រមូលទុក ហើយសិក្សាបណ្តើរ ចារចម្លងទុកបណ្តើរ តាំងពីគម្ពីរធម៌វិន័យ រហូតដល់សាស្ត្រារឿង ច្បាប់ល្បើក និង គម្រាផ្សំថ្នាំ គម្រាហោរាសាស្ត្រ ឬ គម្រាខាងវិជ្ជាសង់ផ្ទះ ធ្វើទូក ធ្វើកំបោរ ធ្វើរទេះ ។ល។ ក៏មានគង់នៅទាំងអស់ ។

គ្រាន់តែរាប់រៀបមកប៉ុណ្ណេះ យើងឃើញថា វត្តអារាមស្រុកខ្មែរយើង មាននាទីក្នុងការកសាងជាតិមួយផ្នែកធំណាស់ ព្រោះជាឃ្លាំង

ជាជម្រកវប្បធម៌ជាតិពិតប្រាកដនេះឯង ។ ព្រះសង្ឃលោកជាគ្រូផង ជាអ្នករក្សាផង និង ជាអ្នកផ្សាយថែមទៀតនូវកេរ្តិ៍ដំណែលវប្បធម៌ជាតិទាំងនេះ ។ ដូច្នេះ អ្នកដែលឈ្លក់ ឬ វិលស្លុងទៅតាមដំនោរវប្បធម៌បរទេស ពិសេស គឺវប្បធម៌អ្នកប្រទេសខាងលិច ក៏ត្រឡប់ជាយល់ថា វត្តអារាម មិនមានសារៈសំខាន់ទៅវិញ ដែលជាហេតុគួរឲ្យស្តាយណាស់ អ្នកយល់ស្មើរដូច្នេះនេះ មកតែមិនបានគិតឲ្យដល់ ពីវប្បធម៌ជាតិខ្លួន គ្មានស្គាល់ឫសគល់ផ្ទះលំនៅខ្លួនឲ្យច្បាស់លាស់ ព្រោះវល់តែពុលក្នុងផ្សែងអារ្យធម៌បរទេសខ្លាំងពេក ។

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ-កាន

ប្រែ - រៀបរៀង

## ( ក )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ    អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលចំណាន    ទាំងមានសត្តានស្នេហាជាតិ

យូរ-អ៊ុន

ខណៈកាលអ៊ុយអៀន ទៀវឃី តាន់សេក និងតៅខេង លើកទ័ព មកជិតដល់តំបន់គីកុក ទទួលខុងបេងប្រើគេងជីតាមមកតាន់ ទាំង ៤ នាយក៏សួរថា: អ្នកមកមានការអ្វី? គេងជីប្រាប់ថា: មហាឧបរាជមិន ទុកចិត្ត ទើបប្រើខ្ញុំឲ្យតាមមកកំជាប់អស់លោកថា ឲ្យរាំងកលសុម៉ាអ៊ី ឲ្យមែនទែន ក្រែងវាបណ្ដោះពលទុកពួនបង្កប់ កុំឲ្យលើកស្រូតចូល រំលងហួសទៅ ត្រូវបង្អែបង្អង់មើលកលការឲ្យច្បាស់លាស់ អ៊ុយអៀន និងនាយកងទាំង ៣ នាក់ឆ្លើយថា: មហាឧបរាជមិនគួរនឹងមកព្រួយរំខាន នឹងការប៉ុណ្ណេះសោះ ព្រោះពលទាហានសុម៉ាអ៊ីត្រាំទឹកភ្លៀងមក ៣០ ថ្ងៃ ហើយ ក្រិសអាវុធទទឹកជោកជាំ ស្បៀងអាហារក៏ផ្អូររលួយ វាគិត តែនឹងឲ្យរបូតរលូតរួចទៅផ្ទះសម្បែងឆាប់ៗ ត្រូវការអ្វីនឹងទៅពួនបង្កប់នោះ

ជាខុសសោះ   វេលានេះបានចំណាប់ទឹងរាយបំបែកទ័ពខ្មាំងស្រួលហើយ មហាឧបកជមកនាំឲ្យខ្មាំងបញ្ចៀតទៅវិញដូច្នេះមិនគួរគោរ ។

គេនជីថា: មហាឧបកជនេះ ទឹងមានប្រសាសន៍ពីគ្មាំងជម្រាបមកមិនដែលខុសដល់មួងសោះ ហេតុម្តេចលោកមកបបេសទីសបាសទៅរកមហាឧបកជវិញដូច្នោះមិនគួរទេ   តាន់សេកក្មូដូច្នោះក៏សើចហើយថា: មហាឧបកជនោះ   លោកមានគំនិតគិតវិសេសមែនហើយ   តែកាលពីគ្រាមុនហេតុម្តេចបានជាឲ្យខូចតំបន់គេគេងទៅ   អ៊ុយអៀនថា : កាលពីមុន   ខ្ញុំបានគិតការជួនមហាឧបកជបានមួង   បើសិនណាជាលោកធ្វើតាមគំនិតខ្ញុំនឹងមិនបានស្រុកឡុកអៀងពីយូរមកហើយ ឬ ?   ណាឡើយនឹងមកព្រួយឈឺវេទនាដល់ពលយោធាទាំងម៉្លេះ ។

តាន់សេកនិយាយនឹងអ៊ុយអៀនថា : មហាឧបកជមិនទុកចិត្តឲ្យមកតាមហាមវ៉ាត្រូកហើយ បើដូច្នោះ ខ្ញុំនឹងនាំពល ១.០០០ នាក់ទៅតែម្នាក់ឯងស្រួតទៅដល់ក្ងួគីកុក ដើម្បីនឹងតាំងបន្ទាយ បើមហាឧកជទៅឯក្ងួគីសានឲ្យមហាឧបកជខ្មាសាយើងម្តងឲ្យបាន   ខណៈនោះតាន់សេកក៏នាំទាហានស្រួតទៅតែម្នាក់ឯង   គេនជីក៏ត្រឡប់វិលទៅវិញ ។

ខណៈកាលតាន់សេកលើកពលចេញទៅ   ចម្ងាយផ្លូវប្រហែល ៦០ សិន (២.៤០០ម.) ទទួលទាហានសុមាអ៊ីតាំងចន្លប់នៅក្បែរនោះបានចំណាប់ក៏អុជផាវជាសញ្ញាឡើងហើយលើកគ្នាចេញស្រមកព័ទ្ធជុំទាំង ៤ ទិស

គាន់សេកនៅជាកណ្ដាលបំណោម ក៏បរពលចូលរោមកាប់ក្ការ ដើម្បីបំ-
ពាន់កផ្លូវចេញ ត្រឹមតែស្លាប់កន្ទិចបំណោមនោះមិញក៏ច្រើនណាស់ សល់
នៅខ្វះប្រហែល ៦០០ ក៏បេះតែរុកកនទ ទ្រូនកណ្ដាលរណរង្គ ទិន័រក
ច្រកចេញក៏មិនរួចសោះ ទ័ពសុម៉ាអ៊ីព្រួតចូលមកដិតផតបន្ទោះត្រង់ណា
អ៊ុយអៀនបានពុទា ហានហោហានគឹកកន់ ក៏លើកពលផង័ពូលជួយដោយ
ពលក្ការ រ័ហកទម្លាយកងយោធា សុម៉ាអ៊ីចូលទៅជះណ្ដើមយកខ្លួនគាន់-
សេក និង ពលសេនាចេញមកបាន ទាហានសុម៉ាអ៊ីក៏លើកដេញពីក្រោយ
តៅខេង និង ទៀវង៉ី ក៏លើកទៅជួយគ្នា នាំយកខ្លួនអ៊ុយអៀន គាន់សេក
មកបាន ហើយដេញកាប់សម្លាប់ទាហានសុម៉ាអ៊ីពថយត្រឡប់ទៅ ទាំង
៤ នាយក៏នាំគ្នាមកបន្ទាយ ទើបថា មហាឧបកជមានប្រាជ្ញាមែន ។

ឯតេង៉ជីនោះ លុះវិលទៅដល់ក៏ចូលទៅជម្រាបខុងបេងថា : មហា
ឧបកជប្រើខ្ញុំបាទទៅហាមប្រាមនោះ អ៊ុយអៀនមិនគាន់សេកនាំគ្នាសើច
បំអកឲ្យមហាឧបកជវិញ ខុងបេងឮដូច្នោះក៏អស់សំណើចហើយថា អ៊ុយ
អៀននោះ ជាមនុស្សចិត្តមិនត្រង់ បើមិនកម្ចាត់បង់ក៏ឲ្យខឹងស្ដាយថ្វីដៃ
ត្រូវតែប្រស្រ័យប្រើប្រាស់ទៅសិន យូរទៅអ៊ុយអៀនគង់ជាក្បត់ផែនដី
មិនខាន កំពុងតែនិយាយគ្នាមានបម្រើល្បាតចូលមកជម្រាប គាន់សេក
លើកពលចូលទៅក្នុងដៃនគេ ថ្វស់ការទឹនពលសុម៉ាអ៊ី ពលរហ័ស្លាប់

វិនាសច្រើនណាស់ សល់ពលប្រហែល ៦០០ នាក់ ឥឡូវថយទ័ពមក សំណាក់នៅដើមផ្លូវដំបន់គីកុក ។

ខុនបេនឮដូច្នោះក៏គិតថា ៖ បើនឹងយកទោសដល់នាយទ័ពនាយកង គ្រានេះ ក៏នឹងប្រែចិត្តគេចរត់ទៅចូលខាងសត្រូវអស់សារឥតការ ទើបប្រើគេឯងទៅចរចាយកចិត្តកុំឲ្យគិតព្រួយវិតក្កភ័យអ្វីឡើយ ថាយើងមិនយកទោសទេ ចូរខំឧស្សាហ៍ធ្វើការកែខ្លួនយកជ័យជំនះចុះ ហើយខុនបេនក៏ប្រើទាហានឲ្យស្រូតទៅប្រាប់ ម៉ាតាយ ម៉ាគុង អងបេង ទៀវអេក ទាំង ៤ នាយ ឲ្យលើកពលញែកគ្នាទៅជា ២ កង ម៉ាតាយ និងអងបេងឲ្យលើកទាហានទៅផ្លូវស្តាំដៃ ម៉ាគុងនិងទៀវអេកឲ្យនាំទាហានទៅខាងផ្លូវឆ្វេងដៃ ពេលថ្ងៃត្រូវពួនបង្កប់ ពេលកណ្តាលយប់ឲ្យដើរទៅបំស្រូតចេញពីតំបន់គីកុកទៅដល់តំបន់គីសានហើយ ត្រូវឲ្យគេគំនរឧសដុតភ្លើងទុកក្បែរជាសម្គាល់ ឲ្យចូលវាយយកបន្ទាយចូជិនឲ្យបាន យើងនឹងលើកទាហានទៅជួយវាយប្រសព្វជា ៣ ផ្លូវ ។

ម៉ាគុង, ម៉ាតាយ, អងបេងនិងទៀវអេក ដឹងដូច្នោះក៏ស្រូតលើកទាហានចេញទៅ ខុនបេនឲ្យគេគួនហ៊ុននិងលៀវហ្វ៊ូចូលមកខ្សឹបប្រាប់ជាសេចក្តីស្ងាត់កំបាំង ហើយឲ្យលើកទ័ពចេញទៅ លុះខុនបេនលើកទ័ពធំទៅដល់កណ្តាលផ្លូវ ក៏បង្គាប់ ងីអី, ង៉ីប៉ាន់ ឲ្យលើកកូនទាហានស្រូតទៅមុន ។

ឯចូជិនទៅតាំងបន្ទាយនៅតំបន់ហ៊ាកុកនោះ   ក៏លុះដោយសេចក្តីធ្វេសប្រមាទមិនសង្វាត  នឹងត្រួតត្រារក្សាកងទាហានឲ្យរបៀបជាពួកទ័ព ពីព្រោះមិនចុះជឿពាក្យស៊ុម៉ាអ៊ីសោះ   សម្គាល់ថាកំណត់ ១០ ថ្ងៃហើយ ក៏នឹងធ្វើផ្ចាលស៊ុម៉ាអ៊ីតាមពាក្យប្រជ្ញា ។

លុះគ្រប់ ៧ ថ្ងៃ  មានទាហានល្បាតទៅប្រាប់ថា : ឥឡូវទាហានស្រុកសៃឈួនកយមកតាមផ្លូវតូចខាងព្រែកភ្នំច្រើនណាស់  ចូជិនក៏បង្គាប់ជិនលៀងឲ្យនាំទាហាន ៥.០០០ ទៅល្បាតមើលតាមផ្លូវ  ដើម្បីបង្ការកុំឲ្យកងទ័ពស្រុកសៃឈួនកចូលមកក្នុងដែនបាន  លុះជិនលៀងនាំទា-ហានទៅដល់កណ្ដាលផ្លូវ  ក៏ប្រទះនឹងកងទ័ពខុងបេងលើកមក  ក៏ឲ្យទា-ហានស្រួតលើកទៅ  ទាហានខុងបេងក៏នាំគ្នាថយក្រោយបណ្ដោយទៅវិញ ជិនលៀងក៏ដេញពលស្រួតតាមទៅនឹងឲ្យទាន់   ទាហានខុងបេងក៏ពួនបង្កប់អស់  ជិនលៀងតាមទៅមិនបានឃើញទាហានស្រុកសៃឈួនសោះ ក៏គិតសង្ស័យទើបឲ្យកងទ័ពឈប់ផ្ទុំ  ពួកល្បាតសេះមកប្រាប់ថា : កងទ័ពពួនបង្កប់នៅខាងមុខច្រើនណាស់  ជិនលៀងឮដូច្នោះក៏ត្រៀមកងទ័ពបង្គាប់ឲ្យប្រុងប្រយ័ត្នខ្លួនគ្រប់គ្នា ។

ខណៈនោះ  ទ្វល  ង៉ុ  ងីប៉ាន់  គួនហ៊ុន  ទៀវអេក  វាយប្រ-សព្វខ្ទប់ពីក្រោយបណ្ដោយមក  ទាហានជិនលៀងមិនដឹងខ្លួនសោះ  នឹងដោះរត់ទៅខាងណាក៏មិនរួច ព្រោះសងខាងផ្លូវនោះមានភ្នំនៅអមឆ្វេង-ស្តាំ

ទាហាននីអ៊ី នីប៉ាន់ គួនហ៊ុន ទៀតអេក ក៏ស្រែកថា : នរណាចូលមកលន់តួសុំចំណុះចុះចូលដោយសុភាព យើងលើកទោសមិនសម្លាប់ ទាហានជិនលៀងប្រគល់ខ្លួនជូនទឹកស្លាយជីវិត ក៏នាំគ្នាចុះចូលមកខាងនីអ៊ី នីប៉ាន់ជាច្រើន ។

ជិនលៀងឃើញដូច្នោះក៏គិតថា: បរសេះចូលទៅកាប់ចាក់សម្លាប់កងទ័ពស្រុកសែឈួន ដើម្បីនឹងដោះខ្លួនឲ្យរួចចេញពីចំណោម លៀវហ៊្វក៏បរសេះចូលតដៃនឹង ជិនលៀង បាន២ក្បួន ក៏យកដាវកាប់ត្រូវជិនលៀងដាច់ពាក់កណ្ដាលខ្លួនធ្លាក់ពីលើសេះស្លាប់ ទាហានទាំងប៉ុន្មាន ក៏ចូលទៅនៅនឹងខុងបេងទាំងអស់ ខុងបេងក៏ឲ្យដោះក្រិសនឹងអាវពួកនោះមកបំពាក់ពួកទាហានស្រុកសែឈួន ហើយក៏តាំងឲ្យបញ្ចុះបញ្ចូលពួកខ្មាំងទាំងប៉ុន្មានឲ្យមកនៅកងក្រោយទាំងអស់គ្នា ទើបឲ្យគួនហ៊ុន លៀវហ៊្វ នីអ៊ី នីប៉ាន់ នាំទាហាន ៥.០០០ ដែលក្លែងខ្លួនបន្ទំជាទាហានជិនលៀងលើកស្រូតតម្រង់ទៅបន្ទាយចូជិន លុះនីអ៊ី នីប៉ាន់ លៀវហ៊្វ គួនហ៊ុន លើកទៅជិតបន្ទាយហើយ ក៏ឲ្យទាហានឈប់នៅក្រៅ ហើយប្រើអ្នកបម្រើម្នាក់ឲ្យជិះសេះចូលទៅក្នុងបន្ទាយនិយាយជម្រាបចូជិនថា: ទាហានខុងបេងដែលពាយគ្នាមកនោះបានដេញបំបែកទៅអស់ហើយ ។

ខណៈនោះ, ចទួលសុម៉ាអ៊ីឲ្យបម្រើមកប្រាប់ថា : ទាហានស្រុកសែឈួន លើកមកតាំងបន្ទប់លបចាំសម្លាប់កងទ័ពយើងស្លាប់អស់

១ ពាន់ប្រាយហើយ, ឲ្យវាំងត្រួតត្រារក្សាបន្ទាយកុំប្រមាទ, ចូដិនញដូបោះ ក៏ឆ្លើយតបថា : ទីតាំងកុកនេះយើងមិនដែលបានឃើញទាហានស្រុកសែឈូនក្តើខ្លួនចូលមកដល់ម្នាក់ទេ, ឯងត្រូវវិលទៅជម្រាបទៅហ្វាយឯងចុះ, បម្រើនោះក៏វិលត្រឡប់ទៅវិញ ទទួលទាហានងីអ៊ុ ង៉ីប៉ាន់ ដែលបន្ទំ ចូលទៅនោះជម្រាបថា : ទាហានខ្មាំងបែកអស់ទៅហើយ ចូដិនញដូបោះក៏តែតែមានសេចក្តីត្រេកអរ សម្គាល់ថាជិនលៀនត្រឡប់មកដល់ហើយ បានជាឲ្យបម្រើចូលមកប្រាប់ ក៏លើកទាហានចេញពីបន្ទាយនឹងទៅទទួលតាមគួរសម ។

ឯងីអ៊ុ, ង៉ីប៉ាន់, លៀវហ៊្វ និងគួនហ៊ុននោះ លុះឃើញចូដិនចេញទៅ ក៏ស្ទុះស្រូចូលទៅក្នុងបន្ទាយបាន ឲ្យទាហានយកភ្លើងដុតឡើងក្នុងមួយរំពេចនោះ ម៉ាតាយ, អង់បេង ក៏បរពលដេញកាប់សម្លាប់តាមក្រោយ ទៀវអេក, ម៉ាគុង ក៏បរពលទល់តពីមុខ ទ័ពចូដិនលើសកម្លាំងនឹងទ្រាំពុំបាន ក៏បែកខ្ចាត់ខ្ចាយគ្នាទៅ ម៉ាតាយ, អង់បេង, ទៀវអេក, ម៉ាគុង ក៏ឲ្យទាហានដេញកាប់សម្លាប់ខ្មាំងអស់ជាច្រើន ចូដិនប្រទល់ខ្លួន ក៏ខំបំពារចេញទៅបានដោយតាំងទាហាន ៥០ នាក់, ទទួលជួបនឹងទ័ពស៊ុម៉ាអ៊ីលើកមកជួយ ស៊ុម៉ាអ៊ីក៏ទទួលយកខ្លួនចូដិននាំទៅបន្ទាយគីកុក ។

ខណៈនោះ ចូដិនក៏មានសេចក្តីអបយសនឹងស៊ុម៉ាអ៊ីណាស់ មិន

ដឹងបើទីនេះទុកមុខទុកមាត់ទៅខាងណាឡើយ សុម៉ាអ៊ីដឹងហើយក៏និយាយ នឹងចូដិនថា : ឥឡូវទ័ពខុងបេងវាយចូលមកតាំងនៅតំបន់គីសានហើយ យើងនឹងតាំងទទួលក្នុងទីគីកុកនេះ ក៏គង់នឹងប្រៀបប្រេនស៊ូនឹងគេមិនបាន ត្រូវតែលើកពលទាហានទៅចាំទទួលនៅទះនូហ៊ុយហោ ។

ចូដិនក៏សួរសុម៉ាអ៊ីថា : ហេតុម្តេចបានជាលោកដឹងថាខ្ញុំចាញ់ប្រៀបដល់សត្រូវ ហើយៈលោកលើកពលទៅជួយ ? សុម៉ាអ៊ីថា : ខ្ញុំបានដឹងថាខុងបេងនឹងលើកមកវាយលោក បានជាខ្ញុំប្រើបម្រើទៅរំឭកលោកឲ្យប្រយត្នត្រួតត្រាការពារក្យាខ្លួន លុះបម្រើត្រឡប់មកប្រាប់ខ្ញុំតាមពាក្យដែលលោកថានោះ ខ្ញុំក៏ដឹងថា លោកដឹងមិនដល់ការនឹងថ្លស់ការជាប្រាកដ បានជាខ្ញុំទំស្រូតទៅជួយលោក ក៏សមដូចបានគិតគ្នេរមិនខុស ។

ចូដិនឮដូច្នោះ ក៏រឹតតែមានសេចក្តីខ្មាសពេកណាស់ តាំងតែទុក្ខក្រំដំទៅជាឈឺធ្ងន់ចុះ សុម៉ាអ៊ីឃើញចូដិនឈឺធ្ងន់ដូច្នោះ លុះនឹងលើកទ័ពត្រឡប់មកក្រុងវិញ ក៏បារម្ភក្រែងទាហានផ្អើលភ្ញាក់ខូចចិត្តគំនិតអស់ទៅ ក៏តាំងតែការឆ័ងប្អង់នៅ១ទីនោះ ។

ឯខុងបេងនោះ លុះវាយចូលទៅដល់ក្នុងគីសានហើយ ក៏ឲ្យបំណាច់រង្វាន់ពលទាហានតាមមានគុណបំណាច់ ខណៈនោះអ៊ុយអៀន, តាន់សេក, គៅខេង, ទៀវង៉ីលើកទ័ពទៅដល់ ក៏ចូលទៅគំនាប់សារ-ភាពទោសដល់ខុងបេង១ ទើបសួរថា : នរណាដែលមិនបាននៅក្នុង

បង្គាប់បញ្ជាយើងជាមេទ័ពក្នុងគ្រានេះធ្វើឲ្យខូចការ ? អ៊ុយអៀនឆ្លើយថា គាន់សេកមិនបានស្តាប់បង្គាប់លោកលើកកងចូលទៅឲ្យថ្វស់ការ គាន់សេកឆ្លើយថា : ខ្ញុំបាទបានធ្វើល្មើសឲ្យខូចការគ្រានេះ ព្រោះអ៊ុយអៀនប្រើខ្ញុំបាទលើកទៅមុន ។

ខុងបេងថា : អ៊ុយអៀនលើកកងទ័ពទៅជួយអ្នកឯង ទើបបានរួចខ្លួនចេញមកអំពីកន្លែងស្លាប់មិនមែនឬ ? ហេតុម្តេចអ្នកឯងឆ្លើយទម្លាក់ទោសទៅលើគេ ? ដែលអ្នកឯងមិននៅក្នុងបង្គាប់យើង ធ្វើឲ្យខូចថ្វស់ការយ៉ាងនេះ បើនឹងមិនលើកទោសសោះក៏មិនបាន ទៅឯមុខពួកទាហានទាំងឡាយនឹងយកយឿងយ៉ាងគេទៅ ទើបបង្គាប់ឲ្យចាប់ខ្លួនគាន់សេកទៅប្រហារជីវិតបង់ ដែលខុងបេងមិនបានឲ្យសម្លាប់អ៊ុយអៀនចេញផងនោះ ព្រោះគិតថាអ៊ុយអៀននោះមានថ្វីដៃខ្លាំងពូកែជាងគេ ទុកឲ្យនៅធ្វើការសង្គ្រាមតទៅ ក៏នឹងបានប្រើឲ្យទៅសម្លាប់ជាខាងមុខទៀត ។

ខណៈនោះ, មានបម្រើល្បាតសេះនាំយកពត៌មានទាំងពួងទៅជម្រាបខុងបេងថា : ឥឡូវចូដិនឈឺធ្ងន់ណាស់ ថយទ័ពទៅរក្សាពេតនៅបន្ទាយទេនហ៊ុយហោ ខុងបេងឮដូច្នោះក៏ថា : ប្រសិនបើចូដិនឈឺជាប្រមាណទេ កាលណាស៊ុម៉ាអ៊ីនឹងនៅគង់នឹងលើកទ័ពត្រឡប់ទៅ នេះប្រហែលចូដិនឈឺណាស់ហើយបានជាមិនលើកទ័ពទៅ ព្រោះខ្លាចរេហ៍ពលទាំងពួងនឹងខូចចិត្ត យើងនឹងធ្វើសំបុត្រមួយច្បាប់ ទៅដល់ចូដិន

ប្រសិនបើបានឃើញសំបុត្រយើងហើយ គង់នឹងក្រំចិត្តស្លាប់ជាប្រាកដ គិតហើយ ខុនចេង ឲ្យហៅទាហានដែនលៀងដែលបានមកទុកជាឈ្លើយនោះចូលមកហើយនិយាយថា: អ្នកឯងពល់គ្នាជាពួកស្រុកឡុកអៀង អ្នកពល់គ្នាសុទ្ធតែមានញាតិសាលោហិតករិយាបុត្រចង់ជួបនៅទាំងអស់ ដែលនឹងមកនៅទីនេះយើងក៏ឆ្ងាយដាច់អាល័យ ហាក់បីដូចយើងក្លែងឲ្យអ្នកឯងកល់គ្នាព្រាត់ព្រាកចាកគ្នា ក៏ជាវេរបាបកម្មដល់យើងធ្ងន់ណាស់ យើងនឹងឲ្យអ្នកកល់គ្នាវិលត្រឡប់ទៅភូមិស្រុកតាមប្រាថ្នា បើនរណាចង់ទៅក៏តាមចិត្ត ដ្បិតចូជិនមានសំបុត្រមកយើងក៏យូរណាស់ហើយ យើងនៅឡើយមិនទាន់ឆ្លើយតបសោះ យើងនឹងផ្ញើសំបុត្រមួយទៅឲ្យចូជិនផង បើអ្នកកល់គ្នាកាន់សំបុត្រនេះទៅឲ្យចូជិនហើយ គង់នឹងមានបំណាច់រង្វាន់ទៀតពួកឈ្លើយទាំងនោះបានស្តាប់ក៏អរណាស់ នាំគ្នាក្រាបគំនាប់ហើយក៏លាខុនចេងទៅ ។

លុះទៅដល់ទន្លេហ៊ុយបោ ក៏ចូលទៅគំនាប់ចូជិន ហើយយកសំបុត្រនោះជូនទៅចូជិនជម្រាបថា: ខុនចេងផ្ញើសំបុត្រជូនលោក ចូជិនឈឺធ្ងន់ពន់កម្លាំង តែឧស្សាហ៍ញ៉ាំង ខ្លួនក្រោកទទួលសំបុត្រហើយហែកស្រោមហូតយកមកមើល ឃើញសេចក្តីថា: មហាឧបាជឲ្យមកដល់ចូជិនមេកងទ័ពធំបំផុត ដ្បិតបុរាណលោកពោលទុកមកថា: បើនរណាធ្វើជាមេកងទ័ពកាន់ពលទាហានចេញទៅធ្វើការណរង្គសង្គ្រោះនោះ គប្បី

ស្គាល់លក្ខណៈក្នុងកលសឹកឲ្យជាក់ច្បាស់គ្រប់ប្រការ ហើយឲ្យមានសតិបញ្ញាដ៏ប្រែប្រួលកែខៃយកជ័យជម្នះជាដើមឲ្យបាន ដែលខ្លួនអ្នកជាមេទ័ពធំមិនដឹងប្រមាណការក្នុងកលឧបាយ ធ្វើឲ្យអន្តរាយរេហ៍ពលចាញ់កលយើង មិនខូចត្រឹមពល ខូចដល់គ្រឿងសព្វាវុធជាច្រើន ដូច្នេះអ្នកនឹងវេះត្រឡប់មុខចូលទៅស្រុកឡុកអៀងវេលានេះ បើព្រះចៅបួយ៉យមិនទ្រង់តម្រិះនឹងយកទោសក៏ជាការល្អ តែថាមុខគួរឲ្យខ្មាសមុខបណ្ដារាស្ត្រចំណុះស្រុកឡុកអៀងនិងពលទាហានពន់ប្រមាណណាស់ រីចិត្តអ្នកមិនមែនគិតខ្មាសដូចគេធម្មតានៅប្រើអាការជាមេទ័ពថោកទាបទៅបាន យើងប្រមាណមិនទាន់ច្បាស់ បើដូច្នេះ គួរឲ្យអ្នកប្រែមុខទៅលំអុតលំទោនចូលជ្រកកោនយើងដោយសុភាពចុះ បើមិនដូច្នោះទេ នឹងនៅរឹងទទឹងមិនចង់ចំណុះយើង ។ នឹងលើកទ័ពទៅជាន់លំអិតស្រុកឡុកអៀងឲ្យរាបដូចផ្ទៃស្គរ ព្រោះខ្លួនអ្នកឯងនឹងពួកពលនិករ ឧបមាដូចហ្វូងពពែដែលកំឡៅនាំចូលទៅត្រង់មាត់ខ្លា សម្រាប់តែនឹងបង់ជីវិតសង្ខារ ដោយអំណាចខ្លាធំមាំមានឫទ្ធិជាទីសំបើម ដូចយើងជាធ្មើមបមលោក មិនគួរនឹងហ៊ាននាំមកប្រឡងចេស្ដានុភាពសោះឡើយ ចូរដិនមើលចប់ហើយក៏ឲ្យកើតទោសៈដោយបដិឃៈចង្អៀតណែនក្នុងឧរា ពេកដែលឈឺក៏បណ្ដាលឲ្យក្អៀវក្អាកម្រ៉េកសព្វសពាង្គ ចូរដិនក៏រំលាងជីវិតផុតអាយុនៅកណ្ដាលយប់នោះឯង ។

ឯសុមាអ៊ី លុះដឹងថាចូដិនធ្វើកាលកិរិយា ក៏រៀបសពគ្គារតម្កល់លើរទេះ ហើយធ្វើសំបុត្រមកបញ្ជូនចូលទៅក្រុងឡូកអៀង ព្រះចៅចូ-យ៉យក៏ឲ្យតែងសំស្ការសពដោយសមគួរតាមប្រពៃណី ហើយមានសារព្រះតម្រាស់ទៅដល់សុមាអ៊ី ឲ្យទំស្រួតរូតធ្វើការសង្គ្រាមយកជ័យជម្នះខុងបេងឲ្យគ្រាតែបាន សុមាអ៊ីបានដឹងសេចក្តីព្រះតម្រាស់ហើយ ក៏ឲ្យប្រមូលរេហ៍ពលយោធាមកត្រៀមប្រចាំការ ហើយចាត់បម្រើនាំសំបុត្រសារទៅដល់ខុងបេង កំណត់ថាពេលព្រឹកស្អែកឲ្យលើកពួកពលយោធាមកតយុទ្ធនាគ្នា ។

ខុងបេងទទួលដំណឹងហើយថា វេលានេះប្រហែលចូដិនស្លាប់ហើយឬ? បានជាសុមាអ៊ីឲ្យបម្រើកាន់សំបុត្រមកកំណត់តច្បាំងនឹងហើយ លុះដល់ពេលយប់ខុងបេងឲ្យហៅកៀងអ៊ុយ និង គួនហ៊ុនចូលមកខ្សិបបង្គាប់ជាសេចក្តីស្ងាត់ កៀងអ៊ុយ និង គួនហ៊ុនទទួលបង្គាប់គ្រប់ប្រការហើយ ក៏លើកទ័ពចេញទៅតាំងពីពេលកណ្តាលអធ្រាត្រ លុះព្រឹកឡើងខុងបេងក៏លើកកងទ័ពចេញពីបន្ទាយគីសានទាំងអស់ លុះទៅដល់ក្បែរមាត់ហ៊ុយហោជាទីវាលកណ្តាលគ្រាញ់ ។

សុមាអ៊ីក៏លើកកងទ័ពមកប្រទល់មុខគ្នា ក្រឡេកឃើញខុងបេងជិះរទេះតូច តែខ្លួនយ៉ាងស្អាតបាតកាន់ផ្លិតកេមសត្វ កាត់ទៅនៅកណ្តាលរណរង្គ សុមាអ៊ីក៏ស្ទុះស្ទុងទៅមុខទាហានស្រែកថា ៖ ម្ចាស់យើងបាន

សោយរាជសម្បត្តិនៅទីក្រុងឡុកអៀងបាន ២ ជួរព្រះអង្គហើយ មិនដែលបានទៅធ្វើទុក្ខដល់ស្រុកសៃឈួន ឬ ស្រុកហាន់តុងជល់មួងសោះ ពីព្រោះលះបង់នូវអំពើអាក្រក់ ចង់ឲ្យគេសុខសប្បាយដោយចាំព្រះទ័យរករាយផ្សាយមេត្តាករុណាតអាណាប្រជារាស្ត្រទាសកម្មករ ឲ្យនៅស្មោះសរជាសុខនិរទុក្ខដោយអំពើព្រះអង្គទ្រង់ធម៌ តែខ្លួនខុងបេងនេះមិនល្អត្រង់ណាសោះ ព្រោះជាតិអ្នកស្រែក្រៅនៅចុងស្រុកឡាំយ៉ុង គួរ ឬ មកទ្រ-នង់អង់អាចឲ្យលើសហួសជាតិកំណើតរបស់ខ្លួន គិតគុំគួនហ៊ានលើកកងទ័ពចូលមកញាំញីដល់ទឹកដែនស្រុកធំ ខ្ពស់អស់ការៈជាច្រើនដងច្រើនគ្រាមកហើយ នេះឯងហើយឃើញថាជាការមិនសមគួរសោះ ហេតុនេះត្រូវឲ្យអ្នកឯងតែងតាំងចិត្តប្រដៅខ្លួនកុំឲ្យកម្រើប ដោយលោកចេតនាលើកពលយោធាមកសង្កត់សង្កិនគេដូច្នេះតទៅ ត្រូវតែលើកទ័ពត្រឡប់ទៅរក្សាខណ្ឌសីមាខែម្ចាស់ខ្លួនតាមប្រវេណីប្រសើរជាង បើនៅអ្នកអាងកាន់ក្រតាខំតែបំពារចូលមកតាមអំពើចិត្ត ឃើញជាជីវិតរបស់អ្នកឯងមិនបានវិលទៅដល់ទឹកដែនស្រុកទេសរបស់ខ្លួនវិញទេ គឺនឹងត្រូវដោយថ្វីដៃពលរេហ៍របស់យើងប្រហារ ។

ខុងបេងបានសរនាការសុម៉ាអ៊ីដូច្នោះ ក៏អស់សំណើចហើយថា ៖ ខ្លួនយើងជាខ្ញុំព្រះចៅឡៅតី ៖ ទ្រង់ព្រះរាជទានបៀវត្សរ៍សម្រាប់ផ្ចាប់ប្រាំ

រក្សាយើងមកជាយូរ អម្បាញ់កាលព្រះអង្គព្រះប្រឈួនមុននឹងទិវង្គត បានទ្រង់មកព្រះរាជាផ្តាំឲ្យយើងជួយចម្រុងរក្សាផែនដីនៃព្រះចៅហៀនតេ ដឹមានខ្ញូវព្រះគុណឲ្យបានរុងរឿងឡើងវិញ ខ្លួនយើងនេះមិញពេញជាបុរសសត្យានុសត្យកតញ្ញូដល់ផែនដី មិនសមដើរនឹងដេកស្ងៀមត្រៀមចាំស៊ីតែបៀវត្ស មិនគិតកម្ចាត់អាចោរសត្រូវរាជសម្បត្តិឲ្យវិនាសចេញ ក៏មិនពេញជាបុរសកតញ្ញូ យ៉ាងខ្លួនឯងទៀតសោតក៏ជាកូនជីតាមាតាបិតាក៏សុទ្ធតែជាខ្ញុំព្រះករុណាចៅហៀនតេត ៗ មក គួរណាស់នឹងយកចិត្តគិតឈឺជួសតបជសំបូរ ម្តេចមកទទូរស្បៀកស៊ុទ១ ចូលដៃនឹងពួកអាចោរចិត្តអាក្រក់ទ្រុស្តម្នាក់ឯងវិញដូច្នេះ ខ្លួនអ្នកឯងនេះក៏ជាជាតិអ្នកចម្ការចុងខិគម បានជាគេលើកឲ្យធ្វើធំ ក៏ចេះតែសម្ងំបំភ្លេចគុណជូនតាម៉ែឪ មកចូលដៃនឹងអាសត្រូវផែនដី គប្បីឲ្យខ្មាសមុខពេកណាស់ ៗ

សុម៉ាអ៊ីឮពាក្យខុងបេងដៀលត្មះ ក៏ខំអត់គិតនឹងរកពាក្យឆ្លើយតបពុំរួច ក៏ខំផ្ចួចផ្តើមពាក្យបានថា បើដូច្នោះយើងត្រូវតែច្បាំងគ្នាចុះ ខុង-បេងថា : បើអ្នកឯងច្បាំងនឹងយើងខ្លួនតនឹងខ្លួនក៏ [illegible] ឬក៏ច្បាំងដោយថ្មីដៃទាហាននិងទាហាន យើងក៏មានច្រើនមិនខ្លាចទេ សុម៉ាអ៊ីថា : បើដូច្នោះយើងនឹងច្បាំងគ្នាដោយកលព្យុហសឹក ខុងបេងថា : បើដូច្នោះត្រូវអ្នកឯងធ្វើកលមកឲ្យយើងមើលជាមុនចុះ សុម៉ាអ៊ីត្រឡប់ចូលទៅខាង

កង។ អស់ពួកទាហានក៏លើកទង់ក្រហមដោតឡើង ទាហានក៏ចូលព្យូហ: ព្រមគ្នា ឈ្មោះថា "អ៊ីគុយទិន" ព្យូហ: ហើយទើបស្រែកសួរខុនបេងថា: កលព្យូហ:របស់យើងនេះ អ្នកឯងដឹងឬទេ ? ខុនបេងឆ្លើយប្រាប់ថា: យើងដឹងហើយ ឈ្មោះ (អ៊ីគុយទិន) កលព្យូហ: ។

ស៊ុម៉ាអ៊ីថា: អ្នកដឹងព្យូហ:របស់យើងហើយ ចូរតាំងព្យូហ:របស់អ្នកមកយើងនឹងមើលវិញ ខុនបេងក៏ត្រឡប់ចូលទៅយកផ្លិតបក់តែម្តង ទាហានទាំងពួងក៏តាំងជាព្យូហ:ចូលមួយរំពេច ស៊ុម៉ាអ៊ីក៏ញាក់សេះដេញពលនឹងចូលវាយទើបហៅតៃលៀង ទៀវហង ឆាក់លិម ទាំង ៣ នាយចូលមកបង្គាប់ថា: ឯព្យូហ:របស់ខុនបេងតាំងក្នុងវេលានេះ មានទ្វារ ៨ អន្លើ គឺទ្វាររស់និងស្លាប់ ទ្វារចេញនិងចូល ទ្វារសុខ ទ្វារភ័យ ទ្វារបញ្ញាត ទ្វារបង្កប់ អ្នកពល់គ្នាត្រូវវាយចូលទៅតាមទិសបូព៌ចេញទៅបស្ចឹម ហើយគេចមកទិសឧត្តរ ឯទិសទក្សិណកុំគប្បីកន្ទងវាយចូលទៅឡើយ បើធ្វើតាមយើងហើយ ទាហានខុនបេងគង់នឹងបែកទៅឯង ៗ

តៃលៀង ទៀវហង និង ឆាក់លិមទាំង ៣ នាយទទួលពាក្យហើយក៏លើកពល ៣០០ វាយចូលទៅតាមផ្លូវទិសបូព៌ ទាហានខុនបេងក៏ត្រឡប់ព្យូហ:ចេញអស់ក្នុងមួយរំពេចនោះ ឲ្យទៅជាទ្វារ ១០ វិញ ទាហានស៊ុម៉ាអ៊ីក៏មិនដឹងផ្លូវដែលនឹងវាយចូលទៅបាន រត់ពានប៉ះទង្គិចគ្នា ទាហាន

ខុនបែនក៏ខួបចាប់បានបនសេកទាំងអស់គ្នា ខុនបែនថា នាយទាហានទាំង ៣ និងកូនទាហាននេះ បើយើងនឹងសម្លាប់ចេញក៏មិនបំពេញខាតទៅប៉ុន្មានដែរ ទើបឲ្យទាហានផ្លាស់យកអាវមួយទុកជាមួយនឹងសេះ ហើយឲ្យយកដីផ្ទាំងលាបមុខមាត់ទាំងអស់គ្នា ហើយបង្គាប់ថា : ឯងពលគ្នាចូរវិលទៅប្រាប់សុម៉ាអ៊ីចៅហ្វាយឯងចុះថា ឲ្យទៅសិក្សារៀនកលព្យុហៈពីអាចារ្យណាដែលចំណាប់ទៀតសិន រួចសឹមមកតនឹងយើងថា ហើយក៏លែងពួកនោះទាំងអស់ទៅ ។

លុះទាហានពួកនោះទៅដល់ ក៏ពណ៌នាប្រាប់សុម៉ាអ៊ីតាមពាក្យខុនបែនប្រាប់គ្រប់ប្រការ សុម៉ាអ៊ីបានស្តាប់ហើយក៏ខឹងខ្លាំងណាស់ និយាយនឹងអស់ទាហានថា : ខុនបែនធ្វើកិរិយាអាក្រក់ដល់យើងឲ្យបានសេចក្តីអាប់យសពេកណាស់ បើយើងមិនយកជ័យជម្នះឲ្យបានគ្រានេះ កាលណានឹងមានមុខត្រឡប់ទៅស្រុកឡុកអៀងបាន អស់អ្នកពលគ្នាចូរឧស្សាហ៍យកចិត្តទុកដាក់ជួយគ្នាធ្វើការឲ្យបានជ័យជម្នះចុះ សុម៉ាអ៊ីកាន់ក្រប៊ីអាជ្ញាសិទ្ធិឲ្យលើកពលចេញទៅតាមចម្ងាយ ហើយនាំទាហានជូនតាមក្រោយមកទៀត ។

[នៅមានត]

# សាស្ត្រាជុច

## [ អត្ថាធិប្បាយ និង អត្ថបទដើម ]

សិក្សាស្រាវជ្រាវដោយ លី-ធាមតេង

ដើម្បីបានជាពន្លឺសម្រាប់អ្នកអាន អ្នកសិក្សាស្រាវជ្រាវស្នាដៃអត្ថបទសាស្ត្រាដុចនេះ យើងសុំល្បងធ្វើការពិនិត្យសង្កេតជាមុនដូចតទៅ ៖

### ១- ប្រភព :

សេចក្ដីផ្ដើមក្ដី សេចក្ដីបញ្ចប់ក្ដី នៃសាស្ត្រានេះ ឥតមានបញ្ជាក់ប្រាប់ថា រឿងនេះ មាមប្រភពដើមដកស្រង់ ឬ ប្រតិស្នូយកពីក្នុងទីណា គម្ពីរណាឡើយ ៗ ហេតុនេះ នាំឲ្យអ្នកសិក្សាសម្គាល់ទុកជាសេចក្ដីសន្មតិមួយទៅតាមប្រភេទអត្ថបទ តាមលក្ខណៈអក្សរសាស្ត្រទៅវិញ ៗ

អត្ថបទនេះ ជាប្រភេទរឿងល្បើក ( Fable ) ដែលមានលក្ខណៈសម្គាល់ត្រង់ :

- សរសេរជាពាក្យកាព្យ សម្ដីទី ៗ តែច្បាស់មិនអណ្ដែតអណ្ដូង
- ដំណើររឿងខ្លី ៗ គ្រាន់តែឲ្យជាគតិដំបូន្មាន
- យកតួអង្គជាសត្វ ជាធម្មជាតិ (ដុច និង ត្រី)

ដូច្នេះ រួមសេចក្ដីទៅ គឺសាស្ត្រាដុច មានប្រភពជាពួករឿងល្បើក ដែលកវីនឹកឃើញ ប្រដូចប្រចមគំនិតទៅនឹងដំណើររឿងយ៉ាងខ្លី ៗ

## ២- កាលបរិច្ឆេទ :

កុំងអត្ថបទសាស្ត្រនេះ គ្មានចុះកាលបរិច្ឆេទនៃការតែងរៀងទេ នាំឲ្យមានការលំបាកការរកឲ្យបានច្បាស់ ។ បើប្រសិនជាយកសម្ដី កាព្យ សំនួរកេបារ ពាក្យសម្ដីដែលប្រើក្នុងនេះ មកធ្វើជាគ្រឿងចុះមើលពេលវេលា យើងសម្គាល់បានថា អត្ថបទនេះមិនឆ្ងាយហួសពីសតវត្សទី ១៨ ឬ ១៧ ទេ ។ ព្រោះថា បើអត្ថបទសរសេរពីសតវត្សទី ១៦-១៥ ឡើងទៅនោះ មានពាក្យសម្ដីប្លែកច្រើនពីភាសាយើងសព្វថ្ងៃ ដូចមានពាក្យខ្មែរបុរាណសុទ្ធ, ពាក្យក្លាយមកពីបាលី-សំស្ក្រឹតច្រើន... ។

## ៣- អ្នកនិពន្ធ :

នាមអ្នកនិពន្ធក៏មិនបានកំណត់ក្នុងសាស្ត្រនេះដែរ ដូច្នេះ យើងពុំអាចដឹងថាជាស្នាដៃលោកណាតែងឡើយ ។

តាមចាស់ៗ និយាយតៗគ្នា : ខ្លះថា លោកតា សុគន្ធមានបុណ្យ ដែលជានាយកសង្ឃក្នុងសតវត្សទី ១៧ ជាអ្នកតែង ព្រោះលោកធ្លាប់បានតែងសាស្ត្រច្បាប់ឯទៀតដែរ ដូចជាច្បាប់ក្រមជាដើម ។ មិនតែប៉ុណ្ណោះ គេនិយាយថា លោកតា សុគន្ធមានបុណ្យ ចង់ប្រដៅមនុស្ស ពិសេសគឺសិស្សគណផ្ទាល់របស់លោក ឲ្យស្គាល់នូវកម្លាំងនៃ "ទុក្ខសំសារវដ្ដ" ដោយលោកលើកយកធម្មជាតិមាន ដុប និងត្រីមកធ្វើជាតំណាង គឺត្រីជាសត្វលោក ឯដុបជាសំសារទុក្ខ ។ កល់ថ្ងៃ

សំសារទុក្ខមែនទៅរង់ចាំសត្វលោកជានិច្ច ឲ្យតែរុលក្បាលចូលហើយ កាន់តែតឹងតែណែនខ្លាំងឡើងៗ គ្មានបេះដូងថយ ។ ឯសត្វលោកវិញ បើទោះជាដឹងថាកងទុក្ខកងសំសារផ្ដុំនៅពីមុខយ៉ាងណា ក៏នៅតែខំសុលក្បាល មិនគិតងាកបែររកផ្លូវគេចដែរ លុះដឹងថាខ្លួនជាប់ហើយរាំខក ពេលស្រេច ទឹងកថយក៏មិនរួច ម្ល៉ោះហើយមានតែរុលទៅមុខឲ្យតាល់ តែអស់កម្លាំងត្រឹមណា ស្លាប់ត្រឹមនោះទៅ ។ នេះហើយជាទស្សនៈសំខាន់នៃល្បើក ដុប ទិង ត្រី ។

តាមពាក្យចាស់ៗ និយាយតៗគ្នានេះ គួរជឿបានដែរ ព្រោះលោកតា សុគន្ធមានបុណ្យ លោកមានបញ្ញាជ្រៅ ចង់បង្ហាញទស្សនវិជ្ជា ដែលពិបាកយល់ ឲ្យមានជារូបកាន់ស្រួលយល់ឡើង ដោយប្រើឧបមាវិធី ធៀបទៅនឹងរូបធម្មជាតិដូច្នេះ ។

បើតាមការស្រាវជ្រាវរបស់លោក ឈឹម-ស៊ុម ពីប្រវត្តិលោកវិសេសដូង ចុះក្នុងកម្ពុជសុរិយាលេខ ២ ឆ្នាំ ១៩៦៨ រាប់ក្នុងតាកង ស្នាដៃរបស់វិសេសថា រឿងល្បើកដុប ជាស្នាដៃរបស់លោកវិសេសដូង ដែរ ។ ប៉ុន្តែលោកឥតមានបញ្ជាក់ពីហេតុផល ឬ មានសេចក្ដីវែងឆ្ងាយទៅទៀតឡើយ ។

ការណ៍ទាំងនេះ ទុកនៅជាបទស្រាវជ្រាវតទៅទៀត ៖

## ៤- ឧត្តមគតិ :

ដូចបានរាប់រៀបក្នុងវគ្គស្ដីពីអ្នកនិពន្ធរួចហើយ រឿងនេះ មានន័យក្នុងការអប់រំមនុស្ស ពិសេសគឺអប់រំខាងផ្លូវចិត្តឲ្យមនុស្សបានយល់ច្បាស់នូវទស្សនវិជ្ជាព្រះពុទ្ធសាសនាផង ។ បើគេទាញយកយោបល់នេះ ពីក្នុងសាស្ត្រាដុច មកធ្វើជាដំបូន្មានទូទៅ គេនឹងស្រង់បានន័យថា :

មនុស្សដែលកើតឡើង តែងមានទុក្ខសំសារវដ្ដរង់ចាំជានិច្ចហើយ នោះជាមនុស្សមិនហៅរកក៏ដោយ ៗ ប៉ុន្តែបើគេយល់ច្បាស់លាស់ហើយ រកគៀចជៀសរួចបានខ្លះៗដែរ ដោយរំងាប់ចិត្តលោភៈ ទោសៈ មោហៈ ហើយតាំងខ្លួនឲ្យមានចិត្តស្មោះស្មើ គ្មានផ្អើលក្អាក់ផ្ដេសផ្ដាស់ ៗ

# ល្បើកជុច

## ចម្លងចេញពីសាស្ត្រាស្លឹករឹត

### បទបណ្តោលកាក[១]

៙ ថ្ងៃដោយទំនង     ដំណើរត្រីផងយាត្រា
ពេលមិនដូចណា     ត្រីស្រែកថាវើយជៀសចេញ ។
ដូចថាអើះអើ     បងអ្នកនេះតើម្តេចមិញ
ហ៊ានមកប្រើអញ     ជៀសចេញឲ្យអ្នកជាល្បែង ។
ត្រីថាបើប្លោះ     អញនឹងទម្លុះពោងឯង
ឲ្យយល់ជាក់ស្តែង     ត្បិតឯងមកនៅកំផ្លូវ ។
ដូចថាអើះហោង     បើឯងចង់លងឥឡូវ
សមត្រូវនឹងម្លូវ     ប្រហើញាំភ្ញាសាអាំង ។
ត្រីថាអើះអើ     ប៉ុនរើងទៅតើម្តេចខ្លាំង
អួតមានកម្លាំង     កំស្មានជាអញខ្លាចហោង ។
ដូចថាបើប្លោះ     កញ្ចើញមកចុះចង់លង
ឲ្យយល់នេះម្តង     ឫទ្ធីតេជះរេជដៃ ។

---

១- ឈ្មោះបទនេះ បើសរសេរឲ្យត្រឹមត្រូវគឺ "មណ្ឌុកគតិ" ប្រែថាដំណើរកង្កែប ឬ កង្កែបលោត ព្រោះសំនៀងបទនេះ មានចង្វាក់យាវវែងម្តង ហើយញាប់ញ័រ ១ ម្តង ដូចកង្កែបលោតផ្លោតទៅហើយ ដើរញាប់ ១៤-៥ ជំហានរួចលោតផ្លោតទៅទៀត ។

| | | |
|---|---|---|
| ត្រីស្លុះភ្លាមចូល | កន្ទុយរមួលហើយនែ | |
| ជំពាក់ក្រក្រៃ | ទីងថយក៏ពុំរួចឡើយ | ៗ |
| ជុចថាអើហៅ | ឥឡូវម្ដេចនៅត្រងើយ | |
| សៀមស្ទាត់កន្ដើយ | សម្រឹងសម្រាន្តធ្វើអ្វី | ៗ |
| ត្រីព្រួជុចថា | ខំស្លុះបំពារទៅទី | |
| រីឯអស់ឥន្ទ្រិយ | ដួចគៅតែរួតអាត្មា | ៗ |
| ជុចថាអើបេះ | កម្លាំងប៉ុណ្ណោះទេណា | |
| អួតឯងបំពារ | ខម្លះខម្លាយមិញតើ | ៗ |
| ត្រីថាម្ចាស់ថ្លៃ | ពាក្យខ្ញុំនេះនែបញ្ចើ | |
| ឥឡូវនេះតើ | អ្នកម្ចាស់មានបុទ្ធិក្រៃ | ៗ |
| ជុចថាបុទ្ធី | តេជៈបារមីអ្វីនែ | |
| ឯងកុំបេះស្ដី | បំអកបំអន់ឲ្យគ្នា | ៗ |
| ត្រីថាម្ចាស់ថ្លៃ | អស់ពាក្យនេះនែខ្ញុំថា | |
| ជាបៀប្រង់ទេណា | អ្នកម្ចាស់កុំយកទោសខ្ញុំ | ៗ |
| ជុចថាអើល្បែង | ឯងអួតគគ្រេងស្រេចហើយ | |
| ពិតពុំលង់ឡើយ | ខំស្លុះបំពារមកហោង | ៗ |
| ត្រីថាម្ចាស់ខ្ញុំ | សេចក្ដីពុំសមមែននែ | |
| អ្នកជុចម្ចាស់ថ្លៃ | ម្ចាស់អើយលែងខ្ញុំទៅក៏ | ៗ |

| | | |
|---|---|---|
| ដុចថាអើលែង | មារយាទអ្នកឯងទេណា | |
| អញឃាត់អញថា | ប្រែថាជៀលអញបំផាង | ៗ |
| ត្រីថាទុអញ | មួនខេះឯងមិញក្រៅក្រែ | |
| អ្នកដុចម្ចាស់ថ្ងៃ | អ្នកអើយយកតែបុណ្យហោង | ៗ |
| ដុចថាបុណ្យ ៗ | អំនួតពីមុនរំពង | |
| បុណ្យអ្ហ៊ែនោះហោង | ឲ្យដឹងរិទ្ធីតេជដៃ | ៗ |
| ត្រីថាម្ចាស់ខ្ញុំ | សេចក្ដីពុំសមមែនទែ | |
| អ្នកដុចម្ចាស់ថ្ងៃ | ប្រោសយកសម្បត្តិសួគ៌ា | ៗ |
| ដុចថាឯងបេះ | ឯងមានចំណេះបេះថា | |
| សម្បត្តិសួគ៌ា | សាច់ឯងពិសាណាស់នែ | ៗ |
| ត្រីថាអញក្រែ | ណាស់ពេកកម្រក្រៅក្រែ | |
| អ្នកដុកម្ចាស់ថ្ងៃ | អ្នកអើយយកតែផលា | ៗ |
| ដុចធ្លាស់ធ្ងើយថ្កាត់ | ថាឯសម្បត្តិផលា | |
| សាច់ឯងពិស. | គេស៊ីឯងបានបុណ្យច្រើន | ៗ |
| ត្រីថាបើព្នោះ | អ្នកហារមាត់ចុះខ្ពស់ឡើង | |
| ខ្ញុំក្រាបបាតជើង | សំពះសូមចុះសូមពាញ់ | ៗ |
| ដុចថាអញឆោត | ឯងមកបំពោតលើអញ | |
| ឯងនឹងស្អុះបេញ | បានអ៊ីជាម្ហូបធីបាយ | ៗ |

ត្រីថាទុកអញ មួនេះឯងមិញអន្តពយ
មិនសមរូបកាយ ខ្ពួនអើយអសារទេណា ។
ដូចថាមិនស្លាប់ ឯងកុំមកប្រាប់លើគ្នា
សាច់ឯងពិសា ឆ្ងាញ់ហើយរាសើមមាត់ផង ។
ត្រីថាម្ចាស់ខ្ញុំ អញព្រោសប្រាណកុំញ្ញោះហោង
កាញ់ខ្លួចចិត្តចង ក្រែងមានវេកបាបពៀរ ។
ដូចថាបើបាប សឹងស្មុយផ្ទេះឆ្អាបអញវៀរ
បៀសអស់ពាំងៀវ តែសាច់ឯងអត់មិនបាន ។
ត្រីថាអ្នកថ្ងៃ ថាម្ដេចញ្ញោះនៃពុំមាន
ធម៌ថាបាបគ្មាន ដូចអ្នកឯងស្ដីឡើយណា ។
ដូចថាអ្នកត្រី ចែងបេះសម្ដីណាស់ណា
អណ្ដើកជាក់ជា ល្អហើយទៅក្ដក់ហៅថ្កែ ។
ត្រីថាតាយហោង គានិយាយផងប្រែខ្លួន
ចំនឹមឯងថ្កែ រាជាច់ធីកាចម៌គេនៅ ។
ដូចថាអើអញ ពុំដឹងបាបមិញណាទូវ
ឯងថាមិញត្រូវ ល្បែងដូចខ្លួរហើយស៊ីសាច់ ។
ត្រីថាអ្នកដូច អ្នកមិនថយធុបពាក្យពេចន៍
អ្នកអើយបំណាច់ ខ្ញុំលោមអ្នកកុំញ្ញោះឡើយ ។

ផុចពុំស្គាប់ហោង　　រីតរឹងកន្ទួនពុំស្បើយ
ពុំមានធូរឡើយ　　គឹងឡើងស្មើរជាប់ខ្យល់ខ្ទី　ៗ
មានស្ពានតែជាក់　　ឈាមជុំចជាអ្នកខ្ញុំឥ·
ឡូវពុំដឹងអ្វី　　ត្រង់រស់ត្រង់ស្លាប់នោះឡើយ　ៗ
បើម្ដែនឹងស្លាប់　　ឲ្យខ្ញុំបានប្រាប់កូនហើយ
បណ្ដាំទុកក្រោយ　　ឲ្យអញឯងផ្ដាំឲ្យធាប់　ៗ

## បទព្រហ្មគីតិ

ក្មេងណានោះឯមបា　　ហៅបុត្រភ្ញាមកធាប់ ៗ
កូនមកហើយឲ្យញប្រាប់　　ជាទុក្ខកូនពន្ទកម្ដាយ　ៗ
ខ្លួនម្ដាយនឹងស្លាប់ហើយ　　កុំកូនអើយនៅព្រៃឆ្ងាយ
ទៅរកស៊ីឲ្យឆ្ងាយ　　ពីព្រៃនេះផុតមនុស្សម្នា　ៗ
ខ្លួនម្ដាយនេះតឹងណាស់　　និងបម្រះពុំរួចណា
ឈឺអស់អង្គអាត្មា　　ម្ដាយទំនៃផ្ដាំមាសសូន　ៗ
មាសអើយម្ដាយស្លាប់ទៅ　　បូរមាសនៅប្រយ័ត្នខ្លួន
រកស៊ីធាប់ជ្រកពួន　　ដោយព្រៃស្ងាត់កុំប្រហែស　ៗ
ឃើញមនុស្សកុំទ្រមឹង　　ឈប់សម្ងឹងមើលក្រអេះ
ឃើញធាប់រត់កុំធ្វេស　　ក្រែងវាចាក់នឹងចំបូកណា　ៗ

បើមាសស៊ីកូនបក ឆាប់មុជជ្រកឲ្យបាត់ខ្លួន
ក្រែងមនុស្សគុំខ្ទកជួន ឃើញកូនស្ងួនក់លោពាក់ ។
មាសអើយមួយវិញទៀត ប្រកបភ្ញៀតដែលមនុស្សដាក់
ផុតនោះកុំបីអ្នក ដើរត្រង់នោះជៀសឲ្យឆ្ងាយ ។
ខ្លួនអញខូចតាំងម្ល៉េះ ហេតុប្រហែសគិតសប្បាយ
ចូរមាសមើលខ្លួនម្ដាយ ហេតុតែឆោតពាល់ស្លាប់ខ្លួន ។
ហេតុនោះកូនព្រលឹង ចូរតឹងឲ្យមាំមួន
ម្ដាយស្លាប់ ៗ ហើយស្ងួន កុំកូនឆោតដូចម្ដាយឡើយ ។
ឯមច្ឆានោះនៃ សោកកូនក្រៃគន់ពុំផា
រន្ធត់អស់អង្គា លុះសន្ធប់បាត់ស្មារតី ។
ទៀនខ្ញួញពាល់សន្ធប់ ញ័រចំប្រប់អស់ឥន្ទ្រិយ
លុះដល់មានស្មារតី ខ្ញួញរៀបរាប់សព្ទដោយក្រៃ ។
ឳអញគិតទោះហើយ កូនមាសអើយចង់តែក្ស័យ
ខ្លួនអើយស្លាប់ឆាប់ពៃ អញនឹងនៅអ្វីឡើយណា ។
រស់ហើយកំលំបាក ខ្លួនគោកយ៉ាករង់វេទនា
មិនចង់រស់ឡើយណា ឃើញកូនកំរឹងខ្លោចផ្សា ។
ក្រើខ្ញួញនះនៃ ពាល់តែក្ស័យជីវិតណា
រីឯកូនមច្ឆា រកស៊ីតែឯកអង្គឯង ។

វិនិតាននេះនៃ ដុចនិងត្រីនោះរាំកែង
ដើរទៅរកស្ទុះស្មែង ក៏ជួបជួននោះឯងហោង ។

## បទបណ្ដោលកាក

នេះនឹងសម្តែង និទានថាថ្លែងទំនង
ពីម្ចាស់ដុចហោង ឲ្យអ្នកផងដឹងដំណើរ ។
ម្ចាស់ដុចលុះព្រឹក ព្រហាមរលឹកទៅមើល
បេះម្ទេសទុកទើរ មើលទៅថ្ងៃរះក្ដីជាក់ ។
ស្រេចគាត់ស្ទុះដាំង ទៅយកសៀនខាងប្រចក្នាក់-
ដៃដែលគាត់ជាក់ ប្រចទៅខាងក្អមនោះនៃ ។
ហើយឈោងទៅសិត ទឹកមកខ្ចុរមាត់ហើយនៃ
យកកន្សែងស្ងួត មកខេបម្ស៉ាហើយណា ។
លុះខេបស្រេចហោង ស្ទុះទៅចាប់ដងប្រវា
នឹងកាំបិតព្រា ទឹងផ្តៅមួយដើមទៅផង ។
គាត់ចុះទៅទូក អង្គុយលូកខ្សែដែលចង
មកស្រាយចំណង ដែលចងទូកគាត់សព្វថ្ងៃ ។
ស្រាយរួចប្រានទូក គាត់អុំតគ្រុកទៅព្រៃ
ដែលដាក់ដុចនៃ ក្មេកតែងរំពៃចេញស្តាំ ។

អុំបានតិចទៅ បាយាបទុំនៅឈើតាំ
លានគីបធ្វេងស្ដាំ ហើរទៅហើរមកជាក់ស្ដែង ។
ម្ចាស់ដុចថា៖ បាយាបវើយពោរឥតក្រែង
ស្មើរធាបអំបែង ក្បាលអញពុំដឹងមនុស្សម្នា ។
ថ្ងៃនេះទីទៃ មានលាភមានជ័យឬជា
ឥតលាភទេណា បាយាបគៀនអង្គឹគ្គ ។
អុំទៅទៀបដល់ ដុចនោះម៉ិនយលត្រូវត្រើ
ដល់មួយឥតបី សន្សឹមម៉ិនបានទៅស្ទូ ។
ខានដុចបីប្អូន នោះសោតជាក់ដូនប្រកល្អ
ទឹងបានទៅស្ទូ តែដុចបីប្អូននោះឯង ។
គាត់អុំទូកដល់ ដុចបំណោរយល់ជាក់ស្ដែង
ជឿងជាក់អរឯង កខិបកខុបដើកដោក ។
រាតទូកឈោងចាប់ កន្ទុយដុចជាប់ទាញមក
ក្រពើរ៉ាយក ត្រីដុចនោះទៅស៊ីបាត់ ។
ម្ចាស់ដុចចុកទ្រូង ជេរម្ដាយរលូងពេកក្ដាត់
ទៅដុចមួយថ្ងាត់ តាចាស់ខំធ្មៀតរលេញ ។
ធ្វើជាមាត់គរ ញញឹមញញែមឡើងវិញ
ធ្លាប់ពីមុនមិញ ក្រពើស៊ីអស់គ្មានសល់ ។

តែឥឡូវឯង ឃើញមួយកណ្ដាលទឹនថ្កល់
លង់មួយចេះយល់ ក្រញាន់ក្អែកសបង្គ្រាន ៗ
វិជ្ជុចយល់ម្ចាស់ សរសើរខ្ពងណាស់ហើយអរ
ធ្វើយប្រាប់ម្ចាស់មក ពីកន្ទឹកនោះអន្ទាក់ ៗ
កាអើយអ្នកតា ស្ដាប់ខ្ញុំសព្វាប្រាប់អ្នក
តាឲ្យជឹនដាក់ កាលត្រីវមកនោះណា ៗ
វែហលមកដល់ខ្ញុំ វាមិនបារម្ភសោះសា
ជាចៅអ្នកតា ប៊ីនចន់លន់លលើ ៗ
ស្ដីថាកាឃ្មាន ម្ដេចកាបង្គ្រាននេះតើ
ផ្លូវដែលអញដើរ ជៀសចេញអញទឹនដើរទៅ ៗ
ខ្ញុំថាផ្លូវកា ពីដូនពីតាមកនៅ
កន្ទៃព្រៃនេះក្លូវ អន្ទាលអញមិនដឹងផង ៗ
ត្រីថាកាខ្ចប កាលកានៅតូចណាស់ហោង
ផ្លូវប្រែកជ្រលង ប៊ឹនបួនោះសឹងអញក្រាប ៗ
ខ្ញុំថាបើប្លោះ ចក្ដអើយធ្វើម្ដេចលន់គាត់
ខ្ញុំចូលមកកាត់ ទំលាយលន់មើលឥឡូវ ៗ
ត្រីថាអើអញ លន់ឯងមិនចេញនោះក្លូវ
អញបោលឥឡូវ ទំលាយឲ្យបាក់ឆ្អឹនឆ្អែន ៗ

ខ្ញុំថាបើបោះ    អញ្ចើញមកចុះកុំក្រែង
ធ្នឹងអញនេះឯង    តែងជាសម្រាប់ឲ្យអា    ៗ
ត្រីស្មុះភ្ញាមចូល    កន្ទុយមួលទទា
ប្រជួបទ្វារជា    ប្រមាញ់ដំរីសោះសា    ៗ
ជុចដណ្ដឹងត្រី    ថាឯងធ្វើអីបោះណា
អ្នកឯងបំពារ    ទំលុះទំលាយណាទៅ    ៗ
ខាសពាក្យជុចខ្ញុំ    ប្រឹងឡើងពិតពុំរួចទៅ
មកនៅខាងជួរ    ទ្រមឹងក្នុងជុចព្រងើយ    ៗ
ត្រីថាទុអ្នក    ជុចថ្ងៃកុំអាក់ចិន្តា
ខ្ញុំម្ចាស់បានជា    អ្នកអាងទីងអ្នកជុចថ្ងៃ    ៗ
អាសូរខ្ញុំទៅ    ឲ្យខ្ញុំរស់នៅផងនៃ
ខ្ញុំចូលប្រស្រ័យ    ជាខ្ញុំបម្រើអ្នកហោង    ៗ
ខ្ញុំថាអញនោត    ឯងមកបំពោតលើលង
ម្ចាស់អញបំណង    ចង់ជ្រក់តែខ្លួរសត្វថ្ងៃ    ៗ
ត្រីឮពាក្យជុច    កិតញ័ររន្ធត់ពេកក្រៃ
ទុអ្នកម្ចាស់ថ្ងៃ    អ្នក ប្រោសយកតែបុណ្យផង    ៗ
ខ្ញុំថាកុសល    អញមើលមិនយល់ទេហោង
ឆ្ងាយក្រែកខ្វង    អញមកពុំបានឡើយណា    ៗ

ដុចដំណាលប្រាប់ ឲ្យម្ចាស់ស្ពែនស្លាប់ហើយក៏
ដំណើរគាថា កាលត្រឹមគឺត្រូវនោះនៃ ៗ
ម្ចាស់ស្លាប់ហើយណា ផ្ដែផ្ដាំដុចថាកុំធ្លោយ
ថ្ងៃនេះថ្ងៃក្រោយ អ្នកលេងឲ្យមួនពីដៃ ៗ
ផ្ដាំស្រេចហើយណា ដាក់ដុះម្ហីម្ហាវៃ ១
រួចស្រេចហើយនៃ គាត់អុំទូកវិលវិញខ្ញី ៗ
អុំមកក្នុងបឹង ហើយគាត់សម្លឹងរំពៃ
ថានុអញត. ឡូវនេះរាំថ្ងៃខ្ពស់ជួន ៗ
គេខុសបានគិត ហើយអញទឹងក្ដិចត្រកួន
ត្រកៀតត្រាវស្ងួន អន្ទក់មួរសណ្ដាន់ ៗ
បេះបានសព្វគ្រប់ គាត់អុំគ្មានឈប់រួសរាន់
ដល់ហើយទ្រនាន់ ចងទូកហើយឡើងម៉្ហូម៉ា ៗ
បានដងប្រវ៉ា ទឹងកាំបិទព្រាហើយណា
ពុនតាំងត្រីប្រា និងឧសបន្ទុម្ហូវជា ៗ
ដល់ទៅមុខផ្ទះ ហើយទើបតាប្រាសឧសណា
រីឯភរិយា ភ្ញាក់ឡើងឃើញប្ដីត្រីផង ៗ
ឯប្ដីនោះណា កាប់ត្រីម្ហូមាហើយហាន
លាងដៃហុតហ្នង គាត់ចូលទៅដេកលក់ក្រៃ ៗ

រីឯភរិយា　　ស្ទុះហើយម្នីម្នាវៃ ៗ
ដស់ដួសហើយនៃ　　ចូលទៅដាស់ប្ដីនោះណា ។
អ្នកអើយអ្នកឆាប់　　អញ្ជើញប្រញាប់ពិសារ
ក្រែងត្រជាក់ណា　　ហើយអ្នកពិសាមិនបាន ។
ប្ដីក្រោកម្នីម្នា　　ចរចេញទៅឯក្រៅហាន
ហើយហៅថាភាណ　　យកទឹកមកទន់ឆាប់ខ្ញី ។
ទន់ស្រេចហើយណា　　រីឯភរិយានោះនៃ
លើកបាយលើកត្រី　　អស់ទូវសម្ហាមុខ ។
មានអាំងសាចប្រៃ　　អាំងសាចនោះនៃគ្រាន់ជ្រក់
ទឹកគ្រឿងជ្រលក់　　អន្លក់សណ្ដែកត្រកួនខ្ចី ។
ហូបស្រេចហើយណា　　រីឯភរិយានោះនៃ
គាត់មួរបារី　　ហើយគាត់បៀកស្លាឲ្យប្ដី ។
រីយើងនិទាន　　ដំណើរដោយដានដុចត្រី
សួរសេចហើយនៃ　　បរិបូណ៌តែនចប់ម្ល៉េះហោង ។

# រាជកុល

## (ក)

### បទកាកគតិ

គិតស្រេចហើយនៃ    មានកាលមួយថ្ងៃ    ឡើងទៅគ្រប់គ្នា
ទីងពិតទូបេថ្កាន    ព្រះបទូរាជា    ថ្លែងពីអស្ស
ឲ្យស្ដេចប្រាបហោង ។

កាលនោះសោតណា    មន្ត្រីមួយជា    ជំក្រែកទ្វង
ចូលទៅជួញជន់    កំបង់ភបរង    ទូលដោយទំនង
ពីសេះនោះណា ។

បពិត្រក្សត្រក្សាន្ត    យើងខ្ញុំសូមតាន    ទូលព្រះរាជា
ឲ្យប្រាបហឫទ័យ    ក្សត្រថ្លៃឲ្យជា    ដំណឹងអស្ស
សេះមួយនោះនៃ ។

ត្បិតយើងខ្ញុំយក    សេះសួគ៌មង្គល    ប្រសើរថ្លាថ្លៃ
សេះព្រះរាជា    មហិមាច្រើនក្រៃ    ផ្ទឹមពុំបាននៃ
សេះមួយនោះហោង ។

ប្រសិនក្សត្រក្សាន្ត    យល់សេះគល្យាណ    ប្រសើរសោភា
ទីងសព្វព្រះទ័យ    ពេកក្រៃមហិមា    យកសេះនោះណា
បង្កើនប្រពៃ ។

ឯសេះនោះណា ឃើញទៅដៃតា តាស់មួយដងទៃ
តែងដឹកទៅចង រក្សាសព្វថ្ងៃ សេះនោះប្រពៃ
ល្អឥតផ្ទឹមបាន ។
កាលនោះក្សត្រា ស្ដេចពជអម្ចាស់ ទូលទើបស្ដេចមាន
ព្រះបន្ទូលខ្ចី អំពីសេះមាន ហឫទ័យចង់បាន
សេះនោះមហិមា ។
ស្ដេចបន្ទូលហៅ ថាវើយឈ្មោះពៅ ឯងឆាប់មីម្នា
ទៅយកឲ្យបាន ហើយយកទាំងតា តាស់តែងរក្សា
សេះនោះមកផង ។
អមាត្យក្រាបលា ទទួលអាជ្ញា នាំគ្នាទៅហោង
ដល់ផ្ទះតាតាស់ នោះច្បាស់ជាម្ដង ថ្លែងដោយគន្លង
ព្រះពជប្រញាប្តិ ។
ថាហៃតាតាស់ ព្រះបន្ទូលត្រាស់ ឲ្យតាទៅឆាប់
ឥឡូវនេះឯង កុំលេងសារស័ព្ទ ម្ល៉ោះហើយប្រញាប់
យកសេះទៅផង ។
តាតាស់នោះណា ស្ដាប់ពាក្យអាជ្ញា ដូច្នោះហើយហោង
កិតញ័រជើងដៃ កើតភ័យកិតផង តាស់ពីនាក់ហោង
ភ័យពន់ប្រមាណ ។

ការសួរតាចាស់ គាត់ភិតភ័យណាស់ ទប់ទល់ពុំបាន
ដាលដល់សន្លប់ ស្ងួតស្ងប់ប្រាសប្រាណ ស្មារតីសោតគ្មាន
ស្ទើរក្ស័យជន្មា ៗ

លុះមានស្មារតី យំហើយស្រដី ទៅនឹងភរិយា
នាងអើយចូរស្តាប់ អញប្រាប់ទោសា សមយើងមរណា
ពុំលែងឡើយហោង ៗ

ទុះយើងទាំងពីរ ចាស់ហើយចំណារ តែងមានភ័យផង
ពីក្មេងលុះចាស់ ភ័យណាស់ច្រើនផង ទុះយើងតែងរង
ភ័យលុះមរណា ៗ

នាងអើយចូរចាំ ពាក្យអញផ្តែផ្តាំ ចូរនាងរក្សា
ជីវិតឲ្យស្ងៀម ទំរាំមរណា កុំបីមុសា
ធ្វើបាបឡើយហោង ៗ

ថាបើអញទៅ ដល់ក្សត្របមទៅ ឥស្សូរច្បះច្បង
លោកឲ្យធ្វើទុក ធ្វើទោសអញបង់ ពុំលែងឡើយហោង
លុះក្ស័យជន្មា ៗ

ដូចចាស់ស្តែងស្តាប់ ប្តីយំខ្ញូញប្រាប់ ដូច្នេះហើយណា
ពុំអាចទប់ទល់ គម្ពល់គាគ្នា សឹងសោយសោកា
នឹងប្តីនោះហោង ៗ

ជូនចាស់ភ័យក្រៃ ជីវិតប្រល័យ បង់បាត់ឆាត្រ(១)
បងប្រុសស្វាមី ទីទៃនឹងគ្នា ថ្ងៃនេះឯណា
ប្រាកដជាម្ដង ។

ជូនចាស់ទូញថា នុអញកំព្រា ពិបាកក្ដាត់ហោង
ម្ដេចឡើយព្រាត់ប្រាស ខ្វាយខ្វាត់ជាម្ដង បាបនោះឲ្យវង
ទុក្ខទោសច្នេះណា ។

នក្សត្រឧត្ដម បង្រាសប្ដីខ្ញុំ ឲ្យលុះមរណា
ឲ្យយើងប្រាសព្រាត់ ខ្វាយខ្វាត់ពីគ្នា ឲ្យអញអសារ
បាបម្ដេចអម្បាយ ។

នុប្ដីសម្លាញ់ ប្រាសពីទ្រូងអញ បាត់ទៅឋានឆ្ងាយ
ថាបើនឹងស្លាប់ គួរគាប់នៅអាយ តិចហើយខ្ញុំងាយ
នឹងស្លាប់ព្រមផង ។

អ្នកអើយខ្ញុំផ្ដាំ ប្អូនអ្នកម្ចាស់ចាំ ពាក្យខ្ញុំប្ដេជ្ញា
ថាបើអ្នកក្ស័យ ប្រល័យជន្មា ឲ្យខ្ញុំដឹងក៏
នឹងស្លាប់ទៅផង ។

ជូនចាស់នោះណា ផ្ដាំមកអាជ្ញា អង្វរអង្វង
ហើយក្រាបសំពះ ទៀបបាតជើងធង តាមដោយទំនង
ដំណើរនោះនៃ ។

---

១- ពាក្យថា ឆាត្រា នេះ ដូចជាមិនមានន័យ ។

បពិត្រអាផ្កា ប្អូរអ្នកករុណា អន្ទរក្សត្រថ្ងៃ
កុំឲ្យសម្លាប់ ប្តីខ្ញុំក្សិណក្ស័យ អ្នកបានបុណ្យក្រៃ
លែងលើសផលផង ។

រីសេះនេះណា ប្តីខ្ញុំពុំផា ចោរលួចហើយហោង
បិត(១)មកសុំស្រូវ នោះគួរបាប់បង់ រក្សាឥតគ្គង
ដល់តិចឡើយណា ។

ជូនចាស់ផ្តាំប្តី អ្នកខំស្រដី ទូលមហាក្សត្រា
ដោយពិតពុំលាក់ កុំកួតមោសា ក្រែងអស់ទេវ្តា
ពុំជួយយើងហោង ។

កាលនោះអាផ្កា ស្តាប់ជូនទីងតា ខ្ញួញក្រែកនួង
ថ្នាក់អ៊ូទីងយំ ដាលដំទ្រូងផង បទគាត់ឥតគ្គង
ទីងក្សត្រជៀសជ័យ ។

ក្សិណនោះឯតា ចាស់ពាប់អស្សា ដឹកកាលនោះនៃ
នៅទាំងពីប្អាក គោកយ៉ាកពេកក្រៃ ពោះសោតសង្វៃ
សន្ធឹកសោតសល់ ។

រីក្អុកទាំងសង(២) មានទឹកហូរផង ដោយមានទុក្ខទល់
អនាថអាណិត គង់គិតនៅដល់ ប្រពន្ធអម្ពល់
ពេញទាំងទុក្ខា ។

---

១- ពាក្យបិតនេះ មកពីពាក្យថា ឡើត ។ ២- ពាក្យសៀម ប្រែថា ២ ។

ញ័រខ្លួនរន្ធត់ ដៃកាន់ឈើច្រត់ ទំទប់យាត្រា
ទំដឹកទាំងសេះ ស្ទើរប្រេះទុក រំពឹងមរណា
ពុំក្លួចឡើយនៃ ។

កាលនោះតាជា នាំសេះនិងតា ចាស់ដល់ក្សត្រថ្លៃ
ឡើងទៅក្រាបទូល អង្គក្សត្រថ្លៃ ប្រោសប្រាណពីភ័យ
ចាស់សោយសោកា ។

កាលនោះព្រះបាទ ព្រះច័ន្ទរនោថ ស្តាប់ពាក្យអម្ចាស់
ស្តេចជ្រាបអស់ក្តី អំពីដូនតា ទូរកជអស្វា
សេះសព្វប្រពៃ ។

ហើយស្តេចទតយល់ សេះសួគិមង្គល ប្រសើរថ្លៃថ្លៃ
ស្តេចសព្វទ័យ មហិមាពេកក្រៃ ក្រាស់ក្រៃវិស័យ
លែងលើសជាយា ។

លើសលែងបុត្រី នាងទេ ចចាំងបី ប្រសើរសោភា
លើសកជសម្បត្តិ មេរ្យរត្នសីមា ស្តេចអភេស្វក
ស្មើកជស្តេចហោង ។

ស្តេចសព្វព្រះទ័យ ទឹងសេះនោះនៃ ក្រាស់ក្រៃកន្លង
ហើយស្តេចគាស្វរ ទៅតាចាស់ផង យកមាសមួយស្បោង
ឲ្យតានោះនៃ ។

ស្ដេចមានព្រះតម្រះ ទៅនឹងតាចាស់ ពីរោះប្រពៃ
ថាចូរតាយក មាសនេះសំរៃ តាកតាយសព្វថ្ងៃ
ចិញ្ចឹមខ្លួនហោង ។
តាចាស់នោ ទទួលសុវណ្ណ ពីក្សត្រត្បេះត្បង
ហើយថ្វាយបង្គំ ប្រណម្យលាផង វិលវឹងទៅផ្គង
កាន់ស្ថានអាត្មា ។
ហេតុព្រះបារមី ពន្លកពោធិ បំពេញជូនតា
ឲ្យបានសក្តិយស របស់គណនា រូបឆោមសោភា
កើតជាកេងផង់ ។
តាចាស់នោះណា រូបឆោមឆាយា កម្លោះឥតផ្គង
ល្អដូចទេវបុត្រ ប្រាកដឥតហ្មង ពុនតាំងមាសផង
ទៅផ្ទះអាត្មា ។
ចាស់ទៅបាន ក្សិណនោះប្រែប្រាណ រូបឆោមសោភា
កើតជាក្រមុំ ឧត្តមថ្លៃថ្លា ដូចទេពអក្ខា
ពីស្មតិនាយហោង ។
ផ្ទះបែកបាក់ ជញ្ជាំងធ្លាយធ្លាក់ ស្ទឹកជាំជអស់ផង
នាបនូត របូតតែងគោង បាក់សុះហ្មត់ហ្មង
ស្ទើរដេកពុំបាន ។

ហេតុបុណ្យបារមី ព្រះពង្សពោធី បំពេញឲ្យបាន
ខ្ទមបាក់បែកបែរ ប្រែកើតជាស្ថាន ប្រាសាទពិមាន
សឹងល្អប្រពៃ ។

ពេញសឹងប្រាក់មាស ទ្រព្យផងពោរពាស អនេកក្រាស់ក្រៃ
មានភោជន៍អាហារ សំពត់អាវស្បៃ ជូនចាស់បិតលើ
ប្រាសាទមាសផង ។

តាចាស់ដើរដល់ រមិលមើលយល់ ប្រាសាទឥតហ្មង
យុងយល់ករិយា អាត្មានោះហោង រូបឆោមសព្វផង
ពុំយល់ឡើយណា ។

តាចាស់កាន់កាំង ឈរស្រសាំងកាំង ទើបដណ្ដឹងថា
ហៃនាងក្រមុំ ឧត្ដមថ្លៃថ្លា នាងមកពីណា
ផ្នែកក្រៅវិស័យ ។

ជូនចាស់ស្ដាប់ហើយ ទៀងទើបគាត់ឆ្លើយ ប្អូនតាថាហៃ
អ្នកប្រុសកម្លោះ ពាក្យនោះក្រក្រៃ ខ្ញុំនេះវិស័យ
ជាចាស់ទេហោង ។

ម្ដេចឡើយថាខ្ញុំ ជាស្រីក្រមុំ បំអកខ្ញុំផង
ខ្ញុំយល់ពិបាក គោកយ៉ាករស់រង កម្មពៀរខ្ញុំហោង
ពិតពីបុរាណ ។

មួយសោកប្ដីខ្ញុំ　ក្សត្រផ្ទៃឧត្ដម　លោកថាទោសមាន
បងតែតាប់សេះ　មិនអេះក្សត្រក្សាន្ត　ឲ្យនាំតាំងប្រាណ
តាំងសេះទៅផង ។ (១)

អ្នកមកពីណា　ទើបធ្ងើយដោះសា　ខ្ញុំនៅនេះឯង
ខ្ញុំពុំពាយឆ្ងាយ　ចំអកនាងឡើយ ។
ខ្ញុំឈ្មោះនេះណា　អ្នកផងហៅថា　តាទូរគីហើយ
ប្រពន្ធអាត្មា　ខ្ញុំណាអ្នកអើយ　ឈ្មោះនាងដើមឡើយ
ទុគ៌តកុមារី ។

យើងពីរអ្នក　ពិបាកកំព្រា　កំសត់ពេកក្រៃ
តែងដើរសូមទាន　គេជាប្រក្រតី　នោះទើបបានស៊ី
រស់ជីវិតបាន ។

ដូនតាស់ស្ដែងស្ដាប់　ពាក្យប្ដីថ្លែងប្រាប់　អំពីដើមទង
កំសត់អាត្មា　ខឹងស្វាមីផង　ដឹងដោយទំនង
ដំណើរនោះណា ។

ដូនតាស់ស្រដី　ប្រាប់ទៅកាន់ប្ដី　ខ្ញុំឯងនាមា
ទុគ៌តកុមារី　ឈ្មោះពីមាតា　ក្សត្រដូចអ្នកថា
ប្រាប់ខ្ញុំនោះហោង ។

---

១- ត្រង់នេះបាត់ពីរឃ្លា ។

បើអ្នកជាប្ដី ខ្ញុំអើយហេតុអ្វី អ្នកល្អកន្ទង
កើតជាកម្មោះ ដូច្នេះមកផង ហេតុនោះឯងហោង
ខ្ញុំឆ្ងល់ពេកក្រៃ ។
តាចាស់សោតណា ស្ដាប់នូវកិរិយា ឆ្លើយទៅថាហៃ
នាងឈ្មោះទុគិត រូបល្អប្រពៃ ហេតុម្ដេចច្នេះនៃ
អញឆ្ងល់ពេកណា ។
ពាក្យយើងស្រដី រំលឹកអំពី មុខនោះត្រូវគ្នា
ប្រាប់ពីកំសត់ ទុគិតអាត្មា ម្ដេចឡើយប្រែជា
ក្រមុំល្អក្រៃ ។
ផ្ទះចាស់បាក់បែក កើតឡើងល្អផ្លែក ជាស្ថានប្រពៃ
ជាប្រាសាទមាស ឧកាសថ្វាថ្ងៃ យល់ឆ្ងល់ពេកក្រៃ
ពុំដឹងបើថា ។
បើគេថាធាត អញចង់ពិសោធ មើលស្រូវអាត្មា
ដែលសេះស៊ីមិញ ល្អវិញទុកជា អស្ចារ្យហើយណា
សមកើតទៀតហោង ។
តាចាស់នោះណា ហៅកិរិយាថា បើឈ្មោះយើងលង
ទៅមើលស្រូវស្រែ ដែលសេះស៊ីមិញ ល្អហើយគាប់ណា
យើងនេះឃើញជា សេះឲ្យគុណហោង ។

បុរសទាំងពីរ　គិតហោះហើយហើរ　ដើរទៅកាន់ស្រែ
មៀងមើលទៅស្រូវ　មិញក្បូរស្រាប់តែ　ទុំពេញទាំងស្រែ
អរផុតគណនា ។

បុរសទាំងពីរ　ក្សាក្សាក់ឥន្ទ្រីយ៍　រំពឹងគិតថា
សមសេះឲ្យផល　យើងយល់កាលគ្រា　នេះដឹងទើបជា
អស្ចារ្យម្ល៉េះហោង ។

ឱសេះនេះណា　សមសេះទេព្ដា　ពុំទេឡើយហោង
គាប់ឲ្យដល់យើង　ចុំប្កើងកទ្ទង　ក្រៃលែងអ្នកផង
នៅមនុស្សលោកនាយ ។

អ្នកពីរនោះណា　ម្ល៉ោះហើយនាំគ្នា　សង្វាតខ្វល់ខ្វាយ
ខិតខំច្រូតស្រូវ　យកទៅចែកចាយ　ឲ្យសព្វទាំងឡាយ
ពុំអស់ឡើយហោង ។

ច្រូតស្រូវនោះណា　សព្វទិនទៅ　ពុំអស់ជាម្ដង
ច្រូតទៅឯមុខ　ឯក្រោយនៅពេញ　បានដូចបំណង
ប្រុសប្រុងប្រាថ្នា ។

មិនប៉ុន្មានម្ល៉ោះ　អ្នកទាំងពីរនោះ　បរិបូណ៌មហិមា
ឬទ្រព្យសម្បត្តិ　ច្រើនក្ដាត់គ្រៀបគ្រា　សោឡសកោដ្ឋា
ឃ្លាំងខ្ទមទ្រព្យផង ។

ឬអ្នកទាំងពីរ    និត្យនៅឋិតថេរ    ប្រសើរឥតហ្មង
បង្កើតកូនប្រុស    កូនស្រីឥតគ្នង    ខ្ញុំស្រីប្រុសផង
អនេកក្រាស់ក្រៃ ។

ប្រុសទាំងពីរ    បានជាសេដ្ឋី    សម្រាប់ក្សត្រថ្ងៃ
ជាសុខសប្បាយ    ពណ្ណរាយសព្វថ្ងៃ    ប្រាសលែងទុក្ខភ័យ
ក្សៀណក្សត្រនោះហោង ។

មាសប្រាក់កព្រា    ឲ្យមានអាត្មា    ប្រសើរកន្ទង
ឲ្យទៅជាមាន    សម្បីយាយបកផង    តាមដោយគន្ទង
ព្រះពុទ្ធទាំងឡាយ ។

និមានសេដ្ឋី    យើងស្មេះទុកខ្ញី    ហើយទើបនិយាយ
វិលវេសទៅក្រោយ    ថ្លែងដោយបរិយាយ    និមាននៅឆ្ងាយ
តាមដោយគន្ទង ។

ឬមហាក្សត្រា    ព្រះចន្ទកជា    បានសេះហើយហោង
ស្ដេចឲ្យគេក្បា    អាសោឥតគ្នង    ប្រដាប់កេងចង
សេះសោតប្រពៃ ។

ប្រដាប់កម្រាល    ពូកគ្រែកន្ទេល    ដូចមនុស្សវិស័យ
ហាក់ដូចបុត្រី    ទាំងបីនោះនៃ    ស្ដេចសព្វព្រះទ័យ
ថ្លែងថ្លឹងពុំបាន ។

ហេតុព្រះបារមី ព្រះពង្សពោធិ៍ ច្រើនទើបស្តេចមាន
ហយទ័យស្នេហា យាត្រាទៅឋាន កេងសេះនោះបាន
បីដងមួយថ្ងៃ ។

បើស្តេចទៅដល់ ព្រះហស្តមង្គល បពោសប្រពៃ
អង្អែលអស់អង្គ ប្រដៅយ៉ាន(១)អាជានេយ្យ ពុំដែលលោះថ្ងៃ
ដំមួយតិចឡើយ ។

ទោះយប់ទោះថ្ងៃ ព្រះកជហយទ័យ ក្បត្រាក្បត្រើ
ពុំបានស្នេហា ពុំគ្រាន់ទីងស្បើយ ពុំផ្អែតផ្អូន់ឡើយ
ទីងសេះនោះណា ។

យូរបន្តិចទៅ ក្បិណនោះឯទៅ កជកុលអាសា
ស្តែងស្តេចរិះគិត ក្នុងចិត្តចិន្តា រីឯកមា
អញឲ្យអ្នកផង ។

ដឹងឈ្មោះអញណា ប្រាកដហៅថា កជកុលសោះហោង
ឲ្យស្គាល់គ្រាន់គ្រប់ សាយសត្វនេះមួន ទើបអស់អ្នកផង
ហៅអញឈ្មោះណា ។

ពោធិសត្វគិត រំពឹងក្នុងចិត្ត ស្រាប់ស្រេចប្រពៃ
ហើយទើបស្រែកស្រៀវ ខ្ញាខៀវវិស័យ សត្វសេះអាជានេយ្យ
ពុំប្តូកឡើយណា ។

---

១- ពាក្យសាស្ត្រ ប្រត្តីយ៉ង ។

ក្សត្រថ្លៃឧត្តម ព្ទួសព្ទូសេះយំ ប្រាប់ព្រះទេយា
ព្រួយព្រះហឫទ័យ ស្ទើរក្បែរជន្មា បទស្តេចស្នេហា
ស្រឡាញ់សេះសល់ ។

ទើបបើកព្រះសូរ ព្រះឱស្ឋមធុរ ឱះឱអញឆ្ងល់
សេះអញនេះណា តើមានកន្ទុល់ ជម្ងឺដិតដល់
ឬម្តេចចេះណា ។

ឬមួយស្រេកទឹក ឃ្លានស្មៅពីព្រឹក ពុំទាន់គោគ្គា
ក្រែងអស់អ្នកផង ពុំសូវរក្សា ឬយល់ញីជា
ក្រសាលសប្បាយ ។

ស្តេចទ្រង់ចិន្តា ទើបឲ្យហោរា ទាយឲ្យយល់ធ្លាយ
ដោយទូលហោបល់ យង់យល់ទូលាយ ទើបហោរទូលទាយ
ដោយដឹងនោះហោង ។

បពិត្រក្សត្រា ដោយជាតិហោរា ខ្ញុំទាយនេះហោង
សេះចង់បានពជ កុលនោះហោង ដោយទំនាយផង
ពុំឃ្លាតឡើយណា ។

ស្តេចស្តាប់ហោរហើយ អរេតត្ថមឡើយ ទើបបន្ទូលថា
ប៉េះឈ្មោះអញឯង នឹងកត់នាមា សន្ធតហៅជា
ពជកុលឈ្មោះនៃ ។

ស្ដេចឲ្យហោរ ទាយរកពេលា ឧត្តមប្រពៃ
ប្រកបឫក្សពារ នូវការជោគជ័យ ប្រាប់ឲ្យចងដៃ
ដូចកាលមកផង ។

ស្ដេចឲ្យគត់ឈ្មោះ ពោធិសត្វនោះ រាជកុលហើយហោង
ឬទ្រព្យធនធាន គេបានគួបផង ដៃដូចអ្នកផង
ការអស់កូនចៅ ។

ទ្រព្យបំណាន់ដៃ មាសប្រាក់ចងដៃ ស្ដេចឲ្យយកទៅ
ឲ្យជាងក្បាច់ក្បូរ គូរគូរឆ្លាក់ឆ្លៅ គ្រឿងប្រដាប់ទៅ
រាជកុលអាជនេយ្យ ។

ប្រដាប់ធ្វើជា កើតកងអស្សពាហ៍ រុងរឿងប្រពៃ
ដូចទិព្វវិមាន សួគ៌ស្ថានល្អក្រៃ កម្រាលស្ដេចទៃ
ល្អឥតផ្ទឹមបាន ។

ប្រដាប់ស្រេចហើយ ក្សត្រាត្រាណត្រើយ ហឫទ័យក្សេមក្សាន្ត
ហើយឲ្យរក្សា អាសូរពុំបាន(១) ពិតពីឲ្យមាន
ខេរខឹងឡើយណា ។

កាលៈនោះរាជកុល ព្រះអង្គគិតដល់ នាងនាថស្រីថ្លៃ
អ្នកផ្អើលក្នុងចិត្ត គង់គិតសព្វថ្ងៃ ពុំភ្លេចហឫទ័យ
ដល់តិចឡើយណា ។

---

១- សេះ

អកទ្រន់ចិន្តា　ដូច្នេះហើយណា　ស្រែកយំមហិមា
ប្រាបដល់ព្រះបាទ　នរនាថកថា　ហឫទ័យខ្លោចផ្សា
ទុក្ខទៀងជូនព្រៃ ។

ស្តេចឮសព្ទសេះ　នុកស្ទើរប្រេះ　បែកបញ្ញាទៃ
ហាក់ដូចនឹងមរណ　ព្រះជន្មក្សត្រា　បទស្តេចអាល័យ
អាសូរសេះសល់ ។

ស្តេចបន្ទូលថា　រាជកុលអស្សពាហ៍　សមមានគន្លល់
ទើបយំច្នេះណា　ដោយនាអញយល់　អំពីកិច្ចកល
ពុំទេឡើយហោង ។

យំពីមុនមិញ　កាលនោះឯងអញ　ឲ្យអស់ហាប
ដូរដោយបុត្រពារ　ដោយត្វាមាសា　សឹងយល់ជាក់ជា
ប្រាកដពេកក្រៃ ។

ឥឡូវនេះណា　គួរឲ្យហោរ　ទាយទៀតមើលនៃ
សេះអញព្រួយចិត្ត　តែងគិតសព្វថ្ងៃ　ដោយចិត្តអាល័យ
រាជកុលអស្សពាហ៍ ។

ស្តេចគិតច្នេះហើយ　ពុំយូរលន់ឡើយ　ហើយហៅហោរ
ឲ្យទាយជៀងជាក់　ចូលចិត្តទាយថា　រីអស់ហោរ
ទៀងទើបទូលថា ។

បពិត្រក្សត្រា ប្អូនដអស្ចា ព្រះអង្គនេះនៅ
បង់បានករិយា មហិមាក្រាស់ក្រៃ វិស័យយើងនៅ
ដឹងជាក់ក្តាត់ណា ។

ហោរយល់អស់ក្តី សេះទឹនបុត្រី ហើយមានបំណង
នាងពៅពុំងា ប្រាជ្ញាប៉ុនប៉ង មេត្រីទៅផង
នាងពៅពេកក្រៃ ។

យល់តែសច្ចា នាងពៅពុំងា រូបរ័ត្នស្រីថ្លៃ
ព្រះអង្គល្អល្អម ពាក់ស្រោមអាជានេយ្យ បិទបាំងវិស័យ
ពុំយល់ឡើយណា ។

ពុំហ៊ានទូលស្មោះ ពុំទូលចំពោះ ប្រាយប្រាប់ក្សត្រា
ទូលជាឯកទេស ជាលេសគ្រាន់ជា ហេតុនឹងព្រះមហា
ក្សត្រក្សិណនោះញ ។

កាលនោះក្សត្រា ស្តាប់ហោរទាយថា រូបរ័ត្នអាជានេយ្យ
បង់មានករិយា មហិមាពេកក្រៃ ទើបមហាក្សត្រថ្លៃ
ឲ្យរើសសេះផង ។

ស្រាល់សឹងសេះញី ច្រើនពាន់មុឺនទៃ នាំមកហើយហោង
ដាក់ពេនជាមួយ នឹងរាជកុលផង ព្រះអង្គពុំចង់
ចិត្តបង់ស្នេហា ។

ក្សិណនោះក្សត្រា ស្តាប់ពាក្យហោរា ទាយនោះជាម្តង
ស្តេចបើកព្រះសូរ បន្ទូលទៅផង បើហ្នោះអញល្អង
លោមនាងទាំងបី ។
ស្តេចបន្ទូលថា ទីនពជអម្ចាស់ ឲ្យហៅបុត្រី
នាងនាថជាច្បង មកផងកាលក- ឲ្យវទឹងស្រដី
លោមល្អងនាងហោង ។
កមាត្យតែខ្ញុំ អញ្ជើញបុត្រី មកដល់ឆាប់ហោង
ទើបស្តេចទុនទុប ក្រលោបត្រកង បីបុត្រស្ងួនគ្រង
បន្ទូលត្រាសថា ។
ហៃទេពក្សត្រី បុត្រច្បងពីសី មិត្រមាសស្នេហា
ឪពុកនឹងឲ្យ នាងជាករិយា ពជកុលអស្សា
សេះស្លូតប្រពៃ ។
នាងស្តាប់បិតា បន្ទូលលោមថា ដូហ្នោះហើយនៃ
នាងថ្វាយបង្គំ ប្រណមក្សត្រថ្លៃ ទូលលោមហឫទ័យ
ព្រះវរបិតា ។
បពិត្រព្រះបាទ សម្តេចនរនាថ ឥស្សូរសិរសា
ខ្ញុំថ្វាយបង្គំ ប្រណម្យលោមលា កុំឲ្យខ្ញុំជា
ប្រពន្ធសេះហោង ។

បើព្រះជៀស្ឋជ័យ សព្វព្រះហឫទ័យ រិះគិតប៉ុនប៉ង
ឲ្យខ្ញុំមានប្តី នៅនឹងមនុស្សផង ពិបាករំរង
ទុក្ខទល់កំព្រា ។
ខ្សត់ក្រោយសន្តាន អាក្រក់ខ្លួនប្រាណ ដូរជាតិមហិមា
លែងតែពេញប្រុស ជាមនុស្សផងគ្នា នោះខ្ញុំទៅជា
ប្រពន្ធគេហោង ។
រីសេះនោះណា អ្នកផងរែងថា កំណើតយល់ធ្តង
ជាសត្វតិរច្ឆាន ពុំមានភ័ព្វផង ស៊ីស្មៅនោះហោង
ខ្ញុំដោយម្តេចបាន ។
ព្រះវរបិតា ស្តាប់បុត្រទូលថា ហ្នោះទើបក្សត្រក្សាន្ត
បន្ទូលទៀតទៅ ហៃពៅកល្យាណ តាមតែនាងមាន
ចិត្តចង់ស្នេហា ។
ទើបក្សត្ររង្វល ស្តែងស្តាប់បន្ទូល នឹងទើបក្សត្រា
បុត្រីកណ្តាល ក្រវល់លោមថា ហៃស្ងួនពុំងា
មាសមិត្តថ្លើមថ្លៃ ។
កូនអើយបិតា ចង់ឲ្យនាងជា ប្រពន្ធគាជានេយ្យ
គឺចៅពជកុល មង្គលប្រពៃ ម្តេចឡើយមាសថ្លៃ
នាងព្រមឬទេ ។

នាងទេពក្សត្រា ស្តាប់ព្រះបិតា បន្ទូលតបថា
នាងនាថគន់គិត រិះរេធុញថប់ ពេកពន់កន្លង
ទើបនាងទូលថា បពិត្របិតា ឥតសុខស្រ្តផង
ខ្ញុំរហូទ័យ ក្សត្រថ្ងៃនេះម្តង កុំឲ្យខ្ញុំវង
ពាក្យលោកជៀលថា ។
រីកផុត្រ័ ព្រះបាទចក្រី ស្តេចឲ្យទៅជា
ប្រពន្ធកដកុល សេះសត្វទេណា ដូរជាតិមហិមា
ធំស្មោសត្វថ្ងៃ ។
បើព្រះកជា ពុំទ្រង់មេត្តា អាសូរខ្ញុំក្រៃ
ឲ្យខ្ញុំទៅជា ប្រពន្ធអាជានេយ្យ សូរអញខ្ញុំក្ស័យ
ជីវិតមរណា ។
គ្រង់សត្វតិរច្ឆាន អញខ្ញុំសូមទាន អន្តរទេយា
បើស្តេចឲ្យខ្ញុំ ទៅជាកិរិយា មនុស្សលោកផងគ្នា
នោះខ្ញុំដោយហោង ។
ទោះវ័ទ្ធិនខ្ទាក់ ដើងដៃបែកបាក់ តាមកម្មបុរាណ
ខ្ញុំមានមកហោង ខ្សែទ្រព្យហោពង់ ខ្ញុំឥតបើថា
និទាននេះនៃ អស់កាថសេចក្តី វែម្ហួយជាតជា
កាលក្សត្រហោមចា ឲ្យហៅធីតា ទាំងបមកណា
សួរចេបប់ហោង ។

ផ្នែកកំណត់-ប្រវត្តិការណ៍

# បុណ្យនមស្ការព្រះសក្យមុនីចេតិយ

ថ្វីត្បិតតែប្រទេសយើងកំពុងមានកើតចលាចលដោយសារសង្គ្រាមឈ្លានពានពីពួកវៀតកុង-យួនខាងជើងជាទមិឡឥតសាសនា បណ្ដាលពេញផ្ទៃប្រទេសក្ដី រដ្ឋាភិបាលនៃសាធារណរដ្ឋខ្មែរ នៅតែមានសមានចិត្តភក្ដីជានិច្ច ចំពោះព្រះសម្មាសម្ពុទ្ធបរមគ្រូ ដ៏ជាអង្គអ្នកបង្កើតនូវទ្រឹស្ដីសន្តិភាពដ៏បរិសុទ្ធ ដែលហៅថា បរមសុខ ។ សត្វលោកទូទាំងសាកលបានក្រេបរសជាតិបរមសុខនេះឯងជាទីមនោរម្យណាស់ ហើយក៏សន្មតរសជាតិនេះ ថាជា ទឹកអម្រឹត ។

អាស្រ័យហេតុនេះ បណ្ដាជនខ្មែរ ដែលមានរដ្ឋាភិបាលជាប្រមុខ បានចាត់ចែងធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយ ដែលជាទីតម្កល់ព្រះបរមអដ្ឋិនៃព្រះពុទ្ធ ដែលប្រតិស្ឋាននៅខាងមុខស្ថានីយអយស្មយយាន ក្រុងភ្នំពេញ ជាផ្លូវការដូចពីឆ្នាំមុនៗដែរ ។ ពិធីនេះ ប្រារព្ធឡើង ដោយមានការជួបជុំនូវរដ្ឋការជាន់ខ្ពស់ ទាំងទាហាន-ស៊ីវិល ដែលមានលោកប្រមុខរដ្ឋជាប្រធាន ព្រមទាំងព្រះសង្ឃដែលមានសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន ដ៏មានសូត្រនមស្ការចំពោះព្រះសក្យមុនី-

ចេតិយ និង ការគោរពទង់ជាតិ សាសនា ថ្វាយបទសរភេញយ៉ាងអឹកធឹក ផង ។

លុះព្រឹកឡើង មានការជួបជុំមន្ត្រីដូចពីល្ងាចដែរ ដើម្បីប្រគេនបង្ហាន់បិណ្ឌបាតចំពោះព្រះសង្ឃ ៨០ អង្គ តាមកំណត់អាយុកាលនៃព្រះពុទ្ធ ។

តទៅនេះ យើងសូមចុះជូនទូន្សុនរកថា លោក អ៊ុង-តាំ ឧបនាយករដ្ឋមន្ត្រីទី ១ ទទួលបន្ទុកក្រសួងមហាផ្ទៃសន្តិសុខជាតិ និង ធម្មការ ដែលបានថ្លែងក្នុងឱកាសនោះ :

## សន្ទរកថាលោកឧបនាយករដ្ឋមន្ត្រី ទី ១ ទទួលបន្ទុកក្រសួងមហាផ្ទៃ សន្តិសុខជាតិ និង ធម្មការ ថ្លែងក្នុងឱកាសបុណ្យឆ្លងមហាស្តូបព្រះសក្យមុនីចេតិយ ថ្ងៃ ៩-៥-៧១

- សូមថ្វាយបង្គំសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ព្រមទាំងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ

- សូមគោរព លោកប្រមុខរដ្ឋ

- សូមជម្រាប ពុទ្ធបរិស័ទទាំងឡាយ

ថ្ងៃនេះ ជានក្ខត្តឫក្សពេញបូណ៌មីខែពិសាខ ដែលពុទ្ធសាសនិក-ជនទូទៅ ធ្លាប់ប្រារព្ធធ្វើពិធីបុណ្យរំលឹកអភិលក្ខិតសម័យ នៃព្រះសម្មា-សម្ពុទ្ធបរមគ្រូ គឺជាថ្ងៃដែលព្រះអង្គទ្រង់ប្រសូត ទ្រង់បានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ និងទ្រង់យាងចូលកាន់ព្រះបរិនិព្វាន ។

ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមថ្លែងអំណរព្រះគុណ អំណរគុណ ចំពោះសម្តេចទាំងពីរព្រះអង្គ លោកប្រមុខរដ្ឋ និងពុទ្ធបរិស័ទ ដែលបាននិមន្ត និង អញ្ជើញមកជាអធិបតី និង រួបរួមក្នុងឱកាសមហោឡារិកនេះ បញ្ជាក់នូវសន្តានព្រះទ័យ សន្តានចិត្ត គោរពជ្រះថ្លាយ៉ាងស្មោះចំពោះព្រះពុទ្ធសាសនា ជាទីស្រឡាញ់ស្មើជីវិតនៃជនជាតិខ្មែរយើង ។ ត្រង់នេះហើយដែលពុទ្ធសាសនិកខ្មែរទាំងប្រទេស តែងនាំគ្នាប្រារព្ធធ្វើពិធីវិសាខបូជានៅគ្រប់ទិសទីវត្តអារាមទាំងអស់គ្មានសល់ខាន ។ នៅរដ្ឋធានីយើងក៏បានរៀបចំធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយនេះ ជារៀងរាល់ឆ្នាំ ជាប់ជាប្រពៃណីជាផ្លូវការរៀងរហូតមកដែរ តាំងតែពីឆ្នាំ ១៩៥២ ដែលយើងបានដង្ហែយកព្រះបរមអដ្ឋិនៃព្រះពុទ្ធបរមគ្រូ មកពីប្រទេសសេ-រីលង្កាមកម្ល៉េះ ។ គ្រប់ពេលដែលប្រារព្ធធ្វើពិធីនមស្ការ យើងតែងតែមានបីតិប្រាមោជ្ជជ្រះថ្លា ចំពោះព្រះសទ្ធម្មរឹងរឹតតែខ្លាំងក្លាឡើងរៀងរាល់លើក ។ ប៉ុន្តែជាហេតុគួរឲ្យស្តាយណាស់ កាលពីឆ្នាំទៅមិញនេះ យើងឡប់ជាអាក់ខានពុំបានប្រារព្ធធ្វើអស់មួយឆ្នាំ បណ្តាលមកពីប្រទេស

ជាតិយើង ជួបប្រទះនូវការឈ្លានពានដ៏ឃោរឃៅពីសំណាក់មារសត្រូវអន្តរជាតិ គឺ យៀកកុង-យៀកណាមខាងជើង ។ ពួកទមិឡបង្កើតសង្គ្រាមក្នុងស្រុកយើងនេះ ពិតជាសង្គ្រាមសាសនា ដោយហេតុក្រុមនេះជាបក្សពួកដែលមេដឹកនាំរបស់គេបង្កើតទ្រឹស្តីសម្រាប់ធ្វើជាមនោគមវិជ្ជាមួយ ដើម្បីបំផ្លិចបំផ្លាញនូវទ្រឹស្តីសន្តិភាពឯទៀត ។ មានព្រះពុទ្ធសាសនា នេះជាដើម ។ មិនតែប៉ុណ្ណោះ ចូលមកដំបូងពួកខ្មាំងវាកុហកអ្នកស្រុកស្លូតត្រង់យើងថា ការវាយប្រហាររបស់វាមកលើប្រទេសខ្មែរបណ្តាលមកពីយើងបានទម្លាក់អតីតប្រមុខរដ្ឋពីតំណែង ជាពួកវាជាអ្នកជួយរំដោះខ្មែរ ចេញពីការគ្រប់គ្រងថ្មី ដែលទម្លាក់ចោលប្រមុខរដ្ឋចាស់ទៅនោះ ។ ការពិតគឺប្រមុខរដ្ឋចាស់នោះខ្លួនឯងទេ ដែលរត់ចោលយើងនាំឲ្យកើតវិកល ព្រោះតែទៅចូលដៃនឹងខ្មាំងសត្រូវមេបង្កើតលទ្ធិកុម្មុយនិស្តនៅអាស៊ី ហើយពន្យល់ឲ្យខ្មាំងចូលមកវាយធ្វើបាបពុកឡុកពេញទឹកដីខ្លួនឯងវិញ នេះបានសមដូចពាក្យទំនិមទំនៀមអ្នកស្រុកចាំមាត់មកថា "ពងហាន្សហើរបង់ចោលសំបុក ហើរទៅយកកុកជាសម្លាញ់" គឺថាខ្លួនឯងដែលធ្លាប់ជាអ្នកមានសាសនា មានប្រពៃណីទុកដូចជាពងហាន្សនោះ ត្រឡប់បែរជាយល់ខុស ទៅចូលបក្សពួកជាមួយកុក ដែលជាសត្វថយថោកនោះទៅវិញ ។ អ្នកស្រុកខ្លះចាំមាត់ពីរឿងចិនលីគម្ពីរ ក្នុងរឿងនេះទៀត ក៏ស្របទ័យនឹងចម្បាំងសព្វថ្ងៃ ដែលមានចិនជាមេដើរផ្សាយ

ទ្រឹស្តីដែលមានន័យផ្ទុយស្រឡះពីពុទ្ធសាសនា ។ ទ្រឹស្តីគេបានទុកពុទ្ធ-សាសនាថាជាអាភៀន ធ្វើឲ្យប្រជាពលរដ្ឋញៀនទន់ដៃជើងធ្វើការមិនកើត ហើយចាត់ទុកព្រះសង្ឃជាទីគោរពនិងជាស្រែបុណ្យរបស់យើងថា ជាព្រូន ដែលរស់នៅក្នុងពោះវៀនមនុស្ស ។

ប៉ុន្តែជាភ័ព្វល្អដែរ ដោយសារតែខ្មែរទាំងអស់ធ្លាប់គ្រប់រសជាតិព្រះពុទ្ធវចនៈ មានសតិសម្បជញ្ញៈក្នុងខ្លួន ពាក្យភូតភររបស់សត្រូវទាំងប៉ុន្មានអាចមានឥទ្ធិពលខ្លះតែនៅពេលដំបូងប៉ុណ្ណោះ លុះសង្គ្រាមនេះ បន្តមកដល់ឥឡូវអស់រយៈជាងមួយឆ្នាំមក នាំឲ្យអ្នកស្រុកឃើញច្បាស់នូវចរិតភូតភររបស់ខ្មាំង បណ្តាជនយើងក៏ងាកបែរមូលសាមគ្គី ពង្រីកស្មារតីជាតិកាន់តែមុតមាំឡើងវិញ ។ ម៉្លោះហើយយើងសង្ឃឹមជាក់ក្នុងចិត្តណាស់ថា យើងពិតជាឈ្នះសត្រូវក្នុងពេលដ៏ឆាប់នេះជាប្រាកដ ព្រោះតែខ្មាំងអមនុស្សធម៌ បានបញ្ចេញចង្កូមកាចសាហាវព្រៃផ្សៃ ធ្វើទុក្ខបុកម្នេញអ្នកស្រុកយើងនិងធ្វើបាបព្រះសង្ឃ ដុតវត្តអារាមពុទ្ធសាសនាដែលមកទល់និងថ្ងៃនេះ វាបំផ្លាញអស់វត្តជិត ៣០០ ធ្វើឃាតព្រះសង្ឃអស់ជាង ៣០ អង្គ ធ្វើទារុណកម្មឲ្យមានរបួសប្រមាណជាកប់រយអង្គ ដែលខ្លះកំពុងតែគង់ព្យាបាលក្នុងមន្ទីរពេទ្យ និងមានព្រះសង្ឃភៀសព្រះអង្គមកគង់ជ្រកនៅក្រុងភ្នំពេញ ប្រមាណជា ៤០០ អង្គផង ។

អាស្រ័យគោលគំនិតនេះ បានជារដ្ឋាភិបាល បើកឱកាសជា

មហោឡារិកតាំងពីវេលានេះទៅ ដើម្បីឲ្យជនរួមជាតិយើងដែលរស់នៅក្រោមការជិះជាន់របស់ខ្មាំង បួលមករួបរួមក្នុងសង្គមជាតិសាងសាមគ្គីឲ្យមាំមួនការពារទឹកដីខ្មែរ និងសាសនារបស់ព្រះពុទ្ធជាព្រះបរមគ្រូជាមួយគ្នាកុំបីខ្វាបវែងអ្វីឡើយ ។

ទាំងនេះហើយជាការគួរឲ្យសោកសៅ ដែលត្រូវលើកយកមកថ្លែងក្នុងឱកាសប្រារព្ធពិធីវិសាខបូជាក្នុងឆ្នាំនេះ ដែលពុំមែនជារឿងសប្បាយទូលាយដូចសព្វដងទេ ។ ទោះបីយ៉ាងនេះក្ដី រដ្ឋាភិបាលនិងបណ្ដាជនខ្មែរ នៅតែធ្វើពិធីបុណ្យសម្ដែងសេចក្ដីគោរពចំពោះព្រះពុទ្ធបរមគ្រូជាដរាប ។

តទៅនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងអភិវន្ទនាការចំពោះព្រះសារីរិកធាតុដែលតម្កល់នៅព្រះចេតិយនេះ :

បពិត្រព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូ

វេលានេះ ខ្ញុំព្រះអង្គទាំងឡាយ ជាពុទ្ធបរិស័ទក្នុងសាធារណរដ្ឋខ្មែរ បានមករួបរួមគ្នាធ្វើពិធីនមស្ការ ចំពោះព្រះសារីរិកធាតុរបស់ព្រះអង្គ ដើម្បីសម្ដែងនូវទឹកចិត្តគោរពដ៏ជ្រាលជ្រៅចំពោះព្រះមហាករុណាទិគុណនៃព្រះអង្គ ដែលបានទុកព្រះសាសនាពោលគឺព្រះធម៌ ពាក្យទូន្មានដ៏ឧត្តមដល់យើងខ្ញុំព្រះអង្គគ្រប់គ្នា ទុកដូចជាទឹកអម្រឹតស្រោចស្រពបន្ទំចិត្ត បណ្ដុះសតិបញ្ញា ឲ្យស្រឡាញ់សន្តិភាពសេចក្ដីស្ងប់រៀបរយ និងសភាព

ចម្រើនរុងរឿងដ៏ជាសការៈប្រសើរនៃសត្វលោក ។ សូមសម្តេចព្រះបរមសាស្តាសម្មាសម្ពុទ្ធជាម្ចាស់ មេត្តាទទួលនូវអភិវន្ទនាការព្រមទាំងគ្រឿងសក្ការៈបូជាទាំងឡាយ មានៈទៀនធូប ផ្កាភ្ញី ប្រទីបផ្កាលា និងសេចក្តីគោរពដោយកាយវាចាចិត្តរបស់យើងខ្ញុំព្រះអង្គទាំងឡាយ ។ សូមព្រះតេជានុភាពព្រះបារមីរបស់ព្រះអង្គ ជួយគាំពារបណ្តាជនជាតិខ្មែរក្នុងយុគអាសន្ននេះ ព្រោះព្រះពុទ្ធវាចា: ថា "នត្ថិ សន្តិ បរំ សុខំ" គ្មានសេចក្តីសុខណាក្រៅពីសេចក្តីស្ងប់នោះ, ត្រូវពួកមារទុរយសបំផ្លាញហើយ ។ យើងខ្ញុំព្រះអង្គសុទ្ធតែបានបរផ្តាច់ថា: និង តស៊ូជាមួយខ្មាំងសត្រូវដែលវាកំពុងតែចូលមកយាយីសាសនាព្រះអង្គសព្វថ្ងៃនេះ ឲ្យវាវិនាសទៅវិញយ៉ាងឆាប់រហ័ស ដើម្បីជាឱកាសឲ្យយើងខ្ញុំព្រះអង្គបានសន្តិភាពសុខសាន្តត្រាណទឹកសាងព្រមទាំងផ្សព្វផ្សាយ រសជាតិព្រះធម៌ថ្ងៃវិសេសតទៅមុខទៀត ។ យើងខ្ញុំព្រះអង្គកំពុងតែតស៊ូសព្វថ្ងៃ សូមព្រះតេជានុភាពនៃទសបារមីព្រះអង្គ ស្ថិតនៅគាំពារយើងខ្ញុំព្រះអង្គជានិច្ចកុំបីអាក់ខានឡើយ ។

ទីបំផុត សូមផលានិសង្សដែលកើតឡើងដោយកងការកុសលក្នុងវេលានេះ ជួយទ្រទ្រង់សម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ មួយអន្លើដោយព្រះថេរានុត្ថេរៈទាំងអស់ក្នុងសាធារណរដ្ឋខ្មែរ សូមឲ្យប្រកបនឹងសុខសាន្តព្រះកាយពល មានព្រះជន្មាយុយឺនយូរគ្រប់ៗព្រះអង្គ ។

មួយចំណែកទៀត សូមផលានិសង្សនេះផ្សាយដល់ពុទ្ធបរិស័ទជនជាតិខ្មែរទាំងអស់ ជាពិសេសពួកយុទ្ធជនដែលកំពុងតែប្ដូរជាកម្លាំងកាយ កម្លាំងចិត្តការពារទឹកដីខ្មែរ និង ការពារពុទ្ធសាសនា សូមឲ្យប្រកបដោយកម្លាំងពលំមុតមាំក្លាហានរឹតតែខ្លាំងក្លាឡើងទៀត និង សូមឲ្យសេចក្ដីសុខសន្តិភាពកើតមានឡើងវិញយ៉ាងរួសរាន់ក្នុងសាធារណរដ្ឋខ្មែរ ។

សូមថ្វាយបង្គំ ! សូមគោរព !

# សាធារណរដ្ឋខ្មែរ

លេខ ៤៦-៧១-បរ

# ក្រឹត្យ

## ប្រមុខរដ្ឋ នៃ សាធារណរដ្ឋខ្មែរ

បានឃើញ ច្បាប់រដ្ឋធម្មនុញ្ញលេខ ៤៤២-៧០ បរ ចុះថ្ងៃទី ៨ ខែតុលា គ.ស. ១៩៧០ ដែលប្រកាសសាធារណរដ្ឋខ្មែរ ហើយតម្កល់ទុកឲ្យអនុវត្តន៍នូវរដ្ឋធម្មនុញ្ញបច្ចុប្បន្ន លើកលែងតែចំពោះបទបញ្ញត្តិផ្ទុយពីគំនិត និង របបសាធារណរដ្ឋ ។

បានឃើញ ក្រឹត្យលេខ ៤៥៩-៦៩ បរ ចុះថ្ងៃទី ១៤ ខែសីហា គ.ស.១៩៦៩ កែប្រែដោយអត្ថបទជាបន្តបន្ទាប់មក ជាអាទិ៍ក្រឹត្យលេខ ៣៧៩-៧០ បរ ចុះថ្ងៃទី ១ ខែកក្កដា គ.ស. ១៩៧០ ស្ដីពីការតែងតាំងគណៈរដ្ឋមន្ត្រី ។

បានឃើញ ក្រឹត្យលេខ ១៧១-៧០ បរ ចុះថ្ងៃទី ២៨ មីនា គ.ស. ១៩៧០ ដែលបែងអំណាចជាអចិន្ត្រៃយ៍ជូនឧបនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខាអមក្នុងនាមនៃនាយករដ្ឋាភិបាលនូវក្រឹត្យទាំងអស់ ដែលមានលក្ខណៈជាឯកជន ។

បានឃើញ ក្រឹត្យលេខ ១២ នស ចុះថ្ងៃទី ៩ ខែកុម្ភៈ គ.ស. ១៩៤៣ កែប្រែដោយក្រមលេខ ៦៨ នស ចុះថ្ងៃទី ១៨ ខែកញ្ញា គ.ស. ១៩៤៣

និងលេខ ១ រវ ចុះថ្ងៃទី ២៦ ខែឧសភា គ.ស. ១៩៤៨ ស្ដីពីការរៀបចំរដ្ឋការសង្ឃ គ្រប់សាធារណរដ្ឋខ្មែរ ។

បានឃើញ ក្រឹត្យលេខ ៨០៩ បរ ចុះថ្ងៃទី ៣០ ខែធ្នូ គ.ស. ១៩៦៥ ស្ដីពីការរៀបចំទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនសិក្សាធិការ ។

បានឃើញ ក្រឹត្យលេខ ២៩ រវ ចុះថ្ងៃទី ២៧ ខែកញ្ញា គ.ស. ១៩៦៩ ស្ដីពីការលើកព្រះសមណស័ក្ដិជា សម្ដេចព្រះសង្ឃនាយក ។

តាមសេចក្ដីស្នើសុំ នៃសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកគណៈមហានិកាយ និង ក្រោយពីការយល់ព្រម នៃរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សន្តិសុខជាតិ និង ធម្មការ ។

បង្គាប់ដូចមានចែងខាងក្រោមនេះ ៖

ប្រការ ១.– ព្រះសង្ឃមានឋានន្តរស័ក្ដិនៃគណៈមហានិកាយ ដែលមាននាមតទៅនេះ ត្រូវតម្លើងទៅគ្រប់ថ្នាក់ ៖

ក – ព្រះមុនីកោសល ស្បូរ-បាយរ មន្ត្រីសង្ឃថ្នាក់ទោ ឲ្យឡើងជាមន្ត្រីសង្ឃថ្នាក់ឯក មានឋានន្តរស័ក្ដិជា ព្រះពោធិវង្ស ។

ខ – ព្រះសាសនមុនី គាំម-តូ មន្ត្រីសង្ឃថ្នាក់ទោ ឲ្យឡើងជាមន្ត្រីសង្ឃថ្នាក់ឯក មានឋានន្តរស័ក្ដិជា ព្រះធម្មលិខិត ។

គ – ព្រះឃោសធម្ម ប៊ុណ្យ-សុក្ខាជ មន្ត្រីសង្ឃថ្នាក់ទោ ឲ្យឡើងជាមន្ត្រីសង្ឃថ្នាក់ឯក មានឋានន្តរស័ក្ដិជា ព្រះវនរ័ត ។

ឃ- ព្រះសិរីសម្មតិវង្ស ជន់-ពាន់ មន្ត្រីសង្ឃថ្នាក់ត្រី ឲ្យឡើងជាមន្ត្រីសង្ឃថ្នាក់ទោ មានឋានន្តរស័ក្តិជា ព្រះមុនីកោសល ។

ង- ព្រះពុទ្ធវង្ស សេង-ឆាង មន្ត្រីសង្ឃថ្នាក់ត្រី ឲ្យឡើងជាមន្ត្រីសង្ឃថ្នាក់ទោ មានឋានន្តរស័ក្តិជា ព្រះធម្មឃោសាចារ្យ ។

ច- ព្រះបិដកសោភ័ណ ប៉ែន-សុខ មន្ត្រីសង្ឃកិត្តិយស ឲ្យឡើងជាពិសេសទៅជាមន្ត្រីសង្ឃថ្នាក់ទោ មានឋានន្តរស័ក្តិជា ព្រះឃោសធម្ម ។

ឆ ព្រះធម្មវិសុទ្ធវង្ស គង់-កួយ មន្ត្រីសង្ឃថ្នាក់ចត្វា ឲ្យឡើងជាមន្ត្រីសង្ឃថ្នាក់ត្រី មានឋានន្តរស័ក្តិជា ព្រះសិរីសម្មតិវង្ស ។

ជ- ព្រះវិសុទ្ធញាណ អ៊ុម-និត មន្ត្រីសង្ឃថ្នាក់ចត្វា ឲ្យឡើងជាមន្ត្រីសង្ឃថ្នាក់ត្រី មានឋានន្តរស័ក្តិជា ព្រះសុមេធាវង្ស ។

ឈ- ព្រះញាណកោសល ពុទ្ធ-សំអុយ មន្ត្រីសង្ឃថ្នាក់ចត្វា ឡើងជាមន្ត្រីសង្ឃថ្នាក់ត្រី មានឋានន្តរស័ក្តិជា ព្រះពុទ្ធវង្ស ។

ញ- ព្រះវិន័យធរ ឡុង-ឡូរ ឋានានុក្រម ឲ្យឡើងជាមន្ត្រីសង្ឃថ្នាក់ចត្វា មានឋានន្តរស័ក្តិជា ព្រះសិរីវិសុទ្ធិ ។

ដ- ព្រះគ្រូមុនីសោភ័ណ ទៀវ ញឹម ឋានានុក្រម ឲ្យឡើងជាមន្ត្រីសង្ឃថ្នាក់ចត្វា មានឋានន្តរស័ក្តិជា ព្រះទេពសត្ថា ។

៥ ព្រះគ្រូបញ្ញាវិសុទ្ធិ តេជ្រ-មៀង ហៅនុនាក្រម ឲ្យឡើងជាមន្ត្រីសង្ឃថ្នាក់ចត្វា មានឋានន្តរស័ក្តិជា ព្រះវិកន្ធញ្ញាណ ។

៦ – ព្រះបាឡាត់ពោធិកម លៀង-ប៊ុច ហៅនានុក្រម ឲ្យឡើងជាមន្ត្រីសង្ឃថ្នាក់ចត្វា មានឋានន្តរស័ក្តិជា ព្រះធម្មវិសុទ្ធិវង្ស ។

៧ – ព្រះគ្រូពោធិញ្ញាណ ធិត-កុំ ហៅនានុក្រម ឲ្យឡើងជាមន្ត្រីសង្ឃថ្នាក់ចត្វា មានឋានន្តរស័ក្តិជា ព្រះញាណកោសល ។

ប្រការ ២ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សន្តិសុខជាតិ និងធម្មការ ត្រូវទទួលការបាត់ការ ឲ្យបានសម្រេចតាមក្រឹត្យនេះ ។

ធ្វើនៅភ្នំពេញថ្ងៃទី ២៥ ខែមករា ១៩៧១

ហត្ថលេខា : ចេង-ហេង

បានជូន សូមចុះហត្ថលេខា

លោកប្រមុខរដ្ឋ

រដ្ឋមន្ត្រីក្រសួងធម្មការ

ហត្ថលេខា : ឌិប-គីមអាង

ទទួលបញ្ជានៃលោកប្រមុខរដ្ឋ

ជ. នាយករដ្ឋមន្ត្រី និងតាមកិច្ចបែង

អំណាច

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា : ស៊ីសុវត្ថិ-សិរិមតៈ

## ជូនដំណឹង

ដោយកាលទេសៈសព្វថ្ងៃ ការបោះពុម្ពត្រូវលំបាកដោយសារក្រដាសឡើងថ្លៃ ហើយដោយបំណងយើង មិនចង់ឱ្យទស្សនាវដ្ដីនេះឡើងថ្លៃតាមក្រដាសនោះ គណៈកម្មការបោះពុម្ពទស្សនាវដ្ដី ក៏សម្រេច ទុកនៅតម្លៃជាវដដែលដូចឆ្នាំមុន គឺ ១ ក្បាល២០ រៀល មួយឆ្នាំ ១២ ក្បាល ២៣០ រៀល ប៉ុន្តែយើងត្រូវបន្ថយទំព័រតិចជាងឆ្នាំមុនបន្តិច ។

ហេតុនេះ សូមលោក-អ្នកអាន មេត្តាអភ័យទោស តាមកាលទេសៈនេះឱ្យទាន ។

ពុទ្ធសាសនបណ្ឌិត្យ